ប្រវត្តិពុទ្ធទ្វិចរសក

ភាគទី ១

ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុផាត

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

ប្រវត្តិពុទ្ធសាសក

ភាគទី ១

ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា

អាត្មាភាព **យង់ សុផាត**

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងបរហារ
លេខ: ២៤.៤ សជ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ពិតថេរដីកា
ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

កម្មវត្ថុ : អំពីការសុំចុះបញ្ជីរបស់ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ។

យោង : លិខិតលេខ ***០១/១០ស.ធ.អ.យ.ស*** ចុះថ្ងៃទី ***២៣*** ខែ ***តុលា*** ឆ្នាំ ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់ ***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ ***រំចេក៣*** សង្កាត់ ***រតនៈ*** ក្រុង ***បាត់ដំបង*** ខេត្ត ***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានឥម្ពល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីជ្រាប "
- សាលាខេត្តបាត់ដំបង
" ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ

អារម្ភកថា

សៀវភៅប្រវត្តិពុទ្ធឧបាសក ឬប្រវត្តិរបស់ឧបាសក ភាគ ១ នេះ មានប្រវត្តិរបស់ឧបាសកជាឯតទគ្គៈក៏មាន មិនមែនជាឯតទគ្គៈក៏មានដែរ មានខ្លឹមសារជាប្រវត្តិរឿងរ៉ាវរបស់ឧបាសក នាសម័យពុទ្ធកាលដែលបានទទួលតំណែងជាឯតទគ្គៈ ហើយមានឈ្មោះល្បីល្បាញ នាសម័យនោះ ថែមទាំងជាអ្នកជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា ឲ្យបានរុងរឿងចម្រើនដល់ពុទ្ធបរិស័ទ នៅក្នុងសម័យនោះផងដែរ ។

ក្នុងសម័យនោះ ពុទ្ធបរិស័ទដ៏ច្រើន សុទ្ធតែបានស្គាល់តំណែង ឬភាពអស្ចារ្យ នៃឧបាសកទាំងអស់នោះ ដោយថា អ្នកខ្លះ បានស្តាប់ព្រះធម៌របស់លោក អ្នកខ្លះ បានធ្វើធម្មសាកច្ឆាជាដើម ។ ប៉ុន្តែ ឥឡូវនេះ ភាពអស្ចារ្យរបស់ឧបាសកខ្លះៗ ពុទ្ធបរិស័ទក្នុងសម័យនេះ ស្ទើរតែលែងស្គាល់អស់ទៅហើយ ដោយសារហេតុនេះ សៀវភៅនេះនឹងបានជាពន្លឺជំនួយឲ្យដល់ពុទ្ធបរិស័ទ បានស្គាល់ច្បាស់នូវភាពអស្ចារ្យ តួនាទី ចរិយាអធ្យាស្រ័យ វត្តបដិបត្តិ និងការសម្តែងព្រះធម៌ផ្សេងៗ របស់ឧបាសកទាំងអស់នោះ ដែលមានសម្តែងទុកនៅក្នុង **គម្ពីរព្រះត្រៃបិដក** *និងក្នុង*

អដ្ឋកថា ជាដើម ព្រោះថា ព្រះពុទ្ធសាសនា ដែលចម្រើនរុងរឿងនោះ ក៏អាស្រ័យមានអ្នកចង់ចាំ បដិបត្តិតាម និងចេះសម្តែងព្រះធម៌ ឲ្យដល់អ្នកដទៃបានស្តាប់ មិនមែនដោយប្រការដទៃទេ ដូច្នេះ ឧបាសកទាំងអស់នោះ ជាសក្ខីភាព បញ្ជាក់ឲ្យដឹងបានថា ព្រះពុទ្ធសាសនា ដែលរុងរឿងនៅក្នុងសម័យនោះ ក៏ដោយសារលោកផងដែរ ទើបខ្ញុំព្រះករុណាអាត្មាភាព ខំប្រឹងប្រែងស្វែងរកក្បួនច្បាប់មកចង់ក្រង ទុកជាពន្ធឹដល់ពុទ្ធបរិស័ទក្នុងសម័យនេះ ។

សៀវភៅនេះ ខ្ញុំមិនអាចជាក់កាសាថាលីផងបានទេ ព្រោះថាមានសេចក្តីពិស្តារពេក បើអ្នកសិក្សាត្រូវការកាសាថាលី ចូរតាមរកមើលក្នុង **គម្ពីរព្រះត្រៃបិដក** និង **អដ្ឋកថា** ក្នុងចំណុចដែលលើកឡើងមកនីមួយៗ ចុះ ព្រោះគ្រប់ចំណុច ដែលលើកឡើងមកនោះ សុទ្ធតែបានច្រាប់ពី **គម្ពីរ** ឬច្បាប់ដើម ជាមូលដ្ឋានរួចអស់ហើយ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍ ចំពោះបុគ្គលអ្នកប្រាថ្នាការចេះដឹងក្នុងព្រះពុទ្ធវចនៈ បើមិនក្រៃលែង ក៏ប្រសើរជាងអត់ផងដែរ ខ្ញុំ និងសព្រហ្មចារី ខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត

ពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ទោះបីយ៉ាងនោះក៏ដោយ ក៏គង់នៅមានខុសមិនខាន ជួនដោយចេះមិនដល់ ជួនដោយការភ្លេចភ្លាំង ជាពិសេសនោះគឺអក្ខរាវិរុទ្ធ ដូច្នេះ យើងខ្ញុំ សូមសង្ឃឹមនៅលើលោកអ្នកជាបណ្ឌិតជាសប្បុរស ជួយកែលម្អ ឲ្យដល់យើងខ្ញុំផង ដើម្បីជាប្រយោជន៍ដល់ជាតិ សាសនា របស់យើងទាំងអស់គ្នា ។

សូមអស់មិត្តអ្នកអាន បានទទួលនូវការចេះដឹង ជាកេរ្តិ៍មរតកផ្ទាល់ខ្លួន ដើម្បីបានជាកិច្ចប្រតិបត្តិ ឬបានជាឧបនិស្ស័យប្រហារបង់នូវអាសវក្កិលេស បានចូលដល់ព្រះនិព្វាន ដែលជាបរិយោសាន ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាមខេត្ត ក្រុង ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណាអាត្មាភាព បានសម្តែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកជាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥០ ប្រាក់ខ្មែរចាន ១៨.៤៩៥០០០ រៀល (១៨ លាន ៤

សែន ៩ ម៉ឺន ៥ ពាន់រៀល) និងប្រាក់ចុងសារ ៦៤៥ ចុងសារសរសេរជួរអារមេរិក ។ *នៅបុណ្យ*
កុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅ
ថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា** *ដែលមានពុទ្ធបរិស័ទទៅ*
ប្រមាណ ៦៥ នាក់ *ក្នុងនោះ ក៏មាន ព្រះសង្ឃ* **១០** *ព្រះអង្គផងដែរ*
ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៉ុត សាខង្ឃ** *ជាប្រធាន ក្នុងការដឹកនាំ*
គណៈធម្មយាត្រានោះ ដោយទៅ **ថ្វាយបង្គំបាន ៥១ កន្លែង** *បានការ*
ឧបត្ថម្ភអំពីឧបាសក **ឡាយ សុខុម** *និងឧបាសិកា* **ឱម លក្ខណា** *នៅក្នុង*
ព.ស. ២៥៥០ *(១០.០២.២០០៧) ។*

និតឃើញស្រុកព្រះ

និតឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា
សិរីសាលំទោន ទុកជូចឈូកផ្កា បូជាសាស្តា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចង់ចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស.២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥០ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ត្រាក់ខ្មែរចាស ១៥.៨៣១០០០ រៀល (១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល) និង ត្រាក់ជុល្លារ ៤៥ ជុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ម៉ៃត សាឥច្ច ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតន: ឧបាសិកា ស៊ិម ចណ្ណា នៅក្នុង ព.ស. ២៥៥១ (០៤.០៤.២០០៨) ។

នីកយើញ្សេលង្កា

នីកយើញលង្កា នៅពុទ្ធស្ថាន នីកយើញកាលណា ១៩ កន្លែង ជ្រះថ្លាក្រៃលែង ដែលខ្ញុំបានស្វែង ទៅថ្វាយបង្គំ ។

១២១ អង្គា គាល់ព្រះបាទា នាស្ថានមនោរម
លើសុមនកូដ ជេស្ដាឧត្ដម ជាកំពូលភ្នំ
ក្នុងប្រវត្តិពុទ្ធ ។
ទឹកដីលង្កា ទឹកដីអស្ចារ្យ ពេញពោរដោយឫទ្ធិ
នឹកឃើញកាលណា ជ្រះថ្លាក្រៃពិត ធម្មយាត្រាប្រណីត
ក្នុង ព.ស.២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥២** *ផ្នែកខាងសម្ដែងព្រះធម៌ ជូចគ្នានឹង* **ព.ស. ២៥៥១** *ដែរ ដោយសរុបប្រាក់នៅក្នុង* **ព.ស. ២៥៥២ ប្រាក់ខ្មែរចាន ២៧.១២៨០០០ រៀល** *(* **២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់រៀល** *)* **និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង* **ប្រទេសឥណ្ឌាជាលើកទីពីរ** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ប៊ុត សាខឡ** *មានលោកគ្រូធម្មបណ្ឌិត* **រស់ សុផាត** *និងលោកគ្រូធម្មាចារ្យ* **រឿ សៅ** *ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ* **៦៧ នាក់** *ក្នុងនោះ ក៏មាន* **ព្រះសង្ឃ ៥**

ព្រះអង្គដងដែរ បានការឧបត្ថម្ភមកអំពីឧបាសក **យីត សូណោត** ឧបាសិកា **ហ៊ួន ម៉ារ៉ានី** M. SU SOKUNORA et MmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា **ឡុច ឡៃហ្គារី** ឧបាសិកា **ស្ងួន រស្មីណា** ឧបាសិកា **ស្ងួន ចរ៉ាណា** នៅក្នុង **ព.ស. ២៥៥២** (១៦.០២.២០០៩) ។

ជ្រះថ្លាខ្ញុំចណាស់

ជ្រះថ្លាខ្ញុំឯណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសកវាជ សាសនាអង្វែង ល្អហួសការថ្លែង
ខ្មុំ! ព្រះសាសនា ។
នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នានមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្ចង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំ ព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ស្រុទេសស្រែលង្កាជាលើកទីពីរ** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុវ៉ាត** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ

៣៦ ឆាតំ *នៅក្នុងនោះទៀត ក៏មាន ព្រះសង្ឃ* **៣** *ព្រះអង្គផងដែរ បានការឧបត្ថម្ភមកអំពីឧបាសក* **ឆាយ អ៊ឹតសោច** *ឧបាសិកា* **ហួច គីមសែ** *ក្រោមការជ្រោមជ្រែងរបស់ឧបាសក* **យន្ត សួន** *នៅក្នុង* **ព.ស. ២៥៥២** *(១១.០៣.២០០៩) ។*

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥៣** *ផ្នែកខាងសម្ដែងព្រះធម៌ ជូចគ្នានឹង* **ព.ស. ២៥៥២** *ដែរ ដោយសរុបប្រាក់នៅក្នុង* **ព.ស. ២៥៥៣ ត្រាក់ខ្មែរចាន ១៣.០៨០០០០ រៀល** *(* **១៣ លាន ០ សែន ៨ ម៉ឺន** *)* **និងត្រាក់ជុល្លារ ២០៨ ជុល្លារ ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង* **ប្រទេសឥណ្ឌាជាលើកទី ៣** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ម៉ុក សាវង្ស** *ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ* **១១១ ឆាតំ** *ក្នុងនោះ ក៏មាន ព្រះសង្ឃ* **៦** *ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន* **៩៦ ឆន្លែង** *បានការជ្រោមជ្រែងពីឧបាសក* **ឡាយ សុខុម** *នៅក្នុង* **ព.ស. ២៥៥៣** *(២៩.០១.២០១០) ។*

ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្បប់ស្បែងអស្ចារ្យ
ខ្ទុះខ្ទិ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គា ៩៦ ពុទ្ធស្ថាន ព.ស.ភប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥៤** *ផ្នែកខាងសម្តែងព្រះធម៌ ជូចគ្នានឹង* **ព.ស. ២៥៥៣** *ដែរ ដោយសរុបប្រាក់នៅក្នុង* **ព.ស. ២៥៥៤ ត្រាក់ខ្មែរបាន ៣១. ៩៩០០០០ រៀល (៣១ លាន ៩ សែន ៩ ម៉ឺន) និងត្រាក់ប៉ុល្លារ ៧២០ ប៉ុល្លារ ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានទានៅក្នុង* **ប្រទេសឥណ្ឌាជាលើកទី ៥** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ម៉ុក សាវង្ស** *ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ* **១១១ នាក់** *ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅ*

ថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ (២៧.០២.២០១១) ។

គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែហាន
ប្រៀបបានព្រៃស្វាត់ ។
២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាដែនពុទ្ធវត្ត ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស យង់ សុច (ស្លាប់) និងញោមស្រី ឈឹម ហាយ (ស្លាប់) ម្ល៉ាងទៀត ញាតិកានៅក្នុងសង្ឃាវាដ្ត ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស លោកគ្រូធម្មបណ្ឌិត

រសំ សុផាត និង**លោកគ្រូធម្មាចារ្យ គាំ អ៊ឹម** ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះ ស្មើនឹងអាត្មាភាពផងដែរ **សូមអនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗ គ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម៉្យាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគតកុំបីអាក់ខានឡើយ (***សូមឲ្យបានជាសាវ័កបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណានីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុប្បដ្ឋាក ១***) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ព្រះសក្យមុនីទ្រង់ត្រាស់ថា **ឧត្តិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ដោយប្រឆាន

ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកជំទាវ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកជំទាវ សឿង ឆុសល ជួយវាយកុំព្យូទ័រ

លោកអ្នកជំទាវ គីម ម៉ានិត ជួយប្រែ

លោកអ្នកជំទាវ ម៉ុន ម៉ូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកជំទាវ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកជំទាវ ហាន ឥឡូនា ជួយវាយកុំព្យូទ័រ

លោកអ្នកជំទាវ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម វ៉ីរ៉ាយ៉ា ជាទីប្រឹក្សាក្នុងកិច្ចការងារធម្មទាន

ឧបាសក សន ឈៀត ជួយប្រែ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក ប៊ួ ស៊ីផ្ង ជួយពិនិត្យអក្ខរាវិរុទ្ធ

លោកគ្រូធម្មាចារ្យ គាំ អ៊ឹត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឌិម ឌំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក រីម សុមេធ ជួយពិនិត្យអក្ខរាវិរុទ្ធ

សមាជិកសមាគមធម្មទានអរិយតឡុយចំសូផាត

សម្តេចព្រះសង្ឃរាជគណមហានិកាយ **នន្ទ ខែ័ត** *ជាប្រធានកិត្តិយស*

កិកុ អគ្គបណ្ឌិតោ **យចំ សូផាត** *ជាប្រធានសមាគម*

លោកអភិបាលស្រុក **ស្រែច ស្រ៊ាច** *ជាទីប្រឹក្សាសមាគម*

ឧបាសក **អ៊ឹម ម៉ែយ៉ោ** *ជាអនុប្រធានសមាគម*

ឧបាសិកា **ខែ័ត យូរេច** *ជាអនុប្រធានសមាគម*

សាមណេរ **ម៉ី សាល្ងន** *ជាលេខាធិការ*

ឧបាសក **ឡាន សូខ្ងម** *ជាលេខាធិការរង*

ឧបាសិកា **តាំច ដ៉ោចជីច** *ជាហេរញ្ញិក*

ឧបាសិកា **ជា ឆាច** *ជាបេឡា*

លោកគ្រូធម្មបណ្ឌិត **អ៊ឿ សៅ** *សមាជិកកិត្តិយស និងឧបការគុណ*

ឧបាសក **ឡាយ សូខ្ងម** *សមាជិកកិត្តិយស និងឧបការគុណ*

ឧបាសិកា **អ៊ឹច រិទ្ធារី** *សមាជិកកិត្តិយស និងឧបការគុណ*

ឧបាសិកា **ហោ ឆាព** *សមាជិកកិត្តិយស និងឧបការគុណ*

ឧបាសិកា **ឆួ ប៊ុនឆាច** *សមាជិកកិត្តិយស និងឧបការគុណ*

ឧបាសិកា **ឈុំ សូធា** *សមាជិកកិត្តិយស និងឧបការគុណ*

ឧបាសិកា ម៉ែន រម្ហណីយ៍ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឱម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ឹង ចិនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ប្ង ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ចិន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ខ្ញុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង ស្រីជា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង ស្រីចន្ទ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង តន្ថា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ហេង សុភ័ក្រ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា តែវ កល្យាណ ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុប្ផោតនី ជាសមាជិកសកម្ម

ឧបាសក ហ្វង សុភណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហ្វង សុភណ្ណារ៉ែត ជាសមាជិកសកម្ម

មាតិការឿង

លរ ទំព័រ

១- ឈ្មោះរបស់ឧបាសក ..... ត

២- ជីវប្រវត្តិរបស់តបុស្សៈ និងកល្លិកៈ ១

លោកទាំងពីរជាឯតទគ្គៈផ្នែកខាងអ្នកដល់សរណៈជាបឋម

៣- ជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី ១៥

លោកជាឯតទគ្គៈផ្នែកខាងអ្នកឲ្យទាន

៤- ជីវប្រវត្តិរបស់ហត្ថកអាឡវកឧបាសក ១៥៨

លោកជាឯតទគ្គៈផ្នែកខាងសង្គ្រោះបរិស័ទដោយសង្គហវត្ថុ ៤ ប្រការ

៥- ជីវប្រវត្តិរបស់ព្រះមហានាមសក្យឧបាសក ២០៩

លោកជាឯតទគ្គៈផ្នែកខាងឲ្យកោជនមានរសដ៏ឧត្តម

៦- ជីវប្រវត្តិរបស់ឧគ្គគហបតី អ្នកនៅក្នុងក្រុងវេសាលី ២៥២

លោកជាឯតទគ្គៈផ្នែកខាងឲ្យកោជនជាទីគាប់ចិត្ត

៧- ជីវប្រវត្តិរបស់ឧគ្គតគហបតីឧបាសក ២៧២

លោកជាឯតទគ្គៈផ្នែកខាងឧបដ្ឋាកព្រះសង្ឃ

៨- ជីវប្រវត្តិរបស់សូរអម្ពដ្ឋឧបាសក ២៧៧

លោកជាឯតទគ្គៈផ្នែកខាងអ្នកជ្រះថ្លាមិនកម្រើក

៩- ជីវប្រវត្តិរបស់ចិត្តគហបតីឧបាសក ២៨៧

ដែលជាឯតទគ្គៈផ្នែកខាងធម្មកថិក

១០-ជីវប្រវត្តិរបស់ពេទ្យជីវកកោមារភច្ចឧបាសក ៣៤៩

ជាអ្នកប្រសើរផ្នែកខាងញុំាងបុគ្គលឲ្យជ្រះថ្លា

១១-ជីវប្រវត្តិរបស់នកុលបិតាគហបតីឧបាសក ៤៥៧

ជាអ្នកប្រសើរផ្នែកខាងជាអ្នកចេះនិយាយឲ្យអ្នកដទៃស្និទ្ធស្នាល

១២-ជីវប្រវត្តិរបស់ព្រះអង្គម្ចាស់អកយរាជកុមារ ៤៧៦

ជាឧបាសកដ៏ឆ្នើមមួយរូបនៅក្នុងព្រះពុទ្ធសាសនានេះ

១៣-ជីវប្រវត្តិរបស់ឆត្តមាណពឧបាសក ៥១១

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

១៤-ជីវប្រវត្តិរបស់ទីឃនខឧបាសក ៥៣០

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

១៥-ជីវប្រវត្តិរបស់ទោណព្រាហ្មណ៍ឧបាសក ៥៤៥

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

១៦-ជីវប្រវត្តិរបស់ធម្មិកឧបាសក ៥៦៩

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

១៧-ជីវប្រវត្តិរបស់នន្ទិយឧបាសក ៥៨៤

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

១៨-ជីវប្រវត្តិរបស់នាយកេសីឧបាសក ៦០៣

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

១៩-ជីវប្រវត្តិរបស់បុក្កុសមល្លបុត្រឧបាសក ៦១០

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

២០-ជីវប្រវត្តិរបស់ឆត្តបាណិឧបាសក ៦២៨

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

២១-ជីវប្រវត្តិរបស់ជោតលិយគហបតីឧបាសក ៦៤៣

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

២២-ជីវប្រវត្តិរបស់នាយចុន្ទកម្មារបុត្រឧបាសក ៦៦៤

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

២៣-ជីវប្រវត្តិរបស់នាយសុមនមាលាការឧបាសក ៧១២

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

២៤-ជីវប្រវត្តិរបស់បញ្ចគ្គទាយកឧបាសក ៧៣៤

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

២៥-ជីវប្រវត្តិរបស់បិង្គលកោច្ឆឧបាសក ៧៤៣

ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

ជីវប្រវត្តិពុទ្ធឧបាសក ឬជីវប្រវត្តិរបស់ឧបាសក

មានឈ្មោះ តបុស្សៈ និងកល្លិកៈ អនាថបិណ្ឌិកសេដ្ឋីជាដើម សុទ្ធសឹងតែជាឧបាសកដែលមានជំនាញឯកទេស ដែលគ្មានអ្នកដទៃប្រជែងបាន បាលីហៅថា **ឯតទគ្គៈ** *គឺបានដល់ ភាពប្រសើរបស់ឧបាសកម្នាក់ៗ ដូចជាតបុស្សៈ និងកល្លិកៈ ជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងអ្នកដល់សរណៈជាបឋម អនាថបិណ្ឌិកសេដ្ឋី ជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងការឲ្យទានជូច្នេះជាដើម ។*

ជូច្នេះ ពុទ្ធឧបាសករបស់ព្រះបរមគ្រូនៃយើងនេះ មានឈ្មោះរបស់លោកដូចខាងក្រោមនេះ គឺ

១- តបុស្សៈ និងកល្លិកៈឧបាសក *២- អនាថបិណ្ឌិកសេដ្ឋីឧបាសក*

៣- ចិត្តគហបតីឧបាសក *៤- ហត្ថកអាឡវកឧបាសក*

៥- ព្រះមហានាមសក្យឧបាសក *៦- ឧគ្គតគហបតីឧបាសក*

៧- ឧគ្គគហបតីឧបាសក *៨- សូរអម្ពដ្ឋឧបាសក*

៩-ពេទ្យជីវកកោមារភច្ចឧបាសក *១០- នកុលបិតាគហបតីឧបាសក*

១១-ព្រះអង្គម្ចាស់អភយរាជកុមារ *១២- ធម្មិកឧបាសក*

๑๓- ឆត្តមាណវឧបាសក	๑๔- ទីឃនខឧបាសក
๑๕- ទោណព្រាហ្មណ៍ឧបាសក	๑๖- ធម្មិកឧបាសក
๑๗- នន្ទិយឧបាសក	๑๘- នាយកេសីឧបាសក
๑๙- បុក្កុសមល្លបុត្រឧបាសក	๒๐- ពោតលិយគហបតីឧបាសក
๒๑- ព្រះបាទពិម្ពិសារវរាជឧបាសក	๒๒- នាយចុន្ទកម្មារបុត្រឧបាសក
๒๓-នាយសុមនមាលាការឧបាសក	๒๔- បញ្ចង្គទាយកឧបាសក
๒๕-បិង្គលកោច្ឆឧបាសក	๒๖- កទ្ទិយលិច្ឆវីឧបាសក
๒๗-ព្រះបាទអជាតសត្តុរាជឧបាសក	๒๘- ពោធិរាជកុមារឧបាសក
๒๙-នាយព្រាននកុក្កុជមិត្តឧបាសក	๓๐- មាគន្ទិយឧបាសក
๓๑- មេណ្ឌកសេដ្ឋីឧបាសក	๓๒- វេរញ្ជព្រាហ្មណ៍ឧបាសក
๓๓- សេដ្ឋីគហបតីឧបាសក	๓๔- សុប្បពុទ្ធកុដ្ឋិឧបាសក
๓๕- សិង្គាលកមាណវឧបាសក	๓๖- សុកមាណវឧបាសក
๓๗- អតុលឧបាសក	๓๘- អស្សលាយនឧបាសក
๓๙- សុជាតឧបាសក	

✍ ជីវប្រវត្តិរបស់តបុស្សៈ និងភល្លិកៈ ✍

“ លោកទាំងពីរជាឯតទគ្គៈផ្នែកខាងអ្នកដល់សរណៈជាឋបមំ ”

លោកទាំងពីរចាត់ថា ជា ***ទ្វេវាចិកឧបាសក*** *ប្រែថា* ***ឧបាសកអ្នកមានវាចាពីរ*** *មានន័យថា ជាអ្នកពោលវាចាដល់សរណៈ ២ បានដល់ព្រះពុទ្ធ និងព្រះធម៌មុនឧបាសកទាំងឡាយ រហូតជាអ្នកបានទទួលនូវការលើកតម្កើងពីព្រះលោកនាថថា ជាអ្នកប្រសើរជាងឧបាសកទាំងឡាយ អ្នកដល់សរណៈមុនឧបាសកទាំងឡាយ ក្នុងព្រះសាសនានេះ ចំណែកជីវប្រវត្តិរបស់លោកទាំងពីរនាក់ ក៏មានសម្តែងទុកទាំងអតីតជាតិ និងបច្ចុប្បន្នជាតិផងដែរ ។*

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ ***តបុស្សៈ*** *និង* ***ភល្លិកៈ*** *មានសម្តែងច្រកដនៅក្នុង* ***គម្ពីរមហាវគ្គ ព្រះវិនัยបิដក*** *នៃ* ***មហាខន្ធកៈ*** *និងក្នុង* ***គម្ពីរបឋមសម្ពោធិកថា*** *និងក្នុង* ***គម្ពីរតតិយសមន្តបฏาสาទิกา*** *និងក្នុង* ***អដ្ឋកថាមនោរថបូរណี*** *និងក្នុង* ***អដ្ឋកថាមធុរត្ថวิลาสินี*** *និងក្នុង*

អដ្ឋកថាវិសុទ្ធជនវិលាសិនី ដូចមានសេចក្តីថា ៖-

តបុស្សៈ និងកលិកៈ ជាបុត្ររបស់កុដុម្ពិក នៅក្នុងនគរអសិតញ្ជនៈ ហើយលោកទាំងពីរ កើតឡើងមុនសម័យ ដែលព្រះបរមពោធិសត្វរបស់យើងបានសម្រេចព្រះសព្វញ្ញុតញ្ញាណ (ញាណដែលដឹងទូវត្ថុទាំងពួង ទាំងអតីត អនាគត និងបច្ចុប្បន្ន ឬញាណ គឺភាពជាព្រះសព្វញ្ញូ) ។ តបុស្សៈជាបង ចំណែកឯកលិកៈជាប្អូន អ្នកទាំង ២ នាក់នេះ ជាបងប្អូនបង្កើតនឹងគ្នា ។ តបុស្សៈ និងកលិកៈ កាលបើចម្រើនវ័យធំដឹងក្តីហើយ ដំណើរជីវិតរបស់អ្នកទាំងពីរ គឺធ្វើជាអ្នកជំនួញ ឯការធ្វើជំនួញនោះ គឺធ្វើជំនួញទៅដោយរទេះប្រមាណ ៥០០ផ្ទុកទំនិញផ្សេងៗ យកទៅលក់ដូរគ្រប់ទីកន្លែងទូទៅ គឺប្រព្រឹត្តទៅតាមរដូវកាលដែលអាចអំណោយផលបានច្រើន ។ ពេលដែលព្រះបរមពោធិសត្វបរមគ្រូនៃយើង បានសម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងស្ថានទីផ្សេងៗ ក្នុងបរិវេណដែលព្រះសម្មាសម្ពុទ្ធគ្រាស់ជើងអស់ ៧ សប្តាហ៍ គិតជាថ្ងៃអស់ ៤៩ ថ្ងៃ លុះដល់ខាងដើម

សប្តាហ៍ទី ៨ ព្រះអង្គស្តេចគង់ប្រថាប់ក្រោមដើមរាជាយតនៈ ហើយ
ព្រះឥន្ទ្របាននាំផ្លែសម៉ែទិព្វ និងទឹកខ្ទុះព្រះឱស្ឋមកថ្វាយដល់ព្រះអង្គ ។

ក្នុងគ្រានោះ តបុស្សៈ និងភល្លិកៈ ជាពាណិជបងប្អូនពីរនាក់
បាននាំរទេះដែលផ្ទុកទៅដោយទំនិញ ៥០០ រទេះ ធ្វើដំណើរចេញអំពី
កោសលជនបទ មកដល់តំបន់នោះ មានទេវតាមួយអង្គ ទេវតាមួយ
អង្គនោះ កាលពី ៥ ជាតិមុន ធ្លាប់ជាមាតារបស់ពាណិជទាំងពីរនាក់
បងប្អូន តែបច្ចុប្បន្ននេះ បានមកកើតជារុក្ខទេវតា នៅហ្នឹងដើមឈើមួយ
ដើម ដែលស្ថិតនៅក្បែរផ្លូវធ្វើដំណើរទៅមកនោះ កាលទេវតាទតឃើញ
តបុស្សៈ និងភល្លិកៈមកជាមួយព្រមដោយរទេះទាំង ៥០០ ទើបគិតថា
ឥឡូវនេះ ព្រះសម្ពុទ្ធគួរបានសោយព្រះក្រយាហារ ព្រោះតពីនេះទៅ
ព្រះអង្គមិនអាចតាំងព្រះជន្មនៅបាន ដោយព្រះអង្គមិនបានសោយព្រះ
ក្រយាហារអស់ ៤៩ ហើយ ។ឯបុត្រទាំងពីររបស់យើងក៏កំពុងធ្វើ
ដំណើរមកក្នុងទីនេះល្មម ដូច្នេះ ថ្ងៃនេះយើងគួរឲ្យបុត្ររបស់យើងបាន
ថ្វាយអាហារបិណ្ឌបាតដល់ព្រះទសពល កាលគិតដូច្នេះហើយ ទើប

បណ្តាលឲ្យគោទាំងឡាយដែលអូសរទេះទាំង ៥០០ នោះ ឈប់ទ្រឹងនៅមួយកន្លែង ពួកពាណិជទាំងអស់បាននាំគ្នាវាយគោដែលឈប់ទ្រឹងមួយកន្លែង មិនព្រមអូសរទេះទៅមុខនោះ ដើម្បីវាយឲ្យវាដើរទៅមុខ តែគោមិនព្រមដើរទៅមុខ ឲ្យហ្វាតចាកទីនោះទៅបាន តបុស្សៈ និងកល្បិកពាណិជទាំងពីរនាក់បងប្អូន ក៏គិតក្នាមថា មានហេតុការណ៍អ្វីហ្ន៎ បាននាំគ្នាជួយរកមើលហេតុផ្សេងៗ រហូតអស់ចិត្ត ក៏មិនដឹងថា មានហេតុអ្វីដែរ ទើបនាំគ្នាធ្វើពលិកម្ម (បួងសួង) ដល់ទេវតាទាំងឡាយដែលជាម្ចាស់ទីកន្លែង ។ តែក្នុងពេលដែលគេទាំងពីរនាក់ កំពុងធ្វើពលិកម្ម ទេវតាបានជ្រាបដល់ការលំបាកចិត្តរបស់គេទាំងពីរនាក់ ទើបសម្តែងកាយឲ្យច្រាកដ (ក្នុង **អដ្ឋកថាមនោរថបូរណី** ពោលថា ទេវតាបានចូលទៅក្នុងខ្លួនរបស់បុរសម្នាក់) ហើយពោលថា អ្នកទាំងឡាយមានការលំបាកចិត្ត ដោយមានហេតុអ្វី ឬមានការរុកកួនផ្សេងៗកើតឡើង គឺការរុកកួនពីពួកយក្ខ ខ្មោច បិសាច ឬពីពួកនាគ ដូច្នេះ អ្នកទាំងឡាយកុំភ័យអី ការរុកកួនទាំងអស់នោះ មិនកើតមានដល់អ្នក

ទាំងឡាយទេ តែថា យើងធ្លាប់ជាមាតារបស់អ្នកកាលពី ៥ ជាតិមុន ហើយឥឡូវនេះ យើងបានមកកើតជារុក្ខទេវតានៅត្រង់ទីនេះ នឹងសូមប្រាប់ឲ្យពួកអ្នកបានជ្រាបថា ពេលនេះព្រះទសពលទ្រង់គង់ប្រថាប់នៅក្រោមដើមរាជាយតនៈ អ្នកទាំងពីរចូរថ្វាយអាហារបិណ្ឌបាតជាលើកដំបូងដល់ព្រះសក្យមុនី ដែលទើបតែនឹងបានត្រាស់ជើងថ្មីៗ ចុះ ដែលនឹងអាចធ្វើឲ្យអ្នកទាំងឡាយបានទទួលនូវប្រយោជន៍ និងសេចក្តីសុខអស់កាលជ័យូរអង្វែង ។

តបុស្សៈ និងភល្លិកៈ បានស្តាប់ពាក្យរបស់ទេវតា ដែលប្រាប់ដូច្នេះហើយ ក៏មានការរីករាយសប្បាយចិត្ត ហើយបានឃើញព្រះអង្គទ្រង់គង់ប្រថាប់នៅក្រោមដើមរាជាយតនៈ ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ ព្រមទាំងរស្មីទាំង ៦ ពណ៌ ផ្សាយចេញអំពីព្រះវរកាយរបស់ព្រះអង្គ ហើយក៏ធ្វើឲ្យកើតសទ្ធាជ្រះថ្លាឡើង ដោយគិតថា ព្រះលោកនាយកកើតឡើងក្នុងលោកពិតប្រាកដមែន ទើបពោលថា នេះជាលាភដ៏ប្រសើររបស់យើងហើយ

ទើបនាំគ្នារៀបចំសដូវផង់ និងសដូវដុំ ដែលជាស្បៀងបម្រុងសម្រាប់ធ្វើដំណើរ ដោយលាយច្របល់ជាមួយទឹកដោះថ្លា ទឹកឃ្មុំ និងទឹកអំពៅជាដើម ដាក់ចូលទៅក្នុងថាសមាស នាំចូលទៅថ្វាយដល់ព្រះជិនស្រីថ្វាយបង្គំរួចហើយ ឈរនៅក្នុងទីដ៏សមគួរ ហើយបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់អនុគ្រោះទទួលនូវសដូវផង់ និងសដូវដុំ របស់ខ្ញុំព្រះករុណាទាំងពីរនាក់ផង ដើម្បីឲ្យខ្ញុំព្រះករុណាបានទទួលនូវប្រយោជន៍ និងសេចក្តីសុខ ព្រោះអាស្រ័យទាននេះ ខណៈនោះ ព្រះសម្មាសម្ពុទ្ធទ្រង់បានពិចារណាមើលវត្តប្រតិបត្តិ ដែលជាពុទ្ធប្បវេណី ដែលព្រះពុទ្ធទាំងឡាយក្នុងអតីតកាល ទ្រង់ប្រព្រឹត្តមក ហើយថា ព្រះតថាគតទាំងឡាយ ទ្រង់មិនព្រមទទួលអាហារបិណ្ឌបាតដោយព្រះហស្តទេ តើតថាគតគួរទទួលសដូវផង់ និងសដូវដុំដោយអ្វីហ្ន៎ ទើបទ្រង់មានបរិវិតក្កថា ជាត្រាបស់យើងក៏បាត់ ។

ព្រះមានព្រះភាគ ទ្រង់ត្រិះរិះដូច្នេះហើយ ដោយហេតុយ៉ាងណា មានពាក្យពោលទុកថា ជាត្រាដែលឃដិការមហាព្រហ្មបានថ្វាយនោះ

បានបាត់ទៅហើយ តាំងតែពីពេលដែលព្រះអង្គទ្រង់ទទួលមធុបាយាស
របស់នាងសុជាតា ដោយកាលនោះ ព្រះអង្គទទួលដោយថាសមាស
កាលព្រះអង្គសោយមធុបាយាសស្រេចហើយ ទ្រង់បានយកថាសមាស
ទៅអធិដ្ឋានបណ្តែតក្នុងស្ទឹងនេរញ្ជរា ហើយថាសមាសនោះបានលិចចុះ
ទៅដល់ពិភពកាឡនាគរាជ ។ ក្នុងកាលនោះ ស្តេចចាតុម្មហារាជិកា
ទាំង ៤ បានជ្រាបដល់បរិវិតក្កបស់ព្រះលោកនាថ ទើបទ្រង់បង្ហាន
នាំយកបាត្រសិលា ដែលមានពណ៌ ដូចពណ៌សណ្តែកខៀវ មួយអង្គ
មួយៗ (ទាំងអស់ ៤) បាននាំគ្នាចូលទៅថ្វាយព្រះទសពល ព្រមទាំង
ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទទួលសដូវផង់ និង
សដូវជុំ ដោយបាត្របស់ខ្ញុំព្រះអង្គចុះ ព្រះមហាវីរៈទ្រង់ទទួលបាត្រ
ទាំង ៤ ដោយមានបំណងដើម្បីរក្សាបសាទសទ្ធា គឺសេចក្តីជ្រះថ្លា
របស់មហារាជទាំង ៤ ព្រះអង្គក៏ព្រមទទួលតែទ្រង់មិនមែនជាអ្នកប្រាថ្នា
ច្រើននោះទេ ពេលដែលព្រះអង្គទទួលរួចហើយ ព្រះអង្គក៏បានអធិដ្ឋាន
បាត្រទាំង ៤ ឲ្យទៅជាបាត្រតែមួយប៉ុណ្ណោះ ហើយទើបទ្រង់ទទួល

សដូវផង់ និងសដូវដុំដោយបាត្រសិលានោះ ។

តបុស្សៈ និងកលិកៈពីរនាក់បងប្អូននោះ កាលបានរៀបចំនូវសដូវផង់ និងសដូវដុំជាក់ចូលទៅក្នុងបាត្រេបស់ព្រះសម្ពុទ្ធរួចហើយ ក៏បានថ្វាយទឹកក្នុងពេលដែលព្រះអង្គធ្វើកត្តកិច្ចរួចរាល់ហើយ ដោយគេទាំងពីរនាក់ ក៏បានថ្វាយបង្គំ ហើយនាំគ្នាអង្គុយក្នុងទីដ៏សមគួរលំដាប់នោះ ព្រះសក្យមុនីទ្រង់សម្តែងធម៌ឲ្យដល់តបុស្សៈ និងកលិកៈទាំងពីរនាក់បងប្អូនបានស្តាប់ ។ លុះចប់ព្រះធម៌ទេសនា តបុស្សៈ និងកលិកៈក៏បានតាំងនៅក្នុងសរណៈដែលគេទាំងពីរនាក់បានពោលវាចាដល់សរណៈ ២ ប្រការ គឺព្រះពុទ្ធរតនៈ ១ និងព្រះធម្មរតនៈ ១ ដែលហៅថា **ទ្វេវាចិកសរណាគមន៍** ប្រែថា អ្នកពោលដល់សរណៈដោយវាចា ២ ដែលគេទាំងពីរនាក់បានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណាទាំងពីរនាក់ សូមដល់ព្រះមានបុណ្យ ជាសរណៈផង ព្រះធម៌ជាសរណៈផង ជាទីពឹងជាទីរឭក សូមព្រះអង្គទ្រង់ចាំទុកខ្ញុំព្រះករុណាទាំងពីរនាក់ថា ជាឧបាសកអ្នកដល់នូវសរណាគមន៍ស្មើដោយជីវិត

ចាប់តាំងពីថ្ងៃនេះតទៅ ព្រះអង្គ ។ កាលតបុស្សៈ និងកល្លិកៈពីរនាក់បងប្អូន បានប្រកាសខ្លួនជាទ្វេវាចិកឧបាសកដូច្នេះហើយ ក៏មានបំណងនឹងធ្វើដំណើរត្រឡប់ទៅកាន់ស្រុករបស់ខ្លួនវិញ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់តាំងពីថ្ងៃនេះតទៅ ខ្ញុំព្រះករុណានឹងធ្វើការក្រាបថ្វាយបង្គំ រឭកដល់គុណនៃព្រះសម្ពុទ្ធជានិច្চកាល ហេតុដូច្នេះ សូមព្រះអង្គទ្រង់ប្រទានបរិចរណាចេតិយ (ព្រះចេតិយសម្គែងនូវការថ្វាយជីវិតក្នុងការទទួលបម្រើព្រះអង្គ ដល់ខ្ញុំព្រះករុណាផងចុះ) ។

គ្រានោះ ព្រះមានជោគទ្រង់បានយកព្រះហស្តសាបព្រះសិរសាព្រះកេសាទាំងឡាយ ក៏ជាប់ព្រះហស្តមក ៨ សរសៃ ព្រះអង្គក៏បានប្រទានព្រះកេសា ៨ សរសៃនោះឲ្យដល់តបុស្សៈ និងកល្លិកៈទាំងពីរនាក់បងប្អូន ។ តបុស្សៈ និងកល្លិកៈពីរនាក់បងប្អូនបានទទួលព្រះកេសធាតុហើយយាងព្រះកេសធាតុទៅប្រតិស្ឋាននៅក្នុងប្រអប់មាស ដោយសេចក្តីជ្រះថ្លា ទើបថ្វាយបង្គំលាព្រះសម្ពុទ្ធ ហើយយាងព្រះកេសធាតុទៅកាន់នគររបស់ខ្លួន នាយពាណិជពីរនាក់បងប្អូន កាលត្រឡប់មក

ដល់អសិតញ្ជនគរហើយ បានបញ្ចុះព្រះកេសធាតុទាំង ៨ សរសៃទុក ក្នុងព្រះចេតិយមួយកន្លែង ដើម្បីធ្វើសក្ការគោរពបូជា ។

ពេលដល់ថ្ងៃឧបោសថ មានស្ត្រីពណ៌ខៀវផ្សាយចេញពីព្រះចេតិយ ដែលបញ្ចុះព្រះកេសធាតុនោះ ។ តបុស្សៈ និងភល្លិកៈពីរនាក់បងប្អូន បានជាឧបាសកនៅក្នុងព្រះសាសនានេះ ដោយពោលដល់ព្រះរតនត្រ័យពីរ គឺព្រះពុទ្ធ ព្រះធម៌មុនឧបាសកទាំងឡាយ ។ ហេតុដែលអ្នកទាំងពីរនាក់បងប្អូន បានពោលវាចាដល់ព្រះរតនត្រ័យទាំង ២ នោះ ពីព្រោះព្រះសង្ឃមិនទាន់កើតមានក្នុងលោក ។

ភាពជាអ្នកដាក់ចិត្តជឿ ក្នុងព្រះពុទ្ធជាម្ចាស់របស់តបុស្សៈ និងភល្លិកៈ ដូចដែលព្រះលោកនាយកទ្រង់ត្រាស់សម្តែងទុកនៅក្នុង ***គម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត*** ដូចមានសេចក្តីថា ៖-

ព្រះសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តបុស្សៈ និងភល្លិកៈ មានធម៌ ៦ ប្រការ ជាអ្នកអាចដាក់ចិត្តជឿក្នុងព្រះតថាគត ព្រោះបាន

ឃើញនូវអមតធម៌ (ធម៌មិនស្លាប់) ធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ធម៌ ៦ ប្រការនោះ តើដូចម្តេច ? ធម៌ ៦ ប្រការនោះ បានដល់ ១- សេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធអង្គជាម្ចាស់ ២- សេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ ៣- សេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃ ៤- ជាអ្នកមានអរិយសីល សំដៅដល់លោកុត្តរសីល (សីលដែលផុតចាកលោក) គឺអស់ទោសហើយ ៥- ជាអ្នកមានអរិយញ្ញាណ សំដៅដល់បច្ចវេក្ខណញ្ញាណ គឺញាណពិចារណាមគ្គផលសាឡើងវិញ ៦- ជាអ្នកមានអរិយវិមុត្តិ សំដៅដល់ផលវិមុត្តិ (ផល គឺការរួចផុតកិលេស) របស់ព្រះសេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តបុស្សៈ និងភល្លិកៈ ប្រកបដោយធម៌ ៦ ប្រការនេះឯង ជាអ្នកជាក់ចិត្តជឿក្នុងតថាគត (អដ្ឋកថាអធិប្បាយថា ជាអ្នកមានចិត្តតាំងមាំ ហើយក្នុងព្រះពុទ្ធគុណ គឺអ្នកអស់ទុវិសេចក្តីសង្ស័យហើយ) ជាអ្នកឃើញនូវអមតធម៌ ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ហើយ ។

កាលតមក តបុស្សៈ និងកលិកៈបានទទួលទូវការលើកតម្កើងពីព្រះសម្ពុទ្ធ ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងជាអ្នកដល់ទ្វៃចិកៈ ដូចមានសម្តែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះភគវាទ្រង់គង់ប្រថាប់នៅវត្តជេតពន ទ្រង់បានប្រកាសតែងតាំងឧបាសកទាំងឡាយទុកក្នុងតំណែងផ្សេងៗ ពីគ្នា ហើយទ្រង់បានប្រកាសតែងតាំងតបុស្សៈ និងកលិកៈពីរនាក់បងប្អូន ទុកក្នុងតំណែងដ៏ប្រសើរថា

ឯតទគ្គំ កិក្ខវេ មម សាវកានំ ឧបាសកានំ បឋមំ សរណំ គច្ឆន្តានំ យទិទំ តបុស្សភល្លិកាវាណិជា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសក អ្នកដល់សរណៈជាបឋម ដែលជាសាវ័ករបស់តថាគត សម្រេចនឹងតបុស្សពាណិជ និងកលិកពាណិជ ប្រសើរជាងគេ ។

នៅមានបច្ច័យដ៏សំខាន់មួយប្រការទៀត ដែលជួយឲ្យតបុស្សៈ

និងកល្យិក:ពីរនាក់បងប្អូន បានទទួលទូវតំណែង ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ អ្នកដល់សរណៈមុនគេ ដូចមានរឿងសម្តែងនៅ**ក្នុងអដ្ឋកថា មនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីថ្លៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖-

ក្នុងអតីតកាល រាប់ថយក្រោយពីកទូកប្បនេះទៅ មួយសែនកប្ប ក្នុងសម័យព្រះសម្មាសម្ពុទ្ធបទុមុត្តរៈជាម្ចាស់ ។ តបុស្សៈ និងកល្យិក: ពីរនាក់បងប្អូននោះ បានកើតក្នុងត្រកូលអ្នកមានធនធានមួយ នៅក្នុងនគរហង្សវតី ។ ក្នុងកាលតមក កាលអ្នកទាំងពីរនាក់នោះចម្រើនវ័យធំដ៏ថ្កើហើយ បានទៅស្តាប់ព្រះទេសនារបស់ព្រះបទុមុត្តរៈ ហើយបានឃើញព្រះបទុមុត្តរៈប្រកាសតែងតាំងឧបាសកពីរនាក់ ទុកក្នុងតំណែងឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ អ្នកដល់សរណៈមុនគេ អ្នកទាំងពីរនាក់នោះ ក៏កើតសេចក្តីជ្រះថ្លាពេញចិត្តក្នុងតំណែងនោះ ទើបធ្វើអធិការកុសល មានការថ្វាយទានដល់កិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន

ហើយតាំងសេចក្តីជ្រះថ្លានៅចំពោះព្រះភក្ត្រនៃព្រះពុទ្ធជាម្ចាស់ ដើម្បីឲ្យបានសម្រេច ដូចជាឧបាសកទាំងពីរនាក់នោះដែលបានទទួលការតែងតាំងពីព្រះពុទ្ធអង្គនោះហើយ ។

កុលបុត្រទាំងពីរនាក់នោះ កាលបើអស់ជីវិតអំពីជាតិនោះហើយ បានត្រាច់រង្គាត់ជាមនុស្ស និងទេវតា រហូតមួយសែនកប្ប លុះដល់ពុទ្ធកាលព្រះបរមគ្រូនៃយើង អ្នកទាំងពីរនាក់នោះបានមកកើតនៅក្នុងត្រកូលកុដុម្ពិក ក្នុងអសិតញ្ជនគរ ហើយមានឈ្មោះថា តបុស្សៈ និងភល្លិកៈ ដូចដែលបានពោលរួចមកហើយ ។

(ជីវប្រវត្តិរបស់តបុស្សៈ និងភល្លិកៈ ចប់)

ssssssssssssssssssssssssssssssssssssssssssssssssss

✍ ជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី ✍

“ លោកជាឯតទគ្គៈផ្នែកខាងអ្នកឱ្យទាន ”

អនាថបិណ្ឌិកសេដ្ឋី លោកជាអរិយឧបាសក ដែលជាអ្នកពេញចិត្ត ក្នុងការបរិច្ចាគទាន រហូតដល់មានអ្នកដទៃស្គាល់លោកជាច្រើន ពីព្រោះលោកមិនធ្លាប់ស្តាយទ្រព្យសម្បត្តិក្នុងការឲ្យទាន ទោះជាអស់ប៉ុន្មានក៏មិនថា ហេតុដូច្នេះហើយ ទើបលោកបានទទួលការលើកតម្កើងពីព្រះសយម្ភូថា ជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងការឲ្យទាន ក្នុងព្រះពុទ្ធសាសនានេះ ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់អនាថបិណ្ឌិកសេដ្ឋី មានសម្តែងទុកនៅក្នុង ***អដ្ឋកថាមនោរថបូរណី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង* ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** *ដូចមានសេចក្តីថា ៖-*

ក្នុងកាលមួយសែនកប្បកន្លងមកហើយ ដោយរាប់ថយក្រោយពីកទុកប្បនេះទៅ ក្នុងសម័យពុទ្ធកាល នៃព្រះបទុមុត្តរសម្ពុទ្ធជាម្ចាស់

ក្នុងកាលនោះ អនាថបិណ្ឌិកសេដ្ឋីបានកើតនៅក្នុងត្រកូលមួយ នៅក្នុងនគរហង្សវតី កាលលោកចម្រើនវ័យធំដឹងក្តីឡើង លោកបានទៅស្តាប់ព្រះធម៌ទេសនានៃព្រះបទុមុត្តរៈជាម្ចាស់ កាលនោះ លោកបានឃើញព្រះបទុមុត្តរៈប្រកាសតែងតាំងឧបាសកមួយរូប ទុកក្នុងតំណែងឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងការឲ្យទាន ទាំងនេះជាហេតុ ធ្វើឲ្យលោកនឹកពេញចិត្តក្នុងតំណែងនោះ ទើបបានរៀបចំការថ្វាយទាន និងបំពេញសេចក្តីល្អ ហើយតាំងសេចក្តីប្រាថ្នាក្នុងតំណែងនោះ ដោយអំណាចអធិការកុសលនេះ កាលលោកអស់ជីវិតពីជាតិនោះទៅហើយ ធ្វើឲ្យលោកមានការត្រាច់រង្គាត់ជាមនុស្ស និងទេវតា អស់មួយសែនកប្ប ។ តមក ក្នុងពុទ្ធុប្បាទកាលនេះ បានមកកើតជាបុត្ររបស់ **សុមនសេដ្ឋី** នៅក្នុងនគរសាវត្ថី ។ មាតាបិតា និងពួកញាតិ បានដាក់ឈ្មោះលោកថា **សុទត្តៈ** ប្រែថា អ្នកឲ្យសេចក្តីសុខ ។ ក្នុងកាលតមក សុទត្តមាណពបានរស់នៅក្នុងការគ្រប់គ្រងផ្ទះ មានភរិយារបស់លោកឈ្មោះ **បុញ្ញលក្ខណាទេវី** មានកូនស្រី ៣ នាក់ ឈ្មោះ **មហាសុភទ្ទ**

ចូឡសុភទ្ទា និង **សុមនាទេវី** ហើយមានកូនប្រុស ឈ្មោះ **កាលៈ** ។ លោកបានជាអធិបតី (អ្នកជាម្ចាស់ទាន) ទាំងបានបរិច្ចាគទាន រហូតមាននាមថា **អនាថបិណ្ឌិក** ប្រែថា អ្នកមានជុំបាយដល់បុគ្គលអនាថា គឺជាឈ្មោះដែលមហាជនដាក់ឲ្យ ព្រោះគុណ គឺសេចក្តីល្អ ដែលលោកបានធ្វើហើយ និងជាឈ្មោះដែលកើតឡើង ដោយអំណាចសេចក្តីល្អដែលលោកធ្វើទុកបួចមកហើយតាំងអំពីអតីតជាតិ ហើយប្រាថ្នាក្នុងតំណែងនោះ ។

ជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី ក្រៅពីការពោលទុកនៅក្នុង **អដ្ឋកថាគម្ពីរមនោរថបូរណីហើយ** នៅមានពោលទុកក្នុង **អនាថបិណ្ឌិក-គហបតិកថា សន្តិកេនិទាន គម្ពីរនិបាតជាតក** ក្នុងព្រះបាលី **សេនាសនក្ខន្ធកៈ គម្ពីរចូឡវគ្គ ព្រះវិន័យបិដក** និងក្នុង **ព្រះបាលីយក្ខសំយុត្ត គម្ពីរខុទ្ទកនិកាយ សគាថវគ្គ នៃសុទ្តសូត្រ** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះមានព្រះភាគ គង់ប្រថាប់នៅក្នុងព្រៃសីតវន នៅនគរោជគ្រឹះ ។ អនាថបិណ្ឌិកសេដ្ឋី ត្រូវជាបួនថ្លៃរបស់រាជគហសេដ្ឋី

អ្នកនៅនគរវាជគ្រឹះ (គម្ពីរខ្លះពោលថា ជាសម្ងាញ់នឹងគ្នា) ។ គ្រាមួយ អនាថបិណ្ឌិកសេដ្ឋីផុតទំនិញ ៥០០ រទេះ ហើយនាំហ្វូងរទេះចេញពីក្រុងសាវត្ថី ធ្វើដំណើរទៅជួញដូរនៅនគរវាជគ្រឹះ ដោយបានទៅស្នាក់នៅក្នុងនិវេសន៍របស់រាជគហសេដ្ឋី កាលនោះរាជគហសេដ្ឋីបាននិមន្តភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដើម្បីទទួលភត្តាហារ ក្នុងថ្ងៃស្អែក ទើបប្រាប់ដល់ពួកទាសកម្មករថា ពួកអ្នកចូរក្រោកពីព្រលឹម ចូរដាំបបរជាំបាយ ធ្វើម្ហូប ហើយចូរជួយគ្នារកអាហារដែលមានរសជាតិឆ្ងាញ់ៗ ទុកឲ្យច្រើន កុំឲ្យខ្វះ ។ អនាថបិណ្ឌិកសេដ្ឋីធ្លាប់បានមកស្នាក់នៅផ្ទះរបស់រាជគហសេដ្ឋី រាល់ពេលដែលធ្វើដំណើរមកដល់ក្រុងរាជគ្រឹះ តែការមកស្នាក់អាស្រ័យលើកនេះ មានហេតុការណ៍ខុសប្លែក ធ្វើឲ្យលោកគហបតីគិតថា កាលលើកមុន ពេលយើងមកដល់រាជគហសេដ្ឋី ត្រូវផ្អាកកិច្ចធុរៈទាំងពួងអស់ ហើយមកសម្តែងនូវការរាក់ទាក់រីករាយនិងសន្ទនាប្រាស្រ័យជាមួយយើងតែម្នាក់ តែពេលនេះ គេមានកាយវិការផ្ទាស់ប្តូរ គេរវល់ខ្វល់ខ្វាយប្រាប់ទាសកម្មករទាំងឡាយ ឲ្យក្រោកពីព្រលឹម

ឲ្យជួយដាំស្រូ ធ្វើអាហារដែលមានរសជាតិឆ្ងាញ់ បែបគេមានរៀបចំពិធី ***អាវាហមង្គល វិវាហមង្គល*** ឬធ្វើពិធីបូជាមហាយញ្ញ ឬក៏ក្រាបទូលយាងព្រះបាទពិម្ពិសារមហារាជ ព្រមដោយពួកអាមាត្យ មកសោយអាហារក្នុងថ្ងៃស្អែកនេះទេដឹង ។

ពេលរាជគហសេដ្ឋីជ្រាប់កម្មករ និងទាសៈ រួចស្រេចហើយទើបទៅរកអនាថបិណ្ឌិកសេដ្ឋី ហើយអង្គុយសន្ទនាគ្នា នៅត្រង់កន្លែងដែលសមគួរមួយ ។ អនាថបិណ្ឌិកសេដ្ឋី បានសួរព្រះរាជគហសេដ្ឋីថា កាលមុនពេលដែលខ្ញុំមកដល់ លោកបានផ្អាកកិច្ចការងារទាំងពួងហើយមកសម្តែងសេចក្តីរីករាយ និងសន្ទនាជាមួយខ្ញុំតែម្នាក់គត់ តែពេលនេះលោកវិលទៅជាមួយនឹងការងារ ទាំងជ្រាប់កម្មករ និងទាសៈឲ្យរៀបចំអាហារផ្សេងៗ លោករៀបចំអាវាហមង្គល វិវាហមង្គល ឬក៏ធ្វើពិធីបូជាមហាយញ្ញ ឬក្រាបទូលយាងព្រះបាទពិម្ពិសារមហារាជនៃដែនមគធៈព្រមដោយពួកអាមាត្យ ដើម្បីមកសោយអាហារនៅថ្ងៃស្អែក ឬយ៉ាងណា ? រាជគហសេដ្ឋីទើបតបថា លោកគហបតី ខ្ញុំមិនបានរៀបចំអាវាហមង្គល

ឬវិហារមង្គល និងរៀបចំអ្វីសម្រាប់ស្តេចផែនដី ព្រមទាំងពួកអាមាត្យ ដើម្បីមកសោយអាហារក្នុងថ្ងៃស្អែកនោះទេ តែខ្ញុំនឹងធ្វើពិធីបូជាមហាយញ្ញ គឺខ្ញុំបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីស្តេចយាងមកទទួលកត្តក្នុងថ្ងៃស្អែកនេះ ។

ទើបអនាថបិណ្ឌិកសេដ្ឋីសួរថា លោកពោលថា ព្រះពុទ្ធជាម្ចាស់ឬ? រាជគហាសេដ្ឋីតបថា ត្រូវហើយ ខ្ញុំពោលថា ព្រះពុទ្ធជាម្ចាស់មែន ។ អនាថបិណ្ឌិកសេដ្ឋី បានសួររាជគហាសេដ្ឋីដូច្នេះ រហូតដល់ ៣ ដង ព្រមគ្នានោះឯង ក៏បានស្តាប់ពាក្យឆ្លើយតបព្រះនាមថា ព្រះពុទ្ធជាម្ចាស់ ទើបពោលថា លោករាជគហាសេដ្ឋី ពាក្យថា ព្រះពុទ្ធជាម្ចាស់ នេះជាពាក្យដែលរកបានដោយកម្រក្នុងលោក តើខ្ញុំអាចចូលទៅគាល់ព្រះសម្ពុទ្ធដែលទ្រង់ជាព្រះអរហន្តសម្មាសម្ពុទ្ធ នៅក្នុងលោកនេះបានដែរឬទេ ? រាជគហាសេដ្ឋីតបថា លោកគហបតី ពេលនេះជាពេលដែលមិនគួរដើម្បីនឹងចូលទៅគាល់ព្រះលោកនាថទេ ព្រោះមិនមែនជាវេលាដែលនឹងត្រូវចូលទៅគាល់ រង់ចាំស្អែកសិនចុះ លោកនឹងអាចចូលទៅគាល់

បាន ។ ពេលអនាថបិណ្ឌិកសេដ្ឋីចប់ការសន្ទនាហើយ ក៏ចូលទៅកាន់ទីសម្រាក លោកក៏បានដេកនឹកដល់ព្រះពុទ្ធជាម្ចាស់មកជាអារម្មណ៍ជានិច្ចថា ព្រឹកស្អែកនេះ យើងនឹងបានចូលទៅគាល់ព្រះលោកនាយកទ្រង់ជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ។ ពេលដែលអនាថបិណ្ឌិកសេដ្ឋីដេកនឹកដល់ព្រះពុទ្ធអង្គដូច្នេះហើយ យប់នោះ លោកបានភ្ញាក់ ៣ ដង ហើយយល់ថាភ្លឺហើយ ទើបក្រោកឡើង ធ្វើដំណើរទៅកាន់ព្រៃសីតវនៈ ពួកអមនុស្ស បានជួយបើកទ្វារឲ្យដល់អនាថបិណ្ឌិកសេដ្ឋី លោកបានធ្វើដំណើរចេញទៅដោយសុវត្ថិភាព ។

ខណៈដែលអនាថបិណ្ឌិកសេដ្ឋី បានដើរចេញពីដែនព្រះនគរទៅហើយ ពន្លឺក៏បាត់អស់ទៅ ភាពងងឹតក៏ប្រាកដឡើងមក លោកសេដ្ឋីក៏កើតការភ័យតក់ស្លុត រហូតដល់បះរោមឡើង ក៏គិតថា នឹងត្រឡប់ទៅវិញ ។ ក្នុងពេលនោះ **សីវកយក្ខ** មិនប្រាកដកាយឲ្យលោកសេដ្ឋីបានឃើញទេ តែបានបញ្ចេញសំឡេងឲ្យឮថា លោកសេដ្ឋី ជីវិតមួយសែនក្បាល សេះមួយសែនក្បាល កុមារីតូចប្រដាប់ដោយក្រវិលពេជ្រផ្សេងៗ

មួយសែននាក់ ក៏នៅមិនស្មើនឹងចំណែកទី ១៦ ដែលជ្រៀកហើយជា ១៦ ចំណែកនៃការឈានទៅមុខត្រឹមតែមួយជំហាន ហេតុដូច្នេះ សូមលោកឈានទៅខាងមុខចុះ ការឈានទៅមុខរបស់លោក ទើបប្រសើរជាង លោកកុំត្រឡប់ថយក្រោយឡើយ ។ ពេលនោះ កាពង់ងឺតក៏បាត់អស់ទៅ ហើយពន្លឺក៏កើតមានច្រាកជឡើង ធ្វើឲ្យអនាថបិណ្ឌិកសេដ្ឋីបាត់ការភ័យខ្លាច រោមដែលបះឡើងក៏ស្ងប់ទៅ ។ អនាថបិណ្ឌិកសេដ្ឋីទើបឈានជើងដើរទៅមុខទៀត ពេលដើរទៅបានមួយសន្ទុះ ហេតុការណ៍ដូចមុនបានច្រាកជឡើងទៀត ធ្វើឲ្យលោកសេដ្ឋីអល់អែកចិត្ត គិតនឹងថយក្រោយ តែក៏មានសំឡេងរបស់ **សីវកយក្ខ** មកពោលរញ្ជួយឲ្យកម្សាន់ចិត្តដល់អនាថបិណ្ឌិកសេដ្ឋីម្តងទៀតជាលើកទី ២ ដូចមុន ។

ពេលកាពង់ងឺតបាត់ទៅ ពន្លឺក៏កើតច្រាកជឡើង ដល់អនាថបិណ្ឌិក-សេដ្ឋី ទើបឈានដើរទៅមុខទៀត តែបន្ទាប់មកកាពង់ងឺតក៏កើតឡើងម្តងទៀត កាលបើជួបហេតុនោះទៀតហើយ លោកក៏គិតនឹងត្រឡប់ទៅវិញ តែសីវកយក្ខបានពោលឲ្យកម្សាន់ចិត្តដូចលើកទី ២ ដែរ ហើយ

ហេតុការណ៍ ក៏ត្រឡប់ពីភាពឆងឹតមកភ្លឺវិញ ធ្វើឲ្យអនាថបិណ្ឌកសេដ្ឋី អស់នូវភាពភ័យខ្លាច រោមដែលបះឡើងក៏ស្ងប់ទៅ ហើយអនាថបិណ្ឌិក-សេដ្ឋី បានដើរទៅមុខរហូតដល់ព្រៃសីតវ័ន ដែលជាស្ថានទីស្នាក់អាស្រ័យនៅរបស់ព្រះសម្ពុទ្ធ ។ ក្នុងពេលនោះ ជាពេលជិតភ្លឺ ព្រះសក្យមុនីទ្រង់តើនឡើង ទ្រង់យាងចង្រ្កមក្នុងទីស្រឡះមួយ បានទតឃើញអនាថបិណ្ឌិកសេដ្ឋី កំពុងធ្វើដំណើរមកអំពីចម្ងាយ ទើបទ្រង់ចេញពីទីចង្រ្កមទៅគង់លើអាសនៈដែលគេក្រាលទុក បន្ទាប់មក ព្រះអង្គបានត្រាស់ជាមួយអនាថបិណ្ឌិកសេដ្ឋីថា មកចុះ ***សុទត្តៈ*** ។ កាលអនាថបិណ្ឌិកសេដ្ឋីបានស្តាប់ពុទ្ធតម្រាស់ត្រាស់ហៅ ក៏កើតការសប្បាយចិត្តថា ព្រះភគវាត្រាស់ហៅឈ្មោះរបស់យើងត្រូវ ទើបចូលទៅក្រាបថ្វាយបង្គំ ទៀបព្រះយុគលបាទនៃព្រះមុនី ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន តើព្រះអង្គសុខសប្បាយឬទេ ? ព្រះមានជោគបានត្រាស់តបជាធម្មកថាដោយត្រាស់ថា ព្រាហ្មណ៍ដែលជាអ្នករំលត់ទុក្ខបានហើយ រមែងនៅជាសុខគ្រប់ពេលវេលា អ្នកណាមិនជាប់នៅក្នុងកាមទាំងឡាយ ជាអ្នក

មានចិត្តត្រជាក់ ជាអ្នកមិនមានឧបធិ ជាអ្នកកាត់នូវចំណងបានគ្រប់យ៉ាងហើយ ជាអ្នកកម្ចាត់នូវគ្រឿងកង្វល់ក្នុងចិត្ត ជាអ្នកដល់នូវភាពស្ងប់រំងាប់នៃចិត្ត បុគ្គលនោះ រមែងនៅជាសុខ ។

ជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី បន្ទាប់តពីនេះទៅ ក៏មានសម្តែងនៅក្នុង **គម្ពីរចុល្លវគ្គ ព្រះវិន័យបិដក** ដូចមានសេចក្តីថា ៖-

កាលព្រះសម្ពុទ្ធ ទ្រង់គ្រាស់តបដូច្នេះហើយ ទើបទ្រង់សម្តែង **អនុបុព្វីកថា** ដែលពោលអំពី **ទានកថា ១ សីលកថា ១ សគ្គកថា ១ អាទីនវកថា ១ នេក្ខម្មានិសំសកថា ១** ។ កាលទ្រង់ប្រកាសអានិសង្សក្នុងការចេញចាកកាមដូចនេះហើយ ក្នុងខណៈនោះ ព្រះមានជោគទ្រង់ជ្រាបថា អនាថបិណ្ឌិកសេដ្ឋី មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តជ្រះថ្លា ទើបព្រះអង្គទ្រង់សម្តែងនូវព្រះធម្មទេសនាទៀត បានដល់ **សាមុក្កង្សិកធម្ម** គឺព្រះធម៌ដែលព្រះសម្ពុទ្ធ ទ្រង់លើកមកសម្តែងដោយព្រះអង្គឯង សំដៅដល់ **អរិយសច្ច ៤** ។ អនាថបិណ្ឌិកសេដ្ឋីបានស្តាប់ព្រះធម៌ទេសនានេះហើយ **ធម្មចក្ខុ** បានដល់ ភ្នែក គឺបញ្ញា ដោយ

ពិចារណាឃើញថា ***វត្ថុណាមួយមានការកើតជាធម្មតា វត្ថុនោះមានការរលត់ទៅវិញជាធម្មតា*** ប្រៀបដូចជាសំពត់ដែលជ្រាសចាកនូវភាពកខ្វក់ គួរដល់ការទទួលទឹកជ្រលក់ពណ៌ ដូច្នោះ ។ ពេលដែលអនាថបិណ្ឌិកសេដ្ឋី បានឃើញធម៌ហើយ (សំដៅដល់ បានសម្រេចជាព្រះសោតាបន្នហើយ) បានសម្រេចធម៌ហើយ បានដឹងធម៌ច្បាស់ហើយ ជាអ្នកចុះកាន់ធម៌ហើយ ជាអ្នកឆ្លងផុតនូវសេចក្តីសង្ស័យបានហើយ ជាអ្នកដល់នូវភាពក្លៀវក្លា ជាអ្នកមិនជឿបុគ្គលដទៃទៀត ក្នុងព្រះសាសនានេះ បានក្រាបទូលពោលសរសើរនូវព្រះធម៌ទេសនាថា បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ***ក្តីច្បាស់ពេកណាស់ ពីរោះពេកណាស់*** ។ ព្រះអង្គបានសម្តែងនូវព្រះធម៌ទេសនា ដោយអនេកបរិយាយយ៉ាងនេះ ប្រៀបដូចជាបុគ្គលផ្ងារបស់ដែលផ្កាប់ ហើយបើករបស់ដែលបិទ ប្រាប់ផ្លូវដល់បុគ្គលអ្នកវង្វេងផ្លូវ ឬត្រាលប្រទីបក្នុងទីងងឹត ដោយតាំងចិត្តថា ឲ្យអ្នកមានភ្នែកក្តី បានឃើញនូវរបស់ដែលចង់ឃើញ ។

អនាថបិណ្ឌិកសេដ្ឋី បានប្រកាសខ្លួនជាឧបាសក (អ្នកអង្គុយជិត

ព្រះរតនត្រ័យ) ថា ខ្ញុំព្រះករុណា សូមដល់ព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ គឺជាទីពឹងជាទីរឭក សូមព្រះអង្គចាំទុកខ្ញុំព្រះករុណាថា ជាឧបាសកអ្នកដល់ព្រះរតនត្រ័យ ចាប់ពីថ្ងៃនេះតទៅរហូតអស់មួយជីវិត ព្រះអង្គ ។ បន្ទាប់ពីអនាថបិណ្ឌិកសេដ្ឋី បានប្រកាសខ្លួនជាឧបាសកហើយ ទើបក្រាបទូលនិមន្តថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គព្រមទាំងភិក្ខុសង្ឃ ទទួលនូវភត្តាហាររបស់ខ្ញុំព្រះករុណាក្នុងថ្ងៃស្អែកនេះ ដើម្បីសេចក្តីចម្រើននូវបុណ្យកុសលដល់ខ្ញុំព្រះករុណាផង ព្រះអង្គ ។ គ្រានោះ ព្រះភគវា ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ ពេលនោះ អនាថបិណ្ឌិកសេដ្ឋីបានជ្រាបថា ព្រះសម្មុទ្ទ ទ្រង់ទទួលនិមន្តហើយ ទើបក្រោកចាកពីទីនោះថ្វាយបង្គំលា ហើយធ្វើប្រទក្សិណ (គឺការដើរជុំវិញ ៣ ជុំ) ហើយត្រឡប់ទៅកាន់និវេសន៍របស់រាជគហសេដ្ឋីវិញ ។ ចំណែករាជគហសេដ្ឋីបានជ្រាបថា អនាថ-បិណ្ឌិកសេដ្ឋី បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីទទួលភត្តាហារក្នុងថ្ងៃស្អែកនេះ ក៏បានសួរអនាថបិណ្ឌិកសេដ្ឋីថា លោកគហបតី

ខ្ញុំបានឮថា លោកបានទិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ប៉ុន្តែលោកជាភ្ញៀវមកពីស្រុកក្រៅ ខ្ញុំនឹងឲ្យលោកខ្ចីទ្រព្យដើម្បីយកទៅចំណាយ ឬវត្ថុរបស់របរផ្សេងៗ ដើម្បីរៀបចំថ្វាយបិណ្ឌបាតដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាននោះ ។ អនាថបិណ្ឌិកសេដ្ឋីពោលហាមថា នែគហបតី មិនចាំបាច់ទេ ព្រោះទ្រព្យសម្បត្តិរបស់របរផ្សេងៗដែលត្រូវថ្វាយបិណ្ឌបាតដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាននោះ របស់ខ្ញុំមានហើយ ។គ្រានោះ ព្រះបាទពិម្ពិសារ ជាព្រះរាជានៃដែនមគធៈ បានឮដំណឹងនោះ ក៏ទ្រង់មានព្រះរាជបំណងនឹងឲ្យអនាថបិណ្ឌិកសេដ្ឋីខ្ចីទ្រព្យ ដើម្បីចំណាយចាយវាយទៅក្នុងការថ្វាយចង្ហាន់បិណ្ឌបាតដល់ភិក្ខុសង្ឃ មានព្រះពុទ្ធអង្គជាប្រធាន ។

ចំណែកអនាថបិណ្ឌិកសេដ្ឋី បានក្រាបទូលបង្គំសេចថា សូមតេជៈក្រោមល្អងធូលីព្រះបាទ ជីវិតតម្កល់លើត្បូង នេះជាព្រះមហាករុណារបស់ព្រះអង្គ ប៉ុន្តែទ្រព្យសម្បត្តិខ្ញុំព្រះអង្គ ដែលត្រូវយកទៅចំណាយចាយវាយ ក្នុងការរៀបចំថ្វាយចង្ហាន់បិណ្ឌបាតដល់ភិក្ខុសង្ឃ ដែលមាន

ព្រះពុទ្ធជាប្រធាននោះ របស់ខ្ញុំព្រះអង្គមានហើយ ព្រះអង្គ ។ លុះដល់ព្រឹកស្អែកឡើង អនាថបិណ្ឌិកសេដ្ឋី បានបញ្ជូនមនុស្សឲ្យទៅក្រាបទូលកត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កត្តកាលដល់ហើយ កត្តសម្រេចហើយ ព្រះអង្គ ។ គ្រានោះ ព្រះសក្យមុនីព្រមទាំងភិក្ខុសង្ឃ ស្តេចយាងទៅកាន់និវេសន៍ របស់រាជគហសេដ្ឋី លុះទៅដល់ហើយ ទ្រង់គង់ប្រថាប់នៅលើអាសនៈ ដែលគេក្រាលទុកសម្រាប់ថ្វាយព្រះអង្គ រីឯភិក្ខុសង្ឃ បាននិមន្តគង់តាមលំដាប់វស្សាគ្នាចុះមក ។ អនាថបិណ្ឌិកសេដ្ឋី បានរៀបចំការថ្វាយចង្ហាន់ចំណូលបាត និងគ្រឿងបរិក្ខារដ៏ប្រណីតៗ ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាននោះ ដោយដៃខ្លួនឯង រហូតដល់ព្រះមានជោគសោយរួចស្រេចហើយ ទើបអង្គុយចុះនៅក្នុងទីដ៏សមគួរ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះសមុទ្ទ ព្រមដោយភិក្ខុសង្ឃ ទទួលអាវាធនាយាងទៅចាំវស្សានៅក្នុងក្រុងសាវត្ថី ដែលជាស្រុកកំណើតរបស់ខ្ញុំព្រះអង្គផង ព្រះអង្គ ។ ព្រះកគវាត្រាស់ថា នែគហបតី តថាគតតែងតែរីករាយ ក្នុងសុញ្ញាគារ

(ផ្ទះស្ងាត់ឬទីកន្លែងដែលមិនមានមនុស្ស) ។ កាលអនាថបិណ្ឌិកសេដ្ឋី ក្រាបទូលថា ខ្ញុំព្រះករុណាជ្រាបហើយ ព្រះអង្គ ។ បន្ទាប់ពីនោះ ព្រះលោកនាយក ទ្រង់សម្តែងព្រះធម៌ទេសនា ឲ្យអនាថបិណ្ឌិកសេដ្ឋី ឃើញច្បាស់ ឲ្យជឿមាំ ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈ ស្តេចយាងត្រឡប់ទៅវិញ ។

ពេលដែលអនាថបិណ្ឌិកសេដ្ឋី បានធ្វើដំណើរត្រឡប់មកវិញ តាមផ្លូវនោះ បាននិយាយបបួលអ្នកស្រុកតាមផ្លូវថា អ្នកទាំងអស់គ្នា ចូរនាំគ្នាជួយកសាងអារាម កសាងវិហារ ផ្តើមបំពេញទាន ពីព្រោះឥឡូវនេះ ព្រះពុទ្ធជាម្ចាស់ ទ្រង់ឧប្បត្តិឡើងក្នុងលោកហើយ ម្យ៉ាងទៀត ខ្ញុំបានក្រាបទូលអារាធនានិមន្តទុកហើយ ព្រះលោកនាយកស្តេចយាងមកតាមផ្លូវនេះឯង ។ ពពួកអ្នកស្រុក កាលដែលអនាថបិណ្ឌិកសេដ្ឋី បានបបួលយ៉ាងនេះហើយ ក៏នាំគ្នាកសាងអារាម កសាងវិហារ នាំគ្នាបំពេញទាន ទៅតាមកម្លាំងទ្រព្យដែលខ្លួនមាន ។ ពេលដែលអនាថ-បិណ្ឌិកសេដ្ឋី ត្រឡប់មកដល់ក្រុងសាវត្ថីវិញ បានចេញទៅកាន់មើលដី

នៅក្នុងក្រុងសាវត្ថី ដោយពិចារណាមើលថា តើព្រះលោកនាថ ទ្រង់គួរគង់ប្រថាប់ក្នុងទីណា ទើបជាស្ថានទីដែលសមគួរ ជាស្ថានទីមិនឆ្ងាយពេក មិនជិតពេកពីភូមិ មានផ្លូវទៅមកស្រួល ហើយពេលថ្ងៃមិនមានមនុស្សពពាក់ពពូន ពេលយប់ស្ងប់ស្ងាត់ មិនមានសំឡេងអឺកធឺក ជាស្ថានទីសមគួរដល់សមណៈ ជាស្ថានទីពួនសំងំ លោកក៏បានឃើញព្រះឧទ្យានរបស់ស្តេចជេត ដែលជាស្ថានទីដ៏សមគួរ គិតឃើញដូច្នេះហើយ បានចូលទៅគាល់ស្តេចជេតក្រាបទូលថា សូមថ្វាយបង្គំមហាបពិត្រ សូមទ្រង់ប្រទានលក់ព្រះឧទ្យានឲ្យដល់ខ្ញុំព្រះអង្គ ដើម្បីកសាងអាវាសថ្វាយដល់ព្រះពុទ្ធជាម្ចាស់ ។

គ្រានោះ ស្តេចជេតត្រាស់ថា នែគហបតី ឧទ្យានរបស់យើងមិនអាចលក់ឲ្យបានទេ លុះត្រាតែអ្នកយកទ្រព្យទៅក្រាលក្នុងស្ថានទីនោះឲ្យពេញត្រឹមណា ចូរអ្នកយកទៅចុះ ។ ពេលនោះ អនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា បើយ៉ាងនោះពិតមែន ព្រះអង្គទ្រង់ព្រមលក់ព្រះរាជឧទ្យាននោះឲ្យខ្ញុំព្រះអង្គពិតមែន ស្តេចជេតតបថា នែគហបតី យើងមិនទាន់ព្រមលក់

ឲ្យលោកនៅឡើយទេ ។ កាលអ្នកទាំង ២ នាក់ បាននិយាយមិនត្រូវគ្នា ទើបចូលទៅសួរអាមាត្យពិភាក្សាគ្នាថា ព្រមលក់ ឬមិនព្រមលក់ ។ អាមាត្យអ្នកពិភាក្សាតបថា ពេលដែលព្រះអង្គវាយតម្លៃហើយ គឺប៉ុនគ្នានឹងព្រះអង្គព្រមលក់ហើយ ព្រះអង្គ ។ ចំណែកអនាថបិណ្ឌិកសេដ្ឋី កាលបើបានទទួលការយល់ព្រមពីស្តេចជេតហើយ ទើបប្រាប់ឲ្យមនុស្សទាំងឡាយ នាំគ្នាជីកប្រាក់កាសដោយរាទេះ នាំយកទៅក្រាលក្នុងព្រះរាជ-ឧទ្យាននោះ តែប្រាក់ដែលយកទៅនោះ នៅខ្វះត្រង់ខ្ញោងទ្វារ លោកសេដ្ឋីបានឲ្យគេទៅប្រមូលប្រាក់មកទៀត ។ ខណៈនោះ ស្តេចជេតទ្រង់គិតថា រឿងនេះគង់មិនមែនជារឿងតូចតាចឡើយ ទើបធ្វើឲ្យលោកគហបតីហ៊ានលះបង់ទ្រព្យច្រើនយ៉ាងនេះ ទ្រង់ត្រិះរិះដូច្នេះហើយ ក៏បានប្រាប់ដល់អនាថបិណ្ឌិកសេដ្ឋីថា ល្មមហើយ លោកគហបតី លោកកុំយកប្រាក់មកក្រាលក្នុងទីនេះទៀតអី លោកចូរទុកទីនេះឲ្យខ្ញុំ ខ្ញុំនឹងចូលរួមជាមួយលោកដែរ ។

ពេលនោះ អនាថបិណ្ឌិកសេដ្ឋីពិចារណាឃើញថា ស្តេចជេត

ទ្រង់ជាអ្នកចង់បានឈ្មោះ នឹងធ្វើឲ្យមនុស្សទាំងឡាយ កាន់តែស្គាល់ព្រះអង្គថា ជាអ្នកធំ ហេតុនេះ ក៏នឹងធ្វើឲ្យព្រះអង្គកើតសេចក្តីជ្រះថ្លាក្នុងធម្មវិន័យនេះបានដែរ ទើបទុកទីនោះឲ្យស្តេចជេត ។ គ្រានោះ ស្តេចជេតបានឲ្យគេកសាងខ្ទោងទ្វារទុកនៅក្នុងទីនោះ ។ ចំណែកអនាថបិណ្ឌិកសេដ្ឋីបានឲ្យគេកសាងសេនាសនៈជាច្រើនខ្នងទុកនៅក្នុងវត្តជេតពន ឲ្យកសាងបរិវេណ ឲ្យកសាងខ្ទោងទ្វារ ឲ្យកសាងសាលាធាន់ ឲ្យកសាងរោងភ្លើង ឲ្យកសាងកប្បិយកុដិ ឲ្យកសាងវច្ចកុដិ ឲ្យកសាងទីចង្រ្កម ឲ្យកសាងអណ្តូងទឹក ឲ្យកសាងសាលានៅត្រង់អណ្តូងទឹក ឲ្យកសាងផ្ទះបាយ ឲ្យកសាងសាលាបាយ ឲ្យកសាងស្រះបោក្ខរណី និងឲ្យគេកសាងមណ្ឌបសម្រាប់ជាទីនៅ និងជាទីប្រព្រឹត្តបដិបត្តិធម៌របស់កិក្ខុសង្ឃទាំងឡាយ ។ ទីសេនាសនៈផ្សេងៗ ដែលអនាថបិណ្ឌិកសេដ្ឋីបានកសាងឡើង នៅក្នុងវត្តជេតពនមហាវិហារនោះ បានដល់ **ព្រះគន្ធកុដិ** (កុដិដែលអប់ទៅដោយក្លិនក្រអូប) សម្រាប់ព្រះភគវា ទុកនៅក្នុងកណ្តាល មានកុដិ ១ ជាន់ កុដិ ២ ជាន់ សាលាវែងមានឈ្មោះ **ហង្សវដ្តិកៈ** មណ្ឌបដែល

ជាអាវាស កន្លែងនៅរួមសម្រាប់ព្រះថេរៈ ៨០ អង្គ ស្រះបោក្ខរណី (ស្រះឈូក) ទីចង្រ្កម កន្លែងសម្រាកពេលយប់ និងកន្លែងសម្រាកពេលថ្ងៃ នៅជុំវិញព្រះគន្ធកុដិនោះ ។

ក្នុងរឿងការកសាងសាលាសម្នាក់តាមផ្លូវ ពីនគរោជគ្រឹះមកកាន់ក្រុងសាវត្ថី និងការកសាងវត្តជេតពន ដែលអនាថបិណ្ឌិកសេដ្ឋីបានលះបង់ទ្រព្យសម្បត្តិអស់ចំនួនជាច្រើន មានសម្តែងប្រាកដនៅក្នុង ***អនាថបិណ្ឌិកគហបតិកថាសន្តិកេនិទាន នៃអដ្ឋកថាជាតក ក្នុងអដ្ឋកថាមនោរថបូរណី*** និងក្នុង ***អដ្ឋកថាសារត្ថប្បកាសិនី*** ដូចមានសេចក្តីថា ៖-

អនាថបិណ្ឌិកសេដ្ឋី លោកបានលះបង់ទ្រព្យ ដើម្បីកសាងសាលាសម្នាក់មកតាមផ្លូវ ១ ខ្នង ១ សែនកហាបណៈ បានសាងឡើង ក្នុងរវាងផ្លូវ ១ យោជន៍ ១ ខ្នងៗ សម្រាប់ទុកជាទីសម្រាកតាមផ្លូវរបស់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បើគិតរយៈផ្លូវពីនគរោជគ្រឹះមកដល់ក្រុងសាវត្ថី មានចម្ងាយផ្លូវ ៤៥ យោជន៍ បើគិតពីចំនួនប្រាក់ ដែលអនាថបិណ្ឌិកសេដ្ឋីបរិច្ចាគកសាងសាលាមកតាមផ្លូវ ទាំងអស់ ៤ លាន

៥ សែនកហាបណៈ ។ ចំណែកប្រាក់ដែលចំណាយចាយវាយយកទៅ
ក្រាលព្រះរាជឧទ្យានរបស់ស្តេចជេតអស់ចំនួន ១៨ កោដិកហាបណៈ
និងប្រាក់ដែលចំណាយចាយវាយ ក្នុងការកសាងវត្តជេតពនទាំងអស់
ចំនួន ១៨ កោដិកហាបណៈ សរុបប្រាក់ដែលចំណាយចាយវាយទៅ
លើដី និងទៅលើការកសាងទីសេនាសនៈទាំងអស់ចំនួន ៣៦ កោដិ
កហាបណៈ ។ វត្តដែលអនាថបិណ្ឌិកសេដ្ឋីកសាងឡើង មានឈ្មោះថា
វត្តជេតពនមហាវិហារ ដោយនាំយកព្រះនាមរបស់ស្តេចជេតមកដាក់
ជាឈ្មោះវត្ត ។ កាលកសាងវត្តជេតពនមហាវិហាររៀបរយស្រេចហើយ
អនាថបិណ្ឌិកសេដ្ឋីបានបញ្ជូនទូត ឲ្យទៅក្រាបទូលអារាធនាព្រះភគវា
មួយអន្ទើដោយភិក្ខុសង្ឃជាច្រើន ឲ្យស្តេចយាងមកកាន់ក្រុងសាវត្ថី ។
ព្រះមានជោគ មួយអន្ទើដោយភិក្ខុសង្ឃជាច្រើន ស្តេចបានយាងចេញ
ចាកពីនគរោជគ្រឹះ មកតាមផ្លូវដែលអនាថបិណ្ឌិកសេដ្ឋី បានកសាង
សាលា តាមលំដាប់ផ្លូវមកសម្រាប់ជាទីសម្រាកក្នុងរវាងផ្លូវ ១ ថ្ងៃ ១
យោជន៍ សរុបពេលវេលាដែលព្រះសម្ពុទ្ធ ទ្រង់ធ្វើពុទ្ធដំណើរមកអស់

រយៈពេល ៤៥ ថ្ងៃ ទើបស្តេចយាងមកដល់ក្រុងសាវត្ថី ។

ចំណែកអនាថបិណ្ឌិកសេដ្ឋី ក៏បានឲ្យគេរៀបចំតាក់តែងព្រះវិហារយ៉ាងស្អាត ហើយបានឲ្យបុត្រ ព្រមទាំងកុមារី ៥០០ នាក់ ឲ្យកាន់ទង់សំពត់ ៥ ពណ៌ ចំនួន ៥០០ ទង់ ទៅទទួលព្រះអង្គ ។ ក្នុងពេលដែលទទួលព្រះជិនស្រី មួយអន្ទៀដោយភិក្ខុសង្ឃ អនាថបិណ្ឌិកសេដ្ឋីបានរៀបចំក្បួនទទួលព្រះអង្គ ដោយឲ្យកុមារកាន់ទង់ ៥០០ នាក់នោះដើរនាំមុខព្រះសម្ពុទ្ធ ចំណែកក្បួនបន្ទាប់មកមានពួកឧបាសកដើរនាំមុខព្រះអង្គ ព្រមដោយភិក្ខុសង្ឃ ក្បួនបន្ទាប់តមកឲ្យភរិយា និងស្ត្រីបរិវារ ៥០០ នាក់ កាន់ឃ្លោកជាក់ទឹកដើរតាមក្រោយក្បួនព្រះលោកនាយក ហើយក្បួនចុងក្រោយជាក្បួនរបស់អនាថបិណ្ឌិកសេដ្ឋី និងសេដ្ឋីដែលជាបរិវារ ៥០០ នាក់ ដើរតាមក្បួនរបស់ព្រះមានជោគ ចូលទៅកាន់ **វត្តជេតពន** ។ ម្យ៉ាងទៀត អនាថបិណ្ឌិកសេដ្ឋី បានក្រាបទូលព្រះបាទបសេនទិកោសល ដើម្បីសូមព្រះរាជានុញ្ញាត ក្រាបទូលយាងព្រះនាងសុមនារាជកុមារី ឲ្យទៅទទួលព្រះមុនីផង ហើយព្រះនាងសុមនារាជកុមារី

បានទទួលព្រះបរមរាជានុញ្ញាត ព្រមដោយកុមារី ៥០០ នាក់ ទាំងព្រះនាងសុមនារាជកុមារី បានស្តាប់ព្រះធម៌ទេសនាហើយ ក៏បានសម្រេចព្រះសោតាបត្តិផល ព្រមដោយកុមារី ៥០០ នាក់ ដែលបានមកទទួលព្រះមានព្រះភាគនោះដែរ ។

កាលដែលព្រះសម្មាសម្ពុទ្ធ ស្តេចយាងចូលទៅកាន់ព្រះវិហារ ព្រះអង្គបានឲ្យពួកឧបាសក នាំដំណើរព្រះអង្គ ចំណែកព្រះមានជោគ ព្រមដោយភិក្ខុសង្ឃ ស្តេចយាងទៅតាមក្រោយ ចូលទៅកាន់វត្តជេតពន ដោយពុទ្ធលីលាដ៏សមសួន ដែលគ្មានអ្វីប្រៀបផ្ទឹមបាន ដោយទ្រង់បញ្ចេញរស្មី ៦ ពណ៌ ផ្សាយចេញពីព្រះវរកាយរបស់ព្រះអង្គ ទៅកាន់ទិសទាំងពួង ដែលគួរឲ្យអស្ចារ្យបំផុត សម្រាប់មនុស្ស និងទេវតាទាំងឡាយ ។ ពេលដែលព្រះភគវា ចូលទៅកាន់វិហាររៀបរយហើយ អនាថបិណ្ឌិកសេដ្ឋី បានក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គគប្បីបដិបត្តិយ៉ាងណាក្នុងវិហារនេះ ? គ្រានោះ ព្រះសយម្ភូទ្រង់ត្រាស់តបថា ម្នាលគហបតី ចូរអ្នកថ្វាយវិហារនេះចំពោះភិក្ខុសង្ឃ

ដែលមកអំពីទិសទាំង ៤ ចុះ ។

អនាថបិណ្ឌិកសេដ្ឋី ទើបក្រាបទូលព្រះសម្ពុទ្ធថា ព្រះករុណាព្រះអង្គ ហើយបានចាប់យកឃ្លោកមាសដែលមានទឹកជាក់ពេញ ច្រួចទៅលើព្រះហស្តនៃព្រះលោកនាយក ហើយក្រាបទូលថា ខ្ញុំព្រះអង្គសូមថ្វាយវត្តជេតពនមហាវិហារនេះចំពោះភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ មានព្រះពុទ្ធអង្គជាព្រះប្រធាន ។ គ្រានោះ ព្រះសម្ពុទ្ធទ្រង់ទទួលការថ្វាយវត្តជេតពនមហាវិហារ ហើយទ្រង់អនុមោទនាដោយទានកថា គឺព្រះអង្គទ្រង់ពណ៌នាជល់ទាន បានជល់ ការឲ្យទីអាស្រ័យថា ជាទានមានផលច្រើន ។លុះព្រឹកស្អែកឡើង ចាប់ពីថ្ងៃទី ២ទៅ អនាថបិណ្ឌិក-សេដ្ឋី បានផ្តើមធ្វើបុណ្យឆ្លងវត្តជេតពន ដោយមានការទំនុកបម្រុងបរិស័ទទាំង ៤ ដោយការត្រៀមកត្តាហារ ក្នុងការធ្វើបុណ្យឆ្លងនោះ ដោយមិនឲ្យលំបាកដល់បរិស័ទដែលបានអញ្ជើញមក ចូលរួមជាមួយជារៀងរាល់ថ្ងៃ ការធ្វើបុណ្យឆ្លងវត្តជេតពននោះ ធ្វើរហូតដល់ **៩ ថ្ងៃ** ដោយអនាថបិណ្ឌិកសេដ្ឋី បានចំណាយចាយវាយប្រាក់ធ្វើបុណ្យឆ្លង

ទាំងអស់ៗ ចំនួន **១៨ កោដិកហាបណៈ** ។ បើសរុបប្រាក់ដែលអនាថ-បិណ្ឌិកសេដ្ឋី បានចំណាយចាយវាយទិញជីកសាងវិហារ និងបរិវេណ ហើយធ្វើបុណ្យឆ្លងនោះ រួមទឹកប្រាក់ទាំងអស់ **៥៤ កោដិកហាបណៈ** ។ ចាប់ពីពេលនោះមក អនាថបិណ្ឌិកសេដ្ឋី បានថ្វាយទានជាប្រក្រតីក្នុងផ្ទះរបស់ខ្លួនរៀងរាល់ថ្ងៃ គឺការថ្វាយ **សលាកភត្ត** (អាហារដែលថ្វាយតាមស្លាក) មួយថ្ងៃ ៥០០ អង្គ, **បក្ខិកភត្ត** (អាហារដែលថ្វាយមួយបក្ខម្តង គឺ ១៥ ថ្ងៃម្តង) ម្តង ៥០០ អង្គ, **សលាកយាគូ** (បបរថ្វាយតាមស្លាក) មួយថ្ងៃ ៥០០ អង្គ, **បក្ខិកយាគូ** (បបរថ្វាយមួយបក្ខម្តង) ម្តង ៥០០ អង្គ **ធុវភត្ត** (អាហារថ្វាយជាប្រចាំ) មួយថ្ងៃ ៥០០ អង្គ, **អាគន្តុកភត្ត** (អាហារថ្វាយភិក្ខុសង្ឃមកពីទិសផ្សេងៗ) ៥០០ អង្គ, **គមិកភត្ត** (ភត្តដើម្បីធ្វើដំណើរ) ៥០០ អង្គ, **គិលានភត្ត** (ភត្តដែលថ្វាយដល់ភិក្ខុដែលអាពាធ) និងក្រាលអាសនៈជាប្រចាំសម្រាប់ភិក្ខុសង្ឃ ដែលនិមន្តមកជាប្រចាំ មួយថ្ងៃ ៥០០ អង្គ នៅនឹងផ្ទះរបស់លោក ។

កិត្តិគុណដ៏ថ្លៃថ្លារបស់អនាថបិណ្ឌិកសេដ្ឋី ដែលជាអ្នកបានទទួលការលើកតម្កើងពីព្រះមានជោគ ដែលមានសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖-

ក្នុងកាលបន្តបន្ទាប់មក កាលដែលព្រះសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅវត្តជេតពន ទ្រង់បានប្រកាសតែងតាំងឧបាសកទាំងឡាយ ទុកក្នុងតំណែងជាឯតទគ្គៈ គឺប្រព្រឹត្តទៅតាមឧបនិស្ស័យ និងសមត្ថភាពរបស់ខ្លួនតាមសមគួរ ទ្រង់បានប្រកាសតែងតាំងអនាថបិណ្ឌិកសេដ្ឋី ទុកក្នុងតំណែងជាឯតទគ្គៈថា

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបិណ្ឌិកោ ។ ម្នាលភិក្ខុទាំងឡាយ ពួកឧបាសកជាទាយក (អ្នកឲ្យទាន) ស្រេចនឹងសុទត្តគហបតី គឺអនាថបិណ្ឌិកសេដ្ឋី ។

អនាថបិណ្ឌិកសេដ្ឋី ក្រៅពីមានការសប្បាយចិត្តក្នុងការបរិច្ចាគទានហើយ លោកក៏ជាអ្នកប្រព្រឹត្តបដិបត្តិ សង្រ្គមនៅក្នុងសីល ទាំងមនុស្សដែលនៅក្នុងក្រុមគ្រួសាររបស់លោក ក៏បានជាអ្នកប្រព្រឹត្តប្រតិបត្តិតាម

ដូចដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថា គម្ពីរខុទ្ទកនិកាយជាតក នៃសរិកាឡ្យកណ្ណិជាតក** ដូចមានសេចក្តីថា ៖-

អនាថបិណ្ឌិកសេដ្ឋី បានរក្សាសីល ៥ អស់កាលជានិច្ច តាំងពីពេលដែលលោកសម្រេចព្រះសោតាបត្តិផលហើយ សីល ៥ ដែលអនាថបិណ្ឌិកសេដ្ឋីរក្សាជានិច្ចនោះ ជាសីលសម្រាប់អ្នកគ្រប់គ្រងផ្ទះ ដែលប្រែថា ***បកតិ*** *ឬត្រជាក់ មាន ៥ ប្រការ គឺ ១. វៀរចាកការសម្លាប់សត្វ (* ***បាណាតិបាតា វេរមណី*** *) ២. វៀរចាកការកាន់យកវត្ថុដែលគេមិនបានឲ្យ (* ***អទិន្នាទានា វេរមណី*** *) ៣. វៀរចាកការប្រព្រឹត្តខុសក្នុងប្រពន្ធកូនអ្នកដទៃ (* ***កាមេសុមិច្ឆាចារ វេរមណី*** *) ៤. វៀរចាកការនិយាយកុហក (* ***មុសាវាទា វេរមណី*** *) ៥. វៀរចាកការផឹកនូវទឹកស្រវឹង គឺសុរាមេរ័យ និងមជ្ជៈ ដែលជាទីតាំង នៃសេចក្តីប្រមាទ (* ***សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី*** *) ។ រីឯនាង* ***បុញ្ញលក្ខណាទេវី*** *ដែលជាភរិយារបស់អនាថបិណ្ឌិកសេដ្ឋីក៏បានជាអ្នករក្សាសីល ៥ ជានិច្ចដូចគ្នា សូម្បីបុត្ររបស់លោកសេដ្ឋី ក៏រក្សាសីល ៥ តាមលោកសេដ្ឋី*

និងរហូតដល់ទាសកម្មករទាំងឡាយរបស់លោក ក៏តាំងចិត្តរក្សាសីល ៥ ដូចគ្នា (ទាំងនេះចាត់ជាគ្រួសារគំរូ ដែលប្រកាន់យកក្នុងដំណើរជីវិត ជាអ្នកដល់ព្រមទៅដោយការរក្សាសីល) ។ ផលល្អនៃការរក្សាសីល របស់ទាសកម្មករ ដែលនៅក្នុងក្រុមគ្រួសាររបស់អនាថបិណ្ឌិកសេដ្ឋី បានផ្សាយទូទៅ គឺថ្ងៃមួយ ភិក្ខុទាំងឡាយ បានអង្គុយសន្ទនាគ្នា ក្នុងសាលាធម្មសភាថា លោកសេដ្ឋី ជាមនុស្សល្អទាំងខ្លួនឯង និងល្អទាំងបរិវារ ជាអ្នកប្រព្រឹត្តតាំងនៅក្នុង **បញ្ចសីល** គឺសីល ៥ អស់កាលជានិច្ច ។

ព្រះមុនី ស្តេចបានយាងទៅគង់ប្រថាប់នៅក្នុងសាលាធម្មសភា ដែលមានភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នា ហើយក៏បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុ អនាថបិណ្ឌិកសេដ្ឋីជាមនុស្សល្អ ទាំងខ្លួនឯង និងបរិវារទាំងអស់ ដែលជាអ្នកប្រព្រឹត្តខ្ជាប់ខ្ជួនក្នុងសីល ។ ចំពោះបុគ្គលដែលជាអ្នកមានបុណ្យបារមីធ្វើទុកបួចមកហើយ រមែងតែងតែប្រព្រឹត្តទៅឲ្យអ្នកដទៃបានទទួលនូវប្រយោជន៍ ដូចជាអនាថបិណ្ឌិកសេដ្ឋី ដែលជា

អ្នកមានបុញ្ញាភិនីហារ ផ្សាយទៅដល់ទាសកម្មករបស់លោក ម្យ៉ាងទៀត ទាំងលោកក៏ជាអ្នកបដិបត្តិខ្ជួនឯងឲ្យជាគំរូផង ទើបជាហេតុធ្វើឲ្យទាសកម្មករទាំងអស់ ជាអ្នកប្រព្រឹត្តតាម ។

ដូចមានរឿងពោលទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** និង **អដ្ឋកថាធម្មបទ** នៃ **អប្បមាទវគ្គ** ក្នុងរឿង **ព្រះនាងសាមាវតី** ថា ៖-

មានបុរសកម្សត់ម្នាក់ ជាអ្នកដើរស្វែងរកស៊ីឈ្នួល ក៏បានទៅធ្វើជាកូនឈ្នួលនៅក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី ដោយការធ្វើកិច្ចការងារក្នុងផ្ទះរបស់លោកសេដ្ឋី ដើម្បីចិញ្ចឹមជីវិត កាលតមក ដល់ថ្ងៃឧបោសថថ្ងៃមួយ អនាថបិណ្ឌិកសេដ្ឋី បានត្រឡប់ពីវត្តមកវិញ បានសួរថា ថ្ងៃនេះមាននរណា បានប្រាប់អំពីថ្ងៃឧបោសថដល់កូនឈ្នួល ដែលមកថ្មីនោះឬទេ ? មនុស្សនៅក្នុងផ្ទះឆ្លើយថា បពិត្រលោកម្ចាស់ មិនមាននរណាបានប្រាប់ឲ្យគេបានដឹងឡើយទាន ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋី ទើបប្រាប់ថា បើដូច្នោះ ពួកអ្នកចូរធ្វើអាហារសម្រាប់ពេលល្ងាចទុកឲ្យផង ។ ហើយមនុស្សទាំងនោះ បាននាំគ្នាធ្វើអាហារគ្រប់ទុកឲ្យកូនឈ្នួលនោះ

ចំណែកកូនឈ្នួលនោះ កាលត្រឡប់មកអំពីការងារក្នុងព្រៃពេញមួយថ្ងៃ ហើយគេបានត្រឡប់មកជល់ផ្ទះវិញ ក្នុងពេលល្ងាច កាលមនុស្សទាំងឡាយបាននាំគ្នាយកអាហារមកឲ្យ ក៏មិនទាន់បរិភោគនៅក្នុងពេលនោះភ្លាមទេ ដោយគិតថា យើងកំពុងតែអស់កម្លាំង តែគិតពិចារណាថា ក្នុងថ្ងៃផ្សេងៗ កន្លែងដែលដើរទៅមក តែងតែមានភាពអ៊ូអរនៅក្នុងផ្ទះនេះ ដោយអ្នកខ្លះនិយាយថា សូមលោកឲ្យបាយផង ឲ្យសម្លផង តែក្នុងថ្ងៃនេះ មនុស្សទាំងនោះ បែរជាដេកនៅស្ងៀមគ្មានសំឡេងអ៊ូអរ តែគេបានចាត់ចែងអាហារគ្រប់ទុកឲ្យយើង តែម្នាក់ប៉ុណ្ណោះ នេះប្រាកដជាមានហេតុអ្វីហើយ ទើបសួរថា អ្នកជនៃៗ បានបរិភោគអាហារអស់ហើយឬ ? មនុស្សទាំងនោះឆ្លើយថា ពួកយើងទាំងអស់គ្នាមិនបានបរិភោគអាហារទេ ។ បុរសកម្សត់នោះ សួរដើម្បីឲ្យដឹងការពិត ព្រោះហេតុអ្វីបានជាអ្នកទាំងអស់គ្នាមិនបរិភោគអាហារ ។

មនុស្សទាំងនោះ ឆ្លើយតបយ៉ាងច្បាស់ថា នៅក្នុងផ្ទះនេះ គេមិនបរិភោគអាហារនៅពេលល្ងាច ក្នុងថ្ងៃឧបោសថទេ ដោយមនុស្សគ្រប់គ្នា

ទាំងអស់ ជាអ្នកបានសមាទានទូវឧបោសថសីល ដោយហោចទៅ សូម្បីតែទាវកនៅជៀដោះ លោកសេដ្ឋីក៏ឲ្យគ្រុមាត់ ហើយបញ្ចុកបបរដែលមានរសផ្អែម ៤ មុខ ហើយធ្វើឲ្យជាបុគ្គលរក្សាឧបោសថ កាលប្រទីបភ្លើងឆេះដោយប្រេងក្រអូបអុជឡើងហើយ ក្មេងតូចៗ និងក្មេងធំទាំងឡាយបានចូលទៅកាន់កន្លែងដេក ហើយបាននាំគ្នាស្វាធ្យាយអាការៈ ៣២ តែថាពួកយើងក្មេចច្រាប់ដល់លោកថា ថ្ងៃនេះ ជាថ្ងៃឧបោសថ ព្រោះហេតុនោះទើបពួកយើងធ្វើអាហារទុកសម្រាប់លោកតែម្នាក់ ចូរលោកទទួលទានអាហារនោះចុះ ។ បុរសកម្សត់ក៏សួរថា តើខ្ញុំអាចរក្សាឧបោសថ ក្នុងពេលនេះទៅបានឬទេ ហើយខ្ញុំឈ្មោះថា ជាអ្នកបានសមាទានរក្សាឧបោសថសីលដែរឬទេ ? មនុស្សទាំងនោះ និយាយច្រាប់ថា ចំពោះសេចក្តីនេះ មានតែអនាថបិណ្ឌិកសេដ្ឋី ទើបជាអ្នកដឹងក្នុងរឿងនេះ ។ បុរសកម្សត់និយាយថា បើដូច្នោះ សូមអ្នកទាំងអស់គ្នា សូរបញ្ជាក្នុងរឿងនេះ ចំពោះអនាថបិណ្ឌិកសេដ្ឋីឲ្យខ្ញុំផងណា ។ អ្នកទាំងនោះ ក៏បាននាំគ្នាទៅសួរចំពោះអនាថបិណ្ឌិកសេដ្ឋីហើយ ។ គ្រានោះ អនាថបិណ្ឌិក-

សេដ្ឋី ប្រាប់បុរសនោះថា បាន បុរសនោះកាលបើដឹងដូច្នេះហើយ ទើបតាំងចេតនា ក្នុងការសមាទានឧបោសថសីល រួចខ្ចុរមាត់ ហើយបានអធិដ្ឋានឧបោសថសីល មួយរំពេចក្នុងពេលហ្នឹងឯង ។ បុរសកម្សត់នោះបានស្តាប់ពាក្យនោះហើយ ក៏បានធ្វើតាមពាក្យណែនាំទាំងនោះ ប៉ុន្តែគេមានការស្រេកឃ្លានយ៉ាងខ្លាំង ព្រោះគេធ្វើការងារពេញមួយថ្ងៃ ដោយការអត់អាហារនោះ ក៏បណ្តាលឲ្យកើតខ្យល់ចាប់ ធ្វើឲ្យរាងកាយរបស់គេញ័រខ្លួត ដូច្នេះគេយកខ្សែមកចងរឹតពោះ ចាប់ចុងខ្សែដេកបម្រះទៅមក ។ អនាថបិណ្ឌិកសេដ្ឋី បានឮសំឡេងនោះហើយ ទើបឲ្យគេកាន់គប់ភ្លើង ហើយឲ្យយករបស់មានរស ៤ យ៉ាង រួចទៅកាន់កន្លែងនៅរបស់បុរសកម្សត់នោះ លុះទៅដល់ហើយ បានសួរថា យ៉ាងណាហើយលោក ? បុរសកម្សត់នោះឆ្លើយថា លោកសេដ្ឋី ខ្យល់បានកើតឡើងពេញពងកាយរបស់ខ្ញុំខ្លាំងណាស់ ។ អនាថបិណ្ឌិកសេដ្ឋីប្រាប់ថា បើដូច្នោះ អ្នកចូរក្រោកឡើង ទទួលអាហារនេះចុះ ។ បុរសកម្សត់សួរថា លោកសេដ្ឋី លោកទទួលទានហើយឬនៅ ? អនាថបិណ្ឌិកសេដ្ឋី

ពោលតបថា នែអ្នក ពួកយើងមិនបានឈឺអ្វីឡើយ អ្នកចូរបរិភោគអាហារនេះចុះ ។ បុរសកម្សត់ពោលដល់ការតាំងចិត្តថា លោកសេដ្ឋី ខ្ញុំបានសមាទានឧបោសថសីល តែពាក់កណ្តាលថ្ងៃ ដូច្នេះ សូមឲ្យឧបោសថសីលដែលបានសមាទានរួចមកហើយនេះ របស់ខ្ញុំម្ចាស់ កុំឲ្យជាច់ពពាលឡើយ គេពោលដូច្នេះហើយៗ គេក៏មិនបរិភោគនូវអាហារនោះឡើយ ។ សូម្បីអនាថបិណ្ឌិកសេដ្ឋី ក៏និយាយអង្វរថា ចូរអ្នកកុំធ្វើយ៉ាងហ្នឹងឡើយ ។

បុរសនោះក៏មិនព្រមធ្វើតាមពាក្យអង្វរបស់អនាថបិណ្ឌិកសេដ្ឋី ដោយការអត់អាហារដូច្នេះមួយថ្ងៃ លុះដល់ពេលអរុណរះឡើង បុរសនោះក៏ស្លាប់ទៅ ប្រៀបដូចផ្កាឈើដែលក្រៀមស្វិតដូច្នោះ ហើយគេបានទៅកើតជាទេវតា នៅនឹងដើមជ្រៃមួយដើម ទេវតានោះ បានពោលពណ៌នាគុណរបស់អនាថបិណ្ឌិកសេដ្ឋីថា លោកសេដ្ឋីជាអ្នករាប់អានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ក្នុងរឿងបុរសអ្នកស៊ីឈ្នួល បានទៅកើតជាទេវតា ព្រោះបានឃើញគុំរូដ៏ល្អ របស់អនាថបិណ្ឌិកសេដ្ឋី និងបរិវារ

របស់លោកសេដ្ឋីគ្រប់គ្នា សុទ្ធតែជាអ្នកតាំងចិត្តក្នុងការសមាទានរក្សានូវឧបោសថសីលជូចគ្នាទាំងអស់ ទើបជាហេតុធ្វើឲ្យបុរសកម្សត់នោះតាំងចេតនាក្នុងការសមាទានឧបោសថសីលនោះដែរ សូម្បីនៅសល់ពេលវេលាត្រឹមតែកន្លះថ្ងៃប៉ុណ្ណោះ តែអានិសង្សរបស់ឧបោសថ ដែលគេតាំងចិត្តរក្សា ក៏ឲ្យផលដល់អ្នករក្សាជាច្រើនដែរ ។

រឿងមិនទៀងទាត់នៃជីវិតដោយទូទៅ ត្រូវគ្នានឹងពាក្យពោលថា មានហើយត្រឡប់ជាមិនមាន មិនមានត្រឡប់ជាមាន ឬរបស់នេះមានទើបរបស់នោះមាន ហេតុការណ៍បែបនេះ ក៏បានកើតមានដល់អនាថបិណ្ឌិកសេដ្ឋី ដែលជាព្រះសោតាបន្នដូចគ្នា ដែលមានរឿងពោលទុកនៅក្នុង **គម្ពីរធម្មបទ** នៃ **ចាបវគ្គ** និងក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីចាលីក្នុង **ទទិវង្កជាតក** នៅក្នុង **គម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះមានជោគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ព្រះអង្គបានត្រាស់ធម្មទេសនា ប្រោរព្ធចំពោះអនាថបិណ្ឌិកសេដ្ឋី ដែល

មានសេចក្តីជ្រះថ្លា បរិច្ចាគទ្រព្យសម្បត្តិ រហូតដល់អស់ ៥៤ កោដិ កហាបណៈ សម្រាប់កសាងវត្តជេតពន និងធ្វើបុណ្យឆ្លងវត្តជេតពន ក្នុងព្រះសាសនានេះ ។ ប្រក្រតីរបស់អនាថបិណ្ឌិកសេដ្ឋី តែងតែទៅកាន់វត្តមួយថ្ងៃ ៣លើក រៀងរាល់ថ្ងៃ មុនពេលដែលលោកសេដ្ឋីទៅកាន់វត្ត លោកបានពិចារណាថា កិកុក្តី សាមណេរក្តី តែងតែមើលដៃរបស់យើង ដោយគិតថា តើលោកសេដ្ឋីបានកាន់យកអ្វីមកខ្លះហ្ន៎! ដោយលោកសេដ្ឋីគិតដល់កិកុ និងសាមណេរ ដូច្នេះហើយ ពេលដែលលោកទៅកាន់វត្ត ដៃរបស់លោកមិនទៅដោយទទេទេ តែងតែកាន់របស់អ្វីទៅជាមួយ ។ ពេលដែលលោកសេដ្ឋីទៅក្នុងពេលព្រឹក ក៏បានឲ្យមនុស្សកាន់បបរទៅជាមួយ បន្ទាប់ពីបរិភោគអាហារព្រឹកហើយ វេលានឹងទៅកាន់វត្ត បានឲ្យគេកាន់យកកេសជ្ជៈទាំងឡាយ មានទឹកដោះថ្លា ទឹកដោះខាប់ ប្រេង លាប និងក្រណាត់ជាដើម លោកសេដ្ឋីបានថ្វាយទាន រក្សាសីល ដោយធ្វើយ៉ាងនេះជារៀងរាល់ថ្ងៃ អស់កាលជានិច្ចនិរន្តន៍ ។ តែពេលក្រោយមក អនាថបិណ្ឌិកសេដ្ឋី បានដល់នូវការអស់ទ្រព្យ ទាំងត្រូវអ្នករកស៊ីខូចខ្ជី

ប្រាក់របស់លោក ១៨ កោដិកហាបណៈមិនសង និងប្រាក់ ១៨ កោដិកហាបណៈដែលកប់ទុកជិតមាត់ទន្លេ ត្រូវទឹកទន្លេជន់លិចហូរកួចយកទៅអស់ ទ្រព្យរបស់លោកសេដ្ឋី ត្រូវបានវិនាសហិនហោចទៅជាលំដាប់ដូចដែលបានពោលរួចមកហើយ រហូតធ្វើឲ្យអនាថបិណ្ឌិកសេដ្ឋីធ្លាក់ខ្ជិនក្លាយជាអ្នកក្រីក្រលំបាក ។

លោកសេដ្ឋី សូម្បីជាអ្នកខ្សត់ទ្រព្យសម្បត្តិ គ្មានអ្វីចំណាយក៏នៅតែតាំងចិត្តថ្វាយទានដល់ភិក្ខុសង្ឃជារឿយៗ តទៅទៀត តែមិនអាចថ្វាយទានទូវរបស់ដែលប្រណីតៗ បាន ។ ថ្ងៃមួយ ព្រះមានជោគត្រាស់សួរថា ម្នាលគហបតី អ្នកមានការឲ្យទូវទានជាប្រចាំឬ ? លោកសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូលរបស់ខ្ញុំព្រះអង្គនៅតែធ្វើជារឿយៗ ដដែល តែទាននោះមិនសូវប្រណីតទេ ព្រះអង្គដោយបាយកញ្ចុងអង្ករជាមួយនឹងទឹកជ្រក់ជាគម្រប់ពីរ ព្រះអង្គ ។ គ្រានោះព្រះកគវាត្រាស់នឹងអនាថបិណ្ឌិកសេដ្ឋីថា ម្នាលគហបតី អ្នកកុំគិតថាយើងថ្វាយទានដែលសៅហ្មង ព្រោះថា បើចិត្តប្រណីតហើយ ទានដែល

បុគ្គលថ្វាយដល់ព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម រមែងមិនឈ្មោះថាជាទានសៅហ្មងទេ ។ម្នាលគហបតី ប្រការមួយទៀត អ្នកបានថ្វាយទានដល់ព្រះអរិយបុគ្គល ទាំង ៨ ពួកហើយ ។ ចំណែកតថាគតកាលនៅជាវេលាមព្រាហ្មណ៍ បានឲ្យអ្នកស្រុក ឬអ្នកជម្ពូទ្វីបទាំងអស់ឲ្យផ្នាកធ្វើស្រែ ដើម្បីថ្វាយមហាទានដល់ពួកគេ ពេលនោះ សូម្បីទក្ខិណេយ្យបុគ្គលប្រកេទណានីមួយក៏ដោយ ដែលជាអ្នកដល់នូវព្រះរតនត្រ័យ រមែងមិនមាន ទក្ខិណេយ្យបុគ្គលទាំងឡាយ រកបានដោយកម្រណាស់ កាលបើបុគ្គលរកបានយ៉ាងនេះ ព្រោះហេតុនោះ អ្នកកុំគិតឡើយថា ទានរបស់អ្នកសៅហ្មងឲ្យសោះ ។

ព្រះលោកនាយក ទ្រង់ព្រះករុណាត្រាស់ទេសនាប្រោសដល់អនាថបិណ្ឌិកសេដ្ឋី ដោយត្រាស់ **វេលាមសូត្រ** ដែលមានរឿងពោលទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ នវកនិបាត** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះមានជោគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនក្បែរក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានចូលទៅគាល់

ព្រះសម្មាសម្ពុទ្ធ ថ្វាយបង្គំហើយ អង្គុយចុះក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះមានជោគ ទ្រង់ត្រាស់សួរថា ម្នាលគហបតី ត្រកូលរបស់លោក នៅតែថ្វាយទានជាប្រក្រតីឬ ? អនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា នៅតែឲ្យទានដដែល ព្រះអង្គ តែថា ទាននោះ ជារបស់សៅហ្មង ដោយមានបាយកញ្ចង់អង្គរជាមួយនឹងទឹកជ្រក់ ជាគម្រប់ពីរប៉ុណ្ណោះ ព្រះអង្គ ។ ពេលនោះ ទើបព្រះលោកនាថត្រាស់ទូន្មានថា ម្នាលគហបតី បុគ្គលសូម្បីឲ្យរបស់ដែលសៅហ្មង ឬរបស់ប្រណីតក៏ដោយ បើឲ្យទានដោយការមិនគោរព ឲ្យទានដោយមិនកោតក្រែង មិនបានឲ្យទានដោយដៃរបស់ខ្លួនឯង ឲ្យទានដូចបោះចោល ឲ្យទានដោយមិនជឿនូវផលរបស់ទាន ពេលអ្នកនោះកើតក្នុងទីណាៗ ក៏មិនបង្អោនចិត្តទៅដើម្បីនឹងបរិភោគអាហារដែលល្អ ឬប្រណីត មិនដើម្បីនឹងប្រើប្រាស់គ្រឿងស្លៀកដណ្តប់ដែលល្អ មិនដើម្បីនឹងប្រើប្រាស់យានដែលល្អ ជាពិសេសនោះ សូម្បីបុត្រ និងភរិយា ឬបាវព្រៅក៏មិនជឿស្តាប់ពាក្យសម្តី ប្រការនេះព្រោះហេតុអ្វី ព្រោះហេតុថា សេចក្តីនោះជាផលនៃទាន ដែលគេឲ្យដោយ

ការមិនគោរព ។បុគ្គលដែលឲ្យទានទូវបស់ដែលអន់ ឬបស់ប្រណីត ក៏ដោយ ប្រសិនបើឲ្យដោយការគោរព ឲ្យដោយការរាប់អាន ឲ្យដោយដៃរបស់ខ្លួនឯង ឲ្យមិនដូចជារបស់ចោះចោល ឲ្យដោយការជឿផលនៃទាន ពេលអ្នកនោះកើតក្នុងទីណាៗ គេក៏មានចិត្តបង្អោនទៅដើម្បីបរិភោគអាហារដែលល្អ និងស្លៀកដណ្តប់របស់ដែលល្អៗ សូម្បីប្រើប្រាស់យានក៏ជារបស់ល្អ ទាំងបុត្រ និងភរិយា ឬជាវ្រាវតែងតែជឿស្តាប់ពាក្យសម្តី សេចក្តីនោះព្រោះហេតុអ្វី ព្រោះហេតុថា នុ៎ះជាផលនៃទាន ដែលគេថ្វាយដោយសេចក្តីគោរព ។

ម្នាលគហបតី កាលមុនមានព្រាហ្មណ៍ម្នាក់ ឈ្មោះថា វេលាម-ព្រាហ្មណ៍ៗ បានឲ្យមហាទានប្រព្រឹត្តទៅដូច្នេះ គឺបានឲ្យថាសមាស ដែលជាក់ប្រាក់ពេញ ๘ ម៉ឺន ๔ ពាន់ថាស បានឲ្យថាសប្រាក់ ដែលជាក់មាសពេញ ๘ ម៉ឺន ๔ ពាន់ថាស បានឲ្យថាសសំរឹទ្ធ ដែលជាក់មាស ๘ ម៉ឺន ๔ ពាន់ថាស បានឲ្យដំរី ๘ ម៉ឺន ๔ ពាន់ក្បាល ដែលជាដំរីប្រដាប់ដោយគ្រឿងមាស មានទង់មាសគ្របដណ្តប់ ដោយសំណាញ់

មាស បានឲ្យវេច ៨ ម៉ឺន ៤ ពាន់គ្រឿង ពាសដោយស្បែករាជសីហ៍ ស្បែកខ្លាធំ ស្បែកខ្លាដំបង សំពត់កម្ពលពណ៌លឿង ប្រដាប់ដោយគ្រឿងមាស បានដល់ទង់មាស ស្រោបដោយមាស បានឲ្យមេគោជំទង់ ៨ ម៉ឺន ៤ ពាន់ក្បាល ជាមួយនឹងថាសសីរីទ្ធ សម្រាប់ត្រង់ទឹកដោះគោ បានឲ្យស្រីក្រមុំ ៨ ម៉ឺន ៤ ពាន់នាក់ ម្នាក់ៗ សុទ្ធតែប្រដាប់ដោយកែវមុក្តា កែវមណី កណ្ឌល បានឲ្យបល្ល័ង្ក ៨ ម៉ឺន ៤ ពាន់ ក្រាលដោយសំពត់រោមសត្វ ដែលមានរោមវែងៗ ដែលធ្វើដោយរោមសត្វចៀម ធ្វើក្បាច់ដូចផ្កាឈើលាត ដោយសំពត់ស្បែកសត្វ មានសម្ផស្សយ៉ាងទន់ នៅខាងលើធ្វើជាពិតាន មានខ្នើយឱប ខ្នើយកល់ជើង បានឲ្យសំពត់ ៨ ម៉ឺន ៤ ពាន់ដុំ មានសំពត់សំបកក្រចៅ សំពត់សំបកឆ្មៃ សំពត់សរសៃអំបោះយ៉ាងល្អ ចំណែកបាយ ទឹក បង្អែម ចម្អាប គ្រឿងលាបទីជេក ទីស្នាក់អាស្រ័យ មិនចាំបាច់និយាយដល់ ព្រោះថា មានច្រើនប្រៀបដូចនឹងទឹកទន្លេ ដែលហូរជន់ ។ ម្នាលគហបតី អ្នកកុំនឹកថា វេលាមព្រាហ្មណ៍ ដែលបានឲ្យមហាទានក្នុងកាលនោះ ជាអ្នកដទៃ

ការពិតតថាគតនេះឯង ជាវេលាមព្រាហ្មណ៍ ក្នុងកាលនោះ តថាគតបានឲ្យមហាទាន ដូចដែលបានពោលរួចមកហើយនេះ តែថា ការឲ្យមហាទានក្នុងគ្រានោះ មិនមានអ្នកគួរដល់ទក្ខិណាទានឡើយ មិនមានអ្នកណាធ្វើឲ្យទក្ខិណាទាន (ទានដែលធ្វើឲ្យមានផលច្រើន) ឲ្យបរិសុទ្ធ ។ ម្នាលគហបតី បុគ្គលណាឲ្យទានដល់អ្នកដែលបរិបូណ៌ដោយទស្សនៈ គឺឲ្យដល់ព្រះសោតាបន្នត្រឹមតែមួយរូបត្រឹមតែម្តងការឲ្យទានត្រឹមតែម្តងចំពោះព្រះសោតាបន្ននោះ តែមួយរូបនោះ រមែងមានផលច្រើនជាងមហាទាន ដែលវេលាមព្រាហ្មណ៍ ឲ្យនោះទៅទៀត ។

បុគ្គលណាឲ្យទានដល់ **ព្រះសោតាបន្ន ១០០ រូប** ការឲ្យទានដល់ **ព្រះសកទាគាមី** ត្រឹមតែមួយរូប មានផលច្រើនជាងការឲ្យទានដល់ **ព្រះសោតាបន្ន ១០០ រូប** ។ បុគ្គលឲ្យទានដល់ **ព្រះសកទាគាមី ១០០ រូប** មានផលតិចជាងការឲ្យទានដល់ **ព្រះអនាគាមីមួយរូប** ។ បុគ្គលឲ្យទានដល់ **ព្រះអនាគាមី ១០០ រូប** មានផលតិចជាងការឲ្យទានដល់ **ព្រះអរហន្តមួយរូប** ។ បុគ្គលថ្វាយទានដល់ **ព្រះបច្ចេកពុទ្ធ ១០០ រូប**

មានផលតិចជាងការថ្វាយទានដល់ **ព្រះសម្មាសម្ពុទ្ធ** ។ បុគ្គលថ្វាយទានដល់ **ព្រះអរហន្តសម្មាសម្ពុទ្ធ** មានផលតិចជាងការឲ្យទានដល់ **ព្រះសង្ឃ** ដែលមានព្រះពុទ្ធជាប្រធាន ។ បុគ្គលឲ្យទានដល់ **ព្រះសង្ឃ** មានព្រះពុទ្ធជាប្រធាន មានផលតិចជាងការកសាងវិហារថ្វាយដល់កិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ ។ បុគ្គលកាលកសាងវិហារថ្វាយដល់ **ព្រះសង្ឃ** ដែលមកអំពីទិសទាំង ៤ នៅមានផលតិចជាង ដែលមានចិត្តជ្រះថ្លាគោរពរាប់អានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ជាទីឰក ដែលហៅថា ការដល់ **ព្រះត្រៃសរណាគមន៍** ។ ការដល់ត្រៃសរណាគមន៍តែម្យ៉ាង នៅមានផលតិចជាង ការដល់ត្រៃសរណាគមន៍ ហើយជាអ្នកដល់ព្រមដោយការសមាទានសីល ៥ ផង ។ ការដល់ត្រៃសរណាគមន៍ព្រមដោយ**សីល ៥**ហើយនោះនៅមានផលតិចជាងការអប់រំ**មេត្តាចិត្ត** គឺចិត្តមានមេត្តាត្រឹមតែមួយខណៈនៃការហិតក្លិនក្រអូប ។ ការចម្រើន**អនិច្ចសញ្ញា** គឺការសម្គាល់ថា មិនទៀងត្រឹមតែមួយផ្ចាត់ក្រចក មានផលច្រើនជាងការអប់រំមេត្តាចិត្តទៅទៀត ។

នៅមានរឿងរបស់អនាថបិណ្ឌិកសេដ្ឋី ដែលបានពោលទុកក្នុង **អដ្ឋកថាធម្មបទ** នៃ **បាបវគ្គ** និងក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលី **ទសិវង្សារជាតក** ក្នុង **គម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្តីថា ៖-

អនាថបិណ្ឌិកសេដ្ឋី សូម្បីធ្លាក់ខ្លួនក្រខ្សត់ តែក្នុងផ្ទះរបស់លោកនៅមានការថ្វាយទានដល់ភិក្ខុសង្ឃប្រមាណ ៥០០ រូបជារៀងរាល់ថ្ងៃ មានពាក្យប្រៀបធៀបថា រឿងរបស់អនាថបិណ្ឌិកសេដ្ឋី ដូចគ្នានឹងស្រះបោក្ខរណី គឺស្រះដែលជីកទុកនៅត្រង់ផ្លូវបែកជា ៤ សម្រាប់ភិក្ខុសង្ឃតាំងនៅក្នុងឋានៈប្រហែលគ្នានឹងមាតាបិតា របស់ភិក្ខុសង្ឃទាំងឡាយទូទៅ ។ ព្រោះហេតុនោះ ព្រះមានជោគ ស្តេចយាងទៅកាន់គេហដ្ឋានរបស់អនាថបិណ្ឌិកសេដ្ឋី ព្រមទាំងព្រះអសីតិមហាសាវក ៨០ រូប ក៏និមន្តទៅជាមួយដែរ ។ ចំណែកភិក្ខុក្រៅពីនោះ ក៏បាននិមន្តទៅមកៗមិនមានកំណត់ចំនួនថាប៉ុន្មានទេ ។ ផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី មាន ៧ ជាន់ មានទ្វារ ៧ នៅទ្វារទី ៤ នៃផ្ទះនោះ មានទេវតា ដែលជា

មិច្ឆាទិដ្ឋិមួយអង្គអាស្រ័យនៅ ។ ទេវតានោះ កាលព្រះមានព្រះភាគ
ស្តេចយាងចូលទៅក្នុងផ្ទះ និងស្តេចយាងចេញមកវិញ រមែងមិនអាច
នៅក្នុងវិមានរបស់ខ្លួនបាន ចាំបាច់ត្រូវនាំកូនទាំងឡាយចុះមក ពីវិមាន
របស់ខ្លួនទៅខាងក្រោម ឬសូម្បីពេលដែលព្រះអសីតិមហាសាវក ៨០
រូប ចូលទៅក្នុងផ្ទះ និងចេញមកវិញ ទេវតានោះក៏ត្រូវធ្វើដូច្នោះដែរ ។
កាលទេវតានោះ បានទទួលការលំបាកយ៉ាងនេះហើយ ទើបគិតថា
កាលព្រះសមណគោតម និងមហាសាវកនិមន្តចូលទៅក្នុងផ្ទះ របស់
អនាថបិណ្ឌិកសេដ្ឋីនេះ យើងមិនមានសេចក្តីសុខឡើយ ព្រោះយើង
មិនអាចចុះទៅមកជារឿយៗ អស់កាលជានិច្ចយ៉ាងនេះបានទេ ហេតុនេះ
យើងគួរនឹងធ្វើឲ្យភិក្ខុសង្ឃទាំងឡាយនោះ ចូលមកក្នុងផ្ទះនេះមិនបាន ។
ក្រោយមក ថ្ងៃមួយ ទេវតានោះក៏បានទៅរកបុរសម្នាក់ ដែលជាមេការ
របស់លោកសេដ្ឋី ដែលនៅពេលនោះ បុរសនោះកំពុងតែរៀបចំចូល
ដេកហើយ ទេវតានោះក៏បានបញ្ចេញពន្លឺឲ្យប្រាកដជាប់មេការ ។ បុរស
ដែលជាមេការនោះស្រែកសួរថា នរណាគេហ្នឹង ? ទេវតាឆ្លើយថា ខ្ញុំ

ជាទេវតានៅទីឆ័ត្រទី ៤ របស់លោកសេដ្ឋី បុរសនោះសួរទៀតថា អ្នកមកទីនេះមានការអ្វី ? ទេវតាឆ្លើយថា អ្នកជ័ចម្រើន អ្នកមិនបានពិចារណាមើលការធ្វើរបស់លោកសេដ្ឋីទេឬ ព្រោះលោកសេដ្ឋី គិតតែលះបង់ទ្រព្យសម្បត្តិទំនុកបម្រុងព្រះសមណាគោតម ដោយមិនទៅប្រកបការជួញដូរ និងមិនធ្វើការងារអ្វីឡើយ ហេតុដូច្នេះ ទើបធ្វើឲ្យលោកសេដ្ឋីក្រលំបាក ចូរលោកប្រាប់រឿងដល់អនាថបិណ្ឌិកសេដ្ឋីឲ្យប្រកបកិច្ចការងារនោះដូចដើមវិញទៅ ហើយកុំឲ្យព្រះសមណាគោតមនិងសាវ័កចូលមកក្នុងផ្ទះនេះទៀត ។ បុរសដែលជាមេការ ក៏ពោលនឹងទេវតាថា **នែទេវតាពាល** លោកសេដ្ឋីដែលលះបង់ទ្រព្យសម្បត្តិធ្វើយ៉ាងនោះ គឺការទំនុកបម្រុងព្រះសាសនានេះ ក៏ជាផ្លូវប្រព្រឹត្តទៅដើម្បីរួចផុតចាកទុក្ខ សូម្បីលោកសេដ្ឋីយកខ្ញុំទៅលក់ ដូចជាទំនិញក៏ខ្ញុំមិនថាអ្វីនឹងលោកសេដ្ឋីដែរ តែទេវតាពាលឯង ចូរចេញពីទីនេះទៅកុំនិយាយរឿងនេះនឹងយើងឡើយ ។ ថ្ងៃបន្ទាប់តមក ទេវតានោះ កាលនិយាយជាមួយនឹងមេការនោះមិនបានសម្រេច ក៏ចូលទៅរកកូនច្បង

របស់អនាថបិណ្ឌិកសេដ្ឋី ហើយបាននោលណែនាំហេតុផលតែមួយ ដូចដែលបាននោលជាមួយនឹងមេការនោះ ។

កូនប្រុសច្បងរបស់លោកសេដ្ឋី បានស្តាប់ពាក្យនិយាយច្រាប់ របស់ទេវតានោះហើយ ក៏ជ្រាបអធ្យាស្រ័យរបស់ទេវតានោះថា នេះជាទេវតាមិច្ឆាទិដ្ឋិ គេបាននិយាយបណ្តេញទេវតានោះទៅ ដូចបុរស ដែលជាមេការបណ្តេញដែរ ។ ទេវតាកាលមិនអាចនិយាយញុះញង់ ឲ្យបុគ្គលទាំងពីរនាក់នោះជឿបានហើយ ក៏រង់ចាំរកមើលឱកាសដើម្បី ទៅនិយាយជាមួយនឹងលោកសេដ្ឋី តែក្នុងពេលដែលលោកសេដ្ឋីនៅ មានទ្រព្យជាឥស្សរៈ ទេវតាក៏មិនហ៊ាននិយាយ លុះដល់ពេលលោក សេដ្ឋីក្រខ្សត់ ទេវតាយល់ថា លោកសេដ្ឋីក្រខ្សត់ហើយ គង់នឹងជឿពាក្យ របស់យើង ទើបចូលទៅចន្ទប់ដ៏មានសិរីរបស់លោកសេដ្ឋី នៅក្នុងពេល ពាក់កណ្តាលយប់ ដោយទេវតាស្ថិតនៅលើអាកាស ហើយបញ្ចេញរស្មី ឲ្យលោកសេដ្ឋីបានឃើញ ។ លោកសេដ្ឋីឃើញរស្មីនោះ ក៏សួរថា នរណាគេហ្នឹង ? ទេវតាឆ្លើយថា លោកសេដ្ឋី ខ្ញុំជាទេវតាដែលអាស្រ័យ

នៅទីឆ័ស៊ុមទ្វារទី ៤ របស់លោក ។ លោកសេដ្ឋីសួរថា អ្នកមករកខ្ញុំមានការអ្វី ? ទេវតាឆ្លើយថា ខ្ញុំមកនេះដើម្បីជាសំតៀនលោក ។ លោកសេដ្ឋីពោលថា បើយ៉ាងនោះ ចូរលោកនិយាយមកចុះ ។ ទេវតាពោលថា លោកសេដ្ឋី លោកមិនបានមើលក្នុងកាលជាខាងក្រោយឡើយ លោកមិនគិតដល់បុត្រធីតារបស់លោក ដោយលោកបានចំណាយទ្រព្យសម្បត្តិជាច្រើននៅក្នុងព្រះសាសនា របស់ព្រះសមណគោតម ដោយលោកអាស្រ័យព្រះសមណគោតម ទើបធ្វើឲ្យលោកធ្លាក់ខ្លួនក្រខ្សត់ ព្រោះហេតុដែលលោកចំណាយទ្រព្យសម្បត្តិ ច្រើនហួសពេក ដោយលោកមិនបានទៅធ្វើការលក់ដូរ និងការងារដទៃទៀត ហេតុដូច្នេះ ឥឡូវនេះ ទើបលោកជាអ្នកក្រលំបាក លោកជាអ្នកក្រលំបាកហើយ ក៏នៅតែលះបង់ទ្រព្យសម្បត្តិធ្វើជាទានទៀត រាល់ថ្ងៃនេះ សមណៈទាំងនោះ នាំគ្នាចូលមកផ្ទះរបស់លោក ទ្រព្យដែលសមណៈទាំងនោះនាំទៅហើយ មិនអាចនាំត្រឡប់មកវិញបាន បើលោកនៅតែធ្វើយ៉ាងនេះតទៅទៀត លោកនឹងមិនមានសូម្បីតែអាហារ និងគ្រឿងស្លៀកដណ្តប់នៅពីរបីថ្ងៃទៀតនេះ

យ៉ាងពិតប្រាកដ ចាប់ពីថ្ងៃនេះតទៅ លោកកុំទៅកាន់សម្នាក់ព្រះសមណ-គោតមទៀតឡើយ ហើយកុំឲ្យសាវ័កទាំងឡាយរបស់ព្រះសមណគោតមចូលមកកាន់ផ្ទះរបស់លោកទៀត លោកចូរលើកការបរិច្ចាគទានដែលលើសកម្លាំងចេញ ហើយចូរប្រកបកិច្ចការងារលក់ដូរ ដូចដើមវិញចុះ ។

លោកសេដ្ឋីសួរថា នេះជាពាក្យជាស់តឿនដែលលោកចង់ប្រាប់ដល់ខ្ញុំឬ ? ទេវតាតបថា ត្រូវហើយលោកសេដ្ឋី ពាក្យនេះឯង ។ អនាថបិណ្ឌិកសេដ្ឋី បាននិយាយបណ្តេញទេវតាថា អ្នកចូរចេញទៅ ខ្ញុំមិនត្រូវការបុគ្គលដូចជាអ្នកទេ សូម្បីមានចំនួនទាំងរយ ទាំងពាន់ ទាំងសែននាក់ក៏ដោយ ក៏មិនអាចធ្វើឲ្យខ្ញុំញាប់ញ័របាន លោកនិយាយពាក្យដែលមិនសមគួរពោល លោកជាអ្នកគ្មានអាចារៈ (មារយាទល្អ) ជាអ្នកគ្មានសីល និងជាកាឡកណ្ណី ដូច្នេះ មិនឃើញមានប្រយោជន៍អ្វីឡើយ ដែលលោកនៅនឹងផ្ទះនេះ ដូច្នេះ ចូរលោកចេញអំពីផ្ទះរបស់ខ្ញុំទៅឲ្យឆាប់ភ្លាម ។ ទេវតាបានស្តាប់ពាក្យបណ្តាញរបស់អនាថបិណ្ឌិក-សេដ្ឋី ដែលជាព្រះសោតាបន្នអរិយសាវ័កហើយ ក៏មិនអាចនឹងនៅលើស៊ុម

ទ្វារតទៅទៀតដូចមុនបាន ទើបនាំកូនទាំងអស់ចេញទៅ ហើយកាលទេវតានោះចេញពីស៊ុមទ្វារបស់លោកសេដ្ឋីហើយ ក៏ទៅរកកន្លែងដទៃទៀតមិនបាន ទើបគិតថា យើងនឹងសូមឲ្យលោកសេដ្ឋីអត់ទោសឲ្យហើយនឹងសូមនៅកន្លែងដើមវិញ ហើយក៏បានចូលទៅរកទេវតា ដែលរក្សាព្រះនគរ សារភាពទោសកំហុសដែលខ្លួនបានធ្វើហើយ ហើយយាំអង្វរទេវតានោះថា សូមលោកជួយជូនខ្ញុំទៅកាន់សម្នាក់របស់លោកសេដ្ឋីដើម្បីសុំឲ្យលោកសេដ្ឋីអត់ទោស ដែលខ្ញុំបានធ្វើហើយៗ ឲ្យខ្ញុំបាននៅត្រង់ស៊ុមទ្វារនោះដូចដើមវិញ ។

ទេវតានោះពោលថា លោកពោលពាក្យនេះមិនសមគួរ ខ្ញុំមិនអាចហ៊ានជូនលោកទៅជួបលោកសេដ្ឋីទេ ។ ទេវតានោះ កាលអស់សង្ឃឹម ក៏ចេញអំពីទេវតានោះ ទៅកាន់សម្នាក់របស់មហារាជទាំង ៤ ក៏ត្រូវមហារាជទាំង ៤ នោះបដិសេធដូចគ្នា ក្រោយមក ទើបទេវតានោះចូលទៅគាល់សក្កទេវរាជ ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ហើយក្រាបទូលអង្វរយ៉ាងគួរឲ្យអាណិតថា បពិត្រមហារាជ ខ្ញុំព្រះអង្គមិនមាន

ទីអាស្រ័យទេ ត្រូវនាំកូនដើរផ្សងព្រេងរកទីស្នាក់អាស្រ័យ ក៏រកមិនបាន
ហេតុដូច្នេះ សូមមហាវាជមេត្តាប្រោសជល់ខ្ញុំ ឲ្យលោកសេដ្ឋីអត់ទោស
ឲ្យទីអាស្រ័យនោះដល់ខ្ញុំព្រះអង្គវិញផង ។ សក្កទេវរាជត្រាស់ជាមួយ
ទេវតានោះថា សូម្បីយើងក៏មិនហ៊ាននិយាយជាមួយនឹងលោកសេដ្ឋីនោះ
ដែរ ព្រោះហេតុតែអ្នកពោលពាក្យមិនសមគួរនោះ តែយើងនឹងប្រាប់
ឧបាយដល់អ្នកមួយ ។ ទេវតាក្រាបទូលថា ល្អហើយ មហាបពិត្រ
សូមព្រះអង្គករុណាប្រាប់ឧបាយនោះមកចុះ ។ សក្កទេវរាជប្រាប់ឧបាយ
វិធីថា អ្នកចូរត្រឡប់ទៅហើយ ចូរក្លែងធ្វើជាស្មៀនរបស់លោកសេដ្ឋី
ឲ្យគេនាំយកបញ្ជីខ្ចីប្រាក់ ពីដៃរបស់លោកសេដ្ឋីមក ហើយដោយឲ្យ
អ្នកជំពាក់បំណុល ឲ្យគេសងប្រាក់ ១៨ កោដិកហាបណៈ ដែលពួកគេ
បានខ្ចីដោយអានុភាពរបស់ខ្លួនហើយ នាំយកមកទុកជាក់ក្នុងឃ្លាំងឲ្យពេញ
មួយទៀត ទ្រព្យ ១៨ កោដិកហាបណៈ ដែលហូរទៅកាន់មហាសមុទ្រនោះ
និងទ្រព្យដទៃទៀត ដែលគ្មានម្ចាស់ មាននៅក្នុងទីនោះ ចូរលោកប្រមូល
ទ្រព្យទាំងនោះ យកមកទុកជាក់នៅក្នុងឃ្លាំងរបស់លោកសេដ្ឋី កាលបើ

អ្នកធ្វើយ៉ាងនេះរួចហើយ ចូរលោកទៅសុំទោសចំពោះលោកសេដ្ឋីចុះ ។ ទេវតាក្រាបទូលថា ព្រះករុណាមហាបពិត្រ ហើយក៏បានធ្វើតាមគ្រប់យ៉ាង ដែលសក្កទេវរាជបានប្រាប់រួចស្រេចហើយ បានទៅកាន់បន្ទប់ដ៏មានសិរីរបស់អនាថបិណ្ឌិកសេដ្ឋី ដោយធ្វើឲ្យមានពន្លឺប្រាកដឡើង ខ្លួនឯងក៏ស្ថិតនៅលើអាកាស ពេលនោះ អនាថបិណ្ឌិកសេដ្ឋី បានឃើញហើយ លោកសួរថា នរណាគេហ្នឹង ? ទេវតាតបថា ខ្ញុំជាទេវតា **អន្ធពាល** ដែលអាស្រ័យនៅស៊ុមទ្វារទី ៤ របស់លោកសេដ្ឋី ពាក្យដែលខ្ញុំពោលហើយចំពោះលោក គឺដោយសេចក្តីល្ងង់ខ្លៅ ហេតុដូច្នេះ សូមលោកអត់ទូវាទោសនោះ ដល់ខ្ញុំផងចុះ ព្រោះខ្ញុំបានទទួលទោសនោះហើយ ដោយខ្ញុំទៅប្រមូលទ្រព្យ ៥៤ កោដិកហាបណៈ មកដាក់ឲ្យពេញក្នុងឃ្លាំងរបស់លោកហើយ តាមបញ្ជារបស់សក្កទេវរាជ ខ្ញុំកាលមិនបានទីអាស្រ័យនៅត្រង់ស៊ុមទ្វាររបស់លោកទេ រមែងជួបការលំបាក ឬមិនមានកន្លែងនៅ ។

លោកសេដ្ឋីគិតថា ទេវតានេះពោលថា **ទណ្ឌកម្ម** គឺការដាក់ទោស

របស់ខ្ញុំបានធ្វើហើយ ចាត់ថា ជាអ្នកក្រាក់រឭកដីធ្លនូវកំហុសរបស់ខ្លួន យើងនឹងនាំទេវតានេះទៅគាល់ព្រះសម្ពុទ្ធ លោកសេដ្ឋីគិតដូច្នេះហើយ ទើបនាំទេវតានោះទៅកាន់សម្នាក់ព្រះមានបុណ្យ ហើយក្រាបទូលកម្ម ដែលទេវតា បានធ្វើហើយទាំងអស់ថ្វាយព្រះអង្គឲ្យទ្រង់បានជ្រាប ។ ចំណែកទេវតា បានថ្វាយបង្គំទៀបព្រះបាទមូលរបស់ព្រះជិនស្រីហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនដឹងនូវគុណទាំងឡាយ របស់ព្រះអង្គ បានពោលពាក្យអាក្រក់ ព្រោះកាពជាបុគ្គលល្ងង់ខ្លៅ ហេតុដូច្នេះ សូមព្រះអង្គអត់ទោសដល់ខ្ញុំព្រះអង្គ ដែលបានពោលពាក្យ មិនសមគួរផងចុះ ព្រះអង្គ ។ ព្រះបរមសាស្តា កាលដែលទ្រង់ទូន្មាន លោកសេដ្ឋី និងទេវតាដោយអំណាចវិបាកនៃកម្មល្អ និងអាក្រក់ ទើបត្រាស់ថា ម្នាលគហបតី បុគ្គលដែលធ្វើបាបក្នុងលោកនោះ រមែងឃើញបាបថាល្អ ដរាបណា បាបនៅមិនទាន់ឲ្យផល តែកាលណាបាបរបស់គេឲ្យផល ពេលនោះ គេរមែងឃើញថា បាបពិតជាអាក្រក់មែន ចំណែកបុគ្គលដែលធ្វើអំពើល្អ រមែងឃើញកម្មល្អ ថាអាក្រក់ ដរាប

ដែលកម្មល្អ នៅមិនទាន់ឲ្យផល តែកាលណាកម្មល្អរបស់គេឲ្យផល ពេលនោះ គេរមែងឃើញថា បុណ្យ គឺល្អពិតមែន ។

កាលព្រះអង្គទ្រង់តអនុសន្ធិសម្តែងព្រះធម៌ ទើបត្រាស់ព្រះគាថាដូច្នេះថា បុគ្គលដែលធ្វើបាប រមែងឃើញថាបាបល្អ កាលណាបាបនោះនៅមិនទាន់ឲ្យផល កាលណាបាបឲ្យផល គេឃើញថា បាបនេះពិតជាអាក្រក់មែន បុគ្គលដែលធ្វើកម្មល្អ រមែងឃើញកម្មល្អថា អាក្រក់ដរាបដែលកម្មល្អនៅមិនទាន់ឲ្យផល នៅពេលណាដែលកម្មល្អឲ្យផលហើយ ពេលនោះ គេរមែងឃើញថា កម្មល្អ ពិតជាល្អមែន ។ តាមន័យព្រះគាថា ដែលអដ្ឋកថាចារ្យអធិប្បាយទុកថា បុគ្គលដែលធ្វើបាបកម្មតាមផ្លូវកាយ វាចា ចិត្ត ឈ្មោះថា អ្នកធ្វើបាប បុគ្គលនោះ កាលសោយសុខ ដែលកើតឡើងដោយអានុភាពនៃសុចរិតកម្មក្នុងអតីតជាតិ រមែងឃើញបាបកម្មថាល្អ ហើយបាបកម្មរបស់គេ ដែលនៅមិនទាន់ឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ ឬក្នុងសម្បរាយិកភព គឺភពខាងមុខ ឬជាតិខាងមុខ (អ្នកធ្វើបាបរមែងឃើញថាបាបល្អជានិច្ច) តែពេលណាបាប

របស់គេឲ្យផល ក្នុងបច្ចុប្បន្នជាតិនេះ ឬក្នុងសម្បរាយិកភព ពេលនោះ គេរមែងទទួលនូវសេចក្តីទុក្ខផ្សេងៗ ទាំងក្នុងបច្ចុប្បន្នជាតិ និងទុក្ខក្នុងអបាយ ឬសម្បរាយិកភព រមែងឃើញថា បាបអាក្រក់ពិតមែន ។

បុគ្គលដែលធ្វើកម្មល្អ មានការធ្វើសុចរិត តាមផ្លូវកាយ វាចា ចិត្ត ឈ្មោះថា ធ្វើកម្មល្អ បុគ្គលធ្វើកម្មល្អនោះ ខណៈដែលបានទទួលទុក្ខដែលកើតឡើង ដោយអានុភាពនៃទុច្ចរិតកម្មក្នុងកាលមុន គេរមែងឃើញកម្មល្អថាអាក្រក់ ហើយបើកម្មល្អរបស់គេនៅមិនទាន់ឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ ឬក្នុងសម្បរាយិកភពជរាបណា (បុគ្គលធ្វើកម្មល្អរមែងឃើញកម្មល្អថាអាក្រក់ជរាបនោះ) តែពេលណា កម្មល្អនោះឲ្យផល ពេលនោះ បុគ្គលធ្វើកម្មល្អ រមែងបានទទួលសេចក្តីសុខ ដែលអាស្រ័យអាមិស មានលាភសក្ការៈជាដើម ក្នុងបច្ចុប្បន្នភព និងសុខដែលអាស្រ័យសម្បត្តិដែលជាទិព្វ ក្នុងភពខាងមុខ គេរមែងឃើញកម្មល្អថា ល្អពិតមែន ។កាលព្រះលោកនាថត្រាស់ព្រះធម៌ទេសនានេះចប់ហើយ ទេវតានោះបានសម្រេចនូវសោតាបត្តិផល ហើយព្រះធម៌

ទេសនានោះ បានជាប្រយោជន៍ដល់ពុទ្ធបរិស័ទ ដែលមកប្រជុំគ្នា ក្នុងគ្រានោះជាច្រើនដែរ ។

អនាថបិណ្ឌិកសេដ្ឋី បានស្តាប់ព្រះធម៌ទេសនាពីព្រះទសពលដោយព្រះអង្គទ្រង់ព្រះករុណាប្រោសទេសនានេះ ដូចមានរឿងដែលសម្តែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត** នៃ **បត្តកម្មវគ្គទី ២** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះលោកនាថ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានចូលទៅគាល់ព្រះមានជោគដល់ទីគង់ប្រថាប់ ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរដល់ហាន:របស់ខ្លួន ។ គ្រានោះ ព្រះលោកនាយក ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី ធម៌ ៤ ប្រការ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តដែលបុគ្គលរកបានដោយកម្រក្នុងលោកនេះ ។ធម៌ ៤ ប្រការ ដូចម្តេចខ្លះ ? បានដល់ ១- បំណងថាកោគៈទាំងឡាយ ចូរកើតដល់អាត្មាអញដែលប្រកបដោយធម៌ ។ ២- កាលបើអាត្មាអញបាននូវកោគៈ ដោយកម្ម

ប្រកបដោយធម៌ហើយ សូមយសរបស់អាត្មាអញ ល្បីខ្ចរខ្ចាយឡើង ព្រមទាំងពួកញាតិ ព្រមទាំងពួកឧបជ្ឈាយ៍ គឺមិត្រសម្លាញ់ទាំងឡាយ ។ ៣- កាលបើអាត្មាអញបាននូវភោគៈ ដោយកម្មប្រកបដោយធម៌ហើយ បានយសហើយ ទើបអាត្មាអញព្រមទាំងពួកញាតិ ព្រមទាំងឧបជ្ឈាយ៍ នឹងចិញ្ចឹមជីវិតអស់កាលយូរ រក្សាអាយុឲ្យបានវែង ។ ៤- កាលបើអាត្មាអញ បាននូវភោគៈ ដោយកម្មប្រកបដោយធម៌ហើយ បានយសហើយ ទើបអាត្មាអញ ព្រមទាំងពួកញាតិ ព្រមទាំងឧបជ្ឈាយ៍ បានចិញ្ចឹមជីវិតអស់កាលយូរ រក្សាអាយុឲ្យបានវែង ហើយលុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ សូមឲ្យបានទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលគហបតី ធម៌ ៤ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីបានចំពោះនូវធម៌ ៤ ប្រការ ដែលជាទីជ្រាជ្ញា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោកនេះ ។ ធម៌ ៤ ប្រការដូចម្តេច ? បានដល់ **១. សទ្ធាសម្បទា** គឺដល់ព្រមដោយសទ្ធា **២. សីលសម្បទា** គឺដល់ព្រមដោយសីល **៣. ចាគសម្បទា** គឺការដល់ព្រមដោយបរិច្ចាគទាន

៤. បញ្ញាសម្បទា គឺការដល់ព្រមដោយបញ្ញា ។

ម្នាលគហបតី **សទ្ធាសម្បទា** គឺដល់ព្រមដោយសទ្ធា តើដូចម្តេច ? សំដៅដល់ ការជឿចំពោះការត្រាស់ដឹងរបស់ព្រះតថាគតថា **ឥតិបិ សោ ភគវា ។បេ។ ពុទ្ធោ ភគវា** សូម្បីហេតុនេះ ព្រះមានព្រះភាគនោះ ជាព្រះអរហន្ត ទ្រង់ត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯង ដល់ព្រមដោយវិជ្ជា និងចរណៈ ស្តេចយាងទៅដោយល្អហើយ ជាអ្នកត្រាស់ដឹងនូវលោក ជាសារថី ទូន្មាននូវបុគ្គលដែលគួរទូន្មានបាន មិនមាននរណាក្រៃលែងជាងព្រះសាស្តា ទ្រង់ជាគ្រូរបស់ទេវតា និងមនុស្សទាំងឡាយ ទ្រង់ជាអ្នកភ្ញាក់ និងរីកហើយ ជាអ្នកចែកនូវព្រះធម៌ នេះហៅថា **សទ្ធាសម្បទា** គឺការដល់ព្រមដោយសទ្ធា ។ **សីលសម្បទា** គឺការដល់ព្រមដោយសីល តើដូចម្តេច ? សំដៅដល់ ការវៀរចាកការសម្លាប់សត្វ ការវៀរចាកការលួចទ្រព្យគេ ការវៀរចាកការប្រព្រឹត្តខុសចំពោះប្រពន្ធកូនអ្នកដទៃ ការវៀរចាកការនិយាយកុហក ការវៀរចាកការផឹកទឹកស្រវឹងគឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។ **ចាគសម្បទា**

គឺការដល់ព្រមដោយការបរិច្ចាគទាន តើដូចម្តេច ? សំដៅដល់ ជាអ្នក
មានចិត្តប្រាសចាកសេចក្តីកំណាញ់ ជាមនុស្ស មានការបរិច្ចាគហើយ
មានដៃលាងស្អាត ត្រេកអរក្នុងការលះបង់ គួរដល់ការសួរ ត្រេកអរ
ក្នុងទាន និងការចែកចាយ ។ **បញ្ញាសម្បទា** គឺការដល់ព្រមដោយបញ្ញា
តើដូចម្តេច ? សំដៅដល់ បុគ្គលដែលមានចិត្ត ត្រូវលោភៈគ្របសង្កត់
ហើយ ត្រូវព្យាបាទគ្របសង្កត់ហើយ ត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ
ត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ហើយ ត្រូវវិចិកិច្ឆាគ្របសង្កត់ហើយ រមែង
ធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែង
សាបសូន្យចាកយស និងសេចក្តីសុខ ។ ម្នាលគហបតី អរិយសាវ័ក
ដឹងថា សេចក្តីលោភជាគ្រឿងសៅហ្មងរបស់ចិត្ត ក៏លះបង់នូវសេចក្តី
លោភនោះបាន ដឹងថា ព្យាបាទជាគ្រឿងសៅហ្មងរបស់ចិត្ត ក៏លះបង់
ព្យាបាទចេញ ដឹងថា ថីនមិទ្ធៈជាគ្រឿងសៅហ្មងរបស់ចិត្ត ក៏លះបង់
ថីនមិទ្ធៈចេញ ដឹងថា ឧទ្ធច្ចកុក្កុច្ចៈជាគ្រឿងសៅហ្មងរបស់ចិត្ត ក៏លះបង់
ឧទ្ធច្ចកុក្កុច្ចៈចេញ ដឹងច្បាស់ថា វិចិកិច្ឆាជាគ្រឿងសៅហ្មងរបស់ចិត្ត

ក៏លះបង់វិចិកិច្ឆាចេញបាន ។ ព្រោះហេតុដែលព្រះអរិយសាវ័កលះបង់លោក ព្យាបាទ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆាចេញបាន ទើបហៅថាជាអ្នកមានបញ្ញាច្រើន ជាអ្នកមានបញ្ញាទូលំទូលាយ ជាអ្នកឃើញផ្លូវជាអ្នកដល់ព្រមដោយបញ្ញា ។

ម្នាលគហបតី អរិយសាវ័ក រមែងឃើញវត្ថុដែលគួរឃើញ ៤ ប្រការ ដោយការបរិភោគទ្រព្យ ដែលខ្លួនរកបានមក ដោយសេចក្តីព្យាយាម ដែលសន្សំរកបានដោយកម្លាំងស្មង ដែលធ្វើរហូតដល់ហូរញើសជោកកាយ ប្រកបដោយធម៌ ទើបបានមកហើយដោយត្រឹមត្រូវតាមធម៌ វត្ថុដែលគួរធ្វើ ៤ ប្រការ តើបានដល់វត្ថុអ្វីខ្លះ ? គឺព្រះអរិយ-សាវ័កក្នុងធម្មវិន័យនេះ បានបរិភោគទ្រព្យដែលរកបានដោយសេចក្តីព្យាយាម ដោយការសន្សំដោយកម្លាំងស្មងរបស់ខ្លួនឯង និងដោយការធ្វើការ រហូតដល់ហូរញើសជោកកាយ ទើបបានភោគទ្រព្យដែលត្រឹមត្រូវតាមធម៌ ១. បានទ្រព្យមក ដែលត្រឹមត្រូវតាមធម៌ហើយ ចិញ្ចឹមខ្លួនឯងឲ្យជាសុខ ចិញ្ចឹមមាតាបិតាឲ្យជាសុខ ចិញ្ចឹមបុត្រភរិយា បាវព្រាវ

ឲ្យនៅជាសុខ ចិញ្ចឹមមិត្តអាមាត្យឲ្យនៅជាសុខ ។ **២.** បានកោគទ្រព្យ ដែលត្រឹមត្រូវតាមធម៌មកហើយ រមែងការពារនូវអន្តរាយទាំងឡាយ ដែលកើតមកអំពីភ្លើង ពីទឹក ពីព្រះរាជា ពីចោរ ពីទាយាទដែលជាអ្នករួមមត៌ក ធ្វើខ្លួនឲ្យរួចផុតភ័យទាំងនោះ ដោយសួស្តី ។ **៣.** កោគទ្រព្យដែលបានមកហើយ ត្រឹមត្រូវតាមធម៌ គប្បីធ្វើនូវពលីកម្ម ៥ យ៉ាង បានដល់ **១. ញាតិពលី** បានដល់ ការសង្គ្រោះញាតិ **២. អតិថិពលី** បានដល់ ការទទួលភ្ញៀវ **៣. បុព្វបេតពលី** បានដល់ ការធ្វើបុណ្យឧទ្ទិសដល់អ្នកស្លាប់ **៤. រាជពលី** បានដល់ ការថ្វាយមានពន្ធអាករជាដើមដល់ព្រះរាជា **៥. ទេវតាពលី** បានដល់ ការធ្វើបុណ្យឧទ្ទិសដល់ទេវតា ។ **៤.** បានកោគទ្រព្យ ដែលត្រឹមត្រូវតាមធម៌ហើយ បរិច្ចាគទានដល់សមណព្រាហ្មណ៍ ដែលជាអ្នកវៀរចាកសេចក្តីប្រមាទ ជាអ្នកមិនបណ្តែតបណ្តោយខ្លួន ជាអ្នកតាំងនៅក្នុងខន្តី និងសោរច្ចៈ ជាអ្នកហ្វឹកហាត់ខ្លួន ជាអ្នកស្ងប់ ជាអ្នករំលត់កិលេសក្នុងខ្លួន ។

ម្នាលគហបតី អរិយសាវ័កនេះ ឈ្មោះថា ជាអ្នកធ្វើវត្ថុដែលគួរ

ធ្វើ ៤ ប្រការ ដោយភោគទ្រព្យ ដែលរកបានមកដោយសេចក្តីព្យាយាម និងដែលរកបានមកដោយកម្លាំងស្មង មានការធ្វើការងារ រហូតទៅដល់ហូរញើសជោកខ្លួន ប្រកបក្នុងធម៌ ទើបបានមកដោយត្រឹមត្រូវតាមធម៌ ។ ម្នាលគហបតី ភោគទ្រព្យរបស់អ្នកណា អស់ទៅដោយហេតុដទៃក្រៅពីវត្ថុដែលគួរធ្វើ ៤ ប្រការនេះ ភោគទ្រព្យរបស់អ្នកនោះ អស់ទៅដោយមិនមែនហេតុ អស់ទៅដោយមិនសមគួរ ចាយក្នុងផ្លូវដែលមិនត្រូវ ។ ចំណែកភោគទ្រព្យរបស់អ្នកណា ដល់នូវការអស់ទៅ ដោយការធ្វើវត្ថុដែលធ្វើ ៤ ប្រការនេះ ភោគទ្រព្យរបស់អ្នកនោះ ឈ្មោះថាអស់ទៅដោយហេតុដែលមិនសមគួរ អស់ទៅក្នុងស្ថានទីដែលមិនសមគួរ ចាយក្នុងផ្លូវដែលមិនត្រូវនោះទេ ។ កាលព្រះសាស្តាត្រាស់ដូច្នេះហើយ ទើបត្រាស់ព្រះគាថាថា ភោគទ្រព្យទាំងឡាយ យើងបានបរិភោគហើយ បុគ្គលគួរចិញ្ចឹម យើងបានចិញ្ចឹមហើយ យើងបានធ្វើផុតនូវសេចក្តីអន្តរាយទាំងឡាយហើយ ម្យ៉ាងទៀត ទក្ខិណាទានរបស់យើង ជាទានមានផលច្រើន យើងបានឲ្យហើយ ។ ចំពោះពលីកម្ម ៥ ប្រការ យើង

បានធ្វើហើយ អ្នកដែលមានសីល សង្រួមនៅក្នុងឥន្ទ្រិយ ប្រព្រឹត្តព្រហ្មចារ្យ យើងបានទំនុកបម្រុងហើយ បណ្ឌិតអ្នកនៅគ្រប់គ្រងផ្ទះ គប្បីប្រាថ្នាភោគទ្រព្យដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ យើងបានដល់ហើយ តាមលំដាប់ កម្មដែលមិនក្តៅក្រហាយក្នុងកាលជាខាងក្រោយ យើងបានធ្វើហើយ នរជនដែលត្រូវស្ងាប់ កាលពិចារណាដល់ហេតុនេះ ជាអ្នកត្រូវនៅក្នុងធម៌របស់ព្រះអរិយៈ បណ្ឌិតទាំងឡាយរមែងសរសើរគេក្នុងលោកនេះ កាលគេស្ងាប់ចាកលោកនេះទៅហើយ រមែងរីករាយក្នុងស្ថានសួគ៌ ។

ការប្រារព្ធហេតុយ៉ាងណានីមួយ ដើម្បីរកឱកាសនឹងធ្វើបុណ្យកុសល ឲ្យកើតផលដែលអ្នកបានធ្វើល្អ អនាថបិណ្ឌិកសេដ្ឋីបានធ្វើទុកជាទិទ្ទេស៍ ជាឧទាហរណ៍ ដូចមានរឿងពោលទុកក្នុង **គម្ពីរមង្គលត្ថទីបនី ឬមង្គលសូត្រ នៃបទទី ១១** ពោលដោយការចិញ្ចឹមមាតាបិតា ។ ដូចមានរឿងពោលថា ស្ត្រីកីលៀងរបស់ក្មេងស្រី ដែលត្រូវជាចៅរបស់អនាថបិណ្ឌិកសេដ្ឋី យកកូនតុក្កតាអំបែងឲ្យដល់ក្មេងស្រីនោះ ពោលថា

អូនតូច យកតុក្កតានេះទៅលេងចុះថ្ងៃមួយ ពួកគេលេងតុក្កតាអំបែងនោះ ភ្លាត់ដៃក៏ធ្លាក់បែក ព្រោះសេចក្តីធ្វេសប្រហែស ទើបគេស្រែកយំថា កូនរបស់យើងស្លាប់ហើយ ពេលនោះ ព្រះលោកនាថទ្រង់គង់ប្រថាប់នៅក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី ហើយសូម្បីលោកសេដ្ឋីក៏អង្គុយគាល់នៅជិតព្រះសាស្តា ស្ត្រីភីលៀងបាននាំក្មេងស្រីដែលកំពុងតែយំចូលទៅរកអនាថបិណ្ឌិកសេដ្ឋី ហើយនិយាយប្រាប់រឿងនោះឲ្យលោកសេដ្ឋីបានជ្រាប ។ លោកសេដ្ឋី កាលបានជ្រាបហើយ បានឲ្យចៅស្រីអង្គុយលើភ្លៅ ហើយនិយាយលួងលោមថា តានឹងថ្វាយទានដើម្បីឧទ្ទិសកុសលជូនដល់កូនស្រីរបស់ចៅ ហើយលោកសេដ្ឋីបានក្រាបទូលសេចក្តីនេះដល់ព្រះមានជោគ ហើយក្រាបទូលទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយទាន ដើម្បីឧទ្ទិសដល់តុក្កតា ដែលជាកូនរបស់ចៅស្រីរបស់ខ្ញុំ សូមព្រះសាស្តា ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ មកទទួលចង្ហាន់ក្នុងថ្ងៃស្អែកនេះ ។ ព្រះមុនីទ្រង់ទទួលការនិមន្តន៍ហើយ ក្នុងថ្ងៃទី ២ ព្រះអង្គបានស្តេចយាងទៅកាន់ផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី

ព្រមដោយភិក្ខុសង្ឃប្រមាណ ៥០០ រូប បន្ទាប់ពីព្រះអង្គទទួលភត្តរួច
ហើយ ពេលដែលព្រះអង្គទ្រង់ធ្វើការអនុមោទនាទាន ទើបត្រាស់ព្រះ
គាថាដូច្នេះថា បុគ្គលណាមិនមានសេចក្តីកំណាញ់ ធ្វើហេតុយ៉ាងណា
នីមួយឲ្យជាអារម្មណ៍ ប្រារព្ធនូវបុព្វការីជនដែលស្លាប់ទៅហើយ ទេវតា
ដែលស្ថិតនៅក្នុងទីទាំងឡាយ ឬមហារាជដែលជាលោកបាលទាំង ៤
ទិស **គឺព្រះបាទកុវេរៈ ព្រះបាទធតរដ្ឋៈ ព្រះបាទវិរូបក្ខៈ ព្រះបាទវិរុឡ្ហកៈ**
ហើយគប្បីថ្វាយទាន បុព្វការីជន និងទេវតាទាំងឡាយជាដើមនោះ
រមែងជាអ្នកដែលគេបូជាហើយ រមែងមិនឥតផលឡើយ ។ ការយំស្រែក
សេចក្តីសោយសោក ឬសេចក្តីខ្សឹកខ្សួលយ៉ាងណានីមួយ បុគ្គលមិន
គប្បីធ្វើឡើយ ព្រោះការយំជាដើមនោះ ជារបស់មិនមានប្រយោជន៍
ដល់ជនដែលស្លាប់ទៅហើយទេ ញាតិទាំងឡាយ រមែងតាំងនៅយ៉ាងនោះ
ជដែល ។ ទក្ខិណាទាននេះឯង ដែលគេឲ្យហើយ ឈ្មោះថា តាំងទុក
ដោយល្អហើយក្នុងសង្ឃ រមែងសម្រេចប្រយោជន៍ដ៏ប្រសើរ ដល់អ្នក
ដែលស្លាប់ទៅហើយ អស់កាលដ៏យូរអង្វែងតាមហានៈ ។

អនាថបិណ្ឌិកសេដ្ឋី បានប្រើឧបាយធ្វើឲ្យកូនប្រុសរបស់លោកចូលវត្ត បានសម្រេចតាមការតាំងចិត្ត ដូចដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **លោកវគ្គ ក្នុងរឿងនាយកាឡៈ** ដែលជាកូនរបស់អនាថបិណ្ឌិកសេដ្ឋី ដូចមានរឿងពោលទុកថា ៖-

ក្នុងសម័យមួយ ព្រះលោកនាយក ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ទ្រង់ប្រោរព្ធនាយកាឡៈ ដែលជាកូនរបស់អនាថបិណ្ឌិកសេដ្ឋី ហើយទ្រង់ត្រាស់ព្រះធម៌ទេសនាប្រោសដល់ពុទ្ធបរិស័ទគ្រានោះផងដែរ ។ នាយកាឡៈជាកូនរបស់អនាថបិណ្ឌិកសេដ្ឋី ដែលលោកសេដ្ឋីដល់ព្រមដោយសទ្ធា គឺការជឿមាំទាំហើយ តែនាយកាឡៈមិនជ្រាប្ញា ដើម្បីនឹងទៅកាន់សម្នាក់របស់ព្រះបរមសាស្តាឡើយ ថែមទាំងមានបំណងមិនចង់ឃើញព្រះមានជោគ ពេលព្រះអង្គស្តេចយាងមកកាន់ផ្ទះរបស់ខ្លួន មិនត្រូវការដើម្បីនឹងស្តាប់ធម៌ និងមិនរីករាយក្នុងការធ្វើបដិសណ្ឋារៈដល់ភិក្ខុសង្ឃ សូម្បីត្រូវបិតានិយាយថា កូនចូរធ្វើយ៉ាងនេះ គេក៏មិនជឿស្តាប់ពាក្យរបស់លោកសេដ្ឋី ។ ដោយហេតុ

ដូច្នេះ អនាថបិណ្ឌិកសេដ្ឋីពិចារណាថា កាឡៈកូនរបស់យើង កាលប្រកាន់ទិដ្ឋិវិនត្ថឹងយ៉ាងនេះតទៅ ក្នុងកាលខាងមុខ (កាលអស់ជីវិត) នឹងទៅកាន់អវីចីនរក ដែលយើងដឹងដូច្នេះហើយ ក្នុងដំណើរបស់កូនយើង ដែលនឹងទៅកាន់នរកនោះ យើងមិនគួរនឹងបណ្តែតបណ្តោយឲ្យគេទៅដាយ៉ាងនោះទេ ដែលបានឈ្មោះថាសត្វ ជាអ្នកមិនប្រាថ្នាចង់បានទ្រព្យសម្បត្តិនោះ រមែងមិនមានឡើយ យើងគួរនឹងប្រើវិធីក្នុងការចំណាយទ្រព្យ ដើម្បីទម្លាយនូវទិដ្ឋិ ដ៏វិនត្ថឹងរបស់កូនយើង ។ កាលអនាថបិណ្ឌិកសេដ្ឋីគិតឃើញយ៉ាងនេះហើយ ទើបនិយាយនឹងនាយកាឡៈថា នែកាឡៈកូនប្រុសឪពុក កូនចូរជាអ្នករក្សាឧបោសថសីលហើយទៅកាន់វិហារដើម្បីស្តាប់ព្រះធម៌ទេសនាចុះ ពុកនឹងឲ្យកហាបណៈដល់កូន ១០០ កហាបណៈ ។

នាយកាឡៈសួរថា លោកឪពុក នឹងឲ្យកហាបណៈដល់កូនពិតមែនឬ ? អនាថបិណ្ឌិកសេដ្ឋីតបថា ពុកនឹងឲ្យកហាបណៈដល់កូនពិតៗ ។ នាយកាឡៈបានទទួលប្តេជ្ញា ហើយបានជាអ្នករក្សាឧបោសថសីល និង

ទៅវត្តស្តាប់ព្រះធម៌ ។ តែកិច្ច គឺការស្តាប់ព្រះធម៌នោះ គេមិនបានធ្វើតាមឡើយ ព្រោះគេបានទៅដេកលក់ក្នុងកន្លែងមួយ លុះព្រឹកឡើងគេទើបក្រោកឡើងត្រឡប់ទៅផ្ទះវិញ ។ អនាថបិណ្ឌិកសេដ្ឋី បានប្រាប់អ្នកបម្រើថា កូនរបស់យើង ទើបមកពីការរក្សាឧបោសថសីល ហេតុដូច្នេះ អ្នកទាំងឡាយចូរលើកបបរជាដើមមក ឲ្យកូនរបស់យើងដោយរហ័ស ចំណែកនាយកាឡៈ បានពោលបដិសេធមិនទាន់ព្រមទទួលអាហារ ដោយនិយាយទារថ្លៃឈ្នួលថា បើកូនមិនទាន់បានទទួលកហាបណៈទេ កូនទីងមិនព្រមបរិភោគអាហារ ។ លោកសេដ្ឋី កាលបានស្តាប់ពាក្យនិយាយរបស់កូនប្រុសដូច្នេះហើយ ទើបឲ្យទៅយកកហាបណៈ តាមដែលសន្យាទុកមកឲ្យ ។ នាយកាឡៈ លុះបានទទួលកហាបណៈហើយ ទើបបរិភោគអាហារនោះ តមកថ្ងៃរះឡើង លោកសេដ្ឋី បានប្រាប់ឲ្យនាយកាឡៈទៅដោយពោលថា នែកូនប្រុសឪពុកទីងឲ្យកហាបណៈ ១000 ដល់កូន តែកូនត្រូវឈរចំពោះព្រះភក្ត្រនៃព្រះសម្ពុទ្ធ និងរៀនយកព្រះធម៌ ឬស្តាប់ធម៌ឲ្យបានមួយបទ

ហើយត្រឡប់មក ។ នាយកាឡៈបានយល់ព្រម ហើយទៅកាន់វិហារ ចូលទៅឈរចំពោះព្រះភក្ត្រនៃព្រះសាស្តា ក្នុងបំណងដើម្បីនឹងស្តាប់ព្រះធម៌ឲ្យចាំត្រឹមតែមួយបទប៉ុណ្ណោះ នឹងត្រឡប់មកវិញ ។ លំដាប់នោះ ព្រះលោកនាយក ទ្រង់ជ្រាប ទ្រង់បានធ្វើឲ្យនាយកាឡៈមិនអាចស្តាប់ចាំបានសូម្បីត្រឹមតែមួយបទ ។ ទោះបីនាយកាឡៈ ប្រឹងស្តាប់យ៉ាងណា ក៏នៅតែមិនចាំ ទើបបានឈរស្តាប់តទៅទៀត ដោយតាំងចិត្តថា យើងនឹងប្រឹងស្តាប់ឲ្យចាំមួយបទទាល់តែបាន ។ កាលបុគ្គលបានតាំងចិត្តស្តាប់ព្រះធម៌ ដោយគិតថា យើងនឹងស្តាប់ឲ្យចាំ ដូច្នេះឈ្មោះថាស្តាប់ព្រះធម៌ដោយសេចក្តីគោរព កាលបើបុគ្គលតាំងចិត្តស្តាប់ព្រះធម៌ដោយសេចក្តីគោរពយ៉ាងនេះហើយ រមែងឲ្យដល់នូវសោតាបត្តិមគ្គ (ផ្លូវបដិបត្តិដែលឲ្យសម្រេចផល ជាព្រះសោតាបន្ន) ជាដើម ។

សូម្បីនាយកាឡៈ ក៏ស្តាប់ធម៌ដោយគិតថា យើងនឹងស្តាប់ព្រះធម៌ឲ្យចាំមួយបទទាល់តែបាន ។ ព្រះទសពល ទ្រង់ជ្រាបដល់ឆន្ទៈរបស់នាយកាឡៈដូច្នេះហើយ ក៏ធ្វើឲ្យនាយកាឡៈចាំមិនបាន ។ ខណៈ

ដែលនាយកាឡៈកំពុងតែឈរស្តាប់ដោយការប៉ង់ក្នុងចិត្តថា យើងនឹងស្តាប់តទៅទៀតឲ្យចាំ ការតាំងចិត្តយ៉ាងនេះ ក៏ធ្វើឲ្យចិត្តរបស់នាយកាឡៈស្ងប់ មានចិត្តបង្អោនទៅតាមក្រសែនៃព្រះធម៌ រហូតបានសម្រេចនូវសោតាបត្តិផល (ផលដែលចូលដល់ក្រសែនៃធម៌ ឬក្រសែនៃព្រះនិព្វាន) ។ លុះថ្ងៃរះឡើង នាយកាឡៈបានត្រឡប់ពីវត្តចូលទៅកាន់ក្រុងសាវត្ថី ព្រមដោយភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដើម្បីស្តេចយាងទៅកាន់និវេសន៍ របស់អនាថបិណ្ឌិកសេដ្ឋី ។ លោកសេដ្ឋីលុះក្រឡេកឃើញនាយកាឡៈ ដែលជាកូនប្រុសរបស់ខ្លួនហើយ ទើបគិតថា ថ្ងៃនេះ យើងពេញចិត្តចំពោះអាកប្បកិរិយារបស់កូនយើងណាស់ ។ ចំណែកនាយកាឡៈ បានមានបរិវិតក្ក គឺនឹកភ័យព្រួយក្នុងចិត្តថា ថ្ងៃនេះលោកឪពុករបស់យើងមិនគប្បីឲ្យកហាបណៈ នៅចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ គប្បីជួយបិទបាំងយើង ដែលជាអ្នករក្សាឧបោសថសីលព្រោះហេតុនៃការចង់បានកហាបណៈ តែប៉ុណ្ណោះ ។ សេចក្តីពិតវឿងទាំងអស់នោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានជ្រាបថា នាយកាឡៈ ជាអ្នក

រក្សាឧបោសថសីល ព្រោះហេតុនៃការចង់បានកហាបណៈតាំងអំពីមុរិលមិញមកហើយ ។ កាលលោកសេដ្ឋី ឲ្យប្រគេនយាគូដល់ភិក្ខុសង្ឃដែលមានព្រះភគវាជាប្រធានរួចស្រេចហើយ ទើបឲ្យគេលើកបបរមកឲ្យដល់នាយកាឡៈ ។ ចំណែកនាយកាឡៈក៏អង្គុយនៅស្ងៀមដូចបុគ្គលដែលមានការកង្វល់ក្នុងចិត្ត កាលលើកបបរមកដល់ក៏បរិភោគ ដោយមិនទាវរកកហាបណៈដូចថ្ងៃមុនទៀត ។ ពេលស្រេចភត្តកិច្ចនៃព្រះភគវាហើយ អនាថបិណ្ឌិកសេដ្ឋី ទើបប្រើអ្នកបម្រើឲ្យទៅយកកហាបណៈ ១០០០ យកមកឲ្យនាយកាឡៈ ហើយពោលថា កាឡៈកូនជាទីស្រឡាញ់ពុកនិយាយថា នឹងឲ្យកហាបណៈ ១០០០ ដល់កូន ទើបឲ្យកូនទៅសមាទានឧបោសថសីលនៅឯវត្ត និងស្តាប់ព្រះធម៌ នេះកហាបណៈ ១០០០ របស់កូន ហេតុដូច្នេះ ចូរកូនយកទៅចុះ ។ នាយកាឡៈបានក្រឡេកឃើញកហាបណៈដែលឪពុកឲ្យនៅចំពោះព្រះភក្ត្រនៃព្រះសាស្តាក៏កើតការអៀនខ្មាសឡើង ទើបពោលថា បពិត្រលោកឪពុក ខ្ញុំលែងត្រូវការកហាបណៈទៀតហើយ ។ សូម្បីអនាថបិណ្ឌិកសេដ្ឋីពោល

ទទួចអង្វរថា ចូរកូនទទួលយកទៅចុះ គេក៏មិនព្រមទទួលយក ។

កាលអនាថបិណ្ឌិកសេដ្ឋី ឃើញកូនប្រុសរបស់ខ្លួនមិនព្រមទទួលយក ទើបក្រាបបង្គំព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះ ខ្ញុំព្រះអង្គពេញចិត្តចំពោះអាការៈនៃកូនប្រុសរបស់ខ្ញុំព្រះករុណាព្រះអង្គ ។ ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលគហបតី មានហេតុការណ៍អ្វីឬ ? អនាថបិណ្ឌិកសេដ្ឋីក្រាបទូលតបថា ក្នុងថ្ងៃមុន ខ្ញុំព្រះអង្គបានសន្យាថា ពុកនឹងឲ្យកហាបណៈដល់កូន ១០០ កហាបណៈ ហើយឲ្យទៅសមាទានឧបោសថសីលនៅឯវត្ត លុះដល់ថ្ងៃរះឡើង គេត្រឡប់មកដល់ផ្ទះវិញ កាលបើមិនទាន់បានកហាបណៈ គេក៏មិនព្រមបរិភោគអាហារដែរ តែថ្ងៃនេះ គេមិនត្រូវការកហាបណៈ សូម្បីទាំងដែលខ្ញុំព្រះអង្គឲ្យ ឬពោលអង្វរយ៉ាងណាក៏មិនព្រមដែរ ព្រះអង្គ ។ គ្រានោះ ព្រះមានជោគត្រាស់ថា ត្រូវហើយគហបតី សោតាបត្តិផលរបស់បុត្រលោក ប្រសើរជាងសម្បត្តិរបស់ស្តេចចក្រពត្តិ សម្បត្តិក្នុងទេវលោក និងប្រសើរជាងសម្បត្តិក្នុងព្រហ្មលោក ហើយព្រះអង្គត្រាស់

ព្រះគាថាថា សោតាបត្តិផលប្រសើរជាងឯករាជ្យលើផែនដី ប្រសើរជាងការទៅកាន់ស្ថានសួគ៌ និងប្រសើរជាងអធិបតីភាពក្នុងលោកទាំងមូល ។

តាមអត្ថន័យ ដែលអដ្ឋកថាចារ្យបានអធិប្បាយទុកថា ព្រះរាជាសូម្បីសោយរាជសម្បត្តិ ក្នុងទីមានប្រមាណប៉ុនណាៗ ក៏ដោយ រមែងជាអ្នកមិនអាចរួចផុតអំពីនរកបានឡើយ ។ចំណែកព្រះសោតាបន្ន ជាអ្នកបិទទ្វារអបាយភូមិបានហើយ ព្រោះដូច្នោះ សោតាបត្តិផល ទើបប្រសើរឧត្តមជាងភាពជាស្តេចចក្រពត្តិ ឬជាងជំណើរទៅកាន់ស្ថានសួគ៌ ២៦ ជាន់ និងភាពជាធំក្នុងលោកទាំងពួង ។

អនាថបិណ្ឌិកសេដ្ឋី បានជួយសង្គ្រោះទាសីរបស់លោក ដោយការជួយចាត់ចែងបូជាសពរបស់ទាសីឲ្យរៀបរយ ទាំងនេះក៏ជាគំរូដ៏ល្អដែលចៅហ្វាយនាយត្រូវតែអនុគ្រោះដល់បាវព្រាវក្នុងគ្រាមានទុក្ខ ដូចដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាជាតក** ដែលពង្រីកសេចក្តីបាលីនៃ **រោហិណីជាតក ក្នុងគម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅវត្តជេតពន ទ្រង់បានត្រាស់ព្រះធម៌ទេសនា រឿងអមិត្តប្រសើរជាង ដោយទ្រង់ប្រារព្ធទាសីម្នាក់របស់អនាថបិណ្ឌិកសេដ្ឋី ដូចមានរឿងពោលថា នាងវេហិណីជាទាសីរបស់អនាថបិណ្ឌិកសេដ្ឋី នាងមានម្តាយចាស់ជរាមកដេកនៅក្នុងវេងបុកស្រូវ រុយទាំងឡាយមករេមចំពោះម្តាយរបស់នាងយ៉ាងច្រើន បីដូចម្ល៉ុលចាក់ ម្តាយទើបប្រាប់នាងវេហិណីឲ្យជួយដេញរុយឲ្យ នាងវេហិណីគិតនឹងសម្លាប់រុយទាំងនោះឲ្យស្លាប់អស់ ហើយទើបលើកអង្រែវាយចំពោះរុយ ក៏ចំមាតា មាតារបស់នាងក៏ស្លាប់ទៅ កាលនាងវេហិណីដឹងដូច្នោះហើយ ក៏បានយំសោកខ្សឹកខ្សួល ដោយរៀបរាប់ថា មាតារបស់យើងស្លាប់ទៅហើយ ។ មនុស្សទាំងឡាយទើបនាំយករឿងនោះទៅប្រាប់អនាថបិណ្ឌិកសេដ្ឋី កាលលោកសេដ្ឋីបានជ្រាបហើយ បានឲ្យនាំគ្នាចាត់ចែងបូជាសពរបស់ម្តាយនាងវេហិណី ហើយលោកសេដ្ឋីក៏បានទៅឯវត្តជេតពន ដោយក្រាបទូលរឿងនេះថ្វាយព្រះបរមសាស្តាឲ្យទ្រង់ជ្រាប ។

កាលព្រះសម្ពុទ្ធទ្រង់ជ្រាប ទើបត្រាស់ថា ម្នាលគហបតី ស្រីនេះបានធ្វើបាបសម្លាប់មាតា ដោយអន្ទែងដោយគិតថា នឹងសម្លាប់រុយត្រង់ខ្នងមាតា មិនមែនមានតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្វើបាបមានដែរ កាលព្រះពុទ្ធអង្គត្រាស់ដូច្នេះហើយ ទើបទ្រង់ត្រាស់សម្តែងរឿងក្នុងអតីតកាលថា

ក្នុងអតីតកាល ក្នុងរាជសម័យរបស់ព្រះបាទព្រហ្មទត្ត គ្រប់គ្រងរាជសម្បត្តិនៅក្នុងក្រុងពារាណសី សម័យនោះ ព្រះពោធិសត្វកើតនៅក្នុងត្រកូលសេដ្ឋី កាលបិតាស្លាប់ទៅហើយ ក៏បានទទួលតំណែងជាសេដ្ឋីជំនួសបិតា ហើយព្រះពោធិសត្វមាននាងរោហិណីជាទាសី ។ សម័យមួយ មាតារបស់នាងរោហិណី មកដេកនៅត្រង់រោងបុកអង្ករ បានប្រាប់ឲ្យនាងរោហិណីដែលជាកូនស្រី ដេញរុយដែលមកវាយ នាងរោហិណីក៏វាយរុយដោយអន្ទែងបុកអង្ករ ក៏ចំម្តាយរហូតដល់អស់ជីវិត កាលនាងដឹងថា ម្តាយរបស់នាងស្លាប់ហើយ នាងក៏យំសោកស្តាយចំពោះមាតា ។ គ្រានោះ ព្រះពោធិសត្វបានដឹងរឿងនោះហើយក៏ត្រិះរិះថា

ក្នុងលោកនេះ បណ្ឌិតសូម្បីជាសត្រូវ គង់ប្រសើរជាង ហើយពោលព្រះគាថាថា

សត្រូវ (អមិត្ត) ដែលមានបញ្ញាប្រសើរជាងបុគ្គល ដែលល្ងង់ខ្លៅ ដែលជាមិត្ត មានចិត្តគិតអនុគ្រោះ ចូរមើលនាងរេហិណីដ៏អាក្រក់ (ល្ងង់ខ្លៅ) នាងសម្លាប់មាតារបស់ខ្លួន ហើយសោយសោក ។

ព្រះលោកនាថ ទើបត្រាស់នឹងអនាថបិណ្ឌិកសេដ្ឋីតទៅទៀតថា ម្នាលគហបតី ស្រីនេះសម្លាប់មាតា ដោយយល់ថា នឹងសម្លាប់រុយ មិនមែនមានតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន គេក៏សម្លាប់មានសភាពដូចគ្នាក្នុងកាលនេះឯង ហើយព្រះពុទ្ធអង្គទ្រង់ប្រមូលអតីតនិទានជាតកថា

មាតាក្នុងកាលនោះ បានមកជាមាតាក្នុងបច្ចុប្បន្នជាតិនេះ រីឯនាងរេហិណីក្នុងកាលនោះ ក៏បានមកជានាងរេហិណីក្នុងបច្ចុប្បន្នជាតិនេះដូចគ្នា ចំណែកព្រះពោធិសត្វ ដែលជាមហាសេដ្ឋី ឬដែលជាចៅហ្វាយរបស់នាងក្នុងកាលនោះ គឺជាតថាគតនេះឯង ។ នេះជានាទីរបស់ចៅហ្វាយ

ដែលល្អ ដែលជាអ្នកមានគុណធម៌ ក្នុងឋានៈជាចៅហ្វាយ ដោយបានជួយអើពើឧបការៈចំពោះបាវព្រាវ ក្នុងឋានៈជាអ្នកបម្រើ ដែលដល់នូវសេចក្តីទុក្ខលំបាក និងជាឧទាហរណ៍ឲ្យដឹងថា មនុស្សក្នុងពុទ្ធសម័យដែលព្រះអង្គទ្រង់ធរមាននៅ ក៏មានធ្វើការបូជាសព ។

សម័យមួយ អនាថបិណ្ឌិកសេដ្ឋី បានចូលទៅក្រាបទូលសួរចំពោះចំណុចបដិបត្តិ ក្នុងការជ្រើសរើស ឬការរាប់អានភិក្ខុ ចំពោះព្រះមានព្រះភាគ ដូចមានរឿងដែលពោលទុកនៅក្នុង **គម្ពីរមហាវគ្គ ព្រះវិន័យបិដក នៃកោសម្ពីខន្ធក:** មានសេចក្តីថា ៖-

សម័យមួយ អនាថបិណ្ឌិកសេដ្ឋីបានជ្រាបដំណឹងថា ភិក្ខុដែលនៅក្នុងក្រុងកោសម្ពី ដែលជាអ្នកបង្កវឿងឈ្លោះទាស់ទែងគ្នា បង្កវិវាទធ្វើការប្រៈឆា បង្កអធិករណ៍ក្នុងសង្ឃទាំងនោះ នាំគ្នាមកកាន់ក្រុងសាវត្ថី ទើបចូលទៅក្នុងពុទ្ធសម្នាក់ ថ្វាយបង្គំព្រះសាស្តារួចហើយក៏បានអង្គុយនៅក្នុងទីដ៏សមគួរ ទើបក្រាបទូលសួរ១.បដិបត្តិនេះនឹងព្រះទសពលថា ខ្ញុំព្រះអង្គបានជ្រាបដំណឹងមកថា ភិក្ខុនៅក្នុងក្រុងកោសម្ពី

បានបង្កវៀងវៀតបៀនគ្នា បង្កការឈ្លោះវិវាទ ទាស់ទែងគ្នា និងធ្វើការប្រេះឆា បង្កអធិករណ៍ក្នុងសង្ឃទាំងនោះ បាននាំគ្នាមកកាន់ក្រុងសាវត្ថី ខ្ញុំព្រះអង្គនឹងបដិបត្តិចំពោះភិក្ខុទាំងនោះដូចម្តេច ព្រះអង្គ ? ព្រះសាស្តាទ្រង់ត្រាស់ណែនាំថា ម្នាលគហបតី បើដូច្នោះ អ្នកចូរថ្វាយទានចំពោះភិក្ខុទាំងពីរចំណែកនោះ កាលបើអ្នកថ្វាយទានដល់ភិក្ខុទាំងពីរចំណែកនោះហើយ អ្នកចូរស្តាប់ធម៌ ក្នុងសម្នាក់ភិក្ខុទាំងពីរចំណែកនោះសិនកាលលោកស្តាប់ធម៌ របស់ភិក្ខុទាំងពីរចំណែកនោះ ហើយ (ចូរអ្នកពិនិត្យពិចារណាមើល) ពួកភិក្ខុណាក្នុងចំណែកទាំងពីរនោះ ជាធម្មវាទី (អ្នកពោលតាមធម៌) អ្នកចូរពេញចិត្តក្នុងការយើញ និងការជឿកាន់យកតាមភិក្ខុដែលជាធម្មវាទីនោះចុះ (នេះជាវិធីការជ្រើសរើសរាប់អានភិក្ខុក្នុងព្រះពុទ្ធសាសនានេះ ត្រូវមើលធម៌វិនិច្ឆ័យ ដែលលោកប្រព្រឹត្តប្រតិបត្តិជាគោល) ។

ភាពជាអ្នកមានការចេះដឹង ក្នុងគោលធម៌របស់អនាថបិណ្ឌិកសេដ្ឋីរហូតអាចអធិប្បាយគោលធម៌ ក្នុងព្រះសាសនានេះឲ្យពួកអន្យតិ្ថយ

និងបរិព្វាជកឲ្យអស់ផ្លូវ (ក្នុងការ) លើកវាទៈ និងបានទទួលការលើកតម្កើងអំពីព្រះសយម្ភូ ដូចដែលមានរៀងសម្តែងប្រាកដនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ទសកនិបាត ក្នុងទិដ្ឋិសូត្រ** (ព្រះសូត្រដែលពោលដោយការយល់ឃើញផ្សេងៗ) **នៃឧបាសកវគ្គ** មានសេចក្តីថា ៖-

សម័យមួយ ព្រះមហាវីរៈ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋីបានចេញពីក្រុងសាវត្ថីក្នុងពេលថ្ងៃត្រង់ ដើម្បីនឹងចូលទៅគាល់ព្រះកគវា តែលោកសេដ្ឋីបែរជាគិតថា ពេលនេះ មិនមែនជាពេលគួរនឹងចូលទៅគាល់ព្រះសម្ពុទ្ធទេ ព្រោះព្រះកគវា ព្រះអង្គពួនសំងំក្នុងទីស្ងាត់ និងមិនមែនជាពេលវេលានឹងទៅសួរសុខទុក្ខកិក្ខុសង្ឃទាំងឡាយដែរ ដែលជាអ្នកមានប្រក្រតីចម្រើនទៅដោយវិវេក ហើយជាអ្នកពួនសំងំនៅក្នុងទីស្ងាត់ កុំដូច្នោះឡើយ យើងនឹងឆៀងទៅកាន់លំនៅរបស់ពួកអន្យតិ្ថយ និងបរិព្វាជកល្អជាង លុះអនាថបិណ្ឌិកសេដ្ឋីគិតឃើញដូច្នេះហើយទើបចូលទៅកាន់លំនៅរបស់ពួកអន្យតិ្ថយ និងបរិព្វាជក ក្នុងកាលនោះ ពួកអន្យតិ្ថយ

និងបរិព្វាជកកំពុងតែប្រជុំគ្នា មានសំឡេងអ៊ូអរ ដោយអង្គុយនិយាយគ្នា ក្នុងរឿងតិរច្ឆានកថាផ្សេងៗ លុះពួកអន្យតិរ្ថិយ និងបរិព្វាជកទាំងនោះ បានក្រឡេកឃើញអនាថបិណ្ឌិកសេដ្ឋីដើរមកអំពីចម្ងាយ ក៏ឲ្យសញ្ញាគ្នាថា អ្នកទាំងអស់គ្នាចូរនិយាយសំឡេងតិចៗ កុំនិយាយសំឡេងខ្លាំងៗ ឡើយ ព្រោះអនាថបិណ្ឌិកសេដ្ឋីនេះ ជាសាវ័កបស់ព្រះសមណគោតម សាវ័ក ព្រះសមណគោតម សុទ្ធតែចូលចិត្តនិយាយសំឡេងតិចៗ បានទទួល ការណែនាំឲ្យធ្វើសំឡេងតិច ពោលសរសើរសំឡេងតិច ទោះយ៉ាងនោះ ក៏ដោយ គាត់ឃើញទីប្រជុំរបស់ពួកយើងមានសំឡេងតិច គាត់ប្រាកដ ជាចូលមកវក ។ ពេលនោះ ពួកបរិព្វាជកទាំងនោះក៏នាំគ្នានៅស្ងៀម ។ គ្រានោះ លោកសេដ្ឋី បានឆៀងចូលទៅរកពួកបរិព្វាជកទាំងនោះដល់ទី លំនៅ បានអង្គុយចុះ សន្ទនាប្រាស្រ័យចរចាជាមួយគ្នា និងពួកបរិព្វាជក ទាំងនោះ ដោយពាក្យសម្តីដែលគួរពួកដល់គ្នានិងគ្នា ។ រួចស្រេចហើយ ពួកបរិព្វាជកទាំងនោះ បានពោលជាមួយអនាថបិណ្ឌិកសេដ្ឋីថា ម្នាល គហបតី សូមលោកជួយប្រាប់ផងចុះថា ព្រះសមណគោតម មានការ

យល់ឃើញដូចម្តេច ? អនាថបិណ្ឌិកសេដ្ឋីឆ្លើយថា អ្នកដ៏ចម្រើនទាំងឡាយ ខ្ញុំមិនជ្រាបដល់ការយល់ឃើញ របស់ព្រះមានជោគទាំងអស់នោះទេ ។

ពួកបរិព្វាជកទើបពោលថា ម្នាលគហបតី កាលលោកមិនជ្រាបដល់ការយល់ឃើញទាំងអស់ របស់ព្រះសមណគោតម ក៏មិនជាអ្វី តែសូមលោកជួយប្រាប់ផងចុះថា កិក្ខុទាំងឡាយមានការយល់ឃើញដូចម្តេច ? អនាថបិណ្ឌិកសេដ្ឋីតបថា អ្នកដ៏ចម្រើនទាំងឡាយ ខ្ញុំមិនជ្រាបដល់ការយល់ឃើញទាំងអស់ របស់កិក្ខុទាំងនោះដូចគ្នា ។ ពួកបរិព្វាជកបានពោលតទៅទៀតថា ម្នាលគហបតី បើលោកមិនជ្រាបដល់ការយល់ឃើញទាំងអស់ របស់ព្រះសមណគោតម និងការយល់ឃើញទាំងអស់ របស់កិក្ខុទាំងឡាយក៏មិនជាអ្វី តែខ្លួនលោកមានការយល់ឃើញដូចម្តេច ? គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានពោលថា អ្នកដ៏ចម្រើនទាំងឡាយ ខ្ញុំមានការយល់ឃើញយ៉ាងណា ការយល់ឃើញយ៉ាងនោះ ខ្ញុំប្រាប់បានមិនលំបាកទេ តែចង់អញ្ជើញលោកទាំងអស់គ្នាប្រាប់ការយល់ឃើញ របស់លោកទាំងឡាយ ឲ្យខ្ញុំបានស្តាប់សិន

ហើយខ្ញុំទើបនឹងជ្រាប់ដល់ការយល់ឃើញរបស់ខ្ញុំ ឲ្យលោកទាំងឡាយ
បានជ្រាបជាខាងក្រោយ មិនមែនជាការលំបាកទេ ។ កាលអនាថបិណ្ឌិក-
សេដ្ឋីពោលយ៉ាងនេះហើយ បរិព្វាជកម្នាក់បានពោលនឹងអនាថបិណ្ឌិក
សេដ្ឋីថា ម្នាលគហបតី យើងមានការយល់ឃើញថា លោកនេះទៀង
ការយល់ឃើញបែបនេះឯងពិត ការយល់ឃើញដទៃទៀតមិនពិត ។
បរិព្វាជកម្នាក់ទៀត បានពោលជំទាស់នឹងអ្នកទី ១ ថា ម្នាលគហបតី
យើងមានការយល់ឃើញថា លោកមិនស្ថិតស្ថេរ វត្ថុនេះប៉ុណ្ណោះពិត
វត្ថុដទៃទៀតមិនពិត ។ បរិព្វាជកម្នាក់ទៀតពោលថា ម្នាលគហបតី
យើងមានការយល់ឃើញថា លោកមានទីបំផុត វត្ថុនេះប៉ុណ្ណោះពិត
វត្ថុដទៃទៀតមិនពិត ។ បរិព្វាជកដទៃទៀត ពោលផ្ទុយគ្នាថា ម្នាល
គហបតីយើងមានសេចក្តីយល់ឃើញថា លោកមិនមានទីបំផុត វត្ថុនេះ
ប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។

បរិព្វាជកម្នាក់ទៀត ទើបពោលថា ម្នាលគហបតីយើងមានការ
យល់ឃើញថា ជីវៈ និងសរីរៈដូចគ្នា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀត

មិនពិត ។ បរិព្វាជកម្នាក់ទៀតពោលជំទាស់នឹងបរិព្វាជក ដែលពោលរួចមកហើយថា ម្នាលគហបតី យើងមានការយល់ឃើញថា ជីវៈ និងសរីរៈជារបស់ផ្សេងគ្នា វត្តុនេះប៉ុណ្ណោះពិត វត្តុដទៃមិនពិត ។ បរិព្វាជកម្នាក់ទៀតពោលផ្ទុយគ្នានឹងបរិព្វាជកមុនៗ ថា ម្នាលគហបតី យើងមានការយល់ឃើញថា សត្វស្លាប់ហើយកើតទៀត វត្តុនេះប៉ុណ្ណោះពិត វត្តុដទៃទៀតមិនពិត ។ បរិព្វាជកម្នាក់ទៀតបានពោលផ្ទុយនឹងបរិព្វាជកមុនថា ម្នាលគហបតី យើងមានការយល់ឃើញថា សត្វស្លាប់ទៅហើយមិនកើតទៀត វត្តុនេះប៉ុណ្ណោះពិត វត្តុដទៃទៀតមិនពិត ។ បរិព្វាជកម្នាក់ទៀតពោលថា ម្នាលគហបតី យើងមានការយល់ឃើញថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន វត្តុនេះប៉ុណ្ណោះពិត វត្តុដទៃទៀតមិនពិត ។ កាលពួកបរិព្វាជកបានសម្តែងការយល់ឃើញរបស់ខ្លួនម្នាក់ម្យ៉ាងៗ សុទ្ធតែជំទាស់គ្នាឯងយ៉ាងនេះហើយ អនាថបិណ្ឌិក-សេដ្ឋីទើបពោលនឹងបរិព្វាជកទាំងនោះថា អ្នកដ៏ចម្រើនទាំងឡាយ អ្នកណាពោលថា យើងយល់ឃើញថា លោកស្ថិតស្ថេរ វត្តុនេះប៉ុណ្ណោះពិត

វត្ថុដទៃទៀតមិនពិត ការយល់ឃើញរបស់អ្នកនោះ កើតឡើងហើយ ព្រោះហេតុនៃការធ្វើទុកក្នុងចិត្ត ដោយមិនត្រូវឧបាយរបស់ខ្លួនខ្លះ ឬព្រោះជឿស្តាប់ការឃោសនារបស់អ្នកដទៃជាបច្ច័យខ្លះ ការឃើញបែបនេះឯង កើតឡើងហើយ ដែលអាស្រ័យបច្ច័យតាក់តែងហើយ ដែលបច្ច័យក.ឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ មិនថាវត្ថុណានីមួយ ដែលកើតឡើងហើយ ដែលបច្ច័យតាក់តែងហើយ ដែលបច្ច័យក.ឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ វត្ថុនោះមិនទៀង វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ វត្ថុណាជាទុក្ខ អ្នកនោះក៏ជ្រាបនៅហ្នឹងវត្ថុនោះ អ្នកនោះក៏ចូលដល់នូវវត្ថុនោះឯង ។ អ្នកណាពោលថា យើងមានការយល់ឃើញថា លោកមានទីបំផុត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណាពោលថា យើងមានការយល់ឃើញថា លោកមិនមានទីបំផុត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។

អ្នកណាពោលថា យើងមានការយល់ឃើញថា ជីវៈ និងសរីរៈតែមួយដូចគ្នា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណា

ពោលថា យើងមានការយល់ឃើញថា ជីវៈ និងសរីរៈជារបស់ផ្សេងគ្នា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណាពោលថា យើងមានការយល់ឃើញថា សត្វទាំងឡាយស្លាប់ហើយ កើតទៀត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណាពោលថា យើងមានការយល់ឃើញថា សត្វស្លាប់ហើយមិនកើតទៀត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណាពោលថា យើងមានការយល់ឃើញថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ បុគ្គលណាពោលថា យើងមានការយល់ឃើញថា សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ ការយល់ឃើញរបស់អ្នកទាំងអស់នេះ កើតឡើងហើយព្រោះហេតុនៃការធ្វើទុកក្នុងចិត្ត ដោយឧបាយមិនប្រពៃរបស់ខ្លួនខ្លះ ឬព្រោះជឿការយោសនារបស់អ្នកដទៃជាបច្ច័យខ្លះ ការយើញនេះឯងកើតឡើងហើយ ដែលអាស្រ័យបច្ច័យតាក់តែងហើយ ដែលបច្ច័យ

ក.ឡើងហើយ កើតឡើងហើយព្រោះអាស្រ័យបច្ច័យ មិនថា វត្តុណានីមួយ ដែលកើតឡើងហើយ ដែលបច្ច័យតាក់តែងហើយ ដែលបច្ច័យ.កឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ វត្តុនោះមិនទៀង វត្តុណាមិនទៀង វត្តុនោះក៏ជាទុក្ខ ជាទីជាប់នៅរបស់បុរសនោះ ។ ការឃើញរបស់អ្នកទាំងអស់ កើតឡើងព្រោះហេតុនៃការធ្វើទុកក្នុងចិត្ត ដោយឧបាយមិនត្រូវទំនងរបស់ខ្លួនខ្លះ ព្រោះជឿការឃោសនារបស់អ្នកដទៃខ្លះ ។

កាលអនាថបិណ្ឌិកសេដ្ឋីពោលយ៉ាងនេះហើយ ពួកបរិព្វាជកទាំងនោះ បានពោលថា ម្នាលគហបតី ពួកយើងទាំងអស់គ្នា បានជ្រាប់ដល់ការយល់ឃើញរៀងៗខ្លួន ឲ្យលោកបានស្តាប់ហើយ នែគហបតី ការយល់ឃើញរបស់លោកដូចម្តេច ចូរជ្រាប់ឲ្យពួកយើងខ្ញុំ បានជ្រាបខ្លះផង ? អនាថបិណ្ឌិកសេដ្ឋីពោលបញ្ជាក់ថា អ្នកដ៏ចម្រើនទាំងឡាយ ក៏វត្តុណានីមួយ ដែលកើតឡើងហើយ ដែលបច្ច័យតាក់តែងហើយ ដែលបច្ច័យ.កឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ វត្តុនោះ

មិនទៀង វត្តុណាមិនទៀង វត្តុនោះជាទុក្ខ វត្តុណាជាទុក្ខ ខ្ញុំមានការ
យល់ឃើញនូវវត្តុនោះថា វត្តុនោះមិនមែនរបស់យើង វត្តុនោះមិនមែន
ជាយើង វត្តុនោះមិនមែនជាតួខ្លួនរបស់យើង ។ គ្រានោះ ពួកបរិព្វាជក
ទើបពោលថា ម្នាលគហបតី វត្តុណានីមួយដែលកើតឡើងហើយ ដែល
បច្ច័យតាក់តែងហើយ ដែលបច្ច័យ.ករឡើងហើយ កើតឡើងព្រោះ
អាស្រ័យបច្ច័យ វត្តុនោះមិនទៀង វត្តុណាមិនទៀង វត្តុនោះជាទុក្ខ
វត្តុណាជាទុក្ខ លោកគហបតី ជាអ្នកជាប់នៅជាមួយនឹងវត្តុនោះ លោក
ចូលដល់នូវវត្តុនោះឯង ។ អនាថបិណ្ឌិកសេដ្ឋីបានពោលអធិប្បាយថា
អ្នកជ័ចម្រើនទាំងឡាយ វត្តុណានីមួយ ដែលកើតឡើងហើយ ដែល
បច្ច័យតាក់តែងហើយ ដែលបច្ច័យ.ករឡើងហើយ កើតឡើងព្រោះ
អាស្រ័យបច្ច័យ វត្តុនោះមិនទៀង វត្តុណាមិនទៀង វត្តុនោះជាទុក្ខ
ខ្ញុំឃើញវត្តុនោះដោយបញ្ញា (ការដឹងដោយជុំវិញ) ដ៏ប្រពៃតាម
សេចក្តីពិតយ៉ាងនេះថា វត្តុនោះមិនមែនរបស់យើង វត្តុនោះមិនមែន
ជាតួខ្លួនរបស់យើង ទាំងដឹងនូវឧបាយដែលជាគ្រឿងរលាស់ចោលនូវ

វត្តនោះយ៉ាងកំពូលតាមសេចក្តីពិត ។

កាលអនាថបិណ្ឌិកសេដ្ឋី បានពោលអធិប្បាយហេតុផលយ៉ាងនេះ ហើយ ពួកបរិព្វាជកទាំងនោះ ក៏នាំគ្នាអង្គុយនៅស្ងៀម ដោយខ្មាសអៀន ដោយឱនមុខសំយុងចុះ មិនមានពាក្យអ្វីណានីមួយឆ្លើយឆ្លងមកទៀត បានឡើយ ហើយអនាថបិណ្ឌិកសេដ្ឋី ទើបក្រោកចាកទីនោះទៅ ហើយ ចូលទៅគាល់ព្រះភគវាជល់ទីគង់ប្រថាប់ ថ្វាយបង្គំរួចហើយ បានអង្គុយ ក្នុងទីដ៏សមគួរ ហើយក្រាបទូលចំពោះរឿងរ៉ាវ ដែលខ្លួនបានសន្ទនាគ្នា ជាមួយពួកអន្យតិ្ថរិយបរិព្វាជកទាំងនោះ ទាំងអស់ឲ្យព្រះអង្គទ្រង់ជ្រាប គ្រប់ប្រការ ។ គ្រានោះ ព្រះសម្មុទ្ទទ្រង់ប្រទានសាធុការថា ល្អហើយៗ គហបតី ដែលអាចកាច់ទិដ្ឋិពួកមោឃបុរសទាំងនោះ ឲ្យជាការមួយ ដ៏សមគួរ ដោយប្រពៃតាមធម៌ ហើយតពីនោះទៅ ព្រះសយម្ភូទ្រង់ ចង្អុលបង្ហាញដល់អនាថបិណ្ឌិកសេដ្ឋី ឲ្យឃើញច្បាស់ ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។ កាលអនាថបិណ្ឌិកសេដ្ឋីបានស្តាប់ធម្មីកថា ហើយ ទើបក្រាបថ្វាយបង្គំលា និងធ្វើប្រទក្សិណហើយចៀសចេញទៅ ។

អនាថបិណ្ឌិកសេដ្ឋីក្រាបថ្វាយបង្គំលាត្រឡប់ទៅមិនយូរប៉ុន្មាន ព្រះភគវា
ទើបទ្រង់ត្រាស់ជាមួយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា
បានដឹងច្បាស់នូវធម៌ដ៏មាំទាំក្នុងធម្មវិនៃយនេះ មកអស់កាលដ៏យូរហើយ
ភិក្ខុនោះ គប្បីសង្កត់សង្កិនពួកអន្យតិ្ថរិយបរិព្វាជកទាំងនោះ ឲ្យជាការ
សង្កត់សង្កិនដោយល្អ ដោយប្រពៃតាមធម៌ ដូចជាអនាថបិណ្ឌិកសេដ្ឋី
បានសង្កត់សង្កិនរួចហើយ ។

សច្ចវាចារបស់ព្រះអរិយបុគ្គល រមែងជាឯក (ពិត) ដូចដែល
អនាថបិណ្ឌិកសេដ្ឋី បានសន្យាជាមួយនឹង **នាងបុណ្ណាទាសី** តាមដែល
មានរៀងពោលទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថា
អធិប្បាយសេចក្តីបាលីនៃ **មាតាសូត្រ** ក្នុង **គម្ពីរអង្គុត្តរនិកាយ សត្តកនិបាត**
និងក្នុង **អដ្ឋកថាបបញ្ចសូទនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ
រថវិនីតសូត្រ នៅក្នុង **គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក:** តែក្នុងទីនេះ
សូមលើកយកសេចក្តីមកពោលតាមន័យនៅក្នុង **អដ្ឋកថាមនោរថបូរណី**
ដែលមានសេចក្តីតទៅថា ៖-

សម័យមួយ ព្រះសាស្តា ទ្រង់គង់ចាំវស្សូបនាយិកសមាបត្តិរួចហើយ ព្រះអង្គឲ្យអគ្គសាវ័កគង់នៅក្នុងវត្តជេតពន ដោយព្រះអង្គស្តេចយាងចេញពីវត្តជេតពន ដោយទ្រង់បំណងនឹងយាងចារិកទៅកាន់ទក្ខិណាគិរីជនបទ ។ គ្រានោះ ព្រះបាទបសេនទិកោសល អនាថបិណ្ឌិកសេដ្ឋី មហាឧបាសិកាវិសាខា និងបុគ្គលដទៃទៀតជាច្រើន គ្រប់ៗគ្នា មិនអាចនឹងក្រាបទូលអារាធនា ឲ្យព្រះមានជោគ ទ្រង់គង់ក្នុងទីនេះទៀតបាន ។ ចំណែកអនាថបិណ្ឌិកសេដ្ឋី ប្រារព្ធហេតុនោះ ទើបអង្គុយជញ្ជឹងគិតខ្វល់ក្នុងចិត្ត នៅត្រង់ទីកន្លែងមួយថា យើងមិនអាចនឹងក្រាបទូលអារាធនាឲ្យព្រះសាស្តា ទ្រង់គង់នៅក្នុងទីនេះទៀតបាន ។ ពេលនោះ នាងបុណ្ណទាសី បានក្រឡេកឃើញអនាថបិណ្ឌិកសេដ្ឋីហើយ ទើបជម្រាបសួរថា បពិត្រលោកសេដ្ឋី លោកមានឥន្ទ្រិយមិនផូរផង់ ដោយទឹកមុខស្រពាប់ស្រពោន តើមានហេតុអ្វី ? គ្រានោះ អនាថបិណ្ឌិកសេដ្ឋីតបថា ត្រូវហើយ នាងបុណ្ណទាសី តើឲ្យយើងសប្បាយដូចម្តេចទៅកើត បើព្រះមានជោគស្តេចយាងចារិកទៅហើយ ដោយយើងមិនអាចនឹងយាងព្រះសាស្តា

ឲ្យត្រឡប់មកវិញបាន ទាំងនៅមិនទាន់ជ្រាបថា ព្រះលោកនាយកនឹងយាងត្រឡប់មកវិញ ឬក៏អត់ទេ ព្រោះហេតុនោះ យើងទើបអង្គុយសញ្ជប់សញ្ជឹង ខ្វល់ចិត្តនៅត្រង់ទីនេះ ។ ពេលនោះ នាងបុណ្ណាទាសី បានសាកសួរអនាថបិណ្ឌិកសេដ្ឋីថា លោកសេដ្ឋី ប្រសិនបើនាងខ្ញុំក្រាបទូលអារាធនាយាងព្រះអង្គត្រឡប់មកវិញបាន តើលោកសេដ្ឋីឲ្យអ្វីជល់នាងខ្ញុំ ? អនាថបិណ្ឌិកសេដ្ឋីតបថា ប្រសិនបើជាយ៉ាងនោះមែន យើងនឹងឲ្យនាងជាអ្នកជា (គឺរួចអំពីភាពជាទាសីមួយរំពេច) ។ នាងបុណ្ណាទាសី កាលឮដូច្នោះហើយ ទើបប្រញាប់ទៅថ្វាយបង្គំ ក្រាបចុះទៀបព្រះបាទទាំងគូនៃព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ព្រះករុណាជ្រោសយាងត្រឡប់ទៅវិញ ព្រះអង្គ ។ គ្រានោះ ព្រះមុនីត្រាស់សួរថា ម្នាលនាងបុណ្ណាទាសី កាលតថាគតត្រឡប់ទៅវិញនោះ តើនាងធ្វើដូចម្តេច នាងបុណ្ណា ? នាងបុណ្ណាទាសី បានក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធអង្គក៏ជ្រាបហើយថា ខ្ញុំព្រះអង្គជាទាសីរបស់គេ ដោយការនៅបម្រើគេចិញ្ចឹមជីវិត ខ្ញុំព្រះអង្គមិនអាចនឹងធ្វើអ្វី

បានទេ (ព្រោះទេយ្យធម៌មិនមាន) តែខ្ញុំព្រះអង្គនឹងតាំងនៅក្នុងសរណាគមន៍ ព្រមទាំងរក្សាសីល ៥ ព្រះអង្គ ។ ពេលនោះ ព្រះជិនស្រីទ្រង់ប្រទានសាធុការថា ល្អហើយៗ នាងបុណ្ណាទាសី ហើយព្រះអង្គក៏ស្តេចយាងត្រឡប់មកវិញ ទាំងនេះព្រោះការធ្ងន់ក្នុងធម៌ ។ សមដូចមានព្រះពុទ្ធតម្រាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកធ្ងន់ក្នុងធម៌ ឬមានធម៌ជាទីគោរព ។

ព្រះបរមសាស្តា ស្តេចបានយាងត្រឡប់ចូលទៅកាន់វត្តជេតពនមហាវិហារវិញ ។ មហាជន កាលបើដឹងដូច្នោះហើយ ម្នាក់ៗ បានឲ្យសាធុការ សម្តែងនូវការកោតសរសើរដល់នាងបុណ្ណាទាសី ។ ព្រះសម្ពុទ្ធទ្រង់បានសម្តែងព្រះធម៌ប្រោសដល់ពួកពុទ្ធបរិស័ទទាំងនោះ ធ្វើឲ្យសត្វ ៨៤.០០០ បានផឹកនូវទឹកអម្រឹត ។

រឿងរបស់នាងបុណ្ណាទាសី ដែលអាចធ្វើការបានសម្រេចតាមបំណងរបស់លោកសេដ្ឋី ហើយនាងបានទទួលផលតបស្នងដ៏ប្រសើរដូចមានសម្តែងនៅក្នុង **អដ្ឋកថាបបញ្ចសូទនី** យ៉ាងពិស្តារថា ៖-

អនាថបិណ្ឌិកសេដ្ឋី បានឮអ្នកស្រុកនិយាយថា ព្រះមហាវីរៈ ដែលស្តេចយាងត្រឡប់មកវិញនេះ ក៏ព្រោះតែនាងបុណ្ណាទាសី ដូច្នេះ អនាថបិណ្ឌិកសេដ្ឋី ឃើញគុណសម្បត្តិរបស់នាងបុណ្ណាទាសីយ៉ាងនេះ ហើយ ទើបឲ្យនាងរួចផុតភាពជាទាសី ហើយតាំងនាងទុកក្នុងឋានៈជាធីតាទៀតផង ។

ភាពជាបុគ្គលមានការស្មោះត្រង់ចំពោះមិត្ត របស់អនាថបិណ្ឌិក-សេដ្ឋី ដោយលោកបានជួយស្រោចស្រង់មិត្តសម្លាញ់របស់លោក ដែលមានការប្រព្រឹត្តខុសផ្លូវ ឲ្យប្រែចិត្តមកប្រកបរបរក្នុងផ្លូវត្រូវវិញ ហើយទាំងនេះរាប់ថា ជាផលការងាររបស់លោក មួយរឿងទៀត ដែលលោកបានដឹកនាំបុគ្គលដែលរាប់អានលទ្ធិ របស់ពួកអន្យតិរ្ថិយ ឲ្យចូលមកប្តេជ្ញាខ្លួនជាឧបាសក រាប់អានព្រះពុទ្ធសាសនា ដូចមានរឿងសម្តែងប្រាកដនៅក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **អបណ្ណកជាតក** ក្នុង **គម្ពីរខុទ្ទកនិកាយជាតក** មានសេចក្តីថា ៖-

សម័យមួយ ព្រះជិនស្រី ស្តេចយាងទៅស្នាក់អាស្រ័យនៅក្នុង

ក្រុងសាវត្ថី ដោយព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន បានត្រាស់ព្រះធម្មទេសនាអបណ្ណកធម៌ (វត្ថុដែលមិនខុស) ដោយទ្រង់ប្រារព្ធចំពោះសាវ័កអន្យតិ្ថយ ៥០០ នាក់ ដែលជាសម្ងាញ់របស់អនាថបិណ្ឌិកសេដ្ឋីថា ថ្ងៃមួយ អនាថបិណ្ឌិកសេដ្ឋី បាននាំសាវ័កអន្យតិ្ថយ ៥០០ នាក់ ដែលជាសម្ងាញ់របស់ខ្លួន ឲ្យកាន់ផ្កា និងគ្រឿងក្រអូបជាច្រើន ព្រមទាំងប្រេង ទឹកឃ្មុំ ទឹកអំពៅ និងសំពត់ដែលជាគ្រឿងស្លៀកដណ្តប់ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តារួចហើយ នាំគ្នាបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ទាំងបានប្រគេនកេសជ្ជៈ និងសំពត់ជាគ្រឿងស្លៀកដណ្តប់ទាំងឡាយ ដល់កិក្ខុសង្ឃស្រេចហើយ អនាថបិណ្ឌិកសេដ្ឋី ក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ សូម្បីសាវ័ករបស់ពួកអន្យតិ្ថយទាំងនោះ កាលថ្វាយបង្គំព្រះសម្ពុទ្ធហើយ ក៏បានអង្គុយនៅជិតអនាថបិណ្ឌិកសេដ្ឋី ដោយពួកគេបានក្រឡេកមើលព្រះភក្ត្រនៃព្រះលោកនាថដែលផូរផង់ ប្រកបដោយសិរី ប្រៀបបីដូចជាដួងព្រះចន្ទ ដែលរះក្នុងថ្ងៃពេញបុណ្ណមី (១៥ កើត) ថែមទាំងសម្លឹងមើលព្រះវរកាយ ដែលប្រៀបបីដូចកាយនៃព្រហ្ម

ប្រកបដោយមហាបុរិសលក្ខណៈ និងអនុព្យញ្ជនៈ និងព្រះរស្មីផ្សាយចេញអំពីព្រះវរកាយ ប្រមាណ ១ ព្យាម ហើយពួកគេសម្លឹងមើលរស្មីព្រះពុទ្ធរង្សី ដែលផ្សាយចេញវិលជុំវិញជាគូៗ ។ ព្រះភគវាបានត្រាស់ធម្មកថា គឺព្រះវាចាដែលពោលដល់ធម៌ ដ៏ពីរោះវិចិត្រដោយន័យផ្សេងៗ ដូចជាសំឡេងព្រហ្ម ដែលគួរឲ្យចង់ស្តាប់ ប្រកបដោយអង្គ ៨ ដូចជារាជសីហ៍ជំទង់ កំពុងតែបន្ទឺសីហនាទ ដូចមេឃភ្លៀងដែលមានផ្គរគ្រហឹម ដូចទេវតាបណ្តាលឲ្យភ្លៀងធ្លាក់ចុះ និងដូចផ្តាក្រងកម្រងកែវ ។

ពួកសាវ័កអន្យតិ្ថយទាំងនោះ កាលបើស្តាប់ព្រះធម្មទេសនារបស់ព្រះមានជោគហើយ ក៏មានចិត្តជ្រះថ្លា ទើបក្រោកឡើងថ្វាយបង្គំព្រះមានបុណ្យ ដោយការបានប្រកាសក្នុងការឈប់រាប់អានសាសនាអន្យតិ្ថយជាសរណៈតទៅទៀត និងសូមដល់ព្រះពុទ្ធជាសរណៈ ។ ចាប់ពីថ្ងៃនោះតមក ពួកសាវ័កដែលជាអន្យតិ្ថយទាំងនោះ បាននាំគ្នាកាន់ផ្កា និងគ្រឿងក្រអូបជាដើមទៅវត្តជេតពន ជាមួយនឹងអនាថបិណ្ឌិក-សេដ្ឋី ហើយបានស្តាប់ព្រះធម៌ទេសនា និងដល់ព្រមដោយការថ្វាយទាន

និងសមាទានឧបោសថសីលអស់កាលជានិច្ច ។ កាលតមក ព្រះសយម្ភូ
ស្តេចយាងចេញអំពីក្រុងសាវត្ថី ទៅនគរាជគ្រឹះ ។ ពេលដែលព្រះអង្គ
ស្តេចយាងទៅហើយ ពួកសាវ័កដែលជាអន្យត្ថិយ ជាអ្នកគោរពរាប់អាន
ព្រះរតនត្រ័យនោះ ក៏បាននាំគ្នាឈប់គោរពរាប់អានព្រះរតនត្រ័យជា
សរណៈទៀត ហើយត្រឡប់ទៅគោរពរាប់អានសាសនាអន្យត្ថិយជា
សរណៈវិញ ដោយពួកគេប្រព្រឹត្តទៅក្នុងឋានៈ ដែលគេធ្លាប់រាប់អាន
ដូចពីមុននោះ ។ ចំណែកព្រះលោកនាយក ស្តេចយាងទៅគង់នៅក្នុង
នគរាជគ្រឹះ និងទីជនៃទៀត ប្រមាណ ៧-៨ ខែ ហើយព្រះអង្គស្តេចយាង
ត្រឡប់មកកាន់វត្តជេតពនវិញ នាក្រុងសាវត្ថីម្តងទៀត ។

អនាថបិណ្ឌិកសេដ្ឋី លុះបានជ្រាបការយាងត្រឡប់មកវិញ នៃ
ព្រះសាស្តាហើយ ទើបបាននាំពួកសាវ័កអន្យត្ថិយទាំងនោះ ចូលទៅ
ថ្វាយបង្គំព្រះមានជោគទៀត ដោយអនាថបិណ្ឌិកសេដ្ឋីបានបូជាចំពោះ
ព្រះសយម្ភូ ដោយគ្រឿងក្រអូប និងផ្កាជាដើម ថ្វាយបង្គំរួចហើយ
ក៏អង្គុយក្នុងទីដ៏សមគួរ ។ ចំណែកពួកសាវ័កបស់អន្យត្ថិយទាំងនោះ

ក៏នាំគ្នាថ្វាយបង្គំចំពោះព្រះមុនី រួចហើយក៏អង្គុយនៅក្នុងទីដ៏សមគួរ ។
គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានក្រាបទូលហេតុការណ៍ ដែលពួកគេទាំងនោះ បោះបង់ចោលក្នុងការគោរពរាប់អានព្រះរតនត្រ័យ តាំងពីពេលដែលព្រះទសពលស្តេចយាងទៅកាន់ទីដទៃម្ល៉ះ ហើយពួកគេទើបវិលត្រឡប់ទៅគោរពរាប់អាន ក្នុងលទ្ធិអន្យតិ្ថរិយជាសរណៈ ដូចដើមវិញ ។
ពេលដែលព្រះជិនស្រីទ្រង់ជ្រាបរឿងនោះហើយ ទើបបន្ទឺព្រះសូរសៀងដ៏ពីរោះ ប្រៀបបីដូចបើកប្រអប់កែវ ដែលពេញដោយគ្រឿងក្រអូបច្រើនប្រការ ដែលលាយគ្រឿងក្រអូបដ៏ជាទិព្វ ដោយអានុភាពនៃវចីសុចរិត ដែលព្រះពុទ្ធអង្គទ្រង់បំពេញមកជានិច្ចនិរន្តរ៍ អស់កោដិកប្បរាប់ប្រមាណមិនបាន ព្រះសាស្តាក៏បានត្រាស់សួរថា ម្នាលឧបាសក តថាគតបានឮថា អ្នកទាំងឡាយបានបោះបង់ចោលការគោរពរាប់អានព្រះរតនត្រ័យ ហើយត្រឡប់ទៅគោរពរាប់អានលទ្ធិអន្យតិ្ថរិយជាសរណៈដូចដើមវិញឬ ? កាលពួកគេមិនអាចនឹងបិទបាំងបាន ទើបក្រាបទូលតាមការពិតថា បពិត្រព្រះអង្គទ្រង់និរទុក្ខ ពិតយ៉ាងហ្នឹងហើយ ព្រះអង្គ ។

គ្រានោះ ព្រះលោកនាយក ត្រាស់អធិប្បាយថា ម្នាលឧបាសក ទាំងឡាយ ដែលបាននឹងឈ្មោះថា បុគ្គលដែលដូចគ្នានឹងព្រះពុទ្ធ ដោយគុណ ទាំងឡាយ មានសីលជាដើម រមែងមិនមាន ដែលរាប់តាំងពីអវីចីនរក ឡើងរហូតទៅដល់ភវគ្គព្រហ្ម (ព្រហ្មជាន់ខ្ពស់ គឺនេវសញ្ញានាសញ្ញា-យតនៈ) និងចំហៀងក្នុងលោកធាតុ (ចក្រវាឡ) ដែលរកប្រមាណ មិនបាន នឹងមាននរណាក្រៃលែងជាងព្រះអង្គឡើយ ទ្រង់បានប្រកាស គុណព្រះរតនត្រ័យ ដែលច្រោកដក្នុងសូត្រទាំងឡាយជាដើមថា ម្នាល ភិក្ខុទាំងឡាយ សត្វឥតជើង សត្វជើងពីរ សត្វជើង ៤ ឬសត្វមានជើង ច្រើនក្តី មាននៅប្រមាណប៉ុនណា ។ល។ ដែលគេពោលថា ព្រះតថាគត ជាបុគ្គលប្រសើរលើសជាងសត្វទាំងនោះ ។ ទ្រព្យ គឺគ្រឿងរីករាយចិត្ត ឯណានីមួយ ក្នុងលោកនេះ ឬលោកខាងមុខ ។ល។ បុគ្គលណាជ្រះថ្លាហើយ នូវវត្ថុដែលប្រសើរនោះ ហើយព្រះអង្គត្រាស់ថា ឧបាសក ឬឧបាសិកា ក៏ដោយ ដែលជាអ្នកគោរពរាប់អានព្រះរតនត្រ័យ ដែលប្រកបដោយគុណ ដ៏ឧត្តមយ៉ាងនេះជាសរណៈហើយ ដំណើរទៅកាន់នរកជាដើមមិនមាន

ជាអ្នកបានរួចផុតអំពីកំណើតអបាយភូមិ(ទីកន្លែងដែលមិនមានសេចក្តីចម្រើន បានដល់ នរក ប្រេត តិរច្ឆាន និងអសុរកាយ)ហើយជាអ្នកទៅកើតក្នុងទេវលោក ជាអ្នកបរិបូណ៌ដោយសម្បត្តិទិព្វ តែព្រោះហេតុអ្វី ព្រោះហេតុអ្នកទាំងនោះលះនូវសរណៈ គឺការគោរពរាប់អានក្នុងលទ្ធិរបស់ពួកតិរ្ថិយជាសរណៈ ។

ពិតណាស់ ក្នុងរឿងនេះ ដើម្បីសម្តែងដល់សត្វទាំងឡាយជាអ្នកដល់នូវព្រះរតនត្រ័យ ជាសរណៈហើយ ដោយអំណាចមោក្ខៈ(ការរួចផុតចាកកិលេស) និងឧត្តម (ប្រសើរបំផុត) ដោយមិនធ្វើឲ្យបុគ្គលនោះទៅកើតក្នុងអបាយភូមិ មានសូត្រអាងថា ៖-

ជនពួកណានីមួយ ជាអ្នកដល់នូវព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃជាសរណៈ ជាទីពឹង ជាទីពឹក ជនទាំងនោះ នឹងមិនទៅកាន់អបាយភូមិ ក្រោយពីស្លាប់ទៅហើយ នឹងជាអ្នកបានទទួលទិព្វសម្បត្តិ ។មនុស្សទាំងឡាយ មានចំនួនច្រើន កាលបើភ័យគ្រប សង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាម និងដើមឈើ និងចេតិយ

ទាំងឡាយខ្លះជាទីពឹង ។ទីពឹងនោះឯង មិនមែនជាទីពឹងដ៏ក្សេម មិនមែនជាទីពឹងដ៏ឧត្តម បុគ្គលមិនដែលរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនោះទេ ។ បុគ្គលណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ជាទីពឹង ជាទីរឭក ហើយឃើញនូវអរិយសច្ចទាំង ៤ គឺ សេចក្តីទុក្ខ ១ សមុទយៈជាដែនកើតឡើងព្រមនៃសេចក្តីទុក្ខ ១ និរោធ ជាទីកន្លងបង់នូវសេចក្តីទុក្ខ ១មគ្គមានអង្គ ៨ ដ៏ប្រសើរ ដែលញុំាងសត្វ ឲ្យដល់នូវព្រះនិព្វាន ជាស្ថានរំងាប់បង់នូវសេចក្តីទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ ។ ទីពឹងនោះឯង ជាទីពឹងដ៏ក្សេម ទីពឹងហ្នឹងឯងជាទីពឹងដ៏ឧត្តម (របស់បុគ្គលនោះ) បុគ្គលរមែងរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។

ព្រះបរមគ្រូ មិនមែនតែទ្រង់នឹងសម្តែងធម៌ ឲ្យដល់គេត្រឹមតែនយប៉ុណ្ណោះទេ ដោយទ្រង់សម្តែងព្រះធម៌ ដោយនយផ្សេងៗ ទៀតជាច្រើន ដូចមានសេចក្តីថា ៖-

ម្នាលឧបាសកទាំងឡាយ កម្មដ្ឋានដែលប្រារព្ធនូវពុទ្ធានុស្សតិ

ធម្មានុស្សតិ សង្ឃានុស្សតិ រមែងឲ្យបានសោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ ឲ្យបានសម្រេចអរហត្តផល ។ ហើយព្រះពុទ្ធអង្គត្រាស់ទៀតថា ឈ្មោះថា សរណៈ គឺជាទីពឹង ជាទីរឭកនោះ បានដល់ ព្រះរតនត្រ័យ ដែលអ្នកទាំងឡាយ បានលះបង់នូវការគោរពរាប់អាន ទាំងនេះរាប់ថា ជាការធ្វើមិនសមគួរបស់អ្នកទាំងឡាយឡើយ ។ ម៉្យាងទៀត ពពួកសត្វដែលមាននូវពុទ្ធានុស្សតិ ជាកម្មដ្ឋានជាដើម មកជាអារម្មណ៍ រមែងបានសម្រេចអរិយធម៌ មានព្រះសោតាបត្តិមគ្គជាដើម គួរសម្តែងសូត្រទាំងឡាយ ឲ្យឃើញថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាឯក ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកវាគៈ (សេចក្តីតម្រេកក្នុងកាម) ដើម្បីការរំលត់ ដើម្បីសេចក្តីស្ងប់ ដើម្បីការដឹងដ៏ក្រៃលែង ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វាន (ការរំលត់កិលេស និងកងទុក្ខ) ធម៌ឯក បានដល់អ្វី ? បានដល់ពុទ្ធានុស្សតិ គឺការរឭកដល់ព្រះពុទ្ធ ។

កាលព្រះលោកនាយក បានត្រាស់ប្រៀនប្រដៅដល់ពួកឧបាសក ដោយប្រការផ្សេងៗ ដូច្នេះហើយ ទើបត្រាស់បញ្ជាក់ថា ៖-

ម្នាលឧបាសកទាំងឡាយ សូម្បីកាលមុន ពួកមនុស្សដោយច្រើនតែងតែគោរងយកវត្ថុ ដែលមិនមែនជាសរណៈមកហើយ ដោយប្រកាន់តាមការរិះគិតនូវការប្រកាន់ខុសជាសរណៈ ទើបត្រូវក្លាយជាអាហាររបស់យក្ខ នៅក្នុងផ្លូវកន្តារ ដែលពួកអមនុស្សអាស្រ័យនៅ បានធ្វើឲ្យដល់នូវសេចក្តីវិនាសដល់បុរសទាំងនោះ ។ ចំណែកពួកមនុស្ស ដែលប្រកាន់មិនខុស ប្រកាន់ផ្លូវដែលត្រូវតែម្យ៉ាង ក៏បានចូលដល់ភាពជាសុខសាន្តក្នុងផ្លូវកន្តារនោះ ។ កាលព្រះសម្ពុទ្ធ ទ្រង់ត្រាស់បញ្ជាក់ ដូច្នេះហើយ ទើបទ្រង់នៅស្ងៀម ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋីក្រោកឡើងពីអាសនៈ ហើយថ្វាយបង្គំព្រះជិនស្រី ដោយក្រាបទូលសរសើរ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលពួកឧបាសកទាំងនេះឈប់គោរពរាប់អានសរណៈដ៏ឧត្តមហើយ ដោយទៅគោរពរាប់អានសរណៈរបស់គេដូចដើមវិញ ដោយការគិតឃើញខុស ខ្ញុំកុរណាបានឃើញច្បាស់ ក្នុង

ពេលឥឡូវនេះហើយ ព្រះអង្គ តែការវិនាសរបស់ពួកមនុស្ស ដែលប្រកាន់ការគិតឃើញខុស ក្នុងផ្លូវកន្លារ ដែលពួកអមនុស្សអាស្រ័យនៅនិងភាពសួស្តីរបស់ពួកមនុស្ស ដែលមានការគិតឃើញត្រូវ ក្នុងកាលមុននោះ ខ្ញុំព្រះអង្គទាំងឡាយ មានសេចក្តីជ្រាបច្បាស់ជាក់ ព្រះអង្គ ។

ទើបព្រះមានព្រះភាគត្រាស់អតីតនិទាន ឲ្យអនាថបិណ្ឌិកសេដ្ឋីនិងឧបាសកទាំងនោះ បានស្តាប់ (នឹងសូមលើកយកមកពោលដោយសេចក្តីសង្ខេបក្នុងទីនេះ) ដូចមានសេចក្តីថា ៖-

ក្នុងអតីតកាល ដែលគ្រប់គ្រងរាជសម្បត្តិ ដោយព្រះបាទព្រហ្មទត្ត នៅក្នុងក្រុងពារាណសី ក្នុងកាលនោះ មាននាយឈ្មួញ ២ នាក់ ម្នាក់ៗ មានក្រុមពួករទេះជាបរិវារ ៥០០ រទេះ ។ នាយឈ្មួញម្នាក់ ជាបុគ្គលល្ងង់ខ្លៅ ជាអ្នកមានការគិតឃើញខុសថា គង់នឹងជាយ៉ាងនោះមែន ។ ហើយគ្រាមួយ គេបាននាំពួកក្រុមរទេះប្រមាណ ៥០០ រទេះ ផ្ទុកដោយទំនិញ ធ្វើដំណើរចេញទៅជួញ តែក្នុងរវាងផ្លូវ មានពួកយក្ខកើតក្នុងព្រៃ ធ្វើជាមនុស្សមកប្រាប់ថា ចំពោះផ្លូវកន្លារនេះ ពេលនេះឈប់លំបាកហើយ

ពីព្រោះមានភ្លៀងធ្លាក់ ទឹក និងស្មៅបរិបូណ៌ ពួកលោកចូរនាំគ្នាចោលទឹក និងស្មៅដែលនាំមកនោះ ឲ្យអស់ទៅ ទើបអាចធ្វើដំណើរទៅបានយ៉ាងរហ័ស ។ នាយឈ្មួញល្ងង់ខ្លៅ ក៏បានជាក់ចិត្តជឿ ដោយធ្វើតាមពាក្យដែលយក្ខិនីបានប្រាប់ ដែលនាងបានក្រឡាខ្លួនធ្វើជាមនុស្ស លុះធ្វើដំណើរទៅដល់ផ្លូវកន្តារនោះហើយ ទើបបានដឹងខ្លួនថា ត្រូវចាញ់បោកពពួកជនទាំងនោះ ពីព្រោះមិនមានទឹក និងស្មៅ តាមដូចដែលបានប្រាប់នោះទេ ធ្វើឲ្យពួកបរិវារបស់គេ ត្រូវអស់ទឹក ទាំងគោរបស់ពួកគេក៏មិនមានទឹកផឹក និងស្មៅស៊ី រាងកាយក៏ទន់ខ្សោយ មិនមានកម្លាំងនឹងអាចដើរទៅមុខបាន ។ កាលជាទីបំផុត ទាំងមនុស្ស និងសត្វពាហនៈបានត្រូវយក្ខិនីចាប់ស៊ីទាំងអស់ នៅសល់តែគំនរឆ្អឹងរាត់រាយ នៅក្នុងរវាងផ្លូវកន្តារនោះឯង ។

ចំណែកនាយឈ្មួញដែលជាអ្នកឆ្លាត បានទូន្មានពពួកបរិវារថា ពួកអ្នកទាំងអស់គ្នាកុំឲ្យជឿនរណាងាយៗ ទោះមាននរណាមកប្រាប់ថា នៅខាងមុខមានភ្លៀងធ្លាក់នោះ ចូរនាំគ្នាពិចារណាមើលមេឃសិន បើត្រូវ

ទំនង ឬមានសភាពដូចជាភ្លៀងធ្លាក់មែន ដោយមានពពកខ្មៅ ផ្លេកបន្ទោរ
នុះឆ្វៀលធ្វាត់ ទាំងផ្គរលាន់ក៏គ្រហឹម បើមានហេតុយ៉ាងនេះមែន ប្រាកដ
ជាមានភ្លៀងមែនហើយ ទាំងនេះជាបទពិចារណាសម្រាប់អ្នកទាំងឡាយ
ទោះបីមាននរណាមកប្រាប់ក្នុងរឿងនេះ ចូរពួកអ្នកទាំងអស់គ្នា ប្រាប់ឲ្យ
យើងបានដឹងផង ឬទាំងការទទួលបន្ទែដែលពួកអ្នកទាំងអស់គ្នា មិនស្គាល់
ក្រែងបរិភោគទៅហើយមានជាតិពុល ។ ពួកឈ្មួញរនេះដែលជាអ្នកធ្លាត
ទាំង ៥០០ រនេះនោះ ដែលធ្វើដំណើរឆ្លងកាត់ផ្លូវកន្តារ ក៏ឆ្លងផុតទៅដោយ
សុវត្ថិភាព ពពួកយក្ខដែលនិយាយបោកបញ្ឆោតនាយឈ្មួញល្ងង់ខ្លៅទាំង
៥០០ រនេះ ដែលធ្វើដំណើរចេញទៅមុននោះ មិនអាចនិយាយបោកបញ្ឆោត
ឲ្យពួកឈ្មួញ ដែលជាអ្នកធ្លាតទាំង ៥០០ រនេះនោះជឿបាន ទាំងនេះ
ព្រោះពួកឈ្មួញរនេះទាំងនោះមិនជឿការនិយាយ ពួកគេបានពិចារណា
ហេតុផលត្រូវទំនង ។ គ្រានោះ ព្រះលោកនាយក ទ្រង់ត្រាស់និទាន
ក្នុងរឿងនេះចប់ហើយ ទើបទ្រង់ត្រាស់បញ្ជាក់ថា ម្នាលគហបតី ក្នុង
កាលមុន បុគ្គលព្រោះតែជឿដោយការស្មានខុស ដូច្នេះហើយ ទើបចូល

ដល់នូវសេចក្តីវិនាស ។

រីឯបុគ្គលមិនជឿដោយការយល់ហេតុផល ទើបអាចធ្វើឲ្យខ្លួនរួចផុតអំពីកណ្តាប់ដៃរបស់ពួកយក្ខ ក៏បានធ្វើដំណើរទៅដោយសុវត្ថិភាព ត្រឡប់មកដល់ផ្ទះវៀងៗខ្លួន ហើយព្រះអង្គទ្រង់ត្រាស់ព្រះធម្មទេសនាអបណ្ណកធម៌ ហើយព្រះវិជិតមារ ទ្រង់បានសម្តែងបដិបទា ដែលធ្វើឲ្យជួបកុសលសម្បត្តិ ៣ ប្រការ និងព្រហ្មលោក សម្បត្តិក្នុងស្ថានសួគ៌ជាន់កាមាវចរៈ ៦ ជាន់ ដល់ឧបាសកទាំងនោះ ហើយជាទីបំផុតទ្រង់ត្រាស់ដល់ផ្លូវដែលបដិបត្តិមិនខុស គឺអរហត្តផល ទ្រង់ត្រាស់ដល់បដិបទា គឺផ្លូវដែលធ្វើឲ្យទៅកើតក្នុងអបាយភូមិទាំង ៤ និងកើតនៅក្នុងត្រកូលទាបថោក ដែលជាផ្លូវបដិបត្តិខុស ហើយព្រះអង្គទ្រង់ប្រកាសអរិយសច្ចធម៌ទាំង ៤ ប្រការ ។ កាលព្រះលោកនាយក ទ្រង់ត្រាស់អរិយសច្ចធម៌ទាំង ៤ ចប់ហើយ ឧបាសកទាំង ៥០០ នាក់នោះ បានសម្រេចព្រះអរហត្តផល (ហើយពួកឧបាសកទាំងនោះមិនត្រឡប់ទៅកាន់លទ្ធិអន្យតិ្ថយតទៅទៀតឡើយ ទាំងនេះក៏ព្រោះតែមកអំពីអនាថ-

បិណ្ឌិកសេដ្ឋីជាអ្នកដឹកនាំទៅក្នុងផ្លូវត្រូវ) ។

កាលតមកជាខាងក្រោយ អនាថបិណ្ឌិកសេដ្ឋី តែងតែមានអ្នកដទៃអញ្ជើញលោកឲ្យទៅចូលរួមនៅក្នុងកម្មវិធីបុណ្យផ្សេងៗ យ៉ាងមមាញឹករហូតដល់មិនមានពេលទំនេរ ក៏បានឲ្យកូនស្រីរបស់លោកទទួលនាទីក្នុងការចាត់ចែងថ្វាយចង្ហាន់ចំពោះព្រះភិក្ខុសង្ឃ ដែលនិមន្តមកកាន់ផ្ទះរបស់ខ្លួន ដូចមានរឿងសម្តែងនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **យមកវគ្គ** ក្នុងរឿង **នាងសុមនាទេវី** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះមានជោគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ទ្រង់បានត្រាស់ធម្មទេសនាប្រារព្ធនាងសុមនាទេវី ដូចមានសេចក្តីថា ឯផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី តែងតែមានភិក្ខុសង្ឃមកឆាន់ជាប្រចាំពីរពាន់អង្គជារៀយៗ រីឯផ្ទះមហាឧបាសិកាវិសាខាក៏មានសភាពនោះដូចគ្នាដែរ ។ កាលបើមានបុគ្គលណា ឬក៏អ្នកណានៅក្នុងក្រុងសាវត្ថីបានធ្វើបុណ្យ បុគ្គលនោះៗ តែងតែទៅអញ្ជើញអនាថបិណ្ឌិកសេដ្ឋី និងនាងវិសាខាមកចូលរួមក្នុងកម្មវិធីបុណ្យនោះ ។

មានពាក្យសួរថា ព្រោះហេតុអ្វី ? មានពាក្យឆ្លើយថា ប្រសិនបើមានបុគ្គលដទៃៗ សួរ (ម្ចាស់ទាន) ថា អនាថបិណ្ឌិកសេដ្ឋី ឬមហាឧបាសិកាវិសាខាអញ្ជើញមកចូលរួមទានរបស់អ្នកដែរឬ បើអ្នកម្ចាស់ទានឆ្លើយថាមិនបានមកទេ សូម្បីទានដែលអ្នកថ្វាយដោយលះទ្រព្យដល់ទៅ ១ សែនកហាបណៈ ថ្វាយជាទានហើយក៏ដោយ អ្នកទាំងនោះរមែងតិះដៀលថា នេះជាទានស្អី ទាំងនេះព្រោះតែអ្នកទាំងពីរនោះ មិនបានចូលរួមជាមួយដោយម្យ៉ាងទៀត លោកទាំងពីរនោះរមែងជីងអធ្យាស្រ័យរបស់កិក្ខុសង្ឃនិងកិច្ចដែលសមគួរដល់កិក្ខុសង្ឃហើយ កាលបើលោកទាំងពីរនាក់នៅ (រួមធ្វើបុណ្យផង) កិក្ខុសង្ឃទាំងឡាយ រមែងឆាន់របស់តាមគាប់ចិត្តនោះឯង ព្រោះដូច្នោះ គ្រប់ៗគ្នា កាលដែលមានបំណងនឹងធ្វើបុណ្យតែងតែទៅអញ្ជើញអ្នកទាំងពីរនោះ ឲ្យមកចូលរួមជាមួយ ហេតុដូច្នេះហើយ ទើបធ្វើឲ្យអ្នកទាំងពីរនាក់នោះ មិនសូវបាននៅផ្ទះទំនុកបម្រុងកិក្ខុសង្ឃ ដោយហេតុដូច្នេះឯង ។

ព្រោះហេតុនោះ ឧបាសិកាវិសាខា បានពិចារណាថា នរណាហ្ន៎

អាចអង្គាសភិក្ខុសង្ឃជំនួសយើងបាន ពិចារណាទៅៗ ក៏បានឃើញចៅស្រី សមគួរជល់ហាន:នេះ ទើបប្រាប់ឲ្យចៅស្រីជំនួស ក្នុងការអង្គាសភិក្ខុសង្ឃ ដែលមកកាន់ផ្ទះរបស់ខ្លួន ដោយចង្ហាន់បិណ្ឌបាត ។ ចំណែកអនាថបិណ្ឌិកសេដ្ឋី ក៏បានពិចារណាក្នុងរឿងនេះដែរ ហើយក៏បានតាំងធីតាច្បង ដែលឈ្មោះថាមហាសុភទ្ទា ឲ្យជាអ្នកជំនួស ក្នុងការអង្គាសចង្ហាន់បិណ្ឌបាតភិក្ខុសង្ឃទាំងឡាយ ដែលនិមន្តមកកាន់ផ្ទះរបស់ខ្លួន ដោយឲ្យធ្វើកិច្ចការងារនេះជំនួសបិតា ។ រីឯនាងមហាសុភទ្ទា កាលបើបានទទួលនាទីនោះហើយ នាងក៏មានការខ្វល់ខ្វាយ ក្នុងការអង្គាសចង្ហាន់បិណ្ឌបាតជល់ភិក្ខុសង្ឃទាំងឡាយ ហើយថ្ងៃមួយ នាងបានស្តាប់ព្រះធម៌ទេសនា ក៏បានសម្រេចជាព្រះសោតាបន្ន ក្នុងកាលជាខាងក្រោយមក នាងក៏មានស្វាមី ហើយនាងក៏បានទៅរស់នៅក្នុងត្រកូលស្វាមីរបស់នាងទៅ ។ ព្រោះហេតុដូច្នោះ អនាថបិណ្ឌិកសេដ្ឋី ទើបបានតាំងនាងចុល្លសុភទ្ទាជំនួស ក្នុងតំណែងរបស់នាងមហាសុភទ្ទាវិញ ។ សូម្បីនាងចុល្លសុភទ្ទា ក៏មានប្រក្រតីធ្វើដូចជានាងមហាសុភទ្ទាជារៀយៗ

ដូចគ្នា ហើយកាលនាងចុល្លសុភទ្ទាបានសម្រេចជាព្រះសោតាបន្នហើយ ក្នុងកាលជាខាងក្រោយ នាងក៏មានស្វាមី នាងក៏បានទៅនៅក្នុងត្រកូលរបស់ស្វាមីនាងទៅ ។កាលតមក អនាថបិណ្ឌិកសេដ្ឋីក៏បានតាំងកូនស្រីពៅដែលមានឈ្មោះថា នាងសុមនាទេវី ឲ្យមើលការខុសត្រូវដូចគ្នានឹងនាងមហាសុភទ្ទា និងនាងចុល្លសុភទ្ទា ដែលធ្វើកន្ទងរួចមកហើយ ។ ចំណែកនាងសុមនាទេវី ក៏ពេញចិត្តក្នុងកិច្ចការងារទាំងនោះ ដោយសេចក្តីជ្រះថ្លា ក្នុងថ្ងៃមួយ នាងបានស្តាប់ព្រះធម៌ទេសនាហើយ ក៏បានសម្រេចជាសកទាគាមិផល នៅក្នុងភាពជាកុមារិកានៅឡើយ កាលតមកជាខាងក្រោយ នាងសុមនាទេវីក៏ធ្លាក់ខ្លួនឈឺ រហូតដល់ទទួលទានថ្នាំមិនបានសម្រាន្តមិនលក់ នាងក៏មានបំណងនឹងចង់ជួបអនាថបិណ្ឌិកសេដ្ឋីដែលជាបិតារបស់នាង ទើបឲ្យមនុស្សទៅអញ្ជើញបិតាមកជួប ។ រីឯអនាថបិណ្ឌិកសេដ្ឋី លុះបានជ្រាបដំណឹងថា សុមនាទេវីជាកូនស្រីពៅមានជំងឺធ្ងន់ ចង់ជួបនឹងខ្លួន ទើបចូលទៅរក ហើយសួរថា សុមនាកូនតើកូនកើតអី ?គ្រានោះ នាងសុមនាទេវីតបថា មិនកើតអ្វីទេបុនប្រុស ។

កាលអនាថបិណ្ឌិកសេដ្ឋី បានឮដូច្នេះហើយ ក៏សួរចំពោះកូនស្រីដោយការតក់ស្លុតក្នុងចិត្តថា កូនឯងកើតការរវើរវាយហើយ ។ នាងសុមនាឆ្លើយថា ខ្ញុំមិនបានរវើរវាយទេបុនប្រុស អនាថបិណ្ឌិកសេដ្ឋីសួរតទៅទៀតថា កូនខ្លាចឬកូន ? នាងសុមនាឆ្លើយថា ខ្ញុំមិនបានខ្លាចទេបុនប្រុស ។ នាងសុមនាទេវីពោលឆ្លើយឆ្លងបានត្រឹមតែប៉ុណ្ណេះ នាងក៏អស់ជីវិតទៅ ។

អនាថបិណ្ឌិកសេដ្ឋី សូម្បីជាព្រះសោតាបន្ន ក៏មិនអាចនឹងអត់ធន់ចំពោះសេចក្តីយំសោក ដែលកើតឡើងព្រោះតែនាងសុមនាទេវី ធ្វើកាលកិរិយាទៅ លោកសេដ្ឋីក៏បានឲ្យគេចាត់ចែងបូជាសព របស់នាងសុមនាទេវីរួចស្រេចហើយ បានចូលទៅគាល់ព្រះភគវា ទាំងមានមុខជោកជាំទៅដោយទឹកភ្នែក ។ គ្រានោះ ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលគហបតី តើលោកមានបញ្ហាអ្វីមិនសប្បាយចិត្ត បានជាមានទឹកមុខជោកជាំទៅដោយទឹកភ្នែក តើមានហេតុអ្វី ? គ្រានោះ អនាថបិណ្ឌិកសេដ្ឋីបានក្រាបទូលចំពោះព្រះសាស្តាឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដែលខ្ញុំព្រះអង្គមានមុខទទឹកទៅដោយទឹកភ្នែកនេះ ពីព្រោះមកពីសុមនាទេវី

កូនស្រីពៅរបស់ខ្ញុំ ធ្វើកាលកិរិយាទៅហើយ ព្រះអង្គ ។ គ្រានោះ ព្រះជិនស្រីទ្រង់ត្រាស់សួរថា បើដូច្នោះ ព្រោះហេតុអ្វី បានជាលោកគហបតីសោកស្តាយចំពោះនាងសុមនាទេវី ពីព្រោះថា សេចក្តីស្លាប់របស់សព្វសត្វមានពិតប្រាកដមិនមែនឬ ? អនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា សេចក្តីនេះខ្ញុំព្រះករុណាជ្រាបហើយ ព្រះអង្គ តែកូនស្រីពៅរបស់ខ្ញុំព្រះករុណា ជាអ្នកសម្បូណ៌ទៅដោយហិរិ (ការខ្មាសចំពោះបាប) និងឱត្តប្ប: (ការខ្លែងខ្លាចបាប) បែបនេះព្រះអង្គ តែជិតនឹងស្លាប់ កូនស្រីពៅរបស់ខ្ញុំព្រះអង្គ មិនអាចនឹងគ្រប់គ្រងសតិស្មារតីបាន នាងក៏បាននិយាយរវើរវាយ ហើយក៏ស្លាប់ទៅ ដោយហេតុនេះ ទើបសេចក្តីសោកកើតមានដល់ខ្ញុំព្រះករុណា ព្រះអង្គ ។

គ្រានោះ ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលគហបតី តើនាងសុមនាទេវីនិយាយរវើរវាយយ៉ាងណា ? អនាថបិណ្ឌិកសេដ្ឋីបានក្រាបទូលតបថា បពិត្រព្រះអង្គទ្រង់និរទុក្ខ ខ្ញុំព្រះករុណាសួរនាងថា កូនសុមនា តើកូនកើតអ្វី លំដាប់នោះ នាងនិយាយជាមួយនឹងខ្ញុំថា មិនកើតអីទេ ឪពុកប្រុស

កាលខ្ញុំព្រះករុណាសួរថា កូនមានចិត្តរវើរវាយទៅហើយឬ នាងក៏តបថា ប្អូនប្រុស ខ្ញុំមានចិត្តមិនបានរវើរវាយទេ កាលខ្ញុំព្រះករុណាសួរថា សុមនា កូនខ្លាចឬ នាងក៏តបថា មិនខ្លាចទេប្អូនប្រុស នាងពោលបានត្រឹមតែប៉ុណ្ណេះ ក៏ធ្វើកាលកិរិយាទៅ ព្រះអង្គ ។ លំដាប់នោះ ព្រះសយម្ភូទើបត្រាស់ប្រាប់អនាថបិណ្ឌិកសេដ្ឋីថា ម្នាលគហបតី សុមនាកូនស្រីពៅរបស់លោក ជាអ្នកមិនមានចិត្តរវើរវាយទេ ។ អនាថបិណ្ឌិកសេដ្ឋីទើបក្រាបទូលសួរថា បើជាយ៉ាងនោះមែន ហេតុអ្វីក៏នាងនិយាយដូច្នោះព្រះអង្គ ? ព្រះលោកនាថត្រាស់តបថា ព្រោះលោកជាប្អូនប្រុសនាងដោយពិត (នាងទើបនិយាយជាមួយនឹងលោកដូច្នោះ) ម្នាលគហបតី ដែលនាងសុមនា ហៅលោកដូច្នោះ គឺហៅទៅតាមគុណធម៌ ព្រោះលោកបានត្រឹមតែសោតាបន្ន ចំណែកនាងសុមនា នាងបានសម្រេចជាសកទាគាមី ទើបបានជានាងពោលដូច្នេះ នាងជាធំដោយមគ្គ និងផល ។

អនាថបិណ្ឌិកសេដ្ឋី ទើបក្រាបទូលសួរថា យ៉ាងនោះមែនឬព្រះអង្គ ? ព្រះលោកនាថត្រាស់តបថា ពិតយ៉ាងនោះហើយ គហបតី ។

អនាថបិណ្ឌិកសេដ្ឋីបានក្រាបទូលសួរដល់នាងសុមនាទេវី ដែលជាកូនស្រីពៅថា បពិត្រព្រះអង្គដ៏ចម្រើន តើពេលនេះ សុមនាទេវី នាងទៅកើតក្នុងទីណា ព្រះអង្គ ? ព្រះទសពលត្រាស់តបថា ម្នាលគហបតី នាងទៅកើតក្នុងស្ថានតុសិតហើយ ។ អនាថបិណ្ឌិកសេដ្ឋីទើបក្រាបទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចម្រើន តើកូនស្រីពៅរបស់ខ្ញុំព្រះករុណាជាអ្នកវីរភាយ ដូចកាលដែលគេនៅជាមួយនឹងពួកញាតិក្នុងលោកនេះ ចុះភាពវីរភាយនេះ មានចំពោះគេដែរឬទេព្រះអង្គ ក្នុងទេវលោកនោះ ? គ្រានោះ ព្រះសាស្តាត្រាស់ជាមួយនឹងអនាថបិណ្ឌិកសេដ្ឋីថា ត្រូវហើយ ម្នាលគហបតី គ្រហស្ថ ឬបព្វជិត ជាអ្នកមិនមានសេចក្តីប្រមាទ រមែងវីរភាយក្នុងលោកនេះផង និងលោកខាងមុខផងយ៉ាងពិតប្រាកដ រួចហើយ ព្រះពុទ្ធអង្គទើបត្រាស់ព្រះគាថាក្នុងធម្មបទថា

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរ ក្នុងលោកទាំងពីរ គឺ ត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងត្រេកអរ ដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើ

មរណកាលទៅកាន់សុគតិភព ក៏រីងរឹតតែត្រេកអរជ៏ក្រៃលែង ។

ក្នុងពេលដែលព្រះវិជិតមារ ទ្រង់ត្រាស់ទេសនានេះចប់ហើយ មានបុគ្គលជាច្រើន បានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។ ព្រះធម្មទេសនានេះ ក៏បានជាប្រយោជន៍ដល់មហាជន ដែលមកប្រជុំគ្នាក្នុងទីនោះ ។

ភាពជាអ្នកវិះគិតចាប់ផ្តើម រកនូវវត្ថុដែលគួរធ្វើសក្ការបូជាទុកជំនួសព្រះលោកនាថ របស់អនាថបិណ្ឌិកសេដ្ឋី ដូចមានរឿងសម្តែងនៅក្នុង **អដ្ឋកថា គម្ពីរខុទ្ទកនិកាយជាតក** នៃ **កលិង្គជាតក** ថា ៖-

សម័យមួយ ព្រះមានជោគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ហើយព្រះសាស្តា បានស្តេចយាងចារិកចៀសចេញពីវត្តជេតពនទៅកាន់ជនបទនានា ដោយមានព្រះពុទ្ធបំណងនឹងសង្គ្រោះដល់វិនេយ្យសត្វ (សត្វដែលគួរទូន្មានប្រៀនប្រដៅបាន) ។ ពពួកអ្នកស្រុកក្រុងសាវត្ថី ក៏បាននាំគ្នាកាន់គ្រឿងសក្ការៈទាំងឡាយ មានផ្កាឈើនិងគ្រឿងក្រអូបជាដើមទៅឯវត្តជេតពន កាលដែលមិនមានកន្លែងដែល

គួរជាក់បូជានោះ ទើបនាំគ្នាយកគ្រឿងសក្ការៈទាំងនោះទៅជាក់ត្រង់ទ្វារ
ព្រះគន្ធកុដិនៃព្រះទសពល ហើយក៏ត្រឡប់ទៅវិញ ។ ការធ្វើបែបនេះ
របស់ពួកអ្នកក្រុងសាវត្ថី ដែលគ្រាន់តែយកគ្រឿងសក្ការៈទៅជាក់គោរព
បូជាទុកនៅត្រង់មុខទ្វារព្រះគន្ធកុដិ រមែងមានចិត្តរីករាយយ៉ាងខ្លាំង ។
គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានឃើញហេតុដូច្នេះហើយៗ ក្នុងពេល
ដែលព្រះសយម្ភូ ស្តេចយាងត្រឡប់មកគង់ប្រថាប់ឯវត្តជេតពនវិញ
អនាថបិណ្ឌិកសេដ្ឋីទើបចូលទៅរកព្រះអានន្ទ ហើយពិតថេរាចាឡើងថា
បពិត្រលោកម្ចាស់អានន្ទដ៏ចម្រើន វិហារនេះ ពេលដែលព្រះសាស្តា
ស្តេចយាងចារិកចៀសចេញទៅហើយ រមែងជ្រុសចាកទីពឹងពំនាក់របស់
ជនទាំងឡាយដែលជ្រះថ្លា ដោយមិនមានស្ថានទីដែលគួរធ្វើសក្ការបូជា
មានផ្ការឈើ និងគ្រឿងក្រអូបជាដើមនោះ បើមានកន្លែងណាមួយគង់
និងជាការល្អ ប្រសិនបើលោកម្ចាស់អានន្ទដ៏ចម្រើន ក្រាបទូលរឿងនេះ
ឲ្យព្រះសម្ពុទ្ធទ្រង់ជ្រាប ហើយព្រះជិនស្រី ព្រះអង្គទ្រង់ត្រាស់អនុញ្ញាត
ស្ថានទីដែលគួរធ្វើសក្ការគោរពបូជានៅត្រង់ណា ពួកយើងនឹងនាំគ្នា

ទៅធ្វើសក្ការគោរពបូជា ដើម្បីជាប្រយោជន៍ និងដើម្បីសេចក្តីសុខ លោកម្ចាស់ ។ ព្រះអានន្ទត្ថេរ បានពោលជានាគំនិតរបស់អនាថបិណ្ឌិក-សេដ្ឋីថា ល្អហើយ ហើយព្រះអានន្ទក៏បានចូលទៅគាល់ ហើយក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន វត្ថុដែលគួរជាចេតិយ មានប៉ុន្មានព្រះអង្គ ? ព្រះមានបុណ្យត្រាស់ឆ្លើយថា ម្នាលអានន្ទ វត្ថុដែលគួរដល់ចេតិយ មាន ៣ យ៉ាង ដែលគួរដល់ការគោរពបូជា ។

ព្រះអានន្ទត្ថេរ ក្រាបទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចម្រើន តើចេតិយមាន ៣ ប្រការ បានដល់អ្វីខ្លះ ព្រះអង្គ ? ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ចេតិយដែលមាន ៣ ប្រការនោះ បានដល់ **១. ធាតុចេតិយ** គឺព្រះចេតិយដែលបញ្ចុះព្រះសារីរិកធាតុរបស់ព្រះសម្មុទ្ធ ឬព្រះអរហន្តធាតុ ។ **២. បរិភោគចេតិយ** គឺព្រះចេតិយដែលបញ្ចុះគ្រឿងបរិក្ខារប្រើប្រាស់ មានបាត្រ ចីវរ និងដើមពោធិព្រឹក្សជាដើម ។ **៣. ឧទ្ទិស្សកចេតិយ** គឺព្រះពុទ្ធរូបដែលសាងឡើងតំណាងព្រះភគវា ។ ព្រះអានន្ទត្ថេរ ក៏បានក្រាបទូលសួរទៀតថា បពិត្រព្រះអង្គ ទ្រង់និរទុក្ខ

កាលដែលព្រះមានព្រះភាគស្តេចយាងចារិកទៅកាន់ទីជនៃ ខ្ញុំព្រះករុណានឹងធ្វើព្រះចេតិយទុក គ្រាន់បានធ្វើសក្ការគោរពបូជាបានឬទេ ព្រះអង្គ ? គ្រានោះ ព្រះកគវាទ្រង់ត្រាស់បញ្ជាក់ថា ម្នាលអានន្ទ រឯងជាតុចេតិយពេលនេះមិនទាន់មានទេ ទាល់តែតថាគតបរិនិព្វានទៅទើបមាន ចំណែកឧទ្ទិស្សកចេតិយវិញ ក៏មិនមានអ្នកណាមួយសាងឡើងដែរ ចំពោះដើមពោធិព្រឹក្សដែលជាបរិភោគចេតិយនោះ ក៏នៅមានហើយ ជាទីសមគួរដល់ពុទ្ធបរិស័ទ ដែលជាអ្នកជ្រះថ្លាបានសព្វកាល ។

ព្រះអានន្ទត្ថេរ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងពេលដែលព្រះមានព្រះភាគ ស្តេចយាងទៅកាន់ទីជនៃហើយ មិនមានវត្ថុណានីមួយ ដែលនឹងជាទីសក្ការគោរពបូជា របស់ពួកពុទ្ធបរិស័ទទាំងឡាយទុកឯក្នុងវត្តជេតពននេះ ព្រោះដូច្នោះ ខ្ញុំព្រះករុណានឹងនាំគ្រាប់ពូជមកអំពីដើមមហាពោធិ៍ យកមកដាំនៅត្រង់មាត់ទ្វារវត្តជេតពនទុកដើម្បីធ្វើសក្ការគោរពបូជារបស់ពួកពុទ្ធបរិស័ទទាំងឡាយ ព្រះអង្គ ។ គ្រានោះ ព្រះមហាវីរៈទ្រង់ត្រាស់អនុញ្ញាតថា ម្នាលអានន្ទ ល្អហើយ

អ្នកចូរនាំយកមកដាំតាមបំណងចុះ ។ កាលព្រះអានន្ទត្ថេរ បានទទួលពុទ្ធានុញ្ញាតហើយ ទើបប្រាប់ដំណើរវៀងនេះឲ្យដល់ព្រះបាទបសេនទិ-កោសល អនាថបិណ្ឌិកសេដ្ឋី និងឧបាសិកាវិសាខា ហើយឲ្យមនុស្សជីករណ្តៅដើម្បីដាំគ្រាប់ពូជមហាពោធិ៍ នៅហ្នឹងជិតមាត់ទ្វារវត្តជេតពន ហើយក៏បានពោលនឹងព្រះមហាមោគ្គល្លានត្ថេរ ដោយឲ្យទៅអារាធនាគ្រាប់ពោធិ៍មកអំពីមហាពោធិ៍ កន្លែងដែលព្រះអង្គគ្រាស់ជើង យកមកប្រតិស្ឋានក្នុងទីនេះ ។ ព្រះមហាមោគ្គល្លានក៏បានទទួលការៈនោះហើយក៏បាត់អំពីទីនោះ ទៅប្រាកដឯពោធិមណ្ឌលស្ថាន ដោយលាតចីវរឡើងគ្រាប់មហាពោធិ៍ ក៏បានជ្រុះធ្លាក់មកអំពីដើមមហាពោធិ៍ មកលើចីវរបស់ព្រះមហាមោគ្គល្លាន ដោយមិនបានធ្លាក់ទៅលើដី ហើយព្រះមហាមោគ្គល្លានក៏បាននាំយកទៅឲ្យព្រះអានន្ទ ។

ចំណែកព្រះអានន្ទ ក៏បានប្រាប់ដំណឹងឲ្យដល់ព្រះបាទបសេនទិ-កោសលជាដើម ឲ្យបានជ្រាបទាំងអស់ អំពីថ្ងៃដែលនឹងដាំគ្រាប់ពោធិ៍ និងពេលវេលា ដោយកំណត់យកពេលរសៀល ។ ក្នុងពេលរសៀល

ក្នុងថ្ងៃដែលជាំដើមពោធិ៍នោះ ព្រះបាទបសេនទិកោសល ទើបចាត់ឲ្យ
ភ្នាក់ងារ (រាជបុរស) កាន់គ្រឿងឧបករណ៍គ្រប់ប្រភេទ ស្តេចយាងទៅ
ជាមួយនឹងរាជបរិវារទាំងនោះ ។ អនាថបិណ្ឌិកសេដ្ឋី និងឧបាសិកាវិសាខា
ក៏បាននាំគ្នាកាន់គ្រឿងសក្ការគោរពបូជា ទៅកាន់ស្ថានទីនោះដែរ រីឯ
បុគ្គលដទៃជាច្រើនទៀត ដែលជាអ្នកមានសទ្ធាជ្រះថ្លា ក៏បាននាំគ្នាទៅ
កាន់ស្ថានទីនោះដូចគ្នា ។ ព្រះអានន្ទបានជាក់ផើងមាសដ៏ធំក្នុងរណ្តៅ
ហើយឲ្យគេចោះបាតផើងមាសរួចជាក់គ្រាប់មហាពោធិ៍ ព្រមទាំងក្រាប
ទូលថា សូមស្តេចបរមមហាចពិត្រ ព្រះរាជសម្ភារ ទ្រង់ជាំគ្រាប់ពោធិ៍
នេះចុះ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ក៏បានទទួលគ្រាប់
មហាពោធិ៍ហើយ ទ្រង់មានព្រះរាជតម្រិះថា កាពជាព្រះរាជារបស់យើង
មិនអាចតម្រង់នៅអស់កាលជាអង្វែងទេ យើងគួរឲ្យអនាថបិណ្ឌិកសេដ្ឋី
ជាំគ្រាប់ពោធិ៍នេះ ហើយព្រះលោកនាយកក៏ឲ្យគ្រាប់ពោធិ៍នេះទៅដល់
អនាថបិណ្ឌិកសេដ្ឋី ។ ចំណែកអនាថបិណ្ឌិកសេដ្ឋី កាលបើបានទទួល
គ្រាប់ពោធិ៍នោះហើយ ទើបច្រចាប់ដីកក់ ដែលផ្សំដោយគ្រឿងក្រអូប

ហើយក៏កប់គ្រាប់ពោធិ៍ទៅក្នុងដីកក់នោះ ។

តែពេលដែលគ្រាប់ពោធិ៍ ដែលអនាថបិណ្ឌិកសេដ្ឋីដាក់ផុតចុះអំពីដៃ ដើមពោធិ៍នោះក៏ធំឡើងមួយរំពេច ដោយមានកម្ពស់ប្រមាណ ៥០ ហត្ថ ហើយមានមែក ៥ គឺលាតសន្ធឹងទៅកាន់ទិសទាំង ៤ នោះ ៤ មែក និងលូតឡើងទៅខាងលើមួយមែក មែកនីមួយៗ ប្រមាណ ៥០ ហត្ថស្មើគ្នា ជ្រុកជគួរឲ្យជាទីជ្រះថ្លារបស់ពួកមហាជនក្នុងពេលនោះ ។ គ្រានោះ ព្រះបាទបសេនទិកោសល ប្រទានឲ្យធ្វើផើងជ្រាក់ ផើងមាស ១០៨ ផើង ឲ្យជាក់គ្រឿងក្រអូបពេញ ហើយឲ្យជាំបទុមជាតិ កម្ពស់ប្រមាណមួយហត្ថជាដើម ឲ្យរៀបជាជួរជុំវិញដើមមហាពោធិ៍ និងឲ្យកសាងបុស្បកដោយកែវទាំង ៧ ប្រការ ឲ្យរោយខ្សាច់ដែលលាយដោយត្បូងក្នុងបុស្បក ឲ្យរៀបរបងជុំវិញគល់មហាពោធិ៍ រឯចំណែកទ្វាររបងធ្វើដោយកែវ ៧ ប្រការ លុះធ្វើរួចជាស្រេចសព្វគ្រប់អស់ហើយ ព្រះអានន្ទត្ថេរ បានចូលទៅគាល់ព្រះសម្ពុទ្ធ ដោយក្រាបទូលអារាធនាឲ្យព្រះអង្គយាងទៅគង់ប្រថាប់នៅត្រង់ដើមមហាពោធិ៍ និងក្រាបទូល

ឲ្យព្រះអង្គទ្រង់ចូលសមាបត្តិ នៅត្រង់គល់មហាពោធិ៍នោះទៀតផង ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ កាលតថាគតចូលសមាបត្តិនៅត្រង់គល់មហាពោធិ៍នេះហើយ ចំណែកទីដទៃ ក៏មិនអាចនឹងទ្រទ្រង់បាន (គឺកម្រើកញាប់ញ័រ) ។

គ្រានោះ ព្រះអានន្ទ ទើបក្រាបទូលថា បើជាយ៉ាងនោះ សូមព្រះអង្គទ្រង់យកនូវគល់មហាពោធិ៍នេះ នៅដោយសេចក្តីសុខ ដែលកើតអំពីសមាបត្តិចុះ ព្រះអង្គ ។ ព្រះមុនីក៏ទ្រង់យកនូវគល់មហាពោធិ៍នោះ ដោយនៅជាសុខ ដែលកើតអំពីសមាបត្តិអស់មួយរាត្រី ។ ចំណែកព្រះអានន្ទ ទើបប្រាប់ដល់ពុទ្ធបរិស័ទទាំងឡាយ មានព្រះបាទបសេនទិ-កោសលជាដើម ដែលមកធ្វើសក្ការៈក្នុងការយកគ្រាប់មហាពោធិ៍មកដាំ ឲ្យជ្រាបរឿង៉ាវទាំងអស់នោះ ។ តមក ដើមមហាពោធិ៍នោះ ឈ្មោះថា អានន្ទពោធិ៍ ព្រោះជាដើមមហាពោធិ៍ ដែលព្រះអានន្ទឲ្យយកមកដាំទុក ដើម្បីធ្វើសក្ការគោរពបូជាជំនួសព្រះមានជោគ ។

អនាថបិណ្ឌិកសេដ្ឋីជាពីជំងឺ ដោយបានស្តាប់ធម្មកថា របស់

ព្រះសារីបុត្រ ដូចមានរឿងតំណាលប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ ទុសីល្យសូត្រទី ១** មានសេចក្តីថា ៖-

សម័យមួយ ព្រះលោកនាថ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ។ កាលនោះ អនាថបិណ្ឌិកសេដ្ឋី មានជំងឺជាទម្ងន់ ហើយក៏បានបញ្ជូនបុរសម្នាក់ ឲ្យទៅពិតថេរវាចាជល់ព្រះសារីបុត្របាន ជ្រាប និងឲ្យនិមន្តលោកមកសួរសុខទុក្ខផង ។ គ្រានោះ ព្រះសារីបុត្រ កាលបើជ្រាបដូច្នោះហើយ ក៏បានគ្រងចីវរ ប្រដាប់ដោយបាត្រ និមន្ត ទៅសួរសុខទុក្ខអនាថបិណ្ឌិកសេដ្ឋី ក្នុងវេលាព្រឹក ដោយមានព្រះអានន្ទ និមន្តទៅជាមួយផង ។ កាលព្រះថេរៈទាំងពីរអង្គ និមន្តទៅដល់ផ្ទះ អនាថបិណ្ឌិកសេដ្ឋីហើយ ទើបសួរសុខទុក្ខថា យ៉ាងម៉េចទៅហើយ លោកគហបតី បានធូរស្រាលខ្លះទេ ? អនាថបិណ្ឌិកសេដ្ឋីពិតថេរដីកា តបថា បពិត្រលោកម្ចាស់ដ៏ចម្រើន អាការជំងឺរបស់ខ្ញុំព្រះករុណា មិន បានធូរស្រាលទេ មានតែធ្ងន់ធ្ងរឡើង ទុក្ខវេទនាកើតមានយ៉ាងខ្លាំងក្លា មិនអន់ថយឡើយ ។ ព្រះសារីបុត្រទើបពោលថា ម្នាលគហបតី បុថុជ្ជន

អ្នកមិនបានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះអរិយៈ ទាំងមិនប្រកបដោយសទ្ធា គឺភាពមិនតាំងមាំនៅក្នុងគុណព្រះពុទ្ធ នៅក្នុងគុណព្រះធម៌ នៅក្នុងគុណព្រះសង្ឃ យ៉ាងណានីមួយ ពេលដែលរាងកាយបែកធ្លាយទៅហើយ (ស្លាប់) រមែងចូលទៅកាន់អបាយភូមិ ទុគ្គតិ វិនិបាត នរក ។ (បុគ្គល) ដែលជាអ្នកជ្រះថ្លាក្នុងគុណព្រះពុទ្ធ ក្នុងគុណព្រះធម៌ ក្នុងគុណព្រះសង្ឃ ដំណើរបែបនោះរមែងមិនមាន (ទៅកាន់អបាយភូមិជាដើម) ។ ម្នាលគហបតី បុថុជ្ជនដែលមិនជឿស្តាប់ពាក្យប្រៀនប្រដៅនិងជាអ្នកទ្រុស្តសីល (គឺជាអ្នកល្មើសក្នុងសិក្ខាបទឬវិន័យ) យ៉ាងណា ថែមទាំងជាអ្នកប្រកបដោយការយល់ខុសយ៉ាងណា ជាអ្នកប្រកបដោយការត្រិះរិះខុស វាចាខុស ការងារខុស ការចិញ្ចឹមជីវិតខុស ការព្យាយាមខុស ការរឭកខុស ការតាំងចិត្តខុស ដំឯខុស រួចផុតខុស យ៉ាងណា ភាពជាអ្នកទ្រុស្តសីល និងភាពជាអ្នកយល់ខុស ត្រិះរិះខុស សម្តីខុស ការងារខុស ការចិញ្ចឹមជីវិតខុស ការព្យាយាមខុស ការរឭកខុស ការតម្កល់ចិត្តខុស ការដំឯខុស ការរួចផុតខុសយ៉ាងនេះ របស់អ្នកមិនមាន

អ្នកមានតែសីលដែលល្អ គឺសីលដែលព្រះអរិយៈស្រឡាញ់ សីលមិនជាប់ពពួស ពពាល សីលដែលមិនជាទាសៈនៃតណ្ហា សីលដែលមិនប្រឡាក់ដោយតណ្ហា សីលដែលអ្នកត្រាស់ដឹងទាំងឡាយបានសរសើរហើយ សីលដែលធ្វើឲ្យកើតសមាធិ ។ អ្នកមានតែការយល់ត្រូវត្រិះរិះត្រូវ វាចាត្រូវ ការងារត្រូវ ចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ រឭកត្រូវ តម្កល់ចិត្តត្រូវ ដឹងត្រូវ រួចផុតត្រូវ កាលអ្នកពិចារណាសីល ការយល់ត្រូវ ការត្រិះរិះត្រូវ វាចាត្រូវ ការងារត្រូវ ចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ រឭកត្រូវ តម្កល់ចិត្តត្រូវ ដឹងត្រូវ រួចផុតត្រូវ (សំដៅដល់ព្រះអរហន្ត) ដែលនៅក្នុងខ្លួនរបស់អ្នកហើយ វេទនានឹងរំងាប់ទៅដោយឆាប់រហ័ស ។

លំដាប់តពីនោះមក អនាថបិណ្ឌិកសេដ្ឋី កាលបើបានស្តាប់ព្រះធម៌ដូច្នោះហើយ វេទនាក៏ស្ងប់រំងាប់អន់ថយចុះទៅដោយឆាប់រហ័សក្នុងពេលនោះឯង ។ អនាថបិណ្ឌិកសេដ្ឋី ក៏បានរៀបចំថ្វាយកត្តជល់ព្រះសារីបុត្រ និងព្រះអានន្ទដោយខ្លួនឯង ។ កាលព្រះថេរៈទាំងពីរអង្គឆាន់កត្តរួចស្រេចហើយ អនាថបិណ្ឌិកសេដ្ឋី បានចូលទៅអង្គុយជិត

ព្រះថេរៈទាំងពីរ ហើយព្រះសារីបុត្របានពោលអនុមោទនាទានដោយធម្មកថា ដូចមានសេចក្តីថា

បុគ្គលណាមានសទ្ធាតាំងមាំដោយល្អហើយ មិនញាប់ញ័រក្នុងព្រះតថាគត និងជាអ្នកមានសីលល្អ ដែលជាទីពេញចិត្តនៃព្រះអរិយៈ ថែមទាំងព្រះអរិយៈបានសរសើរ ប្រកបដោយសទ្ធាជ្រះថ្លាចំពោះព្រះសង្ឃ មានការយល់ត្រង់ អ្នកមានញាណទាំងឡាយ ហៅបុគ្គលនោះថា មិនក្រីក្រ ជីវិតរបស់បុគ្គលនោះ ជាជីវិតមិនទទេ ព្រោះដូច្នោះ បុគ្គលដែលមានគំនិតល្អ បុគ្គលដែលរឭកដល់ព្រះពុទ្ធសាសនា គួរប្រកបនូវសទ្ធា និងសីល សេចក្តីជ្រះថ្លា និងការឃើញព្រះធម៌ ។

កាលពោលអនុមោទនាទានកថាចប់ហើយ ព្រះសារីបុត្រ និងព្រះអានន្ទបានក្រោកចាកអាសនៈ ចម្រើនពរត្រឡប់ទៅវិញ ។ ចំណែកព្រះអានន្ទ កាលត្រឡប់ទៅដល់វត្តជេតពនហើយ បានចូលទៅគាល់ព្រះសម្ពុទ្ធ ថ្វាយបង្គំរួចហើយ អង្គុយក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះភគវា ត្រាស់សួរថា ម្នាលអានន្ទ អ្នកមកអំពីទីណា ? ព្រះអានន្ទក្រាបទូល

តបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណានិមន្តអំពីផ្ទះអនាថបិណ្ឌិក-សេដ្ឋីជាមួយនឹងព្រះសារីបុត្រ ដោយព្រះសារីបុត្របានទៅសួរសុខទុក្ខ និងសម្តែងធម្មកថា ឲ្យដល់អនាថបិណ្ឌិកសេដ្ឋីបានស្តាប់ ព្រះអង្គ ។ ព្រះជិនស្រី ក៏ទ្រង់ត្រាស់សរសើរព្រះសារីបុត្រថា ម្នាលអានន្ទ សារីបុត្រជាបណ្ឌិត ជាអ្នកមានបញ្ញាច្រើន ដែលបានចែកអង្គនៃព្រះសោតាបន្ន ៣ ប្រការ ដោយអាការ ១០ យ៉ាង ។

ភាពមិនទៀងនៃជីវិត គឺការចាស់គ្រាំគ្រា និងសេចក្តីស្លាប់ រមែងមានទូទៅដល់សត្វលោកយ៉ាងពិតប្រាកដ បានកើតមានមកដល់អនាថបិណ្ឌិកសេដ្ឋី ដែលមានទាំងប្រាក់ និងគុណធម៌នោះ ដូចដែលមានរឿងសម្តែងប្រាកដនៅក្នុង **គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសក:** នៃ **សឡាយតនវគ្គ** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះសម្ពុទ្ធ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថ-បិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង អនាថបិណ្ឌិកសេដ្ឋី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់យ៉ាងខ្លាំង ។ គ្រានោះ

អនាថបិណ្ឌិកសេដ្ឋី ហៅបុរសម្នាក់មកថា នែបុរសដ៏ចម្រើន អ្នកឯង
ចូរមកអាយ ចូរអ្នកទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ
ចូរអ្នកថ្វាយបង្គំព្រះបាទាព្រះភគវាដោយសិរសា តាមពាក្យរបស់យើង
រួចហើយ ចូរក្រាបបង្គំទូលយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន អនាថ-
បិណ្ឌិកសេដ្ឋី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ក្រាប
ថ្វាយបង្គំព្រះបាទា ព្រះលោកនាយកដោយសិរសា រួចហើយចូរអ្នក
ថ្វាយបង្គំព្រះសារីបុត្រមានអាយុ តាមពាក្យរបស់យើង រួចហើយ ចូរ
អ្នកទូលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន អនាថបិណ្ឌិកសេដ្ឋី
មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ថ្វាយបង្គំព្រះបាទា
ព្រះសារីបុត្រមានអាយុដោយសិរសា ដូច្នេះផង ចូរអ្នកទូលយ៉ាងនេះថា
បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមអង្វរ សូមព្រះសារីបុត្រ
មានអាយុ អាស្រ័យសេចក្តីអនុគ្រោះ ចូលទៅកាន់លំនៅរបស់អនាថ-
បិណ្ឌិកសេដ្ឋី ដូច្នេះផង ។បុរសនោះ ទទួលពាក្យអនាថបិណ្ឌិកសេដ្ឋីថា
បាទ លោកដ៏ចម្រើន ហើយក៏ចូលទៅគាល់ព្រះសាស្តា លុះចូលទៅ

ដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយនៅក្នុងទីដ៏សមគួរ ។

លុះបុរសនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះលោកនាយកដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អនាថបិណ្ឌិកសេដ្ឋី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ក្រាបថ្វាយបង្គំព្រះបាទា ព្រះមានបុណ្យដោយសិរសា ហើយបុរសនោះ ក៏ចូលទៅរកព្រះសារីបុត្រមានអាយុ លុះចូរទៅដល់ថ្វាយបង្គំព្រះសារីបុត្រមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។លុះបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ទូលព្រះសារីបុត្រមានអាយុ ដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន អនាថបិណ្ឌិកសេដ្ឋី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ថ្វាយបង្គំព្រះបាទា ព្រះសារីបុត្រមានអាយុដោយសិរសា ហើយបុរសនោះទូលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមអង្វរសូមព្រះសារីបុត្រមានអាយុ អាស្រ័យសេចក្តីអនុគ្រោះ ចូលទៅកាន់លំនៅរបស់អនាថបិណ្ឌិកសេដ្ឋី (ឲ្យទាន) ។ ព្រះសារីបុត្រមានអាយុ

ក៏ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះសារីបុត្រមានអាយុ
ស្បៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ មានព្រះអានន្ទដ៏មានអាយុ
ជាបច្ឆាសមណៈ ក៏ចូលទៅកាន់ផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី លុះចូល
ទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលប្រគេន ។

លុះព្រះសារីបុត្រមានអាយុ គង់រួចហើយ ក៏មានថេរវាចានឹង
អនាថបិណ្ឌិកសេដ្ឋីដូច្នេះថា ម្នាលគហបតី សរីរយន្ត អ្នកល្មមអត់ធន់
បានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានដែរឬ ទុក្ខវេទនាបានស្រាកស្រាន្ត
មិនចម្រើនឡើងទេឬ ការធូរថយរមែងប្រាកដ ឯការចម្រើនឡើងរមែង
មិនប្រាកដទេឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំព្រះករុណាអត់ធន់
មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនាដ៏ខ្លាំងក្លារបស់ខ្ញុំ ចេះតែ
ចម្រើនឡើង មិនស្រាកស្រាន្តទេ ការចម្រើនចេះតែប្រាកដ ការធូរថយ
មិនប្រាកដទេ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន បុរសមានកម្លាំង ចាក់
អំបែងក្បាលដោយដែកស្រួចមុត យ៉ាងណាមិញ បពិត្រព្រះសារីបុត្រ
ដ៏ចម្រើន ខ្យល់ដ៏ខ្លាំងចាក់ដោតអំបែងក្បាលខ្ញុំ ក៏យ៉ាងនោះដែរ បពិត្រ

ព្រះសារីបុត្រ ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាជ័ខ្លាំងក្លារបស់ខ្ញុំ រមែងចម្រើនឡើង មិនស្រាកស្រាន្តទេ ឥតធូរថយសោះ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន បុរសមានកម្លាំងយកចង្វាយព្រ័ត្រដ៏មាំមកត្របែងក្បាល យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ដ៏ខ្លាំង ឆ្អៀលក្បាលខ្ញុំ ក៏យ៉ាងនោះដែរ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទាដ៏ខ្លាំងក្លារបស់ខ្ញុំ តែងចម្រើនឡើង មិនស្រាកស្រាន្តទេ ឥតធូរថយសោះ ។

បពិត្រព្រះសារីបុត្រដ៏ចម្រើន អ្នកសម្លាប់គោក្តី កូនសិស្សរបស់អ្នកសម្លាប់គោដ៏ឈ្លាសក្តី វះពោះ ដោយកាំបិតសម្រាប់វះគោដ៏មុតយ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ដែលខ្លាំង រមែងអាពោះរបស់ខ្ញុំ ក៏យ៉ាងនោះឯង បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ខ្លាំងក្លារបស់ខ្ញុំ តែងចម្រើនឡើង មិនស្រាកស្រាន្ត ឥតធូរថយសោះ ។ បុរស ២ នាក់ មានកម្លាំងចាប់បុរសម្នាក់ដែលខ្សោយជាង ត្រង់ដើមដៃទាំងពីរ ហើល

កម្តៅលើរណ្តៅរងើកភ្លើង យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ឯសេចក្តីក្តៅក្រហាយដ៏ខ្លាំង ក្នុងកាយរបស់ខ្ញុំ ក៏យ៉ាងនោះឯង បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ខ្លាំងក្លារបស់ខ្ញុំ តែងចម្រើនឡើង មិនស្រាកស្រាន្តទេ ឥតធូរថយសោះ ។

ព្រះសារីបុត្រតបថា ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុ ទាំងវិញ្ញាណដែលអាស្រ័យចក្ខុរបស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវត្រចៀក ទាំងវិញ្ញាណដែលអាស្រ័យត្រចៀករបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវច្រមុះ ទាំងវិញ្ញាណដែលអាស្រ័យច្រមុះ របស់អាត្មាអញក៏នឹងមិនមាន

ទ្បើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញ នឹងមិនប្រកាន់នូវអណ្តាត ទាំងវិញ្ញាណដែលអាស្រ័យអណ្តាត របស់អាត្មាអញក៏នឹងមិនមានទ្បើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវកាយ ទាំងវិញ្ញាណដែលអាស្រ័យកាយរបស់អាត្មាអញក៏នឹងមិនមានទ្បើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចិត្ត ទាំងវិញ្ញាណដែលអាស្រ័យហទយវត្ថុរបស់អាត្មាអញក៏នឹងមិនមានទ្បើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវរូប ទាំងវិញ្ញាណដែលអាស្រ័យរូបរបស់អាត្មាអញ ក៏នឹងមិនមានទ្បើយ ម្នាលគហបតី អ្នកត្រូវសិក្សា

យ៉ាងនេះចុះ។ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសំឡេង... នឹងមិនប្រកាន់នូវក្លិន... នឹងមិនប្រកាន់នូវរស... នឹងមិនប្រកាន់នូវផោដ្ឋព្វៈ... នឹងមិនប្រកាន់នូវធម្មារម្មណ៍ ទាំងវិញ្ញាណដែលអាស្រ័យធម្មារម្មណ៍របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញ នឹងមិនប្រកាន់ចក្ខុវិញ្ញាណ... នឹងមិនប្រកាន់នូវសោតវិញ្ញាណ... នឹងមិនប្រកាន់នូវឃានវិញ្ញាណ... នឹងមិនប្រកាន់នូវជិវ្ហាវិញ្ញាណ... នឹងមិនប្រកាន់នូវកាយវិញ្ញាណ... នឹងមិនប្រកាន់នូវមនោវិញ្ញាណ ទាំងវិញ្ញាណដែលអាស្រ័យហទយវត្ថុរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យចក្ខុសម្ផស្សរបស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូ

សិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសោតសម្ផស្ស... នឹងមិនប្រកាន់នូវឃានសម្ផស្ស... នឹងមិនប្រកាន់នូវជិវ្ហាសម្ផស្ស... នឹងមិនប្រកាន់នូវកាយសម្ផស្ស... នឹងមិនប្រកាន់នូវមនោសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យមនោសម្ផស្សរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនាដែលកើតអំពីចក្ខុសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យវេទនា ដែលកើតអំពីចក្ខុសម្ផស្ស របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីសោតសម្ផស្ស... នឹងមិនប្រកាន់នូវវេទនាដែលកើតអំពីឃានសម្ផស្ស... នឹងមិនប្រកាន់នូវវេទនាដែលកើតអំពីជិវ្ហាសម្ផស្ស... នឹងមិនប្រកាន់នូវវេទនាដែលកើត

អំពីកាយសម្ផស្ស... នឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីមនោសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យវេទនា ដែលកើតអំពីមនោសម្ផស្ស របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវបឋវីធាតុ ទាំងវិញ្ញាណដែលអាស្រ័យបឋវីធាតុ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអាបោធាតុ... នឹងមិនប្រកាន់នូវតេជោធាតុ... នឹងមិនប្រកាន់នូវវាយោធាតុ... នឹងមិនប្រកាន់នូវអាកាសធាតុ... ទាំងវិញ្ញាណ ដែលអាស្រ័យវិញ្ញាណធាតុ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវរូប ទាំងវិញ្ញាណដែលអាស្រ័យរូប របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាង

នេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនា.. នឹងមិនប្រកាន់នូវសញ្ញា... នឹងមិនប្រកាន់នូវសង្ខារទាំងឡាយ... នឹងមិនប្រកាន់នូវវិញ្ញាណ... ទាំងវិញ្ញាណដែលអាស្រ័យនាមរូបរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអាកាសានញ្ចាយតនៈ ទាំងវិញ្ញាណដែលអាស្រ័យអាកាសានញ្ចាយតនៈ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវិញ្ញាណញ្ចាយតនៈ... នឹងមិនប្រកាន់នូវអាកិញ្ចញ្ញាយតនៈ... នឹងមិនប្រកាន់នូវនេវសញ្ញានាសញ្ញាយតនៈ... ទាំងវិញ្ញាណដែលអាស្រ័យនូវនេវសញ្ញានាសញ្ញាយតនៈ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាល

គហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវលោកនេះ (អដ្ឋកថា លោកនេះសំដៅយកកន្ទែងសម្រាប់នៅ គ្រឿងសម្រាប់ស៊ី និងគ្រឿងស្លៀកពាក់) ទាំងវិញ្ញាណដែលអាស្រ័យនូវលោកនេះ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវលោកខាងមុខ (**អដ្ឋកថា** សង្គ្រោះយកលោកជនៃ លើកលែងតែមនុស្សលោកចេញ ។ អធិប្បាយថា ឲ្យលះចិត្តគិតថា អាត្មាអញនឹងកើតក្នុងទេវលោកឯណោះ នៅក្នុងទេវលោកឯណោះ បរិភោគ និងស្លៀកដណ្តប់យ៉ាងនេះ) ទាំងវិញ្ញាណ ដែលអាស្រ័យលោកខាងមុខ របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា ធម្មជាតិណា ដែលអាត្មាអញបានឃើញហើយ ឮហើយ ប៉ះពាល់ហើយ ដឹងច្បាស់ហើយ ស្វែងរកហើយ សូបសូងដោយចិត្ត

ហើយ អាត្មាអញនឹងមិនប្រកាន់នូវធម្មជាតិនោះ ទាំងវិញ្ញាណដែលអាស្រ័យធម្មជាតិនោះ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

កាលដែលព្រះសារីបុត្រ មានថេរវាចាយ៉ាងនេះហើយ អនាថបិណ្ឌិកសេដ្ឋី យំសម្រក់ទឹកភ្នែក ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ មានថេរវាចានឹងអនាថបិណ្ឌិកសេដ្ឋីដូច្នេះថា ម្នាលគហបតី អ្នកជាប់នៅក្នុងទ្រព្យសម្បត្តិឬ ម្នាលគហបតី អ្នកលិចនៅក្នុងទ្រព្យសម្បត្តិឬ ? អនាថបិណ្ឌិកគហបតីឆ្លើយថា បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំមិនជាប់មិនលិចនៅក្នុងទ្រព្យសម្បត្តិទេ តែថា ខ្ញុំព្រះករុណា ដែលចូលទៅអង្គុយជិតព្រះសាស្តា អស់កាលយូរហើយផង ចូលទៅអង្គុយជិតពួកភិក្ខុជាអ្នកចម្រើនចិត្ត អស់កាលយូរហើយផង ក៏ខ្ញុំព្រះករុណា មិនដែលបានស្តាប់ធម្មីកថាមានសភាពដូច្នេះឡើយ ។ ម្នាលគហបតី ធម្មីកថាមានសភាពដូច្នេះ តែងមិនច្បាស់ប្រាកដដល់ពួកគ្រហស្ថអ្នកស្លៀក.សទេ ម្នាលគហបតី ឯធម្មីកថាមានសភាពដូច្នេះ រមែងច្បាស់ប្រាកដដល់

ពួកបព្វជិត (តែប៉ុណ្ណោះ) ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន បើដូច្នោះ ធម្មីកថាមានសភាពដូច្នេះ សូមឲ្យបានច្បាស់ជ្រាកដល់ពួកគ្រហស្ថ អ្នកស្មៀក.សផង៑ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះថា មានពួកកុលបុត្រ ដែលប្រកបដោយជាតិ ជាអ្នកមានធូលីតិចក្នុងភ្នែក ជាអ្នកដឹងច្បាស់ នូវធម៌ ព្រោះតែមិនបានស្តាប់ធម៌ មុខជានឹងសាបសូន្យចាកធម៌មិនខាន ។ លុះព្រះសារីបុត្រ និងព្រះអានន្ទដ៏មានអាយុទូន្មានអនាថបិណ្ឌិកគហបតី ដោយឱវាទនេះរួចហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ កាលបើព្រះសារីបុត្រ និងព្រះអានន្ទដ៏មានអាយុចៀសចេញទៅ អស់កាលមិនយូរប៉ុន្មាន អនាថបិណ្ឌិកគហបតីក៏ធ្វើមរណកាល ទៅកើតក្នុងពួកទេវតាក្នុងស្ថានតុសិត ។ លំដាប់នោះ អនាថបិណ្ឌិកទេវបុត្រ លុះរាត្រីបឋមយាមកន្លងទៅហើយ មានពន្លឺដ៏រុងរឿងញុំាងវត្តជេតពនទាំងអស់ ឲ្យភ្លឺស្វាងហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះសាស្តា ហើយស្ថិតនៅក្នុងទីសមគួរ ។ លុះអនាថ-បិណ្ឌិកទេវបុត្រស្ថិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះសម្ពុទ្ធ

ដោយគាថាទាំងឡាយថា

វត្តជេតពននេះ សុទ្ធតែពួកអ្នកស្វែងរកគុណដ៏ល្អ នៅអាស្រ័យជានិច្ច ដែលព្រះពុទ្ធជាធម្មរាជគង់អាស្រ័យនៅ ជាទីញុំាងបីតិឲ្យកើតព្រមដល់ខ្ញុំព្រះអង្គ កម្ម គឺមគ្គចេតនា ១ វិជ្ជា គឺមគ្គប្បញ្ញា ១ ធម៌ទាំងឡាយជាបក្ខពួកខាងសមាធិ ១ សីលឈ្មោះថាជីវិតខ្ពស់បំផុត ១ សត្វទាំងឡាយរមែងស្អាតដោយធម៌នេះ មិនមែនដោយគោត្រ ឬមិនមែនដោយទ្រព្យឡើយ ព្រោះហេតុនោះ បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ត្រូវពិចារណាធម៌ ដោយឧបាយនៃប្រាជ្ញា ទើបស្អាតក្នុងធម៌នោះយ៉ាងនេះបាន មានតែព្រះសារីបុត្រ ១ ទើបប្រសើរដោយបញ្ញាផង ដោយសីលផង ដោយកិរិយារំងាប់នូវកិលេសផង ទុកជាកិក្ខុណាជល់នូវត្រើយ គឺព្រះនិព្វាន (កិក្ខុនោះ) ក៏មានគុណអស់ត្រឹមប៉ុណ្ណោះឯង ។

លុះអនាថបិណ្ឌិកទេវបុត្រពោលនូវគាថានេះចប់ ព្រះសាស្តាក៏មានព្រះហឫទ័យត្រេកអរ ។ លំដាប់នោះ អនាថបិណ្ឌិកទេវបុត្រ

ដ៏ឆ ថា ព្រះសាស្តារបស់អាត្មាអញ មានព្រះហឫទ័យត្រេកអរហើយ ក៏ក្រាបថ្វាយបង្គំព្រះទសពល ធ្វើប្រទក្សិណ រួចក៏បាត់ក្នុងទីនោះទៅ ។ លុះកន្លងរាត្រីនោះទៅហើយ ព្រះមានជោគត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ កាលដែលរាត្រីបឋមយាមកន្លងទៅហើយ ក្នុងយប់នេះឯង មានទេវបុត្រមួយអង្គ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាង ហើយក៏ចូលមកវកតថាគត លុះចូលមកដល់ថ្វាយបង្គំតថាគត ហើយស្ថិតនៅក្នុងទីសមគួរ ។ លុះទេវបុត្រនោះស្ថិតនៅក្នុងទីសមគួរហើយ ពោលគាថាទាំងនេះ ចំពោះតថាគតថា

វត្តជេតពននេះ សុទ្ធតែពួកអ្នកស្វែងរកគុណដ៏ល្អ នៅអាស្រ័យជានិច្ច ដែលព្រះពុទ្ធជាធម្មរាជគង់អាស្រ័យនៅ ជាទីញុំាងបីតិឲ្យកើត ព្រមដល់ខ្ញុំព្រះអង្គ កម្ម គឺមគ្គចេតនា ១ វិជ្ជា គឺមគ្គប្បញ្ញា ១ ធម៌ទាំងឡាយជាបក្ខពួកខាងសមាធិ ១ សីលឈ្មោះថាជីវិតខ្ពស់បំផុត ១ សត្វទាំងឡាយរមែងស្អាតដោយធម៌នេះ មិនមែនដោយគោត្រ ឬមិនមែនដោយទ្រព្យឡើយ ព្រោះហេតុនោះ បុរសជាបណ្ឌិត កាលបើ

ឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ត្រូវពិចារណាធម៌ ដោយឧបាយ
នៃប្រាជ្ញា ទើបស្អាតក្នុងធម៌នោះយ៉ាងនេះបាន មានតែព្រះសារីបុត្រ ១
ទើបប្រសើរដោយបញ្ញាផង ដោយសីលផង ដោយកិរិយារំងាប់នូវ
កិលេសផង ទុកជាកិក្ខុណាដល់នូវត្រើយ គឺព្រះនិព្វាន (កិក្ខុនោះ)
ក៏មានគុណអស់ត្រឹមប៉ុណ្ណោះឯង ។

ម្នាលភិក្ខុទាំងឡាយ លុះទេវបុត្រនោះ កាលពោលនូវគាថា
នេះចប់ហើយ ដឹងច្បាស់ថា ព្រះសាស្តារបស់អាត្មាអញ មានព្រះ
ហឫទ័យត្រេកអរហើយ ក៏ក្រាបថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ ក៏បាត់
ក្នុងទីនោះទៅ ។ កាលបើព្រះជិនស្រី មានពុទ្ធដីកាយ៉ាងនេះហើយ
ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមហាវីរៈដូច្នេះថា បពិត្រព្រះអង្គ
ដ៏ចម្រើន ទេវបុត្រនោះឯង ប្រាកដជាអនាថបិណ្ឌិកគហបតីនោះ បពិត្រ
ព្រះអង្គដ៏ចម្រើន ព្រោះអនាថបិណ្ឌិកគហបតី បានជ្រះថ្លាក្រៃពេក ក្នុង
ព្រះសារីបុត្រមានអាយុ ។ ម្នាលអានន្ទ ត្រូវហើយៗ ម្នាលអានន្ទ ហេតុ
ដែលអ្នកបានត្រិះរិះនោះ ត្រូវហើយ ទេវបុត្រនោះ គឺអនាថបិណ្ឌិកសេដ្ឋី

ហ្នឹងឯង មិនមែនអ្នកដទៃទេ ។ លុះព្រះទសពល ទ្រង់ត្រាស់នូវពាក្យនេះចប់ហើយ ព្រះអានន្ទមានអាយុ មានសេចក្តីត្រេកអរ រីករាយនឹងភាសិតព្រះសម្មុទ្ធណាស់ ។

ការបានសម្រេចជាព្រះសោតាបន្ន របស់អនាថបិណ្ឌិកសេដ្ឋី ចាត់ជាករណីយ៍ពិសេស ព្រោះលោកអស់ជីវិតទៅ បានទៅកើតក្នុងទេវលោក ដោយមិនវិលត្រឡប់មកកើតក្នុងមនុស្សលោកទៀតឡើយ ដូចដែលមានសម្តែងទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរបុគ្គលប្បញ្ញត្តិ ព្រះអភិធម្មបិដក** ថា ៖-

អនាថបិណ្ឌិកសេដ្ឋី និងមហាឧបាសិកាវិសាខាជាដើម ដែលមានគ្នាទាំងអស់ ៧ នាក់ (ជន ៥ នាក់ទៀត គឺចូឡរដ្ឋទេវបុត្រ មហារដ្ឋទេវបុត្រ អនេកវណ្ណទេវបុត្រ សក្កទេវរាជ និងនាគទត្តទេវបុត្រ) ជាសោតាឧទ្ធង្គសោតៈ គឺជាអ្នកត្រូវទៅកើតក្នុងស្ថានសួគ៌ជាន់តៗ ទៅទៀតដោយលំដាប់ រហូតទៅដល់ជាន់សុទ្ធាវាសព្រហ្ម ហើយលោកនឹងបរិនិព្វានក្នុងអកនិដ្ឋកព្រហ្ម គឺរូបព្រហ្មជាន់ខ្ពស់បំផុត ក្នុងព្រហ្មទាំង

១៦ ជាន់ ដែលជាជាន់ប្រសើរជាង ជាន់សុទ្ធាវាសព្រហ្មខាងក្រោម ៤ ដោយមិនត្រឡប់មកកើត ក្នុងមនុស្សលោកទៀតឡើយ តែជាព្រះសោតាបន្ន ដែលហៅថា **វដ្តកិរតិ** ប្រែថា អ្នកត្រេកអរក្នុងវដ្ត: គឺស្ងាប់កើត កើតស្ងាប់ក្នុងទេវលោកជាលំដាប់ ទាំងនេះរាប់ថា ជាអ្នកពេញចិត្តក្នុងវដ្ត: បុញ្ញបារមីរបស់លោក ដែលបានធ្វើរួចមកហើយអស់កាលដ៏យូរអង្វែងនោះ ទើបធ្វើឲ្យលោកបានសោយទិព្វសម្បត្តិក្នុងស្ថានសួគ៌ ជាន់ផ្សេងៗ រហូតអស់កាលដ៏យូរអង្វែង ហើយទីបំផុតលោកក៏បានរំលត់ខន្ធបរិនិព្វាន នៅក្នុងអកនិដ្ឋកព្រហ្ម ជាបរិយោសាននៃជីវិតរបស់លោក ដែលសម្រេចមកអំពីការបំពេញបុណ្យបារមី ។

(***ជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី*** ចប់)

✍ ជីវប្រវត្តិរបស់ហត្ថកអាឡវកឧបាសក ✍

“ លោកជាឯតទគ្គៈផ្នែកខាងសង្គ្រោះបរិស័ទដោយសង្គហវត្ថុ ៤ ប្រការ ”

ហត្ថកអាឡវក: *ជាឧបាសកមួយរូប ជាអ្នកបរិបូណ៌ដោយគុណធម៌ គឺសេចក្តីល្អដោយសង្គហវត្ថុ ៤ ប្រការ រហូតដល់បានទទួលការលើកតម្កើងពីព្រះមានជោគ ឲ្យជាឯតទគ្គបុគ្គល នៅក្នុងចំណោមពួកឧបាសកទាំងឡាយ ដែលជាឯតទគ្គៈនៅក្នុងព្រះពុទ្ធសាសនានេះ ។*

ជីវប្រវត្តិរបស់ហត្ថកអាឡវកឧបាសក ដូចមានសម្តែងនៅក្នុង ***អដ្ឋកថាមនោរថបូរណី*** *និងក្នុង* ***អដ្ឋកថាបរមត្ថជោតិកា*** *ថា ៖*

ក្នុងអតីតកាលដែលកន្លងមកហើយបានមួយសែនកប្ប ដោយរាប់ថយក្រោយពីកទុកប្បនេះទៅ ដែលត្រូវនឹងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ហត្ថកអាឡវកឧបាសក បានកើតនៅក្នុងត្រកូលមួយនាក្រុងហង្សវតី ។ ថ្ងៃមួយ កុលបុត្រនោះ (ហត្ថកអាឡវកៈ) បានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះបទុមុត្តរៈ ហើយបានឃើញព្រះពុទ្ធអង្គ

ទ្រង់ប្រកាសតែងតាំងឧបាសកម្នាក់ ដែលជាអ្នកប្រកបដោយសទ្ធាហារត្តុ ៤ ប្រការ ទុកក្នុងតំណែងឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ទើបកើតការពេញចិត្តក្នុងតំណែងនោះ ហើយក៏តាំងចិត្តបំពេញបុណ្យកុសលដើម្បីប្រាថ្នាឲ្យបានតំណែងដូចជាឧបាសកនោះដែរ ។ ដោយអធិការកុសលនោះ ពេលដែលកុលបុត្រនោះអស់ជីវិតទៅហើយ គេក៏បានត្រាច់វង្វាត់ស្ទាប់កើតៗ ស្ទាប់ជាមនុស្ស និងទេវតាអស់មួយសែនកប្ប ។

កាលកន្ងងមកដល់ពុទ្ធកាល ព្រះសមណគោតមបរមគ្រូនៃយើងនេះ លោកបានមកកើតជាព្រះរាជឱរសរបស់ព្រះរាជាអាឡវី ក្នុងដែនអាឡវី ហើយទ្រង់មានឈ្មោះថា **អាឡវកៈ** ។ ពេលដែលអាឡវកកុមារ ជាអ្នកត្រូវបញ្ជូនទៅឲ្យដល់អាឡវកយក្ខ ព្រមជាមួយភាជនៈដែលដាក់អាហារក្នុងថ្ងៃស្អែកនោះ ក៏មានរឿងរ៉ាវដែលពោលទាក់ទងហេតុការណ៍ទាំងនោះដូច្នេះថា ព្រះរាជាអាឡវី ទ្រង់បានលះបង់សេចក្តីសុខក្នុងរាជសម្បត្តិច្រើនប្រការ ហើយស្តេចយាងទៅប្រពាតព្រៃដើម្បីបរបាញ់សត្វគ្រប់ៗ ៧ ថ្ងៃម្តង ទាំងទ្រង់បំណងដើម្បីកម្ចាត់ពួកចោរ និងដើម្បីទ្រង់ការពារ

ព្រះរាជាដែលជាសត្រូវ និងដើម្បីទ្រង់បញ្ចេញកម្លាំងកាយ ។

ថ្ងៃមួយ ព្រះរាជាទ្រង់ធ្វើកតិកាជាមួយនឹងពួកពលយោធាទុកថា បើម្រឹគគេចចេញទៅរួចច្រកអ្នកណា អ្នកនោះត្រូវដេញទៅតាមម្រឹគនោះ ។ គ្រានោះ សត្វម្រឹគក៏បានរត់ចេញទៅតាមច្រករបស់ព្រះរាជា។ ឃើញដូច្នោះហើយ ដោយទ្រង់ជាអ្នកបរិបូណ៌ដោយកម្លាំងផង ទាំងទ្រង់ក៏ជាអ្នករត់បានរហ័សរហួន ព្រះអង្គទើបបានកាន់ធ្នូ ស្ដេចរត់ដេញទៅតាមម្រឹគនោះ ទៅរហូតអស់រយៈផ្លូវ ៣ យោជន៍ ។ ចំណែកសត្វម្រឹគនោះ កាលរត់ទៅអស់ចម្ងាយផ្លូវ ៣ យោជន៍ ក៏ខ្សោយកម្លាំង ទើបគេចចុះទៅផឹកទឹក ។ពេលនោះ ព្រះរាជាយាងមកទាន់ ទើបទ្រង់កាប់ម្រឹគនោះជាច់ជាពីរកំណាត់ សូម្បីថាព្រះអង្គ ក៏ទ្រង់មិនត្រូវការម្រឹគ តែដើម្បីជាសាក្សី ការពារពាក្យពោលរបស់អ្នកជនៃថា ព្រះរាជាទ្រង់មិនអាចចាប់ម្រឹគបាន ព្រះអង្គទើបទ្រង់ប្រើដងធ្នូ ជាដងវែក ហើយទ្រង់វែកម្រឹគនោះមក ។

កាលព្រះរាជាអាឡវី ទ្រង់វែកសាច់យាងមក ដោយត្រូវពន្លឺថ្ងៃ

និងកម្ចាំងខ្សល់ខ្លាំង ទ្រង់ក៏ហត់នឿយ ទ្រង់បានជួបនឹងដើមជ្រៃធំមួយដើម ដែលមានមែក និងស្លឹកត្រឈឹងត្រឈៃ ដែលនៅមិនឆ្ងាយអំពីក្រុងអាឡវី ព្រះអង្គទើបយាងចូលទៅត្រង់គល់ជ្រៃនោះ ដើម្បីប្រថាប់សម្រាកព្រះកាយ ។ គ្រានោះ អាឡវកយក្ខ ដែលមានវិមាននៅត្រង់ដើមជ្រៃនោះ ជាអ្នកបានទទួលពរអំពីស្តេចវេស្សវណ មហារាជថា ឲ្យចាប់មនុស្ស និងសត្វទាំងពួង ដែលចូលមកខាងក្រោមម្លប់នៃដើមជ្រៃនោះ ដោយយកស្រមោលរបស់ដើមជ្រៃក្នុងវេលាថ្ងៃត្រង់ជាដែនកំណត់ កាលបើអ្នកចាប់បានចូរស៊ីជាអាហារចុះ ។

អាឡវកយក្ខ បានឃើញព្រះរាជាអាឡវីយាងចូលទៅក្នុងដែនកំណត់នោះហើយ ពេលដែលព្រះរាជាទ្រង់មកសម្រាកមួយសន្ទុះបាត់ហត់ហើយ ក៏ស្តេចយាងចេញទៅ គ្រានោះ អាឡវកយក្ខទើបពោលថា លោកចូរឈប់សិន ព្រោះលោកជាអាហាររបស់យើង ថាហើយ ទើបចាប់ព្រះហស្តព្រះរាជាទុក ។ កាលព្រះរាជាធ្លាក់ទៅក្នុងអំណាចរបស់យក្ខហើយ ទ្រង់មិនឃើញឧបាយឯណាមួយ ដែលធ្វើឲ្យទ្រង់រួចផុត

អំពីកណ្តាប់ដៃរបស់អាឡវកយក្ខទៅបាន ទើបទ្រង់ធ្វើកតិកាទុកជាមួយអាឡវកយក្ខថា លោកចូរដោះលែងយើងទៅ បើយើងរួចខ្លួនទៅ យើងនឹងបញ្ជូនមនុស្ស និងភាជន:ផ្ទុកដោយអាហារ យកមកឲ្យលោកបរិភោគជាប្រចាំ ជារៀងរាល់ថ្ងៃ ។ គ្រានោះ អាឡវកយក្ខ មិនទាន់ព្រមលែងព្រះរាជា ថែមទាំងពោលថា លោកជាអ្នកស្រេវឹង ដោយសេចក្តីសុខក្នុងរាជសម្បត្តិ ហើយមុខជានឹងភ្លេចកតិកានេះមិនខាន ដោយយើងមិនអាចនឹងស៊ីអ្នក ដែលមិនចូលទៅក្នុងព្រំដែនយើងបានឡើយ ពីព្រោះយើងបានទទួលការអនុញ្ញាតឲ្យចាប់ពពួកមនុស្ស និងសត្វដែលចូលទៅក្នុងខេត្តនេះតែប៉ុណ្ណោះជាអាហារ ។

ទើបព្រះរាជាទ្រង់ត្រាស់បញ្ជាក់ទៀតថា បើថ្ងៃណាយើងមិនបានបញ្ជូនអាហារ និងមនុស្សមកឲ្យលោកទេ ថ្ងៃនោះ លោកចូរទៅចាប់ខ្ញុំស៊ីចុះ ។ អាឡវកយក្ខ កាលបានស្តាប់ពាក្យសន្យារបស់ព្រះរាជាអាឡវីទុកដូច្នេះហើយ ក៏បានដោះលែងព្រះរាជាទៅ ។ ព្រះរាជាអាឡវី ក្រោយពីអាឡវកយក្ខដោះលែងនោះ ទើបទ្រង់យាងសំដៅទៅត្រង់ព្រះនគរ

រវាងផ្លូវនោះ ក៏បានជួបនឹងពលយោធា ដែលនៅរង់ចាំ ។ ពេលដែលពួកពលយោធាបានជួបព្រះរាជាហើយ ក៏នាំគ្នាក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ព្រះអង្គទ្រង់លំបាកព្រះកាយ ព្រោះភ័យឯណាមួយឬព្រះអង្គ ? គ្រានោះ ព្រះរាជាទ្រង់ក៏និយាយប្រាប់រឿង"រ៉ាវទាំងអស់នោះឲ្យស្តាប់ទាំងអស់ហើយ ស្តេចក៏យាងចូលទៅក្នុងព្រះនគរ ។ លុះដល់ព្រឹកឡើង ពេលដែលព្រះរាជាសោយព្រះក្រយាហារព្រឹកហើយ ទើបទ្រង់មានព្រះតម្រាស់ត្រាស់ឲ្យអាមាត្យ ដែលជាអ្នករក្សាក្រុងចូលមកគាល់ ព្រះរាជាក៏ទ្រង់និយាយរឿង"រ៉ាវទាំងអស់នោះឲ្យបានជ្រាប ដែលទ្រង់ត្រូវយក្ខចាប់ និងទ្រង់ធ្វើកតិកាជាមួយយក្ខឲ្យបានស្តាប់សព្វគ្រប់ ។

អាមាត្យដែលជាអ្នករក្សាក្រុង ក្រោយពីបានស្តាប់រឿង"រ៉ាវទាំងអស់នោះហើយ ក៏បានក្រាបទូលសួរព្រះរាជាថា តើព្រះអង្គទ្រង់សន្យាដោយកំណត់ថ្ងៃ, វេលាឬទេ ព្រះអង្គ ? គ្រានោះ ព្រះរាជា មានព្រះរាជតម្រាស់តបថា មិនបានកំណត់ថ្ងៃ, វេលាទុក ។ អាមាត្យ ទើបក្រាបបង្គំទូលថា ព្រះករុណាជីវិតមិនស្មើលើត្បូង ទ្រង់ធ្វើមិនត្រូវឡើយ

ព្រោះធម្មតានៃអមនុស្សទាំងឡាយ រមែងបានវត្ថុដែលខ្លួននឹងគប្បីបាន តាមកំណត់ប៉ុណ្ណោះ កាលព្រះអង្គទ្រង់មិនបានកំណត់ទុកកាពក្តៅក្រហាយ នឹងត្រូវមានដល់ប្រជាជន តែណ្តើយចុះ សូមព្រះអង្គទ្រង់បានធ្វើទុកយ៉ាងនេះក៏ដោយ សូមព្រះអង្គទុកព្រះទ័យ និងសូមសោយសុខក្នុងរាជសម្បត្តិចុះ ទូលបង្គំនឹងទទួលធានាក្នុងរឿងនេះខ្លួនឯង ព្រះអង្គ ។ គ្រានោះ ព្រះរាជាទ្រង់មានព្រះរាជឱង្ការឲ្យបញ្ជូនអ្នកទោស ដែលត្រូវប្រហារជីវិតនៅក្នុងគុកយកទៅឲ្យយក្ខសុី ។

អាមាត្យដែលជាអ្នកធានាក្នុងរឿងនោះ ក៏បានក្រាក់ពីងងឹត បានទៅឯគុកប្រាប់ថា អ្នកណាដែលត្រូវសម្លាប់ ឬអ្នកណានឹងត្រូវសម្លាប់ បើអ្នកនោះចង់មានជីវិតរស់នៅ ក៏ចូរចេញមក ។ កាលអ្នកទោសណាចេញមកមុន គេក៏ទទួលអ្នកទោសនោះទៅឯផ្ទះរបស់គេ ឲ្យផ្តល់ទឹកបរិភោគអាហារហើយ ទើបប្រើឲ្យកាន់កាជនៈដាក់អាហារដើរយកទៅឲ្យអាឡវកយក្ខ ។ លុះអ្នកទោសនោះចូលទៅត្រង់គល់ជ្រៃ អាឡវកយក្ខក៏ប្រែកាឡាឲ្យជាវត្ថុដែលគួរខ្លាច ហើយខាំស៊ីអ្នកទោសនោះ ដូចខាំជុំ

ដំឡូង ហើយរាងកាយទាំងមូលរបស់មនុស្ស មានសក់ជាដើម រមែងជូចជាជុំទឹកដោះរឹត ទាំងនេះដោយអានុភាពរបស់យក្ខ ។បុរសទាំងឡាយដែលតាមមើលអ្នកទោស ដោយសង្កេតឃើញថា ត្រូវនាំយកទៅឲ្យយក្ខសុី ឃើញដូច្នេះហើយក៏ភ័យខ្លាច ប្រាប់ដល់មិត្តសម្លាញ់គ្រប់គ្នាឲ្យបានដឹងក្នុងរឿងនោះ ។ រាប់តាំងពីនោះមក មនុស្សទាំងឡាយបាននាំគ្នាវៀរចាកធ្វើចោរកម្ម ដោយបានជ្រាបថា ព្រះរាជាឲ្យចាប់ចោរបញ្ជូនទៅឲ្យយក្ខសុីជាអាហារ ។

កាលតមក គុកក៏ទំនេរ អ្នកទោសចាស់ក៏អស់ទៅ ព្រោះត្រូវបញ្ជូនទៅឲ្យយក្ខសុីអស់ អ្នកទោសថ្មីក៏មិនមាន ដោយមិនមានអ្នកណាត្រូវទោសជាប់គុក ។ អាមាត្យទើបចូលទៅគាល់ក្រាបបង្គំទូលឲ្យព្រះរាជាអាឡវីទ្រង់ជ្រាបថា អ្នកទោសក្នុងគុកអស់ហើយ ។ព្រះរាជាកាលទ្រង់ជ្រាបដូច្នេះ ទើបទ្រង់មានព្រះរាជឫទម្រិះឲ្យនាំយកទ្រព្យទៅទុកចោលតាមផ្លូវបែកជា ៣ និងផ្លូវបែកជា ៤ ដោយត្រាស់ថា ទោះជាយ៉ាងណាគង់នឹងមានអ្នកកាន់យកទ្រព្យនេះ ដោយសេចក្តីប្រថ្នាចង់បាន តែមិន

មាននរណានឹងហ៊ានកាន់យកទ្រព្យទាំងនោះ សូម្បីដោយបន្តិចបន្តួច ។ កាលព្រះរាជាទ្រង់រកចោរមិនបាន ដោយវិធីយ៉ាងនេះ ទើបទ្រង់ប្រាប់ដល់ពួកអាមាត្យទាំងឡាយឲ្យបានដឹង ។

ពួកអាមាត្យក្រាបបង្គំទូលថា សូមទ្រង់ឲ្យបញ្ជូនមនុស្សចាស់តាមលំដាប់ត្រកូល ទៅឲ្យយក្ខសុី មួយថ្ងៃៗ ១ ព្រោះមនុស្សចាស់ទាំងនោះ ជិតនឹងស្លាប់ទៅហើយព្រះអង្គ ។ (រឿងចំណុចនេះនៅក្នុង ***អដ្ឋកថាមនោរថបូរណី*** បានសម្តែងបញ្ជាក់ថា ព្រះរាជាទ្រង់យល់ស្របដោយបានបញ្ជូនមនុស្សចាស់ទៅឲ្យយក្ខសុីទាល់តែអស់) ។ ព្រះរាជាត្រាស់ឃាត់ថា កុំឡើយ ស្រុកទេសនឹងកើតចលាចលឡើង នឹងមានអ្នកនិយាយគ្នាថា ព្រះរាជាបានបញ្ជូនបិតារបស់យើងទៅឲ្យយក្ខសុី អ្នកខ្លះនឹងនិយាយថា ព្រះរាជាបានបញ្ជូនតារបស់យើងទៅឲ្យយក្ខសុី ព្រោះដូច្នេះ ការដែលនឹងបញ្ជូនមនុស្សចាស់ទៅឲ្យយក្ខសុី យើងមិនយល់ព្រមឡើយ ។

ពួកអាមាត្យ ទើបក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បើ

យ៉ាងនោះ សូមទ្រង់បញ្ជូនទារកតូចៗ ទៅឲ្យដល់យក្ខ ប្រាកដជាមិនមានអ្នកណាពោលថា ជាមាតាបិតារបស់យើងទេព្រះអង្គ ។ ព្រះរាជាក៏យល់ព្រមឲ្យពួកអាមាត្យរៀបចំបញ្ជូនទារក ទៅឲ្យយក្ខស៊ីជាអាហារមួយថ្ងៃម្នាក់ៗ ។ ក្នុងគ្រានោះ មាតារបស់ទារកបាននាំទារកគេចចេញទៅនៅក្នុងជនបទដទៃ ដោយហោចទៅសូម្បីតែពួកស្ត្រីមានគភ៌ក៏ខ្លាចបានគេចទៅនៅក្នុងជនបទដទៃយ៉ាងនេះអស់កាល ១២ ឆ្នាំ ។ តមកថ្ងៃមួយ កាលពួកអាមាត្យរកទារក រហូតពេញព្រះនគរមិនបានហើយ ទើបទៅក្រាបទូលព្រះរាជាអាឡវីថា ទារកក្នុងព្រះនគរមិនមានឡើយ ព្រះអង្គ មានតែព្រះអាឡវកកុមារ ដែលជាព្រះឱរសរបស់ព្រះអង្គ ដែលនៅក្នុងព្រះរាជវាំងប៉ុណ្ណោះ ព្រះអង្គ ។

គ្រានោះ ព្រះរាជាមានព្រះរាជតម្រាស់ថា បុត្ររបស់យើងៗក៏ស្រឡាញ់យ៉ាងណា អ្នកជនៃក៏ដូច្នោះ តែអ្នកដែលស្រឡាញ់អ្នកជនៃជាងខ្លួននោះមិនមានឡើយ សូម្បីជាបុត្ររបស់យើងៗ ក៏ពេញចិត្តឲ្យលោកទាំងឡាយ ដើម្បីរក្សាជីវិតរបស់យើងទៅចុះ ។ ក្នុងថ្ងៃនោះ

ព្រះមានជោគ ទ្រង់ចូលព្រះមហាករុណាសមាបត្តិ ត្រង់ព្រះគន្ធកុដិក្នុងវត្តជេតពន ក្នុងពេលជិតភ្លឺ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏ទ្រង់បានឃើញឧបនិស្ស័យ ដែលនឹងបានសម្រេចព្រះអនាគាមិផលរបស់អាឡវកកុមារ ទើបព្រះតម្រិះថា ព្រះកុមារនេះ បានតាំងសេចក្តីប្រាថ្នាមកអស់មួយសែនកប្បហើយ បានចុតិអំពីទេវលោកមកកើតជាព្រះឱរសរបស់ព្រះបាទអាឡវី ក្នុងថ្ងៃស្អែកនេះ បើពួកវាជបុរសរកទារកដទៃមិនបាន ក៏នឹងចាប់អាឡវកកុមារនេះបញ្ជូនទៅ ព្រមនឹងភាជនអាហារ ។ ហើយព្រះអង្គថែមទាំងទ្រង់ឃើញឧបនិស្ស័យរបស់អាឡវកយក្ខ ដែលនឹងបានសម្រេចសោតាបត្តិផល ថែមទាំងទ្រង់ឃើញឧបនិស្ស័យ ដែលនឹងបានធម្មចក្ខុ បានដល់ ភ្នែក គឺបញ្ញាដែលជីងធម៌ (ដែលហៅថា បានសម្រេចសោតាបត្តិមគ្គញ្ញាណ គឺញាណដែលធ្វើឲ្យជាព្រះសោតាបន្ន) នៃទេវតា និងមនុស្សទាំង ២៤.០០០ នាក់ ។ បច្ចូសសម័យជិតភ្លឺ ព្រះសាស្តាទ្រង់ធ្វើកិច្ចមុន ឆាន់កត្តស្រេចហើយៗ ព្រះអង្គទ្រង់ធ្វើកិច្ចផ្សេងៗ តមកហួតដល់ព្រះអាទិត្យអស្តង្គត ក្នុងវេលា

នៃថ្ងៃឧបោសថខាងរនោច ព្រះអង្គទើបទ្រង់កាន់បាត្រ និងចីវរ ស្តេចយាងទៅតែមួយព្រះអង្គឯង ដោយព្រះអង្គយាងចេញអំពីក្រុងសាវត្ថីទៅអស់ចម្ងាយផ្លូវ ៣ យោជន៍ ក៏យាងទៅដល់ទីលំនៅរបស់អាឡវកយក្ខ ហើយបានប្រថាប់ឈរនៅត្រង់មុខទ្វារវិមានរបស់អាឡវកយក្ខនោះ ។

តែក្នុងវេលានោះ អាឡវកយក្ខ មិនបាននៅក្នុងវិមាន ដោយបានទៅកាន់សមាគមនៃពួកយក្ខ ក្នុងព្រៃហិមពាន្ត ។ ត្រង់ទ្វារវិមានរបស់អាឡវកយក្ខ មានយក្ខមួយឈ្មោះថា **គន្ធព្វ** (គន្ធព្វ ឈ្មោះនេះហៅតាមក្នុង **អដ្ឋកថាមនោរថបូរណី** តែក្នុង **អដ្ឋកថាបរមត្ថជោតិកា** ហៅថា គន្ធេក) ។ ដែលជាអ្នកយាមទ្វារ បានក្រាបទូលសួរព្រះមុនីថា ហេតុអ្វីបានជាព្រះវិជិតមារស្តេចយាងមកកាន់ទីនេះ ក្នុងវេលាវិកាលដូច្នេះ ព្រះអង្គ ? គ្រានោះ ព្រះមានបុណ្យត្រាស់តបថា នែគន្ធព្វយក្ខ បើអ្នកមិនទើសទាល់ទេនោះ តថាគតនឹងសុំចូលទៅក្នុងវិមាន នឹងសុំសម្រាកមួយយប់ ក្នុងវិមានរបស់អាឡវកយក្ខនេះ ។

គន្ធព្វយក្ខក្រាបទូលថា ខ្ញុំព្រះករុណាមិនទើសទាល់ទេ តែអាឡ-

វកយក្ខជាអ្នកវែងគ្នីង គីវែងរូសណាស់ សូម្បីតែមាតាគេក៏មិនរាប់អាន ត្រឹមតែម្រាមដៃមួយ គេក៏មិនធ្លាប់លើកឡើងសំពះអ្នកណាមួយឡើយ ខ្ញុំព្រះករុណាទើសទាល់ក្នុងរឿងនេះឯង សូមព្រះអង្គទ្រង់កុំពេញព្រះទ័យគង់សម្រាកនៅក្នុងទីនេះអី ព្រះអង្គ ។ គ្រានោះ ព្រះទសពលត្រាស់ថា ម្នាលគន្ធព្វយក្ខ កាពគ្រោតគ្រោត និងកាពវែងរូសរបស់អាឡវកយក្ខនោះ តថាគតដឹងហើយ តែថា អន្តរាយណាៗ នឹងមានដល់តថាគតមិនមានឡើយ បើអ្នកមិនទើសទាល់ទេ តថាគត នឹងសុំស្នាក់នៅក្នុងទីនេះមួយយប់ផង ។ គន្ធព្វយក្ខបានក្រាបទូលបដិសេធក្នុងវារៈទី២ថា បពិត្រព្រះសុគត អាឡវកយក្ខមានចិត្តកាចដូចអម្បែងដែលត្រូវភ្លើងក្តៅ គេមិនដឹងថា មាតាបិតា ឬសមណព្រាហ្មណ៍ជាអ្វី គេមិនដឹងថា អ្វីជាធម៌ ឬជាអធម៌ អ្នកដែលចូលមកក្នុងទីនេះ គេបានធ្វើឲ្យអន្តរាយផ្សេងៗ គឺគេធ្វើឲ្យមានចិត្តរវើរវាយក៏មានគេហែកបេះដូងចោលក៏មាន គេចាប់ជើងគ្រវែងទៅខាងនាយ មហាសមុទ្រក៏មាន គេគ្រវែងទៅដល់ចក្រវាឡដទៃក៏មាន ព្រះអង្គ ។

គ្រានោះ ព្រះសយម្ភូត្រាស់តបជាលើកទី ៣ ថា តថាគតដឹងក្នុងរឿងនេះហើយ បើអ្នកមិនមានការទើសទាល់ទេ តថាគតក៏នឹងសុំស្នាក់នៅត្រឹមតែមួយយប់ប៉ុណ្ណោះ ។ គន្ធព្វយក្ខបានក្រាបទូលជាមួយព្រះមហាវីរៈជាលើកទី ៣ ដោយពាក្យពេចន៍ដែលពោលហើយ ក្នុងវារៈទី ២ មកពោលអះអាងទៀត ។ ព្រះពុទ្ធអង្គ ក៏ទ្រង់ត្រាស់បញ្ជាក់ព្រះវាចាដើមថា ម្នាលគន្ធព្វយក្ខ តថាគតដឹងក្នុងរឿងនេះហើយ បើអ្នកមិនមានការទើសទាល់ទេនោះ តថាគតក៏នឹងសុំស្នាក់អាស្រ័យមួយយប់ផង ។ គន្ធព្វយក្ខក្រាបទូលថា បពិត្រព្រះមានជោគ ខ្ញុំព្រះករុណាមិនមានការទើសទាល់ទេ តែអាឡវកយក្ខនឹងត្រូវសម្លាប់ ខ្ញុំព្រះករុណាមិនខាន ដោយសារខ្ញុំព្រះករុណាមិនបានប្រាប់ឲ្យគេបានដឹង ព្រោះដូច្នោះ ខ្ញុំព្រះករុណានឹងថ្វាយបង្គំលាទៅប្រាប់ក្នុងរឿងនេះ ឲ្យគេបានជ្រាបជាមុនសិន ព្រះអង្គ ។ ព្រះជិនស្រីត្រាស់ថា បើយ៉ាងនោះ អ្នកចូរទៅប្រាប់គេតាមបំណងចុះ ។ គន្ធព្វយក្ខ ទើបក្រាបទូលថា បើដូច្នោះ សូមព្រះសាស្តា ទ្រង់ជួយមើលការខុសត្រូវក្នុងទីនេះឲ្យផង ព្រះអង្គ កាល

ក្រាបទូលដូច្នេះហើយ បានក្រាបបង្គំលាឆ្ពោះមុខទៅកាន់ព្រៃហិមពាន្ត ។

ក្នុងខណៈនោះ ភាពដ៏អស្ចារ្យបានកើតឡើង ដោយទ្វារវិមានរបស់អាឡវកយក្ខបានរបើកឯង ដើម្បីយោងព្រះលោកនាយកឲ្យស្តេចយាងចូលទៅខាងក្នុងវិមាន ។ ព្រះសម្ពុទ្ធទើបស្តេចយាងចូលទៅខាងក្នុងវិមាន ហើយបានគង់ប្រថាប់លើរតនបល្ល័ង្កដ៏ជាទិព្វ ដែលជាទីអង្គុយសម្រាកក្នុងថ្ងៃមង្គលផ្សេងៗ របស់អាឡវកយក្ខ ហើយទ្រង់បានបញ្ចេញព្រះរស្មីលឿងផ្សាយចេញទៅ ។ ពួកស្រីស្នំរបស់អាឡវកយក្ខ បានក្រឡេកឃើញព្រះរស្មីហើយ ទើបនាំគ្នាមកថ្វាយបង្គំ ហើយអង្គុយចោមរោមព្រះមានជោគ ។ ព្រះពុទ្ធអង្គ ក៏ទ្រង់សម្តែងព្រះធម៌ទេសនាគឺបកិណ្ណកធម៌ ឲ្យនាងយក្ខទាំងអស់នោះបានស្តាប់ ដោយមានន័យជាដើមថា ពីមុននាងទាំងអស់គ្នាបានឲ្យទាន រក្សាសីល បូជាបុគ្គលដែលគួរបូជាទុកហើយ ទើបបានសម្បត្តិបែបនេះ សូម្បីក្នុងឥឡូវនេះ អ្នកទាំងឡាយគប្បីធ្វើយ៉ាងនោះទៀត អ្នកទាំងអស់ ចូរកុំហួងហែង និងកុំកំណាញ់ចំពោះគ្នានិងគ្នា ។ ពួកនាងយក្ខទាំងនោះ លុះបានស្តាប់

ព្រះសូរសៀងដ៏ពីរោះ របស់ព្រះសម្មាសម្ពុទ្ធហើយ ទើបបានបន្លឺវាចា សាធុការឡើងព្រមគ្នាថា សាធុ ព្រះអង្គ ហើយនាំគ្នាអង្គុយចោមរោម នៅក្នុងទីនោះតទៅទៀត ។

ចំណែកគន្ធព្វយក្ខ បានទៅដល់ព្រៃហិមពាន្តហើយ បានប្រាប់អាឡវកយក្ខថា បពិត្រលោកអ្នកនិរទុក្ខ សូមលោកជ័ងថា ពេលនេះ ព្រះសមណគោតម បានស្តេចយាងមកគង់ប្រថាប់នៅក្នុងវិមានរបស់លោកហើយ ។ គ្រានោះ អាឡវកយក្ខទើបឲ្យសញ្ញាដល់គន្ធព្វយក្ខថា អ្នកឯងចូរស្ងៀម យើងនឹងត្រឡប់ទៅ ហើយយើងនឹងធ្វើវត្តដែលគួរធ្វើ ។ កាលដែលអាឡវកយក្ខបានឲ្យសញ្ញាយ៉ាងនោះ ព្រោះមិនចង់ឲ្យនរណាៗ ក្នុងទីប្រជុំនោះបានដឹង ឬបានឮ ។ ក្នុងគ្រានោះ សាតាគិរីយក្ខ និង ហេមវតយក្ខនិយាយគ្នាថា ពួកយើងនឹងទៅថ្វាយបង្គំព្រះបរមគ្រូនៅឯ វត្តជេតពនមហាវិហារសិន ហើយទើបនាំគ្នាទៅកាន់ឯសមាគមរបស់យក្ខ និយាយគ្នាដូច្នេះហើយ បាននាំបរិវារទៅតាមផ្លូវអាកាស សំដៅទៅកាន់ វត្តជេតពន ។ ម្យ៉ាងទៀត វិមានមាស ដែលតាំងនៅក្នុងអាកាស មាន

ច្រើនយ៉ាងតាមផ្លូវដែលទៅនោះ រមែងគេចវិមានទាំងនោះ ។ ចំណែកវិមានរបស់អាឡវកយក្ខ ដែលជាវិមានតាំងនៅត្រង់ភាគផែនជី ហ៊ុមព័ទ្ធយ៉ាងក្រាស់ មានប៉ម និងប្រឡាយហ៊ុមទំព្នៅដូចជាហិប ដែលមានគម្របបិទយ៉ាងល្អ មានកម្ពស់ដល់ ៣ យោជន៍ លើវិមាននោះ រមែងមានផ្លូវទៅមក ។

សាតាគិរីយក្ខ និងហេមវតយក្ខទាំគ្នាហោះមកដល់ទីកន្លែងនោះ ក៏មិនអាចហោះរំលងទៅបាន ។ទាំងនេះ ដោយសារពុទ្ធានុភាព ព្រោះថាព្រះពុទ្ធទាំងឡាយ ទ្រង់គង់ប្រថាប់នៅក្នុងទីណា ខាងលើនៃទីកន្លែងនោះ កម្ពស់ឡើងទៅដល់ព្រហ្មលោក ដែលខ្ពស់បំផុត ក៏មិនមាននរណាអាចឆ្លងកាត់ទៅបាន យក្ខទាំងពីរអាត្មានោះ កាលហោះឆ្លងទៅមិនរួច ទើបគិតថា មានហេតុអ្វីហ្ន៎ លុះក្រឡេកចុះទៅ ក៏បានឃើញព្រះភគវាប្រថាប់គង់នៅ ទើបនាំគ្នាចុះអំពីអាកាសយ៉ាងរហ័ស ដូចជាដុំដីដែលធ្លាក់ចុះមកអំពីអាកាសដូច្នេះដែរ ហើយបាននាំគ្នាចូលទៅថ្វាយបង្គំ និងនាំគ្នាអង្គុយស្តាប់ព្រះធម៌ លុះស្តាប់ព្រះធម៌ចប់ហើយ ក៏នាំគ្នាថ្វាយបង្គំ

លោថា បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះករុណាទាំងឡាយ នឹងថ្វាយបង្គំលាទៅកាន់ទីសមាគមរបស់យក្ខ ក្រាបទូលដូច្នេះហើយ ក៏បាននាំគ្នាហោះទៅកាន់ទីសមាគមរបស់យក្ខ ក្នុងព្រៃហិមពាន្តទៅ ។ ចំណែកអាឡវកយក្ខ បានក្រឡេកឃើញសាតាគិរិយក្ខ និងហេមវតយក្ខ បានថយចេញទៅហើយ បានពោលថា សូមលោកទាំងអស់គ្នាអង្គុយក្នុងទីនេះសិន ។

យក្ខសេនាបតីទាំងពីរអាត្មានោះ ទើបជ្រាបដល់អាឡវកយក្ខថា ម្នាលអាឡវក៎ ព្រះសម្ពុទ្ធ ទ្រង់ជាបុគ្គលកំពូលក្នុងលោក ព្រមទាំងទេវលោក ទ្រង់ស្តេចយាងមកគង់ប្រថាប់ក្នុងវិមានរបស់លោក រាប់ថាជាមហាលាភដល់លោកៗ ចូរទៅគាល់ព្រះសម្មាសម្ពុទ្ធចុះ ហើយស្តាប់ព្រះធម៌របស់ព្រះអង្គផង ។ កាលអាឡវកយក្ខ បានស្តាប់ពាក្យពោលសរសើរអំពីព្រះគុណនៃព្រះជិនស្រី អំពីយក្ខសេនាបតីទាំងពីរនោះហើយ ក៏គិតថា ពួកយក្ខទាំងនេះពោលដល់រឿងសមណៈក្បាលត្រងោលម្នាក់ដែលអង្គុយលើបល្ល័ង្ករបស់យើង ក៏កើតការក្តៅក្រហាយឡើងក្នុងចិត្ត

មួយរំពេច មានអាការហាក់បីដូចជាដុំអំបិល ដែលបុគ្គលចោះចូលទៅក្នុងភ្លើង ហើយផុះបែកប្រែះៗ ដូច្នោះ ហើយគេបានពោលឡើងថា សមណៈដែលចូលទៅក្នុងវិមានរបស់យើងនោះ ជានរណា ? យក្ខសេនាបតីទាំងពីរទើបជ្រាប់ថា លោកមិនស្គាល់ព្រះសម្ពុទ្ធជាគ្រូរបស់យើងទេឬ ? លុះជ្រាប់ដូច្នេះហើយ ទើបបានពោលសរសើរព្រះជិនស្រី ដោយផ្តើមអំពីព្រះអង្គសោយទិព្វសម្បត្តិនៅក្នុងសួគ៌ជាន់តុសិត បានមានទេព្តាក្នុងម៉ឺនចក្កវាឡទៅទូលអារាធនា ឲ្យយាងចុះមកឧប្បត្តិគ្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធជាដើម រហូតដល់បុព្វនិមិត្ត ៣២ ប្រការ ដែលប្រាកដក្នុងពេលដែលព្រះអង្គចុះចាប់បដិសន្ធិជាដើម ឲ្យដល់អាឡវកយក្ខស្តាប់ដោយពិស្តារ ហើយសួរឡើងថា នែអាឡវកៈ កាពអស្ចារ្យផ្សេងៗទាំងនេះ លោកមិនធ្លាប់ដឹងទេឬ ? សូម្បីអាឡវកយក្ខបានដឹងដូច្នេះហើយ គេក៏តបថា មិនបានដឹង ព្រោះអំណាចនៃសេចក្តីខឹងក្រោធចូលគ្របសង្កត់ចិត្តរបស់គេ ។ យក្ខសេនាបតីទាំងពីរនោះទើបពោលបៀបបញ្ឈឺថា ម្នាលអាឡវកៈ លោកធ្លាប់ដឹង ឬមិនធ្លាប់ដឹងកាពអស្ចារ្យទាំងនេះរបស់

ព្រះមានជោគក៏ដោយ គង់គ្មានប្រយោជន៍អ្វីដល់លោកទេ លោកនឹងធ្វើអ្វីដល់គ្រូរបស់យើងបាន ព្រោះលោកដូចជាកូនគោ ដែលទើបតែកើតដែលនៅជិតគោឧសភរាជ ឬដូចជាកូនដំរីដែលនៅក្នុងទីជិតស្តេចដំរី ឬដូចឆ្កែចចកកញ្ជាស់ ដែលនៅជិតស្តេចរាជសីហ៍ ឬដូចកូនក្អែកបាក់ស្លាបដែលនៅជិតស្តេចគ្រុឌ ដែលមានស្លាបប្រវែង ១៥០ យោជន៍ លោកនឹងធ្វើវត្តុណាដល់គ្រូរបស់យើង ក៏ចូរធ្វើទៅចុះ ។

អាឡវកយក្ខ កាលបានស្តាប់ដូច្នេះហើយ ក៏រឹងរឹតតែមានសេចក្តីក្រោធខ្លាំងឡើងទៀត រហូតដល់ពោលថា ថ្ងៃនេះ សង្គ្រាមរវាងយើងនិងសមណៈនេះនឹងមានឡើងក្នុងទីនេះ ពួកលោកចូរជាសម្ងាញ់របស់យើង ថាហើយ ក៏ក្រោកឡើងឈរជាន់មនោសិលា ដោយជើងឆ្វេង ហើយលើកជើងស្តាំជាន់កំពូលក្តាំកៃលាស ដែលមានកម្ពស់ ៦០ យោជន៍ រហូតក្តាំបែកចេញជាពីរចំណែក ព្រមទាំងស្រែកគំរាមថា អ្នកទាំងឡាយគ្រូរបស់ពួកលោក និងយើង អ្នកណាមានអានុភាពច្រើនជាងអ្នកណា ហើយស្រែកប្រកាសឡើងដោយសំឡេងយ៉ាងខ្លាំងថា យើង គឺអាឡវក:

ដូច្នេះ ។ សំឡេងស្រែកប្រកាសរបស់អាឡវកយក្ខ បានលាន់ឮទូទៅទាំងជម្ពូទ្វីប ។ម្យ៉ាងទៀត សំឡេងស្រែកដែលលាន់ឮទូទៅទាំងជម្ពូទ្វីបនោះ មាន ៤ សំឡេងគឺ ១. សំឡេងរបស់បុណ្ណកយក្ខសេនាបតីដែលស្រែកប្រកាសឡើងថា យើងឈ្នះហើយៗ ក្នុងគ្រាដែលលេងបាស្កាឈ្នះព្រះបាទធនញ្ជយកោរព្យៈ ។ ២. សំឡេងរបស់សក្កទេវរាជ ដែលត្រាស់បញ្ជាឲ្យវិស្សកម្មទេវបុត្រកាឡាខ្ជូនជាឆ្កែធំ ក្នុងកាលដែលព្រះពុទ្ធសាសនានៃព្រះសម្មាសម្ពុទ្ធកស្សបៈវិនាសថយចុះទៅ ហើយទ្រង់ស្រែកឡើងថា យើងនឹងឲ្យឆ្កែរបស់យើងខាំសុីកិក្ខុ កិក្ខុនី ឧបាសក ឧបាសិកា ដែលជាអ្នកប្រព្រឹត្តធម៌ដ៏លាមក និងសុីបុគ្គលទាំងពួង ដែលជាអ្នកមិនកាន់សុចរិតធម៌ ។ ៣. សំឡេងរបស់ព្រះបាទកុសរាជ ទ្រង់ប្រកាសថា យើង ***គឺសីតស្សរកុសមហារាជ*** ក្នុងគ្រាដែលព្រះរាជាទាំង ៧ នគរ លើកគ្នាមកព័ទ្ធព្រះនគររបស់ព្រះអង្គទុក ។ ៤. សំឡេងរបស់អាឡវកយក្ខដែលឈរនៅលើកំពូលភ្នំកៃលាស ហើយស្រែកប្រកាសថា យើង គឺអាឡវកៈ ។ សំឡេងរបស់អាឡវកយក្ខបានលាន់ឮទូទៅទាំងជម្ពូទ្វីប

ដូចជាឈរនិយាយមុខទ្វារផ្ទះរបស់បុគ្គលទាំងឡាយដូច្នោះ ។ ហើយ
ព្រៃហិមពាន្ត ដែលមានទំហំ ៣ ពាន់យោជន៍ ក៏កក្រើកញាប់ញ័រទៅ
ដោយអានុភាពរបស់អាឡវកយក្ខ ។

គ្រានោះ អាឡវកយក្ខ បានបណ្តាលឲ្យកើតខ្យល់ព្យុះឡើង
ដោយគិតថា យើងនឹងឲ្យសមណៈគេចចេញទៅដោយខ្យល់នេះ ។
ខ្យល់ព្យុះដែលអាឡវកយក្ខបណ្តាលឲ្យប្រព្រឹត្តទៅ បានតាំងឡើងមក
អំពីទិសផ្សេងៗ មានទិសខាងកើតជាដើម ហើយបានទម្លាយកំពូលភ្នំ
ដែលមានកម្ពស់បានកន្លះយោជន៍ មួយយោជន៍ ពីរយោជន៍ និងបី
យោជន៍ ឲ្យបាក់ធ្លាក់ចុះមក សូម្បីតែគុម្ពឫស្សី ដើមឈើ ក្នុងព្រៃ
ក៏មានឫសសណ្តកឡើងមក ហើយខ្យល់ព្យុះទាំងនោះ បានបក់សំដៅ
ទៅក្រុងអាឡវី ធ្វើឲ្យស្ថានទីផ្សេងៗ មានរោងជីរចាស់ជាដើម ធ្លុះធ្លាយ
ល្អិតជាផង់ធូលី ធ្វើឲ្យក្បឿងប្រក់ដំបូលហើរទៅក្នុងអាកាស ។ គ្រានោះ
ព្រះមានជោគ ទ្រង់អធិដ្ឋានថា សូមកុំឲ្យនរណាៗ មានអន្តរាយឡើយ
ខ្យល់ព្យុះនេះ កាលបក់ទៅរកព្រះលោកនាយក ក៏មិនអាចធ្វើព្រះអង្គ

សូម្បីត្រឹមតែជាយចីវរឲ្យកម្រើកបាន តអំពីនោះ អាឡវកយក្ខ ទើបបណ្តាលជាភ្លៀងមេធំឲ្យធ្លាក់ចុះមក ដោយសង្ឃឹមថា យើងនឹងឲ្យទឹកជន់លិចសមណៈនេះឲ្យស្លាប់ទៅ ។

គ្រានោះ ពពកក៏តាំងឡើងមួយរយជាន់ មួយពាន់ជាន់ ក៏ធ្វើឲ្យភ្លៀងមេធំនោះធ្លាក់ចុះមកលើផែនពសុធា ធ្លុះធ្លាយដោយកម្លាំងនៃគ្រាប់ភ្លៀង ។ ពពកធំដែលរសាត់នៅខាងលើព្រៃ និងលើដើមឈើទាំងឡាយ កាលមកដល់ព្រះអង្គហើយ ក៏មិនអាចធ្វើឲ្យ សូម្បីត្រឹមតែជាយចីវរបស់ព្រះអង្គ ឲ្យសើមបានដោយតំណក់ទឹក សូម្បីត្រឹមតែមួយតំណក់ ។លំដាប់តទៅ អាឡវកយក្ខ បានបណ្តាលឲ្យភ្លៀងថ្មធ្លាក់ចុះមក ហើយភ្លៀងថ្មទាំងនោះ បានធ្វើឲ្យកំពូលភ្នំធំៗ កើតជាផ្សែងផ្ការភ្លើង ហើយឆេះជាអណ្តាតភ្លើង អណ្តែតឡើងមកតាមអាកាស តែលុះមកដល់ក្បែរព្រះមានបុណ្យ ក៏ក្លាយជាផ្ការឈើទិព្វធ្វើជាសក្ការៈគោរពបូជាព្រះមហាមុនី ។

លំដាប់តទៅ អាឡវកយក្ខ ទើបបណ្តាលឲ្យភ្លៀងអាវុធធ្លាក់

ចុះមក អាវុធដែលធ្លាក់ចុះមកនោះ មានលំពែង មានដាវ មានកាំបិត ជាដើម សុទ្ធតែឆេះជាអណ្តាតភ្លើង អណ្តែតមកតាមអាកាស តែលុះមកដល់ក្បែរព្រះលោកនាយកហើយ ក៏ក្លាយជាផ្កាឈើទិព្វគោរពបូជាព្រះសម្ពុទ្ធទៅវិញ ។ លំដាប់តមកទៀត អាឡវកយក្ខ ទើបបណ្តាលឲ្យភ្លៀងរងើកភ្លើងធ្លាក់មកទៀត ភ្លៀងរងើកភ្លើងនោះ មានពណ៌ដូចជាផ្កាចារ តែកាលធ្លាក់មកជិតដល់ព្រះកគវា ក៏ក្លាយជាគ្រឿងសក្ការបូជាចំពោះព្រះសក្យមុនី ។ ក្នុងលំដាប់តទៅទៀតនោះ អាឡវកយក្ខ បានបណ្តាលឲ្យភ្លៀងខ្យាច់ធ្លាក់ចុះមកទៀត រីឯភ្លៀងខ្យាច់នោះ ជាភ្លៀងខ្យាច់ល្អិតបំផុត ទាំងជាផ្សែង ទាំងជាអណ្តាតភ្លើង ធ្លាក់ចុះមកដល់ជិតព្រះមានជោគ ក៏ក្លាយជាផ្កាឈើទិព្វបូជាព្រះលោកនាថ ។

លំដាប់តទៅទៀតនោះ អាឡវកយក្ខ បានបណ្តាលឲ្យជាភ្លៀងកក់ចុះមក ហើយភ្លៀងកក់នោះ មានទាំងផ្សែង មានទាំងអណ្តាតភ្លើង តែកាលធ្លាក់មកជិតដល់ព្រះមហាវីរៈក៏ត្រឡប់ក្លាយជាផ្កាឈើទិព្វបូជាព្រះសយម្ភូទៀតដូចគ្នា ។ លំដាប់ចុងក្រោយ អាឡវកយក្ខ ទើបបាន

បណ្តាលឲ្យកើតភាពងងឹតឡើង ដោយគិតថា នឹងធ្វើឲ្យសមណៈនេះកើតការភ័យខ្លាច ហើយគេចចេញទៅ ។ ភាពងងឹតនោះ មានហេតុ ៤ ប្រការ (ភាពងងឹតដែលមានហេតុ ៤ ប្រការនោះ គឺ ១. ថ្ងៃ ១៤ រោច ២. ព្រៃស្មុក ៣. ពពកដែលបិទបាំងផ្ទៃមេឃ ៤.ពេលពាក់កណ្តាលយប់ ដែលមានមកក្នុង **គម្ពីរអដ្ឋកថាបបញ្ចសូទនី**) ដូចជាភ្លៀង តែលុះភាពងងឹតជិតមកដល់ព្រះជិនស្រី ក៏វិនាសអន្តរធានបាត់ទៅ មិនអាចនឹងធ្វើភាពភ័យខ្លាចឲ្យកើតមានដល់ព្រះមានជោគ ។

គ្រានោះ អាឡវកយក្ខ កាលមិនអាចធ្វើឲ្យព្រះលោកនាយកស្តេចយាងចេញ ដោយឫទ្ធិរបស់ខ្លួនទាំងនោះបាន ទើបចូលទៅជិតព្រះសម្ពុទ្ធដោយខ្លួនឯង ព្រមទាំងចតុរង្គសេនា ដែលរំកិលទៅ ដោយពពួកភូតបិសាច ដែលមានរាងកាយប្លែកៗច្រើនប្រភេទ ហើយម្នាក់ៗសុទ្ធតែកាន់គ្រឿងអាវុធផ្សេងៗ គ្នា ។ ពួកភូតបិសាចទាំងនោះ បានសម្តែងកិរិយាអាការផ្សេងៗ គ្នា ដូចជាសម្តែងខ្លួនមកខាងលើព្រះសម្ពុទ្ធ ព្រមទាំងស្រែកសន្ធាប់មកថា អ្នកទាំងឡាយចូរចាប់ អ្នកទាំងឡាយ

ចូរសម្លាប់សមណៈនេះ ។តែថា កូតបិសាចទាំងនោះ មិនអាចចូលមកជិតព្រះសក្យមុនីបានឡើយ ប្រៀបបីដូចពពួកវុយ ដែលមិនអាចចូលជិតជុំដែកដែលក្តៅបានដូច្នោះដូចគ្នា ។

សូម្បីកាលបើដូច្នេះក្តី ពពួកកូតបិសាចទាំងនោះ ក៏មិនព្រមនាំគ្នាគេចទៅ នៅតែពពាក់ពពូនគ្នា រហូតដល់ពាក់កណ្តាលយប់ មិនដូចពពួកមារដែលលើកកងទ័ពមកច្បាំង ក្នុងពេលព្រះមានជោគជិតនឹងបានត្រាស់ដឹងនោះ ។ កាលអាឡវកយក្ខ មិនអាចធ្វើអ្វីឲ្យព្រះសម្ពុទ្ធភ័យខ្លាច ឲ្យញាប់ញ័របាន ដោយអាការសម្តែងវត្ត ដែលគួរឲ្យខ្លាច ដោយអនេកប្បរិយាយនោះនៅរហូតដល់ពាក់កណ្តាលយប់ទើបគិតឡើងថា ទោះជាយ៉ាងណាក៏ដោយ យើងត្រូវបញ្ចេញអាវុធ គឺសំពត់ជូតក្បាលរបស់យើង ដែលជាអាវុធពិសេស មិនមាននរណាអាចយកឈ្នះបាន ក្នុងពេលឥឡូវនេះ ។ ម្យ៉ាងទៀត អាវុធដែលវិសេសបំផុតក្នុងលោកមាន ៤ យ៉ាង បានដល់ ១. **វជិរាវុធ** របស់ព្រះឥន្ទ្រ ២. **គទាវុធ** របស់ស្តេចវេស្សវ័ណ ៣. **នយ្យនាវុធ** របស់ស្តេចយមរាជ

៤.ទុស្សាវុធ (អាវុធគឺសំពត់ជូតក្បាល) របស់អាឡវកយក្ខ អាវុធទាំងអស់នេះ ជាអាវុធប្រសើរក្នុងលោក ។

បើព្រះឥន្ទ្រទ្រង់ពិរោធកើតឡើង ហើយទ្រង់គ្រវែងវជិរាវុធទៅត្រង់កំពូលភ្នំសិនេរុ ក៏អាចទម្លាយភ្នំសិនេរុ ដែលមានកម្ពស់ ១ សែន ៦ ម៉ឺន ៨ ពាន់យោជន៍ ធ្លាក់ទៅដល់ខាងក្រោមបាន ។ ចំណែកស្តេចវេស្សវណៈ ក្នុងកាលដែលនៅជាបុថុជ្ជន កាលសេចក្តីក្រោធកើតឡើង ក៏បានលែងគទាវុធ បានដល់អាវុធ គឺដំបងពេជ្រ។ ក៏ទៅវាយក្បាលយក្ខច្រើនពាន់ឲ្យធ្លាក់ចុះហើយ។ ក៏ត្រឡប់មកនៅក្នុងដៃដូចដើមវិញ ។ ចំណែកស្តេចយមរាជ កាលបើសេចក្តីក្រោធកើតឡើងហើយ បានសម្លឹងមើលពពួកកុម្ភណ្ឌ ពួកកុម្ភណ្ឌទាំងនោះ ក៏ខ្ទេចជាផងទៅដូចជាស្វ៊ីកឈើងាប់ ដែលនៅលើអម្បែងក្តៅដូច្នោះ ។ រីឯអាឡវកយក្ខ កាលបើសេចក្តីក្រោធកើតឡើង បើគេគ្រវែងសំពត់ជូតក្បាលទៅលើអាកាស ទឹងរាំងភ្លៀង ១២ ឆ្នាំ បើគេគ្រវែងសំពត់ជូតក្បាលទៅលើផែនដី វត្ថុទាំងពួងដែលនៅលើផែនដី មានដើមឈើ និងស្មៅជាដើម

ត្រូវស្លាប់មិនដុះអស់ ១២ ឆ្នាំ បើគេគ្រវែងទៅមហាសមុទ្រ ទឹកមហាសមុទ្រក៏នឹងស្ងួតហួតហែងទៅ ដូចជាតំណក់ទឹកនៅលើអម្បែងក្តៅជូរច្នោះ បើគេគ្រវែងទៅត្រង់ភ្នំផ្សែងៗ ដូចជាភ្នំសិនេរុជាដើម ភ្នំទាំងនោះនឹងត្រូវបែកខ្ចាត់ខ្ចាយទៅ ។

គ្រានោះ អាឡវកយក្ខ **បានដោះសំពត់ជូតក្បាល** ដែលមានអានុភាពសម្បើមយ៉ាងក្រៃលែងនោះមកកាន់ ។ ក្នុងពេលនោះ ពួកទេវតាក្នុងម៉ឺនចក្រវាឡដោយច្រើន បានប្រញាប់ប្រញាល់មកប្រជុំគ្នា ដោយគិតថា ថ្ងៃនេះ ព្រះមានព្រះភាគ ទ្រង់ទូន្មានអាឡវកយក្ខ ពួកយើងនឹងបានស្តាប់ព្រះធម៌ទេសនាក្នុងទីនោះមិនខាន ។ គ្រានោះ ទេវតាទាំងឡាយដែលត្រូវការនឹងមើលពុទ្ធានុភាព ក្នុងការទ្រង់តយុទ្ធ ទើបបានមកប្រជុំគ្នា ។ អាកាសទាំងមូលក្នុងបរិវេណានោះ បានក្តៅឡើងដោយទេវតាទាំងឡាយមកប្រជុំគ្នា ។ អាឡវកយក្ខ បានដើរត្រឡប់ទៅត្រឡប់មក ក្នុងស្ថានទីជិតព្រះសម្ពុទ្ធ ហើយបានគ្រវែងសំពត់ជូតក្បាលតម្រង់ទៅព្រះកគវា ។ ប៉ុន្តែសំពត់ជូតក្បាលដែលជាអាវុធដ៏ពិសេសនោះ បានបណ្តាលសំឡេង

ឡើង ដែលគួរឲ្យភ័យខ្លាចនៅឰដ៏អាកាស ហាក់បីដូចជាសំឡេងរន្ទះមួយសែនដង ហើយក៏កើតជាផ្សែងខ្មួលខ្មាញ់នៅឰដ៏អាកាស មួយសន្ទុះក៏ឆេះជាអណ្តាតភ្លើងធំឡើង លុះមកដល់ទីជិតនៃព្រះវិជិតមារ ក៏ធ្លាក់ចុះមកទៀបព្រះបាទ ប្រៀបបីដូចជាសំពត់ជូតជើងដូច្នោះដែរ ទាំងនេះដើម្បីទម្លាក់មានះរបស់អាឡវកយក្ខ ។

កាលអាឡវកយក្ខ បានឃើញសភាពការណ៍ដូច្នេះ ក៏ដល់នូវភាពជាអ្នកអស់ឫទ្ធិតេជៈ អស់នូវភាពស្រវឹង អស់នូវមានៈ គឺការប្រកាន់ខ្លួន ដូចជាគោឧសភរាជដែលមានស្នែងបាក់ ឬប្រៀបបីដូចជាអាសិរពិសដែលត្រូវគេជកចង្កឹមហើយ ដូច្នោះ គេទើបគិតថា សូម្បីសំពត់ជូតក្បាលរបស់យើង ក៏មិនអាចធ្វើអ្វីសមណៈនេះបាន ដោយហេតុអ្វីហ្ន៎ ហើយគេទើបដឹងបានថា កើតដោយសមណៈរូបនេះប្រកបដោយមេត្តាព្រហ្មវិហារ បើដូច្នោះ យើងនឹងធ្វើឲ្យសមណៈរូបនេះ លះបង់នូវមេត្តាចេញសិន ។គេគិតដូច្នេះហើយ ទើបចូលទៅជិត ហើយពោលវាចាបណ្តេញព្រះសម្ពុទ្ធថា ហេតុអ្វី ក៏លោកមកគង់នៅក្នុងទីនេះ ទាំង

ដែលមិនបានទទួលការអនុញ្ញាតអំពីយើង ដែលជាម្ចាស់ផ្ទះ ហើយមកគង់នៅកណ្តាលផ្ទះរបស់យើង ដែលពោរពេញទៅដោយមាតុគ្រាម ដូចបុរសម្ចាស់ផ្ទះ ការដែលបរិភោគរបស់ដែលម្ចាស់គេមិនបានឲ្យ និងការច្រឡូកច្រឡំទៅដោយពួកស្ត្រី មិនសមគួរដល់សមណៈ មិនមែនឬបើលោកតាំងនៅក្នុងធម៌របស់សមណៈ ចូរលោកចេញទៅ។ គ្រានោះ ព្រះសម្ពុទ្ធទ្រង់ជ្រាបថា អាឡវកយក្ខ កំពុងតែមានចិត្តរីងស្ងួត តថាគតមិនអាចដឹកនាំបាន ដូចឆ្កែកាច បើបុគ្គលយកប្រមាត់លាបត្រង់ច្រមុះក៏រីងរឹតតែកាចឡើង យ៉ាងណា បុគ្គលដែលមានចិត្តរីងស្ងួត បើតថាគតដឹកនាំក្នុងពេលដែលកំពុងតែមានចិត្តរីងស្ងួត ក៏រីងរឹតតែរីងស្ងួតខ្លាំងឡើងទៀត ដូច្នោះ តមក កាលគេមានចិត្តទន់ភ្លន់ ទើបអាចទូន្មានប្រៀនប្រដៅគេបាន ព្រះសាស្តាទ្រង់ជ្រាបដូច្នេះហើយ ទើបទ្រង់ធ្វើតាមពាក្យរបស់អាឡវកយក្ខ ។

រឿងដែលអាឡវកយក្ខពោលបណ្តេញព្រះទសពល ឲ្យចេញអំពីទីលំនៅរបស់ខ្លួន ដើម្បីធ្វើឲ្យព្រះមានជោគវិនិច្ឆ័យនោះ ដូចមាន

សម្តែងប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ** និងក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ដែលមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងលំនៅរបស់យក្ខឈ្មោះអាឡវក: ក្នុងដែនអាឡវី ។ ក្នុងគ្រានោះ អាឡវកយក្ខ ចូលទៅរកព្រះមានជោគ លុះចូលទៅដល់ហើយ ទើបពោលនឹងព្រះទសពលយ៉ាងនេះថា បពិត្រសមណ: ចូរលោកចេញទៅ ។ ព្រះមានព្រះភាគទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចេញទៅ ។ អាឡវកយក្ខ ពោលថា ម្នាលសមណ: ចូរលោកមកវិញ ។ ព្រះមុនីទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចូលមកវិញ ។ អាឡវកយក្ខ បានពោលនឹងព្រះជិនស្រី យ៉ាងនេះអស់វារៈពីរដងថា ម្នាលសមណ: ចូរលោកចេញទៅ ។ ព្រះលោកនាយក ក៏ទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចេញទៅ ។ អាឡវកយក្ខ ពោលថា ម្នាលសមណ: ចូរលោកមកវិញ ។ ព្រះកគវាទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចូលមកវិញ ។ អាឡវកយក្ខ

បានពោលនឹងព្រះជិនស្រីយ៉ាងនេះអស់គម្រប់ចីជង៥ថា ម្នាលសមណៈ ចូរលោកចេញទៅវិញ ។ ព្រះមុនីទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចេញទៅ ។ អាឡវកយក្ខ ពោលថា ម្នាលសមណៈ ចូរលោកចូលមកវិញ ។ព្រះកគវាទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ទ្រង់ចូលមកវិញ ។

អាឡវកយក្ខ បានពោលនឹងព្រះលោកនាថ អស់វារៈ ៤ ដង ទៀតថា ម្នាលសមណៈ ចូរលោកចេញទៅវិញ ។ ព្រះកគវា ទទួលថា ម្នាលអាវុសោ តថាគតនឹងមិនចេញទៅទេ កិច្ចណាអ្នកឯងត្រូវធ្វើ ចូរអ្នកឯងធ្វើកិច្ចនោះចុះ ។ ម្នាលសមណៈ ខ្ញុំនឹងសួរប្រស្នាចំពោះលោក បើលោកមិនដោះប្រស្នាខ្ញុំទេ ខ្ញុំនឹងបន្សាត់ចិត្តលោក ឬវះហឫទ័យរបស់លោក ពុំនោះសោត ខ្ញុំនឹងចាប់ជើងលោកបោះទៅឯត្រើយខាងនាយនៃទន្លេគង្គា ។ ព្រះសម្មាសម្ពុទ្ធត្រាស់ថា ម្នាលអាវុសោ បុគ្គលណាបន្សាត់ចិត្តតថាគត ឬវះហឫទ័យ ឬក៏ចាប់ជើងគ្រវែងទៅឯត្រើយខាងនាយនៃទន្លេគង្គា តថាគត មិនដែលឃើញបុគ្គលនោះសោះ ក្នុងលោក

ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសម្នាលអារុំសោ បើដូច្នោះ អ្នកឯងចូរសួរប្រស្នា ដែលប៉ុនប៉ងសួរមកចុះ។

អាឡវកយក្ខ សួរថា អ្វីហ្ន៎ ជាទ្រព្យប្រសើររបស់បុរសក្នុងលោកនេះ ? អ្វីហ្ន៎ ដែលបុគ្គលសន្សំដោយប្រពៃហើយ នាំសេចក្តីសុខមកឲ្យ ? របស់អ្វី ដែលមានរសឆ្ងាញ់វិសេសជាងរសទាំងឡាយ ? ពួកអ្នកប្រាជ្ញពោលថា បុគ្គលដែលរស់នៅដូចម្តេច ឈ្មោះថារស់នៅប្រសើរ ?

ព្រះសម្មាសម្ពុទ្ធត្រាស់ថា សទ្ធាជាទ្រព្យដ៏ប្រសើរ របស់បុរសក្នុងលោកនេះ សុចរិតធម៌ដែលបុគ្គលសន្សំដោយប្រពៃ តែងនាំសេចក្តីសុខមកឲ្យ ពាក្យពិតមានរសឆ្ងាញ់វិសេសជាងរសទាំងឡាយ ពួកអ្នកប្រាជ្ញពោលថា បុគ្គលដែលរស់នៅដោយប្រាជ្ញា ឈ្មោះថារស់នៅប្រសើរ។

អា. បុគ្គលឆ្លងអន្ទង់បាន ដោយអ្វីហ្ន៎ ? ឆ្លងសមុទ្របាន ដោយអ្វី ? បុគ្គលកន្លងសេចក្តីទុក្ខបាន ដោយអ្វី ? បរិសុទ្ធបាន ដោយអ្វី ?

ព. បុគ្គលឆ្លងអន្ទង់បាន ដោយសទ្ធា ឆ្លងសមុទ្របាន ដោយសេចក្តីមិនប្រមាទ បុគ្គលកន្ទងសេចក្តីទុក្ខបាន ដោយសេចក្តីព្យាយាម បរិសុទ្ធបាន ដោយប្រាជ្ញា ។

អា. បុគ្គលបានប្រាជ្ញាដោយអ្វី ? បានទ្រព្យដោយអ្វី ? ដល់នូវសេចក្តីសរសើរដោយអ្វី ? ចងពួកមិត្របានដោយអ្វី ? បុគ្គលលះលោកនេះ ទៅកាន់លោកខាងមុខ មិនសោកសៅ ក្នុងលោកខាងមុខ ដោយអ្វី ?

ព. បុគ្គលជឿធម៌របស់ព្រះអរហន្តទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីដល់ព្រះនិព្វាន បុគ្គលមានប្រាជ្ញាមិនប្រមាទ កាលស្តាប់ដោយប្រពៃ រមែងបាននូវប្រាជ្ញា បុគ្គលមានការងារសមតាមកាល មានធុរៈ (មិនទម្លាក់ចោល) ជាអ្នកឥស្សី រមែងបាននូវទ្រព្យ បុគ្គលដល់នូវសេចក្តីសរសើរដោយសច្ចៈ បុគ្គលអ្នកឲ្យ រមែងចងពួកមិត្របាន បុគ្គលដែលមានសទ្ធាគ្រប់គ្រងផ្ទះ ត្រូវមានធម៌ ៤ ប្រការ គឺ ***សច្ចៈ*** *(ពាក្យពិត) ១* ***ធម្មៈ*** *(បញ្ញា) ១* ***ធិតិ*** *(ព្យាយាម) ១* ***ចាគៈ***

(ការបរិច្ចាគ) ១ រមែងមិនសោកសៅក្នុងលោក ខាងមុខដោយពិត បើដូច្នោះ ចូរអ្នកសួរសមណព្រាហ្មណ៍ឯទៀតឲ្យច្រើនគ្នាចុះ ក្រែងមានធម៌ណាក្នុងលោកនេះវិសេសជាង **សច្ចៈ ធម្មៈ ធិតិ ចាគៈ** ទៅទៀត ។

អា. ក្នុងវេលានេះ ខ្ញុំនឹងសួរពួកសមណព្រាហ្មណ៍ច្រើនគ្នាដូចម្តេចបាន (ព្រោះ) ខ្ញុំទើបតែដឹងប្រយោជន៍ ក្នុងបរលោកក្នុងថ្ងៃនេះ ដោយសារព្រះពុទ្ធ ស្តេចមកគង់ក្នុងដែនអាឡវីជាប្រយោជន៍ដល់ខ្ញុំ ។ ខ្ញុំទើបតែដឹងក្នុងថ្ងៃនេះថា ទានដែលគេឲ្យចំពោះបុគ្គលណាមានផលច្រើន ខ្ញុំនឹងចេញពីស្រុកមួយ ទៅស្រុកមួយ ចេញពីបុរីមួយ ទៅបុរីមួយ នមស្ការនូវព្រះសម្ពុទ្ធផង ព្រះធម៌ដ៏ប្រសើរផង ។

រឿងរបស់ហត្ថកអាឡវកឧបាសក ដែលបានសម្រេចមគ្គផលមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាមនោរថបូរណី** និងក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដូចមានសេចក្តីថា ៖

ក្នុងពេលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ឆ្លើយបញ្ហា ដែលអាឡវកយក្ខក្រាបទូលសួរចប់ អាឡវកយក្ខក៏បានសម្រេចសោតាបត្តិផល

ជាព្រះអរិយបុគ្គលថ្នាក់ដំបូង ក្នុងព្រះពុទ្ធសាសនានេះដែរ ។ លុះដល់ព្រឹកស្អែកឡើង ពួករាជបុរសរកកូនក្មេងក្នុងព្រះនគរ ដែលសមគួរនឹងចាប់បញ្ជូនទៅក្នុងពេលដែលនាំភាជនអាហារមិនបាន ទើបក្រាបទូលព្រះបាទអាឡវីឲ្យទ្រង់ជ្រាប ។ ព្រះរាជាអាឡវីត្រាស់ថា ទារកមាននៅក្នុងស្ថានទីដែលមិនគួរចាប់ទៅមិនមានឬ ពួករាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព ទារកមាន គឺព្រះរាជឱរសរបស់ព្រះអង្គ ដែលនៅក្នុងព្រះរាជវាំង ។ ព្រះរាជាអាឡវីបានមានព្រះរាជតម្រាស់ថា សូម្បីថាជាបុត្ររបស់យើងៗ ក៏ពេញចិត្តនឹងឲ្យពួកលោកចាប់យកទៅ ដើម្បីរក្សាជីវិតរបស់យើង ហើយកាលបើយើងនៅមានជីវិតរស់នៅ ក៏អាចនឹងមានបុត្របានទៀត ពួកលោកចូរបញ្ជូនទារកទៅព្រមជាមួយភាជន-អាហារចុះ ។

ក្នុងខណៈនោះ ព្រះរាជទេវី ដែលជាព្រះរាជមាតារបស់ព្រះអាឡវកកុមារ ទ្រង់កំពុងតែងូតទឹកជម្រះព្រះកាយឲ្យ ទ្រង់លាបមៀតាក់តែងព្រះកាយឲ្យព្រះអង្គហើយ ទើបទ្រង់ដណ្តប់ដោយព្រះភូសា

សាច់ដ៏ឃ្មាងល្អ ហើយឲ្យផ្ទំលើភ្លៅ ។ គ្រានោះ ពួករាជបុរស កាលបានទទួលព្រះរាជបញ្ជាហើយ ទើបនាំគ្នាទៅក្រាបបង្គំទូលព្រះរាជទេវី ឲ្យទ្រង់ដឹងដល់ព្រះរាជបំណង ហើយបានទទួលព្រះអាឡវកកុមារទៅ ដោយក្រាបបង្គំទូលថា បពិត្រព្រះនាង ថ្ងៃស្អែកនេះ ព្រះរាជកុមារនេះ នឹងត្រូវជាអាហាររបស់អាឡវកយក្ខ ។ ចំណែកព្រះរាជមាតារបស់អាឡវកកុមារ និងពួកស្រីស្នំទាំង ៦ ម៉ឺន ៨ ពាន់នាក់ គ្រប់គ្នាបានយំខ្សឹកខ្សួលទ្រហឹងអឺងកងពេញព្រះរាជវាំង ។ ពួករាជបុរសទាំងនោះ បានជួយគ្នានាំព្រះរាជកុមារ ព្រមទាំងកាជនអាហារទៅកាន់ទីកន្លែងរបស់អាឡវកយក្ខ ។

ការជួបដោយហេតុការណ៍ ដែលកើតឡើងគួរស្រែង គឺការក្រាបទូលពាក្យចុងក្រោយរបស់អាឡវកយក្ខ និងភាពក្លីស្វាង់នៃរាត្រីសំឡែងបន្ទឹសាធុការនិងការនាំព្រះអាឡវកកុមារមកឲ្យដល់អាឡវកយក្ខ បានមានឡើងក្នុងពេលជាមួយគ្នា ។ ពួករាជបុរស បានស្តាប់សំឡែងសាធុការ គឺបន្ទឹវាចាសរសើរ ឬលើកតម្កើង ក៏នាំគ្នានឹកថា សំឡែង

សាធុការដូច្នេះ រៀវរៃលង់តែព្រះសម្ពុទ្ធចេញហើយ រមែងមិនមានដល់បុគ្គលដទៃ ព្រះសម្ពុទ្ធគង់យាងមកក្នុងកន្លែងនេះពិតប្រាកដ ។ ពេលរាជបុរសនឹកដូច្នេះហើយ ក៏បានឃើញព្រះរស្មីរបស់ព្រះសម្ពុទ្ធប្រាកដផ្សាយចេញទៅ ទើបមិនឈរនៅខាងក្រៅបរិវេណដើមជ្រៃ ដូចអំពីមុន ព្រោះអស់សេចក្តីរង្គៀស និងអស់សេចក្តីភ័យខ្លាចហើយ បាននាំគ្នាចូលទៅខាងក្រោមដើមជ្រៃ ដែលជាបរិវេណហួងហែងរបស់អាឡវកយក្ខមួយរំពេចនោះឯង លុះចូលទៅដល់ហើយ ក៏បានឃើញព្រះលោកនាថគង់ប្រថាប់នៅក្នុងវិមានរបស់អាឡវកយក្ខ ទាំងបានឃើញអាឡវកយក្ខឈរប្រណម្យអញ្ជលី ទើបពោលជាមួយអាឡវកយក្ខថា នែមហាយក្ខ ព្រះរាជកុមារ និងភាជនអាហារនេះ ពួកយើងនាំយកមកដើម្បីជាពលិកម្មដល់លោក សូមលោកបរិភោគ ឬធ្វើតាមសេចក្តីត្រូវការចុះ ។ គ្រានោះអាឡវកយក្ខបានស្តាប់ដូច្នេះហើយ ក៏កើតសេចក្តីអៀនខ្មាស ព្រោះខ្លួនបានជាព្រះអរិយសាវកហើយ ទើបអង្គុយឈ្ងោកមុខនៅស្ងៀម ។

ព្រះសាស្តា ទើបត្រាស់ជាមួយអាឡវកយក្ខថា ម្នាលអាឡវក:

អ្នកមិនត្រូវអៀនខ្មាសទេ ចូរអ្នកទទួលយកទារកនោះ ហើយនាំយក មកជាក់លើព្រះហស្តតថាគតមក ។ អាឡវកយក្ខ ទើបបានទទួលព្រះ រាជកុមារអំពីដៃ របស់ព្រះរាជបុរសដោយដៃទាំងពីរ ហើយបង្អោន ចូលទៅជាក់លើព្រះហស្តរបស់ព្រះមុនី ព្រមទាំងក្រាបទូលថា បពិត្រ ព្រះទសពល កុមារនេះគេបានបញ្ជូនមកឲ្យដល់ខ្ញុំព្រះអង្គ តែខ្ញុំព្រះអង្គ សូមថ្វាយកុមារនេះដល់ព្រះបរមគ្រូ ហេតុដូច្នេះ សូមព្រះអង្គទទួលយក នូវព្រះរាជកុមារនេះទុកដើម្បីប្រយោជន៍ និងសេចក្តីសុខដល់កុមារនេះ ផងចុះ ព្រះអង្គ ។ អាឡវកយក្ខ កាលក្រាបទូលដូច្នេះហើយ ទើប បានក្រាបទូលឡើងទៀតថា ខ្ញុំព្រះករុណាមានចិត្តធូរឡើង ដោយការ សប្បាយចិត្ត សូមថ្វាយព្រះរាជកុមារនេះ ដែលមានលក្ខណៈនៃបុណ្យ ទាំង ១០០ ដែលប្រកបដោយអវយវៈដ៏ល្អល្អះ នៅក្នុងចំណែកផ្សេងៗ នៃរាងកាយ ទាំងមានពណ៌សម្បុរល្អដល់ព្រះលោកនាយក សូមព្រះ បរមសាស្តា ដែលទ្រង់មានទូវញ្ញាណចក្ខុ សូមទ្រង់ទទួលកុមារនេះទុក ដើម្បីជាប្រយោជន៍ដល់សត្វលោកចុះ ព្រះអង្គ ។

ព្រះមានព្រះភាគ ទ្រង់ទទួលព្រះរាជកុមារនោះទុកហើយ កាលព្រះអង្គ ទ្រង់ទទួលព្រះរាជកុមារហើយ បានត្រាស់ព្រះគាថា ដែលជាគ្រឿងឃុំគ្រងការពារ ដើម្បីឲ្យកើតជាមង្គល ដល់អាឡវកយក្ខ និងព្រះរាជកុមារនោះ ដោយព្រះលោកនាយកត្រាស់ថា សូមឲ្យកុមារនេះមានអាយុយឺនយូរ ម្នាលអាឡវកយក្ខ អ្នកចូរមានសេចក្តីសុខ កុំមានជំងឺតម្កាត់ឡើយ ចូរតាំងខ្លួននៅដើម្បីជាប្រយោជន៍ដល់សត្វលោក ។ កាលព្រះលោកនាយក ទ្រង់ទទួលព្រះរាជកុមារហើយ ក៏ទ្រង់បញ្ជូនព្រះរាជកុមារត្រឡប់ទៅជាក់លើដៃអាឡវកយក្ខម្តងទៀត ។ ចំណែកអាឡវកយក្ខទទួលព្រះរាជកុមារហើយ បានជាក់ព្រះរាជកុមារឲ្យទៅលើដៃ របស់ពួកព្រាជបុរសវិញ ។ ដោយហេតុការណ៍ដូចពោលមកនេះ ព្រះរាជកុមារទើបទ្រង់មានព្រះនាមថា **ហត្ថកអាឡវកៈ** ព្រោះព្រះកុមារជាអ្នកជាក់អំពីដៃមួយទៅដៃមួយទៀត គឺពួកព្រាជបុរសបានបញ្ជូនព្រះរាជកុមារជាក់លើដៃរបស់អាឡវកយក្ខ ហើយអាឡវកយក្ខបានយកទៅជាក់លើព្រះហស្តព្រះសម្ពុទ្ធ ហើយព្រះមហាមុនីប្រទានព្រះរាជកុមារ

ជាក់ទៅលើដៃរបស់អាឡវកយក្ខៗ បានបញ្ជូនឲ្យត្រឡប់ទៅជាក់លើដៃពួករាជបុរសទៀត ។ ពួកព្រះរាជបុរសទាំងនោះ បានទទួលព្រះហត្ថក-អាឡវកកុមារហើយ ក៏មានចិត្តសប្បាយរីករាយ ហើយនាំយកព្រះហត្ថកអាឡវកកុមារ ទៅកាន់សម្នាក់របស់ព្រះរាជាអាឡវី ។ ព្រះរាជាទ្រង់ទតព្រះនេត្រឃើញព្រះហត្ថកអាឡវកកុមារហើយ ទ្រង់មានព្រះតម្រិះក្នុងព្រះទ័យថា ថ្ងៃនេះ អាឡវកយក្ខ មិនទទួលភោជនអាហារ ហើយត្រាស់សួរពួករាជបុរសថា អ្នកទាំងឡាយ ពួកលោកត្រឡប់មកដោយអាការយ៉ាងនេះបានព្រោះហេតុអ្វី ?

ពួករាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព ភាពរីករាយនិងសេចក្តីចម្រើនបានកើតឡើងហើយ ដល់រាជត្រកូល ព្រោះហេតុថា ព្រះលោកនាថ យាងមកគង់ប្រថាប់នៅក្នុងទីលំនៅរបស់អាឡវកយក្ខ ហើយទ្រង់ទូន្មានអាឡវកយក្ខឲ្យជាឧបាសកហើយ អាឡវកយក្ខ ទើបប្រគល់ព្រះរាជកុមារ ឲ្យដល់ទូលព្រះបង្គំវិញ ព្រះអង្គ ។ ចំណែកព្រះមានបុណ្យប្រទានជាត្រ និងចីវរឲ្យអាឡវកយក្ខកាន់ ហើយបាន

ទ្រង់ពុទ្ធដំណើរទៅកាន់នគរអាឡវី អាឡវកយក្ខកំពុងដើរតាមព្រះមុនី ទៅបានពាក់កណ្តាលផ្លូវ ក៏កើតសេចក្តីអៀនខ្មាសឡើងមក ក៏គិតនឹងត្រឡប់ លុះបានវេលា (គឺពេលដែលទ្រង់) យាងបិណ្ឌបាត ទើបក្រាបទូលលាព្រះមានជោគ ដើម្បីនឹងវិលទៅកាន់លំនៅរបស់ខ្លួនវិញ ។ ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលអាឡវក: អ្នកមានសេចក្តីអៀនខ្មាសឬ? អាឡវក:ក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណាមានសេចក្តីអៀនខ្មាស ព្រះអង្គ ព្រោះដោយពួកអ្នកស្រុក ត្រូវឲ្យមាតា និងបិតាខ្លះ បុត្រ និងភរិយាខ្លះ ត្រូវស្លាប់បាត់បង់ទៅព្រោះអាស្រ័យខ្ញុំព្រះអង្គជាដើមហេតុ កាលពួកអ្នកស្រុកទាំងនោះឃើញខ្ញុំព្រះអង្គ ក៏នឹងប្រហារប្រទូស្តខ្ញុំព្រះអង្គ ដោយកំណាត់ឈើ ឬដោយដុំដី និងដោយព្រួញខ្លះ ព្រោះហេតុនេះ បពិត្រព្រះភគវា ខ្ញុំព្រះអង្គទើបសូមត្រឡប់វិលទៅវិញ ព្រះអង្គ ។

គ្រានោះ ព្រះជិនស្រីទើបត្រាស់ថា ម្នាលអាឡវក: ភ័យដែលកើតដល់អ្នក ដែលទៅជាមួយតថាគត រមែងមិនមាន អ្នកចូរជាអ្នក

តាំងចិត្តឲ្យសប្បាយចុះ ព្រះអង្គទ្រង់បានឈប់ស្នាក់នៅត្រង់ព្រៃមួយកន្លែង ដែលនៅមិនឆ្ងាយអំពីព្រះនគរ ។ ចំណែកព្រះរាជាអាឡវី ទ្រង់ជ្រាបថា ព្រះសយម្ភូ ស្តេចយាងមកគង់ប្រថាប់នៅក្នុងដងព្រៃធំនោះ ទើបព្រះរាជានាំពួកអ្នកស្រុកចូលទៅគាល់ព្រះអង្គ ។ ព្រះភគវាត្រាស់និទានរឿងដែលព្រះអង្គទ្រង់ច្បាំងជាមួយអាឡវកយក្ខ និងទ្រង់សម្តែងព្រះធម៌ដល់បរិស័ទ ដែលមកប្រជុំគ្នាក្នុងទីនោះ ។ កាលព្រះសយម្ភូទ្រង់ត្រាស់ទេសនាចប់ ទេវតា និងមនុស្សចំនួន ៨៤.០០០ បានផឹកអមតធម៌ បានដល់ធម៌ដែលប្រៀបដូចទឹកអម្រឹត គឺទឹកដែលធ្វើឲ្យអ្នកផឹកមិនស្លាប់ សំដៅដល់ព្រះនិព្វាន ។ តអំពីនោះ ព្រះរាជាអាឡវី និងអ្នកនគរបាននាំគ្នាធ្វើលំនៅឲ្យដល់អាឡវកយក្ខ ហើយតាំងពិធីថ្វាយពលីគឺគ្រឿងបួងសួងជាប្រចាំឆ្នាំ ។ អាឡវកយក្ខ បានសង្គ្រោះអ្នកនគរដោយការរក្សាតាមធម៌ ។ ចំណែកហត្ថកអាឡវកកុមារ ទ្រង់បានចម្រើនព្រះជន្មវស្សាឡើងដ៏ធំក្លាហើយ បានទៅស្តាប់ព្រះធម្មទេសនារបស់ព្រះទសពល ក៏បានសម្រេចជាព្រះអនាគាមី ហើយព្រះអង្គទ្រង់មានអរិយ

ឧបាសក ៥០០ នាក់ជាបរិវារ តាមហែហមគ្រាច់ទៅគ្រប់ៗ កាល ។

មានរឿងដែលព្រះភគវាគ្រាស់ដល់ភាពជាអ្នកមាន **អច្ឆរិយធម៌** របស់ហត្ថកអាឡវកឧបាសក ដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ប្រថាប់នៅឯអាគាឡវចេតិយ ជិតក្រុងអាឡវី ។ គ្រាមួយ ព្រះពុទ្ធអង្គគ្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្រាបទូលទទួលថា ព្រះករុណាព្រះអង្គ ព្រះសម្ពុទ្ធកាលជីងថា ភិក្ខុទាំងឡាយក្រាបទូលទទួលហើយ ទើបគ្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំហត្ថកអាឡវកឧបាសក អ្នកក្រុងអាឡវីទុក ព្រោះឧបាសកនេះជាអ្នកប្រកប ដោយ **អច្ឆរិយធម៌** គឺធម៌ដែលគួរឲ្យអស្ចារ្យ ៧ ប្រការ ដែលមិនធ្លាប់មានមកឡើយ **អច្ឆរិយធម៌ ៧ ប្រការនោះ** បានដល់អ្វីខ្លះ ?

ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវកឧបាសក អ្នកក្រុងអាឡវី

(ជាអ្នកមានធម៌ទាំងនេះ គឺ) **១. ជាអ្នកមានសទ្ធា ២. ជាអ្នកមានសីលបរិសុទ្ធ ៣. ជាអ្នកមានហិរិ ៤. ជាអ្នកមានឱត្តប្បៈ ៥. ជាពហូសូត ៦. ជាអ្នកមានចាគៈ ៧. ជាអ្នកមានបញ្ញា** ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចាំហត្ថកអាឡវកឧបាសក អ្នកក្រុងអាឡវីថា ជាអ្នកប្រកបដោយអច្ឆរិយធម៌ ៧ ប្រការទាំងនេះ ដែលមិនធ្លាប់មានមកកាលព្រះសាស្តាត្រាស់ព្រះពុទ្ធដីកានេះចប់ហើយ ទើបទ្រង់ក្រោកចាកអាសនៈ យាងចូលទៅកាន់ព្រះវិហារ ។

កាលដល់វេលាព្រឹក មានភិក្ខុមួយរូបគ្រងចីវរជាបរិមណ្ឌលកាន់បាត្រ ហើយបានចូលទៅកាន់និវេសន៍របស់ហត្ថកអាឡវកឧបាសកលុះនិមន្តចូលទៅដល់ហើយ ទើបគង់លើអាសនៈដែលគេក្រាលទុក ។ តអំពីនោះ ហត្ថកអាឡវកឧបាសក បានចូលទៅរកភិក្ខុអង្គនោះ ថ្វាយបង្គំហើយ ក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ ភិក្ខុអង្គនោះ ទើបពោលនឹងអាឡវកឧបាសកថា ម្នាលឧបាសកដ៏ចម្រើន ព្រះសាស្តា ទ្រង់ត្រាស់

ព្យាករសរសើរថា លោកជាអ្នកប្រកបដោយអច្ឆរិយធម៌ ៧ ប្រការ គឺ **ជាអ្នកមានសទ្ធា មានសីល មានហិរិ មានឱត្តប្បៈ មានការសិក្សារៀនសូត្រច្រើន មានចាគៈ មានបញ្ញា** ។ ហត្ថកអាឡវកឧបាសកពិតជេរវាចាថា បពិត្រលោកម្ចាស់ដ៏ចម្រើន គ្រហស្ថឯណាមួយដែលស្មៀក.ស មិននៅក្នុងហានៈ ដែលព្រះបរមសាស្តាទ្រង់ព្យាករនេះខ្លះឬ ? កិកុនោះពោលតបថា ម្នាលឧបាសកដ៏ចម្រើន មិនមានឡើយ ។ ហត្ថកអាឡវកឧបាសក ទើបពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើយ៉ាងនោះ ក៏ជាការល្អហើយ !

កិកុអង្គនោះ កាលបានទទួលបិណ្ឌបាតក្នុងនិវេសន៍របស់ហត្ថកអាឡវកឧបាសកហើយ ក្រោកចាកអាសនៈត្រឡប់ទៅ ហើយក្នុងវេលាក្រោយភត្តកិច្ច លោកបានចូលទៅគាល់ព្រះមហាមុនី ក្រាបទូលឲ្យទ្រង់ជ្រាបតាមពាក្យ ដែលលោកសន្ទនាជាមួយហត្ថកអាឡវកឧបាសក ទាំងអស់ឲ្យទ្រង់ជ្រាប ។ គ្រានោះ ព្រះពុទ្ធអង្គទើបត្រាស់ថា

ម្នាលភិក្ខុ ល្អហើយ កុលបុត្រនោះជាអ្នកមានសេចក្តីជ្រាជ្ញាតិច មិនបំណងឲ្យអ្នកដទៃ ដឹងដល់កុសលធម៌ ដែលមាននៅក្នុងខ្លួនគេទេ ម្នាលភិក្ខុ បើយ៉ាងនោះ អ្នកចូរចាំហត្ថកអាឡវកឧបាសកទុកថា ជាអ្នកមានអច្ឆរិយធម៌ គឺធម៌ដែលគួរឲ្យអស្ចារ្យ ដោយចំពោះភាពជាអ្នកជ្រាជ្ញាតិច មិនបំណងឲ្យអ្នកដទៃដឹង ដល់កុសលធម៌ដែលមាននៅក្នុងខ្លួនរបស់គេ ។

ហើយមានរឿងសង្គហវត្ថុ និងអច្ឆរិយធម៌របស់ហត្ថកអាឡវកឧបាសក ដែលមានសម្តែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត** និងក្នុង **អដ្ឋកថាមនោរថបូរណី** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះលោកនាថ ប្រថាប់នៅត្រង់អាគាឡវចេតិយ ជិតក្រុងអាឡវី គ្រានោះ ហត្ថកអាឡវកឧបាសក អ្នកក្រុងអាឡវី មានឧបាសកប្រមាណ ៥០០ នាក់ តាមហែហមនោះ បានចូលទៅគាល់ព្រះលោកនាថដល់ទីគង់ប្រថាប់ ថ្វាយបង្គំហើយ ក៏នាំគ្នាអង្គុយក្នុងទី

ជ័សមគួរ ។ គ្រានោះ ព្រះសាស្តាត្រាស់សួរហត្ថកអាឡវកឧបាសកថា ម្នាលហត្ថក: អ្នកមានបរិស័ទច្រើន អ្នកសង្គ្រោះបរិស័ទ ដែលមានចំនួនច្រើននេះ ដោយវិធីដូចម្តេច ? ហត្ថកអាឡវកឧបាសកក្រាបទូលថា បពិត្រព្រះអង្គជ័ចម្រើន ព្រះអង្គបានទ្រង់សម្តែងសង្គហវត្ថុ ៤ ប្រការទុក ខ្ញុំព្រះករុណាសង្គ្រោះបរិស័ទ មានចំនួនច្រើននេះ ដោយសង្គហវត្ថុ ៤ ប្រការទាំងនោះឯង បពិត្រព្រះអង្គជ័ចម្រើន ខ្ញុំព្រះករុណាជីងថា បុគ្គលនេះគួរសង្គ្រោះដោយការចែករំលែក ខ្ញុំព្រះអង្គក៏សង្គ្រោះដោយការឲ្យទាន បុគ្គលនេះគួរសង្គ្រោះដោយពាក្យសម្តីដែលទន់ភ្ងន់ គួរឲ្យជាទីស្រឡាញ់ គួរឲ្យរាប់អាន ខ្ញុំព្រះករុណាក៏សង្គ្រោះដោយការបំពេញប្រយោជន៍ គឺធ្វើវត្តុដែលជាប្រយោជន៍ ខ្ញុំព្រះអង្គក៏សង្គ្រោះដោយការបំពេញប្រយោជន៍ គឺធ្វើវត្តុដែលជាប្រយោជន៍ ឲ្យបុគ្គលនេះគួរសង្គ្រោះដោយភាពមានខ្លួនស្មើ ខ្ញុំព្រះករុណា ក៏សង្គ្រោះដោយភាពមានខ្លួនស្មើ បពិត្រព្រះអង្គជ័ចម្រើន ក្នុងត្រកូលរបស់ខ្ញុំព្រះអង្គ មានទ្រព្យសម្រាប់ទុកឲ្យដល់ជន

ទុគិតយ៉ាងណា ជនទាំងឡាយក៏ឃើញថា ពាក្យសម្តីរបស់ខ្ញុំព្រះអង្គ គួរជឿស្តាប់ ដូច្នេះ ព្រះអង្គ ។

ព្រះមានព្រះភាគទើបត្រាស់ថា ល្អហើយ ហត្ថកៈ ឧបាយនេះ របស់អ្នកល្អ អ្នកអាចសង្គ្រោះបរិស័ទក្រុមធំនេះបាន ម្នាលហត្ថកៈ នរណាៗ ក៏ដោយ ដែលសង្គ្រោះបរិស័ទក្រុមធំមកហើយ ក្នុងអតីតកាល ក៏សុទ្ធតែបានសង្គ្រោះដោយសង្គហវត្ថុ ៤ ប្រការនេះហើយ នរណាៗ ក៏ដោយ ដែលនឹងសង្គ្រោះបរិស័ទក្រុមធំក្នុងអនាគតកាល ក៏សុទ្ធតែនឹងសង្គ្រោះដោយសង្គហវត្ថុ ៤ ប្រការនេះ នរណាៗ ក៏ដោយ រមែងសង្គ្រោះបរិស័ទក្រុមធំបច្ចុប្បន្ននេះ សុទ្ធតែសង្គ្រោះដោយសង្គហវត្ថុ ៤ ប្រការនេះឯង ។ ហត្ថកអាឡវកឧបាសក ដែលព្រះសម្មាសម្ពុទ្ធទ្រង់ចង្អុលបង្ហាញឲ្យឃើញច្បាស់ ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ លោកទើបក្រោកឡើងអំពីទីអង្គុយ ក្រាបថ្វាយបង្គំលាព្រះអង្គ ធ្វើប្រទក្សិណ ហើយក៏ត្រឡប់ទៅវិញ ។

កាលហត្ថកអាឡវកឧបាសក ត្រឡប់ទៅហើយមិនយូរប៉ុន្មាន ព្រះមានបុណ្យ ទើបត្រាស់ទឹងកិក្ខុទាំងឡាយថា ម្នាលកិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំហត្ថកអាឡវកឧបាសក ដែលជាអ្នកប្រកបដោយអច្ឆរិយធម៌ គឺធម៌ដែលគួរឲ្យអស្ចារ្យ ៨ ប្រការ ដែលមិនធ្លាប់មានមកហើយ អច្ឆរិយធម៌ គឺធម៌ដែលគួរអស្ចារ្យ ៨ ប្រការនោះ បានដល់អ្វីខ្លះ ? ម្នាលកិក្ខុទាំងឡាយ ហត្ថកអាឡវកឧបាសក **๑. ជាអ្នកមានសទ្ធា ๒. ជាអ្នកមានសីល ๓. ជាអ្នកមានហិរិ ๔. ជាអ្នកមានឱត្តប្បៈ ๕. ជាអ្នកមានការសិក្សារៀនសូត្រច្រើន ๖. ជាអ្នកមានចាគៈ ๗. ជាអ្នកមានបញ្ញា ๘. ជាអ្នកមានសេចក្តីប្រាថ្នាតិច** ។ ម្នាលកិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចាំហត្ថកអាឡវកឧបាសក អ្នកក្រុងអាឡវីថាជាអ្នកប្រកបដោយអច្ឆរិយធម៌ គឺធម៌ដែលគួរឲ្យអស្ចារ្យ ៨ ប្រការ ដែលមិនធ្លាប់មានមកហើយ ។

ក្នុងកាលតមក ហត្ថកអាឡវកឧបាសក បានទទួលការលើក

តម្កើងឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងសង្គ្រោះបរិស័ទ ដោយសង្គហវត្ថុ ៤ ប្រការ ពីព្រះសក្យមុនី ដែលមានសម្ដែងប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ ឯកនិបាត** ដូចមានសេចក្ដីថា ៖

សម័យមួយ ព្រះបរមគ្រូប្រថាប់គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី កាលព្រះអង្គទ្រង់ប្រកាសតែងតាំងទុកក្នុងតំណែងផ្សេងៗ នោះព្រះអង្គក៏ទ្រង់ប្រកាសតែងតាំងហត្ថកអាឡវកឧបាសក ទុកក្នុងតំណែងជាឯតទគ្គៈ គឺឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងសង្គ្រោះបរិស័ទ ដោយសង្គហវត្ថុ ៤ ប្រការ ៕

(ជីវប្រវត្តិរបស់ហត្ថកអាឡវកឧបាសក ចប់)

8888888888888888888888888888888888888888

✍ ជីវប្រវត្តិរបស់ព្រះមហានាមសក្យឧបាសក ✍

“ លោកជាឯតទគ្គៈផ្នែកខាងឱ្យភោជនមានរសដ៏ឧត្តម ”

ព្រះមហានាមសក្យៈ *លោកជាឯតទគ្គៈមួយរូបក្នុងបណ្តាឧបាសកទាំងឡាយ ដែលចូលចិត្តថ្វាយទេយ្យធម៌ដ៏ប្រណីត និងជាឧបាសកដែលមានប្រវត្តិគួរឲ្យជ្រះថ្លា រីឯប្រវត្តិរបស់លោកមានសម្តែងទុកទាំងអតីតជាតិ និងបច្ចុប្បន្នជាតិផងដែរ ។*

ជីវប្រវត្តិរបស់ព្រះមហានាមសក្យឧបាសក ដែលគួរឲ្យជាទីជ្រះថ្លានោះ មានសម្តែងទុកនៅក្នុង ***អដ្ឋកថាមនោរថបូរណី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង* ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** *ថា ៖*

ក្នុងអតីតកាលដែលកន្លងមកហើយ បានប្រមាណមួយសែនកប្បដោយរាប់ថយក្រោយអំពីកន្លះកប្បនេះ ។ ***មហានាមសក្យឧបាសក*** *បានកើតនៅក្នុងត្រកូលមួយ ក្នុងនគរហង្សវតី ត្រូវនឹងពុទ្ធកាលនៃ* ***ព្រះសម្ពុទ្ធបទុមុត្តរៈ*** *តែមិនជ្រាកដឈ្មោះថា មានឈ្មោះអ្វី ។ ថ្ងៃមួយ*

កុលបុត្រនោះ បានទៅស្តាប់ព្រះធម៌ទេសនា របស់ព្រះបទុមុត្តរសម្ពុទ្ធ ហើយបានឃើញព្រះលោកនាយក ទ្រង់ប្រកាសតែងតាំងឧបាសកម្នាក់ទុកក្នុងតំណែង ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងការថ្វាយទានមានរសដ៏ឧត្តម លុះលោកបានឃើញដូច្នោះហើយ ក៏កើតមានការពេញចិត្តក្នុងតំណែងនោះ ទើបបានធ្វើព្យាយាមបំពេញមហាកុសលហើយតាំងចិត្តប្រាថ្នា ឲ្យបានទូវតំណែងនោះ ។ កាលកុលបុត្រនោះអស់ជីវិតទៅហើយ គេក៏បានត្រាច់វង្វាត់ ស្លាប់កើតៗ ស្លាប់ជាមនុស្ស និងទេវតា អស់កាលដ៏ឃ្លាអង្វែង លុះមកដល់ពុទ្ធកាលព្រះសមណ-គោតមបរមគ្រូនៃយើងនេះ គេបានមកកើតនៅក្នុងត្រកូលសក្យរាជ ក្នុង**នគរកបិលពស្តុ** មាននាមថា **មហានាម** ។ កាលព្រះអង្គម្ចាស់មហានាមសក្យៈ ទ្រង់ចម្រើនវ័យធំដឹងក្តីហើយ បានស្តាប់ព្រះធម៌ទេសនា ក៏បានតាំងនៅក្នុង **ព្រះសោតាបត្តិផល** ទ្រង់បានជាព្រះអរិយបុគ្គលថ្នាក់ដំបូង នៅក្នុងព្រះពុទ្ធសាសនានេះ ។

សម័យមួយ ព្រះជិនស្រី ប្រថាប់ចាំវស្សានៅឯ **ស្រុកវេរញ្ជា**

លុះដល់ពេលចេញវស្សាហើយ ព្រះអង្គយាងទៅកាន់នគរកបិលពស្តុ ព្រះអង្គប្រថាប់នៅក្នុងវត្តនិគ្រោធារាម ។ ព្រះអង្គម្ចាស់មហានាមសក្យៈ ទ្រង់បានឮដំណឹងថា ព្រះសាស្តាយាងមកគង់នៅក្នុងវត្តនិគ្រោធារាម ទើបស្តេចយាងចូលទៅគាល់ព្រះមានបុណ្យ ថ្វាយបង្គំហើយ ទ្រង់គង់ក្នុងទីដ៏សមគួរ ហើយទ្រង់ក្រាបទូលឡើងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណា បានឮដំណឹងថា ភិក្ខុសង្ឃទាំងឡាយ លំបាកដោយការគ្រាច់បិណ្ឌបាតឯស្រុកវេរញ្ជា ព្រោះដូច្នោះ សូមព្រះអង្គប្រទានបដិញ្ញា (ការឲ្យពាក្យសន្យា) ដែលនឹងឲ្យខ្ញុំព្រះអង្គបដិបត្តិទំនុកបម្រុងភិក្ខុសង្ឃ អស់កាល ៤ ខែចុះ ព្រះអង្គ ខ្ញុំព្រះករុណានឹងឲ្យភិក្ខុសង្ឃបានធាន់ឱជាគីគ្រឿង ឬវត្ថុទំនុកបម្រុងចិញ្ចឹមជីវិតឲ្យបាន ជាទីសប្បាយដោយអាហារដ៏ប្រណីត ព្រះអង្គ ។

គ្រានោះ ព្រះលោកនាថ ទ្រង់ទទួលការក្រាបទូលនិមន្តរបស់ព្រះអង្គម្ចាស់មហានាមសក្យៈ ដោយតុណ្ហីភាព ។ ព្រះអង្គម្ចាស់មហានាមសក្យៈ ទ្រង់ក៏ជ្រាបអាការទទួលនិមន្តរបស់ព្រះសម្មាសម្ពុទ្ធហើយ

ចាប់តាំងពីព្រលឹមជាដើមនេះទៅ ព្រះអង្គទទួលបដិបត្តិទំនុកបម្រុងភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដោយភត្តាហារមានរសដ៏ឧត្តមនិងមធុរស គឺរសឆ្ងាញ់ ៤ ប្រការ (ទឹកដោះ ស្ករ ទឹកឃ្មុំ ទឹកអំពៅ) ជាដើម កាលទំនុកបម្រុងយ៉ាងនេះគ្រប់កំណត់ ៤ ខែហើយ ព្រះអង្គម្ចាស់មហានាមសក្យៈ ទើបទ្រង់ក្រាបទូលសូមបដិញ្ញា ដើម្បីនឹងទ្រង់សូមបដិបត្តិទំនុកបម្រុងតទៅ ៤ ខែទៀត កាលគ្រប់ ៨ ខែហើយ ក៏ទ្រង់សូមទទួលបដិញ្ញា ៤ ខែតទៅទៀត ការទំនុកបម្រុងចំពោះភិក្ខុសង្ឃទាំង ៣ លើកនេះ ដោយការទូលសូមពីព្រះលោកនាយក សរុបទៅបានមួយឆ្នាំ ។ តពីនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់មិនបានប្រទានឱ្យការទំនុកបម្រុងភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាព្រះប្រធាន បែបនេះដល់ព្រះអង្គម្ចាស់មហានាមសក្យៈតទៅទៀតឡើយ ។ រាប់តាំងអំពីនោះមក ព្រះអង្គម្ចាស់មហានាមសក្យៈ ទ្រង់ក៏បានធ្វើសក្ការៈតាមទំនង ដែលទ្រង់បានធ្វើហើយនោះ ដល់ភិក្ខុសង្ឃ ដែលនិមន្តមកអំពីទិសផ្សេងៗ តទៅទៀតជារឿយៗ ដូច្នេះហើយ ទើបធ្វើឲ្យកិត្តិគុណរបស់ព្រះអង្គ

ម្ចាស់មហានាមសក្យៈ ល្បីទូទៅទាំងជម្ពូទ្វីប ដូចដែលពោលរួចមកហើយខាងដើមនោះឯង ។

ក្នុងកាលជាខាងក្រោយមក ព្រះសម្មាសម្ពុទ្ធគង់ប្រថាប់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ព្រះអង្គក៏បានប្រកាសតែងតាំងព្រះអង្គម្ចាស់មហានាមសក្យៈ ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងឲ្យកោជនមានរសដ៏ឧត្តម ដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ បណីតទាយកានំ យទិទំ មហានាមោ សក្កោ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសកជាអ្នកប្រសើរជាងគេ ផ្នែកខាងអ្នកឲ្យកោជនមានរសដ៏ឧត្តម ស្រេចនឹងមហានាមសក្យៈ ។

ការស្វែងយល់រឿងគុណសម្បត្តិរបស់ឧបាសក ដែលជាព្រះពុទ្ធវចនៈនោះ មានការទាក់ទងនឹងព្រះអង្គម្ចាស់មហានាមសក្យៈ ដែលជាអ្នកក្រាបទូលសួរ ដូចដែលមានរឿងសម្តែងប្រាកដនៅក្នុង **គម្ពីរ**

អង្គុត្តរនិកាយ អដ្ឋកនិបាត នៃ**មហានាមសូត្រ** មានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ សក្យមហានាមចូលទៅគាល់ព្រះមានជោគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមហាមុនី រួចគង់ក្នុងទីដ៏សមគួរ ។ លុះសក្យមហានាម គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះវិជិតមារយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលបានជាឧបាសក តើដោយហេតុដូចម្តេច ? បពិត្រមហានាម បុគ្គលអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ដោយហេតុណា បពិត្រមហានាម បុគ្គលបានជាឧបាសក ដោយហេតុប៉ុណ្ណេះឯង បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកមានសីល តើដោយហេតុដូចម្តេច ? បពិត្រមហានាម ឧបាសកជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ដោយហេតុណា បពិត្រមហានាម ឧបាសកអ្នកមានសីល ដោយហេតុប៉ុណ្ណេះឯង ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ តើដោយហេតុដូចម្តេច ? បពិត្រមហានាម ឧបាសកអ្នកបរិបូណ៌ ដោយសទ្ធា ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបានស្តាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់ធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១ អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយ

ហេតុណា បពិត្រមហានាម ឧបាសកអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង តើដោយហេតុដូចម្តេច ? បពិត្រមហានាម ឧបាសកអ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈ ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបានជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបានស្តាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលបានស្តាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយដែលបានស្តាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យពិចារណា

នូវអត្ថ ១ អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា បពិត្រមហានាម ឧបាសកអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯងផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

ធម៌ដែលជាវិហារធម៌របស់អរិយសាវ័កនោះ គឺអ្វី សក្យមហានាមទ្រង់បានក្រាបទូលសួរដល់ព្រះសម្មាសម្ពុទ្ធ តាមដែលមានរឿងសម្តែងប្រាកដនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត** ក្នុង **មហានាមសូត្រ** ជួចមានសេចក្តីថា ៖

សម័យមួយ ព្រះភគវា ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងសក្កជនបទ ។ គ្រានោះ មហានាមសក្យៈ ចូលទៅគាល់ព្រះសាស្តា លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមហាមុនី ហើយប្រថាប់ក្នុងទីដ៏សមគួរ លុះមហានាមសក្យៈ ប្រថាប់ក្នុងទីសមគួរស៊ប់ហើយ បានក្រាបទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គ

ដ៏ចម្រើន អរិយសាវ័កណា បានសម្រេចអរិយផល ដ៏ឆ្ងាស់នូវសាសនា
គឺសិក្ខាហើយ តើអរិយសាវ័កនោះ ច្រើនតែនៅដោយវិហារធម៌ដូចម្តេច ?
ថ្វាយព្រះពរមហានាម អរិយសាវ័កណា បានសម្រេចអរិយផល ដ៏ឆ្ងាស់
នូវសាសនាហើយ អរិយសាវ័កនោះ ច្រើនតែនៅដោយវិហារធម៌នេះ
បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ រឭកឡើយៗ នូវព្រះ
តថាគតថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកវាគាទិក្កិលេស
ត្រាស់ដឹងនូវញេយ្យធម៌ដោយប្រពៃចំពោះព្រះអង្គឯង ព្រះអង្គបរិបូណ៌
ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់
នូវត្រៃលោក ព្រះអង្គជាបុគ្គលប្រសើរ ដោយសីលាទិគុណ ព្រះអង្គ
ជាអ្នកទូន្មាននូវបុរស ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ
ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់កពដ្ឋីទៀត
ដោយហេតុនេះៗ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវ័ក
រឭកឡើយៗ នូវគុណ នៃតថាគត ក្នុងសម័យនោះ អរិយសាវ័កនោះ
រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈ

រួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ ក៏រមែងជាចិត្តត្រង់បាន ព្រោះប្រារព្ធនូវគុណ នៃតថាគត ។ បពិត្រមហានាម លុះអរិយសាវ័ក មានចិត្តត្រង់ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយ ប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រំងាប់ លុះនាមកាយស្ងប់រំងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ លុះប្រកបដោយសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវ័កនេះ ហៅថា ជាអ្នកដល់នូវការស្ងប់រំងាប់ក្នុងពួកសត្វ ដែលប្រាសចាកការស្ងប់រំងាប់ ជាអ្នកមិនចង្អៀតចង្អល់ក្នុងពួកសត្វ ដែលប្រកបដោយសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោតៈ គឺវិបស្សនា ចម្រើននូវពុទ្ធានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវ័កពិចារណារឿយៗ នូវគុណព្រះធម៌ថា ព្រះបរិយត្តិធម៌ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ព្រះនព្វលោកុត្តរធម៌ ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាធម៌ឲ្យផល

មិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជន គប្បីជីងច្បាស់ចំពោះខ្លួន ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវ័ករឭកវឿយៗ នូវគុណព្រះធម៌ក្នុងសម័យនោះ អរិយសាវ័កនោះ រមែងមិនត្រូវរាគៈរួបរឹត មិនត្រូវទោសៈរួបរឹត មិនត្រូវមោហៈរួបរឹត ក្នុងសម័យនោះចិត្តរបស់អរិយ-សាវ័កនោះ ក៏រមែងជាចិត្តត្រង់បាន ព្រោះប្រារព្ធនូវគុណនៃព្រះធម៌ ។ បពិត្រមហានាម លុះអរិយសាវ័ក មានចិត្តត្រង់ រមែងបាននូវការជីងនូវអត្ថ បាននូវការជីងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រំងាប់ លុះនាមកាយស្ងប់រំងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវ័កនេះ ហៅថា ជាអ្នកដល់នូវការស្ងប់រំងាប់ក្នុងពួកសត្វ ដែលប្រាសចាកការស្ងប់រំងាប់ ជាអ្នកមិនចង្អៀតចង្អល់ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោតៈ-

វិបស្សនា ចម្រើនទូវធម្មានុស្សតិកម្មដ្ឋាន ៗបពិត្រមហានាម មួយទៀត អរិយសាវ័ករឭកវើយៗ នូវគុណនៃព្រះសង្ឃថា ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគប្រតិបត្តិល្អហើយ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិត្រង់ហើយ ព្រះសង្ឃសាវ័កនៃព្រះមានជោគ ប្រតិបត្តិដើម្បីត្រាស់ដឹងព្រះនិព្វាន ព្រះសង្ឃសាវ័កនៃព្រះមានបុណ្យ ប្រតិបត្តិគួរដល់សាមីចិកម្ម បើរាប់ជាគូនៃបុរស បាន ៤ គូ បើរាប់រៀងជាបុរសបុគ្គល បាន ៨ ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះសាស្តា គួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរបស់សត្វលោក ៗបពិត្រមហានាម ក្នុងសម័យណា អរិយសាវ័ករឭកវើយៗ នូវគុណព្រះសង្ឃ ក្នុងសម័យនោះ អរិយសាវ័កនោះ ក៏មិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវគុណព្រះសង្ឃ ៗបពិត្រមហានាម លុះអរិយសាវ័កមានចិត្តត្រង់ហើយ

រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយ ប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រំងាប់ លុះនាមកាយស្ងប់រំងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ បពិត្រមហានាម អរិយសាវ័កនេះ ហៅថាជាអ្នកដល់នូវការស្ងប់រំងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រំងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មស្បែតៈ គឺវិបស្សនា ចម្រើនសង្ឃានុស្សតិកម្មដ្ឋាន ។

បពិត្រមហានាម មួយទៀត អរិយសាវ័ករឭករឿយៗ នូវសីលរបស់ខ្លួន ដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរួចខ្លួន គឺមិនជាខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហា និងទិដ្ឋិប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវ័ករឭករឿយៗ នូវសីលរបស់ខ្លួន ក្នុងសម័យនោះ អរិយសាវ័កនោះ រមែងមិនត្រូវរាគៈរួបរឹត មិនត្រូវទោសៈរួបរឹត មិនត្រូវ

មោហៈរបស់តថាគត ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ ក៏រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវសីល ។ បពិត្រមហានាម លុះអរិយសាវ័កមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើចិត្តមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រំងាប់ លុះនាមកាយស្ងប់រំងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវ័កនេះ ហៅថា ជាអ្នកដល់នូវការស្ងប់រំងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រំងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មស្បាតៈ គឺវិបស្សនា ចម្រើននូវសីលានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយ-សាវ័កត្រេកត្រើយៗ នូវចាគៈរបស់ខ្លួនថា ឱហ្ន៎! អញពេញជាមានលាភហើយ ឱហ្ន៎ ! អត្តភាពជាមនុស្ស អញពេញជាបានល្អហើយ ព្រោះកាលពួកសត្វមានសេចក្តីកំណាញ់ ជាមន្ទិល កំពុងរបរឹត អញមានចិត្ត

ប្រាសចាកសេចក្តីកំណាញ់ ជាមនុស្ស ជាអ្នកមានការលះរួចផុតហើយ មានដៃលាងស្អាតហើយ ត្រេកអរក្នុងការលះបង់ ជាបុគ្គលគួរគេសួរ ត្រេកអរក្នុងការចែកចាយទាន នៅគ្រប់គ្រងផ្ទះ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវ័កវៀកវៀយៗ នូវចាគៈ ក្នុងសម័យនោះ អរិយសាវ័កនោះ រមែងមិនត្រូវរាគៈរួបរឹត មិនត្រូវទោសៈរួបរឹត មិនត្រូវមោហៈរួបរឹតបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ ក៏រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវចាគៈ។ បពិត្រមហានាម លុះអរិយសាវ័កមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រំងាប់ លុះនាមកាយស្ងប់រំងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ កាលបីមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។បពិត្រមហានាម អរិយសាវ័កនេះ ហៅថា ជាអ្នកដល់នូវការស្ងប់រំងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រំងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែល

មានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មស្សោតៈ គឺវិបស្សនា ចម្រើននូវចាគានុស្សតិកម្មដ្ឋាន ។

បពិត្រមហានាម មួយវិញទៀត អរិយសាវ័ក ចម្រើននូវទេវតានុស្សតិថា ទេវតាទាំងឡាយជាន់ចាតុម្មហារាជិកាក៏មាន ទេវតាទាំងឡាយជាន់តាវត្តិង្សក៏មាន ទេវតាជាន់យាមាក៏មាន ទេវតាទាំងឡាយជាន់តុសិតក៏មាន ទេវតាទាំងឡាយជាន់និម្មានរតីក៏មាន ទេវតាទាំងឡាយជាន់បរនិម្មិតវសវត្តីក៏មាន ទេវតាទាំងឡាយជាព្រហ្មកាយិកៈក៏មាន ទេវតាទាំងឡាយខ្ពស់លើសជាងនោះក៏មាន ទេវតាទាំងនោះ ប្រកបដោយសទ្ធាមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សទ្ធារបស់អញដែលមានសភាពនោះក៏មាន ទេវតាទាំងនោះប្រកបដោយសីល មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សីលរបស់អញ ដែលមានសភាពយ៉ាងនេះក៏មាន ពួកទេវតាទាំងនោះ ប្រកបដោយសុតៈ មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សុតៈរបស់អញ ដែលមាន

សភាពយ៉ាងនោះមាន ទេវតាទាំងនោះប្រកបដោយចាគៈ មានសភាព
យ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ ចាគៈរបស់
អញដែលមានសភាពដូច្នោះក៏មាន ទេវតាទាំងនោះប្រកបដោយបញ្ញា
មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ
បញ្ញារបស់អញ ដែលមានសភាពដូច្នោះក៏មាន ។ បពិត្រមហានាម
ក្នុងសម័យណា អរិយសាវ័កឮកឮរឿយៗនូវសទ្ធា សីល សុតៈ ចាគៈ
និងបញ្ញារបស់ខ្លួនផង របស់ទេវតាទាំងនោះផង ក្នុងសម័យនោះ អរិយ-
សាវ័កនោះ រមែងមិនត្រេកអរចាគៈរួបរឹត មិនត្រេកអរទោសៈរួបរឹត មិនត្រេ
កអរមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ រមែង
ជាចិត្តត្រង់ ព្រោះប្រារព្ធនូវពួកទេវតា ។ បពិត្រមហានាម លុះអរិយសាវ័ក
មានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌
បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ
បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយនាមកាយក៏ស្ងប់រំងាប់
លុះនាមកាយស្ងប់រំងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើ

មានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ។បពិត្រមហានាម អរិយ-សាវ័កនេះ ហៅថា ជាអ្នកជល់នូវការស្ងប់រំងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រំងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មស្បែតៈ គឺវិបស្សនា ចម្រើននូវទេវតានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម អរិយសាវ័កណា បានសម្រេចអរិយផល ដ៏ឆ្ងាស់នូវសាសនាហើយ អរិយសាវ័កនោះច្រើនតែនៅដោយវិហារធម៌នេះឯង ។

បុគ្គលណា ដែលមានសីលដ៏ល្អ មានសេចក្តីជ្រះថ្លា ក្នុងព្រះរតនត្រ័យតែគ្រាខ្វះចិត្តក្លេចនឹកជល់ព្រះរតនត្រ័យទៀតខ្លះហើយប្រសិនបើបុគ្គលនោះស្លាប់ទៅក្នុងវាងនោះ គតិ គឺដំណើរបស់គេ ដូចម្តេច សក្យមហានាម ទ្រង់ក៏បានក្រាបទូលសួរសេចក្តីនេះចំពោះព្រះសាស្តា តាមដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ** ក្នុង **មហានាមសូត្រទី ១** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះកគរា ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុង

កបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះឯង ព្រះមហានាមសក្យរាជ ចូលទៅគាល់ព្រះសាស្តា ជានាយក លុះបានចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានបុណ្យ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះមហានាមសក្យរាជគង់ក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះមានជោគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន នគរកបិលពស្តុនេះ ជានគរស្តុកស្តម្ភធំទូលាយ មានមនុស្សច្រើន មានមនុស្សកុះករ មានច្រកចង្អៀតដ៏ច្រើន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះឯង បានចូលមកអង្គុយជិតព្រះសម្ពុទ្ធផង បានចូលមកអង្គុយជិតភិក្ខុទាំងឡាយដែលគួរជាទីចម្រើនចិត្តផង ហើយចូលទៅនគរកបិលពស្តុក្នុងវេលាល្ងាចវិញ តែងទៅដោយជំរើលឿនក៏មាន ទៅដោយសេះលឿនក៏មាន ទៅដោយរថលឿនក៏មាន ទៅដោយរទេះលឿនក៏មាន ទៅដោយបុរសលឿនក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងពេលនោះ សតិរបស់ខ្ញុំព្រះអង្គប្រារព្ធព្រះមានព្រះភាគ ក៏ភ្លេចបាត់ទៅ សតិប្រារព្ធព្រះធម៌ក៏ភ្លេចបាត់ទៅ សតិប្រារព្ធព្រះសង្ឃ ក៏ភ្លេចបាត់ទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះមានសេចក្តី

ត្រិះរិះយ៉ាងនេះថា ប្រសិនបើអញធ្វើមរណកាលក្នុងសម័យនេះ គតិរបស់អញដូចម្តេចទៅ អភិសម្បរាយភពរបស់អញដូចម្តេចទៅ ?

ព្រះមានព្រះភាគត្រាស់ថា បពិត្រព្រះមហានាម ព្រះអង្គកុំខ្វាចឡើយ បពិត្រព្រះមហានាម ព្រះអង្គកុំខ្វាចឡើយ មរណភាពរបស់ព្រះអង្គ មុខជាមិនថយថោកទេ កាលកិរិយារបស់ព្រះអង្គ មុខជាមិនថយថោកទេ ។ បពិត្រព្រះមហានាម ចិត្តដែលបុគ្គលណា អប់រំហើយដោយសទ្ធា ចិត្តដែលបុគ្គលណា អប់រំហើយដោយសីល ចិត្តដែលបុគ្គលណា អប់រំហើយដោយសុតៈ ចិត្តដែលបុគ្គលណា អប់រំហើយដោយចាគៈ ចិត្តដែលបុគ្គលណា អប់រំហើយដោយបញ្ញា អស់កាលជ័យូរ ។ ក៏កាយឯណារបស់បុគ្គលនោះ មានរូប ជាទីប្រជុំនៃមហាភូតទាំង ៤ កើតមកអំពីមាតា និងបិតា ចម្រើនឡើងដោយបាយ និងនំកុម្មាស មានការមិនទៀង ការជ្រុសលាង ការគក់ច្រចាច់ ការបែកធ្លាយ និងការរាត់រាយទៅជាធម្មតា ក្អែកទាំងឡាយតែងចឹកស៊ីខ្លះ ត្មាតទាំងឡាយតែងចឹកស៊ីខ្លះ ត្រដក់ទាំងឡាយតែងចឹកស៊ីខ្លះ សុនខទាំងឡាយតែង

ទំពាស៊ីខ្លះ ចចកទាំងឡាយតែងទំពាស៊ីខ្លះ បាណកជាតទាំងឡាយផ្សេងៗ (សត្វតូចៗ មានរុយជាដើម) តែងចោមរោម ជញ្ជក់ស៊ីខ្លះ នូវកាយនោះឯង ។ ចំណែកចិត្តណា ដែលបុគ្គលនោះ អប់រំដោយសទ្ធា សីល សុតៈ ចាគៈ បញ្ញា អស់កាលដ៏យូរ ចិត្តនោះ តែងអណ្តែតខ្ពស់ឡើង ដល់នូវភាពជាចិត្តវិសេស ។

បពិត្រព្រះមហានាម ដូចបុរសចុះទៅកាន់អន្ទង់ទឹកដ៏ជ្រៅហើយ វាយបំបែកនូវឆ្នាំងសប្បិ ឬឆ្នាំងប្រេង គ្រួស ឬអំបែងឯណាដែលមានក្នុងឆ្នាំងនោះ គ្រួស ឬអំបែងនោះ តែងលិចចុះក្រោម ចំណែកសប្បិ ឬប្រេងឯណាដែលមានក្នុងឆ្នាំងនោះ សប្បិ ឬប្រេងនោះ តែងអណ្តែតឡើងលើ ដល់នូវភាពជាវត្ថុវិសេសដូចម្តេចមិញ ។ បពិត្រព្រះមហានាម ចិត្តដែលបុគ្គលណា បានអប់រំហើយដោយសទ្ធា ចិត្តដែលបុគ្គលណា អប់រំហើយដោយសទ្ធា សីល សុតៈ ចាគៈ បញ្ញា អស់កាលដ៏យូរ ចំណែកកាយឯណារបស់បុគ្គលនោះ មានរូបជាទីប្រជុំនៃមហាភូតទាំង ៤ កើតមកអំពីមាតា និងបិតា ចម្រើនឡើងដោយបាយ និងនំកុម្មាស

មានការមិនទៀង ការជុសលាង ការគក់ច្របាច់ ការបែកធ្លាយ និង
ការរាត់រាយទៅជាធម្មតា ក្អែកទាំងឡាយតែងចឹកស៊ីខ្លះ ត្មាតទាំងឡាយ
តែងចឹកស៊ីខ្លះ ត្រដក់ទាំងឡាយតែងចឹកស៊ីខ្លះ សុនខទាំងឡាយតែង
ទំពាស៊ីខ្លះ ចចកទាំងឡាយតែងទំពាស៊ីខ្លះ ជាណាកជាតទាំងឡាយផ្សេងៗ
(សត្វតូចៗ មានរុយជាដើម) តែងចោមរោមជញ្ជក់ស៊ីខ្លះ នូវកាយ
នោះឯង ចំណែកចិត្តណា ដែលបុគ្គលនោះអប់រំហើយ ដោយសទ្ធា
អប់រំហើយ ដោយសីល សុតៈ ចាគៈ បញ្ញា អស់កាលជ័យូរ ចិត្តនោះ
តែងអណ្តែតខ្ពស់ឡើង ដល់នូវភាពជាចិត្តវិសេស មានឧបមេយ្យដូច្នោះ ។
បពិត្រព្រះមហានាម ចិត្តដែលព្រះអង្គបានអប់រំហើយដោយសទ្ធា អប់រំ
ហើយដោយសីល សុតៈ ចាគៈ បញ្ញា អស់កាលជ័យូរ ។ បពិត្រ
ព្រះមហានាម ព្រះអង្គកុំខ្វាចឡើយ បពិត្រព្រះមហានាម ព្រះអង្គកុំខ្វាច
ឡើយ មរណភាពរបស់ព្រះអង្គ មុខជាមិនថយថោកឡើយ កាលកិរិយា
របស់ព្រះអង្គ មុខជាមិនថយថោកឡើយ ។

មានរឿងដែលព្រះមហានាម ទ្រង់ក្រាបទូលសួរចំពោះព្រះអង្គ

អំពីរឿងគតិ តាមដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ** ក្នុង **មហានាមសូត្រទី ២** ដូចមានសេចក្តីថា ៖-

ចំពោះសូត្រទី ២ នេះ មានសេចក្តីខាងដើម ដូចនឹងមហានាមសូត្រទី ១ នោះដែរ ដោយព្រះមហានាមសក្យរាជ យាងចូលទៅគាល់ព្រះមានជោគ ដើម្បីក្រាបទូលសួរដល់ចិត្ត ដែលខ្វះសតិ ភ្លេចព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើអញធ្វើមរណកាល ក្នុងសម័យនេះ គតិរបស់អញ ដូចម្តេចទៅ អភិសម្បរាយភពរបស់អញ ដូចម្តេចទៅ ។ បពិត្រព្រះមហានាម ព្រះអង្គកុំខ្វាចឡើយ បពិត្រព្រះមហានាម ព្រះអង្គកុំខ្វាចឡើយ មរណភាពរបស់ព្រះអង្គ មុខជាមិនថយថោកទេ កាលកិរិយារបស់ព្រះអង្គ មុខជាមិនថយថោកទេ ។ បពិត្រព្រះមហានាម អរិយ-សាវក ប្រកបដោយធម៌ ៤ យ៉ាង តែងបង្អោនទៅរកព្រះនិព្វាន ជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ។ ធម៌ ៤ យ៉ាងគឺអ្វីខ្លះ ? បពិត្រព្រះមហានាម អរិយសាវកក្នុងធម្មវិន័យនេះ ប្រកបដោយសេចក្តីជ្រះថ្លា

មិនញាប់ញ័រក្នុងព្រះពុទ្ធថា ព្រះមហាវីរៈអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់កពថ្មីទៀត ។ (អរិយសាវ័កប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនជាច់ ។បេ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។

បពិត្រព្រះមហានាម ដូចដើមឈើ តែងទេរទៅកាន់ទិសខាងកើត ទោរទៅកាន់ទិសខាងកើត ទ្រេតទៅកាន់ទិសខាងកើត ឈើនោះ កាលបើឫសជាច់ហើយ តើគប្បីដួលទៅទិសខាងណា ។ព្រះមហានាមសក្យរាជក្រាបទូលថា បពិត្រព្រះអង្គ ឈើនោះទេរទៅខាងណា ទោរទៅខាងណា ទ្រេតទៅខាងណា (គប្បីដួលទៅខាងនោះ) ។ ព្រះជិនស្រីត្រាស់ថា បពិត្រព្រះមហានាម អរិយសាវ័ក ប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ រមែងបង្អោនទៅរកព្រះនិព្វាន ជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វានក៏ដូច្នោះឯង ។

បុគ្គលដែលមិនត្រូវទៅកើតក្នុងអបាយភូមិ គឺជាទីកន្លែងដែលមិនមានសេចក្តីចម្រើន បានដល់ នរក ប្រេត អសុរកាយ និងកំណើតសត្វតិរច្ឆាន ព្រះសក្យមហានាមចង់ដឹងក្នុងដំណើរនេះ ទើបក្រាបទូលសួរចំពោះព្រះសយម្ភូ ដូចដែលមានរឿងសម្តែងប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ** ក្នុង **សរកានិសូត្រទី ២** ថា ៖

សម័យនោះឯង ព្រះសរកានិសក្យរាជទ្រង់ទិវង្គតទៅ ព្រះអង្គជាអ្នកដែលព្រះមានព្រះភាគទ្រង់ព្យាករហើយថា ជាសោតាបន្នបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ បានឮថា ពួកសក្យរាជជាច្រើនអង្គ មកប្រជុំគ្នាក្នុងទីនោះហើយ ពោលទោសតិះដៀលបន្ទុះបង្អាប់ថា អើហ្ន៎ អស្ចារ្យណាស់តើ អើហ្ន៎ មិនដែលកើតមានទេតើ បើយ៉ាងហ្នឹង នរណានឹងមិនបានជាសោតាបន្នបុគ្គល ក្នុងសាសនានេះ ព្រះសរកានិសក្យរាជដែលទ្រង់ទិវង្គតទៅហើយនោះ មិនសមបើព្រះសាស្តា ទ្រង់ព្យាករថាជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង

មានការគ្រាស់ជជីងប្រព្រឹត្តទៅក្នុងខាងមុខសោះៗដ្បិតព្រះសរកោនិសក្យរាជ ដល់នូវភាពនៃខ្លួនជាអ្នកមានកម្លាំងខ្សោយដោយសិក្ខា ជាអ្នកក្រេបផឹកនូវទឹកស្រវឹង ។

គ្រានោះឯង ព្រះមហានាមសក្យរាជ ចូលទៅគាល់ព្រះសាស្តា លុះចូលទៅដល់ ថ្វាយបង្គំព្រះសក្យមុនីហើយ គង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះមហានាមសក្យរាជ គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះលោកនាយកដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ ព្រះសរកោនិសក្យរាជ ទ្រង់ទិវង្គតហើយ ព្រះអង្គជាអ្នកដែលព្រះកគវាទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការគ្រាស់ជជីង ប្រព្រឹត្តទៅក្នុងខាងមុខ ។ បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ពួកសក្យរាជជាច្រើនអង្គ បានមកប្រជុំគ្នាក្នុងទីនោះ ពោលទោសតិះដៀលបន្ទុះបន្ទាប់ថា អើហ្ន៎ អស្ចារ្យណាស់តើ អើហ្ន៎ មិនដែលកើតមានទេតើ បើយ៉ាងហ្នឹង នរណានឹងមិនជាសោតាបន្នបុគ្គល ក្នុងព្រះសាសនានេះ ព្រះសរកោនិសក្យរាជ ដែលទ្រង់ទិវង្គត

ទៅហើយនោះ មិនសមបើព្រះមុនី ទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខសោះ ។ ដ្បិតព្រះសរភង្គាធិសក្យរាជ បានដល់នូវភាពនៃខ្លួន ជាអ្នកមានកម្លាំងខ្សោយដោយសិក្ខា ជាអ្នកក្រេបផឹកនូវទឹកស្រវឹង ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា បពិត្រមហានាម បុគ្គលណា ជាឧបាសក ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង អស់រាត្រីវែង បុគ្គលនោះ គប្បីទៅកាន់អបាយដូចម្តេចបាន ។ បពិត្រព្រះមហានាម បុគ្គលកាលពោលចំពោះបុគ្គលដែលជាឧបាសកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង អស់រាត្រីវែង គប្បីពោលដោយប្រពៃ ។ បពិត្រមហានាម បុគ្គលកាលពោលអំពីព្រះសរភង្គាធិសក្យរាជ គប្បីពោលដោយប្រពៃថា ព្រះសរភង្គាធិសក្យរាជ ជាឧបាសក ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង អស់រាត្រីវែង

គប្បីទៅកាន់អបាយដូចម្តេចបាន ។

បពិត្រព្រះមហានាម បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះទសពលអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកមានបញ្ញាជាគ្រឿងរែកយក មានបញ្ញាវាងវៃប្រកបដោយវិមុត្តិ ។ បុគ្គលនោះធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែង ដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ បពិត្រព្រះមហានាម បុគ្គលនេះឯងឈ្មោះថា រួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកកំណើតប្រេត-វិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។ បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះសាស្តាអង្គនោះ ។ល។ ព្រះអង្គជាគ្រូ

នៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកមានបញ្ញាជាគ្រឿងរីករាយ មានបញ្ញាវាងវៃ ប៉ុន្តែមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះ មានសភាពជាឱបបាតិកសត្វ ហើយបរិនិព្វានក្នុងលោកនេះ មានសភាពមិនត្រឡប់ចាកលោកនោះ ព្រោះអស់សំយោជន: ៥ ជាចំណែកខាងដើម ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ឈ្មោះថា រួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកកំណើតប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះមុនីអង្គនោះ ។ល។ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុង

ព្រះសង្ឃ ។ ប៉ុន្តែមិនមានបញ្ញាជាគ្រឿងរីករាយ មិនមានបញ្ញាវាងវៃ និងមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះ ជាសកទាគាមី នឹងមកកាន់លោកនេះម្តងទៀត ធ្វើហើយនូវទីបំផុតទុក្ខ ព្រោះអស់សំយោជន: ๓ ប្រការ ព្រោះធ្វើរាគ: ទោស: មោហ: ឲ្យស្រាលស្តើង ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ឈ្មោះថា រួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកកំណើតប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។ បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះទសពលអង្គនោះ ។ល។ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់កំពង្វាយទៀត ។ (ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប៉ុន្តែមិនមានបញ្ញាជាគ្រឿងរីករាយ មិនមានបញ្ញាវាងវៃ និងមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅ

ក្នុងខាងមុខ ព្រោះអស់សំយោជន: ៣ ប្រការ ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ឈ្មោះថា រួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកកំណើតប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធទេ ។ ក្នុងព្រះធម៌ទេ ។ ព្រះសង្ឃទេ ។ មិនមានបញ្ញាជាគ្រឿងរីករាយទេ មិនមានបញ្ញាវាងវៃទេ មិនប្រកបដោយវិមុត្តិទេ ។ តែថា ធម៌អម្បាលនេះ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ តែងមានដល់បុគ្គលនោះ ។ មួយទៀត ធម៌ទាំងឡាយ ដែលព្រះតថាគតទ្រង់ប្រកាសហើយ តែងសមគួរដល់ការពិចារណា ដោយបញ្ញារបស់បុគ្គលនោះ ដោយក្រៃពេក ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ឈ្មោះថា រួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកកំណើតប្រេត-វិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានប្រកបដោយសេចក្តីជ្រះថ្លា មិន

ញាប់ញ័រ ក្នុងព្រះពុទ្ធទេ ព្រះធម៌ទេ ព្រះសង្ឃទេ ។ មិនមានបញ្ញា ជាគ្រឿងរីករាយទេ មិនមានបញ្ញាវាងវៃទេ មិនប្រកបដោយវិមុត្តិទេ ។ តែថា ធម៌អម្បាលនេះ គឺសទ្ធិន្ទ្រិយ ។ល។ បញ្ញិន្ទ្រិយ តែងមានដល់បុគ្គលនោះ ។ មួយទៀត បុគ្គលនោះ គ្រាន់តែមានសទ្ធា និងសេចក្តីស្រឡាញ់ ក្នុងព្រះតថាគត ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ឈ្មោះថា រួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកកំណើតប្រេត-វិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

បពិត្រមហានាម ដូចពូជទាំងឡាយ ដែលចាក់ខ្ចេច ដែលស្អុយ ដែលក្រៀមក្រោះ ដោយខ្យល់ និងកម្តៅថ្ងៃ ដែលឥតមានពន្លក ដែលគេទុកដាក់ក្នុងទីមិនស្អាត ភ្លៀងក៏បង្អុរនូវទឹកភ្លៀង ដោយស្រួលចុះកាន់ស្រែ ដែលក្រហោងក្រហូង មានផែនដីអាក្រក់ ដែលគេមិនទាន់បានគាស់រានយកដង្កូតឈើចេញនៅឡើយ ពូជទាំងអម្បាលនោះ នឹងដល់នូវសេចក្តីចម្រើន ជុះជាល លូតលាស់បានដែរឬទេ ? មិនបានទេ ព្រះអង្គ ។ បពិត្រមហានាម សេចក្តីឧបមេយ្យក៏ដូច្នោះដែរ ធម៌ក្នុង

លោកនេះ ជាធម៌ដែលបុគ្គលពោលមិនល្អ ជាធម៌ដែលបុគ្គលប្រកាសមិនល្អ ជាធម៌មិននាំសត្វចេញចាកទុក្ខបាន មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ស្ងាត់ ជាធម៌ដែលបុគ្គលមិនមែនព្រះសម្មាសម្ពុទ្ធប្រកាស ហើយតថាគតពោលថា ធម៌នេះ ដូចស្រែដែលក្រហោងក្រហូង ។មួយវិញទៀត សាវ័កដែលប្រតិបត្តិនូវធម៌តាមធម៌ ប្រតិបត្តិសមគួរ ប្រព្រឹត្តនូវធម៌ដ៏សមគួរ នៅគ្រប់ឥរិយាបថក្នុងធម៌នោះ តថាគតពោលថា សាវ័កអ្នកប្រតិបត្តិធម៌តាមធម៌ នៅគ្រប់ឥរិយាបថនេះ ដូចជាពូជអាក្រក់ ។បពិត្រមហានាម ដូចពូជទាំងឡាយ ដែលមិនជាក់ខ្ទេច ដែលមិនស្អុយ ដែលមិនក្រៀមក្រោះ ដោយខ្យល់ និងកម្តៅថ្ងៃ មានពន្លក ដែលគេទុកជាក់ក្នុងទីដ៏ស្អាត ទាំងភ្លៀងក៏បង្អុរនូវទឹកភ្លៀងដោយស្រួល ចុះកាន់ស្រែដែលល្អ មានផែនដីរាបស្មើ ដែលគេបានគាស់រានយកដង្កត់ឈើចេញហើយ ពូជទាំងអម្បាលនោះ នឹងដល់នូវសេចក្តីចម្រើន ដុះដាលលូតលាស់ឡើងបានដែរឬទេ ? យ៉ាងហ្នឹងហើយ ព្រះអង្គ ។បពិត្រមហានាម សេចក្តីឧបមេយ្យក៏ដូច្នោះដែរ ធម៌ក្នុងលោកនេះ ជាធម៌

ដែលបុគ្គលពោលទុកល្អហើយ ធម៌ដែលបុគ្គលប្រកាសទុកល្អហើយ ជាធម៌នាំសត្វចេញចាកទុក្ខបាន ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់ស្ងាត់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធប្រកាសហើយ តថាគតពោលថា ធម៌នេះ ដូចស្រែដ៏ល្អ ។ មួយវិញទៀត សាវ័កដែលប្រតិបត្តិនូវធម៌តាមធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តនូវធម៌ដ៏សមគួរ នៅគ្រប់ឥរិយាបថក្នុងធម៌នោះ តថាគតពោលថា សាវ័កអ្នកប្រតិបត្តិធម៌តាមធម៌ នៅគ្រប់ឥរិយាបថនេះ ដូចជាពូជដ៏ល្អ ។នឹងបាច់ពោលទៅថ្វី ដល់ព្រះសរកានិសក្យរាជ បពិត្រ ព្រះមហានាម ព្រះសរកានិសក្យរាជ ជាអ្នកបានធ្វើឲ្យពេញបរិបូណ៌ ក្នុងសិក្ខា ក្នុងកាលជិតមរណៈ ។

(នេះជាផលល្អ ដែលធ្វើបានទទួលចំណេះដឹង ទាក់ទងនឹងការធ្វើល្អ ឲ្យបុគ្គលចេះបែងចែក និងចេះជ្រើសរើសការធ្វើ ទើបបានផលគាប់ចិត្ត សមនឹងការដាក់កម្លាំងកាយចិត្តចុះទៅ និងធ្វើឲ្យបានជ្រាបដល់ព្រះពុទ្ធតម្រាស់ ដែលជា១.ឧបមេយ្យ ដែលឲ្យចេះជ្រើសរើសពូជ និងស្រែដែលល្អ និងធម៌ដែលល្អ) ។

ព្រះមហានាមសក្យរាជ ទ្រង់បានក្រាបទូលសួរព្រះធម៌ចំពោះព្រះសាស្តាជល់ធម៌ ដែលជាគ្រឿងនៅជាប្រចាំរបស់គ្រហស្ថ សេចក្តីពិតគ្រហស្ថ មិនមានធម៌ជាគ្រឿងនៅជាប្រចាំត្រឹមតែម្យ៉ាងប៉ុណ្ណោះទេ ទើបទ្រង់ក្រាបទូលសួរថា គ្រហស្ថ ដែលមានធម៌ជាគ្រឿងនៅជាប្រចាំដូចម្តេច ទាំងនេះ តាមដែលមានរឿងសម្តែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកាទសកនិបាត** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ។ សម័យនោះឯង ពួកភិក្ខុច្រើនរូបនាំគ្នាដេរចីវរថ្វាយជល់ព្រះមានបុណ្យដោយគិតថា ព្រះមានព្រះភាគមានចីវរសម្រេចហើយ ព្រះអង្គស្តេចនឹងទៅកាន់ចារិក ដោយកាលប្រព្រឹត្តកន្លងទៅនៃខែ ៣ ។ មហានាមសក្យៈ បានឮដំណឹងថា ឮថាពួកភិក្ខុច្រើនរូបដេរចីវរថ្វាយព្រះមានជោគ ដោយគិតថា ព្រះសាស្តាមានចីវរសម្រេចហើយ ព្រះអង្គស្តេចនឹងទៅកាន់ចារិក ដោយកាលប្រព្រឹត្តកន្លងទៅនៃខែ ៣ ។ លំដាប់នោះ មហានាមសក្យៈ ក៏ចូលទៅ

គាល់ព្រះវិជិតមារ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះលោកនាយក រួចគង់ក្នុងទីសមគួរ ។ លុះមហានាមសក្យៈ គង់ក្នុងទីសមគួរហើយ ក្រាបទូលព្រះសាស្តាយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ឮដំណឹងនេះថា ឮថា ពួកភិក្ខុច្រើនរូបដេរចីវរថ្វាយព្រះសុគត ដោយគិតថា ព្រះពុទ្ធអង្គមានចីវរសម្រេចហើយ ព្រះអង្គស្តេចនិងទៅកាន់ចារិក ដោយកាលប្រព្រឹត្តកន្លងទៅនៃខែ ៣ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មិនទាន់បានស្តាប់ធម៌ ចំពោះព្រះភក្ត្រព្រះទសពល មិនទាន់បានទទួល ចំពោះព្រះភក្ត្រ យ៉ាងនេះថា ឧបាសកប្រកបដោយប្រាជ្ញា (សម្រេចសោតៈ) ដែលមានអាពាធ ដល់នូវទុក្ខវេទនា ឈឺធ្ងន់ ត្រូវតែឧបាសក ដែលប្រកបដោយប្រាជ្ញាទូន្មានគ្នា ។

ម្នាលមហានាម ឧបាសក ដែលប្រកបដោយប្រាជ្ញា មានអាពាធ ដល់នូវទុក្ខវេទនា ឈឺធ្ងន់ ត្រូវតែឧបាសកប្រកបដោយប្រាជ្ញា លួងលោម ដោយធម៌ដែលគួរលួងលោម៤ យ៉ាងថា អ្នកដ៏មានអាយុ ចូរដកដង្ហើម ឲ្យស្រួលចុះ ព្រោះអ្នកដ៏មានអាយុ មានសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុង

ព្រះពុទ្ធថា ព្រះមានព្រះភាគនោះ ។ល។ ជាសាស្តានៃទេវតា និងមនុស្ស ទាំងឡាយ ជាព្រះពុទ្ធមានជោគ ដោយហេតុដូច្នេះឯង ។អ្នកដ៏មានអាយុ ចូរដកដង្ហើមឲ្យស្រួលចុះ ព្រោះអ្នកដ៏មានអាយុ (មានសេចក្តីជ្រះថ្លា មិនញាប់ញ័រ) ក្នុងធម៌ ។ ក្នុងព្រះសង្ឃ ។ **អរិយកន្តសីល** ជាសីលមិនជាប់ ប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលមហានាម ឧបាសក ប្រកបដោយប្រាជ្ញា មានអាពាធដល់នូវទុក្ខវេទនា ឈឺធ្ងន់ ដែលឧបាសក ប្រកបដោយប្រាជ្ញាទូន្មាន ដោយធម៌ ដែលគួរលួងលោមទាំង ៤ នេះ ហើយ ត្រូវនិយាយយ៉ាងនេះថា អ្នកដ៏មានអាយុ មានសេចក្តីអាឡោះអាល័យមាតាបិតាឬ ។ បើឧបាសកនោះ និយាយយ៉ាងនេះថា ខ្ញុំនៅមានសេចក្តីអាឡោះអាល័យមាតាបិតាដែរ ។ ត្រូវនិយាយនឹងឧបាសកនោះ យ៉ាងនេះថា អ្នកដ៏មានអាយុ ជាប់ជំពាក់ដោយសេចក្តីស្ងាប់ ទៀងតែនឹងស្ងាប់ ប្រសិនបើអ្នកដ៏មានអាយុនៅជាប់អាឡោះអាល័យនឹងមាតាបិតា អ្នកដ៏មានអាយុគង់តែនឹងស្ងាប់ បើទុកជាអ្នកដ៏មានអាយុ មិនអាឡោះអាល័យនឹងមាតាបិតា អ្នកដ៏មានអាយុ គង់តែនឹងស្ងាប់ដែរ សូមឲ្យអ្នក

ជ័មានអាយុ លះបង់សេចក្តីអាឡោះអាល័យ របស់អ្នកក្នុងមាតាបិតា នោះចេញ ។ បើឧបាសកនោះ និយាយយ៉ាងនេះថា ខ្ញុំលះបង់សេចក្តី អាឡោះអាល័យក្នុងមាតាបិតានោះរួចហើយ ។

ត្រូវនិយាយនឹងឧបាសកនោះ យ៉ាងនេះថា អ្នកជ័មានអាយុ មានសេចក្តីអាឡោះអាល័យ ក្នុងបុត្រ និងភរិយាដែរឬ ។បើឧបាសកនោះ និយាយយ៉ាងនេះថា ខ្ញុំនៅមានសេចក្តីអាឡោះអាល័យ ក្នុងបុត្រ និង ភរិយាដែរ ។ត្រូវនិយាយនឹងឧបាសកនោះយ៉ាងនេះថា អ្នកជ័មានអាយុ ជាប់ជំពាក់នឹងសេចក្តីស្លាប់ ហើយទៀងតែនឹងស្លាប់ បើទុកជាអ្នក ជ័មានអាយុ នៅមានសេចក្តីអាឡោះអាល័យ ក្នុងបុត្រ និងភរិយា អ្នកជ័មានអាយុ គង់តែនឹងស្លាប់ បើអ្នកជ័មានអាយុ មិនមានសេចក្តី អាឡោះអាល័យ ក្នុងបុត្រ និងភរិយា អ្នកជ័មានអាយុ គង់តែនឹងស្លាប់ សូមអ្នកជ័មានអាយុ លះសេចក្តីអាឡោះអាល័យ ក្នុងបុត្រ និងភរិយា របស់អ្នកនោះចេញ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ខ្ញុំបាន

លះសេចក្តីអាឡោះអាល័យ ក្នុងបុត្រ និងភរិយានោះចេញហើយ ។ ត្រូវនិយាយនឹងឧបាសកនោះ យ៉ាងនេះថា អ្នកដ៏មានអាយុ មានសេចក្តីអាឡោះអាល័យ ក្នុងកាមគុណទាំង ៥ ជារបស់មនុស្សដែរឬ ។ បើឧបាសកនោះ និយាយយ៉ាងនេះថា ខ្ញុំមានសេចក្តីអាឡោះអាល័យក្នុងកាមគុណទាំង ៥ ជារបស់មនុស្សដែរ ។ ត្រូវនិយាយនឹងឧបាសកនោះ យ៉ាងនេះថា ម្នាលអាវុសោ កាមជាទិព្វជារបស់រុងរឿងផង ឧត្តមផងជាងកាមទាំងឡាយ ជារបស់មនុស្ស សូមអ្នកដ៏មានអាយុ ធ្វើចិត្តឲ្យផុតចាកកាម ជារបស់មនុស្សចេញហើយ ចូរតម្កល់ចិត្តក្នុងពួកទេវតាស្ថានចាតុម្មហារាជិកាចុះ ។ បើឧបាសកនោះ និយាយយ៉ាងនេះថា ចិត្តរបស់ខ្ញុំផុតស្រឡះចាកកាម ជារបស់មនុស្សហើយ ខ្ញុំបានតម្កល់ចិត្តទុកក្នុងពួកទេវតាជាន់ចាតុម្មហារាជិកាហើយ ។ ត្រូវនិយាយនឹងឧបាសកនោះ យ៉ាងនេះថា ម្នាលអាវុសោ ពួកតាវត្តិង្សទេវតា រុងរឿងជាង ឧត្តមជាងពួកចាតុម្មហារាជិកាទេវតា សូមអ្នកមានអាយុដកចិត្ត អំពីពួក

ចាតុម្មហារាជិកាទេវតា ចេញហើយ តម្កល់ចិត្តក្នុងតាវត្តិង្សទេវតាចុះ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ចិត្តខ្ញុំបានដកផុតអំពីពួក ចាតុម្ម-ហារាជិកាហើយ ខ្ញុំបានតម្កល់ចិត្តទុក ក្នុងពួកតាវត្តិង្សទេវតាហើយ ។ ត្រូវនិយាយនឹងឧបាសកនោះ យ៉ាងនេះថា ម្នាលអាវុសោ ពួកយាមា ទេវតារុងរឿងជាងពួកតាវត្តិង្សទេវតា, ពួកតុសិតទេវតា, ពួកនិម្មានរតី ទេវតា, ពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលអាវុសោ ព្រហ្មលោក រុងរឿងជាង ខ្ពង់ជាងពួកបរនិម្មិតវសវត្តីទេវតា សូមអ្នកដ៏មានអាយុ ដកចិត្តអំពីពួកបរនិម្មិតវសវត្តីទេវតាចេញ ហើយតម្កល់ចិត្តក្នុងព្រហ្ម-លោកវិញ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ចិត្តខ្ញុំបានដកចេញ អំពីពួកបរនិម្មិតវសវត្តីទេវតាហើយ បានតម្កល់ចិត្តក្នុងព្រហ្មលោកហើយ ។

ត្រូវនិយាយនឹងឧបាសកនោះយ៉ាងនេះថា ម្នាលអាវុសោ ទោះជា ព្រហ្មលោកក៏នៅតែមិនទៀង មិនខ្ជាប់ខ្ជួន រាប់បញ្ចូលជាសក្កាយ សូម អ្នកដ៏មានអាយុ ដកចិត្តអំពីព្រហ្មលោកចេញ ហើយប្រមូលចិត្តទៅ

ក្នុងព្រះនិព្វាន ជាទីរំលត់នូវសក្កាយវិញ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ចិត្តខ្ញុំដកផុតអំពីព្រហ្មលោកហើយ ចិត្តក៏បានប្រមូលទៅក្នុងព្រះនិព្វានជាទីរំលត់សក្កាយហើយ ។ ម្នាលមហានាម ចិត្តដែលរួចស្រឡះដោយអរហត្តផលវិមុត្តិ របស់ឧបាសកដែលមានចិត្តរួចស្រឡះហើយយ៉ាងនេះ តថាគតមិនពោលថា មានការធ្វើផ្សេងគ្នា អំពីភិក្ខុដែលមានចិត្តរួចស្រឡះហើយ អស់ ១០០ ឆ្នាំ នោះតែបន្តិចសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះ ដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ ធម៌ ៤ តើដូចម្តេចខ្លះ ? គឺការសេពគប់សប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ ការធ្វើទុកក្នុងចិត្តដោយឧបាយ ១ សេចក្តីប្រតិបត្តិនូវធម៌សមគួរតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះឯងដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យច្បាស់នូវសោតាបត្តិផល ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះ

ដែលបុគ្គលបានចម្រើនហើយធ្វើឲ្យច្រើនហើយតែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យច្បាស់នូវសកទាគាមិផល ។ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យច្បាស់នូវអនាគាមិផល ។តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យច្បាស់នូវអរហត្តផល ។ តែងប្រព្រឹត្តទៅ ដើម្បីបាននូវប្រាជ្ញា ។ តែងប្រព្រឹត្តទៅ ដើម្បីចម្រើនប្រាជ្ញា ។ តែងប្រព្រឹត្តទៅ ដើម្បីធ្វើប្រាជ្ញាឲ្យធំទូលាយ ។ (បុគ្គលបានសម្រេចធម៌ហើយ រមែងមិនមានសេចក្តីត្រូវការនឹងរកធម៌ទុកសម្រាប់ឲ្យចិត្តជាប់នៅនឹងធម៌នោះ ដោយសង្ឃឹមនឹងបានទទួលសេចក្តីសុខអំពីធម៌នោះឡើយ) ฯ

(ជីវប្រវត្តិរបស់ព្រះសក្យមហានាមឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ឧគ្គគហបតី អ្នកនៅក្នុងក្រុងវេសាលី ✍

“ លោកជាឯតទគ្គៈផ្នែកខាងឱ្យភោជនជាទីគាប់ចិត្ត ”

(អ្នកនៅក្នុងក្រុងវេសាលី)

ឧគ្គគហបតី រាប់ថាជាឧបាសកម្នាក់ ជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងឲ្យភោជនជាទីគាប់ចិត្ត នៅក្នុងព្រះពុទ្ធសាសនានេះ ចំណែកជីវប្រវត្តិរបស់ឧគ្គគហបតីវិញ មានសម្តែងទាំងអតីតជាតិ និងបច្ចុប្បន្នជាតិផងដែរ ។

ជីវប្រវត្តិរបស់ឧគ្គគហបតីឧបាសក មានសម្តែងប្រាកដនៅក្នុង ***អដ្ឋកថាមនោរថបូរណី*** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីក្នុង ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** ដូចមានសេចក្តីថា ៖

ឧគ្គគហបតី បានកើតនៅក្នុងត្រកូលជាសេដ្ឋី ក្នុងក្រុងវេសាលី ក្នុងពុទ្ធកាលនៃព្រះសាស្តាចារមគ្រូនៃយើងនេះ ។ ដែលមានឈ្មោះថា ឧគ្គគហបតីនោះ មានហេតុដូច្នេះថា ក្នុងពេលដែលលោកកើតមកហើយ

មិនមានឈ្មោះដែលជាក់ពិតប្រាកដទេ តែកាលខាងក្រោយមក រាងកាយរបស់លោកខ្ពស់ឡើងៗ ហើយខ្ពស់ស្រស់សង្ហា ប្រៀបបីដូចជាសសរដែលគេតុបតែងហើយ ឬប្រៀបបីដូចជាព្រះបត់ គឺសំពត់ ដែលបានវិចិត្រហើយ ដែលបុគ្គលបានលើកឡើងព្យួរទុក សូម្បីតែគុណធម៌របស់លោកក៏បានខ្ពស់ឡើងផងដែរ ហេតុដូច្នេះ លោកទើបមានឈ្មោះថា **ឧគ្គគហបតី** ដោយមានន័យថា លោកខ្ពស់ឡើង ព្រមដោយរាងកាយនិងគុណធម៌ ។

ឧគ្គគហបតី បានតាំងនៅក្នុងគុណធម៌ ថ្នាក់ព្រះសោតាបត្តិផល គឺផលនៃការចូលដល់ក្រសែនៃព្រះធម៌ ឬក្រសែនៃព្រះនិព្វាន ព្រោះការបានឃើញព្រះពុទ្ធ ជាលើកដំបូងប៉ុណ្ណោះ ។ ក្នុងកាលតមកជាខាងក្រោយទៀត ឧគ្គគហបតីបានធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផល ៣ ប្រការបានដល់ លោកបានសម្រេចអរិយធម៌ ជាព្រះអនាគាមី គឺបានជាព្រះអរិយបុគ្គលពួកទី ៣ ក្នុងបណ្តាអរិយបុគ្គល ៤ ពួក ។

ភាពជាអ្នកមាន **អច្ឆរិយធម៌** គឺធម៌ដែលគួរឲ្យអស្ចារ្យរបស់

ឧគ្គគហបតី ដែលមានសម្តែងនៅក្នុង **គម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត** នៃ **គហបតិវគ្គទី ៣** ក្នុង **ឧគ្គសូត្រ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះមានជោគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកវេសាលី ថាជាអ្នកប្រកបដោយធម៌ អស្ចារ្យចម្លែក ៨ យ៉ាង ។ ព្រះមានបុណ្យ បានត្រាស់នូវពាក្យនេះ លុះព្រះសុគតទ្រង់ត្រាស់នូវពាក្យនេះរួចហើយ ទើបក្រោកចាកអាសនៈ ហើយទ្រង់ស្តេចយាងចូលទៅកាន់វិហារ ។ គ្រានោះ មានភិក្ខុមួយរូប ស្បៃកស្បង់ប្រដាប់ដោយជាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់លំនៅរបស់ឧគ្គគហបតី អ្នកស្រុកវេសាលី លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ ទើបឧគ្គគហបតី អ្នកស្រុកវេសាលី ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ថ្វាយបង្គំភិក្ខុនោះដោយគោរព ហើយអង្គុយក្នុងទីសមគួរ លុះឧគ្គគហបតី អ្នកស្រុកវេសាលី

អគ្គិយក្ខន្ធទីសមគួរហើយ ភិក្ខុនោះក៏មានថេរវាចាដូច្នេះថា ម្នាលគហបតី អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាង ដែលព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករហើយ ម្នាលគហបតី អ្នកប្រកបដោយធម៌អស្ចារ្យចម្លែកទាំងឡាយណា ដែលព្រះជិនស្រីទ្រង់ព្យាករហើយ ធម៌អស្ចារ្យចម្លែកទាំង ៨ នោះ តើដូចម្តេច ? បពិត្រលោកម្ចាស់ជ័ចម្រើន ខ្ញុំព្រះករុណាមិនជឿសោះថា ខ្ញុំព្រះករុណាប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាង ដូចម្តេចខ្លះ ដែលព្រះមហាមុនីទ្រង់ព្យាករហើយ បពិត្រលោកម្ចាស់ជ័ចម្រើន ប៉ុន្តែធម៌អស្ចារ្យចម្លែក ៨ យ៉ាងណា ដែលមានដល់ខ្ញុំព្រះករុណា សូមលោកម្ចាស់ប្រុងស្តាប់ សូមធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ខ្ញុំព្រះករុណានឹងសម្តែងនូវធម៌ អស្ចារ្យចម្លែកទាំងនោះ ។ ភិក្ខុទទួលស្តាប់ពាក្យឧគ្គគហបតី អ្នកស្រុកវេសាលីថា ចម្រើនពរគហបតី ។ ឧគ្គគហបតីអ្នកស្រុកវេសាលី បានពោលដូច្នេះថា បពិត្រលោកម្ចាស់ជ័ចម្រើន កាលណាបើខ្ញុំព្រះករុណា បានឃើញព្រះមហាវីរៈអំពីចម្ងាយ ជាលើកដំបូង បពិត្រលោកម្ចាស់ជ័ចម្រើន ចិត្តរបស់ខ្ញុំព្រះករុណា

ក៏ជ្រះថ្លាចំពោះព្រះភគវា ដោយគ្រាន់តែបានឃើញប៉ុណ្ណោះ ។ បពិត្រ លោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ១ តែងមានដល់ខ្ញុំ ព្រះករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លុះខ្ញុំព្រះករុណា មានចិត្ត ជ្រះថ្លាហើយ ក៏ចូលទៅអង្គុយជិតព្រះទសពល ព្រះពុទ្ធអង្គទ្រង់សម្តែង នូវអនុបុព្វីកថាជាដល់ខ្ញុំ ព្រះករុណា គឺទ្រង់សម្តែងទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយដ៏លាមក សៅហ្មង និងអានិសង្ស ក្នុងការចេញចាកកាម ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ខ្ញុំព្រះករុណា មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តអណ្តែត ឡើង មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់ សម្តែងធម៌ទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្តែង ដោយព្រះអង្គឯង គឺទ្រង់សម្តែងទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ មគ្គសច្ចៈ ក្នុងកាលនោះ ។ សំពត់ស្អាតមិនប្រឡាក់ពណ៌ខ្មៅ គួរទទួល ទឹកជ្រលក់បានដោយប្រពៃ យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ខ្ញុំព្រះករុណា លើ

អាសនៈនុ៎ះឯង ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ក៏យ៉ាងនោះដែរ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាបានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានដឹងច្បាស់អរិយសច្ចធម៌ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ បានឆ្លងផុតសេចក្តីសង្ស័យ មិនងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លាហើយ មិនបានជឿស្តាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បានដល់ព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងក្នុងទីនោះ ទាំងបានសមាទាននូវសិក្ខាបទទាំងឡាយ មានព្រហ្មចរិយៈជាគម្រប់ ៥ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ២ តែងមានដល់ខ្ញុំព្រះករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមាននាងកុមារីជាប្រពន្ធ ៤ នាក់ បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះករុណាចូលទៅរកប្រពន្ធទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលទៅហ្នឹងប្រពន្ធទាំងនោះ ដូច្នេះថា ម្នាលនាងទាំងឡាយ យើងសមាទានសិក្ខាបទទាំងឡាយ មានព្រហ្មចរិយៈជាគម្រប់ ៥ ហើយ បើនាងណា

ប្រាថ្នា នាងនោះ ចូរប្រើប្រាស់នូវភោគៈទាំងឡាយនេះផង ចូរធ្វើបុណ្យទាំងឡាយផងចុះ ឬថា ទៅកាន់ត្រកូលញាតិ ជារបស់ខ្លួនក៏បាន ពុំនោះសោត នាងទាំងឡាយ ត្រូវការបុរសណា យើងនឹងឲ្យនាងទាំងឡាយទៅបុរសនោះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំព្រះករុណានិយាយយ៉ាងនេះហើយ នាងដែលជាប្រពន្ធច្បងនោះ និយាយនឹងខ្ញុំព្រះករុណាថា បពិត្រអយ្យបុត្រ ចូរអ្នកឲ្យខ្ញុំទៅបុរសឈ្មោះនេះចុះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ឯខ្ញុំព្រះករុណា ក៏ឲ្យគេហៅបុរសនោះមក ហើយដៃឆ្វេងកាន់ប្រពន្ធ ដៃស្តាំកាន់កុណ្ឌី (ច្រូចទឹក) ប្រគល់ឲ្យដល់បុរសនោះ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំព្រះករុណា លះបង់នូវនាងកុមារី ឲ្យទៅជាទានហើយ ក៏មិនធ្វើចិត្តឲ្យប្រែប្រួលឡើយ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី៣តែងមានដល់ខ្ញុំព្រះករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ភោគៈទាំងឡាយមានច្រើនក្នុងត្រកូលរបស់ខ្ញុំព្រះករុណា តែភោគៈទាំងនោះ មិនបានចែកមុខអំពីលោកអ្នកមានសីល មានទូវកល្យាណធម៌ទាំងឡាយទេ ។ បពិត្រ

លោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៤ តែងមានដល់ខ្ញុំ ព្រះករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើខ្ញុំព្រះករុណាចូលទៅអង្គុយជិតភិក្ខុណា តែងចូលទៅអង្គុយជិតដោយគោរព មិនមែនចូលទៅអង្គុយជិតដោយមិនគោរពទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៥ តែងមានដល់ខ្ញុំព្រះករុណា ។ បើលោកដ៏មានអាយុនោះសម្តែងធម៌ដល់ខ្ញុំព្រះករុណា ខ្ញុំករុណាតែងស្តាប់ដោយគោរព មិនមែនស្តាប់ដោយការមិនគោរពទេ បើលោកដ៏មានអាយុ មិនសម្តែងធម៌ដល់ខ្ញុំព្រះករុណាទេ ខ្ញុំព្រះករុណា តែងសម្តែងធម៌ដល់លោកដ៏មានអាយុនោះវិញ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៦ តែងមានដល់ខ្ញុំព្រះករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកទេវតាតែងចូលមករកខ្ញុំព្រះករុណា ហើយប្រាប់ថា ម្នាលគហបតី ធម៌ដែលព្រះកគវា ទ្រង់សម្តែងហើយ ដោយប្រពៃដូច្នេះ មិនជាទីអស្ចារ្យទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលទេវតានិយាយយ៉ាងនេះហើយ ខ្ញុំព្រះករុណាក៏និយាយទៅរកពួកទេវតាទាំងនោះយ៉ាងនេះថា ម្នាលទេវតា

ទាំងឡាយ អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះក្តី មិនគប្បីពោលយ៉ាងនេះក្តី ឯធម៌ពិត ព្រះសម្ពុទ្ធទ្រង់សម្តែងហើយ ដោយប្រពៃមែន ។ បពិត្រលោកម្ចាស់ជ័ចម្រើន ខ្ញុំមិនជឿថា ចិត្តដែលប៉ោងឡើង ព្រោះរឿងនោះជាហេតុទេ ពួកទេវតាតែងចូលមករកខ្ញុំព្រះករុណាក៏មាន ខ្ញុំព្រះករុណាតែងចរចាជាមួយនឹងពួកទេវតាក៏មាន ។ បពិត្រលោកម្ចាស់ជ័ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៧ តែងមានដល់ខ្ញុំព្រះករុណា ។ បពិត្រលោកម្ចាស់ជ័ចម្រើន សំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ យ៉ាងណា ដែលព្រះសយម្ភូទ្រង់សម្តែងហើយ បណ្តាសំយោជនៈទាំងនោះ ខ្ញុំព្រះករុណាពិចារណារកសំយោជនធម៌បន្តិចបន្តួច ដែលមិនទាន់លះបង់ក្នុងខ្លួន មិនឃើញឡើយ ។ បពិត្រលោកម្ចាស់ជ័ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៨ តែងមានដល់ខ្ញុំព្រះករុណា ។ បពិត្រលោកម្ចាស់ជ័ចម្រើន ធម៌អស្ចារ្យចម្លែកទី ៨ នេះឯង តែងមានដល់ខ្ញុំព្រះករុណា ចំណែកខ្ញុំព្រះករុណាមិនជឿសោះថា ខ្ញុំព្រះករុណាប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាងដូចម្តេចខ្លះ ដែលព្រះមានព្រះភាគ

ទ្រង់បានព្យាករហើយ ។ គ្រានោះ ភិក្ខុនោះទទួលចង្ហាន់បិណ្ឌបាត ក្នុងលំនៅរបស់ឧគ្គគហបតី អ្នកក្រុងវេសាលីហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ លុះភិក្ខុនោះ ត្រឡប់ពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃកត្តហើយ ក៏ចូលទៅគាល់ព្រះមានជោគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានបុណ្យហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនេះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលនូវរឿងរ៉ាវទាំងអស់នោះ ដែលខ្លួនចរចាទាំងប៉ុន្មានជាមួយនឹងឧគ្គគហបតី អ្នកក្រុងវេសាលី ចំពោះព្រះភគវា ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រពៃហើយៗ ឧគ្គគហបតីអ្នកក្រុងវេសាលី កាលបើព្យាករឲ្យសមហេតុ ឈ្មោះថា ព្យាករតាមពិត ម្នាលភិក្ខុ ឧគ្គគហបតី អ្នកស្រុកវេសាលី ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាងនេះឯង ដែលតថាគតបានព្យាករហើយ ម្នាលភិក្ខុ មួយទៀត អ្នកទាំងឡាយ ចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកវេសាលី ថាប្រកបដោយធម៌អស្ចារ្យចម្លែកទាំង ៨ យ៉ាងនេះចុះ ។

ជីវិតចុងក្រោយរបស់ឧគ្គគហបតី លោកបានគិតនឹងថ្វាយទាន

តាមដែលមានរឿងសម្តែងប្រាកដនៅក្នុង **អដ្ឋកថា គម្ពីរមនោរថបូរណី** ដូចមានសេចក្តីថា ៖

កាលឧគ្គគហបតី មានកាពចាស់ជរា ថ្ងៃមួយ លោកបានអង្គុយនៅក្នុងទីស្ងាត់ ហើយបានគិតថា វត្តុណាៗ ដែលជាទីពេញចិត្ត របស់យើងៗ និងថ្វាយវត្តុនោះៗ ដល់ព្រះមហាវីរៈ យើងបានស្តាប់មកអំពីព្រះឱស្ឋរបស់ព្រះសម្ពុទ្ធថា អ្នកដែលឲ្យរបស់ជាទីពេញចិត្ត រមែងបានរបស់ដែលពេញចិត្ត កាលលោកគិតដូច្នេះហើយ ក៏មានបរិវិតក្កថាសូមឲ្យព្រះបរមសាស្តា ទ្រង់ជ្រាបវារៈចិត្តរបស់យើង ហើយយាងមកត្រង់ទ្វានិវេសន៍របស់យើងចុះ ។

ការយាងទៅជ្រោសឧគ្គគហបតី របស់ព្រះទសពល តាមដែលមានរឿងសម្តែងប្រាកដនៅក្នុង **គម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត** និងក្នុង **អដ្ឋកថាមនោរថបូរណី** ដូចមានសេចក្តីថា ៖

សម័យនោះ ព្រះភគវា ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ សម័យនោះ ព្រះសាស្តា ទ្រង់ជ្រាបវារៈ

ចិត្តរបស់ឧគ្គគហបតី ដែលមានការចាស់ជរា លុះព្រឹកឡើង ព្រះអង្គ
ព្រមដោយភិក្ខុសង្ឃជាបរិវារជាច្រើន ស្តេចយាងចូលទៅកាន់និវេសន៍
របស់ឧគ្គគហបតី អ្នកស្រុកវេសាលី កាលយាងចូលទៅដល់និវេសន៍
របស់ឧគ្គគហបតីហើយ ព្រះមានជោគគង់ប្រថាប់លើអាសនៈ ដែលគេ
រៀបចំទុក ។ឧគ្គគហបតី បានចេញមកគាល់ព្រះភគវា ថ្វាយបង្គំហើយ
ក៏អង្គុយក្នុងទីដ៏សមគួរ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន
ខ្ញុំព្រះករុណាបានទទួលស្តាប់មកចំពោះព្រះភក្ត្រព្រះសាស្តាថា អ្នកឲ្យ
របស់ដែលជាទីពេញចិត្ត រមែងបានរបស់ដែលជាទីពេញចិត្តជូរច្នេះ ព្រះអង្គ
ឯងាទនីយាហារឈ្មោះ **សាលបុប្ផកៈ** (មានពណ៌ដូចផ្កាកំងភ្នំ) ដែលធ្វើ
ដោយមេរ្យាស្រូវសាលីមានរស៤ប្រការចៀនដោយទឹកដោះជ្រូនិងអប់ទុក
ដោយគ្រឿងក្រអូប ដែលជាទីពេញចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គ
ទ្រង់មេត្តាទទួលខាទនីយាហាររបស់ខ្ញុំព្រះអង្គផងចុះ ។ គ្រានោះ ព្រះ
សាស្តា ទ្រង់ទទួលសាលបុប្ផកៈខាទនីយាហារ ដោយទ្រង់អនុគ្រោះដល់
ឧគ្គគហបតី ។ ឧគ្គគហបតី បានក្រាបទូលឡើងទៀតថា បពិត្រព្រះអង្គ

ដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលស្តាប់មក ចំពោះព្រះកក្រុបស់ព្រះមុនីថា អ្នកឲ្យរបស់ដែលជាទីពេញចិត្ត រមែងបានរបស់ដែលជាទីពេញចិត្ត សាច់ជ្រូកយ៉ាងនេះល្អ ជាទីពេញចិត្តរបស់ខ្ញុំព្រះករុណា សូមព្រះអង្គទ្រង់មេត្តាទទួលសាច់ សូករយ៉ាងល្អរបស់ខ្ញុំព្រះអង្គចុះ ។ ព្រះសម្ពុទ្ធក៏ទ្រង់ទទួលដោយសេចក្តីអនុគ្រោះដល់ឧគ្គគហបតី ។

ឧគ្គគហបតីបានក្រាបទូលទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលស្តាប់មកចំពោះព្រះកក្រុ របស់ព្រះលោកនាយកថា អ្នកឲ្យរបស់ដែលជាទីពេញចិត្ត រមែងបានរបស់ដែលជាទីពេញចិត្ត ក៏នាលិយសាកខាទនីយាហារ ដែលចៀនដោយខ្លាញ់ ដែលជាទីពេញចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គទ្រង់មេត្តាទទួលនាលិយសាកខាទនីយាហារ របស់ខ្ញុំព្រះអង្គផងចុះ ។ ព្រះមហាមុនីក៏ទ្រង់ទទួលដោយអនុគ្រោះដល់ឧគ្គគហបតី ។ ឧគ្គគហបតីបានក្រាបទូលទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលស្តាប់មកចំពោះព្រះកក្រុរបស់ព្រះសម្ពុទ្ធថា អ្នកឲ្យរបស់ដែលជាទីពេញចិត្ត រមែងបានរបស់ដែលជាទីពេញចិត្ត ឯបាយ

នៃស្រូវសាលីដ៏ស្អាតមិនមានពណ៌ខ្មៅ និងសម្បុរផ្សេងៗ នេះជាទីពេញចិត្ត
របស់ខ្ញុំព្រះអង្គ សូមព្រះអង្គទ្រង់មេត្តាទទួលបាយនៃស្រូវសាលីរបស់
ខ្ញុំព្រះអង្គផងចុះ ។ ព្រះសម្ពុទ្ធក៏ទ្រង់ទទួលដោយសេចក្តីអនុគ្រោះដល់
ឧគ្គគហបតី ។

ចំណែកឧគ្គគហបតី បានក្រាបទូលទ្បើងទៀតថា បពិត្រព្រះអង្គ
ដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលស្តាប់មកចំពោះព្រះភក្ត្ររបស់ព្រះមុនីថា
អ្នកឲ្យរបស់ដែលពេញចិត្ត រមែងបានរបស់ដែលពេញចិត្ត ឯសំពត់
ដែលធ្វើក្នុងដែនកាសី ជាទីពេញចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះសាស្តា
ទ្រង់មេត្តាទទួលសំពត់ដែនកាសីនេះផងចុះ ។ ព្រះវិជិតមារទ្រង់ទទួល
ដោយសេចក្តីអនុគ្រោះដល់ឧគ្គគហបតី ។ ឧគ្គគហបតី បានក្រាបទូល
តទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលស្តាប់មក
ចំពោះព្រះភក្ត្ររបស់ព្រះជិនស្រីថា អ្នកឲ្យរបស់ដែលពេញចិត្ត រមែង
បានរបស់ដែលពេញចិត្ត ឯគ្រែដែលមានជើងធ្វើជារូបសត្វសាហាវ ក្រាល
ដោយសំពត់រោមចៀមពណ៌ស មានរចនាជារូបផ្កា មានស្បែកសត្វ

សំពោចយ៉ាងល្អ ក្រោលពីក្រោម មានពិតានខាងលើ មានខ្នើយ ទាំងសងខាង មានកម្រាលទ្រជើង ជាទីពេញចិត្តរបស់ខ្ញុំព្រះអង្គ ហើយខ្ញុំព្រះអង្គក៏ដឹងថា របស់ទាំងនេះមិនសមគួរដល់ព្រះសាស្តាទេ ចំណែកគ្រែដើមខ្វិមចន្ទន៍ ដែលមានតម្លៃច្រើនជាងមួយសែនកហាបណៈរបស់ខ្ញុំព្រះអង្គមាននៅ សូមព្រះអង្គ ទ្រង់មេត្តាទទួលផងចុះ ។ ព្រះសយម្ភូក៏ទ្រង់ទទួលដោយសេចក្តីអនុគ្រោះដល់ឧគ្គគហបតី ។គ្រានោះ ព្រះមុនីទ្រង់អនុមោទនាឧគ្គគហបតី ដោយអនុមោទនីយកថាថា

អ្នកឲ្យរបស់ដែលពេញចិត្ត រមែងបានរបស់ដែលពេញចិត្ត បុគ្គលណាឲ្យគ្រឿងស្បែកជណ្តប់ ទីដេក ជាយទឹក និងបច្ចัយផ្សេងៗជល់អ្នកបដិបត្តិត្រង់ ដោយការពេញចិត្ត របស់ដែលឲ្យទៅហើយនោះ រមែងជារបស់ដែលបរិច្ចាគហើយ លះបង់ហើយ មិនគិតផលតបស្នង បុគ្គលនោះជាសប្បុរស ស្គាល់ថា ព្រះអរហន្តទាំងឡាយ ប្រៀបដូចស្រែបុណ្យ របស់ដែលបរិច្ចាគបានដោយលំបាកហើយ ឈ្មោះថា ឲ្យរបស់ដែលពេញចិត្ត ។ព្រះមានព្រះភាគ ទ្រង់ធ្វើការអនុមោទនា ដោយ

អនុមោទនីយកថា ចំពោះខុគ្គគហបតីហើយ ស្តេចទើបក្រោកចាកអាសនៈយ៉ាងត្រឡប់ទៅវិញ ។

ក្នុងកាលខាងក្រោយតមក ខុគ្គគហបតី ក៏បានធ្វើកាលកិរិយាគឺស្លាប់ទៅកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស ក្នុងពពួកព្រហ្មដែលមានឈ្មោះថា **មនោមយៈ** ។

ក្នុងសម័យនោះ ព្រះសាស្តាទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ។ គ្រានោះឯង **ខុគ្គព្រហ្ម** មានពណ៌ដ៏រុងរឿង បានចុះមកគាល់ព្រះសម្ពុទ្ធក្នុងវេលាមជ្ឈិមយាម គឺធ្វើវត្តជេតពនទាំងមូល ឲ្យមានពន្លឺស្វាងស្វៃដោយរស្មីរបស់ខ្លួន ថ្វាយបង្គំព្រះលោកនាថហើយ ក៏ឈរក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះជិនស្រី ទើបត្រាស់សួរថា ម្នាលខុគ្គៈ អ្នកបានសម្រេចតាមបំណងហើយឬ ? ខុគ្គព្រហ្ម ក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសម្រេចទៅតាមបំណងហើយព្រះអង្គ ។ លំដាប់នោះ ព្រះសក្យមុនី ត្រាស់ជាមួយខុគ្គព្រហ្មដោយព្រះគាថាពន្ធថា

អ្នកឲ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្ត អ្នកឲ្យវត្ថុដ៏លើស រមែងបាននូវវត្ថុដ៏លើស អ្នកឲ្យរបស់ល្អ រមែងបានរបស់ល្អ អ្នកឲ្យទីស្នាងដ៏ប្រសើរ រមែងចូលទៅដល់ទីស្នាងដ៏ប្រសើរ នរជនប្រុសស្រីឯណា ឲ្យរបស់ដែលលើស ឲ្យរបស់ដែលល្អ និងទីស្នាងដ៏ប្រសើរ នរជនប្រុសស្រីនោះ កើតក្នុងទីណាៗ រមែងជាអ្នកមានអាយុយឺនយូរ មានយសក្នុងទីនោះៗ ។

គុណសម្បត្តិពិសេស ដែលឧគ្គគហបតីឧបាសកទទួលបានពីព្រះលោកនាថ ដោយបានប្រកាសតែងតាំង ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ក្នុងព្រះសាសនានេះ ក្នុងខណៈដែលឧគ្គគហបតីនៅមានជីវិតនៅឡើយ តាមដែលមានសម្តែងនៅក្នុង ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** *ដូចមានសេចក្តីថា ៖*

សម័យមួយ ព្រះទសពល ទ្រង់គង់នៅក្នុងវត្តជេតពន ព្រះអង្គបានប្រកាសតែងតាំងឧគ្គគហបតី នៅក្នុងកណ្តាលពុទ្ធបរិស័ទថា ***ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ មនាបទាយកានំ យទិទំ ឧគ្គោគហបតិ***

វេសាលិកោ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសកអ្នកឲ្យកោជនជាទីគាប់ចិត្ត ស្រេចនឹងឧគ្គគហបតី(ជាអ្នកប្រសើរជាងគេ)អ្នកនៅក្នុងក្រុងវេសាលី ។

តំណែងជាឯតទគ្គៈ ដែលឧគ្គគហបតីឧបាសក បានទទួលការតែងតាំងអំពីព្រះភគវាទាំងនេះ ដោយមានការទាក់ទងនឹងគុណធម៌ផ្សេងៗដែលឧគ្គគហបតីមានក្នុងបច្ចុប្បន្នជាតិនេះដោយចំពោះ គឺសេចក្តីល្អផ្នែកខាងឲ្យកោជន ដែលជាទីគាប់ចិត្ត និងរបស់ដែលជាទីគាប់ចិត្តទាំងនេះជាហេតុប្រការ ១ ។

ចំណែកហេតុក្នុងអតីតជាតិ ដែលឧគ្គគហបតីឧបាសកបានធ្វើកុសល និងតាំងសេចក្តីប្រាថ្នា ដើម្បីឲ្យបានតំណែងជាឯតទគ្គៈ ក្នុងសាសនាព្រះពុទ្ធអង្គណាមួយ ក្នុងកាលជាអនាគត តាមដែលមានរឿងសម្តែងប្រាកដនៅក្នុង ***អដ្ឋកថាមនោរថបូរណី*** ដូចមានសេចក្តីថា ៖

ក្នុងពុទ្ធកាល នៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ដោយរាប់ថយទៅអំពីកទ្ទុកប្បនេះមួយសែនកប្ប ។ ក្នុងគ្រានោះ ឧគ្គគហបតីឧបាសក

លោកបានកើតនៅក្នុងត្រកូលមួយ ក្នុងនគរហង្សវតី ។ថ្ងៃមួយ កុលបុត្រ (ឧគ្គគហបតី) បានទៅស្តាប់ព្រះធម្មទេសនារបស់ព្រះបទុមុត្តរៈ ហើយបានឃើញព្រះជិនស្រី ទ្រង់ប្រកាសតែងតាំងឧបាសកម្នាក់ ទុកនៅក្នុងតំណែងឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងឲ្យរបស់ដែលគាប់ចិត្ត កាលកុលបុត្រនោះបានឃើញហើយ ក៏ទឹកពេញចិត្ត ក្នុងតំណែងនោះ ទើបបានធ្វើអធិការកុសលផ្សេងៗ ហើយតាំងសេចក្តីប្រាថ្នាក្នុងទីចំពោះព្រះកក្តព្រះបទុមុត្តរៈ ដើម្បីឲ្យបានទទួលតំណែង ដូចជាឧបាសកបូបនោះ ក្នុងកាលជាអនាគតដែរ ។ គ្រានោះ ព្រះបទុមុត្តរៈព្រះអង្គក៏ទ្រង់ពិចារណាដោយអនាគតង្សញ្ញាណក្នុងរឿងនេះ ជ្រាបសព្វគ្រប់ហើយ ព្រះសម្ពុទ្ធក៏ទ្រង់ត្រាស់ព្យាករថា សេចក្តីប្រាថ្នារបស់អ្នកនឹងបានសម្រេចនៅក្នុងសាសនានៃព្រះសម្ពុទ្ធ ព្រះនាមសមណគោតមដែលព្រះអង្គត្រាស់ដឹងហើយនៅក្នុងលោក អ្នកនឹងបានសម្រេចតាមបំណង ។ គ្រាន់តែឮព្រះសម្ពុទ្ធបទុមុត្តរៈ ទ្រង់ត្រាស់ព្យាករដូច្នេះហើយ ក៏មានចិត្តរីករាយ បានថ្វាយបង្គំលាព្រះលោកនាយកត្រឡប់ទៅវិញ

ទាំងជាអ្នកស្ថិតនៅក្នុងសេចក្តីមិនប្រមាទ ខំបំពេញបុណ្យកុសលដែលជាមនោរថ ។

លុះកុលបុត្រនោះ អស់ជីវិតអំពីជាតិនោះទៅ បានត្រាច់វង្វាត់ស្លាប់កើតៗ ស្លាប់ជាមនុស្ស និងទេវតាអស់មួយសែនកប្ប មកដល់ជាតិចុងក្រោយនេះ លោកបានមកកើតក្នុងត្រកូលសេដ្ឋី នៅក្នុងក្រុងវេសាលី មានឈ្មោះថា **ឧគ្គៈ** ហើយតមក លោកបានជាសេដ្ឋីថែមទាំងបានជាឧបាសកដ៏ឆ្នើមមួយរូប នៅក្នុងព្រះពុទ្ធសាសនានេះ ដូចដែលបានពណ៌នារួចមកហើយ អំពីជីវប្រវត្តិខាងដើមរបស់ឧគ្គគហបតី ទាំងដែលគួរឲ្យជាទីជ្រះថ្លាទៀតផង ។

(ជីវប្រវត្តិរបស់ឧគ្គគហបតី អ្នកក្រុងវេសាលី ចប់)

88888888888888888888888888888888888888888888

✍ ជីវប្រវត្តិរបស់ឧគ្គតគហបតីឧបាសក ✍

“ លោកជាឯតទគ្គៈផ្នែកខាងឧបដ្ឋាកព្រះសង្ឃ ”

ឧគ្គតគហបតី **ឧបាសក** *រាប់ថាជាឧបាសកដែលទ្រទ្រង់នូវតំណែងជាឯតទគ្គៈម្នាក់ ក្នុងបណ្តាឧបាសកទាំងឡាយ ក្នុងព្រះពុទ្ធសាសនានេះ ដូចដែលមានរឿងសម្តែងប្រាកដនៅក្នុង* ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** *ដូចមានសេចក្តីថា ៖*

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ សង្ឃុប្បដ្ឋាកានំ យទិទំ ឧគ្គតោគហបតិ *ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសកទាំងឡាយ (ដែលជាអ្នកប្រសើរជាងគេ) អ្នកបម្រើព្រះសង្ឃ ស្រេចនឹងឧគ្គតគហបតី ។*

ជីវប្រវត្តិរបស់ឧគ្គតគហបតីឧបាសក ក៏មានសម្តែងទុកនៅក្នុង ***អដ្ឋកថាមនោរថបូរណី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីពាលីនៅក្នុង* ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** *ដូចមានសេចក្តីថា ៖*

ក្នុងពុទ្ធសម័យនៃព្រះបទុមុត្តរសម្មុទ្ធ ដោយរាប់ថយក្រោយអំពី

កន្លះកប្បនេះទៅមួយសែនកប្ប ។ ឧគ្គតគហបតីនេះ បានកើតនៅក្នុងត្រកូលមួយ នៅនគរហង្សវតី ។ កាលកុលបុត្រនោះចម្រើនវ័យធំដឹងក្តីហើយ ថ្ងៃមួយ បានទៅស្តាប់ព្រះធម្មទេសនារបស់ព្រះបទុមុត្តរសម្ពុទ្ធ ហើយបានឃើញព្រះមានព្រះភាគ ទ្រង់ប្រកាសតែងតាំងឧបាសកម្នាក់ទុកក្នុងតំណែង ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងឧបដ្ឋាកព្រះសង្ឃ ពេលនោះ គេក៏ទឹកពេញចិត្តក្នុងតំណែងនោះ ទើបបានប្រឹងប្រែងបំពេញវត្តប្រតិបត្តិផ្សេងៗ មានការបម្រើព្រះសង្ឃ មានការសមាទានសីល ធ្វើទានជាដើម ហើយឲ្យបានតំណែងនោះ ។

កាលកុលបុត្រនោះ អស់ជីវិតទៅហើយ ក៏បានត្រាច់រង្គាត់ស្លាប់កើតៗ ស្លាប់ជាមនុស្ស និងទេវតាអស់មួយសែនកប្ប លុះដល់ពុទ្ធកាលនៃព្រះសមណគោតមបរមគ្រូនៃយើងនេះ លោកបានមកកើតនៅក្នុងត្រកូលជាសេដ្ឋី ក្នុង **ស្រុកហត្ថីគ្រាម** ។ ពពួកញាតិ ដែលមានមាតាបិតាជាដើម បានដាក់ឈ្មោះឲ្យលោកថា **ឧគ្គតកុមារ** ។ ក្នុងកាលតមក ឧគ្គតកុមារចម្រើនវ័យធំដឹងក្តីហើយ កាលបិតារបស់លោកបាន

អស់ជីវិតទៅហើយ លោកក៏បានទទួលតំណែងជាសេដ្ឋីជំនួសអំពីបិតា របស់លោកតមក ។

សម័យមួយ ព្រះមានជោគ ដែលមានភិក្ខុសង្ឃហែហមជាច្រើន ស្តេចយាងចារិកទៅកាន់ហត្ថីគ្រាម ហើយព្រះអង្គទ្រង់គង់នៅក្នុងឧទ្យាន ឈ្មោះ **នាគវន** ។ គ្រានោះ ឧគ្គតគហបតី កំពុងជាអ្នកស្រវឹង ដោយការផឹកទឹកស្រវឹងជាប់តគ្នាមក ៧ ថ្ងៃ ខណៈដែលឧគ្គតគហបតី កំពុងនាំស្រីវជុំគ្រាច់ទៅជុំវិញឧទ្យាន ក៏បានឃើញព្រះសាស្តា លោកក៏បានកើតហិរិ និងឱត្តប្ប:យ៉ាងខ្លាំងឡើងមកមួយរំពេចក្នុងពេលនោះ ហើយឧគ្គតគហបតីបានចូលទៅគាល់ព្រះលោកនាថ ថ្វាយបង្គំព្រះអង្គ រួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះសក្យមុនី ទ្រង់ត្រាស់ សម្តែងព្រះធម៌ប្រោសដល់ឧគ្គតគហបតី ។ ក្នុងពេលដែលព្រះមានជោគ ទ្រង់ត្រាស់សម្តែងព្រះធម៌ចប់ ឧគ្គតគហបតីក៏បានសម្រេចមគ្គ និងផលលំដាប់ទី ៣ ។

រាប់តាំងអំពីឧគ្គតគហបតី បានសម្រេចមគ្គ និងផលលំដាប់ទី៣

(ជាព្រះអនាគាមី) ហើយ លោកបានប្រាប់ដល់ពួកស្រីវប៉ាំទាំងអស់នោះថា ចូរពួកនាងត្រឡប់ទៅវិញតាមសេចក្តីប្រាថ្នាចុះ ចង់ទៅណាក៏បាន ហើយលោកតាំងចិត្តថ្វាយទានដល់កិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាព្រះប្រធានតែម្យ៉ាងប៉ុណ្ណោះ ។ លុះដល់វេលាមជ្ឈិមយាម មានទេវតាមួយអង្គមកប្រាប់ដល់ឧគ្គតគហបតីថា ម្នាលគហបតី កិក្ខុអង្គនេះ ជាអ្នកសម្រេចវិជ្ជា ៣ កិក្ខុអង្គនេះ ជាអ្នកសម្រេចអភិញ្ញា ៦ កិក្ខុអង្គនេះ ជាអ្នកមានសីលបរិសុទ្ធ កិក្ខុអង្គនេះ ជាអ្នកទ្រូស្តសីល ។ ឧគ្គតគហបតី កាលបានស្តាប់ពាក្យពោលសរសើរបស់ទេវតានោះហើយ មិនបានកាន់យកពាក្យប្រាប់របស់ទេវតាទុកជាប្រមាណ ព្រោះលោកជាអ្នកដឹងច្បាស់ទៅតាមសេចក្តីពិតហើយ ទើបបានថ្វាយទេយ្យធម៌ ដោយចិត្តដែលស្មើគ្នាចំពោះកិក្ខុសង្ឃទាំងឡាយ ។

ក្នុងកាល ជាខាងក្រោយមក ព្រះលោកនាថ ទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ទ្រង់ប្រកាសតែងតាំងឧគ្គតគហបតីទុកក្នុងតំណែងជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងបម្រើព្រះសង្ឃ ។

រឿងម្យ៉ាងទៀត របស់ឧគ្គតគហបតី ជារឿងដែលពោលដល់ការឧបដ្ឋាកភិក្ខុសង្ឃ ដោយការធ្វើចិត្តរបស់លោកទៅរកភិក្ខុសង្ឃ ឲ្យមានសភាពស្មើគ្នា ទាំងនេះជាហេតុធ្វើឲ្យការថ្វាយទានរបស់លោកមានផលច្រើន មានអានិសង្សច្រើន **ជាសង្ឃទាន** ទៀតផង បានដល់ ទានដើម្បីសង្ឃ គឺថ្វាយទានជាកណ្តាលៗ ដោយមិនចោះចំពោះភិក្ខុអង្គណានីមួយឡើយ ។

ជំណើរជីវិតរបស់ឧគ្គតគហបតី ក្រោយពីស្លាប់ ទៅកើតក្នុងព្រហ្មពួកណានោះ មិនឃើញមានសម្តែងទុកក្នុងគម្ពីរណា ដូចជីវប្រវត្តិរបស់ឧគ្គគហបតីទេ ដូច្នេះ អ្នកសិក្សាទាំងឡាយ គប្បីជ្រាបក្នុងសេចក្តីនេះផងចុះ ហើយចូរពិចារណាទៅតាមក្រសែជីវប្រវត្តិរឿង៉ាវ នៃព្រះអរិយបុគ្គលមួយរូបៗដែលលោកបានសម្រេចគុណធម៌ថ្នាក់ណា ដូច្នេះ គុណធម៌ថ្នាក់នោះ បានរៀបចំដំណើរជីវិតនៃព្រះអរិយបុគ្គលនោះ ឲ្យទទួលបានទៅតាមគុណធម៌នោះ គ្រប់ៗ ព្រះអរិយបុគ្គល ទៅតាមហានៈរៀងៗ ខ្លួន ។

(ជីវប្រវត្តិរបស់ឧគ្គតគហបតីឧបាសក ចប់)

✍ ជីវប្រវត្តិរបស់សូរអម្ពដ្ឋឧបាសក ✍

“ លោកជាឯតទគ្គៈផ្នែកខាងអ្នកជ្រះថ្លាមិនកម្រើក ”

សូរអម្ពដ្ឋសេដ្ឋីជាឧបាសក ដែលជាអ្នកទ្រទ្រង់នូវគុណធម៌ដ៏ឧត្តមម្នាក់ដែរ ក្នុងបណ្តាឧបាសកទាំងឡាយ ក្នុងព្រះពុទ្ធសាសនានេះ ដោយលោកជាអ្នកបានទទួលការប្រកាសតែងតាំង អំពីព្រះទសពលឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ជាអ្នកជ្រះថ្លាមិនកម្រើក ដូចមានសម្តែងប្រាកដនៅក្នុង ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** *ថា ៖*

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ *ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសក (ដែលជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាង) អ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងសូរអម្ពដ្ឋឧបាសក ។*

ជីវប្រវត្តិរបស់សូរអម្ពដ្ឋឧបាសក មានសម្តែងប្រាកដនៅក្នុង ***អដ្ឋកថាមនោរថបូរណី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីក្នុង*

គម្ពីរអង្គុត្តរនិកាយ ឯកនិបាត ដូចមានសេចក្តីថា ៖

ក្នុងសម័យពុទ្ធកាលនៃព្រះសម្មុទ្ធបទុមុត្តរៈ ដោយរាប់ថយក្រោយអំពីកទុកប្បនេះមួយសែនកប្ប ។ គ្រានោះ សូរអម្ពដ្ឋៈ បានកើតនៅក្នុងត្រកូលមួយ ក្នុងនគរហង្សវតី ។ ពេលដែលលោកចម្រើនវ័យធំដឹងក្តីហើយ ថ្ងៃមួយ លោកបានទៅស្តាប់ព្រះធម្មទេសនារបស់ព្រះបទុមុត្តរៈ ហើយបានឃើញព្រះអង្គ ទ្រង់ប្រកាសតែងតាំងឧបាសកម្នាក់ទុកក្នុងតំណែង ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងជាអ្នកជ្រះថ្លាមិនកម្រើក លុះបានឃើញដូច្នេះហើយ ពេញចិត្តក្នុងតំណែងនោះ ទើបបានធ្វើអធិការកុសលផ្សេងៗ ជាច្រើន មានការបរិច្ចាគទានជាដើម ហើយប្រាថ្នាដើម្បីឲ្យបានតំណែងនោះ ក្នុងកាលជាអនាគត ។ កាលលោកអស់ជីវិតអំពីជាតិនេះទៅហើយ បានត្រាច់រង្គាត់ស្ទាប់កើតៗស្ទាប់ជាមនុស្ស និងទេវតាអស់មួយសែនកប្ប ។ លុះមកដល់ពុទ្ធកាលនៃព្រះសម្មុទ្ធបរមគ្រូនៃយើងនេះ លោកបានមកកើតនៅក្នុងត្រកូលសេដ្ឋីនៅឯក្រុងសាវត្ថី ។ មាតាបិតា បានដាក់ឈ្មោះឲ្យលោកថា **បុរាណៈ**

(ចំណែកក្នុងព្រះបាលីឈ្មោះថា **សូរអម្ពដ្ឋ:**) ។ក្នុងកាលជាខាងក្រោយមក ពេលដែលលោកចម្រើនវ័យធំដឹងក្តីហើយ ជីងការខុសត្រូវបាន ទើបបានជាអ្នកមើលការខុសត្រូវចំពោះផ្ទះសម្បែង តែលោកបានជាឧបដ្ឋាកគឺទំនុកបម្រុងរបស់ពួកអន្យតិរ្ថិយ ។

តមកថ្ងៃមួយ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោកក្នុងវេលាជិតភ្លឺ ដែលរាប់ថា ជាពុទ្ធកិច្ច សំដៅដល់ កិច្ចដែលព្រះសម្មុទ្ទទ្រង់បំពេញប្រចាំថ្ងៃ មាន ៥ ប្រការ បានដល់ គឺ ៖

១- ក្នុងពេលព្រឹក ស្តេចយាងទៅបិណ្ឌបាត

២- ក្នុងពេលល្ងាច ទ្រង់សម្តែងព្រះធម៌ទេសនា

៣- ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ

៤- ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា

៥- ក្នុងពេលជិតភ្លឺ ទ្រង់ប្រមើលមើលនូវសត្វលោក ដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ។

ហើយព្រះអង្គ ទ្រង់បានឃើញឧបនិស្សយ នៃព្រះសោតាបត្តិមគ្គ

របស់សូរអម្ពដ្ឋសេដ្ឋី ។ កាលដល់ពេលទ្រង់ស្តេចយាងចារិកកិក្ខាចារ
ព្រះលោកនាយក បានយាងទៅកាន់ត្រង់ទ្វារផ្ទះរបស់សូរអម្ពដ្ឋសេដ្ឋី ។
សូរអម្ពដ្ឋសេដ្ឋី កាលដែលឃើញព្រះមានព្រះភាគហើយៗ គិតថា
ព្រះសមណគោតម ទ្រង់ជាអ្នកជ័ងប្រាកដក្នុងលោកនេះ ព្រោះដូច្នោះ
ការដែលយើងមិនចូលទៅគាល់ព្រះពុទ្ធអង្គ រមែងជាការមិនសមគួរទេ
លុះសូរអម្ពដ្ឋសេដ្ឋីគិតឃើញដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្តា
ថ្វាយបង្គំទៀបព្រះឃុគលបាទ ហើយបានទទួលបាត្រអំពីព្រះសក្យមុនី
ហើយក្រាបទូលអារាធនា ឲ្យព្រះអង្គស្តេចយាងចូលទៅក្នុងផ្ទះរបស់ខ្លួន
ទាំងក្រាបទូលនិមន្តឲ្យព្រះភគវាទ្រង់គង់លើបល្ល័ង្ក ដែលមានតម្លៃច្រើន
ថែមទាំងបានថ្វាយចង្ហាន់បិណ្ឌបាតដល់ព្រះសម្ពុទ្ធទៀតផង កាលដែល
ព្រះសម្មាសម្ពុទ្ធ ទ្រង់ធ្វើកត្តកិច្ចស្រេចហើយ សូរអម្ពដ្ឋៈ ក៏បានអង្គុយ
នៅក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះបរមសាស្តា ទ្រង់សម្តែងព្រះធម៌
ឲ្យសូរអម្ពដ្ឋៈ បានស្តាប់តាមសមគួរដល់ឧបនិស្ស័យរបស់ខ្លួន ។ ក្នុង
ពេលដែលព្រះអង្គទ្រង់ត្រាស់សម្តែងព្រះធម៌ចប់ សូរអម្ពដ្ឋសេដ្ឋី ក៏បាន

សម្រេចសោតាបត្តិផល បានដល់ផលនៃការចូលដល់ក្រសែព្រះនិព្វាន ដែលរាប់ថា ជាព្រះអរិយបុគ្គលថ្នាក់ដំបូង ក្នុងព្រះពុទ្ធសាសនានេះ ។ កាលព្រះវិជិតមារ ទ្រង់ទូន្មានសូរអម្ពដ្ឋសេដ្ឋីរួចហើយ ទើបស្តេចយាងត្រឡប់ទៅឯវិហារវិញ ។

លំជាប់តពីនោះ មារទើបគិតថា សូរអម្ពដ្ឋសេដ្ឋីនេះ ជាសម្បត្តិរបស់យើង តែថ្ងៃនេះ ព្រះសមណគោតម បានស្តេចយាងទៅកាន់ផ្ទះរបស់គេៗ បានស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាហើយ បានធ្វើមគ្គឲ្យច្រាកដឡើងហើយឬអត់ហ្ន៎ ព្រោះហេតុដូច្នោះ យើងត្រូវធ្វើឲ្យដឹងថា គេកន្ធងផុតវិស័យរបស់យើងទៅ ឬថា គេនៅមិនទាន់កន្ធងផុតវិស័យរបស់យើងទេ កាលមារមានចិត្តចាបគិតដូច្នេះ ក៏បានកាឡាខ្លួន ឲ្យមានរូបស្រដៀងនឹងព្រះសម្ពុទ្ធ ហើយកាន់ចាត្រ គ្រងចីវរឲ្យជាបរិមណ្ឌល ដើរទៅដោយអាកប្បកិរិយានៃព្រះពុទ្ធនុ៎ះឯង ថែមទាំងជាអ្នកប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ហើយទៅឈរនៅត្រង់មុខទ្វារផ្ទះរបស់សូរអម្ពដ្ឋសេដ្ឋី ។ ចំណែកសូរអម្ពដ្ឋៈ បានជ្រាបដំណឹងថា ព្រះមុនី

ស្តេចយាងមក ទើបគិតថា ការយាងមកដោយមិនមានកំណត់ពិតជ្រាកជ
របស់ព្រះពុទ្ធទាំងឡាយ រមែងប្រព្រឹត្តទៅមិនមាន ក៏ព្រះអង្គបានយាង
មកហើយ តើព្រះអង្គយាងមកទៀត ព្រោះហេតុអ្វីហ្ន៎ លុះគិតដូច្នេះហើយ
លោកទើបទៅរកមារ ដែលកាឡាខ្លួនដោយរូសរាន់ ដោយសម្គាល់ថា
ជាព្រះមុនី កាលលោកទៅដល់ទើបក្រាបចុះ ហើយឈរក្នុងទីដ៏សមគួរ
ថែមទាំងក្រាបទូលសួរថា បពិត្រព្រះមានបុណ្យ ព្រះអង្គបានទទួល
ចង្ហាន់ស្រេចជាប់ ហើយយាងត្រឡប់ទៅវិញ តែព្រះអង្គទ្រង់អាស្រ័យ
ហេតុអ្វី ទើបព្រះអង្គយាងត្រឡប់មកទៀត ព្រះអង្គ ?

មារទើបពោលថា ម្នាលសូរអម្ពដ្ឋៈ កាលតថាគតពោលធម៌
មានធម៌បទមួយ ដែលតថាគតមិនបានពិចារណា ហើយពោលទៅ គឺ
តថាគតពោលថា ខន្ធ ៥ សុទ្ធតែជារបស់មិនទៀង ជាទុក្ខ ជាអនត្តា
ដូច្នេះ តែខន្ធ ៥ មិនមែនដូច្នោះទាំងអស់ទេ ខន្ធខ្លះជារបស់ទៀងទាត់
ស្ថិតស្ថេរ និងតាំងមាំមួនមានដែរ ។ សូរអម្ពដ្ឋៈទើបគិតថា ពាក្យយ៉ាងនេះ
ជាពាក្យដែលធ្ងន់ ព្រោះថា ពាក្យរបស់ព្រះពុទ្ធទាំងឡាយ ដែលនឹងក្លាយ

ជាពីរប្រការ រមែងមិនមាន កាលលោកពិចារណាហើយ ទើបគិតថា ឈ្មោះថា **មារ** រមែងជាសត្រូវចំពោះព្រះពុទ្ធ បុគ្គលនេះប្រាកដជាមារ ទើបពោលឡើងថា អ្នកឯងជាមារឬ?ពាក្យសម្តីដែលព្រះអរិយសាវ័ក ពោលហើយ រមែងប្រាកដជាល់មារ ដូចជាគេកាប់ដោយពូថៅដូច្នោះឯង។ ព្រោះហេតុនោះ មារនោះទើបមិនអាច តម្រង់ខ្លួនជាប្រក្រតីបាន ទើប ពោលថា ម្នាលសូរអម្ពដ្ឋៈ មែនហើយ យើងជាមារមែន ។

សូរអម្ពដ្ឋៈផ្ទាត់ម្រាមដៃឲ្យជីងថា មារដូចលោកទាំងរយ ទាំងពាន់ ក៏ដោយ មិនអាចធ្វើឲ្យសទ្ធារបស់យើងញាប់ញ័របានឡើយ ព្រះមហា គោតមទសពល កាលនឹងទ្រង់សម្តែងធម៌ដល់យើង ទ្រង់បានសម្តែង ឲ្យយើងជីងថា សង្ខារធម៌ទាំងឡាយ **ជាអនិច្ចំ ជាទុក្ខំ ជាអនត្តា** ដូច្នេះ លោកកុំមកឈរនៅត្រង់មុខទ្វារផ្ទះរបស់យើងឡើយ ពោលដូច្នេះ ព្រមទាំងទះដៃដេញទៅ ។ មារបានស្តាប់ពាក្យសម្តីរបស់សូរអម្ពដ្ឋៈ ក៏មិនអាចពោលត្វើយឆ្វងបាន ទើបបាត់អំពីទីនោះទៅក្នុងពេលនោះឯង។ ចំណែកសូរអម្ពដ្ឋសេដ្ឋី បានចូលទៅគាល់ព្រះវិជិតមារ ក្នុងវេលាល្ងាច

ក្រាបទូលដល់កិរិយា ដែលមារធ្វើឲ្យព្រះអង្គ ទ្រង់ជ្រាបហើយ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មារព្យាយាមដើម្បីធ្វើឲ្យសទ្ធារបស់ខ្ញុំព្រះអង្គកម្រើក ដោយអាការយ៉ាងនេះឯង ព្រះអង្គ ។ ព្រះកគាទ្រង់ធ្វើរឿងនេះឲ្យជាដើមហេតុទើបទ្រង់ប្រកាសតែងតាំងសូរអម្ពដ្ឋសេដ្ឋីទុកក្នុងតំណែងឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងអ្នកមានសទ្ធាជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធសាសនានេះ ។

មួយវិញទៀត ហេតុផល ដែលសូរអម្ពដ្ឋសេដ្ឋី ដែលបានទទួលការលើកតម្កើងឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងជាអ្នកមានសេចក្តីជ្រះថ្លាមិនកម្រើកនោះ ដោយអាស្រ័យហេតុពីរប្រការគឺ ៖

១- ហេតុក្នុងអតីតជាតិ បានដល់ ការបំពេញបុណ្យកុសលរបស់លោកដែលធ្វើទុករួចមកហើយ ជ្រាបថ្នាឲ្យបានតំណែងនោះ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះបទុមុត្តរសម្មាសម្ពុទ្ធ ។

២- ហេតុក្នុងបច្ចុប្បន្ន បានដល់ ការដែលលោកមិនញាប់ញ័រចំពោះមារ ដែលនឹងមកទម្លាយសទ្ធារបស់ខ្លួន ។

ភាពជាអ្នកជាក់ចិត្តជឿក្នុងព្រះពុទ្ធ របស់សូរអម្ពដ្ឋឧបាសក ដូច ដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត** ថា ៖

ព្រះកគវាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូរអម្ពដ្ឋៈដែលប្រកប ដោយធម៌ ៦ ប្រការ ជាអ្នកជាក់ចិត្តជឿចំពោះតថាគត ឃើញអមតធម៌ ធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ដោយធម៌ ៦ ប្រការ ដូចម្តេច ? ធម៌ ៦ ប្រការនោះ បានដល់អ្វីខ្លះ ? ***១. ជាអ្នកមានសទ្ធាជ្រះថ្លាមិនញាប់ញ័រក្នុងគុណព្រះពុទ្ធ ២.ជាអ្នកមានសទ្ធាជ្រះថ្លាមិនញាប់ញ័រក្នុងគុណព្រះធម៌ ៣. ជាអ្នកមានសទ្ធាជ្រះថ្លាមិនញាប់ញ័រក្នុងគុណព្រះសង្ឃ ៤.ជាអ្នកមាននូវអរិយសីល (សំដៅដល់លោកុត្តរសីល ដែលអស់ទោសហើយ) ៥.ជាអ្នកមានអរិយញ្ញាណ (សំដៅដល់ បច្ចវេក្ខណញ្ញាណ គឺញ្ញាណដែលពិចារណាមគ្គផល) ៦.ជាអ្នកមានអរិយវិមុត្តិ (សំដៅដល់ផលវិមុត្តិបានដល់ ផល គឺការផុតស្រឡះចាកកិលេសរបស់សេក្ខបុគ្គល)*** ។ម្នាលភិក្ខុទាំងឡាយ សូរអម្ពដ្ឋៈ ជាអ្នកប្រកបដោយធម៌ ៦ ប្រការនេះឯង ជាអ្នកជាក់ចិត្តជឿចំពោះតថាគត (អដ្ឋកថាចារ្យបានអធិប្បាយថា ជាអ្នក

មានចិត្តតាំងមាំល្អហើយ ក្នុងគុណព្រះពុទ្ធ គឺជាអ្នកអស់នូវសេចក្តីសង្ស័យ ហើយ) ឃើញនូវអមតធម៌ និងធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ។

សេចក្តីល្អផ្សេងៗដែលសូរអម្ពដ្ឋឧបាសកបានធ្វើទុកមកហើយ រាប់ថាជាឧទាហរណ៍ ដែលនឹងជួយឲ្យអ្នកសិក្សាស្គាល់អំពីជីវប្រវត្តិរបស់លោក ដែលបានជ្រើសរើស ហើយទើបរាប់អាន **សាសនា** ដូចបុគ្គលអ្នកឈ្វាស រមែងជ្រើសរើសផ្លែឈើដែលល្អ និងមានប្រយោជន៍ដល់អ្នកទទួលទាន មិនមែនរាប់អានសាសនាបែបតាមៗ គេទៅទេ ដែលមិនខុសអ្វីនឹងមនុស្សដែលភ្នែកខ្វាក់ ជៀអ្នកជំទៃប្រាប់ ដោយខ្លួនឯងមើលមិនឃើញ សតិបញ្ញារបស់យើងម្នាក់ៗចាត់ថា ជាគ្រឿងសម្ភារៈសម្រាប់ពិសោធ រិះរកសេចក្តីពិត យើងទើបគួរប្រើសតិបញ្ញាជ្រើសរើសវត្ថុដែលជាគុណប្រយោជន៍ និងចៀសវាងវត្ថុ ដែលមិនមានគុណប្រយោជន៍ យើងក៏នឹងបានទទួលតែផលល្អ ក្នុងការប្រព្រឹត្តទៅនៃជីវិតយ៉ាងមានប្រសិទ្ធិភាពពិតប្រាកដ ។

(ជីវប្រវត្តិរបស់សូរអម្ពដ្ឋឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ចិត្តគហបតីឧបាសក ✍

“ ដែលជាឯតទគ្គៈផ្នែកខាងធម្មកថិក ”

ចិត្តគហបតី លោកជាអ្នកទ្រទ្រង់នូវតំណែងជាឯតទគ្គៈមួយដែរ គឺផ្នែកខាងធម្មកថិក ដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់តែងតាំងទុកឲ្យជាអ្នកកំពូលលើសឧបាសកទាំងឡាយ ដោយមានរឿងពោលក្នុង ***អដ្ឋកថាមនោរថបូរណី*** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** និងនៅក្នុង ***អដ្ឋកថាធម្មបទ*** នៃ ***ពាលវគ្គ*** ដូចមានសេចក្តីថា :-

ក្នុងវេលាមួយសែនកប្បកន្លងមកហើយ ដោយរាប់ថយក្រោយត្រឡប់អំពីកទូកប្បនេះទៅ... ចិត្តគហបតីបានកើតក្នុងផ្ទះរបស់ត្រកូលនៅក្នុងនគរហង្សវតី ដែលត្រូវនឹងពុទ្ធកាលរបស់ព្រះបទុមុត្តរសម្ពុទ្ធ ។ តមកខាងក្រោយ នៅថ្ងៃមួយ បានទៅស្តាប់ព្រះធម្មទេសនារបស់ព្រះបទុមុត្តរសម្ពុទ្ធ បានឃើញព្រះអង្គទ្រង់តែងតាំងឧបាសកម្នាក់ ឲ្យជាអ្នក

ប្រសើរលើសឧបាសកទាំងឡាយ ផ្នែកខាងធម្មកថិក ទើបធ្វើអធិការកុសល ហើយប្រាថ្នាដើម្បីឲ្យបាននូវតំណែងនោះ ។ លុះអស់ជីវិតហើយ បានត្រាច់រង្គាត់ក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ហើយបានមកកើតក្នុងផ្ទះរបស់នាយព្រានបរបាញ់សត្វ ដែលមកត្រូវនឹងពុទ្ធកាលរបស់ព្រះកស្សបសម្មាសម្ពុទ្ធ ។

ខាងក្រោយមក កាលគេពេញវ័យហើយ អាចធ្វើការបរបាញ់សត្វក្នុងព្រៃបាន ថ្ងៃមួយ ភ្លៀងកំពុងធ្លាក់ចុះ គេកាន់យកលំពែងទៅដើម្បីបរបាញ់សត្វក្នុងព្រៃ ខណៈដែលគេកំពុងសម្ងំរកមើលម្រឹគដើម្បីនឹងបាញ់ ក៏បានឃើញកិកុ ១ រូប អង្គុយយកចីវរបង់រុំកូលគ្របសីសៈនៅលើផែនថ្ម ត្រង់ចំណោតនៃកូនភ្នំមួយ គេយល់ថា លោកម្ចាស់ ១ រូបអង្គុយធ្វើសមណធម៌ យើងនឹងនាំអាហារមកថ្វាយលោក រួចហើយត្រឡប់ទៅកូមិដ្ឋានរបស់ខ្លួន ដោយរហ័ស អាងសាច់ដែលខ្លួននាំមកលើចង្រ្កានមួយ កាលពីមុនមិញ និងចម្អិនបាយលើចង្រ្កានមួយទៀត តែបានឃើញកិកុ ២ រូប កំពុងត្រាច់បិណ្ឌបាត ក៏ហួសទៅទទួលបាត្រ

របស់លោកមក និងនិមន្តឲ្យលោកគង់លើអាសនៈដែលរៀបចំទុកហើយ ទាំងនិមន្តឲ្យលោកឆាន់អាហារបិណ្ឌបាតថា សូមអាភធនាព្រះគុណម្ចាស់ ឆាន់ចង្ហាន់ចុះ និងបង្គាប់បុគ្គលដទៃ ឲ្យជួយអង្គាសព្រះគុណម្ចាស់ ទាំងឡាយ ចំណែកខ្លួនឯង ដួសបាយដាក់ចុះក្នុងឆ្នាំងហើយ ប្រើស្លឹកឈើចងបិទមាត់ឆ្នាំង និងកាន់ឆ្នាំងនោះដើរទៅ តែក្នុងរវាងផ្លូវគេបានបេះផ្លាឈើច្រើន ប្រភេទយកទៅផង ។ លុះគេទៅដល់ស្ថានទីដែលព្រះថេរៈគង់នៅ ទើបដាក់ឆ្នាំងបាយចុះ ហើយឈរនៅកន្លែងសមគួរម្ខាង ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាអនុគ្រោះខ្ញុំព្រះករុណាផងចុះ គ្រាន់តែគេពោលដូច្នេះហើយ បាននាំបាត្ររបស់ព្រះថេរៈ មកដាក់កន្លាហាររហូតពេញ ហើយយកបាត្រប្រគេនព្រះថេរៈ និងនាំយកផ្លាឈើច្រើនប្រភេទ ដែលខ្លួនបេះប្រមូលមកតាំងចិត្តបូជាព្រះថេរៈ ហើយឈរនៅក្នុងទីដ៏សមគួរម្ខាង បានតាំងសេចក្តីប្រាថ្នាថា ដោយការបូជាផ្លាឈើ ព្រមទាំងការថ្វាយអាហារដ៏មានរសនេះ រមែងធ្វើចិត្តរបស់ខ្ញុំឲ្យត្រេកអរបានច្រើន យ៉ាងណា

សូមគ្រឿងបណ្ណាការចំនួនមួយពាន់ៗ ចូលមកដល់ខ្ញុំ និងភ្លៀងផ្កាឈើ ៥ ពណ៌ ចូរធ្លាក់ចុះក្នុងស្ថានទីដែលខ្ញុំកើតហើយៗ ដូច្នោះចុះ លោកម្ចាស់ ។ ព្រះថេរៈសម្ដែងមើលឧបនិស្ស័យរបស់នាយព្រានហើយ ទើបឲ្យកម្មដ្ឋានដោយអាការ ៣២ ។

នាយព្រាននោះ បានធ្វើបុណ្យកុសលរហូតអស់ជីវិត លុះអស់ជីវិតហើយ បានទៅកើតក្នុងទេវលោក ក្នុងស្ថានទីដែលគេកើតឡើងមានផ្កាឈើទិព្វធ្លាក់ចុះមក រហូតកម្ពស់ត្រឹមក្បាលជង្គង់ ទាំងខ្លួនឯងជាអ្នកមានយសជាងពួកទេវតាដទៃ ។ កុលបុត្រនោះ គ្រាច់រង្គាត់កើតស្ងាប់ៗ កើតអស់កាលយូរមួយចន្លោះព្រះពុទ្ធ ហើយបានមកកើតក្នុងត្រកូលសេដ្ឋី ក្នុង **មច្ឆិកាសណ្ឌនគរ** ក្នុង **មគធរដ្ឋ** ក្នុងពុទ្ធុប្បាទកាលនេះ ។ ក្នុងពេលដែលគេកើត មានភ្លៀងផ្កាឈើ ៥ ពណ៌ ធ្លាក់ចុះមកទូទាំងព្រះនគរ កម្ពស់ប្រមាណត្រឹមជង្គង់ គ្រានោះ មាតាបិតារបស់គេបានពោលថា បុត្ររបស់យើងបាននាំយកឈ្មោះរបស់ខ្លួនមកផង ព្រោះក្នុងថ្ងៃដែលគេកើត នគរទាំងអស់វិចិត្រទៅដោយផ្កាឈើ ៥ ពណ៌ ទើប

តាំងឈ្មោះឲ្យដល់កូនប្រុសថា **ចិត្តកុមារ** ។ តមកខាងក្រោយ គ្រាន់តែចិត្តកុមារពេញវ័យហើយ ក៏បានមានគូគ្រង និងគ្រាបិតាអស់ជីវិតទៅហើយ ទើបបានទទួលតំណែងសេដ្ឋី ក្នុងព្រះនគរនោះជំនួសបិតា ។

រឿងរបស់ចិត្តគហបតីតទៅនេះ មានប្រាកដនៅក្នុង **អដ្ឋកថាមនោរថបូរណី** តែរឿងចំណែកធំមានក្នុង **អដ្ឋកថាធម្មបទ** នៃ **ពាលវគ្គ** ក្នុងរឿងរបស់ព្រះសុធម្មត្ថេរ ជារឿងដែលព្រះសាស្តា កាលគង់ប្រថាប់នៅក្នុងជេតពន ជិនក្រុងសាវត្ថី ទ្រង់ប្រារព្ធព្រះសុធម្មត្ថេរថា :-

មូលហេតុដែលចិត្តគហបតី មានសេចក្តីជឿជ្រះថ្លា នៅក្នុងព្រះពុទ្ធសាសនានេះ ដោយអាស្រ័យគាត់បានឃើញព្រះមហានាមត្ថេរ ដែលជាព្រះថេរៈ ១ រូប ក្នុងចំណោមបញ្ចវគ្គិយភិក្ខុ បាននិមន្តមកកាន់ **មច្ឆិកាសណ្ឌនគរ** និងកំពុងគ្រាច់បិណ្ឌបាត ក៏កើតសេចក្តីជ្រះថ្លាក្លាមក្នុងឥរិយាបថ (គឺការកម្រើកពាងកាយ) របស់ព្រះថេរៈ ទើបសូមទទួលបាត្រ និងនិមន្តលោកចូលទៅកាន់ផ្ទះរបស់ខ្លួន ហើយបង្អោនថ្វាយអាហារបិណ្ឌបាតដល់ព្រះថេរៈ ។ កាលព្រះមហានាមត្ថេរ ឆាន់ស្រេច

ហើយ បានពិចារណាឃើញឧបនិស្ស័យរបស់ចិត្តគហបតី ទើបសម្តែងព្រះធម៌ដោយចែកអាយតនៈ ៦ ប្រការ ឲ្យចិត្តគហបតីស្តាប់រហូត ។ ចិត្តគហបតីបានស្តាប់ព្រះធម៌ទេសនាហើយ បានសម្រេចសោតាបត្តិ-ផល ជាព្រះអរិយបុគ្គលថ្នាក់ដំបូងក្នុងព្រះពុទ្ធសាសនា ដែលហៅអ្នកដែលបានសម្រេចធម៌នេះថា **ព្រះសោតាបន្ន** ទើបគាត់ជាអ្នកមានសទ្ធាមាំទាំមិនញាប់ញ័រ និងជាអ្នកមានបំណងធ្វើសួនរបស់ខ្លួន ឈ្មោះថា **អម្ពាដកវ័ន** (សួនម្លាក់) **ឲ្យជាសង្ឃារាម** គឺលំនៅរបស់សង្ឃ ហើយឲ្យសាងលំនៅសម្រាប់ព្រះសង្ឃ ក្នុងសួនម្លាក់នោះ ទាំងបានច្រួចទឹកចុះក្នុងដៃរបស់ព្រះថេរៈ ដើម្បីជាការប្រគល់ថ្វាយ ។

ក្នុងខណៈដែលចិត្តគហបតី កំពុងច្រួចទឹកចុះក្នុងដៃរបស់ព្រះថេរៈ មហាប្រឹថពីបានកើតមានអាការញាប់ញ័រចុះទៅ រហូតដល់ទឹកទ្រផែនដី ដែលជានិមិត្តសម្តែងប្រាប់ហេតុថា ព្រះពុទ្ធសាសនាតាំងមាំហើយ ។ ចិត្តគហបតីបានឲ្យសាងមហាវិហារក្នុងសួន និងបានជាអ្នកបើកទ្វារទុកសម្រាប់កិក្ខុ អ្នកមកអំពីទិសទាំង ៤ ។ រីឯចិត្តគហបតីសាងឡើងនេះ

មានឈ្មោះថា **អម្ពាដការាម** ដោយព្រះសុធម្មត្ថេរជាចៅអាវាស ព្រោះលោកជាអ្នកធ្វើការកសាង និងជាភិក្ខុឆាន់អាហារបិណ្ឌបាតជាប្រចាំក្នុងត្រកូលរបស់ចិត្តគហបតី ។ កាលខាងក្រោយ ថ្ងៃមួយ មានព្រះឥសិទត្តត្ថេរ បានទៅត្រង់អម្ពាដការាម ក្នុងមច្ឆិកាសណ្ឌនគរនោះ និងក្នុងថ្ងៃនោះ ព្រះមហានាមត្ថេរឆាន់អាហារបិណ្ឌបាត នៅត្រង់និវេសន៍របស់ចិត្តគហបតីស្រេចហើយ លោកមិនប្រាថ្នានឹងឆ្លើយបញ្ហារបស់ចិត្តគហបតី ទើបបាននិមន្តព្រះឥសិទត្តត្ថេរ ឲ្យឆ្លើយនូវបញ្ហារបស់ចិត្តគហបតី ។

រឿងបញ្ហារបស់ចិត្តគហបតី ដោយព្រះឥសិទត្តត្ថេរជាអ្នកឆ្លើយ មានសម្តែងនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ សឡាយតនវគ្គ** នៃ **ឥសិទត្តសូត្រទី ១** ដូចមានសេចក្តីថា :-

សម័យមួយ ភិក្ខុទាំងឡាយ ដែលមានព្រះថេរៈច្រើនរូបនៅក្នុងអម្ពាដកវ័ន គ្រានោះ ចិត្តគហបតីបានចូលទៅរកពួកភិក្ខុជាថេរៈទាំងនោះ ថ្វាយបង្គំហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ហើយបានអារាធនាថា បពិត្រ

លោកម្ចាស់ទាំងឡាយដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ មេត្តាទទួលភត្តាហារបស់ខ្ញុំក្នុងថ្ងៃស្អែកនេះផងចុះ ។ ភិក្ខុទាំងនោះទទួលអាភធនាដោយអាការតុណ្ហីភាព ។ ចិត្តគហបតីបានជ្រាបថា ភិក្ខុទាំងឡាយបានទទួលអាភធនាហើយ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំ និងធ្វើការប្រទក្សិណ ហើយត្រឡប់ទៅ ។លុះដល់ព្រឹកឡើង ភិក្ខុជាព្រះថេរៈទាំងឡាយស្លៀកដណ្តប់រៀបរយហើយ កាន់បាត្រនាំគ្នានិមន្តចូលទៅកាន់និវេសន៍របស់ចិត្តគហបតី ហើយគង់លើអាសនៈដែលគេរៀបចំទុក ។ ចំណែកចិត្តគហបតី បានចូលទៅរកភិក្ខុជាព្រះថេរៈទាំងឡាយ ក្រាបថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរ និងបានសួរព្រះថេរៈជាប្រធានថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានពាក្យពោលថា ការផ្សេងគ្នានៃធាតុៗ ដូច្នេះ ការផ្សេងគ្នានៃធាតុនោះ ព្រះមានព្រះភាគត្រាស់ទុកដោយហេតុប៉ុន្មានហ្ន៎ លោកម្ចាស់ ?

កាលចិត្តគហបតីសួរយ៉ាងនេះ ព្រះថេរៈជាប្រធាន ក៏គង់នៅស្ងៀម ទើបចិត្តគហបតីសួរលើកទី ២ ទៀត និងលើកទី ៣ ព្រះថេរៈ

ជាប្រធានក៏នៅអង្គុយស្ងៀមទៀត (មិនព្រមឆ្លើយនូវសំណួរ) ព្រះឥសិទត្តៈ ជាអ្នកថ្មីជាងពួកភិក្ខុសង្ឃនេះទាំងអស់ បានពោលសូមឱកាសនឹងព្រះថេរៈដែលជាប្រធានថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំសូមអនុញ្ញាតពោលឆ្លើយបញ្ហានេះរបស់ចិត្តគហបតី ។ ព្រះថេរៈ អ្នកជាប្រធានក៏អនុញ្ញាតថា អាវុសោឥសិទត្តៈ ចូរលោកឆ្លើយបញ្ហារបស់ចិត្តគហបតីចុះ ទើបព្រះឥសិទត្តៈ ពោលឡើងថា លោកគហបតី លោកបានសួរដល់ការផ្សេងគ្នា នៃធាតុយ៉ាងនោះឬ ចិត្តគហបតីពិតតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន យ៉ាងហ្នឹងហើយ កុរុណាម្ចាស់ ។ ទើបព្រះឥសិទត្តៈពោលថា គហបតី ការផ្សេងគ្នានៃធាតុ ព្រះមានព្រះភាគជាម្ចាស់បានត្រាស់ទុកដូច្នេះ គឺចក្ខុធាតុ បានដល់ **ធាតុ** គឺភ្នែក រូបធាតុ បានដល់ **ធាតុ** គឺរូប ចក្ខុវិញ្ញាណធាតុ បានដល់ **ធាតុ** គឺការដឹងដែលកើតឡើងព្រោះរូបប៉ះពូបន់នឹងចក្ខុ ។

សោតធាតុ បានដល់ ធាតុ គឺត្រចៀក សទ្ទធាតុ បានដល់ ធាតុ គឺសំឡេង សោតវិញ្ញាណធាតុ បានដល់ ធាតុ គឺការដឹងដែល

កើតឡើងព្រោះសំឡេងប៉ះខ្ទប់នឹងត្រចៀក ។

ឃានធាតុ បានដល់ ធាតុ គឺច្រមុះ គន្ធធាតុ បានដល់ ធាតុ គឺក្លិន ឃានវិញ្ញាណធាតុ បានដល់ ធាតុ គឺការដឹង ដែលកើតឡើង ព្រោះក្លិនប៉ះខ្ទប់នឹងច្រមុះ ។

ជិវ្ហាធាតុ បានដល់ ធាតុ គឺអណ្តាត រសធាតុ បានដល់ ធាតុ គឺរស ជិវ្ហាវិញ្ញាណធាតុ បានដល់ ធាតុ គឺការដឹង ដែលកើតឡើង ព្រោះរូបប៉ះខ្ទប់អណ្តាត ។

កាយធាតុ បានដល់ ធាតុ គឺកាយ ផោដ្ឋព្វធាតុ បានដល់ ធាតុ គឺវត្ថុដែលត្រូវប៉ះខ្ទប់ដោយកាយ កាយវិញ្ញាណធាតុ បានដល់ ធាតុ គឺការដឹង ដែលកើតឡើងព្រោះផោដ្ឋព្វៈប៉ះខ្ទប់កាយ ។

មនោធាតុ បានដល់ ធាតុ គឺចិត្ត ធម្មធាតុ បានដល់ ធាតុ គឺ អារម្មណ៍ ដែលដឹងបានដោយចិត្ត មនោវិញ្ញាណធាតុ បានដល់ ធាតុ គឺការដឹង ដែលកើតឡើងព្រោះធម្មារម្មណ៍កើតជាមួយចិត្ត ។

នៃ គហបតី ការផ្សេងគ្នានៃធាតុ ព្រះសាស្តាបានត្រាស់ទុក

ដោយហេតុប៉ុណ្ណេះឯង ។ ចិត្តគហបតី បានសម្តែងការគ្រេកអរវីកវាយ ចំពោះធម្មកាសិតរបស់ព្រះឥសិទត្ត: ហើយថ្វាយអាហារដ៏ប្រណីត ដល់ព្រះថេរៈទាំងឡាយឲ្យឆ្អែតស្កប់ស្កល់ ។ លុះព្រះថេរៈទាំងឡាយ ឆាន់ស្រេចហើយ ទើបក្រោកឡើងចាកអាសនៈចម្រើនពរលាត្រឡប់ទៅ ចំណែកព្រះថេរៈជាប្រធានបានពោលសរសើរឥសិទត្តៈថា ល្អហើយ ឥសិទត្ត: បញ្ហានោះ លោកយល់ជាក់ច្បាស់ តែខ្ញុំយល់បានតិច អាវុសោ ឥសិទត្ត: តទៅបើបញ្ហាដូច្នេះកើតឡើងទៀត លោកជាអ្នកឆ្លើយ ។

រឿងដែលឥសិទត្ត: បានពោលឆ្លើយបញ្ហារបស់ចិត្តគហបតី មាននៅក្នុង ***ឥសិទត្តសូត្រទី ២*** ដែលចារឹកទុកក្នុងព្រះបាលី ***គម្ពីរសំយុត្តនិកាយ សឡាយតនវគ្គ*** ថា :-

គ្រាមួយ ភិក្ខុជាព្រះថេរៈច្រើនរូប នៅត្រង់អម្ពាដកវ័ន ក្នុងព្រៃ ***មច្ឆិកាសណ្ឌៈ*** ។ គ្រានោះ ចិត្តគហបតីបានទៅនិមន្តភិក្ខុទាំងនោះ ដើម្បីឲ្យទៅឆាន់ត្រង់ផ្ទះរបស់ខ្លួន ដូចដែលបានពោលហើយ កាលភិក្ខុទាំងឡាយទៅឆាន់កត្តាហាររបស់ចិត្តគហបតីស្រេចរៀបរយ ចិត្តគហបតី

ចូលទៅរកភិក្ខុទាំងឡាយ ថ្វាយបង្គំហើយ ទើបអង្គុយក្នុងទីដ៏សមគួរ បានសួរព្រះថេរៈជាប្រធានថា បពិត្រព្រះគុណជាម្ចាស់ដ៏ចម្រើន ទិដ្ឋិ គឺការឃើញផ្សេងៗ រមែងមាននៅក្នុងលោកនេះថា លោកទៀងខ្លះ មិនទៀងខ្លះ លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ជីវៈ (ជីវិត) និងសរីរៈ (កាយ) ដូចគ្នាខ្លះ មិនដូចគ្នាខ្លះ សត្វស្លាប់ហើយ កើតខ្លះ មិនកើតខ្លះ សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀត ក៏មានខ្លះ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ ដូច្នេះ ជាដើម ការឃើញទាំង ៦២ ប្រការនេះ (ដែលលោកហៅថា ទិដ្ឋិ ៦២ មានពោលនៅក្នុង **ព្រហ្មជាលសូត្រ**) បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន កាលអ្វីមាន ទិដ្ឋិ គឺការឃើញទាំងនេះ ទើបមាន កាលអ្វីមិនមាន ទិដ្ឋិ គឺការឃើញទាំងនេះ ទើបមិនមាន ។

ព្រះថេរៈអ្នកជាប្រធាន បានស្តាប់ពាក្យសួររបស់ចិត្តគហបតីហើយ គង់នៅស្ងៀមមិនព្រមឆ្លើយបញ្ហា សូម្បីចិត្តគហបតីបានសួរជាលើកទី ២ និងលើកទី ៣ ដោយពាក្យសួរដដែល ព្រះថេរៈអ្នកជាប្រធាន

ក៏គង់ស្ងៀម មិនព្រមឆ្លើយបញ្ហា ។ ក្នុងគ្រានោះ ព្រះឥសិទត្តៈដែលជាអ្នកថ្មីជាងភិក្ខុគ្រប់រូប ក្នុងក្រុមសង្ឃនោះ បានពោលសូមឱកាសចំពោះព្រះថេរៈដែលជាប្រធានថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំសូមអនុញ្ញាតឆ្លើយបញ្ហារបស់ចិត្តគហបតី ព្រះថេរៈដែលជាប្រធានពោលអនុញ្ញាតថា អាវុសោឥសិទត្តៈ លោកចូរឆ្លើយបញ្ហារបស់ចិត្តគហបតីចុះ ។ ទើបព្រះឥសិទត្តៈសួរថា នែគហបតី លោកសួរដល់ទិដ្ឋិ គឺការឃើញផ្សេងៗ ទាំងនេះថា កាលអ្វីមាន ទិដ្ឋិ គឺការឃើញទាំងនេះ ទើបមាន កាលអ្វីមិនមាន ទិដ្ឋិ គឺការឃើញទាំងនេះ ទើបមិនមាន នែគហបតី កាលសក្កាយទិដ្ឋិ គឺការឃើញជាហេតុប្រកាន់ថា កាយ ឬខ្លួន ជារបស់ខ្លួនមាន ទិដ្ឋិ គឺការឃើញទាំងនេះ ក៏មាន កាលសក្កាយទិដ្ឋិ គឺការឃើញជាហេតុប្រកាន់ថា កាយ ឬខ្លួន ជារបស់ខ្លួនមិនមាន ទិដ្ឋិ គឺការឃើញទាំងនេះ ក៏មិនមាន ។

ចិត្តគហបតីបានពិតសួរថា បពិត្រព្រះគុណជាម្ចាស់ដ៏ចម្រើន សក្កាយទិដ្ឋិ គឺការឃើញជាហេតុប្រកាន់ថា កាយ ឬខ្លួន ជារបស់ខ្លួន

កើតមានឡើងបានដូចម្តេច ? ព្រះឥសិទត្តៈឆ្លើយថា នែគហបតី បុថុជ្ជន គឺជនដែលមានកិលេសក្រាស់ក្នុងលោកនេះ អ្នកមិនបានស្តាប់ មិនបានឃើញព្រះអរិយៈ មិនឆ្លាតក្នុងធម៌របស់ព្រះអរិយៈ មិនបានទទួលពាក្យណែនាំក្នុងធម៌របស់ព្រះអរិយៈ មិនបានឃើញសប្បុរស (មនុស្សល្អមានសីលធម៌) មិនឆ្លាតក្នុងធម៌របស់សប្បុរស មិនបានទទួលពាក្យណែនាំក្នុងធម៌របស់សប្បុរស រមែងឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាតួខ្លួនខ្លះ រមែងឃើញតួខ្លួនថា មានរូប វេទនា សញ្ញា សង្ខារ វិញ្ញាណខ្លះ រមែងឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណនៅក្នុងតួខ្លួនខ្លះ រមែងឃើញតួខ្លួននៅក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណខ្លះ ។ នែគហបតី សក្កាយទិដ្ឋិ គឺការឃើញជាហេតុប្រកាន់ថា កាយ ឬខ្លួន ជារបស់ខ្លួន កើតមានឡើងបាន ដោយអាការយ៉ាងនេះ ចិត្តគហបតីបានសួរតទៅទៀតថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន សក្កាយទិដ្ឋិ គឺការឃើញជាហេតុប្រកាន់ថា កាយ ឬខ្លួន ជារបស់ខ្លួន មិនកើតមានឡើង ដោយអាការដូចម្តេច ?

ព្រះឥសិទត្តៈឆ្លើយថា នែគហបតី ព្រះអរិយសាវ័កក្នុងធម្មវិន័យនេះ អ្នកបានស្តាប់ហើយ បានឃើញព្រះអរិយៈ អ្នកឆ្លាតក្នុងធម៌របស់ព្រះអរិយៈ បានទទួលពាក្យណែនាំក្នុងធម៌របស់ព្រះអរិយៈ បានឃើញសប្បុរស ឆ្លាតក្នុងធម៌របស់សប្បុរស បានទទួលពាក្យណែនាំក្នុងធម៌របស់សប្បុរស រមែងមិនឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាតួខ្លួន រមែងមិនឃើញតួខ្លួនថា មានរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ រមែងមិនឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មាននៅក្នុងតួខ្លួន រមែងមិនឃើញតួខ្លួន មាននៅក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។

ម្នាលគហបតី សក្កាយទិដ្ឋិ គឺការឃើញជាហេតុប្រកាន់ថា កាយ ឬតួខ្លួន ជារបស់ខ្លួន រមែងមិនកើតឡើងដោយអាការយ៉ាងនេះ ។ ចិត្តគហបតីទូលសួរថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន លោកម្ចាស់ឥសិទត្តៈនិមន្តមកអំពីណា ? ព្រះឥសិទត្តៈឆ្លើយថា នែគហបតី អាត្មាមកអំពីអវន្តីជនបទ ។ ចិត្តគហបតីពិតបង្ហាញថា បពិត្រព្រះគុណម្ចាស់

ដ៏ចម្រើន មានកុលបុត្រម្នាក់ឈ្មោះ **ឥសិទត្តៈ** នៅក្នុង **អវន្តីជនបទ** ជាសម្ងាញ់ដែលមិនធ្លាប់ឃើញគ្នានឹងខ្ញុំព្រះករុណា បានបព្វជ្ជាហើយ ឥសិទត្តកុលបុត្រនោះ ព្រះគុណម្ចាស់ ធ្លាប់បានឃើញលោកដែរឬ ? ព្រះឥសិទត្តៈឆ្លើយថា ធ្លាប់បានឃើញគហបតី ។ ចិត្តគហបតីសួរថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ឥឡូវនេះ លោកម្ចាស់ឥសិទត្តៈរូបនោះ នៅទីណា ? កាលចិត្តគហបតីសួរយ៉ាងនេះ ព្រះឥសិទត្តៈនៅស្ងៀម ទើបចិត្តគហបតីសួរដោយយល់ថា ព្រះគុណម្ចាស់ជាឥសិទត្តៈសម្ងាញ់របស់ខ្ញុំព្រះករុណាឬ ? ព្រះឥសិទត្តៈឆ្លើយថា មែនហើយ គហបតី អាត្មាជាឥសិទត្តៈ សម្ងាញ់របស់គហបតី ។

ចិត្តគហបតីនិមន្តថាបពិត្រលោកម្ចាស់ឥសិទត្តៈ សូមលោកម្ចាស់ត្រេកអរនៅក្នុង **អម្ពាដកវ័ន** ដែលជាស្ថានទីគួរឲ្យរីករាយ ក្នុងព្រៃមច្ឆិកាសណ្ឌៈនេះចុះ ខ្ញុំព្រះករុណានឹងទំនុកបម្រុងលោកម្ចាស់ដោយចីវរ អាហារបិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជបរិក្ខារ ។ ព្រះឥសិទត្តៈពោលថា នែគហបតី ញោមពោលល្អហើយ ។ គ្រានោះ ចិត្តគហបតី

បានសម្តែងការរីករាយត្រេកអរ ចំពោះពាក្យរបស់ព្រះឥសិទត្តត្ថេរ ហើយថ្វាយអាហារបិណ្ឌបាត គួរធាន់ដ៏ប្រណីតដល់ភិក្ខុទាំងឡាយ ដោយដៃខ្លួនឯង រហូតដល់ឆ្អែតស្កប់ស្កល់ ។

គ្រាភិក្ខុទាំងឡាយ ឆាន់កត្តាហារស្រេច លាងដៃ លាងបាត្រ ហើយ ក៏លាត្រឡប់ទៅ ។ ក្នុងគ្រានោះ ព្រះថេរៈជាប្រធានបានពោលនឹងឥសិទត្តៈថា ល្អហើយ ឥសិទត្តៈ លោកអាចធ្វើយបញ្ហានេះបាន តែបញ្ហានេះខ្ញុំកុណាធ្វើយមិនបាន ព្រោះដូច្នោះ កាលមានបញ្ហាដូច្នេះ កើតឡើងទៀត ឥសិទត្តៈជួយធ្វើយផងចុះ ។ ព្រះឥសិទត្តៈ កាលជ្រាបការដែលធ្លាប់ជាសម្ងាញ់នឹងចិត្តគហបតីមកតាំងអំពីនៅជាគ្រហស្ថទើបពោលថា ឥឡូវនេះ ខ្ញុំព្រះករុណាមិនគប្បីស្នាក់នៅក្នុងទីនេះបាន ទើបរៀបសេនាសនៈ ហើយកាន់យកបាត្រ និងចីវរចេញទៅអំពីក្រុងមច្ឆិកាសណ្ឌៈ ដូចកិក្ខុរូបដទៃ ដែលបានចេញជំណើរទៅ ។

ប្រវត្តិការបំពេញសេចក្តីល្អរបស់ចិត្តគហបតី មានពោលក្នុង ***គម្ពីរចុល្លវគ្គ វិនយបិដក*** ក្នុង ***អដ្ឋកថាមនោរថបូរណី*** ក្នុង ***អដ្ឋកថា***

គម្ពីរបរមត្ថជោតិកា និងក្នុង **អដ្ឋកថាគម្ពីរធម្មបទ** នៃ **ពាលវគ្គ** រឿង ព្រះសុធម្មត្ថេរ ដូចមានសេចក្តីថា :-

ក្នុងថ្ងៃតមក ចិត្តគហបតី បានអារាធនាព្រះមហាកស្សបត្ថេរ សូមឲ្យលោកធ្វើបាដិហារ្យ (សម្តែងបានជាអស្ចារ្យ) ។ ព្រះមហាកស្សបត្ថេរ បានសម្តែងឥទ្ធិប្បាដិហារ្យដោយតេជោសមាបត្តិ (គឺការចូលឈានមានតេជោធាតុមកជាអារម្មណ៍) ឲ្យចិត្តគហបតីបានមើល ហើយព្រះថេរៈគិតថា យើងមិនគួរនៅក្នុងទីនេះ គ្រាន់តែគិតដូច្នេះហើយ ទើបចៀសចេញទៅកាន់ទីដទៃតាមសេចក្តីប្រាថ្នា ។ ម្យ៉ាងទៀត ការនិមន្តរបស់ចិត្តគហបតី មិនថានិងនិមន្តព្រះសង្ឃ គណៈ ឬបុគ្គលក្នុងវេលាណាមួយ បើមិនបានប្រាប់ព្រះសុធម្មត្ថេរមុនទេ ក៏នៅមិនទាន់និមន្ត ។ ក្នុងសម័យតមក ព្រះអគ្គសាវ័កទាំង ២ រូប បានស្តាប់ពាក្យដែលពោលពណ៌នាគុណរបស់ចិត្តគហបតី មានបំណងនឹងធ្វើការសង្គ្រោះដល់គហបតី ទើបព្រមដោយភិក្ខុ ១០០០ រូប ដែលមានព្រះថេរៈច្រើនរូបមកផង គឺ ព្រះសារីបុត្តត្ថេរ ព្រះមហាមោគ្គល្លានត្ថេរ ព្រះមហាកច្ចាយនត្ថេរ

ព្រះមហាកោដ្ឋិតត្ថេរ ព្រះមហាកប្បិនត្ថេរ ព្រះមហាចុន្ទត្ថេរ ព្រះអនុរុទ្ធត្ថេរ ព្រះរេវតត្ថេរ ព្រះឧបលិត្ថេរ ព្រះអានន្ទត្ថេរ និងព្រះរាហុលត្ថេរ បាននាំគ្នាទៅកាន់ដែនកាសី និងបានធ្វើដំណើរផ្លូវទៅដល់ក្រុងមច្ឆិកាសណ្ឌៈ ។

ចំណែកចិត្តគហបតី ជ្រាបដល់ការមករបស់ព្រះអគ្គសាវ័កទាំង ២ រូប ព្រមទាំងព្រះថេរៈទាំងនោះ ទើបចេញទៅទទួលក្នុងរវាងផ្លូវប្រមាណកន្លះយោជន៍ និងនាំព្រះអគ្គសាវ័កទាំងពីររូប ព្រមដោយព្រះភិក្ខុទាំងអស់មក ហើយនិមន្តឲ្យចូលទៅក្នុងវិហារ ដែលខ្លួនសាងថ្វាយធ្វើអាគន្តុកវត្ត (គឺធម្មទំនៀមដែលគួរបដិបត្តិដល់ភ្ញៀវដែលមកដល់) ដោយបានចាត់ចែងគ្រឿងសក្ការៈច្រើនថ្វាយដល់ព្រះអគ្គសាវ័ក និងព្រះភិក្ខុទាំងនោះ និងបានអារាធនាព្រះធម្មសេនាបតីសារីបុត្រថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ខ្ញុំប្រាថ្នានឹងស្តាប់ធម្មីកថាខ្លះ ។ ព្រះសារីបុត្រពោលថា ឧបាសក ពួកអាត្មានឿយហត់ តាំងអំពីការដើរផ្លូវឆ្ងាយ ចូរគហបតីស្តាប់ត្រឹមបន្តិចបន្តួចចុះ ថាហើយក៏បានពោលនូវធម្មីកថាឲ្យចិត្តគហបតីស្តាប់ ។

ចិត្តគហបតីកំពុងស្តាប់ធម្មីកថារបស់ព្រះថេរៈ ក៏បានសម្រេច **អនាគាមិផល** (ផល គឺការមិនត្រូវត្រឡប់មកកើតក្នុងមនុស្សលោកទៀត រាប់ជាព្រះអរិយបុគ្គលថ្នាក់ទី ៣ ក្នុងចំនួនទាំងអស់ ៤ ថ្នាក់) មូលហេតុដែលចិត្តគហបតីស្តាប់ធម្មីកថាមិនយូរឡើយ ហើយបានសម្រេចព្រះអនាគាមិផល ជាព្រះអនាគាមិបុគ្គល ទាំងនេះព្រោះចិត្តគហបតីបានពិចារណាឃើញសង្ខារ ដែលធ្លាប់បានបៀតបៀនមកហើយក្នុងជាតិមុន ។ គ្រាចិត្តគហបតីបានជាព្រះអនាគាមីហើយ បាននិមន្តព្រះថេរៈទាំងឡាយថា បពិត្រព្រះគុណម្ចាស់ទាំងឡាយដ៏ចម្រើន សូមព្រះគុណម្ចាស់ទាំងឡាយ ករុណាទទួលអាគន្តុកភត្ត (អាហារបិណ្ឌបាត្រដែលរៀបចំទុកសម្រាប់ភិក្ខុអ្នកត្រាច់មក) ត្រង់ផ្ទះរបស់ខ្ញុំព្រះករុណា ដើម្បីចម្រើនបុណ្យកុសលនិងបីតិ បាមោជ្ជ ក្នុងថ្ងៃស្អែកនេះចុះ ។ ចំណែកព្រះថេរៈទាំងឡាយ បានទទួលអាភធនាដោយអាការតុណ្ហីភាព ។ ចិត្តគហបតីជ្រាបថា ព្រះថេរៈទាំងឡាយទទួលនិមន្តហើយ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះថេរៈទាំងឡាយ ធ្វើប្រទក្សិណហើយ ចូលទៅរកព្រះសុធម្មត្ថេរ

ដល់ទីលំនៅរបស់លោក ថ្វាយបង្គំហើយ បាននិមន្តថា សូមព្រះគុណម្ចាស់សុធម្មទៅឆាន់កត្តាហារ ត្រង់ផ្ទះរបស់ខ្ញុំព្រះករុណាក្នុងថ្ងៃស្អែកនេះ ព្រមជាមួយព្រះថេរៈទាំងឡាយចុះ ។

គ្រានោះ ព្រះសុធម្មត្ថេរគិតតូចចិត្តថា កាលមុនចិត្តគហបតីនិមន្តព្រះសង្ឃ ឬគណៈ ឬនិមន្តភិក្ខុរូបណាមួយ កាលមិនទាន់បានប្រាប់យើងមុនទេ ក៏មិននិមន្ត ស្រាប់តែមកឥឡូវនេះ គហបតីមិនបានប្រាប់អញ តែបាននិមន្តព្រះថេរៈទាំងឡាយ ចិត្តគហបតីបំភ្លេចគុណនិងព្រងើយកន្តើយ មិនត្រេកអរចំពោះយើងសោះឡើយ ទើបពោលនឹងចិត្តគហបតីថា កុំឡើយគហបតី អាត្មាទទួលនិមន្តរបស់លោកមិនបានទេ ។ សូម្បីចិត្តគហបតីបាននិមន្តលោក ២ លើកទៀត ក៏លោកពោលបដិសេធមិនព្រមទទួលនិមន្ត ។ ចិត្តគហបតីគិតថា ព្រះគុណម្ចាស់សុធម្មនឹងទទួលនិមន្ត ឬមិនទទួលនិមន្ត ក៏នឹងធ្វើអ្វីដល់យើងមិនបាន ហើយគហបតីថ្វាយបង្គំព្រះសុធម្មត្ថេរ លាត្រឡប់ទៅ ។ លុះដល់ព្រឹកឡើង ចិត្តគហបតីឲ្យបុគ្គលទាំងឡាយចាត់ចែងអាហារ បង្អែម ចម្អាបដ៏ប្រណីត

ទុកសម្រាប់ព្រះថេរៈទាំង៦ព្រះអង្គ ខាងក្នុងផ្ទះរបស់គាត់ ។ក្នុងវេលាព្រឹក នៃថ្ងៃដែលគហបតីចាត់ចែងមហាទាន ព្រះសុធម្មត្ថេរគិតថា យើងនឹងទៅមើលអាហារ បង្អែម ចម្អាប ដែលចិត្តគហបតីត្រៀមទុក ដើម្បីព្រះថេរៈទាំង៦ព្រះអង្គ លុះវេលាព្រឹក លោកស្លៀកស្បង់ហើយ កាន់បាត្រ និងចីវរទៅត្រង់និវេសន៍របស់ចិត្តគហបតី ហើយអង្គុយលើអាសនៈដែលគេចាត់ចែងថ្វាយ ។

ចិត្តគហបតីបានចូលទៅរកព្រះសុធម្មត្ថេរ ថ្វាយបង្គំព្រះសុធម្ម ហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។ ព្រះសុធម្មត្ថេរ បានពោលនឹងចិត្តគហបតីថា នែ៎ចិត្តគហបតី ខាទនីយភោជនីយាហារ (អាហារគួរទំពាគួរបរិភោគ) ដែលលោកតាក់តែងទុកហើយមានច្រើនណាស់តែនៅខ្វះម្យ៉ាងប៉ុណ្ណោះ គឺនំលាយល្ង ។ទើបចិត្តគហបតីពោលថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន កាលព្រះពុទ្ធវចនៈ នៅមានច្រើន តែព្រះគុណម្ចាស់សុធម្មមកពោលថា នំលាយល្ងដែលជាពាក្យថយថោកបពិត្រព្រះគុណម្ចាស់ដ៏ចម្រើន រឿងធ្លាប់មានមកហើយ កាលមុនមាន

ពួកឈ្មួញអ្នកស្រុកទក្ខិណាបថបានទៅត្រង់ជនបទម្ខុំទិសខាងកើត ពួកឈ្មួញបាននាំមេមាន់អំពីស្ថានទីនោះមកចិញ្ចឹមទុក តមក មេមាន់នោះបានរួមសង្វាសនឹងក្អែកឈ្មោល និងបានកូនមួយក្បាល វេលាណាកូនមាន់នោះបំណងនឹងស្រែកដូចក្អែក វេលានោះ រមែងស្រែកសំឡេងក្អែក លាយលើសំឡេងមាន់ វេលាណាបំណងនឹងរងាវដូចមាន់ វេលានោះ រមែងរងាវសំឡេងមាន់ លាយលើសំឡេងក្អែក សេចក្តីនេះ យ៉ាងណា កាលព្រះពុទ្ធវចនៈ មាននៅច្រើន ព្រះគុណម្ចាស់សុធម្ម ត្រឡប់បែរមកពោលថា **នំ** លាយល្ង ដែលជាពាក្យថយថោក សេចក្តីនេះក៏ដូច្នោះ ។

ព្រះសុធម្មត្ថេរបានពោលថា នែ៎ គហបតី លោកបានជេរអាត្មាបានប្រទេចអាត្មា នែ៎ គហបតី នុ៎ះអាវាសរបស់លោក អាត្មានឹងចេញទៅអំពីអាវាសរបស់លោក ។ ទើបចិត្តគហបតីពោលថា បពិត្រព្រះគុណម្ចាស់ ខ្ញុំព្រះករុណា មិនបានជេរប្រទេចព្រះគុណម្ចាស់ទេ សូមព្រះគុណម្ចាស់សុធម្មនៅក្នុងវិហារអម្ពាដកវ័ន ដែលជាស្ថានទីមនោរមក្នុងក្រុងមច្ឆិកាសណ្ឌៈចុះ ខ្ញុំព្រះករុណានឹងខ្វល់ខ្វាយថ្វាយចីវរ អាហារ

សេនាសនៈ (ទីដេក ទីអង្គុយ) ថ្នាំរក្សារោគដល់ព្រះគុណម្ចាស់ ។ ព្រះសុធម្មត្ថេរមិនព្រមជឿស្តាប់ពាក្យរបស់ចិត្តគហបតី និងបានពោលប្រកែកគ្នាដល់ ៣ ដង ក៏មិនអាចចុះសម្រុងគ្នាបាន ។ ចិត្តគហបតីទើបសួរថា ព្រះគុណម្ចាស់សុធម្មនឹងទៅទីណា ? ព្រះសុធម្មត្ថេរឆ្លើយតបថា នែគហបតី អាត្មានឹងទៅក្រុងសាវត្ថី ដើម្បីចូលគាល់ព្រះមានព្រះភាគ ។

ទើបចិត្តគហបតី ពោលថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមព្រះគុណម្ចាស់ក្រាបទូលពាក្យទាំងអស់ ដែលព្រះគុណម្ចាស់ និងខ្ញុំព្រះករុណាបានពោលដល់ព្រះមានព្រះភាគផងចុះ តែព្រះគុណម្ចាស់សុធម្ម នឹងត្រូវត្រឡប់មកក្រុងមច្ឆិកាសណ្ឌៈទៀត វាប់ជារឿងដែលមិនគួរអស្ចារ្យឡើយ ។ គ្រានោះ ព្រះសុធម្មត្ថេរ រៀបចំសេនាសនៈហើយ កាន់យកបាត្រ និងចីវរ ចេញដំណើរទៅកាន់ក្រុងសាវត្ថី កាលលោកទៅដល់ក្រុងសាវត្ថីហើយ បានចូលទៅគាល់ព្រះមានព្រះភាគ ដែលប្រថាប់នៅត្រង់ជេតពនមហាវិហារ និង

ក្រាបទូលពាក្យទាំងពួងដែលខ្លួន និងចិត្តគហបតីតមាត់គ្នា ឲ្យព្រះមានព្រះភាគ ទ្រង់ជ្រាបគ្រប់ប្រការ ។ ព្រះមានព្រះភាគ ទ្រង់តិះដៀលព្រះសុធម្មត្ថេរថា ម្នាលមោឃបុរស ការធ្វើរបស់អ្នកមិនសមរម្យ មិនគួរដល់សមណៈ ប្រើមិនកើត ចិត្តគហបតីជាអ្នកមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការកៈ (អ្នកធ្វើរបស់ដែលសមគួរដល់សមណៈ) អ្នកទំនុកបម្រុងសង្ឃ ម្តេចបានជាអ្នកនិយាយមើលងាយ និយាយសង្កត់សង្កិន ដោយពាក្យដែលថោកទាប ការធ្វើរបស់អ្នកមិនប្រព្រឹត្តទៅដើម្បីការជ្រះថ្លារបស់ប្រជុំជន ដែលនៅមិនទាន់ជ្រះថ្លា ឬដើម្បីការជ្រះថ្លាដ៏ក្រៃលែងរបស់ប្រជុំជនដែលជ្រះថ្លាហើយ រួចហើយព្រះអង្គត្រាស់បង្គាប់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សង្ឃគួរធ្វើបដិសារាណីយកម្ម គឺកម្មដែលឲ្យរឭកដល់កំហុស (សំដៅដល់ការដែលសង្ឃដាក់ទោសឲ្យភិក្ខុទៅសុំខមាទោសគ្រហស្ថ កម្មនេះសង្ឃធ្វើភិក្ខុមាត់រឹង) ដល់ព្រះសុធម្មត្ថេរ គឺឲ្យលោកសុំខមាទោសចំពោះចិត្តគហបតី ដោយសង្ឃត្រូវធ្វើយ៉ាងនេះ ត្រូវចោទព្រះសុធម្មត្ថេរ

មុនសិន រួចហើយ ត្រូវឲ្យលោករឭកដល់កំហុស និងកាលឲ្យរឭក ដល់កំហុសហើយ គប្បីពិនិត្យអាបត្តិ ពេលពិនិត្យអាបត្តិហើយ ត្រូវឲ្យកិក្ខុអ្នកធ្លាត អ្នកអង់អាច គប្បីប្រកាសឲ្យសង្ឃជ្រាបដោយ ញត្តិចតុត្ថកម្មវាចាថា

បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ពាក្យខ្ញុំ កិក្ខុសុធម្មនេះ បាននិយាយសង្កត់សង្កិនមើលងាយចិត្តគហបតី អ្នកមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការកៈ ជាអ្នកទំនុកបម្រុងសង្ឃ ដោយពាក្យ ថោកទាប បើសង្ឃព្រមព្រៀងគ្នាហើយ សង្ឃត្រូវធ្វើបដិសារណីយកម្ម ដល់កិក្ខុសុធម្មនេះ គឺឲ្យសុំទោសដល់ចិត្តគហបតី នេះជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ពាក្យខ្ញុំ កិក្ខុសុធម្មនេះ បាននិយាយសង្កត់សង្កិនមើលងាយចិត្តគហបតី អ្នកមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការកៈ ជាអ្នកទំនុកបម្រុងសង្ឃ ដោយពាក្យ ដ៏ថោកទាប សង្ឃកំពុងធ្វើបដិសារណីយកម្មដល់កិក្ខុសុធម្ម គឺឲ្យ លោកសុំទោសចិត្តគហបតី ការធ្វើបដិសារណីយកម្មដល់កិក្ខុសុធម្ម

គឺឲ្យលោកសុំទោសចិត្តគហបតី លោកម្ចាស់អង្គណាឃើញសមគួរ សូមឲ្យលោកម្ចាស់អង្គនោះ អង្គុយស្បៃម លោកម្ចាស់អង្គណា ឃើញមិនសមគួរ សូមលោកម្ចាស់អង្គនោះ និយាយឡើងដោយឲ្យពោលដូច្នេះ ៣ ដង ហើយឲ្យពោលដូច្នេះ ៣ ដង រួចឲ្យថាសង្ឃបានធ្វើបដិសារាណីយកម្មដល់ព្រះសុធម្ម គឺឲ្យលោកសុំទោសចិត្តគហបតីហើយ សង្ឃក៏ឃើញប្រពៃហើយ ទើបសង្ឃអង្គុយស្បៃមខ្ញុំនឹងចាំទុករឿងនេះដោយអាការយ៉ាងនេះ ។

កាលសង្ឃបានធ្វើបដិសារាណីយកម្មដល់ព្រះសុធម្ម គឺឲ្យលោកសុំទោសចិត្តគហបតីហើយ ព្រះសុធម្មត្ថេរអ្នកដែលត្រូវសង្ឃ ធ្វើបដិសារាណីយកម្ម បានទៅក្រុងមច្ឆិកាសណ្ឌៈ និងបានពោលជាមួយចិត្តគហបតីថា លោកគហបតី ទោសនោះជារបស់អាត្មាប៉ុណ្ណោះ លោកចូរអត់ទោសដល់អាត្មាចុះ ។ ចិត្តគហបតីពោលបដិសេធថា ព្រះគុណម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមិនព្រមអត់ទោសឲ្យព្រះគុណម្ចាស់ទេ ។ ព្រះសុធម្មត្ថេរ បានស្តាប់ពាក្យបដិសេធហើយ កើតអាការ

អៀនអន់ មិនអាចធ្វើឲ្យចិត្តគហបតីឲ្យអត់ទោសបាន ទើបត្រឡប់មកកាន់ក្រុងសាវត្ថីវិញ ។

កិកុទាំងឡាយ សួរព្រះសុធម្មត្ថេរថា លោកម្ចាស់សុធម្ម លោកសុំទោសចិត្តគហបតីហើយឬ ? ព្រះសុធម្មត្ថេរតបថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន ខ្ញុំបានទៅក្រុងមច្ឆិកាសណ្ឌៈហើយតែត្រូវជាអ្នកអៀនអន់ ព្រោះមិនអាចសុំទោសចិត្តគហបតីបាន ។ ទើបកិកុទាំងនោះនាំរឿងនោះ ក្រាបទូលព្រះមានព្រះភាគជាម្ចាស់ឲ្យទ្រង់ជ្រាប ។ សេចក្តីពិតរឿងនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាបហើយថា ចិត្តគហបតីនឹងមិនអត់ទោសឲ្យព្រះសុធម្មត្ថេរ តែទ្រង់ព្រះតម្រិះថា កិកុនេះមានការរីងភ្នឹងព្រោះមានៈ គឺការប្រកាន់ខ្លួន ចូលទៅអស់រយៈផ្លូវ ៣០ យោជន៍ ហើយត្រឡប់មក ទើបទ្រង់បញ្ជូនទៅដោយមិនទ្រង់ប្រាប់ឧបាយដែលនឹងធ្វើឲ្យចិត្តគហបតីអត់ទោសឲ្យ ។ លុះក្នុងពេលដែលព្រះសុធម្មត្ថេរបានទៅអស់រយៈផ្លូវ ៣០ យោជន៍និងខុសបំណងត្រឡប់មកហើយ ព្រះមានព្រះភាគប្រទានកិកុអនុទូត

ដល់ព្រះសុធម្មត្ថេរ អ្នកនាំមាននេះ គឺការប្រកាន់ខ្លួនចេញហើយ ដោយ
ត្រាស់ថា អ្នកចូរទៅជាមួយភិក្ខុនេះចុះ ចូរឲ្យចិត្តគហបតីអត់ទោស
និងទ្រង់ទូន្មានថា ធម្មតាសមណៈមិនគួរធ្វើមាននេះ ឬការប្រណែនថា
វិហាររបស់អញ លំនៅរបស់អញ ឧបាសក ឧបាសិការបស់អញ
ព្រោះកាលសមណៈធ្វើយ៉ាងនេះ កិលេសទាំងឡាយ មានឫស្យា
និងមាននៅជាដើម រមែងចម្រើន ។

កាលព្រះពុទ្ធអង្គទ្រង់បន្ទូរអនុសន្ធិ ដើម្បីសម្តែងធម៌តទៅ
ទើបត្រាស់ព្រះគាថា ដែលមានសម្តែងប្រាកដនៅក្នុងព្រះបាលី ***គម្ពីរ***
ខុទ្ទកនិកាយ គាថាធម្មបទ *ដូចមានសេចក្តីថា ៖*

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន
(ក្នុងខ្លួន) ផង នូវការធ្វើក្នុងទាងមុខ គឺជាប្រមុខ ក្នុងពួកភិក្ខុផង
នូវភាពជាឥស្សរៈ ក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ
ក្នុងត្រកូលនៃជនទាំងឡាយដទៃផង ភិក្ខុពាល តែងមានសេចក្តី
ត្រិះរិះថា គ្រហស្ថ និងបព្វជិត ទាំង ២ ពួក ចូរសម្គាល់នូវកិច្ច

ដែលមនុស្សដទៃធ្វើហើយថា ជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែង របស់អញ ចូរមានក្នុងកិច្ចតូច-ធំណាៗ មួយ (កាលបើយ៉ាងនេះ) ឫស្សា និងមានៈ រមែងចម្រើន ។

អដ្ឋកថាចារ្យ *បានអធិប្បាយសេចក្តីនៃព្រះគាថាទាំងនេះថា*

កិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន គឺ កិក្ខុពាល មិនមានសទ្ធា ជាអ្នកទ្រុស្តសីល ស្តាប់បានតិច មិនមានសេចក្តីស្ងប់ស្ងាត់ ខ្ជិលច្រអូស មានសតិមិនតាំងមាំ មានចិត្តមិនមាំមួន មានបញ្ញាថោកថយ មិនមែនជាព្រះខីណាស្រព រមែងប្រាថ្នាការសរសើរដែលមិនមាននេះថា ធ្វើដូចម្តេចហ្ន៎ បុគ្គលគប្បីដឹងអញថា កិក្ខុនេះមានសទ្ធា មានសីល ជាពហុសូត ជាអ្នកស្ងប់ស្ងាត់ មានការព្យាយាម មានសតិតាំងមាំ មានចិត្តមាំមួន មានបញ្ញាល្អ ជាព្រះខីណាស្រព តាមន័យដែលពោលទុកក្នុង ***ចាបិច្ឆតានិទ្ទេស*** *ថា កិក្ខុពាល រមែងត្រូវការសេចក្តីសរសើរដែលមិនមាន ដូចអ្នកមិនមានសទ្ធា រមែងត្រូវការថា សូមឲ្យមនុស្សដឹងថា អញមានសទ្ធា ដូច្នេះ។*

ចំណែកភិក្ខុពាល ចំណង់នឹងឲ្យភិក្ខុទាំងឡាយហែហមខ្លួន គឺត្រូវការឲ្យភិក្ខុក្នុងវិហារទាំងអស់គប្បីចោមរោមអញជើម្បីសួរបញ្ហាផ្សេងៗ យ៉ាងនេះ ឈ្មោះថា ប្រាថ្នាការហែហមក្នុងភិក្ខុទាំងឡាយ ។ ការប្រាថ្នាភាពជាធំក្នុងអាវាស សំដៅដល់ភិក្ខុពាល ចាត់សេនាសន: ដ៏ប្រណីតកណ្តាលវិហារ សម្រាប់ភិក្ខុជាមិត្រ ជាសម្ងាញ់របស់ខ្លួន ឲ្យនៅក្នុងសេនាសន:ដែលល្អ និងចាត់សេនាសន: ដែលមិនល្អ និងសេនាសន:ដែលមានអមនុស្សហួងហែង ដែលស្ថិតនៅខាងចុងបំផុតជើម្បីភិក្ខុអាគន្តុក: គឺភិក្ខុដែលជាភ្ញៀវគ្រាច់មក ។ ភិក្ខុពាលមិនប្រាថ្នាការបូជាដោយបច្ច័យ ៤ ក្នុងត្រកូល មាតាបិតា និងពួកញាតិឡើយ តែប្រាថ្នាក្នុងត្រកូលនៃបុគ្គលដទៃប៉ុណ្ណោះថា សូមឲ្យបុគ្គលទាំងនេះគប្បីថ្វាយដល់អញតែម្នាក់ មិនគប្បីថ្វាយដល់ពួកភិក្ខុដទៃ ។

ការត្រិះរិះដែលកើតឡើងដល់ភិក្ខុពាលថា ពួកគ្រហស្ថ និងបព្វជិត ចូរសម្គាល់កិច្ចដែលធ្វើស្រេចហើយ ព្រោះអាស្រ័យអញតែម្នាក់ ដោយបំណងថា **នវកម្ម** (គឺការកសាង) យ៉ាងណាមួយ

ដែលគេធ្វើហើយក្នុងវិហារ ដោយអំណាចនៃនវកម្ម គឺការកសាង មានវេងឧបោសថជាដើម នវកម្មនោះទាំងអស់ គឺព្រះថេរៈរបស់ពួកយើងធ្វើហើយ ។ កិកូពាលរមែងមានសេចក្តីត្រិះរិះថា គ្រហស្ថ និងបព្វជិតទាំងអស់ ចូរប្រព្រឹត្តទៅក្នុងអំណាចរបស់យើងតែម្នាក់ ពាហនៈ និងគ្រឿងឧបករណ៍ទាំងឡាយ ដូចជារទេះ គោ កាំបិត ពូថៅ ឬដោយហោចទៅ កិច្ចទាំងឡាយជាដើមថា សូម្បីត្រឹមតែការកម្តៅបបរ ហើយហុត ដែលគ្រហស្ថ និងបព្វជិតគប្បីបានក៏ដោយ តែបណ្តាករណីយកិច្ចទាំងតូចទាំងធំ គ្រហស្ថ និងបព្វជិតចូរប្រព្រឹត្តទៅក្នុងអំណាចរបស់អញប៉ុណ្ណោះ និងសូម្បីក្នុងកិច្ចត្រឹមតែមួយ ក៏ចូរសួរអញប៉ុណ្ណោះហើយ ទើបធ្វើ ។

ការជ្រាជ្ញា និងត្រិះរិះផ្សេងៗ ទាំងនេះ រមែងកើតឡើងដល់កិកូពាលរូបណា វិបស្សនា មគ្គ និងផល រមែងមិនចម្រើនដល់កិកូពាលរូបនោះ តែតណ្ហា (គឺការស្មោកចង់បាន) ដែលកើតក្នុងទ្វារទាំង ៦ និងមានៈ ៩ យ៉ាង រមែងចម្រើនឡើងដល់កិកូពាលតែម្យ៉ាង

ដូចទឹកចម្រើនឡើងដល់ទន្លេក្នុងវេលាព្រះចន្ទរះដូច្នោះ ។ ក្នុងវេលាដែលព្រះមានព្រះភាគ ទ្រង់សម្តែងធម្មទេសនាចប់ ជនច្រើននាក់បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចំណែកព្រះសុធម្មត្ថេរ បានស្តាប់ព្រះពុទ្ធាវាទនេះហើយ ថ្វាយបង្គំព្រះមានព្រះភាគ និងក្រោកចាកអាសនៈ ធ្វើប្រទក្សិណហើយ បានទៅជាមួយភិក្ខុអនុទូតនោះ ដោយសម្តែងអាបត្តិឲ្យចិត្តគហបតីបានឃើញ ហើយឲ្យគហបតីអត់ទោស ។ ចិត្តគហបតីបានអត់ទោសឲ្យព្រះសុធម្មត្ថេរថា ខ្ញុំព្រះករុណាអត់ទោស ឲ្យព្រះគុណម្ចាស់ បើទោសរបស់ខ្ញុំព្រះករុណាមាន សូមព្រះគុណម្ចាស់អត់ទោសឲ្យខ្ញុំព្រះករុណាផងចុះ ។ លុះព្រះសុធម្មត្ថេរបានទទួលការអត់ទោសអំពីចិត្តគហបតីហើយ បានទៅក្នុងអម្ពាដការាមប្រព្រឹត្តល្អអស់ការក្រអឺតក្រអោង កែខ្លួនបាន និងតាំងនៅក្នុងព្រះឱវាទ គឺពាក្យទូន្មានដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ទូន្មានហើយ ដោយលោកបានធ្វើវិបស្សនាឲ្យចម្រើនឡើងដោយលំដាប់ ខាងក្នុងវេលា

២-៣ ថ្ងៃប៉ុណ្ណោះ លោកក៏បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា (ប្រាជ្ញាដែលបែកធ្លាយ ៤ យ៉ាង) ។

ចំណែកចិត្តគហបតីគិតថា យើងនៅមិនទាន់បានគាល់ព្រះមុនីឡើយ ក្រោយអំពីបានសម្រេចសោតាបត្តិផល និងអនាគាមិផលហើយ យើងគួរទៅគាល់ព្រះមានព្រះភាគ តែយើងមិនគួរទៅដៃទទេ កាលគហបតីគិតដូច្នេះហើយ ទើបឲ្យនាំវត្ថុផ្សេងៗ មានល្ង អង្ករ ប្រេង ទឹកឃ្មុំ ទឹកអំពៅ និងសំពត់ដណ្តប់ជាដើម ជាក់ផ្ទុកពេញ ៥០០ រទេះ ហើយឲ្យពិតភិក្ខុទាំងឡាយថា ព្រះគុណម្ចាស់ទាំងឡាយ មានបំណងនឹងទៅគាល់ព្រះមានព្រះភាគ ក៏សូមនិមន្តទៅ នឹងមិនលំបាកដោយអាហារជាដើម ឲ្យពិតភិក្ខុនីទាំងឡាយ ប្រាប់ពួកឧបាសក ឧបាសិកាបានជ្រាបទាំងអស់គ្នា ។ភិក្ខុប្រមាណ ៥០០ រូប ភិក្ខុនីប្រមាណ ៥០០ រូប ឧបាសកប្រមាណ ៥០០ នាក់ ឧបាសិកាប្រមាណ ៥០០ នាក់ បានរួមដំណើរទៅជាមួយចិត្តគហបតី ដើម្បីចូលទៅគាល់ព្រះសម្មុទ្ធនាក្រុងសាវត្ថី ។ចិត្តគហបតីត្រៀមស្បៀងគ្រប់គ្រាន់ហើយ មិនមាន

ការខ្វះខាតដោយបបរ និងបាយជាដើម សូម្បីត្រឹមតែបន្តិចឡើយ ទាក់ទងនឹងការដើរផ្លូវអស់រយៈ ៣០ យោជន៍ ដើម្បីពួកជន ៣ ពាន់នាក់ ដែលមានភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា និងបរិវារបស់ខ្លួន ។ ចំណែកទេវតាទាំងឡាយជ្រាបថា ចិត្តគហបតីចេញដំណើរទៅគាល់ព្រះមានព្រះភាគ ទើបបានសាងទីស្នាក់រាយតាមផ្លូវគ្រប់ៗ មួយយោជន៍ ចាត់គ្រឿងបណ្ណាការទំនុកបម្រុងមហាជនទាំងនោះ ដោយអាហារផ្សេងៗ មានបបរ បាយរបស់គួរទំពា និងទឹកផឹកជាដើមដែលជារបស់ទិព្វ និងការខ្វះខាតវត្ថុទាំងឡាយ ដែលនរណាៗមិនបានទទួលមិនមានឡើយ ។

មហាជន និងទេវតាទាំងឡាយ ទំនុកបម្រុងយ៉ាងនេះរាល់ថ្ងៃ ទាំងការដើរផ្លូវទៅបានមួយថ្ងៃមួយយោជន៍ៗ វេលាមួយខែ ទើបទៅដល់ក្រុងសាវត្ថី ។ មានវត្ថុអស្ចារ្យប្រាកដឡើងមកយ៉ាងគួរឆ្ងល់ គឺ រទេះ ៥០០ នៅតែពេញបរិបូណ៌ដោយវត្ថុផ្សេងៗ ដែលផុកមកជូចដើម ។ គហបតីបានលះបង់គ្រឿងបណ្ណាការ ដែលពួកទេវតា និងមនុស្សទាំងឡាយនាំមកទាំងអស់ ។ ព្រះមានព្រះភាគត្រាស់នឹងព្រះ

អានន្ទត្ថេរថា ម្នាលអានន្ទ ក្នុងវេលារសៀលថ្ងៃនេះ ចិត្តគហបតីមានឧបាសក ៥០០ នាក់ហែហម នឹងមកថ្វាយបង្គំតថាគត ។ ព្រះអានន្ទត្ថេរក្រាបទូលសួរថា បពិត្រព្រះមានព្រះភាគ ក្នុងវេលាដែលចិត្តគហបតីថ្វាយបង្គំព្រះអង្គ នឹងមានបាដិហារ្យអ្វីៗ កើតឡើងឬទេ ព្រះអង្គ ? ព្រះមានព្រះភាគជាម្ចាស់ត្រាស់តបថា ម្នាលអានន្ទ នឹងមានបាដិហារ្យកើតឡើង ។ ព្រះអានន្ទត្ថេរ ក្រាបទូលសួរថា នឹងកើតបាដិហារ្យអ្វីឡើង ព្រះអង្គ ? ព្រះមានព្រះភាគត្រាស់បញ្ជាក់ថា ម្នាលអានន្ទ នៅពេលដែលចិត្តគហបតីមកថ្វាយបង្គំតថាគត ភ្លៀងព្រិលដែលជាផ្កាឈើទិព្វ ៥ ពណ៌ នឹងធ្លាក់ចុះមកជាជួរ កម្ពស់អំពីផែនដីប្រមាណត្រឹមជង្គង់ ក្នុងបរិវេណប្រមាណ ៨ កវីស (១ កវីស = ១២៥ ហត្ថ) ដោយវិធីរាប់របស់ស្តេច (សម័យបុរាណ) ។

អ្នកក្រុងបានឮដំណឹងនេះហើយ បង្ហូកប្រកាសប្រាប់គ្នាថា អ្នកមានបុណ្យច្រើន នឹងមកថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់ថ្ងៃនេះឮថា បាដិហារ្យដែលគួរអស្ចារ្យនឹងមានឡើង ពួកយើងនឹងបានឃើញ

អ្នកមានបុណ្យច្រើន ហើយបានយកគ្រឿងបណ្ណាការ ទៅឈរនៅសងខាងផ្លូវ ។ក្នុងកាលដែលចិត្តគហបតីមកជិតវិហារ មានភិក្ខុ ៥០០ រូបមកដល់មុន ។ចិត្តគហបតីពោលនឹងពួកឧបាសិកាថា បពិត្រអ្នកម៉ែទាំងឡាយ សូមពួកអ្នកម៉ែមកខាងក្រោយ ចំណែកគហបតីខ្លួនឯងផ្ទាល់មានឧបាសក ៥០០ នាក់ចោមរោម បានទៅកាន់សម្នាក់របស់ព្រះមានព្រះភាគជាម្ចាស់ ។

បុគ្គលទាំងឡាយ ដែលឈរ ឬអង្គុយក៏ដោយក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគជាម្ចាស់មិនមាន ព្រោះតែក្នុងទីខាងណោះ ឬខាងណោះត្រឹមតែម្ខាង តែបាននៅឈរយ៉ាងកកកុញទាំងសងខាងពុទ្ធវិថី (ផ្លូវរបស់ព្រះពុទ្ធ) ។ ចិត្តគហបតីឈានចុះកាន់ពុទ្ធវិថីជំហើយ និងស្ថានទីដែលគហបតីជាព្រះអនាគាមីសម្លឹងមើលហើយបានកើតអាការញាប់ញ័រឡើង ។ មហាជនសម្លឹងមើលចិត្តគហបតីដោយគិតថា ឮថា គាត់នោះ គឺលោកចិត្តគហបតី ។ ចំណែកចិត្តគហបតីចូលទៅគាល់ព្រះមានព្រះភាគជាម្ចាស់ ដោយចូលទៅ

ខាងក្នុងពុទ្ធរស្មីដែលមានពណ៌ ៦ ប្រការ ដែលហៅថា ឆព្វណ្ណរង្សី ដោយបានចាប់-កព្រះបាទទាំងពីរបស់ព្រះមានព្រះភាគថ្វាយបង្គំ ។ ក្នុងខណៈនោះ ភ្លៀងផ្កាឈើ ៥ ពណ៌ធ្លាក់ចុះមកអំពីអាកាសភ្លាម និងសាធុការ គឺការបញ្ចេញវាចាថា **សាធុ** ប្រែថា ប្រពៃហើយ (ដើម្បីសម្តែងការស្ងើចសរសើរ) ចំនួន ១ ពាន់លានឮខ្ទាំងក្នុងសមាគមនោះ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ប្រោស ដោយទ្រង់ចែកអាយតនៈ ៦ ប្រការឲ្យបរិស័ទទាំងនោះ ដែលមានចិត្តគហបតីជាប្រធានស្តាប់ ដើម្បីឲ្យត្រូវនឹងអធ្យាស្រ័យរបស់បុគ្គលទាំងនោះ ។ ចិត្តគហបតី បានស្នាក់នៅក្នុងសម្នាក់របស់ព្រះមានព្រះភាគជាម្ចាស់អស់មួយខែ (តែអដ្ឋកថាគម្ពីរមនោរថបូរណីថា កន្លះខែ) បាននិមន្តព្រះសង្ឃទាំងអស់ ដែលមានព្រះមានព្រះភាគជាប្រធានឲ្យគង់ក្នុងវិហារនោះឯង ហើយថ្វាយមហាទាន និងនិមន្តភិក្ខុ ៥០០ រូប ដែលរួមដំណើរមកផងឲ្យនៅខាងក្នុងវិហារនោះ ហើយទំនុកបម្រុង

ដូចគ្នា ។ រាល់ថ្ងៃ ដែលចិត្តគហបតីចាត់ចែងការថ្វាយមហាទាន ដោយមិនបានយកវត្ថុអ្វីៗ ក្នុងរនេះរបស់ខ្លួនចេញមកប្រើឡើយ ។ ហេតុទាំងនេះ ចិត្តគហបតីបានធ្វើកិច្ចគ្រប់យ៉ាង ដោយប្រើគ្រឿងបណ្ណាការ ដែលទេវតា និងមនុស្សទាំងឡាយ នាំមកឲ្យប៉ុណ្ណោះ និងក្រៅអំពីនេះ អ្នកក្រុងរាជគ្រឹះនៅបញ្ជូនមកបន្ថែមឡើងទៀត ។

ចិត្តគហបតីថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់ហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកដោយតាំងចិត្តថា នឹងថ្វាយទានដល់ព្រះអង្គ បានស្នាក់នៅក្នុងរវាងផ្លូវមួយខែ និងមួយខែទៀត ខ្ញុំព្រះអង្គស្នាក់នៅក្នុងទីនេះក៏បានកន្លងផុតទៅហើយ ខ្ញុំព្រះអង្គនៅមិនទាន់បានឱកាស ដើម្បីនឹងកាន់យកវត្ថុអ្វីៗ ដែលខ្ញុំព្រះអង្គនាំមកឡើយ ខ្ញុំព្រះអង្គបានថ្វាយទានអស់កាលយូរប៉ុណ្ណោះ ដោយគ្រឿងបណ្ណាការដែលទេវតា និងមនុស្សទាំងឡាយ នាំមកឲ្យទាំងអស់ ទោះបីខ្ញុំព្រះអង្គស្នាក់នៅក្នុងទីនេះវេលាមួយឆ្នាំ ក៏គង់មិនបានថ្វាយទេយ្យធម៌របស់ខ្ញុំព្រះអង្គជាពិតប្រាកដ ខ្ញុំព្រះអង្គប្រាថ្នានឹងផ្ទេរ

រនេះហើយត្រឡប់ទៅ សូមព្រះមានព្រះភាគជាម្ចាស់ប្រោសត្រាស់ប្រាប់ស្ថានទីសម្រាប់ជាក់របស់ដល់ខ្ញុំព្រះអង្គចុះ ។

ព្រះមានជោគត្រាស់ទីឆ៍ព្រះអានន្ទត្ថេរថា ម្នាលអានន្ទ អ្នកចូរចាត់ចែងស្ថានទីទំនេរមួយកន្លែង ដើម្បីឲ្យដល់ចិត្តគហបតីឧបាសក ។ ព្រះអានន្ទត្ថេរបានធ្វើតាមពុទ្ធប្បញ្ជា ។ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតកប្បិយភូមិ គឺទីទុករបស់សង្ឃ សម្រាប់ធ្វើអាហាររបស់សង្ឃឲ្យដល់ចិត្តគហបតី។ បាននាំវត្ថុផ្សេងៗ ចេញអំពីរនេះទាំងអស់ ដើម្បីថ្វាយដល់ភិក្ខុសង្ឃ ។ ក្រោយអំពីចិត្តគហបតីឧបាសកចាត់ចែងថ្វាយរបស់ដែលមានក្នុងរនេះអស់ហើយ គាត់ ព្រមទាំង៣ ពាន់នាក់ ដែលរួមដំណើរមកជាមួយគាត់ ក៏ធ្វើដំណើរដោយរនេះទេ ។ ទេវតានិងមនុស្សទាំងឡាយក្រោកឡើងហើយ ពោលថា លោកដ៏ចម្រើន លោកបានដើរផ្លូវត្រឡប់ទៅវិញ ដោយរនេះទេហើយទើបផុតរតន: ៧ ប្រការ ពេញរនេះនោះទាំងអស់ ។

ចំណែកចិត្តគហបតី បានចិញ្ចឹមមហាជន ទៅដោយគ្រឿងបណ្ណាការដែលទេវតា និងមនុស្សនាំមកឲ្យដល់ខ្លួន ។ ព្រះអានន្ទថ្វាយបង្គំព្រះមានព្រះភាគហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចិត្តគហបតីកាលមកកាន់សម្នាក់ព្រះអង្គ ដោយការដើរផ្លូវមកវេលាមួយខែ និងស្នាក់នៅក្នុងទីនេះក៏មួយខែដូចគ្នា បានថ្វាយទាន ដោយគ្រឿងបណ្ណាការដែលទេវតា និងមនុស្សទាំងឡាយ នាំមកប៉ុណ្ណោះអស់កាលយូរប៉ុណ្ណោះ និងបានឮថា ឥឡូវនេះ គហបតីបានឲ្យនាំរបស់ចេញអំពីរនេះ ៥០០ រហូតដល់អស់ ដោយធ្វើដំណើរត្រឡប់ទៅវេលាមួយខែដូចគ្នា តែមានទេវតា និងមនុស្សទាំងឡាយក្រោកឡើងហើយ ពោលថា លោកដ៏ចម្រើន បានធ្វើដំណើរត្រឡប់ទៅដោយរនេះទេ ហើយផ្ទុកវគេន: ៧ ប្រការ ក្នុងរនេះពេញទាំងអស់ ចំណែកចិត្តគហបតីទំនុកបម្រុងមហាជន ដោយគ្រឿងបណ្ណាការ ដែលទេវតា និងមនុស្សទាំងឡាយនាំមកដើម្បីខ្លួនឯង ហើយត្រឡប់ទៅ បពិត្រព្រះមានព្រះភាគ គ្រឿងសក្ការៈនេះកើតឡើងដល់គហបតី អ្នកមក

កាន់សម្នាក់វបស់ព្រះមានជោគប៉ុណ្ណោះឬ ឬថា គហបតីទៅក្នុងទីដទៃ ក៏កើតឡើងដូចគ្នា ព្រះអង្គ ?

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ម្នាលអានន្ទ ចិត្តគហបតីមកកាន់សម្នាក់តថាគតក្តី ឬទៅក្នុងទីដទៃក៏ដោយ គ្រឿងសក្ការៈរមែងកើតឡើងទាំងអស់ ព្រោះថា ចិត្តគហបតីឧបាសកជាអ្នកមានសទ្ធាជ្រះថ្លា មានសីលបរិបូណ៌ នឹងទៅក្នុងប្រទេសណាៗ លាភសក្ការៈ ក៏រមែងកើតឡើងដល់គេក្នុងប្រទេសនោះៗ ។ ម្យ៉ាងទៀត ហេតុការណ៍ដែលគួរអស្ចារ្យ ដែលកើតឡើងដល់ចិត្តគហបតីគ្រានេះ មហាជនបាននាំមកសន្ទនាគ្នាថា ចិត្តគហបតីជាអ្នកសម្បូណ៌ដោយគ្រឿងសក្ការៈដែលសម្តែងការគោរព និងគ្រឿងសម្មាន:ដែលសម្តែងការរាប់អានត្រឹមណាហ្ន៎ ។

ព្រះមានព្រះភាគ ទ្រង់សណ្តាប់ការសន្ទនានោះហើយ ទើបត្រាស់ព្រះគាថាធម៌ ដែលមានចារនៅក្នុង **គម្ពីរខុទ្ទកនិកាយ គាថាធម្មបទ** នៃ **បកិណ្ណកវគ្គ** ដូចមានសេចក្តីថា ៖

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្តាប់ស្តាល់ដោយយស និងភោគទ្រព្យ គប់រកប្រទេសណាៗ គេតែងតែបូជា ក្នុងប្រទេសនោះៗ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ទេសនាចប់ស្រេច ជនចំនួនច្រើនបានសម្រេចអរិយផល (ផលដ៏ប្រសើរ) ទាំងឡាយ មានសោតាបត្តិផលជាដើម ។ ចាប់ផ្តើមអំពីកាលនោះមក ចិត្តគហបតីមានឧបាសកដែលសុទ្ធតែជាអរិយសាវ័ក ៥០០ នាក់ជាបរិវារ បានចោមរោមគ្រាច់ទៅ ។ លុះមកខាងក្រោយ កាលព្រះមានព្រះភាគទ្រង់តែងតាំងឧបាសកទាំងឡាយទុកក្នុងតំណែង ដ៏លើសទាំងឡាយតាមសមគួរ ទ្រង់ធ្វើចិត្តសំយុត្ត (គឺរឿងទាក់ទងនឹងចិត្ត) ឲ្យជាហេតុកើតរឿងហើយ ទើបទ្រង់តែងតាំងចិត្តគហបតីឧបាសកទុកក្នុងតំណែងជាឯតទគ្គៈ ដែលមានសម្តែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយឯកនិបាត** ដូចមានសេចក្តីថា ៖

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ ធម្មកថិកានំ

យទិទំ ចិត្តោ គហបតិ បច្ចិកសណ្ឌិកោ ។ប្រែថា ម្នាលភិក្ខុទាំងឡាយ ពួកឧបាសកជាជម្នុកចិក ស្រែចនឹងចិត្តគហបតី ដែលនៅក្នុងស្រុកមច្ឆិកសណ្ឌៈ ។

ម្យ៉ាងទៀត សេចក្តីល្អរបស់ចិត្តគហបតី តាមដែលមានក្នុង ***សទ្ធម្មប្បកាសនីអដ្ឋកថា*** ពោលថា ចិត្តគហបតីជាអ្នកមានសីលធម៌ដ៏ល្អ បើគេនឹងតាំងសេចក្តីប្រាថ្នាទុក ក៏នឹងបានជាស្តេចចក្រពត្តិក្នុងអនាគតកាល ការតាំងចិត្តបរិសុទ្ធ រមែងសម្រេចដល់អ្នកមានសីល ។ នេះជាគ្រឿងសម្តែងឲ្យឃើញដល់ចិត្តគហបតីឧបាសក ជាអ្នកមានសីលធម៌ និងបុណ្យកុសល ដែលបានធ្វើទុកមករហូតអាចនឹងនាំមកតាំងសេចក្តីប្រាថ្នាឲ្យបានសម្រេចជាស្តេចចក្រពត្តិ គឺជាព្រះរាជាធិរាជ សំដៅដល់ព្រះរាជាអ្នកធំក្រៃលែងជាងព្រះរាជាដទៃបាន ភាពជាស្តេចចក្រពត្តិ មានព្រះរាជអាណាខេត្តដែលគ្រប់គ្រងធំទូលាយ ដូចដែលប្រមាណថា មានមហាសមុទ្រទាំង ៤ ជាព្រំប្រទល់របស់ព្រះរាជអាណាចក្រ ស្រុកនគរខាងក្នុង គ្រប់គ្រងមានម្ចប់ត្រជាក់ជាសុខ

បង្ក្រាបសត្រូវដោយធម៌ មិនបាច់ប្រើអាជ្ញា (ការដាក់ទោស) និង
សស្ត្រាវុធ ទាំងមានរតន: គឺកែវ ៧ ប្រការប្រចាំព្រះអង្គ បានដល់
ជំរីកែវ សេះកែវ នាងកែវ នាយឃ្លាំងកែវ សេនាបតីកែវ ចក្រកែវ
និងកែវមណី នេះជាផលដែលកើតឡើង ព្រោះការធ្វើបុណ្យកុសល
ផ្សេងៗ ត្រាតែកើតផលល្អ បានជាស្តេចចក្រពត្តិ ទើបមានជារមី
និងព្រះរាជសម្បត្តិ ដូច្នេះ ។

ផលការងារផ្នែកការអធិប្បាយធម៌ របស់ចិត្តគហបតីឧបាសក
ដែលសម្តែងដល់ភាពជាអ្នកមានបញ្ញាល្អរបស់លោក មានរឿងប្រាកដ
ក្នុងព្រះបាលី **គម្ពីរសំយុត្តនិកាយ សឡាយតនវគ្គ** នៃ **កាមភូសូត្រ**
ដែលពោលដោយវេទ គឺរាងកាយ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះកាមភូត្ថេរ អាស្រ័យនៅអម្ពាដកវ័ន ជិត
ដងព្រៃមច្ឆិកាសណ្ឌ: ។ គ្រានោះ ចិត្តគហបតីបានចូលទៅរកព្រះ
កាមភូត្ថេរ ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរដល់ខ្លួន ។ ព្រះ
កាមភូត្ថេរបានពោលនឹងចិត្តគហបតីថា ម្នាលគហបតី ព្រះសាស្តាជា

ម្ចាស់ត្រាស់ព្រះគាថាធម៌ទុកថា លោកចូរមើលរថដែលមិនមានទោស មានជំបូល-ស មានក្លៅតែមួយ មិនមានទុក្ខ សុះទៅដល់ទីដែលសំដៅកាត់ក្រសែតណ្ហាដាច់ហើយ មិនមានកិលេសជាគ្រឿងរួបរឹត ។

ម្នាលគហបតី លោកគប្បីឃើញសេចក្តីដោយពិស្តារនៃព្រះគាថាធម៌ ដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកដោយសង្ខេបនេះបានដូចម្តេច ? ចិត្តគហបតីសួរថា បពិត្រព្រះគុណម្ចាស់ ព្រះគាថាធម៌នេះ ព្រះមានព្រះភាគជាម្ចាស់បានត្រាស់ឬ ? ព្រះកាមភូឆ្លើយថា យ៉ាងហ្នឹងហើយ គហបតី ។ ចិត្តគហបតីពិតថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមព្រះគុណម្ចាស់ប្រោសរង់ចាំមួយភ្លែត រហូតខ្ញុំព្រះករុណាពិចារណាដល់សេចក្តីនៃព្រះគាថាធម៌នោះបាន ។

កាលចិត្តគហបតីពោលដូច្នេះហើយ អង្គុយនៅស្ងៀមមួយភ្លែត ទើបបានពោលឡើងថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ពាក្យថា **មិនមានទោស** សំដៅដល់ សីលទាំងឡាយ ពាក្យថា **មានជំបូល-ស**

សំដៅដល់វិមុត្តិ (ការរួចផុតអំពីកិលេស) ពាក្យថា **មានភ្លៅមួយ** សំដៅដល់ សតិ (ការរឭកបាន ឬនឹកបាន) ពាក្យថា **សុះទៅ** សំដៅដល់ ការឈានទៅ និងត្រឡប់ក្រោយ ពាក្យថា **រថ** សំដៅដល់ រាងកាយដែលប្រកបដោយមហាភូតរូប ៤ (គឺដី ទឹក ភ្លើង ខ្យល់) មានមាតាបិតាជាដែនកើត ចម្រើនធំធាត់ឡើង ដោយបាយ និងនំ មានការមិនទៀង ការលាបលន គក់ច្របាច់ មានការបែកធ្លាយ និងការវិនាសជាធម្មតា ។

បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន រាគៈ គឺការត្រេកអរក្នុងកាម ទោសៈ គឺការគិតប្រទូសរ៉ាយ មោហៈ គឺការវង្វេង បានដល់ ទុក្ខ ពាក្យថា **សុះទៅដល់ទីដែលសំដៅ** សំដៅដល់ ព្រះអរហន្ត គឺអ្នកមិនមានសត្រូវ គឺកិលេស ឬអ្នកមិនមានកិលេស ។ ពាក្យថា **ក្រៃសែ** សំដៅដល់តណ្ហា គឺការចង់បាន តណ្ហានោះ កិក្ខុជាខីណាស្រពលះបង់បានហើយ បានកាត់ឫសដាច់ហើយ បានធ្វើឲ្យដូចជាត្នោតកំបុត-ក ធ្វើមិនឲ្យមាន មិនឲ្យកើតឡើងតទៅទៀត ព្រោះដូច្នោះ

កិក្ខុជាទីណាស្រេព ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា អ្នកបានកាត់ក្រែសែតណ្ហាជាច់ហើយ ។

រាគៈ ទោសៈ មោហៈ សំដៅដល់ កិលេសជាគ្រឿងរួបរឹត ។ កិលេសជាគ្រឿងរួបរឹតទាំងនោះ គឺកិក្ខុជាទីណាស្រេពបានកាត់ដាច់ឫសហើយ ធ្វើឲ្យដូចជាត្នោតកំបុត-ក ធ្វើមិនឲ្យមាន មិនឲ្យកើតឡើងតទៅទៀត ព្រោះដូច្នោះ កិក្ខុជាទីណាស្រេព ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា អ្នកមិនមានកិលេសជាគ្រឿងរួបរឹត បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ព្រះគាថាធម៌ដែលព្រះមានព្រះភាគត្រាស់ទុកថា :-

លោកចូរមើលរថដែលមិនមានទោស មានជំបូល-ស មានភ្លៅមួយ មិនមានទុក្ខ សុះទៅដល់ទីដែលសំដៅ កាត់ក្រែសែតណ្ហា មិនមានកិលេសជាគ្រឿងរួបរឹត ។

បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាវមែងដឹងទូទៅជល់សេចក្តីនៃព្រះគាថា ដែលព្រះមានព្រះភាគត្រាស់ទុកដោយសង្ខេបនេះ បានដោយពិស្តារយ៉ាងនេះ ។ ព្រះកាមភូត្តេរ ពោលថា

ម្នាលគហបតី ការដែលបញ្ញាចក្ខុរបស់លោកដ៏ឆ្ងាព្រះពុទ្ធវចនៈដ៏មានជម្រៅនេះបាន ឈ្មោះថា ជាលាភរបស់លោក លោកបានលាភដែលល្អហើយ ។

មានរឿងពោលដល់ចិត្តគហបតីឧបាសក ដែលបានសន្ទនាធម៌ជាមួយអចេលកស្សបៈ គឺអ្នកបួសអាក្រាត ជាអ្នកបួសក្រៅព្រះពុទ្ធសាសនា រាប់ជាការសន្ទនាដែលត្រូវប្រយ័ត្នប្រយែងពាក្យនិយាយគ្រប់ពាក្យ មិនឲ្យមានការភ្លាំងភ្លាត់ ដោយនាំសេចក្តីជ្រះថ្លា មកកាន់ព្រះពុទ្ធសាសនាបាន ដែលមានពោលទុកនៅក្នុង ***គម្ពីរសំយុត្តនិកាយ សឡាយតនវគ្គ*** នៃ ***អចេលសូត្រ*** ដែលពោលដល់ធម៌យ៉ាងកំពូលរបស់មនុស្សថា :-

ក្នុងគ្រាមួយ អចេលកស្សបៈ ជាសម្ងាញ់របស់ចិត្តគហបតី ក្នុងសម័យកាលនៅជាគ្រហស្ថ បានទៅព្រៃមច្ឆិកាសណ្ឌៈ ។ ចិត្តគហបតីបានជ្រាបដំណឹងថា អចេលកស្សបៈធ្លាប់ជាសម្ងាញ់ចាស់របស់ខ្លួនមកដល់ព្រៃមច្ឆិកាសណ្ឌៈ ក៏ចេញទៅរកអចេលកស្សបៈ

បានរាក់ទាក់ប្រាស្រ័យ លុមឲ្យជាទីរឭកដល់គ្នាបានហើយ ក៏អង្គុយ
ចុះក្នុងស្ថានទីដ៏សមគួរ ហើយសួរអចេលកស្សបៈថា លោកកស្សបៈ
ដ៏ចម្រើន លោកបួសមកយូរប៉ុន្មាន ? អចេលកស្សបៈ ឆ្លើយថា
ម្នាលគហបតី យើងបួសមកបានប្រមាណ ៣០ ឆ្នាំ ។ ចិត្តគហបតី
សួរថា លោកកស្សបៈដ៏ចម្រើន រាប់អំពីលោកបួសមកអស់ ៣០ ឆ្នាំ
ឧត្តរិមនុស្សធម៌ គឺធម៌យ៉ាងក្រៃលែងរបស់មនុស្ស ដែលជាញាណ
ទស្សនៈ គឺការដឹង ការឃើញដ៏វិសេស ដែលជាការដឹង ការឃើញ
របស់ព្រះអរិយៈយ៉ាងណាមួយ លោកបានសម្រេចហើយឬនៅធម៌
ដែលជាគ្រឿងនៅយ៉ាងសប្បាយ លោកបានហើយឬ ? អចេលកស្សបៈ
ឆ្លើយថា ម្នាលគហបតី រៀលា ៣០ ឆ្នាំមកនេះ ឧត្តរិមនុស្សធម៌ គឺធម៌
យ៉ាងក្រៃលែងរបស់មនុស្ស ដែលជាការដឹង ការឃើញដ៏វិសេស ដែល
ជាការដឹង ការឃើញរបស់ព្រះអរិយៈយ៉ាងណាមួយ យើងមិនទាន់
បានសម្រេចធម៌ដែលជាគ្រឿងនៅសប្បាយ ក៏យើងមិនបាន ក្រៅអំពី
ការប្រព្រឹត្តខ្លួនជាមនុស្សអាក្រាត ជាមនុស្សក្បាលត្រងោល និងការ

សម្អាតខ្លួនដោយកន្ទុយសត្វក្ងោកប៉ុណ្ណោះ ។ កាលអចេលកស្សប: ពោលយ៉ាងនេះហើយ ចិត្តគហបតីពោលថា លោកដ៏ចម្រើន ភាពជាធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ គួរអស្ចារ្យពិត ក្នុងការដែលលោកប្រកាន់ថា អចេលបព្វជ្ជារបស់លោកជាសាសនាល្អតែលោកបួសមករហូតវេលា ៣០ ឆ្នាំ ក៏នៅមិនមានឧត្តរិមនុស្សធម៌ គឺធម៌យ៉ាងក្រៃលែងរបស់មនុស្ស មិនមានការដឹង ការឃើញដ៏វិសេស ដែលជាការដឹង ការឃើញរបស់ព្រះអរិយ:យ៉ាងណាមួយ ធម៌ដែលជាគ្រឿងនៅសប្បាយក៏មិនទាន់បាន ។

ទើបអចេលកស្សប:សួរថា ម្នាលគហបតី លោកប្រកាសខ្លួនជាឧបាសកមកយូរប៉ុន្មាន ? ចិត្តគហបតីតបថា លោកដ៏ចម្រើន ខ្ញុំបានប្រកាសខ្លួនជាឧបាសកមក ៣០ ឆ្នាំហើយ ។ អចេលកស្សប: សួរតទៅទៀតថា ម្នាលគហបតី អស់វេលា ៣០ ឆ្នាំមកនេះ ឧត្តរិមនុស្សធម៌ដែលជាការដឹង ការឃើញដ៏វិសេស ដែលជាការដឹង ការឃើញរបស់ព្រះអរិយ: លោកបានសម្រេចឬ ធម៌ដែលជាគ្រឿង

នៅសប្បាយ លោកបានហើយឬ ?

ចិត្តគហបតីតបថា លោកដ៏ចម្រើន សូម្បីគ្រហស្ថ ក៏គប្បីមានធម៌ដូច្នោះបាន ព្រោះខ្ញុំបំណងនឹងចូលឈានណាៗ ក៏ចូលបានតាមបំណង គឺខ្ញុំបំណងនឹងចូលបឋមជ្ឈាន បានដល់ ឈានទី ១ ដែលប្រាសចាកកាម និងប្រាសចាកអកុសលធម៌ទាំងឡាយ ដែលមានវិតក្ក វិចារៈ បីតិ និងសុខ ដែលកើតអំពីវិវេក ក៏ចូលបានតាមបំណង ខ្ញុំបំណងនឹងចូលទុតិយជ្ឈាន បានដល់ ឈានទី ២ ដែលគ្មានវិតក្ក វិចារៈក៏បាន ខ្ញុំបំណងនឹងចូលតតិយជ្ឈាន បានដល់ ឈានទី ៣ ដែលមិនមានបីតិក៏បាន ខ្ញុំបំណងនឹងចូលចតុត្ថជ្ឈាន បានដល់ ឈានទី ៤ ដែលមិនមានសុខ មិនមានទុក្ខក៏បាន នែ៎លោកដ៏ចម្រើន បើខ្ញុំគប្បីព្យាករមុនព្រះមានព្រះភាគ ក៏នឹងមិនជាការគួរអស្ចារ្យ ការដែលព្រះសាស្តាគប្បីព្យាករខ្ញុំថា មិនមានសំយោជនៈដែលធ្វើចិត្តគហបតីឲ្យត្រឡប់មកកាន់លោកនេះទៀតឡើយ ។

គ្រាចិត្តគហបតីពោលយ៉ាងនេះ អចេលកស្សបៈបានពោលថា

ម្នាលគហបតី ធម៌ដែលព្រះសាស្តាត្រាស់ល្អហើយ គួរអស្ចារ្យពិត មិនធ្លាប់មានមកហើយហ្ន៎ ព្រោះនៅក្នុងព្រះធម្មវិន័យ មានគ្រហស្ថ អ្នកស្មៀកពាក់.ស ក៏នៅបានសម្រេចឧត្តរិមនុស្សធម៌ ដែលជាការដឹង ការឃើញដ៏វិសេស ដែលជាការដឹង ការឃើញរបស់ព្រះអរិយៈ លោកបានសម្រេចធម៌ដែលជាគ្រឿងនៅយ៉ាងសប្បាយដូច្នោះ ម្នាលគហបតី សូមឲ្យយើងបានធម៌ដែលជាគ្រឿងនៅសប្បាយ ឲ្យយើងបានបព្វជ្ជាឧបសម្បទាក្នុងព្រះធម្មវិន័យ របស់ព្រះសមណគោតមចុះ គ្រានោះ ចិត្តគហបតីបាននាំអចេលកស្សបៈចូលទៅរកភិក្ខុទាំងឡាយ និងពោលជាមួយភិក្ខុទាំងឡាយថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើនទាំងឡាយ អចេលកស្សបៈនេះ ធ្លាប់ជាសម្លាញ់ចាស់របស់ខ្ញុំព្រះករុណា កាលនៅជាគ្រហស្ថ សូមព្រះគុណម្ចាស់ទាំងឡាយ ឲ្យអចេលកស្សបៈនេះបព្វជ្ជាឧបសម្បទាចុះ ខ្ញុំព្រះករុណានឹងខ្វល់ខ្វាយបដិបត្តិលោកដោយចីវរ គឺគ្រឿងស្មៀកដណ្តប់ បិណ្ឌបាត គឺអាហារ សេនាសនៈ គឺទីនៅ និងគិលានភេសជ្ជៈ គឺថ្នាំព្យាបាលរោគ ។

អចេលកស្សបៈ ក៏បានបព្វជ្ជាឧបសម្បទាក្នុងធម្មវិន័យ កាលអចេលកស្សបៈឧបសម្បទាហើយមិនយូរ លោកបានគេចចេញអំពីពួកទៅនៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានការព្យាយាមដែលធ្វើឲ្យកិលេសវិនាស មានចិត្តនឹងធឹង ធ្វើឲ្យជាក់ច្បាស់នូវទីបំផុតនៃព្រហ្មចរិយៈដ៏កំពូល ដែលកុលបុត្រទាំងឡាយអ្នកចេញបួស ក្នុងធម្មវិន័យគប្បីត្រូវការ ដោយបញ្ញាដ៏ក្រៃលែង ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ចូលដល់ហើយ ដឹងច្បាស់ថា ជាតិ គឺការកើតអស់ហើយ សម្រេចព្រហ្មចរិយៈហើយ កិច្ចដែលគួរធ្វើ បានធ្វើស្រេចហើយ មិនមានកិច្ចដទៃដែលនឹងត្រូវធ្វើដើម្បីភាពយ៉ាងនេះទៀតហើយ ។

អចេលកស្សបៈបានជាព្រះអរហន្តមួយរូប ក្នុងបណ្តាព្រះអរហន្តទាំងអស់ ។ ការដែលព្រះអចេលកស្សបត្ថេរ បានចូលមកបព្វជ្ជាឧបសម្បទាជាភិក្ខុក្នុងព្រះពុទ្ធសាសនា និងបានមកសម្រេចជាព្រះអរិយបុគ្គលថ្នាក់ខ្ពស់បំផុត ក៏ជាផលដែលជាប់មកអំពីចិត្តគហបតីឧបាសក ជាអ្នកពោលណែនាំមុនដំបូង និងនាំមកបួសនៅក្នុងព្រះ

ធម្មវិនយផង ។

ជីវប្រវត្តិរបស់ចិត្តគហបតីឧបាសក ដែលពោលដល់ផ្នែកទីបំផុត នៃជីវិតរបស់លោក មានប្រាកដក្នុងព្រះបាលី **គម្ពីរសំយុត្តនិកាយ សឡាយតនវគ្គ** ដូចមានសេចក្តីថា :-

ក្នុងគ្រានោះ ចិត្តគហបតីឈឺ មានជំងឺធ្ងន់ ជាទុក្ខ ។ មានទេវតាដែលនៅតាមអាវាម តាមព្រៃ តាមដើមឈើ ដើមថ្នាំ ដើមស្មៅ និងដើមឈើធំ បានមកប្រជុំគ្នា ហើយពោលនឹងចិត្តគហបតីថា ម្នាលគហបតី លោកចូរប្រាថ្នាជាស្តេចចក្រពត្តិក្នុងកាលអនាគតចុះ ចិត្តគហបតីពោលបដិសេធថា ម្នាលទេវតាទាំងឡាយ កាពជាស្តេចចក្រពត្តិនោះ ជារបស់មិនទៀង មិនស្ថិតស្ថេរ ត្រូវលះបង់ទៅទាំងអស់ ។

ពួកមិត្តសម្ភាញ់ ញាតិសាលោហិត កាលបានស្តាប់ចិត្តគហបតីពោលយ៉ាងនេះ ទើបនាំគ្នាពោលជាសំដៅទៀនចិត្តគហបតីថា បពិត្រលោកគហបតី សូមលោកតាំងសតិទុកឲ្យបានល្អ កុំនិយាយផ្តេសផ្តាស ។ ចិត្តគហបតីសួរថា ម្នាលលោកទាំងឡាយ យើងបាននិយាយអ្វីចេញ

ទៅខ្លះឬ ដែលជាហេតុឲ្យពួកលោកជ្រាប់ដល់យើងដូច្នេះ ? មិត្តសម្ងាញ់សាលោហិតឆ្លើយថា ព្រោះកាលលោកនិយាយអម្បាញ់មិញនេះថា កាពជាស្តេចចក្រពត្តិ ជារបស់មិនទៀង មិនស្ថិតស្ថេរ ចាំបាច់ត្រូវលះបង់ទៅ ដូច្នេះ ។

ចិត្តគហបតីទើបជ្រាប់ឲ្យថា ដែលយើងពោលយ៉ាងនេះ ព្រោះទេវតាដែលនៅតាមអាកាស តាមព្រៃ តាមដើមឈើ តាមដើមថ្នាំ តាមដើមស្មៅ និងដើមឈើធំ បានមកពោលនឹងយើងថា ម្នាលគហបតី សូមលោកជ្រាថ្នា ជាស្តេចចក្រពត្តិក្នុងអនាគតកាលចុះ យើងទើបពោលជាមួយទេវតាទាំងនោះថា កាពជាព្រះស្តេចចក្រពត្តិនោះមិនទៀង មិនស្ថិតស្ថេរ ចាំបាច់ត្រូវលះបង់ទៅទាំងអស់ ។ពួកមិត្តសម្ងាញ់ ទើបពោលថា ហេតុអ្វី ទើបទេវតាទាំងនោះ ជ្រាប់ឲ្យលោកជ្រាថ្នាជាស្តេចចក្រពត្តិ ? ចិត្តគហបតីតបថា ម្នាលលោកទាំងឡាយ ព្រោះទេវតាទាំងនោះឃើញថា យើងជាអ្នកមានសីល ធម៌ល្អ បើជ្រាថ្នាជាស្តេចចក្រពត្តិក៏នឹងសម្រេច តែយើងបានជ្រាប់ទេវតា ដូចដែលជ្រាប់

ហើយនោះ ។

ពួកមិត្តសម្ងាញ់ ទើបពោលថា បើដូច្នោះ សូមលោកប្រៀនប្រដៅពួកខ្ញុំផងចុះ ។ ទើបចិត្តគហបតីពោលទូន្មានថា ម្នាលលោកទាំងឡាយ ពួកលោកត្រូវហ្វឹកហាត់ចិត្តយ៉ាងមាំទាំចំពោះព្រះពុទ្ធថា ***ឥតិបិ សោ ភគវា អរហំ*** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា ***អរហំ*** ព្រោះព្រះអង្គផ្ងាយចាកសឹកសត្រូវ ពោល គឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ ***សម្មាសម្ពុទ្ធោ*** ទ្រង់ព្រះនាមថា ***សម្មាសម្ពុទ្ធោ*** ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ***វិជ្ជាចរណសម្បន្នោ*** ទ្រង់ព្រះនាមថា ***វិជ្ជាចរណ-សម្បន្នោ*** ព្រោះព្រះអង្គបរិបូណ៌ ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥ ***សុគតោ*** ទ្រង់ព្រះនាមថា ***សុគតោ*** ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុទ្ធរស្ថាន គឺអមតមហានិព្វាន ***លោកវិទូ***

ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា **សត្ថា ទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃ ឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

ចូរហ្វឹកហាត់ខ្លួន ឲ្យជាអ្នកមានសទ្ធាជ្រះថ្លាយ៉ាងពិតប្រាកដចំពោះព្រះធម៌ថា :-

ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក

ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយល្អ (**ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១) **សន្ទិដ្ឋិកោ** ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិត ដោយបច្ចវេក្ខណាញ្ញាណ គឺថានឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗ ក៏ទេ គឺឃើញច្បាស់ ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ **ឯហិបស្សវិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌ គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃការនា **បច្ចត្តំ វេទិតព្ពោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើមគប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

ហើយចូរហ៊ឺកហាត់ខ្លួន ឲ្យជាអ្នកមានសទ្ធាជ្រះថ្លាយ៉ាងពិតប្រាកដ ចំពោះព្រះសង្ឃ (សំដៅដល់ សាវកសង្ឃ ឬអរិយសង្ឃ) ថា :-

សុបដិបន្នោ ភគវតោ សាវកសង្ឃោ *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្ធង់ព្រះនព្វលោកុត្តរធម៌* ***ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ*** *ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា* ***ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ*** *ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង* ***សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ*** *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរ ដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា* ***យទិទំ ចត្តារិ បុរិសយុគានិ*** *ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយ មាន ៤ គូ គឺព្រះសង្ឃដែលបាន*

សម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១ **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គល មាន ៨ គឺព្រះសង្ឃដែលបានសម្រេច នូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវក នៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយ បង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្តដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា **អញ្ជលិករណីយោ**

លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃ ក្រៃលែងជាងគ្មាន ។

ទាំងចូរហ្វឹកហាត់ខ្លួន ឲ្យជាមនុស្សមានចិត្តត្រេកអរើកាយក្នុងការបរិច្ចាគទាន និងក្នុងសីលគ្រប់យ៉ាង ។

គ្រាចិត្តគហបតី ពោលប្រៀនប្រដៅមិត្តសម្លាញ់ដូច្នេះហើយ ក៏ធ្វើមរណកាល គឺស្លាប់ទៅ ។ ម្យ៉ាងទៀត ស្ថានទីកើតក្នុងបរលោក គឺលោកខាងមុខរបស់អ្នកបានជាព្រះអនាគាមីហើយ បានដល់ សុគតិជាន់សុទ្ធាវាស ។

(ជីវប្រវត្តិចិត្តគហបតីឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ពេទ្យជីវកកោមារភច្ចឧបាសក ✍

“ ជាអ្នកប្រសើរផ្នែកខាងញ៊ាំងបុគ្គលឱ្យជ្រះថ្លា ”

ពេទ្យជីវកកោមារភច្ច ជាបុព្វាចារ្យ ក្នុងបណ្តាពេទ្យទាំងឡាយ ជាទេព្យដែលគួរឲ្យគោរពរាប់អាន ជាអច្ឆរិយពេទ្យ ជាអ្នកពូកែបំផុត ក្នុងការវិនិច្ឆ័យអាការរោគបានយ៉ាងត្រឹមត្រូវ ត្រង់ទៅតាមសមុដ្ឋាន របស់រោគ ហើយជាក់ថ្នាំបំបាត់រោគបានយ៉ាងសក្តិសិទ្ធិទៀតផង ធ្វើឲ្យ ជំងឺដែលកើតឡើងនោះ ជាសះស្បើយទៅបានឆាប់រហ័ស ថែមទាំង ជាអ្នកបានទទួលការលើកតម្កើងអំពីព្រះមានព្រះភាគ ឲ្យជាអ្នកប្រសើរ ជាងឧបាសកទាំងឡាយ ជាអ្នកញ៊ាំងបុគ្គលឲ្យជ្រះថ្លា ទាំងនេះរាប់ថា ជាពេទ្យគំរូ ដែលបានកសាងចរិយាធម៌របស់គ្រូពេទ្យទុកជាគំរូដល់ បុគ្គលជំនែទៀតឲ្យយកតម្រាប់តាម ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ពេទ្យជីវកកោមារភច្ច មានសម្តែង ប្រាកដនៅក្នុង **អដ្ឋកថាមនោរថបូរណី** និងក្នុង **អដ្ឋកថា គម្ភីរតិយ-**

សមន្តបាសាទិកា ដូចមានសេចក្តីថា ៖

ក្នុងពុទ្ធកាលនៃព្រះបទុមុត្តរសម្មាសម្ពុទ្ធ ដោយរាប់ថយក្រោយទៅអំពីកទូកប្បនេះបានមួយសែនកប្ប លោកបានកើតនៅក្នុងត្រកូលអ្នកមានធនធានម្នាក់ នៅក្នុងនគរហង្សវតី ។ ពេលដែលលោកចម្រើនវ័យធំដឹងក្តីហើយ ថ្ងៃមួយ លោកបានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះបទុមុត្តរសម្ពុទ្ធ ហើយបានឃើញព្រះពុទ្ធអង្គ ប្រកាសតែងតាំងឧបាសកម្នាក់ទុកក្នុងតំណែង ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ដែលជាអ្នកញុំាងបុគ្គលឲ្យជ្រះថ្លា ក្នុងឋានៈជាគ្រូពេទ្យ ដែលធ្វើនាទីឧបដ្ឋាកព្រះសម្ពុទ្ធ ដោយមានគុណធម៌ផ្សាយទៅក្នុងបរិស័ទទាំង ៤ ថា គ្រូពេទ្យនេះជាពុទ្ធុប្បដ្ឋាក គឺអ្នកឧបត្ថម្ភទំនុកបម្រុងព្រះមុនី ពេលនោះទើបលោកគិតថា ធ្វើដូចម្តេចហ្ន៎ យើងនឹងគប្បីបាននូវឋានៈបែបនេះបាន ហើយលោកបានចាត់ចែងការថ្វាយមហាទានដល់កិក្ខុសង្ឃ ដែលមានព្រះបទុមុត្តរសម្ពុទ្ធជាប្រធាន រហូតអស់ ៧ ថ្ងៃ ។ កាលលោកថ្វាយទានក្នុងថ្ងៃទី ៧ ស្រេចបាច់ហើយ ទើបថ្វាយបង្គំព្រះបទុមុត្តរសម្ពុទ្ធ ហើយ

បានតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះលោកនាយក ក្នុងអនាគតកាល ខ្ញុំព្រះករុណាសូមបានជាពុទ្ធុប្បដ្ឋាក ដូចជាគ្រូពេទ្យម្នាក់នោះ ដែលបានជាឧបដ្ឋាករបស់ព្រះសាស្តាហើយនោះ បន្ទាប់ពីនោះទៅ លោកក៏បានប្រឹងប្រែងធ្វើកុសលកម្មជារឿយៗ តមក ។ កាលលោកអស់ជីវិតពីជាតិនោះទៅហើយ បានទៅកើតជាទេវតា និងកើតជាមនុស្ស រហូតមួយសែនកប្ប ហើយត្រឡប់មកកើតក្នុងគភ៌របស់ស្រីពេស្យា ដែលមានឈ្មោះថា **សាលវតី** ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់គ្រូពេទ្យជីវកកោមារភច្ច មានសម្តែងទុកក្នុងព្រះបាលី **ចីវក្ខន្ធក:** ក្នុង **គម្ពីរមហាវគ្គ ព្រះវិន័យបិដក** និងក្នុង **អដ្ឋកថាតតិយសមន្តបា្បសាទិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីក្នុង **ចីវក្ខន្ធក: គម្ពីរមហាវគ្គ ព្រះវិន័យបិដក** នោះ និងក្នុង **អដ្ឋកថាមនោរថបូរណី** តែក្នុងទីនេះ នឹងសូមពោលតាមន័យក្នុងព្រះបាលី **ចីវក្ខន្ធក:** នោះ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ប្រថាប់នៅឯវត្តវេឡុវ័ន ទៀប

ក្រុងរាជគ្រឹះ ។ ក្នុងសម័យនោះឯង ក្រុងវេសាលី ជាក្រុងដែលមាំទាំទូលំទូលាយ មានមហាជនជាច្រើន មានមនុស្សកុះករ មានអាហារកបានងាយ មានប្រាសាទ ៧៧០៧ ខ្នង មានផ្ទះកំពូល ៧៧០៧ ខ្នង មានសួនច្បារ ៧៧០៧ មានស្រះបោក្ខរណី ៧៧០៧ មានស្រីស្អាតប្រចាំក្រុងម្នាក់ឈ្មោះ **អម្ពបាលី** នាងជាស្ត្រីដែលមានរូបឆោមលោមពណ៌គួរឲ្យគយគន់ គួរឲ្យពេញចិត្ត នាងជាអ្នកមានពណ៌សម្បុរស្រស់ល្អទាំងនាងជាអ្នកពូកែរាំច្រៀង និងដេញពិណទៀតផង ។ បុគ្គលទាំងឡាយដែលមានសេចក្តីត្រូវការនាំនាងទៅរួមអភិរម្យនោះ ត្រូវបានចំណាយតម្លៃឲ្យថ្លៃខ្លួនមួយយប់ ៥០ កហាបណៈ ។ ក្នុងក្រុងវេសាលីមើលទៅស្រស់ស្រាយឡើងៗ ដោយ **នាងអម្ពបាលី** (ស្រីប្រភេទនេះមានឈ្មោះថា **ស្រីនគរសោភិនី** ប្រែថា ស្រីដែលធ្វើព្រះនគរឲ្យស្អាត ឬស្រីស្អាតក្នុងក្រុង) ។ សម័យមួយ ពួកកុដុម្ពិក អ្នកក្រុងរាជគ្រឹះម្នាក់ បានធ្វើដំណើរទៅកាន់ក្រុងវេសាលី ដោយកណីយកិច្ចឯណាមួយ បានឃើញក្រុងវេសាលី ជាក្រុងដែលមាំទាំទូលំទូលាយ មានមនុស្សរំណែនតាន់តាប់

មានអាហារភោជនងាយ មានប្រាសាទ និងផ្ទះកំពូលសន្ធឹកសន្ធាប់ ជាទីគាប់ភ្នែក មានសួនច្បារ និងស្រះបោក្ខរណី និងមាននាងអម្ពបាលី ដែលជាស្រីធ្វើឲ្យក្រុងវេសាលីស្រស់បំព្រងឡើងទៅ (ទើបគិតនឹងយកជាគំរូ ធ្វើឲ្យក្រុងរាជគ្រឹះមានស្រីបែបនេះដែរ ។

កាលពួកកុដុម្ពិកទាំងនោះ ត្រឡប់មកដល់ក្រុងរាជគ្រឹះនោះវិញហើយ ទើបនាំគ្នាចូលទៅគាល់ក្រាបបង្គំទូលព្រះបាទពិម្ពិសារ ឲ្យទ្រង់ជ្រាបដល់សភាពនៃការប្រព្រឹត្តទៅរបស់ក្រុងវេសាលី ហើយក្រាបបង្គំទូលសូមឲ្យទ្រង់តាំងស្ត្រីស្អាតប្រចាំក្រុងឡើង ដូចជាក្រុងវេសាលី ដែលពួកខ្លួនបានទៅឃើញ ។ គ្រានោះ ព្រះបាទពិម្ពិសារ ត្រាស់អនុញ្ញាតថា បើយ៉ាងនោះ ពួកលោកចូរជ្រើសរើសកុមារី ដែលមានលក្ខណៈស្អាតយ៉ាងនោះ ហើយតាំងឲ្យនាងជាស្រីស្អាតប្រចាំក្រុងចុះ ។ សម័យនោះ ក្នុងក្រុងរាជគ្រឹះ មានកុមារីម្នាក់ឈ្មោះ **សាលវតី** នាងជាស្ត្រីមានរូបឆោមល្អគន់ គួរឲ្យស្នេហា ទាំងមានសម្រស់ឆើតឆាយដែរ ។ គណៈកុដុម្ពិកក្រុងរាជគ្រឹះ ទើបបានតាំងនាងកុមារីសាលវតី ជាស្រីស្អាត

ប្រចាំក្រុងរាជគ្រឹះ ។ កាលនាងសាលវតី បានទទួលការជ្រើសរើស ជាបវរកញ្ញាប្រចាំក្រុងហើយ ទើបនាងហ្វឹកហាត់ រហូតអាចឈ្នាស ក្នុងការរាំច្រៀង និងលេងតន្ត្រី ហើយមានមនុស្សមកជួលនាងទៅរួម អភិរម្យតម្លៃខ្ពង់ក្នុងមួយយប់មួយរយកហាបណៈ ។ តែកាលនាងសាលវតី បានរ៉ាប់ខ្លួនជាអ្នកបម្រើ ក្នុងការរួមអភិរម្យយ៉ាងនេះតមក មិនយូរប៉ុន្មាន នាងក៏មានគភ៌ឡើង ហើយនាងទើបគិតថា ធម្មតាស្រីមានគភ៌ រមែង មិនជាទីពេញចិត្តរបស់បុរសទាំងឡាយ ប្រសិនបើមានអ្នកដទៃដឹងថា យើងមានគភ៌ ប្រាក់ចំណូលរបស់យើងក៏នឹងធ្លាក់ចុះដែរ យើងគួរតែ ប្រាប់ថា យើងមានជំងឺ លុះនាងគិតឃើញដូច្នេះហើយ ទើបបញ្ជាអ្នក យាមទ្វារទុកថា នែនាយទ្វារ លោកកុំឲ្យអ្នកណាចូលមក បើអ្នកណា មកសួរពួកយើង លោកចូរប្រាប់គេថា យើងឈឺ ។

គ្រានោះ នាយយាមទ្វារបានទទួលពាក្យ និងធ្វើតាមពាក្យបញ្ជា របស់នាងសាលវតីរៀយៗ មក រហូតដល់នាងមានគភ៌គ្រប់ខែ ហើយ ក៏បានប្រសូតបុត្រម្នាក់ ។ ជាធម្មតារបស់ពួកស្រីនគរសោភិនី ពេល

នាងប្រសូតបានកូនស្រី នាងក៏តែងទុកចិញ្ចឹម ដើម្បីបន្តធ្វើជាខ្សែស្រឡាយរបស់ពួកនាងតទៅ តែបើមានកូនប្រុស នាងនឹងឲ្យដល់អ្នកជនៃ ឬមិនដូច្នោះទេ ក៏នាំយកទៅចោះចោល ក្នុងខណៈដែលនៅតូចៗនោះ ដោយមិនព្រមទុកចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសនោះឡើយ ។ ដោយហេតុនេះ នាងសាលវតី ពេលដែលប្រសូតកូនបានមក លុះដឹងថាជាកូនប្រុស ទើបនាងបញ្ជាទាសីថា នែនាងទាសី នាងចូរនាំទារកនេះដាក់ក្នុងកន្ត្រកចាស់ៗ នាំទៅចោលត្រង់គំនរសំរាមចុះ ។ លំដាប់នោះ នាងទាសីស្តាប់ពាក្យបញ្ជាហើយ ទើបនាំទារកនោះដាក់ចុះក្នុងកន្ត្រកចាស់ៗ ហើយបាននាំទៅចោលត្រង់គំនរសំរាម ។ ប៉ុន្តែក្នុងព្រឹកថ្ងៃនោះ អភយ-រាជកុមារ ស្តេចកំពុងយាងចូលទៅគាល់ព្រះបាទពិម្ពិសារព្រះរាជបិតា ដោយបានយាងកាត់មកតាមផ្លូវគំនរសំរាមនោះ ហើយបានទតព្រះនេត្រឃើញទារក មានហ្វូងក្អែកចោមរោមយ៉ាងច្រើន ទើបត្រាស់សួរមហា-តលិកថា នែនាយ ក្អែកកំពុងចោមរោមធ្វើអ្វី ? មហាតលិកក្រាបទូលថា ក្អែកទាំងនោះ កំពុងតែចោមរោមទារក ក្រាបបង្គំទូល ។ ព្រះអភយ-

រាជកុមារត្រាស់សួរថា ចុះទារកនោះនៅមានជីវិតឬទេ ? មហាតលិក ក្រាបទូលថា ទារកនោះនៅមានជីវិត ព្រះអង្គ ។ ព្រះអភយរាជកុមារ ត្រាស់បញ្ជាថា បើយ៉ាងនោះ ចូរអ្នកទៅនាំយកទារកនោះទៅឯរាជវាំង របស់យើង ប្រគល់ឲ្យពួកមេដោះចិញ្ចឹមទុកចុះ ។ បុគ្គលទាំងនោះ ទទួលព្រះរាជបញ្ជាថា ព្រះករុណាថ្លៃវិសេស ហើយក៏នាំទារកនោះទៅ កាន់រាជវាំងរបស់ព្រះអភយរាជកុមារ ហើយយកទៅប្រគល់ឲ្យមេដោះ ចិញ្ចឹមបីបាច់ថែរក្សា ។ ការមកនៃឈ្មោះរបស់ទារកនោះ ដោយកាន់យក និមិត្តដែលព្រះអភយរាជកុមារត្រាស់ថា **ជីវកៈ** បានន័យថា នៅមានជីវិត នៅឡើយ បុគ្គលទាំងឡាយ ទើបដាក់ឈ្មោះឲ្យទារកនោះថា **ជីវកៈ** ។ ជីវកៈនោះ ជាអ្នកដែលព្រះអភយរាជកុមារបញ្ជាឲ្យមេដោះចិញ្ចឹមបីបាច់ ថែរក្សា ដែលគេមានឈ្មោះត្រកូលថា **កោមារភច្ចៈ** នោះ មានសេចក្តីថា **ព្រះរាជកុមារទ្រង់ចិញ្ចឹម** ។

កាលតមក ជីវកកោមារភច្ចៈដ៏ឆ្លាតក្តីហើយ បានទៅលេងជាមួយ ព្រះរាជកុមារដទៃៗ ទៀត លុះកើតមានជម្ងោះឡើង ពួកព្រះរាជកុមារ

ទាំងនោះ តែងតែថាឲ្យជីវកកោមារភច្ច កូនមិនមានម៉ែ មិនមានឪ ។ ជាពិសេសនោះ គឺក្នុងពេលដែលមានប្រគំមហោស្រព ឬបុណ្យផ្សេងៗ ពពួកញាតិទាំងឡាយ មានអ៊ំប្រុសស្រីជាដើម តែងតែបញ្ជូនរបស់បញ្ជើ ឯណានីមួយឲ្យដល់ព្រះរាជកុមារជៃៗ តែជីវកកោមារភច្ច មិនឃើញ មាននរណាផ្ញើរបស់អ្វីយ៉ាងណានីមួយ មកអំពីពពួកញាតិ និងអ្នកជៃ ឡើយ ។ ហេតុទាំងនេះ ជាគ្រឿងជាស់តឿនចិត្ត ឲ្យជីវកកោមារភច្ច ត្រិះរិះថា យើងជាអ្នកមិនមានម៉ែឪមែនឬហ្ន៎ ហើយគេទើបក្រាបទូលសួរ ចំពោះព្រះអភយរាជកុមារថា នរណាជាមាតាបិតា របស់ទូលព្រះបង្គំ ព្រះអង្គ ? ព្រះអភយរាជកុមារត្រាស់តបថា ជីវក: យើងមិនស្គាល់ អ្នកណាជាមាតារបស់កូនទេ តែថាយើងជាបិតារបស់កូន ព្រោះយើង បានឲ្យគេចិញ្ចឹមកូនមក ។ ពេលនោះ ជីវកកោមារភច្ចជ្រាបសេចក្តីពិត ហើយ បានមានការគិតថា រាជត្រកូលទាំងឡាយ មិនមែនជាការងាយ ដែលមនុស្សមិនមានសិល្បវិជ្ជា អាចគ្រប់គ្រងរាជសម្បត្តិបាន ដូច្នេះ យើងគួរតែទៅរៀនសិល្បវិជ្ជា ទើបជាការល្អ ។ តែគេមានការគិតដល់

សិល្បៈ ដែលនិងគប្បីរៀនសូត្រថា **ហត្ថិសិល្បៈ** (សិល្បៈខាងដំរី) **និងអស្សសិល្បៈ** (សិល្បៈខាងសេះ) ជាដើមទាំងនេះ ជាសិល្បៈសម្រាប់ប្រើដើម្បីបៀតបៀនអ្នកដទៃ **ចំពោះវិជ្ជាពេទ្យ** មានមេត្តាជាខាងដើម មានប្រយោជន៍ដល់មហាជនជាច្រើន បើដូច្នោះ យើងគួររៀនវិជ្ជាពេទ្យនោះ ទើបជាការប្រសើរជាង ។ ក្នុងសម័យនោះឯង មានពួកឈ្មួញ អ្នកស្រុកតក្កសិលា ធ្វើដំណើរមកកាន់ក្រុងរាជគ្រឹះ ដើម្បីចូលទៅគាល់ព្រះអភយរាជកុមារ ។ គ្រានោះ ជីវកកោមារភច្ចបានសួរពួកឈ្មួញរទេះ ទាំងនោះថា លោកដ៏ចម្រើនទាំងឡាយ ពួកលោកមកអំពីទីណា ? ពួកឈ្មួញទាំងនោះតបថា ពួកខ្ញុំមកអំពីក្រុងតក្កសិលា ។ ជីវកកោមារភច្ចបានសួរតទៅទៀតថា លោកទាំងឡាយនៅក្នុងក្រុងតក្កសិលា មានអាចារ្យបង្រៀនវិជ្ជាពេទ្យឬទេ ? ពួកឈ្មួញតបថា ម្នាលកុមារ មានគ្រូពេទ្យ ដែលជាអាចារ្យទិសាបាមោក្ខ បានតាំងសម្នាក់នៅក្នុងក្រុងតក្កសិលាមានដែរទេតើ គឺមិនអត់ឯណា ។

កាលជីវកកោមារភច្ចបានជ្រាបថា មានអាចារ្យដែលជាអ្នកបង្រៀន

ផ្នែកខាងពេទ្យដូច្នេះហើយ ទើបគេប្រាប់ដល់ពួកឈ្មួញទាំងនោះថា បើដល់ពេលដែលពួកលោកត្រឡប់ទៅវិញ សូមពួកលោកជួយប្រាប់ឲ្យខ្ញុំជីងផង ។ ពួកឈ្មួញទាំងនោះ ក៏បានធ្វើតាមពាក្យជីវកកោមារភច្ច ដែលបានផ្តាំចំពោះខ្លួន ។ កាលជីវកកោមារភច្ច បានជ្រាបដំណឹងដែលពួកឈ្មួញទាំងនោះប្រាប់ហើយ ក៏មានបំណងទៅជាមួយនឹងពួកឈ្មួញទាំងនោះ ដោយមិនបានទៅក្រាបទូលលាព្រះអភយរាជកុមារឡើយ បានដើរលបៗ ធ្វើដំណើរចេញទៅជាមួយនឹងពួកឈ្មួញទាំងនោះ ដោយចេញដំណើរយឺតៗ ទៅជាលំដាប់ រហូតដល់ក្រុងតក្កសិលាហើយ ទើបចូលទៅរកគ្រូពេទ្យ ដែលជាអាចារ្យទិសាបាមោក្ខ ។ កាលអាចារ្យទិសាបាមោក្ខបានឃើញជីវកកោមារភច្ច បានដើរចូលមកកាន់សម្នាក់របស់ខ្លួន ទើបសួរថា បាជានរណា ? ជីវកកោមារភច្ចជម្រាបថា បពិត្រលោកអាចារ្យ ខ្ញុំជាចៅរបស់ព្រះបាទពិម្ពិសារ និងជាបុត្ររបស់ព្រះអភយរាជកុមារ ។ គ្រានោះ អាចារ្យទិសាបាមោក្ខសួរតទៅទៀតថា មានហេតុអ្វីឬ ទើបបាមកដល់ទីនេះ ? ជីវកកោមារភច្ចជម្រាបថា បពិត្រ

លោកអាចារ្យ ខ្ញុំមានបំណងនឹងមកសិក្សាសិល្បវិជ្ជា ជាមួយនឹងលោកអាចារ្យ ។ ទើបអាចារ្យទិសាបាមោក្ខ ពោលថា ម្នាលជីវក: បើអ្នកមានបំណងនឹងមកសិក្សាហើយ ក៏ចូរសិក្សាចុះ ។

ម្ភ៉ាងសិស្សដែលមកសិក្សាក្នុងសម្នាក់ របស់លោកអាចារ្យទិសាបាមោក្ខក្នុងយុគនោះ បានចែកចេញជាពីរប្រភេទ *គឺ ៖*

១- សិស្សប្រភេទបង់ប្រាក់តម្លៃរៀនសូត្រ ឲ្យដល់អាចារ្យ សិស្សប្រភេទនេះ ជាបុត្ររបស់អ្នកមានមាសប្រាក់ ដូចជាព្រះរាជបុត្រ ដូចជាបុត្ររបស់គហបតី ឬដូចជាបុត្ររបស់អមាត្យ ដូចជាបុត្ររបស់កុដុម្ពិក គេបង់ប្រាក់តម្លៃសិស្សរៀនសូត្រ ឲ្យដល់លោកអាចារ្យហើយ មិនចាំបាច់ធ្វើការងារអ្វីឲ្យដល់លោកអាចារ្យទៀយ ដោយតាំងចិត្តសិក្សាវិជ្ជាតែម្យ៉ាងប៉ុណ្ណោះ ។

២- សិស្សប្រភេទ ដែលមិនបានបង់ប្រាក់តម្លៃរៀនសូត្រ ឲ្យដល់លោកអាចារ្យ សិស្សប្រភេទនេះ អាចជាបុត្ររបស់អ្នកក្រីក្រខ្វះខាតទ្រព្យសម្បត្តិ ឬជាអ្នកដែលគេចពីឪពុកម្តាយមករៀនសូត្រ ដូចជា

ជីវកកោមារភច្ច មិនមានប្រាក់ដើម្បីបង់ថ្លៃសិក្សារៀនសូត្រ ឲ្យដល់លោកអាចារ្យឡើយ កាលមិនមានប្រាក់ដូច្នោះ ក៏ត្រូវធ្វើការងារឲ្យដល់លោកអាចារ្យ ដើម្បីជាតម្លៃរៀនសូត្រ ដោយសិស្សប្រភេទនេះត្រូវចែកពេលជាពីរចំណែក គឺចំណែកទី ១ ជាពេលដែលត្រូវធ្វើការងារឲ្យដល់លោកអាចារ្យ ឯមួយចំណែកទៀត ជាពេលវេលា ដែលត្រូវសិក្សាវិជ្ជា ។

ជីវកកោមារភច្ច បានធ្លាក់នៅក្នុងជំពូកសិស្សប្រភេទទី ២ គឺត្រូវធ្វើការងារមួយពេល និងសិក្សារៀនសូត្រមួយពេល ។ ក្នុងសម័យដែលជីវកកោមារភច្ចមកសិក្សាសិល្បវិជ្ជា នៅឯនគរតក្កសិលានេះ គេមានអាយុបាន ១៦ ឆ្នាំ តែជាអ្នកមានបញ្ញាច្រើន សូម្បីនឹងត្រូវធ្វើកិច្ចការផង និងរៀនសូត្រផង គេក៏អាចរៀនវិជ្ជារហ័សចេះចាំ ឬបានច្រើនទៀតផង ថែមទាំងជាអ្នកមានការយល់បានល្អទៀតផង ដោយមានការចាំយ៉ាងស្ទាត់ជំនាញ មិនមានការភ្លេចភ្លាំងឡើយ ។ កាលជីវកកោមារភច្ចឧស្សាហ៍ព្យាយាមរៀនវិជ្ជាពេទ្យ កន្លងមកបាន ៧ ឆ្នាំ

ក៏អាចរៀនវិជ្ជាការប៉ុនដែលលោកអាចារ្យ មានចំណេះដឹងទាំងអស់បាន តែវិជ្ជាការផ្នែកនេះ បណ្តាសិស្សដទៃត្រូវប្រើពេលរៀនសូត្រជល់ទៅ ១៦ ឆ្នាំទើបចប់រូបមន្ត ។ ជីវកកោមារភច្ច កាលរៀនសូត្រវិជ្ជាកន្ទងមក បាន ៧ ឆ្នាំ ក៏នៅមិនទាន់ជ្រាបថា ខ្លួនឯងរៀនចប់សព្វគ្រប់ហើយឬនៅ ទើបគិតថា យើងរៀនវិជ្ជាបានច្រើន រៀនបានយ៉ាងរហ័ស មានការយល់បានយ៉ាងល្អ ថែមទាំងមានការចាំបានមិនភ្លេចភ្លាំង ទាំងយើងរៀនមកបាន ៧ ឆ្នាំហើយ ក៏នៅមិនទាន់សម្រេចសិល្បវិជ្ជា អង្គាល់នឹងបានសម្រេចហ្ន៎ ទើបគេចូលទៅរកអាចារ្យទិសាបាមោក្ខ ហើយគេជម្រាបសួរថា លោកអាចារ្យ ខ្ញុំរៀនវិជ្ជាបានច្រើន រៀនបានយ៉ាងរហ័ស មានការយល់បានយ៉ាងល្អ ថែមទាំងចាំបានយ៉ាងល្អមិនភ្លេចភ្លាំងទៀតផង ទាំងខ្ញុំបានរៀនមកហើយ ៧ ឆ្នាំ ក៏នៅមិនទាន់សម្រេច កាលណានឹងបានសម្រេចទាន ។ គ្រានោះ អាចារ្យទិសាបាមោក្ខតបថា ម្នាលជីវក: បើដូច្នោះ អ្នកចូរកាន់ចបជីក ដើរទៅជុំវិញក្រុងតក្កសិលា ដោយដើរឲ្យឆ្ងាយពីតួក្រុងចេញទៅម្ខាងមួយយោជន៍ ឯងចូរពិនិត្យមើលវត្ថុណា

ដែលមិនមែនជាដើមថ្នាំ ចូរជីកដើមនោះមកឲ្យអាចារ្យមើល ។

គ្រានោះ ជីវកកោមារភច្ចបានធ្វើតាមពាក្យសម្តី របស់លោកអាចារ្យបញ្ជា ដោយគេបានដើរទៅជុំវិញក្រុងតក្កសិលា ក្នុងរយៈផ្លូវម្ភៃមួយយោជន៍ ក៏មិនបានឃើញវត្ថុណា ដែលមិនមែនជាថ្នាំត្រឹមតែមួយទើបគេត្រឡប់មកវិញ ដោយបានចូលទៅកអាចារ្យទិសាបាមោក្ខ ហើយជម្រាបឲ្យលោកអាចារ្យបានជ្រាបថា លោកអាចារ្យ ខ្ញុំបានដើរទៅជុំវិញក្រុងតក្កសិលា ក្នុងរយៈផ្លូវមួយយោជន៍ហើយ មិនបានឃើញវត្ថុដែលមិនមែនជាថ្នាំនោះ មិនមានឡើយ ។ គ្រានោះ លោកអាចារ្យទើបប្រាប់ថា ម្នាលជីវក: អ្នកបានសិក្សាវិជ្ជានេះសម្រេចហើយ ប៉ុណ្ណោះក៏ល្មមចិញ្ចឹមជីវិតបានហើយៗ លោកអាចារ្យបានឲ្យស្បៀងធ្វើដំណើរបន្តិចបន្តួច ដល់ជីវកកោមារភច្ច ។ មូលហេតុដែលលោកអាចារ្យទិសាបាមោក្ខ ឲ្យស្បៀងសម្រាប់ធ្វើដំណើរផ្លូវបន្តិចបន្តួច ដល់ជីវក-កោមារភច្ចនោះ ព្រោះលោកគិតឃើញថា ជីវក:នេះជាបុត្ររបស់ត្រកូលអ្នកធំ លុះគេត្រឡប់ទៅដល់ត្រកូលវិញហើយ គេនឹងបានទទួល

សក្ការៈយ៉ាងធំអំពីសម្ភាក់ចិតា និងជីតា ។ ហើយគេនឹងមិនដឹងគុណ របស់យើង ឬសិល្បវិជ្ជា តែកាលបើគេអស់ស្បៀងនៅពាក់កណ្តាលផ្លូវ ហើយ ចាំបាច់ត្រូវប្រើសិល្បវិជ្ជាចិញ្ចឹមជីវិត ពេលនោះគេនឹងដឹងនូវគុណ របស់យើង និងរបស់សិល្បវិជ្ជាយ៉ាងពិតប្រាកដ ។ ជីវកកោមារភច្ច បានថ្វាយបង្គំលាលោកអាចារ្យ ហើយកាន់យកស្បៀងបន្តិចបន្តួច ដែល លោកអាចារ្យឲ្យហើយ ទើបចេញដំណើរត្រឡប់ទៅកាន់ក្រុងរាជគ្រឹះវិញ តែកាលជីវកកោមារភច្ច ធ្វើដំណើរមកតាមផ្លូវបានមួយរយៈ ស្បៀង ដែលមានបន្តិចបន្តួចនោះ ក៏អស់នៅត្រង់ក្រុងសាកេត នៅក្នុងវាងផ្លូវ ដែលនឹងត្រូវធ្វើដំណើរឆ្ងាយទៀត ទើបគេគិតថា ផ្លូវនេះជាផ្លូវកន្លារ ខ្វះទឹក ខ្វះអាហារ អ្នកដែលមិនមានស្បៀង លំបាកនឹងធ្វើដំណើរដើរ ឆ្ងងផុតទៅបាន បើដូច្នោះ យើងគួរនឹងរកស្បៀង ត្រៀមការធ្វើដំណើរ ដើរផ្លូវទុក ទើបជាការល្អប្រសើរ ។

ក្នុងកាលនោះ ក្រុងសាកេត មានភរិយារបស់លោកសេដ្ឋីម្នាក់ បានកើតរោគឈឺក្បាលមក អស់ ៧ ឆ្នាំហើយ ។ មានគ្រូពេទ្យ ដែល

ជាអាចារ្យទិសាបាមោក្ខធំៗ ជាច្រើនមកហើយ ដែលធ្លាប់មកព្យាបាលក៏មិនអាចព្យាបាលឲ្យជាបាន មានតែយកប្រាក់ថ្លៃព្យាបាលទៅជាច្រើនទៀតផង ។ គ្រានោះ ជីវកកោមារភច្ច បានចូលទៅឯក្រុងសាកេត បានសាកសួរមនុស្សទាំងឡាយក្នុងក្រុងនោះថា ម្នាលអ្នកទាំងឡាយ តើនៅក្នុងក្រុងនេះ មានអ្នកណាមួយឈឺដែរឬទេ ? ខ្ញុំអាចព្យាបាលឲ្យបាន ។ បុគ្គលទាំងនោះ នាំគ្នានិយាយប្រាប់ថា មានដែរ លោកអាចារ្យ ព្រោះថានៅក្នុងក្រុងសាកេតនេះ មានភរិយារបស់សេដ្ឋីម្នាក់ កើតរោគឈឺក្បាលមកអស់ ៧ ឆ្នាំហើយ សូមលោកអាចារ្យទៅជួយព្យាបាលឲ្យដល់ភរិយារបស់សេដ្ឋីផងចុះ ។ ជីវកកោមារភច្ច បានទៅឯនិវេសន៍របស់លោកសេដ្ឋី ប្រាប់អ្នកយាមទ្វារថា លោកចូរទៅជម្រាបភរិយារបស់លោកសេដ្ឋីថា អ្នកស្រី មានគ្រូពេទ្យម្នាក់គាត់ចង់មកសួរសុខទុក្ខអ្នកស្រីទាន ។ ឆ្មាំទ្វារទទួលពាក្យរបស់ជីវកកោមារភច្ចហើយ ក៏ទៅជម្រាបឲ្យដល់ភរិយា របស់លោកសេដ្ឋីបានជ្រាប ។ គ្រានោះ ភរិយាសួរនាយឆ្មាំទ្វារថា ម្នាលនាយ គ្រូពេទ្យនោះក្មេងចាស់ប៉ុនណា ? នាយ

ឆ្នាំទ្វារជម្រាបតបថា អ្នកស្រី គ្រូពេទ្យនោះ នៅក្មេងនៅឡើយទាន ។ ភរិយារបស់លោកសេដ្ឋីពោលបដិសេធថា កុំឡើយនាយឆ្នាំទ្វារ គ្រូពេទ្យក្មេង មិនអាចព្យាបាលខ្ញុំបានទេ ព្រោះថា គ្រូពេទ្យធំៗ ដែលជាអាចារ្យទិសាបាមោក្ខជាច្រើននាក់មកព្យាបាលខ្ញុំមិនកើតផង មានតែយកប្រាក់ដែលជាថ្លៃឆ្វាន់ព្យាបាលទៅតែប៉ុណ្ណោះ ។ គ្រានោះ នាយឆ្នាំទ្វារត្រឡប់ចេញមកប្រាប់ជីវកកោមារភច្ចតាមពាក្យបដិសេធ របស់ភរិយាលោកសេដ្ឋី ។ ជីវកកោមារភច្ច បានពោលជាមួយនាយឆ្នាំទ្វារថា លោកចូរទៅជម្រាបភរិយារបស់លោកសេដ្ឋីឲ្យជ្រាបថា អ្នកស្រី លោកគ្រូពេទ្យប្រាប់មកយ៉ាងនេះថា សូមអ្នកស្រីកុំទាន់ឲ្យអ្វីៗ មុនរោគជាសះស្បើយ កាលរោគជាហើយ អ្នកស្រីបំណងនឹងឲ្យឆ្វាន់យ៉ាងណាក៏បានដែរ ។ នាយឆ្នាំទ្វារចូលមកជម្រាបភរិយា របស់លោកសេដ្ឋីឲ្យជ្រាបតាមពាក្យរបស់ជីវកកោមារភច្ច ។ ភរិយារបស់លោកសេដ្ឋី ក៏បានពោលថា នាយឆ្នាំទ្វារបើដូច្នោះ ចូរទៅអញ្ជើញគ្រូពេទ្យនោះមកចុះ ។ នាយឆ្នាំទ្វារបានទៅប្រាប់ជីវកកោមារភច្ចថា លោកអាចារ្យ ភរិយារបស់លោកសេដ្ឋី

ឲ្យមកអញ្ជើញលោកចូលទៅខាងក្នុង ។

គ្រានោះ ជីវកកោមារភច្ច បានចូលទៅរកភរិយារបស់លោកសេដ្ឋី ជំបូងគេបានពិនិត្យមើលការប្រែប្រួល ដែលជាអាការនៃរោគរបស់ភរិយាលោកសេដ្ឋី ហើយទើបប្រាប់ភរិយាលោកសេដ្ឋីថា អ្នកស្រី ខ្ញុំត្រូវការទឹកដោះថ្លាមួយទូកដៃ ។ ភរិយាលោកសេដ្ឋី បានប្រាប់ឲ្យមនុស្សនាំទឹកដោះថ្លាមួយទូកដៃ មកឲ្យដល់ជីវកកោមារភច្ច ។ រីឯជីវកកោមារភច្ច ទើបចម្អិនទឹកដោះថ្លាមួយទូកដៃ ផ្សំជាមួយថ្នាំផ្សេងៗ ស្រេចហើយ ឲ្យភរិយាលោកសេដ្ឋីដេកផ្ងារលើគ្រែ ហើយឲ្យច្រកថ្នាំនោះចូលតាមច្រមុះ ។ ខណៈនោះ ទឹកដោះដែលច្រកចូលទៅតាមច្រមុះ បានខ្ទុះចេញមកតាមមាត់ ។ ភរិយាលោកសេដ្ឋីបានស្តោះទឹកដោះនោះចូលក្នុងកន្ទោរ ហើយប្រាប់ទាសីថា នែនាង៎ៗ ចូរប្រើសំឡីផ្តិត ទឹកដោះនេះទុក ។ គ្រានោះ ជីវកកោមារភច្ចបានក្រឡេកឃើញការធ្វើក្នុងគ្រានោះហើយ ទើបគិតថា នេះជារឿងចម្លែកពិត មេផ្ទះម្នាក់នេះស្មោកគ្រោកហួសប្រមាណ សូម្បីទឹកដោះនេះ ជារបស់ដែលគេត្រូវចោល បែរជាប្រើឲ្យទាសីយកសំឡី

ផ្តិតទុក ចំណែកថ្នាំរបស់យើង មានតម្លៃថ្លៃណាស់ បណ្តាយឲ្យខូចបង់ទៅ មេផ្ទះនេះនឹងឲ្យរង្វាន់ថ្លៃថ្នាំអ្វីដល់យើងខ្លះហ្ន៎ ។ គ្រានោះ ភរិយាលោកសេដ្ឋីបានសង្កេតឃើញ កិរិយាអាការដែលប្លែករបស់ជីវកកោមារភច្ច ទើបសួរថា លោកអាចារ្យ លោកមានការចម្លែកក្នុងចិត្តអ្វីឬ ? លំដាប់នោះ ជីវកកោមារភច្ច បានពោលតបដល់គំនិតរបស់ខ្លួនថា ពេលនេះខ្ញុំកំពុងគិតថា ហេតុការណ៍ពេលនេះ ជារឿងចម្លែកពិត មេផ្ទះម្នាក់នេះស្មោកគ្រោកហួសប្រមាណ សូម្បីតែទឹកដោះនេះ ជារបស់ដែលគេត្រូវចោល បែរជាឲ្យទាសីយកសំឡីផ្តិតទុកទៅវិញ ចំណែកថ្នាំរបស់យើងមានតម្លៃច្រើនជាង បណ្តាយឲ្យខូចបង់ទៅ តើមេផ្ទះម្នាក់នេះ ឲ្យរង្វាន់អ្វីដល់យើងខ្លះហ្ន៎ ។ កិរិយារបស់លោកសេដ្ឋីពោលប្រាប់ហេតុផលថា លោកគ្រូពេទ្យពួកនាងខ្ញុំជាមេផ្ទះ ចាំបាច់ត្រូវស្គាល់វត្ថុដែលគួរការក្សាទុក ទឹកដោះថ្លានេះ នៅល្មមការក្សាទុកប្រើជាប្រយោជន៍បាន ដូចជាប្រើជាថ្នាំសម្រាប់លាបជើងពួកទាសៈ ឬកម្មករក៏បាន ប្រើជាប្រេងចាក់ចង្កៀងក៏បាន លោកគ្រូពេទ្យកុំបានគិតសង្ស័យឡើយ រង្វាន់ថ្លៃថ្នាំរបស់លោកគ្រូពេទ្យមិន

ថយចុះទៅទ្បើយ ។ កាលនោះ ជីវកកោមារភច្ច បានព្យាបាលរោគ
ឃ្លីក្បាលរបស់ភរិយាលោកសេដ្ឋី ដែលបានឈឺមកវេយៈ ៧ ឆ្នាំឲ្យ
ជាបាន ដោយវិធីហឺតថ្នាំតាមច្រមុះ ត្រឹមតែមួយមុខហើយម្តងប៉ុណ្ណោះ
ក៏បាត់ទៅ ។ កាលភរិយាជាសះស្បើយពីរោគឃ្លីក្បាលហើយ បានឲ្យ
រង្វាន់ដល់ជីវកកោមារភច្ច ជាប្រាក់ ៤ ពាន់កហាបណៈ ។ គ្រានោះ
បុត្រារបស់សេដ្ឋីជ្រាបថា មាតាជារោគហើយ បានឲ្យរង្វាន់បន្ថែមទៀត
៤ ពាន់កហាបណៈ ។ ចំណែកកូនប្រសាស្រីបានជ្រាបថា ម៉ែក្មេក
ជារោគហើយ បានឲ្យរង្វាន់ប្រាក់បន្ថែមទៀត ៤ ពាន់កហាបណៈ ។
រីឯលោកសេដ្ឋីបានជ្រាបថា ភរិយារបស់ខ្លួនជារោគហើយ បានឲ្យរង្វាន់
បន្ថែមទៀត ៤ ពាន់កហាបណៈ ថែមទាំងបានឲ្យទាសាម្នាក់ ទាសីម្នាក់
រទេះសេះមួយ ដល់ជីវកកោមារភច្ច ។ កាលនោះ ជីវកកោមារភច្ច
បានទទួលប្រាក់រង្វាន់ទាំងអស់ ១៦.០០០ កហាបណៈ ទាសាម្នាក់
ទាសីម្នាក់ រទេះសេះមួយ គេបានឡើងជិះលើរទេះសេះធ្វើដំណើរចេញ
អំពីក្រុងសាកេត ទៅកាន់ក្រុងរាជគ្រឹះ ។

កាលគេធ្វើដំណើរមកដល់ក្រុងរាជគ្រឹះហើយ ទើបគេចូលទៅគាល់ព្រះអភយរាជកុមារ ហើយក្រាបទូលថា ព្រះករុណាថ្លៃវិសេស ប្រាក់ ១៦ ពាន់កហាបណៈ ទាសា ទាសី និងរទេះសេះមួយនេះ ជាទ្រព្យដែលទូលបង្គំ បានមកអំពីការធ្វើការងារលើកដំបូង សូមព្រះអង្គទ្រង់មេត្តាទទួលថ្លៃចិញ្ចឹមបីជាប់ទូលបង្គំចុះ ក្រាបទូល ។ គ្រានោះ ព្រះអភយ-រាជកុមារតបថា កុំឡើយជីវកៈ ទ្រព្យទាំងនេះ ចូរជារបស់កូនតែម្នាក់ហើយកូនចូរសង់ផ្ទះនៅក្នុងវាំងរបស់យើងចុះ ។ លំដាប់នោះ ជីវកកោ-មារកចូទទួលព្រះរាជបញ្ជាអំពីព្រះអភយរាជកុមារ ដែលជាព្រះបិតាចិញ្ចឹមថា ជាព្រះករុណាទិគុណក្រៃលែងក្រាបទូល ហើយគេបានសាងផ្ទះនៅក្នុងវាំង របស់ព្រះអភយរាជកុមារទៅ ។

ពេទ្យជីវកកោមារកចូ បានជួយព្យាបាលរោគឫសដូងបាតថ្វាយដល់ព្រះបាទពិម្ពិសារមហារាជ ៖

ក្នុងសម័យជាខាងក្រោយមក ព្រះបាទពិម្ពិសារ ជាអគ្គរាជក្នុងដែនមគធរដ្ឋ ទ្រង់ប្រឈួនរោគឫសដូងបាតត្រង់ទ្វារធំជាទម្ងន់ ព្រះកូសា

ប្រឡាក់ទៅដោយព្រះលោហិត ពពួកស្រីស្នំទាំងឡាយ ឃើញដូច្នោះ
ហើយ ទើបនាំគ្នានិយាយចំអកឲ្យដល់ព្រះរាជាថា ឥឡូវនេះ ព្រះករុណា
ជីវិតតម្កល់លើត្បូងទ្រង់មានរដូវហើយ មិនយូរប៉ុន្មាន ព្រះអង្គនឹងមាន
បុត្រ ។ គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់ខ្មាសអៀនពាក្យចំអករបស់
ពួកស្រីស្នំទាំងនោះ ទើបត្រាស់ប្រាប់ឲ្យអភយរាជកុមារបានជ្រាប ហើយ
ព្រះអង្គមានព្រះរាជតម្រាស់បញ្ជាឲ្យអភយរាជកុមារ រកពេទ្យមកព្យាបាល
ព្រះអង្គ ។ លំដាប់នោះ ព្រះអភយរាជកុមារក្រាបបង្គំទូលថា ព្រះករុណា
ថ្លៃវិសេស ជីវក:ជាពេទ្យប្រចាំទូលព្រះបង្គំ ជាពេទ្យកំលោះ ទ្រទ្រង់
នូវគុណធម៌ គេអាចព្យាបាលព្រះរាជបិតាបាន ព្រះអង្គ ។ គ្រានោះ
ព្រះបាទពិម្ពិសារទ្រង់មានព្រះរាជបញ្ជាថា **ចា អភ័យ** បើដូច្នោះ កូនចូរ
ប្រាប់ពេទ្យជីវក: ឲ្យមកព្យាបាលបិតាចុះ ។ កាលនោះ ព្រះអភយ-
រាជកុមារប្រាប់ជីវកកោមារភច្ចថា ម្នាលជីវក: កូនចូរទៅជួយព្យាបាល
ឫសដូងបាត ថ្វាយដល់ព្រះករុណាជីវិតតម្កល់លើត្បូងផងចុះកូន (ព្រះ
បាទពិម្ពិសារ) ។ គ្រានោះ ជីវកកោមារភច្ចក្រាបទូលស្នងព្រះរាជបញ្ជា

ករុណាថ្ងៃវិសេស ហើយគេប្រើក្រចកកាត់ថ្នាំ ដើរទៅកាន់រាជសម្នាក់
កាលគេទៅដល់ហើយ ទើបចូលទៅគាល់ព្រះបាទពិម្ពិសារមហារាជ
ហើយក្រាបបង្គំទូលថា បពិត្រព្រះករុណាជីវិតម្ភល់លើត្បូង ទូលបង្គំ
ជាខ្ញុំ សូមព្រះរាជានុញ្ញាត ដើម្បីពិនិត្យរោគថ្វាយព្រះអង្គផង ក្រាបទូល ។
ហើយកាលគេបានទទួលព្រះរាជានុញ្ញាតហើយ ទើបព្យាបាលរោគ
ឫសដូងបាតរបស់ព្រះបាទពិម្ពិសារ ដោយការលាបថ្នាំត្រឹមតែម្តង
ក៏ទ្រង់ជាព្រះប្រឈួនទៅ រោគឫសដូងបាតនៅត្រង់ទ្វារធំនោះ ។ កាល
ព្រះបាទពិម្ពិសារ ទ្រង់ជាព្រះប្រឈួនហើយ ទើបមានព្រះរាជតម្រាស់
បញ្ជាឲ្យស្ត្រី ៥០០ នាក់ ដែលតាក់តែងដោយគ្រឿងអលង្ការទាំងអស់
ឲ្យដោះគ្រឿងអលង្ការចេញ ហើយខ្ចប់ជាកញ្ចប់មកគរទុក ហើយមាន
ព្រះរាជតម្រាស់ជាមួយពេទ្យជីវកកោមារភច្ចថា នេះជីវក: គ្រឿងប្រដាប់
ទាំងអស់របស់ស្ត្រី ៥០០ នាក់ទាំងនេះ យើងឲ្យដល់អ្នក ចូរអ្នកទទួល
យកចុះ ។

គ្រានោះ ពេទ្យជីវកកោមារភច្ច ក្រាបបង្គំទូលថា កុំឡើយ

ព្រះអង្គ សូមព្រះអង្គទ្រង់មេត្តាប្រោសរឭកថា នេះជាតួនាទីរបស់ទូលព្រះបង្គំចុះ ព្រះអង្គ ។ ព្រះបាទពិម្ពិសារទ្រង់ព្រះតម្រិះថា ប្រសិនបើជីវកកោមារភច្ចទទួលយកគ្រឿងប្រដាប់ទាំងពួងនេះទៅ យើងនឹងតែងតាំងគេទុកក្នុងតំណែងល្មមប្រមាណ ប្រសិនបើគេមិនទទួលយកគ្រឿងប្រដាប់ទាំងពួងទាំងអស់នេះទេ យើងនឹងតែងតាំងគេឲ្យជាអ្នកស្និទ្ធស្នាលនៅខាងក្នុងរាជវាំង ។ កាលពេទ្យជីវកកោមារភច្ចក្រាបបង្គំទូលបដិសេធមិនព្រមទទួលគ្រឿងប្រដាប់ទាំងនោះ ក៏គាប់ព្រះរាជហឫទ័យរបស់ព្រះបាទពិម្ពិសារៗ ទើបទ្រង់ស្រឡាញ់ ហើយបានព្រះរាជទានផ្ទះដែលបានបំពាក់ដោយគ្រឿងប្រដាប់ទាំងពួង មានសួនអម្ពវន(ចម្ការស្វាយ)ស្រុកសួយ ដែលមានសួយមួយសែនប្រចាំឆ្នាំ និងសក្ការៈដទៃទៀតដល់ជីវកកោមារភច្ច ហើយមានព្រះរាជឱង្ការថា បើយ៉ាងនោះ ជីវកៈចូរទំនុកបម្រុងយើង និងព្រះញាតិ ព្រមទាំងភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធានផងចុះ ។ ពេទ្យជីវកកោមារភច្ចក្រាបបង្គំទូលទទួលស្នងព្រះរាជឱង្ការថា ទូលបង្គំសូមទទួលព្រះរាជឱង្ការរបស់ព្រះអង្គ ក្រាបទូល ។

ពេទ្យជីវកកោមារភច្ច ជួយព្យាបាលឲ្យសេដ្ឋីក្រុងរាជគ្រឹះ ៖

ក្នុងសម័យនោះ សេដ្ឋីនគររាជគ្រឹះ អាពាធរោគឈឺក្បាលមករហូត ៧ ឆ្នាំហើយ ។ មានគ្រូពេទ្យដែលជាអាចារ្យទិសាបាមោក្ខធំៗជាច្រើននាក់មកព្យាបាល តែមិនអាចព្យាបាលឲ្យជាសះស្បើយបានបានត្រឹមតែយកប្រាក់ថ្លៃរង្វាន់ថ្នាំទៅតែប៉ុណ្ណោះ ។ តមក សេដ្ឋីបានត្រូវពួកគ្រូពេទ្យបដិសេធមិនព្រមទៅព្យាបាលឲ្យ ។ គ្រូពេទ្យពួកខ្លះបានព្យាករណ៍ទុកថា លោកសេដ្ឋីនេះ ៧ ថ្ងៃទៀត នឹងធ្វើអនិច្ចកម្ម ។ កាលនោះ ពួកកុដុម្ពិកនគររាជគ្រឹះ បានមានចរិវិតក្តថា លោកសេដ្ឋីនេះជាអ្នកមានឧបការៈច្រើនដល់ព្រះករុណាជីវិតតម្កល់លើត្បូងនិងអ្នកនិគមតែលោកត្រូវពួកគ្រូពេទ្យបដិសេធមិនព្រមទៅព្យាបាលឲ្យ ទើបនាំគ្នានឹកដល់ពេទ្យជីវកកោមារភច្ចថា ពេទ្យជីវកកោមារភច្ច ជាពេទ្យហ្លួងនៅវ័យកំលោះ ទ្រទ្រង់នូវគុណធម៌ ពួកយើងគួរក្រាបបង្គំទូល សូមពេទ្យជីវកកោមារភច្ច អំពីព្រះករុណាជីវិតតម្កល់លើត្បូង ដើម្បីមកព្យាបាលឲ្យលោកសេដ្ឋី កាលគិតឃើញដូច្នេះហើយ ពួកកុដុម្ពិកទាំងនោះ

ទើបនាំគ្នាចូលទៅគាល់ព្រះបាទពិម្ពិសារក្រាបទូលថា បពិត្រព្រះករុណា ជីវិតតម្កល់លើតួង លោកសេដ្ឋីនេះមានឧបការៈច្រើនដល់ទូលបង្គំ និងអ្នកនិគម តែឥឡូវនេះ ត្រូវពួកគ្រូពេទ្យជាច្រើន បដិសេធមិនហ៊ានទៅព្យាបាលឲ្យ ហើយបានពោលព្យាករណ៍ទុកថា លោកសេដ្ឋីនឹងដល់នូវអនិច្ចកម្មក្នុងថ្ងៃទី ៥ ឬក្នុងថ្ងៃទី ៧ មិនខាន ហេតុដូច្នេះ ទូលបង្គំសូមព្រះរាជទានព្រះបរមរាជវាវោកាស សូមព្រះអង្គទ្រង់ព្រះមេត្តាមានព្រះរាជឱង្ការបញ្ជាពេទ្យជីវក: ដើម្បីឲ្យទៅជួយព្យាបាលលោកសេដ្ឋីនោះផង់ចុះ ព្រះអង្គ ។

គ្រានោះ ព្រះបាទពិម្ពិសារ មានព្រះរាជតម្រាស់បញ្ជាឲ្យពេទ្យជីវកកោមារភច្ចថា ម្នាលជីវក: អ្នកចូរទៅជួយព្យាបាលឲ្យលោកសេដ្ឋីនោះផង់ចុះ ។ លំដាប់នោះ ពេទ្យជីវកកោមារភច្ចក្រាបបង្គំទូលទទួលស្នងព្រះរាជឱង្ការថា ករុណាថ្លៃវិសេស ហើយទើបទៅកលោកសេដ្ឋីកាលទៅដល់ហើយ បានសង្កេតមើលអាការដែលខុសប្លែករបស់លោកសេដ្ឋី ហើយបានសួរលោកសេដ្ឋីថា លោកសេដ្ឋី បើខ្ញុំព្យាបាលលោក

ឲ្យជារោគ លោកឲ្យរង្វាន់អ្វីដល់ខ្ញុំ ? ពេលនោះ លោកសេដ្ឋីឆ្លើយថា បពិត្រលោកអាចារ្យ ខ្ញុំនឹងឲ្យទ្រព្យសម្បត្តិទាំងអស់ដល់លោក ហើយខ្លួនរបស់ខ្ញុំ នឹងព្រមធ្វើជាទាសៈរបស់លោក ។ រីឯពេទ្យជីវកកោមារភច្ចៈ បានសួរលោកសេដ្ឋីថា លោកសេដ្ឋី តើលោកអាចដេកផ្អៀងតែម្ខាងអស់ ៧ ខែឬទេ ? លោកសេដ្ឋីតបថា លោកអាចារ្យ ខ្ញុំអាចដេកផ្អៀងតែម្ខាងរហូត ៧ ខែបាន ។ ជីវកកោមារភច្ចៈ បានសួរទៀតថា លោកសេដ្ឋី លោកអាចដេកផ្អៀងម្ខាងទៀតអស់ ៧ ខែទៀតបានឬទេ ? លោកសេដ្ឋីតបថា លោកអាចារ្យ ខ្ញុំអាចដេកផ្អៀងម្ខាងទៀត ៧ ខែទៀតបាន ។ គ្រានោះ ពេទ្យជីវកកោមារភច្ចៈ បានសួរលោកសេដ្ឋីទៀតថា លោកសេដ្ឋី លោកអាចដេកផ្ងារបាន ៧ ខែទៀតបានឬទេ ? លោកសេដ្ឋីតបថា លោកអាចារ្យ ខ្ញុំអាចដេកផ្ងារ ៧ ខែទៀតបាន ។ លំដាប់នោះ ពេទ្យជីវកកោមារភច្ចៈបានឲ្យលោកសេដ្ឋីដេកលើគ្រែ ហើយចងក្ងាប់នឹងគ្រែ ទើបវះកាត់ស្បែកក្បាល ហើយពន្លះស្បែកក្បាលចេញល្មមបើកលលាដ៍ក្បាល បានស្រួលហើយ បានបើកលលាដ៍ក្បាល នាំយក

សត្វជង្ហឹវចេញពីក្បាលហើយប្រាប់ឲ្យមហាជនមើលថា អ្នកទាំងឡាយ
ចូរមើល សត្វជង្ហឹវពីរក្បាលនេះ មួយមានខ្លួនតូច មួយទៀតមានខ្លួនធំ
ហើយពពួកគ្រូពេទ្យដែលទាយថា លោកសេដ្ឋីនឹងធ្វើមរណកាលក្នុងថ្ងៃទី
៥ នោះ ព្រោះគ្រូពេទ្យទាំងនោះបានឃើញសត្វជង្ហឹវធំនេះ ដោយវានឹង
ចោះស៊ីខួរក្បាលរបស់លោកសេដ្ឋី អស់ក្នុងថ្ងៃទី ៥ កាលវាស៊ីខួរក្បាល
អស់ហើយ លោកសេដ្ឋីត្រូវតែធ្វើអនិច្ចកម្ម សត្វជង្ហឹវខ្លួនធំនេះឯង ដែល
ពួកគ្រូពេទ្យទាំងនោះបានទាយហើយថា លោកសេដ្ឋីនឹងធ្វើមរណកាល
ក្នុងថ្ងៃទី ៥ ការទាយនោះ ជាការត្រឹមត្រូវ ។ ចំណែកពួកគ្រូពេទ្យ
ដែលព្យាករណ៍ថា លោកសេដ្ឋីនឹងធ្វើអនិច្ចកម្មក្នុងថ្ងៃទី ៧ នោះ ព្រោះ
ពួកគ្រូពេទ្យទាំងនោះ បានឃើញសត្វជង្ហឹវខ្លួនតូចនេះ ដោយវាចោះខាំស៊ី
ខួរក្បាលរបស់លោកសេដ្ឋី អស់ក្នុងថ្ងៃទី ៧ កាលវាស៊ីខួរក្នុងក្បាល
អស់ហើយ លោកសេដ្ឋីនឹងធ្វើអនិច្ចកម្ម។ ព្រោះសត្វជង្ហឹវខ្លួនតូចនេះ
ឯង ដែលពួកគ្រូពេទ្យទាំងនោះបានឃើញ ហើយបានព្យាករណ៍ទុកថា
លោកសេដ្ឋីនឹងធ្វើអនិច្ចកម្មក្នុងថ្ងៃទី ៧ នោះ ការព្យាករណ៍ទុកនោះ

ជាការត្រឹមត្រូវហើយ ។

តអំពីនោះ គ្រូពេទ្យជីវកកោមារភច្ចបានរៀបចំបិទថ្នេរលាជ័ក្បាល ហើយដេរស្នាមកាត់ត្រង់ស្បែកក្បាល ហើយលាបថ្នាំផ្សះមុខរបួសរួចហើយ ឲ្យលោកសេដ្ឋីដេកផ្អៀងនៅលើគ្រែ ៧ ខែ ។ កាលកន្លងទៅបានមួយសប្តាហ៍ លោកសេដ្ឋីបានពោលជាមួយពេទ្យជីវក-កោមារភច្ចថា លោកអាចារ្យ ខ្ញុំមិនអាចដេកផ្អៀងតែម្នាង រហូតអស់ ៧ ខែបានទេឬយ ។ គ្រានោះ ជីវកកោមារភច្ចបានពោលទាក់ទងនឹងពាក្យដែលសន្យាគ្នាទុកថា លោកសេដ្ឋី លោកបានយល់ព្រមជាមួយនឹងខ្ញុំទុកថា លោកអាចារ្យ ខ្ញុំអាចដេកផ្អៀងតែម្នាងរហូតអស់ ៧ ខែបានដូច្នោះមិនមែនឬ ? លំដាប់នោះ លោកសេដ្ឋីពោលព្រមទទួលសេចក្តីពិតថា ខ្ញុំយល់ព្រមទទួលពាក្យជាមួយលោកអាចារ្យពិតមែន តែទោះជាខ្ញុំស្ងាប់ ខ្ញុំក៏មិនអាចដេកផ្អៀងតែម្នាង រហូតអស់ ៧ ខែបានដែរ ។ ពេលនោះ ពេទ្យជីវក:បានធ្វើតាមពាក្យសំណូមពររបស់លោកសេដ្ឋី តែបានពោលជាមួយលោកសេដ្ឋីតទៅទៀតថា លោកសេដ្ឋី បើដូច្នោះ

សូមលោកដេកផ្អៀងចំហៀងម្ខាងទៀត រហូតអស់ ៧ ខែចុះ ។កាលកន្លងទៅបានមួយសប្តាហ៍ លោកសេដ្ឋីក៏បាននិយាយជាមួយនឹងពេទ្យជីវក:ថា លោកអាចារ្យ ខ្ញុំមិនអាចដេកផ្អៀងចំហៀងម្ខាងទៀតបានរហូត ៧ ខែទេ ។ លំដាប់នោះ ពេទ្យជីវក: បានពោលរឭកដល់ពាក្យដែលសន្យាគ្នាទុកថា លោកសេដ្ឋី លោកបានយល់ព្រមជាមួយនឹងខ្ញុំទុកថា លោកអាចារ្យ ខ្ញុំអាចដេកផ្អៀងមួយចំហៀងទៀត រហូតបាន ៧ ខែ ដូច្នោះមិនមែនឬ ? ពេលនោះ លោកសេដ្ឋីពោលព្រមទទួលថា ខ្ញុំយល់ព្រមទទួលពាក្យលោកអាចារ្យពិតមែន តែទោះជាខ្ញុំស្លាប់ ខ្ញុំក៏មិនអាចដេកផ្អៀងម្ខាងទៀតនេះរហូតអស់ ៧ ខែបានដែរ ។ គ្រានោះ ទើបពេទ្យជីវក: បានធ្វើតាមពាក្យសំណូមពររបស់លោកសេដ្ឋី តែបានពោលជាមួយលោកសេដ្ឋីតទៅទៀតថា លោកសេដ្ឋី បើដូច្នោះ សូមលោកដេកផ្ងារតែម្ខាង រហូតអស់ ៧ ខែ ទៀតចុះ ។ កាលកន្លងទៅបានមួយសប្តាហ៍ ជាពេលវេលាដែលលោកសេដ្ឋីដេកផ្ងារតែម្ខាងរហូតតមក លោកសេដ្ឋី បានពោលជាមួយនឹងពេទ្យជីវក:ថា លោកអាចារ្យ

ខ្ញុំមិនអាចដេកផ្ងារតែម្យ៉ាងរហូតអស់ ៧ ខែបានទេ ។ លំដាប់នោះ ពេទ្យជីវក: បាននិយាយឲ្យលោកសេដ្ឋី នឹកដល់ពាក្យដែលបានសន្យាគ្នាទុកថា លោកសេដ្ឋីបានទទួលពាក្យជាមួយខ្ញុំទុកថា លោកអាចារ្យ ខ្ញុំអាចដេកផ្ងារតែម្យ៉ាង រហូតអស់ ៧ ខែ បាន ដូច្នេះមិនមែនឬ ? ពេលនោះ លោកសេដ្ឋីបានពោលព្រមទទួលថា លោកអាចារ្យ ខ្ញុំបានសន្យាជាមួយលោកអាចារ្យទុកពិតមែន តែទោះជាខ្ញុំស្ងាប់ ខ្ញុំក៏មិនអាចផ្ងារតែម្យ៉ាងរហូតអស់ ៧ ខែបានដែរ ។

គ្រានោះ ពេទ្យជីវកកោមារភច្ចបានពោលថា លោកសេដ្ឋី បើខ្ញុំមិនប្រាប់លោកទុកយ៉ាងនេះ លោកក៏មិនអាចនឹងដេកបានយូរប៉ុណ្ណេះតែខ្ញុំជ្រាបមុនហើយថា លោកសេដ្ឋីនឹងជាសះស្បើយក្នុងសប្តាហ៍ទី ៣ ព្រោះដូច្នោះ សូមលោកក្រោកឡើងចុះ លោកជាហើយ តើលោកនឹងឲ្យរង្វាន់អ្វីដល់ខ្ញុំ ? លំដាប់នោះ ទើបលោកសេដ្ឋីពោលថា លោកអាចារ្យ ខ្ញុំសូមលើកទ្រព្យសម្បត្តិទាំងអស់ឲ្យលោក ទាំងខ្លួនខ្ញុំក៏សូមជាទាស:បម្រើលោកដែរ ។ ពេលនោះ ពេទ្យជីវក:បានពោលហាមថា

កុំឡើយលោកសេដ្ឋី លោកកុំលើកទ្រព្យសម្បត្តិទាំងអស់នោះឲ្យដល់ខ្ញុំឡើយ ហើយលោកក៏មិនចាំបាច់មកធ្វើទាស:បម្រើខ្ញុំដែរ តែសូមលោកថ្វាយទ្រព្យ ដល់ព្រះករុណាជីវិតតម្កល់លើត្បូងមួយសែនកហាបណ: ហើយឲ្យខ្ញុំមួយសែនកហាបណ:ក៏ល្មមហើយ ។ កាលលោកសេដ្ឋីជារោគស្អាហើយ ទើបបានថ្វាយទ្រព្យដល់ព្រះបាទពិម្ពិសារមួយសែនកហាបណ: មួយសែនកហាបណ:ទៀត ប្រគល់ឲ្យពេទ្យជីវកកោមារភច្ចតាមពាក្យណែនាំរបស់ពេទ្យជីវកកោមារភច្ច ។

ពេទ្យជីវកកោមារភច្ច បានជួយព្យាបាលបុត្ររបស់លោកសេដ្ឋីដែលមានជំងឺសាច់ដុះក្នុងពោះវៀន ៖

មានបុត្ររបស់លោកសេដ្ឋីម្នាក់ នៅក្នុងក្រុងពារាណសី ដែលជាអ្នកលេងកីឡាលោតហាក់ត្រឡប់ខ្លួន បានមានជំងឺដុះសាច់ក្នុងពោះវៀន មិនថាបបរ មិនថាបាយ ដែលបុត្ររបស់លោកសេដ្ឋីនោះ ទទួលទានទៅហើយ មិនរលាយ ឧច្ចារបស្សាវៈ បន្ទោបង់ចេញមកមិនស្រួល ឬបន្ទោបង់មិនសូវចេញ ។ បុត្ររបស់លោកសេដ្ឋីមានអាការស្គាំងស្គមចុះ

មានពណ៌សម្បុរសៅហ្មងស្វេកស្វាំង មានសរសៃប្រាកដពេញខ្លួន ។
សម័យនោះឯង លោកសេដ្ឋីនៅក្នុងក្រុងពារាណសី មានសេចក្តីត្រិះរិះថា
បុត្ររបស់យើង មានអាការរោគធ្ងន់ណាស់ ទើបលោកសេដ្ឋីគិតថា
យើងនឹងទៅកាន់ក្រុងរាជគ្រឹះ ហើយក្រាបបង្គំទូលចំពោះព្រះបាទពិម្ពិសារ
សូមឲ្យព្រះអង្គប្រទានពេទ្យជីវកកោមារភច្ច ឲ្យមកជួយព្យាបាលដល់
បុត្ររបស់យើង ។ កាលលោកសេដ្ឋី គិតឃើញដូច្នោះហើយ បានធ្វើ
ដំណើរទៅកាន់ក្រុងរាជគ្រឹះ ចូលទៅគាល់ព្រះបាទពិម្ពិសារ ហើយ
ក្រាបបង្គំទូលថា បពិត្រព្រះករុណាជីវិតត្រូវលើសួង បុត្រខ្ញុំទូល
បង្គំទទួលទានបបរបាយហើយ មិនរលាយ ឧច្ចារបស្សាវៈ បន្ទោបង់
ចេញមកមិនស្រួល មានអាការស្ទាំងស្ទម មានពណ៌សម្បុរសៅហ្មង
ស្វេកស្វាំង មានសរសៃប្រាកដពេញខ្លួន ទូលបង្គំសូមព្រះបរមរាជវរោ-
កាស សូមព្រះករុណាជីវិតត្រូវលើសួង ព្រះអង្គមានព្រះរាជឱង្ការ
បញ្ជាឲ្យពេទ្យជីវកកោមារភច្ចទៅ ដើម្បីជួយព្យាបាលបុត្រខ្ញុំទូល
ព្រះបង្គំផងចុះ ព្រះអង្គ ។ គ្រានោះ ព្រះបាទពិម្ពិសារ បានមាន

ព្រះរាជតម្រាស់ប្រាប់ពេទ្យជីវកកោមារភច្ចថា ទៅចុះបាជីវក: អ្នកចូរទៅកាន់ក្រុងពារាណសី ហើយអ្នកទៅជួយព្យាបាលបុត្ររបស់លោកសេដ្ឋី នៅក្នុងក្រុងពារាណសីផង ។ លំដាប់នោះ ពេទ្យជីវកកោមារភច្ចក្រាបង្គំទូលព្រះរាជបញ្ជា ហើយធ្វើដំណើរទៅកាន់ក្រុងពារាណសី ហើយបានចូលទៅរកបុត្ររបស់លោកសេដ្ឋី កាលបានទៅជួបហើយបានពិនិត្យពិចារណាមើលអាការរោគខុសប្លែករបស់សេដ្ឋីបុត្រ នៅក្នុងក្រុងពារាណសីនោះហើយបានហៅប្រជាជនឲ្យចេញទៅឲ្យផុតពីបរិវេណនោះ ឲ្យភរិយារបស់សេដ្ឋីបុត្រមកនៅខាងមុខ ហើយទើបធ្វើការវះពោះនាំសាច់ដុះត្រង់ពោះវៀនចេញមក ឲ្យភរិយារបស់សេដ្ឋីមើល ព្រមទាំងនិយាយថា អ្នកចូរមើលរោគសាច់ដុះរបស់ស្វាមីនាង ព្រោះរោគសាច់នេះឯង ដែលធ្វើឲ្យស្វាមីរបស់នាង ទទួលទានបបរ ឬបាយហើយមិនរលាយ បន្ទោបង់ឧច្ចារបស្សាវៈចេញមកមិនស្រួល ទើបធ្វើឲ្យកើតអាការស្គាំងស្គម មានពណ៌សម្បុរស្វេកស្វាំង មានសរសៃប្រាកដពេញខ្លួន ហើយទើបកាត់សាច់ដុះក្នុងពោះវៀនចេញមក ហើយញាត់

ពោះវៀនត្រឡប់ចូលទៅក្នុងពោះដូចដើមវិញ បានដេរស្បែកពោះឲ្យល្អ លាបថ្នាំរក្សាមុខដំបៅនៅត្រង់កន្លែងវះកាត់នោះ ។

ក្នុងវេលាតមកមិនយូរ បុត្ររបស់សេដ្ឋីនៅក្នុងក្រុងពារាណសីនោះ ក៏ជាសះស្បើយពីជំងឺ ជាអ្នកមានអាការជាប្រក្រតីវិញ ។ គ្រានោះ សេដ្ឋីដែលជាបិតាគិតថា បុត្ររបស់យើងជាសះស្បើយហើយ ផុតអំពីអន្តរាយហើយ ទើបលោកឲ្យប្រាក់ ១ ម៉ឺន ៦ ពាន់កហាបណៈ ដល់ពេទ្យជីវកកោមារភច្ច ។ ចំណែកពេទ្យជីវកកោមារភច្ច បានទទួលប្រាក់ ១ ម៉ឺន ៦ ពាន់កហាបណៈហើយ ទើបធ្វើដំណើរត្រឡប់ទៅកាន់ក្រុងរាជគ្រឹះវិញ ។

មានរឿង ដែលពេទ្យជីវកកោមារភច្ច បានក្រាបទូលសួរព្រះមុនីទាក់ទងនឹងរឿងសាច់ និងត្រី ដែលមិនមែនជារបស់ត្រូវហាមសម្រាប់ភិក្ខុទាំងឡាយ ដែលមានសម្តែងទុកនៅក្នុងបាលី **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក:** ក្នុង **ជីវកសូត្រ** និងក្នុង **អដ្ឋកថាបបញ្ចសូទនី** ថា ៖

សម័យមួយ ព្រះលោកនាថ ប្រថាប់នៅត្រង់ចម្ការស្វាយរបស់

ពេទ្យជីវកកោមារភច្ច ដែលនៅជិតក្រុងរាជគ្រឹះ ។ គ្រានោះ ពេទ្យជីវក: បានចូលទៅគាល់ព្រះមានបុណ្យ ថ្វាយបង្គំរួចហើយ អង្គុយនៅក្នុងទីដ៏សមគួរ កាលអង្គុយរៀបរយហើយ ទើបក្រាបទូលឡើងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់មកថា បុគ្គលទាំងឡាយ បានសម្លាប់សត្វទុក ចំពោះព្រះសមណគោតម ទាំងព្រះសមណគោតមក៏ទ្រង់ដឹងដែរ ហើយព្រះអង្គក៏ទ្រង់ឆាន់សាច់ ដែលគេធ្វើប្រគេនចំពោះនេះចាត់ជាកម្ម ព្រោះអាស្រ័យសាច់នោះ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយនោះ ដែលបានពោលដូច្នេះ ឈ្មោះថាពោលតាមពាក្យរបស់ព្រះជិនស្រី ឈ្មោះថា មិនបានពោលបង្កាច់ព្រះមហាមុនី ដោយពាក្យមិនពិត ឈ្មោះថា ដោះស្រាយតាមសមគួរដល់ធម៌ ឈ្មោះថាពោលតាមធម៌ មិនដល់នូវហាន: ដែលគួរតិះដៀលទេឬ ព្រះអង្គ ? គ្រានោះ ព្រះទសពល ត្រាស់អធិប្បាយថា ជីវក: ជនពួកណា បានពោលថា បុគ្គលបានសម្លាប់សត្វទុកចំពោះព្រះសមណគោតម ទាំងព្រះសមណ-គោតមក៏ទ្រង់ដឹង ហើយបានសាច់ដែលគេធ្វើប្រគេនចោះចំពោះនោះ

មិនឈ្មោះថាពោលតាមសម្តីរបស់តថាគត ឈ្មោះថាបានពោលបង្កាច់តថាគត ដោយពោលពាក្យមិនពិតតថាគតពោលថា សាច់ដែលមិនគួរបរិភោគមាន ៣ ប្រការ គឺ ១- សាច់ដែលបានឃើញ បានដល់ **សាច់ត្រី** ដែលភិក្ខុបានឃើញថា គេសម្លាប់ដើម្បីខ្លួន ២- សាច់ដែលបានឮ បានដល់ **សាច់ត្រី** ដែលភិក្ខុបានឮថា គេសម្លាប់ដើម្បីប្រគេន ដល់ភិក្ខុទាំងឡាយ ៣- សាច់ដែលសង្ស័យ បានដល់ **សាច់ត្រី** ដែលសង្ស័យដោយការបានឃើញ ឬបានឮថា គេសម្លាប់ដើម្បីប្រគេនដល់ភិក្ខុទាំងឡាយ ។

សាច់ត្រីដែលភិក្ខុបានឃើញ បានឮ បានសង្ស័យថា គេសម្លាប់ដើម្បីភិក្ខុទាំងឡាយ មិនគួរទទួលទុកឆាន់ ។ ចំណែកសាច់ដែលគួរបរិភោគនោះ មាន ៣ ប្រការគឺ ១- សាច់ដែលមិនបានឃើញ ២- សាច់ដែលមិនបានឮ ៣- សាច់ដែលមិនសង្ស័យ (ព្រោះថា បើភិក្ខុមានសេចក្តីសង្ស័យហើយ នៅតែចចេសធ្វើក៏ត្រូវអាបត្តិ) ។ ភិក្ខុមិនបានឃើញ មិនបានឮ និងមិនមានសេចក្តីសង្ស័យថា គេសម្លាប់ដើម្បីប្រគេនភិក្ខុ

ទាំងឡាយ តែគេសម្ងាប់ដើម្បីបរិភោគខ្លួនឯង បើដូច្នោះ សាច់ត្រីនោះ ជារបស់ដែលភិក្ខុទទួលប្រគេនទុកឆាន់បាន ។ ម្នាលជីវក: ភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ អាស្រ័យនៅក្នុងស្រុក ឬក្នុងនិគមកន្លែងណានីមួយ ក៏ដោយ ដែលជាអ្នកមានមេត្តាចិត្តផ្សាយទៅកាន់ទិសទាំងពួង ហើយ នៅដោយមេត្តាចិត្តយ៉ាងខ្ជាប់ខ្ជួន ជាចិត្តធំរកប្រមាណមិនបាន ជាចិត្ត ដែលមិនមានពៀរ មិនមានព្យាបាទ គហបតី ឬបុត្ររបស់គហបតី ចូលទៅរកភិក្ខុនោះហើយ ក៏បាននិមន្តភិក្ខុនោះឲ្យទទួលចង្ហាន់ក្នុងថ្ងៃស្អែក កាលភិក្ខុនោះទទួលការនិមន្ត ។ លុះដល់ព្រឹកថ្ងៃស្អែកឡើងភិក្ខុនោះ ស្លៀកស្បង់ ហើយគ្រងចីវរ កាន់បាត្រចូលទៅត្រង់ផ្ទះរបស់គហបតី ឬបុត្ររបស់គហបតីដែលនិមន្តហើយ ។ កាលគហបតី ឬបុត្ររបស់គហបតី បានអង្គាសចង្ហាន់បិណ្ឌបាតដ៏ប្រណីតៗ ប្រគេនដល់ភិក្ខុនោះ ។ ចំណែកភិក្ខុនោះមិនបានគិតថា សូមឲ្យគហបតី ឬបុត្ររបស់គហបតី ចូរប្រគេនយើងដោយអាហារដ៏ប្រណីត ក្នុងពេលឥឡូវនេះ ថែមទាំង ជាអ្នកមិនជាប់ជំពាក់ ជាមួយនឹងអាហារដ៏ប្រណីតនោះ តែជាអ្នកបាន

សម្ដីឯយើញទោសជានិច្ច ក្នុងអាហារនោះ ជាអ្នកមានបញ្ញាគិតដើម្បីលះបង់ជានិច្ច ។

ម្នាលជីវក: អ្នកគិតថា កិក្ខុនោះនឹងមានចេតនា (តាំងចិត្ត) ដែលនឹងធ្វើខ្លួនឬធ្វើឲ្យអ្នកដទៃ ទាំងខ្លួនឯង និងអ្នកដទៃឲ្យដល់សេចក្ដីលំបាកក្នុងគ្រានោះឬទេ ? គ្រានោះ ពេទ្យជីវកកោមារភច្ច ក្រាបទូលតបថា បពិត្រព្រះភគវា កិក្ខុមិនបានមានចេតនាយ៉ាងនោះទេ ព្រះអង្គ ។ ព្រះសុគតត្រាស់សួរថា ម្នាលជីវក: កិក្ខុនោះបរិភោគអាហារ មិនមានទោសក្នុងគ្រានោះមិនមែនឬ ? ពេលនោះ ពេទ្យជីវក:ក្រាបទូលតបថា ពិតហើយព្រះអង្គ ខ្ញុំព្រះករុណាស្ដាប់មកថា ព្រហ្មវមែងនៅក្នុងមេត្តាធម៌ ខ្ញុំព្រះករុណាឃើញជាក់ច្បាស់ហើយ ព្រោះព្រះភគវា ទ្រង់ជាអ្នកនៅដោយព្រះមេត្តាពិតមែន ។ លំដាប់នោះ ព្រះសយម្ភូត្រាស់ថា ម្នាលជីវក: រាគ: ទោស: មោហ: តថាគតបានលះបង់ហើយ បានកាត់ឫសគល់ជាច់ហើយ បានធ្វើឲ្យដូចជាត្នោតកំបុត.ក ធ្វើមិនឲ្យកើតតទៅទៀតឡើយ ម្នាលជីវក: បើអ្នកពោលព្រោះសំដៅពាក្យនេះ ជាការត្រឹមត្រូវពិតមែន ។

ពេទ្យជីវក:ក្រាបទូលថា បពិត្រព្រះភគវា ខ្ញុំព្រះករុណានឹងពោលសំដៅដល់ពាក្យនោះដែរ ព្រះអង្គ ព្រោះថា ព្រះមានជោគជាអ្នកអស់ទៅនៃរាគ: ទោស: មោហ: ថែមទាំងសម្លាប់ដោយធ្វើមិនឲ្យមានតទៅទៀត ។ គ្រានោះ ព្រះមុនីត្រាស់ថា ម្នាលជីវក: អ្នកដែលសម្លាប់សត្វឧទ្ទិសចំពោះតថាគត ឬចំពោះសាវ័ករបស់តថាគត រមែងទទួលបាបច្រើនដោយហេតុ ៥ ប្រការគឺ ១- គហបតីនោះពោលថា ចូរទៅនាំសត្វមួយនោះមក ហើយសម្លាប់សត្វនោះ ឧទ្ទិសចំពោះតថាគត ឬចំពោះសាវ័ករបស់តថាគត រមែងបានទទួលបាបច្រើន នេះជាហេតុទីមួយ ២- គហបតីនោះពោលថា សត្វនោះត្រូវចងភ្ជាប់ដឹកមក ធ្វើឲ្យសត្វនោះទទួលទុក្ខ ហើយសម្លាប់សត្វនោះ ឧទ្ទិសចំពោះតថាគត ឬចំពោះសាវ័ករបស់តថាគត រមែងបានទទួលបាបច្រើន នេះជាហេតុទីពីរ ៣- គហបតីនោះពោលថា អ្នកចូរសម្លាប់សត្វនោះ ហើយសម្លាប់សត្វនោះ ឧទ្ទិសចំពោះតថាគត ឬចំពោះសាវ័ករបស់តថាគត រមែងបានទទួលបាបច្រើន នេះជាហេតុទីបី ៤- កាលសត្វនោះត្រូវសម្លាប់ហើយៗ សម្លាប់សត្វនោះ ឧទ្ទិសចំពោះ

តថាគត ឬចំពោះសាវ័ករបស់តថាគត រមែងបានទទួលបាបច្រើន នេះជាហេតុទីបួន ៥- មហាជនរមែងនិយាយរុកកួនតថាគត ឬសាវ័ករបស់តថាគតដោយរឿងសាច់ ដែលមិនសមគួរ ហើយសម្ងាប់សត្វនោះ ឧទ្ទិសចំពោះតថាគត ឬចំពោះសាវ័ករបស់តថាគត រមែងបានទទួលបាបច្រើន នេះជាហេតុទីប្រាំ ។ ម្នាលជីវក: អ្នកដែលសម្ងាប់សត្វដោយចេតនាឧទ្ទិសចំពោះ ថ្វាយដល់តថាគត ឬប្រគេនចំពោះសាវ័ករបស់តថាគត រមែងបានទទួលបាបច្រើន ដោយហេតុទាំង ៥ ប្រការនេះឯង ។

កាលព្រះមានព្រះភាគ ត្រាស់អធិប្បាយយ៉ាងនេះហើយ ទើបពេទ្យជីវកកោមារភច្ចក្រាបទូលឡើងថា បពិត្រព្រះសក្យមុនី ទាំងនេះ រាប់ថាជាការអស្ចារ្យណាស់ ក្នុងការដែលកិក្ខុទាំងឡាយបរិភោគអាហារដែលសមគួរដល់សមណ: បរិភោគអាហារដែលមិនមានទោស ព្រះអង្គ។ កាលព្រះសម្ពុទ្ធទ្រង់សម្តែងព្រះធម៌ដល់ខ្ញុំព្រះករុណាយ៉ាងនេះ ចាត់ថាជាការល្អក្រៃពេក ព្រះភគវាទ្រង់បានប្រកាសធម៌ដោយអនេកបរិយាយ

មានអាការដូចជាបុគ្គលផ្ងារបស់ដែលផ្តាច់ បើករបស់ដែលបិទចេញ ប្រាប់ផ្លូវឲ្យដល់បុគ្គលអ្នកវង្វេងផ្លូវ ទ្រោលប្រទីបក្នុងទីងងឹត ដើម្បីឲ្យបុគ្គលអ្នកមានភ្នែកល្អៗ ដទៃៗ បានឃើញវត្ថុផ្សេងៗ ដូច្នោះ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងជាទីរឭក សូមព្រះមុនីទ្រង់ចាំទុក ខ្ញុំព្រះករុណាថាជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យ ស្មើដោយជីវិត ចាប់តាំងពីថ្ងៃនេះតទៅ ព្រះអង្គ ។

ពេទ្យជីវកកោមារភច្ច បានជួយព្យាបាលឲ្យព្រះបាទចណ្ឌប្បជ្ជោត ទ្រង់ព្រះប្រឈួនរោគស្គមលឿង ដែលមានសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរមហាវគ្គ ព្រះវិន័យបិដក** ក្នុង **ចីវរក្ខន្ធក:** ដូចមានសេចក្តីថា ៖

គ្រាមួយ ព្រះបាទចណ្ឌប្បជ្ជោត ដែលជាព្រះរាជានៅក្នុងក្រុងឧជ្ជេនី ទ្រង់ព្រះប្រឈួនរោគស្គមលឿង បណ្តាពេទ្យធំៗ ដែលមានឈ្មោះបោះសំឡេងជាច្រើននាក់ បានមកជួយព្យាបាល ថ្វាយដល់ព្រះរាជា តែមិនអាចធ្វើឲ្យជាបាន មានតែទទួលយកប្រាក់ថ្លៃព្យាបាលទៅតែប៉ុណ្ណោះ ។កាលនោះ ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់បានបញ្ជូនរាជទូត

គឺព្រះរាជសាសន៍ទៅក្នុងព្រះរាជសម្នាក់ព្រះបាទពិម្ពិសារ មានអត្ថន័យថា ទូលបង្គំមានអាពាធ សូមព្រះអង្គព្រះរាជទានពេទ្យជីវកកោមារភច្ចឲ្យមកជួយព្យាបាលរោគ របស់ទូលព្រះបង្គំផងចុះ ។ គ្រានោះ ទើបព្រះបាទពិម្ពិសារ មានព្រះរាជតម្រាស់បញ្ជាពេទ្យជីវក:ថា ជាជីវក: អ្នកចូរទៅកាន់ក្រុងឧជ្ជេនី ដើម្បីទៅជួយព្យាបាលឲ្យព្រះបាទចណ្ឌប្បជ្ជោតផង ។ លំដាប់នោះ ពេទ្យជីវក:ក្រាបបង្គំទូលស្នងព្រះរាជបញ្ជា ហើយធ្វើដំណើរទៅកាន់ក្រុងឧជ្ជេនី បានចូលទៅក្នុងព្រះរាជសម្នាក់ ហើយចូលគាល់ព្រះបាទចណ្ឌប្បជ្ជោត បានក្រាបបង្គំទូលសូមពិនិត្យព្រះអាការ ដែលទ្រង់ព្រះប្រឈួនរបស់ព្រះបាទចណ្ឌប្បជ្ជោត ហើយបានក្រាបបង្គំទូលថា បពិត្រព្រះករុណាជីវិតតម្កល់លើត្បូង ទូលបង្គំនឹងចម្អិនទឹកដោះថ្លាថ្វាយព្រះអង្គនឹងបានសោយទឹកដោះនោះ ក្រាបទូល ។ ពេលនោះ ព្រះបាទចណ្ឌប្បជ្ជោតមានព្រះរាជតម្រាស់ហាមឃាត់ថា កុំឡើយជីវក: បើអ្នកអាចធ្វើឲ្យយើងជារោគបានដោយវិធីណា ដោយវៀរលែងទឹកដោះថ្លាចេញបាន អ្នកចូរធ្វើយ៉ាងនោះចុះ ព្រោះយើងខ្ពើមទឹកដោះថ្លាជាទីបំផុត ។

(**អដ្ឋកថា គម្ភីរតតិយសមន្តបា្បសាទិកា** បានពោលថា ហេតុដែលព្រះបាទចណ្ឌបា្បជ្ជោត ទ្រង់ស្អប់ទឹកដោះថ្លានោះ ព្រោះព្រះអង្គទ្រង់ផ្ងាប់កើតក្នុងកំណើតជាខ្ជួយ ទឹកដោះថ្លាជាថ្នាំ និងជារបស់គួរស្អប់របស់ខ្ជួយទាំងជាថ្នាំកម្ចាត់ពិសខ្ជួយ)។ គ្រានោះ ពេទ្យជីវក:គិតពិចារណាថា រោគរបស់ព្រះករុណាអង្គនេះ ដែលទ្រង់កំពុងព្រះប្រឈួន បើវៀរចាកទឹកដោះថ្លាហើយ មិនអាចជួយឲ្យរោគនេះជាបាន ណ្ហើយចុះ យើងនឹងចម្អិនទឹកដោះថ្លាឲ្យមានពណ៌ មានក្លិន មានរសដូចជាទឹកចត់ លុះពេទ្យជីវក:គិតឃើញដូច្នេះហើយ ទើបបានចម្អិនទឹកដោះថ្លា ថែមទាំងបានផ្សំជាមួយថ្នាំផ្សេងៗ ឲ្យមានពណ៌ មានក្លិន មានរសដូចជាទឹកចត់។

កាលពេទ្យជីវក: គិតឃើញដូច្នេះហើយ បានគិតឃើញទៀតថា ទឹកដោះថ្លាដែលព្រះបាទចណ្ឌបា្បជ្ជោតសោយហើយ ប្រាកដជានឹងក្អួត លុះទ្រង់ក្អួតទឹកដោះថ្លាចេញមក មុខជាធ្វើឲ្យព្រះអង្គទ្រង់ពិរោធមិនខាន កាលបើព្រះរាជាអង្គនេះទ្រង់ពិរោធហើយ ជាបុគ្គលឃោរឃៅ ព្រះអង្គប្រាកដជាមានព្រះរាជបញ្ជាឲ្យសម្លាប់យើងមិនខាន មធ្យោបាយដែលល្អ

យើងគួរក្រាបទូលលាទុកជាមុន កាលគិតឃើញដូច្នេះហើយ ទើបចូលទៅគាល់ក្រាបបង្គំទូលថា បពិត្រព្រះអង្គ ពួកទូលបង្គំជាពេទ្យ រមែងត្រាច់ទៅជីកឫសឈើយកមកធ្វើជាថ្នាំដោយប្រញាប់ ដូចដែលទ្រង់មានបំណងនោះ ទូលបង្គំសូមឲ្យព្រះអង្គមានព្រះរាជឱង្ការបញ្ជានាយក្នាក់ងារក្នុងរោងរាជពាហន: និងត្រង់ទ្វារនគរទុកថា បើពេទ្យជីវក:ត្រូវការទៅដោយពាហន:ឯណានីមួយ ក៏ចូរឲ្យគេទៅ ហើយបំណងនឹងចូល ឬចេញតាមទ្វារណានីមួយ ឬជ្រុងថ្នាននឹងចេញចូលក្នុងពេលណា ក៏បានតាមចិត្ត បានគ្រប់ប្រការព្រះអង្គ ។ គ្រានោះ ព្រះបាទចណ្ឌប្បជ្ជោតទើបមានព្រះរាជឱង្ការដល់ក្នាក់ងារ ឲ្យធ្វើតាមពាក្យដែលពេទ្យជីវក: ក្រាបបង្គំទូលសព្វគ្រប់ប្រការ ។ សម័យនោះ ព្រះបាទចណ្ឌប្បជ្ជោតទ្រង់មានជីវមួយឈ្មោះកទូវតី អាចធ្វើដំណើរបានមួយថ្ងៃ ៥០ យោជន៍ (**គម្ពីរអដ្ឋកថាតតិយសមន្តប្បាសាទិកា** បានពោលថា ព្រះបាទចណ្ឌប្បជ្ជោតមិនមែនមានតែជីវមួយតែប៉ុណ្ណោះទេ ព្រះអង្គមានជីវជាច្រើនទៀត គឺ **នាឡាគីរី** អាចដើរបានមួយថ្ងៃ ១០០ យោជន៍ ទ្រង់មានសេះពីរឈ្មោះ

វេលុកណ្ឌ និង **មុញ្ជកេសៈ** ជាសេះដែលអាចធ្វើដំណើរបានមួយថ្ងៃ ១២០ យោជន៍ ហើយទ្រង់មានអ្នកបម្រើ ឈ្មោះ **កាកៈ** អាចធ្វើដំណើរបានមួយថ្ងៃ ៦០ យោជន៍) ។ មូលហេតុដែលព្រះបាទចណ្ឌប្បជ្ជោតទ្រង់មានពាហនៈសម្បូរបែបយ៉ាងនេះ ទាក់ទងមកអំពីអតីតជាតិ ដែលព្រះអង្គទ្រង់កើតជាបុរសអ្នកបម្រើគេ ហើយមានការខ្នះខ្នែងក្នុងការងារជាបុណ្យ ជាកុសលរបស់ចៅហ្វាយនាយ ។ ថ្ងៃមួយ កុលបុត្រដែលជាឥស្សរជនកំពុងអង្គុយ ដើម្បីទទួលទានអាហារ គ្រានោះ មានព្រះបច្ចេកពុទ្ធមកឈរនៅត្រង់ទ្វារផ្ទះរបស់កុលបុត្រនោះ មួយសន្ទុះហើយក៏និមន្តទៅ តែកុលបុត្រដែលជាឥស្សរជនមិនបានឃើញ ។ ចំណែកបុរសដែលជាអ្នកបម្រើ បានក្រឡេកឃើញព្រះបច្ចេកពុទ្ធដូច្នេះហើយទើបប្រាប់ដល់កុលបុត្រ ដែលជាចៅហ្វាយថា លោកចៅហ្វាយព្រះបច្ចេកពុទ្ធបាននិមន្តមកកាន់ទីនេះ ហើយបាននិមន្តចេញទៅហើយ កុលបុត្រនោះបានស្តាប់ពាក្យប្រាប់ដូច្នេះហើយ បានស្រែកបញ្ជាប្រាប់ឲ្យបុរសដែលជាអ្នកបម្រើនោះថា អ្នកចូរប្រញាប់ទៅនិមន្តលោកម្ចាស់

ឲ្យឈប់ ហើយយកបាត្រេបស់ព្រះបច្ចេកពុទ្ធមកឲ្យហ៊ាស ។ មូលហេតុដែលកុលបុត្រដែលជាចៅហ្វាយ ប្រើបុរសដែលជាអ្នកបម្រើនោះ ឲ្យរត់ទៅនិមន្តព្រះបច្ចេកពុទ្ធ ឬយកបាត្រនោះ ព្រោះបុរសដែលជាអ្នកបម្រើនោះជាអ្នកមានថ្វីជើងពូកែខាងរត់លឿន មិនមានអ្នកណាស្មើបាន ។ បុរសដែលជាអ្នកបម្រើនោះ ទើបប្រញាប់រត់ទៅនិមន្តព្រះបច្ចេកពុទ្ធ និងយកបាត្រមកអំពីដៃព្រះបច្ចេកពុទ្ធ មកឲ្យដល់កុលបុត្រ ដែលជាចៅហ្វាយហើយ បុរសដែលជាចៅហ្វាយនោះ បានយកបាត្រមកដាក់អាហារពេញបាត្រ ទើបប្រើបុរសដែលជាអ្នកបម្រើនោះ ឲ្យរត់យកទៅប្រគេនដល់ព្រះបច្ចេកពុទ្ធវិញ ។ បុរសដែលជាអ្នកបម្រើនោះ ក៏បានធ្វើតាមពាក្យរបស់ចៅហ្វាយនាយ ដោយបានរត់យកបាត្រនោះទៅប្រគេនដល់ព្រះបច្ចេកពុទ្ធ ហើយថែមទាំងបានតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ដ៏ចម្រើន ដោយអំណាចការប្រឹងប្រែងខ្នះខ្នែងក្នុងការរត់យកចង្ហាន់មកប្រគេនដល់លោកម្ចាស់នេះ សូមឲ្យខ្ញុំកើតក្នុងទីណាៗ ជាអ្នកសម្បូរទៅដោយពាហនៈ ចំណែកវាងកាយរបស់ខ្ញុំកុណា

ដែលត្រូវពន្លឺព្រះអាទិត្យជុតរោល សូមឲ្យអំណាចរបស់ខ្ញុំព្រះករុណា ផ្សាយទៅ ដូចជាពន្លឺនៃព្រះអាទិត្យ ក្នុងទីដែលកើតឡើងហើយ ចំណែកបុណ្យកុសលក្នុងចិណ្ឌបាតនេះ ដែលចៅហ្វាយឲ្យហើយដល់ខ្ញុំព្រះករុណា សូមឲ្យខ្ញុំព្រះករុណា បានមានចំណែកនៃការត្រាស់ដឹងធម៌ដែលលោកម្ចាស់បានឃើញហើយ ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធពោលថា អ្នកប្រាថ្នាយ៉ាងណា ចូរឲ្យបានសម្រេចយ៉ាងនោះចុះ ។ ហើយពោលអនុមោទនាថា វត្ថុដែលអ្នកត្រូវការនឹងប្រាថ្នាហើយ ចូរសម្រេចឲ្យបានរួសរាន់ទាន់ចិត្ត សូមសេចក្តីត្រិះរិះទាំងពួងរបស់អ្នក ចូរពេញដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត វត្ថុដែលអ្នកត្រូវការនឹងប្រាថ្នា ចូរសម្រេចឲ្យបានរួសរាន់ទាន់ចិត្ត សូមតម្រិះទាំងពួងរបស់អ្នក ចូរពេញដូចកែវមណីដែលឈ្មោះ **ជោតិរស** ។ ឥឡូវនេះ បុរសដែលជាអ្នកបម្រើនោះ បានមកកើតជាព្រះបាទចណ្ឌប្បជ្ជោត ដែលទ្រង់សម្បូរដោយរាជពាហនៈផ្សេងៗ ព្រោះបានធ្វើកុសលហើយ តាំងសេចក្តីប្រាថ្នាទុកមកអំពីអតីតជាតិ ដូច្នេះហើយ ទើបធ្វើ

ឲ្យព្រះបាទចណ្ឌប្បជ្ជោតជួបប្រសព្វនូវហេតុដែលអស្ចារ្យ ដូចដែលបានពោលរួចមកហើយ ។ កាលពេទ្យជីវក:ចម្អិនទឹកដោះថ្លាផ្សំនឹងថ្នាំផ្សេងៗរួចហើយ ក៏បាននាំយកទៅថ្វាយដល់ព្រះបាទចណ្ឌប្បជ្ជោត ដោយក្រាបបង្គំទូលថា សូមព្រះករុណាជីវិតតម្កល់លើត្បូង សោយទឹកចត់នេះចុះព្រះអង្គ ។ លុះឲ្យព្រះបាទចណ្ឌប្បជ្ជោតសោយទឹកដោះថ្លាហើយ ទើបគេប្រញាប់ទៅឯរោងជីរឡើងជិះជំរី **ភទ្រវតី** ចៀសចេញទៅអំពីព្រះនគរដោយឆាប់រហ័ស ។ ខណៈជាមួយគ្នានោះ ព្រះបាទចណ្ឌប្បជ្ជោតសោយទឹកដោះថ្លាហើយ វេលាតមកមួយសន្ទុះ ព្រះអង្គក៏ទ្រង់ក្អួតចេញមក ទើបទ្រង់ពិរោធមានព្រះរាជតម្រាស់ថា ពេទ្យជីវកកោមារភច្ចជាមនុស្សអាក្រក់ ឲ្យយើងផឹកទឹកដោះថ្លា ដូច្នេះ ពួកលោកចូរទៅចាប់ពេទ្យជីវក:មកឲ្យយើងឲ្យទាល់តែបាន ដោយឆាប់រហ័ស ។ គ្រានោះ ពួកមហាតលិកក្រាបបង្គំទូលថា ព្រះករុណាថ្លៃវិសេស ពេទ្យជីវក:បានឡើងជិះជំរីភទ្រវតី គេចចេញអំពីព្រះនគរទៅហើយ ព្រះអង្គ ។ ក្នុងគ្រានោះ ព្រះបាទចណ្ឌប្បជ្ជោតមានទាសាម្នាក់ឈ្មោះ **កាក:** ។ នាយកាក:គេអាច

ដើរមួយថ្ងៃបាន ៦០ យោជន៍ ។ ពេលនោះ ព្រះបាទចណ្ឌប្បជ្ជោត មានព្រះរាជតម្រាស់បញ្ជាឲ្យនាយកាក:ថា អ្នកចូរទៅតាមពេទ្យជីវក: ត្រឡប់មក ដោយពោលអាង៥ថា លោកអាចារ្យ ព្រះករុណាជីវិតតម្កល់លើត្បូង៍ មានព្រះរាជបញ្ជាឲ្យអញ្ជើញលោកអាចារ្យត្រឡប់ទៅវិញ នែនាយកាក: អ្នកត្រូវប្រុងប្រយ័ត្ន ព្រោះថា ពេទ្យទាំង៥ឃ្លាយជាអ្នកមានកលល្បិចមាយាច្រើន លោកកុំទទួលរបស់អ្វីៗ ដែលពេទ្យជីវក: ឲ្យៗ សោះ ។

គ្រានោះ នាយកាក:ក្រាបបង្គំទូលស្នង៍ព្រះរាជបញ្ជាហើយ បានប្រញាប់ចេញដំណើរទៅតាមមួយរំពេច ហើយបានទៅទាន់ពេទ្យជីវក: ដែលកំពុង៍ទទួលទានអាហារពេលព្រឹក ក្នុង៍រវាង៍ផ្លូវត្រង់ក្រុង៍កោសម្ពី ហើយជម្រាបពេទ្យជីវក: តាមព្រះរាជតម្រាស់បញ្ជាថា បពិត្រលោកអាចារ្យ ព្រះករុណាជីវិតតម្កល់លើត្បូង៍ មានព្រះរាជបញ្ជាឲ្យអញ្ជើញលោកអាចារ្យត្រឡប់ទៅវិញសិន ។ ពេលនោះ ពេទ្យជីវក:បានពោលជាមួយនាយកាក:ថា ម្នាលនាយកាក: លោករង៍ចាំឲ្យខ្ញុំទទួលទាន

អាហារូបចិនណា សូមអញ្ជើញលោកទទួលទានអាហារជាមួយគ្នាមក ។
កាក:តបបដិសេធថា មិនបាច់ទេបាទ បពិត្រលោកអាចារ្យ ព្រះករុណា
ជីវិតតម្កល់លើតង្ស មានព្រះរាជបញ្ជាប្រាប់ខ្ញុំថា ធម្មតាពេទ្យតែងតែ
មានល្បិចកលមាយាច្រើន លោកកុំទទួលរបស់អ្វី ដែលពេទ្យជីវក:
ឲ្យជាដាច់ខាត ។ រំពេចនោះ ពេទ្យជីវក:បានស្តាប់ពាក្យកាក:ហើយ
ទើបរកវិធីដើម្បីឲ្យគេជឿទុកចិត្ត ទើបយកថ្នាំជាក់ទុកត្រង់ក្រចកដៃហើយ
ខាំកន្ទុតព្រៃមួយចំហៀង ហើយផឹកទឹកបន្តែម ហើយប្រាប់នាយកាក:ថា
អញ្ជើញបាកាក:បរិភោគកន្ទុតព្រៃនេះជាមួយគ្នាចុះ ហើយផឹកទឹកនេះ
បន្តែមទៅ គង់នឹងមិនជាអ្វីទេ ។ នាយកាក:បានក្រឡេកឃើញការធ្វើ
របស់ពេទ្យជីវក:គ្រប់យ៉ាងហើយគិតថា មិនមានទោស ហើយទើប
ខាំស៊ីផ្លែកន្ទុតព្រៃមួយចំហៀងដែលសល់នោះ ហើយផឹកទឹកបន្តែម
ចូលទៅ ហើយក្នុងទីបំផុត នាយកាក:ក៏កើតអាការឈឺពោះយ៉ាងខ្លាំង
នៅក្នុងទីនោះឯង នាយកាក:បានសួរទៅពេទ្យជីវក:ថា បពិត្រលោក
អាចារ្យ ខ្ញុំនឹងមានជីវិតរស់នៅតទៅទៀតឬទេ ? គ្រានោះ ពេទ្យជីវក:

តបថា កុំខ្លាចឡើយ ជាកាក: លោកមិនមានអន្តរាយដល់ស្លាប់ទេ តែព្រះករុណាជីវិតតម្កល់លើត្បូងរបស់អ្នកយោរយៅខ្លាំងណាស់ ទ្រង់នឹងឲ្យសម្លាប់យើងចោលក៏បាន ព្រោះដូច្នោះ ខ្ញុំមិនត្រឡប់ទៅវិញទេ ពោលដូច្នេះហើយ ក៏បានប្រគល់ដីរកូវតីឲ្យដល់នាយកាក: ហើយ បានធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះតទៅទៀតទៅ ។

កាលពេទ្យជីវកកោមារកចូធ្វើដំណើរឿយៗ មកដោយលំដាប់រហូតដល់ក្រុងរាជគ្រឹះហើយ ទើបចូលទៅគាល់ព្រះបាទពិម្ពិសារ ក្រាបបង្គំទូលនិទានរឿងហេតុការណ៍ទាំងអស់នោះ ឲ្យទ្រង់បានជ្រាប ។ គ្រានោះ ព្រះបាទពិម្ពិសារ មានព្រះរាជតម្រាស់ថា ល្អហើយ ដែលអ្នកមិនត្រឡប់ទៅកាន់ក្រុងឧជ្ជេនីវិញ ព្រោះថា ព្រះបាទចណ្ឌប្បជ្ជោត ជាព្រះរាជាកាចយោរយៅណាស់ អាចឲ្យគេប្រហារជីវិតរបស់អ្នក ក៏ថាបាន ។ រីឯព្រះបាទចណ្ឌប្បជ្ជោត ទ្រង់ជាព្រះប្រឈួនហើយ ទ្រង់បានបញ្ជូនរាជទូត ឲ្យទៅកាន់សម្នាក់របស់ពេទ្យជីវក:ថា សូមអញ្ជើញលោកអាចារ្យមករកយើងៗ នឹងប្រទានពរឲ្យដល់លោកអាចារ្យ ។

ពេទ្យជីវក:ក្រាបទូលតបទៅ ជាមួយពួករាជទូតវិញថា មិនចាំបាច់ទៅ
ក៏បាន សូមឲ្យព្រះអង្គទ្រង់រឭកសេចក្តីល្អ របស់ទូលបង្គំប៉ុណ្ណោះ ក៏
គ្រប់គ្រាន់ហើយ ព្រះអង្គ ។ ក្នុងសម័យនោះ ព្រះបាទចណ្ឌប្បជ្ជោត
ទ្រង់មានគូសំពត់ **សិវេយ្យក** (សំពត់សូត្រធ្វើក្នុងក្រុងសីវី) មួយគូ
ជាសំពត់សាច់ល្អលើស ប្រសើរក្រៃលែង មានឈ្មោះបោះសំឡេង
ណាស់ ជាសំពត់ដែលប្រសើរជាងសំពត់ដទៃទៀតជាច្រើន ជាសំពត់
ដែលកាត់ថ្លៃមិនបាន ព្រមទាំងសំពត់បរិវារមួយពាន់ផាប់ទៀត ព្រះអង្គ
បានបញ្ជូនសំពត់សិវេយ្យក: និងសំពត់បរិវារមួយពាន់ផាប់ ព្រមដោយ
អង្គរ ៥០០ រទេះ ប្រាក់ ១៦ ពាន់កហាបណៈ ព្រះរាជាព្រះទានឲ្យ
ដល់ពេទ្យជីវក: ជារង្វាន់ដែលមកជួយព្យាបាលរោគឲ្យព្រះអង្គ ឲ្យទ្រង់
បានជាពីព្រះប្រឈួនរោគស្តមលឿងទៅបាន ។ កាលពេទ្យជីវក:បាន
ទទួលព្រះរាជទានសំពត់សិវេយ្យក:មកហើយ គិតពិចារណាថា សំពត់
សិវេយ្យក:គូនេះដែលព្រះបាទចណ្ឌប្បជ្ជោត ទ្រង់បញ្ជូនមកឲ្យជាសំពត់
សាច់ល្អលើស ប្រសើរក្រៃលែង មានឈ្មោះបោះសំឡេង ហើយ

ជាសំពត់ដែលល្អជាងសំពត់ដទៃទៀតជាច្រើនរយគូ ច្រើនពាន់ ឬច្រើនសែនគូ គូសំពត់នេះ ក្រៅអំពីព្រះលោកនាថ ឬព្រះបាទពិម្ពិសារហើយ អ្នកដទៃទៀត មិនគួរនឹងប្រើប្រាស់ទេ ។

ពេទ្យជីវកកោមារភច្ច បានប្រទានឱសថសម្រាប់ប្រើបន្ទោបង់ថ្វាយដល់ព្រះលោកនាយក ៖

សម័យមួយ ព្រះសាស្តា ទ្រង់គង់នៅត្រង់ភ្នំគិជ្ឈកូដ ដែលនៅក្នុងអាណាខេត្តក្រុងរាជគ្រឹះ គ្រានោះ ព្រះកាយរបស់ព្រះភគវា ធ្ងន់ដោយវត្តុដែលជាទោស ទើបព្រះអង្គបញ្ជាព្រះអានន្ទថា ម្នាលអានន្ទ កាយរបស់តថាគតធ្ងន់ដោយវត្តុដែលជាទោស តថាគតត្រូវការនឹងធាន់ថ្នាំបន្ទោបង់ ។ ព្រះអានន្ទបានជ្រាបទូវព្រះពុទ្ធបំណងហើយ ទើបបាននិមន្តទៅរកពេទ្យជីវក: ហើយពោលថា លោកគ្រូពេទ្យជីវក: ព្រះសក្យមុនី ទ្រង់មានព្រះបំណងនឹងសោយថ្នាំបន្ទោបង់ ។ពេទ្យជីវក: ពិតថា បើយ៉ាងនោះ សូមលោកម្ចាស់ ធ្វើព្រះកាយរបស់ព្រះសម្ពុទ្ធឲ្យត្រជាក់ ឬសប្បាយ ២-៣ ថ្ងៃសិន ។ ព្រះអានន្ទបានបដិបត្តិតាម ដែលពេទ្យជីវក:ប្រាប់ ហើយ

កាលវេលាកន្លងទៅ ២-៣ ថ្ងៃ ព្រះអានន្ទបានទិមន្តទៅរកពេទ្យជីវក: ហើយប្រាប់ថា លោកគ្រូពេទ្យជីវក: ឥឡូវនេះ ព្រះមុនីមានព្រះកាយត្រជាក់ ឬសប្បាយហើយ លោកគ្រូពេទ្យជីវក: គួរពិចារណាមើលកាលដ៏សមគួរ ថ្វាយព្រះឱសថបន្ទោបង់ ដល់ព្រះមានព្រះភាគចុះ ។

គ្រានោះ ពេទ្យជីវកកោមារភច្ចគិតពិចារណាថា ការដែលយើងនឹងថ្វាយព្រះឱសថបញ្ចុះ ដែលគ្រោតគ្រាតឲ្យដល់ព្រះមានជោគ មិនសមគួរឡើយ យើងគួរនឹងអប់ផ្កាឧប្បល ៣ ទង ផ្សំជាមួយថ្នាំផ្សេងៗ យកទៅថ្វាយដល់ព្រះភគវា កាលគេគិតពិចារណាយើញដូច្នេះហើយ ទើបអប់ផ្កាឧប្បល ៣ ទង ផ្សំជាមួយថ្នាំផ្សេងៗ ហើយនាំយកទៅថ្វាយដល់ព្រះសម្ពុទ្ធ ហើយក្រាបទូលណែនាំថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើព្រះលោកនាថ ហិតផ្កាឧប្បលទង៍ទី ១ នេះ អាចធ្វើឲ្យព្រះសាស្តាទ្រង់បន្ទោបង់ដល់ ១០ ដង ហើយប្រគេនផ្កាឧប្បលទង៍ទី ២ ព្រមទាំងក្រាបទូលថា បើព្រះសុគតទ្រង់ហិតផ្កាឧប្បលទង៍ទី ២ នេះ អាចធ្វើឲ្យព្រះអង្គ បន្ទោបង់ដល់ ១០ ដងទៀត ហើយបានប្រគេនផ្កាឧប្បលទង៍ទី

៣ ព្រមទាំងក្រាបទូលថា បើព្រះពុទ្ធអង្គ ទ្រង់ហិតផ្ការឧប្បលទង់ទី ៣ នេះ អាចធ្វើឲ្យព្រះអង្គ បន្ទោបង់ជល់ទៅ ១០ ដងទៀត ព្រះអង្គ ។ កាលពេទ្យជីវក: បានថ្វាយព្រះឱសថបន្ទោបង់ឲ្យជល់ព្រះមានព្រះភាគ ដើម្បីឲ្យទ្រង់បន្ទោបង់ ៣០ ដងហើយ ទើបក្រាបថ្វាយបង្គំព្រះសាស្តា ធ្វើប្រទក្សិណត្រឡប់ទៅវិញ ។ ខណៈដែលពេទ្យជីវក:ចេញទៅខាងក្រៅខ្ងោងទ្វារព្រះវិហារ បានគិតឡើងម្តងទៀតថា យើងបានថ្វាយឱសថបន្ទោបង់ឲ្យជល់ព្រះលោកនាយក ដើម្បីឲ្យទ្រង់បន្ទោបង់ទៅ ៣០ ដង តែព្រះកាយរបស់ព្រះលោកនាថ ផ្ទុកដោយវត្តុដែលជាទោសដ៏ច្រើន ព្រះអង្គទ្រង់បន្ទោបង់មិនគ្រប់ ៣០ ដង ទ្រង់និងបន្ទោបង់ត្រឹមតែ ២៩ ដង តមក កាលព្រះមហាវីរៈ ព្រះអង្គទ្រង់ជម្រះព្រះកាយហើយ ទ្រង់និងបន្ទោបង់ម្តងទៀត ក៏រួមជា ៣០ ដងល្មម លុះគេគិតឃើញដូច្នេះហើយ ទើបចូលទៅពិតព្រះអានន្ទឲ្យជ្រាបនូវសេចក្តីនោះ ។

កាលព្រះមហាមុនី ទ្រង់បានជ្រាបជល់គំនិតរបស់ពេទ្យជីវក: ដោយព្រះទ័យហើយ ទើបត្រាស់ប្តូរព្រះអានន្ទថា ម្នាលអានន្ទ អ្នក

ចូរត្រៀមទឹកក្តៅទុក ព្រះអានន្ទក្រាបទូលទទួលព្រះពុទ្ធដីកា ហើយ
បានត្រៀមរៀបចំទឹកក្តៅទុកថ្វាយព្រះអង្គមែន ។ កាលតមក ពេទ្យជីវក-
កោមារភច្ច បានចូលទៅគាល់ព្រះមានបុណ្យ ថ្វាយបង្គំហើយ ក៏អង្គុយ
ក្នុងទីដ៏សមគួរ បន្ទាប់មកក្រាបទូលសួរថា បពិត្រព្រះមានជោគ ទ្រង់
បន្ទោបង់ហើយឬនៅ ព្រះអង្គ ? គ្រានោះ ព្រះវិជិតមារត្រាស់តបថា
ពេទ្យជីវក: តថាគតបន្ទោបង់ហើយ ។ លំដាប់នោះ ពេទ្យជីវក:
ក្រាបទូលពោលការគិតរបស់ខ្លួនថា បពិត្រព្រះជិនស្រី ខណៈដែលខ្ញុំ
ព្រះករុណាកំពុងតែដើរទៅខាងក្រៅទ្វារព្រះវិហារ ខ្ញុំព្រះករុណា បានគិត
ត្រឡប់ឡើងវិញថា យើងបានថ្វាយព្រះឱសថដល់ព្រះភគវា ដើម្បីទ្រង់
បន្ទោបង់គ្រប់ ៣០ ដង តែព្រះកាយរបស់ព្រះភគវា ផ្អាប់ដោយរបស់
ដែលជាទោសយ៉ាងច្រើន ព្រះអង្គនឹងមិនបន្ទោបង់គ្រប់ ៣០ ដងទេ
ទ្រង់នឹងបន្ទោបង់ត្រឹមតែ ២៩ ដងប៉ុណ្ណោះ តមក កាលព្រះសម្មុទ្ទ
ទ្រង់បន្ទោបង់ហើយ ទ្រង់ជម្រះព្រះកាយ ព្រះអង្គក៏នឹងបន្ទោបង់ម្តងទៀត
ទើបគ្រប់ ៣០ ដងល្មម ព្រោះដូច្នោះ សូមព្រះសក្យមុនី ទ្រង់ជម្រះ

ព្រះកាយចុះ ។ កាលព្រះទសពល ទ្រង់ជម្រះព្រះកាយហើយ ទ្រង់ក៏បន្ទោបង់ម្តងទៀត ទើបរួមជា ៣០ ដង គ្រប់តាមដែលពេទ្យជីវក: កំណត់ទុក ។ រួចហើយពេទ្យជីវកកោមារភច្ច បានក្រាបទូលថ្វាយពាក្យណែនាំថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសយម្ភូមិនគួរសោយព្រះក្រយាហារ ដែលផ្សំដោយទឹកស្ងោរដោយបន្លែផ្សេងៗ រហូតដល់អាហារដែលជាគ្រាប់ ទម្រាំនឹងព្រះកាយជា ជាប្រក្រតី ព្រះអង្គ ។តមក មិនយូរប៉ុន្មាន ព្រះកាយរបស់ព្រះភគវា ក៏ជាមានប្រក្រតីវិញ ។

កាលព្រះសម្ពុទ្ធ មានព្រះកាយជាប្រក្រតីហើយ ពួកអ្នកស្រុកបាននាំគ្នាត្រៀមទេយ្យធម៌ទុកថ្វាយជាច្រើន ។ ចំណែកពេទ្យជីវក: បានមកចូលគាល់ក្រាបទូលសេចក្តីនោះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះពួកអ្នកស្រុកមានបំណងនឹងថ្វាយទេយ្យធម៌ដល់ព្រះអង្គ សូមព្រះអង្គយាងចូលទៅកាន់ចន្លោះស្រុក ដើម្បីយាងចារិកបិណ្ឌបាត ព្រះអង្គ ។ ចំណែកព្រះមហាមោគ្គល្លាន បានគិតថា ថ្ងៃនេះ ព្រះលោកនាថសមគួរបានបឋមបិណ្ឌបាតអំពីទីណាហ្ន៎ ហើយ

លោកក៏បានគិតឃើញភ្លាមថា **សោណាសេដ្ឋីបុត្រ** ចាប់ផ្តើមតាំងអំពីគេធ្លាប់ស្រែមក គេរមែងតែងតែទទួលទានជាយ ដែលមានឈ្មោះថា ស្រូវសាលីក្រអូប ដែលធ្វើដោយស្រោចទឹកដោះស្រស់ មិនជាសាធារណៈដល់ពួកជនដទៃ យើងនឹងនាំអាហារបិណ្ឌបាតមកអំពីផ្ទះសោណាសេដ្ឋីបុត្រនោះ មកថ្វាយដល់ព្រះលោកនាយក លុះគិតឃើញដូច្នេះហើយ ទើបព្រះថេរៈទៅដោយឫទ្ធិ បង្ហាញខ្លួនរបស់លោកនៅលើផ្ទៃប្រាសាទរបស់សោណាសេដ្ឋីបុត្រ ។ គ្រានោះ សោណាសេដ្ឋីបុត្រ បានឃើញព្រះមហាមោគ្គល្លានហើយ ទើបទទួលយកបាត្រមកអំពីព្រះថេរៈ មកដាក់អាហារដ៏ប្រណីតពេញក្នុងបាត្រហើយ ទើបនាំយកទៅប្រគេនព្រះថេរៈវិញ ហើយគេបានឃើញអាការរបស់ព្រះថេរៈ ដែលនឹងត្រូវការចង្ហាន់បិណ្ឌបាតអំពីផ្ទះរបស់គេទៅ គេឃើញដូច្នោះហើយ ទើបពោលអាវជនាថា សូមនិមន្តលោកម្ចាស់ឆាន់ចុះ ខ្ញុំព្រះករុណានឹងថ្វាយអាហារបិណ្ឌបាតចំណែកដទៃ ដល់ព្រះទសពលជាខាងក្រោយ ។ ក្រោយអំពីព្រះមហាមោគ្គល្លានឆាន់ចង្ហាន់បិណ្ឌបាតរួចស្រេចហើយ សោណាសេដ្ឋី

បុត្រ បានលាងបាត្រព្រះថេរៈរួចហើយ បានអប់បាត្រដោយគ្រឿងក្រអូប រួចដាក់ចង្ហាន់បិណ្ឌបាត ដែលជាចំណែកត្រូវថ្វាយដល់ព្រះមានព្រះភាគ ក្នុងបាត្រពេញហើយ នាំមកប្រគេនដល់ព្រះថេរៈ។ ក៏បាននាំចង្ហាន់បិណ្ឌបាតនោះ មកថ្វាយដល់ព្រះសម្ពុទ្ធ ។ ចំណែកព្រះបាទពិម្ពិសារ ក៏ទ្រង់ត្រិះរិះថា ថ្ងៃនេះព្រះភគវា ព្រះអង្គត្រូវបានសោយព្រះក្រយាហារអ្វី កាលព្រះអង្គយាងត្រឡប់មកឯព្រះវិហារវិញ លុះព្រះអង្គយាងចូលទៅក្នុងព្រះវិហារ ព្រះមុនីក៏បានធុំក្លិនចង្ហាន់បិណ្ឌបាត រហូតធ្វើឲ្យព្រះអង្គមានបំណងចង់សោយ ។

អាហារបិណ្ឌបាតរបស់ព្រះមានជោគ ដែលទេវតាទាំងឡាយបានដាក់ឱជារស ក្នុងអាហារបិណ្ឌបាតរបស់ព្រះពុទ្ធអង្គ ដែលនៅក្នុងភាជន៍ត្រឹមតែ ២ ដងប៉ុណ្ណោះ ម្តង គឺអាហារបិណ្ឌបាតដែលនាងសុជាតានាំយកទៅថ្វាយមុនព្រះអង្គត្រាស់ដឹងជាព្រះសម្ពុទ្ធ ម្តងទៀត ពេលដែលនាយចុន្ទកម្មារបុត្រ បានចាត់ចែងថ្វាយអាហារបិណ្ឌបាតក្នុងគ្រាមុនព្រះអង្គរំលត់ខន្ធបរិនិព្វាន ។ ចំណែកអាហារបិណ្ឌបាតដទៃៗ ពួកទេវតា

បានដាក់ឱជារសត្រង់មួយពំនូត ដែលព្រះអង្គទ្រង់សោយប៉ុណ្ណោះ ។ កាលព្រះទសពលទ្រង់ជ្រាបថា ព្រះបាទពិម្ពិសារ ទ្រង់មានព្រះបំណងសោយខ្លះ ទើបទ្រង់ប្រាប់ឲ្យថ្វាយអាហារបិណ្ឌបាតបន្តិច ដែលទេវតាមិនទាន់បានដាក់ឱជាចុះទៅឲ្យដល់ព្រះរាជា ។ គ្រានោះ ព្រះបាទពិម្ពិសារសោយហើយ ទ្រង់ក្រាបទូលសួរថា កោជននេះនាំមកអំពីឧត្តរកុរុទ្វីបឬព្រះអង្គ ? ព្រះវិជិតមារត្រាស់តបថា មហាបពិត្រ កោជននេះមិនមែននាំមកអំពីឧត្តរកុរុទ្វីបទេ ជាកោជនរបស់សោណសេដ្ឋីបុត្រ ជាអ្នកនៅក្នុងដែនរបស់មហាបពិត្រទេតើ ហើយត្រាស់ប្រាប់សម្បត្តិរបស់សោណៈ ឲ្យព្រះបាទពិម្ពិសារមហារាជ ទ្រង់ព្រះសណ្តាប់ ។ គ្រានោះ ព្រះរាជាទ្រង់ស្តាប់រឿងរ៉ាវនោះហើយ មានព្រះរាជបំណងចង់ឃើញសោណៈ ហើយក៏បានមានព្រះរាជតម្រាស់បញ្ជាឲ្យសោណៈ ព្រមទាំងកុលបុត្រ ៨ ម៉ឺននាក់ចូលមកគាល់ ។ ក្នុងទីបំផុតកុលបុត្រទាំងនោះបានស្តាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ហើយបានជាព្រះសោតាបន្ន ។ ចំណែកសោណៈបានបួសរួចហើយ មិនយូរប៉ុន្មាន

ក៏បានសម្រេចព្រះអរហត្ត ជាព្រះខីណាស្រព ។

កាលព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយ ពេទ្យជីវក: កាន់គូសំពត់សិវេយ្យក:នោះ ចូលទៅគាល់ព្រះមានបុណ្យ ថ្វាយបង្គំ រួចហើយក៏អង្គុយក្នុងទីដ៏សមគួរ ហើយក្រាបទូលថា ខ្ញុំព្រះករុណានឹង សូមពរចំពោះព្រះមហាវីរ:ត្រឹមតែម្យ៉ាងព្រះអង្គ ។ គ្រានោះ ព្រះសម្ពុទ្ធ ត្រាស់ថា **ជីវក:** ព្រះតថាគតទាំងឡាយលើកការឲ្យពរចេញហើយ ។ ពេលនោះ ពេទ្យជីវក:ក្រាបទូលថា ខ្ញុំព្រះករុណានឹងក្រាបទូលសូមពរ តែវត្ថុ ដែលសមគួរដល់សមណ: ជាពរដែលមិនទាន់មានទេ ព្រះអង្គ ។ ព្រះជិនស្រីត្រាស់ថា ជីវក: បើដូច្នោះ អ្នកចូរពោលមកចុះ ។ ពេទ្យជីវក: ក្រាបទូលថា ព្រះសាស្តា និងភិក្ខុសង្ឃក៏តែងតែទ្រង់ប្រើប្រាស់ស្បៃក ជណ្តប់សំពត់បង្សុកូលជាប្រក្រតីប៉ុណ្ណោះ ប៉ុន្តែសំពត់សិវេយ្យក:មួយ គូនេះ ដែលព្រះបាទចណ្ឌប្បជ្ជោត ទ្រង់បញ្ជូនមកព្រះរាជទានឲ្យដល់ ខ្ញុំព្រះករុណា ដែលជាសំពត់សាច់ល្អ មានឈ្នោះល្បីល្បាញបំផុត ជាងសំពត់ទាំងឡាយដទៃទៀតជាច្រើន ទាំងច្រើនរយគូ ពាន់គូ ឬច្រើន

សែនគួ ហេតុដូច្នេះ សូមព្រះភគវា ទ្រង់មេត្តាទទួលសំពត់សិរីវេយ្យក:
គូនេះ របស់ខ្ញុំព្រះករុណា ហើយសូមព្រះលោកនាថ ទ្រង់ពុទ្ធានុញ្ញាត
គហបតីចីវរ (ចីវរដែលអ្នកស្រុកប្រគេន) ដល់ភិក្ខុសង្ឃផងចុះ
ព្រះអង្គ ។គ្រានោះ ព្រះមានបុណ្យ ទ្រង់ទទួលសំពត់សិរីវេយ្យក:គូនោះ
ហើយទ្រង់សម្តែងធម៌ ប្រោសដល់ពេទ្យជីវក:ឲ្យឃើញច្បាស់ ឲ្យកាន់
យកជ័ណ្ឌ ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា តាមសមគួរដល់
ពេលវេលា ។ពេលនោះ ពេទ្យជីវកកោមារភច្ចៈ បានស្តាប់ព្រះធម៌
ទេសនាហើយ ទើបក្រោកឡើងអំពីអាសនៈ ក្រាបទូលលាព្រះវិជិតមារ
ធ្វើប្រទក្សិណ ហើយត្រឡប់ទៅវិញ ។

ភាពជាអ្នកមានសទ្ធាដ៏មាំទាំ ក្នុងព្រះសាសនានេះ របស់ពេទ្យ
ជីវកកោមារភច្ចៈ ជាហេតុធ្វើឲ្យពេទ្យជីវក:បានកសាងវត្តថ្វាយទុកក្នុង
ព្រះពុទ្ធសាសនានេះ តាមដែលមានរឿងសម្តែងទុកនៅក្នុង ***អដ្ឋកថា
បបញ្ចសូទនី*** និងក្នុង ***អដ្ឋកថាសុមង្គលវិលាសិនី*** ដូចមានសេចក្តីថា ៖

សម័យមួយ ពេទ្យជីវកកោមារភច្ចៈ បានថ្វាយថ្នាំបន្ទោបង់ដល់

ព្រះមានព្រះភាគរហូតធ្វើឲ្យព្រះអង្គទ្រង់មានព្រះវរកាយស្រាលហើយ ទើបថ្វាយសំពត់មួយគូ និងថ្វាយសំពត់បរិវារមួយពាន់ផ្ទាំងដល់ភិក្ខុសង្ឃ ។ គ្រានោះ ព្រះភគវា ទ្រង់ទទួលការថ្វាយសំពត់សិវេយ្យក:អំពីពេទ្យជីវក:ហើយ ទើបទ្រង់ធ្វើការអនុមោទនារឿងការថ្វាយសំពត់ ។ កាលព្រះទសពល ទ្រង់ធ្វើការអនុមោទនាគាថាចប់ហើយ ពេទ្យជីវក: ដែលបញ្ជូនចិត្តទៅតាមក្រសែនៃព្រះធម៌ ក៏បានសម្រេចសោតាបត្តិផល ជាព្រះសោតាបន្ន គឺបានជាព្រះអរិយបុគ្គលលំដាប់ទី ១ ក្នុងបណ្តាព្រះអរិយបុគ្គល ៤ជំពូក ហើយលោកបានជាអ្នកមានអចលនសទ្ធា គឺការជឿមិនកម្រើក ហើយលោកគិតថា យើងបានទៅចូលគាល់ព្រះលោកនាថ ២-៣ ដង ក្នុងវត្តវេឡុវនមហាវិហារ ដែលព្រះសក្យមុនីប្រថាប់នៅបច្ចុប្បន្ននេះតាំងនៅឆ្ងាយ ចំណែកចម្ការស្វាយរបស់យើងនៅជិតជាង យើងគួរសាងវិហារវេរថ្វាយព្រះសម្ពុទ្ធ ត្រង់ចម្ការស្វាយរបស់យើងល្អម្យ៉ាងដែរ ។ លុះលោកគិតយើញដូច្នេះហើយ ទើបបានកសាងទីស្នាក់នៅពេលយប់ និងពេលថ្ងៃក្នុងទីដ៏ស្ងាត់ស្ងៀម សាងកុដិ

និងមណ្ឌបជាដើម ក្នុងចម្ការស្វាយរបស់ខ្លួន ហើយសាងព្រះគន្ធកុដិ ដែលសមគួរសម្រាប់ព្រះវិជិតមារផង ។ កាលពេទ្យជីវក: បានចាត់ចែងកសាងវិហារស្រេចហើយ ទើបឲ្យធ្វើកំពែងកម្ពស់ ១៨ ហត្ថជុំវិញចម្ការស្វាយនោះ កាលសាងកំពែងស្រេចហើយ បានចាត់ចែងថ្វាយអាហារ និងចីវរដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ហើយបានច្រួចទឹកទក្ខិណោទកចុះលើព្រះហស្តរបស់ព្រះសាស្តា ដែលជាសញ្ញាសម្តែងការថ្វាយវិហារនោះ ។ គ្រានោះ ព្រះសាស្តា ព្រមដោយភិក្ខុសង្ឃ ១២៥០ អង្គ បានប្រថាប់នៅក្នុង **អម្ពវនវិហារ** ហើយវិហារនោះបានហៅឈ្មោះពេទ្យជីវកកោមារភច្ចរួមចូលផង ដើម្បីឲ្យដឹងឈ្មោះអ្នកកសាងវិហារនោះ ទើបមានឈ្មោះថា **ជីវកម្ពវនវិហារ** ប្រែថា វិហារចម្ការស្វាយរបស់ពេទ្យជីវក: ។

ព្រះទសពល ទ្រង់អនុញ្ញាតឲ្យភិក្ខុសង្ឃទាំងឡាយ ប្រើប្រាស់គហបតីចីវរបាន តាមដែលពេទ្យជីវក:ក្រាបទូលសូមពរ ដូចដែលមានសម្តែងប្រាកដនៅក្នុងព្រះបាលី **គម្ពីរមហាវគ្គ ព្រះវិន័យបិដក** នៃ

ចីវរក្ខន្ធកៈ ដូចមានសេចក្តីថា ៖

ព្រះសយម្ភូ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគហបតីចីវរ តែភិក្ខុណាបំណងនឹងប្រើប្រាស់សំពត់បង្សុកូលចីវរ ក៏ចូរប្រើប្រាស់សំពត់បង្សុកូលចីវរនោះចុះ តែបំណងនឹងប្រើប្រាស់គហបតីចីវរ ក៏ចូរប្រើប្រាស់គហបតីចីវរចុះ តថាគតតែងតែសរសើរការត្រេកអរ ចំពោះបច្ច័យដែលតាមមានតាមបាន ។ គ្រានោះ ពុទ្ធបរិស័ទនៅក្រុងរាជគ្រឹះ បានជ្រាបដល់ពុទ្ធានុញ្ញាតនោះហើយ ក៏នាំគ្នាមានចិត្តត្រេកអរថា ឥឡូវនេះ ពួកយើងបានថ្វាយទាន និងបានធ្វើបុណ្យ ព្រោះព្រះមានជោគទ្រង់អនុញ្ញាតគហបតីចីវរ ដល់ភិក្ខុសង្ឃទាំងឡាយហើយ ។ ក្នុងវេលាត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ចីវរច្រើនពាន់ផ្ទាំងបានកើតឡើងក្នុងក្រុងរាជគ្រឹះ ។ ចំណែកពុទ្ធបរិស័ទ ដែលជាអ្នកនៅតាមជនបទ បានជ្រាបដំណឹងដូច្នោះហើយ ក៏នាំគ្នាមានចិត្តត្រេកអរវីកវាយ ថែមទាំងបាននាំគ្នាចាត់ចែងចីវរប្រគេនដល់ភិក្ខុសង្ឃទាំងឡាយជាច្រើនពាន់ផ្ទាំងដូចគ្នាដែរ ។

ក្នុងគ្រានោះ **សំពត់ជាវារ** (សំពត់សូត្រ) និងសំពត់រោមសត្វ បានកើតឡើងទៀត ព្រះបរមសាស្តាក៏ត្រាស់អនុញ្ញាតឲ្យទទួលប្រគេន បានថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសង្ឃទទួលសំពត់ **កោសេយ្យជាវារ** និងសំពត់រោមសត្វបាន ។ កាលតមក ពេទ្យជីវក: បានទទួលវង្វាន់ដោយព្រះរាជានៃដែនកាសី (ព្រះអនុជរួមព្រះបិតាជាមួយព្រះបាទបសេនទិកោសល) ទ្រង់ព្រះករុណាបញ្ជូនសំពត់កម្ពលមានតម្លៃ ៥០០ កហាបណៈ ទៅឲ្យដល់ពេទ្យជីវកកោមារភច្ច ។ កាលនោះ ពេទ្យជីវក:បានកាន់សំពត់កម្ពលនោះ ទៅចូលគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់កម្ពលនេះមានតម្លៃ ៥០០ កហាបណៈ ដែលព្រះបាទកាសី ទ្រង់បញ្ជូនមកឲ្យដល់ខ្ញុំព្រះករុណា ហេតុដូច្នេះ សូមព្រះពុទ្ធអង្គទ្រង់ប្រោសមេត្តា ទទួលសំពត់កម្ពលនេះរបស់ខ្ញុំព្រះអង្គ ដើម្បីឲ្យកើតជាប្រយោជន៍ និងសេចក្តីសុខដល់ខ្ញុំព្រះករុណាអស់កាលជាយូរអង្វែងផងចុះ ព្រះអង្គ ។ គ្រានោះ ព្រះសាស្តាទ្រង់ទទួលសំពត់កម្ពលនោះ ហើយទ្រង់សម្តែងធម៌ឲ្យដល់ពេទ្យជីវក:

ចប់ហើយ ពេទ្យជីវក:បានក្រាបទូលលា ព្រះលោកនាថត្រឡប់ទៅវិញ ហើយទើបព្រះអង្គត្រាស់អនុញ្ញាតឲ្យដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតឲ្យទទួលប្រគេនសំពត់កម្ពលបាន ។

ពេទ្យជីវកកោមារភច្ច បានក្រាបទូលព្រះជិនស្រី ដើម្បីឲ្យទ្រង់បញ្ញត្តសិក្ខាបទ ហាមភិក្ខុទាំងឡាយ មិនឲ្យបំបួសដល់កុលបុត្រ ដែលកើតរោគ ៥ ប្រការ មានរឿងសម្តែងទុកនៅក្នុងព្រះបាលី **មហាខន្ធក: គម្ពីរមហាវគ្គ ព្រះវិន័យបិដក** ក្នុង **អន្តរាយិកធម៌** ដែលពោលដោយរោគ ៥ ប្រការ ដូចមានសេចក្តីថា ៖

ក្នុងសម័យនោះ នៅឯមគធជនបទ បានកើតរោគរាតត្បាតឡើង ៥ ប្រភេទ បានដល់ ១- រោគឃ្លង់ ២- រោគបួស ៣- រោគស្រែង ៤- រោគហឺត ៥- រោគឆ្អួតជ្រក ។ បុគ្គលទាំងឡាយ កើតរោគ ៥ ប្រភេទដូចគ្នាជាចំនួនច្រើន ទើបនាំគ្នាទៅរកពេទ្យជីវក: ហើយជ្រាប់ថា លោកអាចារ្យ សូមលោកមេត្តាជួយព្យាបាលឲ្យដល់ពួកខ្ញុំផង ។ គ្រានោះ ពេទ្យជីវក:ពោលថា នែអ្នកទាំងឡាយ ខ្ញុំមានកិច្ចការងារ ដែលត្រូវធ្វើ

ច្រើនណាស់ គឺខ្ញុំត្រូវមើលថែរក្សាព្រះបាទពិម្ពិសារ ត្រូវបម្រើពួកអ្នកខាងក្នុងរាជវាំង ដែលមានការឈឺថ្ពាត់ ថែមទាំងជួយព្យាបាលភិក្ខុសង្ឃដែលមានព្រះពុទ្ធជាប្រធានទៀតផង ខ្ញុំមិនអាចមានពេលវេលាមកជួយព្យាបាលពួកអ្នកទាំងអស់គ្នាបានទេ ។ បុគ្គលទាំងនោះ បាននាំគ្នាអង្វរថា លោកអាចារ្យ ទ្រព្យសម្បត្តិទាំងអស់របស់ពួកខ្ញុំ សូមលើកឲ្យដល់លោកអាចារ្យ ហើយពួកខ្ញុំ"ក៏ចំខ្លួនធ្វើជាទាសៈរបស់លោកដែរ សូមលោកអាចារ្យមេត្តាជួយព្យាបាលឲ្យពួកខ្ញុំផងចុះ ។ លំដាប់នោះ ទើបពេទ្យជីវកៈពោលថា ខ្ញុំមានកិច្ចការងារដែលត្រូវធ្វើច្រើនណាស់ ដូចជាខ្ញុំបានជម្រាបពួកអ្នកទាំងអស់គ្នាឲ្យបានជ្រាបហើយតើ ។ បុគ្គលទាំងនោះ ទើបនាំគ្នាគិតថា ព្រះសមណសក្យបុត្រទាំងនោះ ជាអ្នកមានសេចក្តីសុខសប្បាយជានិច្ច មានការប្រព្រឹត្តយ៉ាងសប្បាយ មានអាហារក៏ល្អ មានបន្ទប់ដេកក៏ល្អដែរ បើដូច្នោះ ពួកយើងគួរបួសនៅក្នុងសម្នាក់របស់ព្រះសមណសក្យបុត្រទាំងនោះ ហើយប្រាកដជាពេទ្យជីវកៈកោមារភច្ចៈទំនុកបម្រុង និងជួយព្យាបាលពួកយើងមិនខាន ។ កាលអ្នកទាំងនោះ

គិតឃើញដូច្នេះហើយ ទើបនាំគ្នាចូលទៅរកភិក្ខុទាំង៦ឡាយ ពិតសូមបព្វជ្ជាចំពោះភិក្ខុទាំង៦ឡាយនោះ ហើយភិក្ខុទាំង៦ឡាយនោះ ក៏បានឲ្យបព្វជ្ជាឧបសម្បទាទៅតាមបំណងរៀងៗ ខ្លួនទៅ ។

សម័យតមក ភិក្ខុទាំង៦ឡាយ មានការកើតរោគអាពាធជាច្រើន ភិក្ខុទាំង៦ឡាយបាននាំគ្នាទំនុកបម្រុងភិក្ខុអាពាធទាំងនោះ ហើយភិក្ខុអាពាធទាំងនោះ ក៏មានការសូមច្រើន គឺសូមថា លោកទាំង៦ឡាយ ចូរឲ្យអាហារសម្រាប់ភិក្ខុឈឺ ចូរឲ្យអាហារសម្រាប់ភិក្ខុដែលជាអ្នកជួយព្យាបាលភិក្ខុដែលអាពាធ ចូរឲ្យភេសជ្ជៈសម្រាប់ភិក្ខុអាពាធ ។ ចំណែកពេទ្យជីវក: តែងទៅជួយព្យាបាលភិក្ខុអាពាធទាំងនោះ ទើបមានពេលវេលាតិចតួចទៅប្រតិបត្តិព្រះរាជា ឬទៅជួយព្យាបាលអ្នកនៅក្នុងរាជវាំង ។ មានបុរសម្នាក់កើតរោគ ៥ ប្រភេទនោះ បានចូលទៅរកពេទ្យជីវក: ហើយជម្រាបថា បពិត្រលោកអាចារ្យ សូមលោកមេត្តាជួយព្យាបាលឲ្យខ្ញុំផងចុះ ។ ចំណែកពេទ្យជីវក:ទើបពោលទៅរកបុរសនោះថា នែអ្នកដ៏ចម្រើន ខ្ញុំមានកិច្ចការងារ ដែលត្រូវធ្វើច្រើនណាស់ ត្រូវទៅជួយមើលថែរក្សា

ព្រះបាទពិម្ពិសារ និងពួកព្រះញាតិវង្សានុវង្ស ទាំងកិកុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដូច្នេះ ខ្ញុំមិនមានពេលវេលាមកជួយព្យាបាលលោកទេ សូមទោសផងណា ។ គ្រានោះ បុរសនោះបានពោលអង្វរថា បពិត្រលោកអាចារ្យ ទ្រព្យសម្បត្តិទាំងអស់របស់ខ្ញុំ សូមលើកជូនដល់លោក ហើយខ្ញុំរ៉ាប់ខ្លួនធ្វើជាទាសៈរបស់លោកដែរ ឲ្យតែលោកអាចារ្យជួយព្យាបាលឲ្យពួកខ្ញុំ ។ រីឯពេទ្យជីវកៈ ក៏បានពោលចង្អុលបង្ហាញឲ្យបុរសនោះបានស្គាប់ដល់កាពជាអ្នកមានកិច្ចការងារច្រើន ដូចដែលបានពោលមកហើយនោះ ។ ទើបបុរសនោះគិតថា សមណសក្យបុត្រទាំងឡាយ ជាអ្នកមានសេចក្តីសុខសប្បាយជានិច្ច ទាំងអាហារ និងទីដេកក៏ល្អ បើដូច្នោះ យើងគួរបួសនៅក្នុងសម្នាក់សក្យបុត្រទាំងនោះ កាលបើយើងបួសហើយ កិកុសង្ឃក្តី ពេទ្យជីវកៈក្តី នឹងជួយព្យាបាលយើង ឬក៏មើលថែទាំយើង កាលបើយើងជារោគហើយ យើងនឹងលាសិក្ខា (សឹក) លុះគិតយើញដូច្នោះហើយ ទើបចូលទៅរកកិកុសង្ឃដើម្បីសូមបព្វជ្ជាចំពោះកិកុទាំងឡាយៗ នោះក៏បានឲ្យបុរសនោះបព្វជ្ជា

ឧបសម្បទាទៅតាមចំណង់ដែលខ្លួនប្រាថ្នានោះ ។ កាលភិក្ខុនោះបព្វជ្ជារួចហើយ ភិក្ខុទាំងឡាយដឹងថា ភិក្ខុរូបនេះមានអាពាធ ទើបនាំគ្នាជួយព្យាបាលមើលថែរក្សា ចំណែកពេទ្យជីវក:ក៏បានមកជួយព្យាបាលដែរ ។ កាលភិក្ខុអាពាធនោះជាពេគហើយ ទើបលាសិក្ខាទៅជាឃរាវាសវិញ ។ ពេទ្យជីវក:បានឃើញបុរសនោះលាសិក្ខាហើយ ទើបសួរបុរសនោះថា អ្នកបួសនៅក្នុងសម្នាក់របស់ភិក្ខុទាំងឡាយមិនមែនឬ ?បុរសនោះជម្រាបតបថា មែនហើយលោកអាចារ្យ ។

លំដាប់នោះ ទើបពេទ្យជីវក:បានសួរតទៅទៀតថា អ្នកបានធ្វើប្រវត្តិការណ៍ដូច្នោះ ដើម្បីបំណង់ដូចម្តេច ? បុរសនោះ ទើបនិទានរឿងរ៉ាវនោះឲ្យពេទ្យជីវក:បានជ្រាបទាំងអស់ ។ គ្រានោះ ពេទ្យជីវក:បានសម្លឹងឃើញទោសដូច្នោះហើយ ទើបតិះដៀលថា ហេតុអ្វីលោកម្ចាស់ទាំងឡាយ ទើបបានឲ្យកុលបុត្រដែលកើតរោគ ៥ ប្រការបួសហើយពេទ្យជីវក: ទើបបានចូលទៅគាល់ព្រះជិនស្រី ថ្វាយបង្គំរួចហើយអង្គុយនៅក្នុងទីដ៏សមគួរ ហើយបានក្រាបទូលសូមពរចំពោះព្រះមុនីថា

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណាសូមព្រះវរោកាស សូមកុំឲ្យលោកម្ចាស់ទាំងឡាយ បំបួសកុលបុត្រដែលកើតរោគ ៥ ប្រការឡើយ ព្រះអង្គ ។លំដាប់នោះ ព្រះមុនីទ្រង់ពន្យល់ឲ្យពេទ្យជីវក: ឲ្យឃើញច្បាស់ ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ពេទ្យជីវក: កាលបានស្តាប់ធម្មកថានោះរួចហើយ ទើបក្រោកឡើងចាកទីអង្គុយ ថ្វាយបង្គំព្រះមុនី ធ្វើប្រទក្សិណ ហើយក៏ត្រឡប់ទៅវិញ ។ លំដាប់តពីនោះ ព្រះកគវាទ្រង់កាន់យកហេតុនោះជាមូលនៃហេតុដំបូង ទើបត្រាស់ហៅភិក្ខុទាំងឡាយ មកថា ម្នាលភិក្ខុទាំងឡាយ កុលបុត្រកើតរោគ ៥ ប្រភេទ ភិក្ខុមិនគួរឲ្យបព្វជ្ជា ភិក្ខុណាឲ្យបព្វជ្ជា ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

មូលហេតុនៃការកើតស្ថានទីចង្រ្កម និងរោងភ្លើងសម្រាប់ទុកប្រើជាទីបរិហារ និងកម្តៅកាយរបស់ភិក្ខុសង្ឃទាំងឡាយ ទាក់ទងមកអំពីពេទ្យជីវកកោមារភច្ច ជាអ្នកក្រាបទូលសូមចំពោះព្រះលោកនាថ ដូចមានរឿងសម្តែងប្រាកដក្នុងព្រះបាលី ***ខុទ្ទកវត្ថុក្ខន្ធក: គម្ពីរចុល្លវគ្គ ព្រះវិន័យបិដក*** ដូចមានសេចក្តីថា ៖

សម័យដែលកិកុទាំងឡាយ ទៅស្នាក់នៅឯក្រុងវេសាលី ពួកទាយក និងទាយិកាដែលនៅក្នុងក្រុងវេសាលី បាននាំគ្នាចម្អិនអាហារដ៏ប្រណីត ប្រគេនដល់កិកុសង្ឃទាំងឡាយ ។ កិកុទាំងនោះឆាន់អាហារដ៏ប្រណីតទាំងនោះហើយ រាងកាយក៏ធាត់ទ្រលុកត្រលន់ តែជារាងកាយដែលមានអាពាធច្រើន ។ កាលនោះ ពេទ្យជីវក:បានទៅឯក្រុងវេសាលី ដោយធុរៈចាំបាច់ណានីមួយ ហើយបានទៅឃើញកិកុសង្ឃទាំងនោះ ដែលមានរាងកាយធាត់ទ្រលុកត្រលន់ខុសប្រក្រតី តែជាអ្នកមានអាពាធច្រើន ។ កាលពេទ្យជីវក:ឃើញដូច្នោះហើយ ទើបចូលទៅគាល់ព្រះលោកនាថ ថ្វាយបង្គំរួចហើយ អង្គុយក្នុងទីដ៏សមគួរ បានក្រាបទូលព្រះពុទ្ធអង្គថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កិកុសង្ឃទាំងឡាយមានរាងកាយធាត់ទ្រលុកត្រលន់ខុសប្រក្រតី តែជាអ្នកមានអាពាធច្រើន ខ្ញុំព្រះករុណាសូមវេកាស សូមព្រះអង្គ ទ្រង់អនុញ្ញាតទីចង្រ្កម និងរោងភ្លើងដល់កិកុទាំងឡាយនោះផង កិកុទាំងឡាយនោះ នឹងជាអ្នកមិនសូវសម្បុរទៅដោយអាពាធ ព្រះអង្គ ។ គ្រានោះ ព្រះលោកនាថ

ក៏ទ្រង់សម្តែងធម្មីកថាឲ្យដល់ពេទ្យជីវក: ឲ្យឃើញច្បាស់ ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ ចំណែកពេទ្យជីវក: ក្រោកឡើងចាកទីអង្គុយ ថ្វាយបង្គំព្រះមានជោគ ហើយធ្វើប្រទក្សិណត្រឡប់ទៅវិញ ។ លំដាប់តអំពីនោះ ព្រះសម្ពុទ្ធ ទ្រង់សម្តែងធម្មីកថា ប្រារព្ធហេតុនោះជាមូលនៃបឋមហេតុកើតឡើង ហើយព្រះអង្គត្រាស់អនុញ្ញាតឲ្យដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យមានទីចង្រ្កមនិងរោងភ្លើងបាន ។

ការធ្វើនាទីព្យាបាលរបួស ដែលពេទ្យជីវកកោមារភច្ចធ្វើថ្វាយដល់ព្រះមានព្រះភាគ មានរឿងពោលទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **អរហន្តវគ្គ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសក្យមុនី ប្រថាប់នៅក្នុងចម្ការស្វាយរបស់ពេទ្យជីវកកោមារភច្ច ដោយទ្រង់ប្រារព្ធបញ្ហា ដែលពេទ្យជីវក:ក្រាបទូលសួរ និងបានត្រាស់ព្រះធម្មទេសនាទូន្មានពេទ្យជីវក:ផង ។ ក្នុងសម័យមួយ ភិក្ខុទេវទត្តបានរួមគំនិត ជាមួយព្រះបាទអជាតសត្រូវ

ដែលទ្រង់ជាព្រះរាជឱរសរបស់ព្រះបាទពិម្ពិសារ ហើយបានឡើងទៅលើកំពូលភ្នំគិជ្ឈកូដ ដោយបានគិតប្រទូស្តព្រះទេវទត្ត ដោយគិតថា យើងនឹងផ្តាច់ព្រះជន្មព្រះសម្ពុទ្ធ ។ កាលព្រះសាស្តា កំពុងយាងចង្រ្កមទើបភិក្ខុទេវទត្តប្រមៀលថ្មចុះមក ដើម្បីឲ្យសង្កត់ព្រះអង្គអស់ព្រះជន្ម ។ តែផលប្រាកដជាថា ព្រះវិជិតមារមិនបានទទួលអន្តរាយដល់អស់ព្រះជន្ម តាមដែលភិក្ខុទេវទត្តប៉ុនប៉ងនោះទេ ព្រោះមានកំពូលភ្នំពីរឱនមកទទួលថ្មមុន ដែលភិក្ខុទេវទត្តប្រមៀលចុះមកនោះទុក ហើយព្រះអង្គ ក៏បានរួចផុតអំពីអន្តរាយទាំងនោះ ដោយបានទទួលអន្តរាយតែបន្តិចបន្តួចប៉ុណ្ណោះ គឺមានចំរៀកថ្មដែលបែកខ្ចាយចេញពីថ្មភ្នំនោះ ខ្ចាតទៅចំព្រះបាទរបស់ព្រះសម្ពុទ្ធ រហូតធ្វើឲ្យព្រះបាទពុះពងព្រះលោហិត ធ្វើឲ្យព្រះអង្គមានការឈឺចាប់ ។ (ម្យ៉ាងមានរឿងសម្តែងបុព្វកម្មក្នុងកណ្ឌនេះ នៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** នៃ **បុព្វកម្ម បិលោតិកៈ** ដោយព្រះភគវាត្រាស់និទានបុព្វកម្មរបស់ព្រះអង្គថា ក្នុងកាលមុន តថាគតធ្លាប់បានសម្លាប់ប្អូនប្រុស ដែលមានមាតាផ្សេងគ្នា ព្រោះរឿងទ្រព្យ

ជាដើមហេតុ ដោយបានបោកប្លន់ប្រុសទៅក្នុងព្រៃកក្នុំ ហើយយកថ្នមបំ
ដោយផលកម្មនោះ ទើបធ្វើឲ្យកិកូទេវទត្តប្រមៀលថ្មដើម្បីផ្តាច់ព្រះជន្ម
តថាគត ប៉ុន្តែតថាគតមិនបានអស់ព្រះជន្មទៅវិញ គ្រាន់តែអម្បែងថ្ម
ខ្ចាតមកប៉ះព្រះបាទរបស់តថាគតប៉ុណ្ណោះ) ។ កិកូទាំងឡាយជួយនាំ
ព្រះវិជិតមារទៅឯចម្ការមទូកុច្ឆិ តែព្រះសម្ពុទ្ធព្រះអង្គមានព្រះបំណង
យាងចេញអំពីចម្ការមទូកុច្ឆិ ទៅកាន់ចម្ការស្វាយរបស់ពេទ្យជីវក: ទើប
ត្រាស់ថា ម្នាលកិកូទាំងឡាយ ពួកអ្នកចូរនាំតថាគតទៅឯចម្ការស្វាយ
របស់ពេទ្យជីវក:វិញ ។ ទើបកិកូទាំងឡាយ យាងព្រះលោកនាថទៅឯ
ចម្ការស្វាយរបស់ពេទ្យជីវក: តាមព្រះបំណង ។

ចំណែកពេទ្យជីវកកោមារភច្ច បានជ្រាបរឿងដែលព្រះសម្ពុទ្ធ
ទ្រង់ព្រះប្រឈួន ហើយយាងមកគង់ប្រថាប់ឯចម្ការស្វាយរបស់ខ្លួន
ទើបប្រញាប់ចូលទៅគាល់ព្រះភគវា បានថ្វាយថ្នាំបន្ទះ ដែលសក្តិសិទ្ធិ
ដើម្បីប្រយោជន៍ផ្សះរបួស ហើយរុំរបួសស្រេចហើយ បានក្រាបទូល
សូមអនុញ្ញាតពីព្រះវិជិតមារថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណា

បានដាក់ថ្នាំឲ្យដល់មនុស្សម្នាក់ ដែលនៅខាងក្រៅព្រះនគរ ខ្ញុំព្រះករុណានឹងទៅឯផ្ទះរបស់អ្នកនោះសិន ហើយនឹងត្រឡប់មកគាល់ព្រះមុនីវិញ ចំណែកថ្នាំ ដែលខ្ញុំព្រះករុណាបានរុំទុកនេះ សូមព្រះអង្គកុំធ្វើអ្វីសោះ ទម្រាំតែខ្ញុំព្រះករុណាត្រឡប់មកគាល់ព្រះអង្គវិញ ។ កាលពេទ្យជីវក: បានទៅជួយព្យាបាលឲ្យបុរសនោះ តាមដែលសន្យាស្រេចហើយ ទើបប្រញាប់ត្រឡប់មកវិញ ដើម្បីនឹងមកគាល់ព្រះមានបុណ្យ តែគេមកក្នុងវេលាដែលគេបិទទ្វារព្រះនគរហើយមកមិនបានគេមានគំនិតស្មុគស្មាញក្នុងព្រះទសពលថា មែនពិត យើងបានធ្វើកម្មធ្ងន់ហើយ ព្រោះយើងបានថ្វាយថ្នាំបន្ទះខ្លាំង និងរុំមុខរបួសព្រះបាទរបស់ព្រះសាស្តាទុក ដូចជាមនុស្សសាមញ្ញ ហើយពេលនេះជាពេលដែលត្រូវប្តូរសំពត់ដែលរុំរបួសទុក កាលរបួសដែលយើងមិនទាន់បានផ្ទាស់សំពត់រុំរបួសចេញទេ ព្រះវរកាយរបស់ព្រះមហាមុនីនឹងក្តៅរោលរាល រហូតអស់មួយរាត្រីមិនខាន ។ ខណៈនោះ ព្រះភគវាត្រាស់ហៅព្រះអានន្ទមកគាល់បញ្ជាថា ម្នាលអានន្ទ ពេទ្យជីវក: ត្រឡប់មកមិនទាន់ ត្រូវគេបិទទ្វារព្រះនគរ

ហើយគេបានគិតថា ពេលនេះជាពេលដែលត្រូវផ្ទាស់ប្តូរសំពត់រុំរបួស ដែលបានរុំទុក ជូច្នោះអ្នកចូរស្រាយសំពត់ កន្ទែងរុំរបួសនេះចេញចុះ ។

គ្រានោះ ព្រះអានន្ទធ្វើតាមព្រះពុទ្ធតម្រាស់ ប្រាកដជា របួសជាជូចលំពង់ឈើផុតចាកអំពីដើមជូច្នោះដែរ ។ ខាងក្នុងវេលាអរុណរះថ្ងៃនោះឯង ពេទ្យជីវក:ប្រញាប់ប្រញាល់មកកាន់ពុទ្ធសម្នាក់ ដោយរួតរះ ហើយក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ការក្តៅក្រហាយកើតឡើងក្នុងព្រះវរកាយរបស់ព្រះអង្គឬទេ ព្រះអង្គ ? គ្រានោះ ព្រះសម្ពុទ្ធគ្រាស់តបជាធម៌ថា ម្នាលជីវក: ការក្តៅក្រហាយទាំងពួងរបស់តថាគតស្ងប់រម្ងាប់ហើយ ត្រង់គល់ពោធិ៍នោះ ហើយកាលព្រះអង្គនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ប្រពន្ធគាថាថា

សេចក្តីក្តៅក្រហាយ រមែងមិនមាន ដល់អ្នកដើរផ្លូវឆ្ងាយ (ផ្លូវកន្លារ ឬវដ្ត:) ដែលដល់ហើយ មិនមានសេចក្តីសោក រួចផុតហើយក្នុងធម៌ទាំងពួង (មានខន្ធ ធាតុ ជាដើម) ជាអ្នកលះកិលេសគ្រឿងរួបរឹតទាំងពួងបានហើយ ។

ក្នុងពេលដែលព្រះសាស្តា ទ្រង់ត្រាស់ព្រះធម៌ទេសនាចប់ មានមហាជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទៅតាមឧបនិស្ស័យរៀងៗ ខ្លួន ។

វត្តជីវកម្ពវន ដែលពេទ្យជីវក:កសាងថ្វាយជាវត្ត ដែលព្រះចុល្លបន្ថកត្ថេរ បានសម្រេចអរិយធម៌ថ្នាក់ជាន់ខ្ពស់នោះ មានរឿងពោលទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដូចមានសេចក្តីថា ៖

ព្រះចុល្លបន្ថកត្ថេរ បានមកចាំវស្សានៅក្នុងវត្តជីវកម្ពវន ហើយបានរៀនគាថា មួយគាថា ប្រើពេល ៤ ខែ ក៏នៅតែមិនចាំ ព្រះមហាបន្ថក: ដែលជាបងប្រុស ទើបបានបណ្តេញឲ្យចេញអំពីវត្តជីវកម្ពវនទៅ ទើបលោកមកឈរយំនៅខាងក្រៅវិហារ ។ក្នុងកាលនោះ ព្រះភគវាយាងចូលមកកាន់ក្រុងរាជគ្រឹះ ហើយបានគង់នៅត្រង់វត្តជីវកម្ពវននោះដែរ ។ គ្រានោះ ពេទ្យជីវក:បានជ្រាបដំណឹង ទើបប្រើឲ្យបុរសម្នាក់ទៅថា អ្នកចូរទៅក្រាបទូលនិមន្តព្រះសាស្តា ព្រមទាំងភិក្ខុសង្ឃ ៥ រយអង្គ ។ កាលនោះ ព្រះមហាបន្ថកត្ថេរ ជាកត្តុទេសក: គឺអ្នកចែកកត្តព្វ ហើយ

ទាំងជាអ្នកចាត់ភិក្ខុទៅកាន់ទីនិមន្តផ្សេងៗ ដែរ កាលបុរសនោះ មកនិមន្ត
ភិក្ខុសង្ឃចំពោះលោកៗទើបបានមានថេរវាចាថា អាត្មាអាចទទួលនិមន្ត
ដើម្បីភិក្ខុសង្ឃទាំងអស់បាន រៀរលែងតែព្រះចុល្លបន្ថក:មួយអង្គចេញ ។
គ្រានោះ ព្រះចុល្លបន្ថក:បានជ្រាបរឿងនោះហើយ ក៏កើតទោមនស្ស
យ៉ាងខ្លាំងឡើងទៀត ។ លំដាប់នោះ ព្រះលោកនាថ ទ្រង់ជ្រាបដល់ការ
បានត្រាស់ដឹងនូវអរិយធម៌ដ៏ប្រសើរ និងទ្រង់ជ្រាបហេតុការណ៍ ដូច្នោះ
ហើយ ទើបព្រះអង្គយាងទៅរកព្រះចុល្លបន្ថក: ហើយត្រាស់សួរថា
ម្នាលចុល្លបន្ថក: អ្នកយំព្រោះមានរឿងអ្វី ? ពេលនោះ ព្រះចុល្លបន្ថក:
ក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះបងប្រុសរបស់ខ្ញុំព្រះអង្គ
បានបណ្តេញខ្ញុំព្រះអង្គចេញ ។ គ្រានោះ ព្រះសាស្តាត្រាស់ថា ម្នាល
ចុល្លបន្ថក: លោកបងរបស់អ្នកមិនមានញាណជាគ្រឿងដឹងចិត្តរបស់
បុគ្គលដទៃ អ្នកឈ្មោះថា ជាបុគ្គលដែលព្រះពុទ្ធគប្បីនាំទៅបាន ព្រះអង្គ
ត្រាស់ដូច្នេះហើយ ទើបព្រះទសពល ទ្រង់បាននិម្មិតសំពត់សមួយផ្ទាំង
បានប្រទានឲ្យដល់ព្រះចុល្លបន្ថក: ហើយត្រាស់ទូន្មានថា អ្នកចូរកាន់

សំពត់សនេះទុក ហើយភាវនាថា **រជោ ហរណំ** ប្រែថា សំពត់ប្រឡាក់ធូលី ដូច្នេះជារឿយៗ ចុះ ។ កាលព្រះចុល្លបន្ថកៈកំពុងអង្អែលសំពត់.សនោះៗ ក៏ប្រឡាក់ដូចជាសំពត់ចាស់ លោកកាន់តែអង្អែលរឿយៗ ក៏ធ្វើឲ្យសំពត់នោះ ដូចជាសំពត់សម្រាប់ជូតឆ្នាំងបាយ លោកអាស្រ័យភាពចាស់ក្លាំនៃញាណ ហើយពិចារណាការអស់ទៅនៃសង្ខារធម៌ថា ចម្រៀកសំពត់នេះ ជាសំពត់សបរិសុទ្ធតែសៅហ្មងហើយ ព្រោះអាស្រ័យរាងកាយដែលមានវិញ្ញាណជាអ្នកគ្រប់គ្រង សូម្បីចិត្តនេះក៏ដូចគ្នា ហើយលោកធ្វើសមាធិឲ្យកើតឡើង រហូតបានសម្រេចនូវរូបាវចរជ្ឈាន ៤ ហើយធ្វើរូបាវចរជ្ឈាន ៤ ឲ្យជាបាទហើយ បានសម្រេចអរហត្តផល ព្រមដោយបដិសម្ភិទាទៀតផង ហើយបានសម្រេចនូវឈាន ដែលសម្រេចដោយចិត្តជាអ្នកអាចធ្វើមនុស្សម្នាក់ ឲ្យជាមនុស្សច្រើននាក់បានធ្វើមនុស្សច្រើននាក់ឲ្យមកជាម្នាក់បាន ហើយការបែកធ្លាយក្នុងព្រះត្រៃបិដក និងអភិញ្ញា ៦ បានកើតមានដល់លោក ព្រមជាមួយនឹងការបានសម្រេចអរហត្តមគ្គ ។

លុះព្រឹកឡើង ព្រះលោកនាយក ព្រមដោយភិក្ខុសង្ឃប្រមាណ

៤៩៩ អង្គ យាងទៅឯនិវេសន៍របស់ពេទ្យជីវក: ចំណែកព្រះចុល្លបន្ថក: មិនបាននិមន្តទៅឡើយ ព្រោះលោកត្រូវបង់ប្រុសមិនបានឲ្យនិមន្តទៅដើម្បីទទួលចង្ហាន់ នៅឯនិវេសន៍របស់ពេទ្យជីវក: ។ ចំណែកពេទ្យជីវក:ផ្តើមនឹងប្រគេនយាគូ ព្រះទសពលទ្រង់ប្រើព្រះហស្តបិទបាត្រទុក ទើបពេទ្យជីវក:ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ទើបព្រះអង្គ ទ្រង់មិនទទួល ? គ្រានោះ ព្រះសម្ពុទ្ធត្រាស់ថា ជីវក: ព្រោះថា នៅឯវិហារមានភិក្ខុមួយអង្គទៀត ។ ពេលនោះ ពេទ្យជីវក: ទើបប្រើឲ្យបុរសទៅថា នែបា អ្នកចូរទៅនិមន្តលោកម្ចាស់ ដែលលោកគង់នៅឯវិហារមក ។ ចំណែកព្រះចុល្លបន្ថក: ក្នុងពេលដែលបុរសនោះមិនទាន់ទៅដល់ ទើបនិម្មិតភិក្ខុឡើង ១០០០ រូប មិនឲ្យដូចគ្នា សូម្បីមួយអង្គៗ ឲ្យធ្វើកិច្ចការងារផ្សេងៗ គ្នា ដូចជាអង្គខ្លះ កាត់ចីវរ អង្គខ្លះដេរចីវរ អង្គខ្លះជ្រលក់ចីវរជាដើម ។ កាលបុរសនោះទៅឃើញភិក្ខុនៅឯវិហារមានសភាពច្រើនដូច្នោះ ទើបបានត្រឡប់មកក្រាប់ពេទ្យជីវក: វិញថា លោកម្ចាស់នៅឯវិហារមានច្រើនណាស់ ខ្ញុំមិនដឹងថា និមន្តលោក

ម្ចាស់អង្គណាមកទេ ។ ទើបពេទ្យជីវក:ក្រាបទូលសួរថា បពិត្រព្រះអង្គ
ដ៏ចម្រើន ភិក្ខុដែលនៅឯវិហារនោះឈ្មោះអ្វី ព្រះអង្គ ? គ្រានោះ ព្រះ
សាស្តាត្រាស់ថា ឈ្មោះចុល្លបន្ថក: ទើបពេទ្យជីវក: បញ្ជាបុរសនោះថា
អ្នកចូរទៅម្តងទៀត ហើយសួរឡើងថា លោកម្ចាស់អង្គណា ឈ្មោះ
ចុល្លបន្ថក: លុះជ្រាបហើយចូរនិមន្តលោកមក ។ លំដាប់នោះ បុរសនោះ
ក៏បានទៅឯវិហារម្តងទៀត ហើយសួរថា បពិត្រលោកម្ចាស់ទាំងឡាយ
លោកម្ចាស់អង្គណា ឈ្មោះថា ព្រះចុល្លបន្ថក: ? ភិក្ខុទាំងនោះបាន
ពោលព្រមគ្នាថា អាត្មានេះហើយឈ្មោះថា ចុល្លបន្ថក: ។ បុរសនោះ
ទើបត្រឡប់មកជ្រាប់ដល់ពេទ្យជីវក:វិញទៀតថា លោកនាយ ភិក្ខុទាំង
ឡាយនោះសុទ្ធតែជ្រាប់ថា អាត្មានេះហើយដែលឈ្មោះថាចុល្លបន្ថក:
ដូច្នេះ ខ្ញុំមិនដឹងថានិមន្តលោកម្ចាស់អង្គណាមកទេ ។ពេលនោះ ពេទ្យជីវក:
ក៏ដឹងបានដោយនយ័ថា ភិក្ខុដែលមានឫទ្ធិច្រើន ព្រោះជាអ្នកត្រាស់ដឹង
សច្ចធម៌ហើយ ទាំងនេះព្រោះពេទ្យជីវក: ជាអ្នកបានត្រាស់ដឹងសច្ចធម៌ដែរ
ទើបបញ្ជាបុរសនោះថា នែបា បើអង្គណានិយាយឡើងមុន អ្នកចូរចាប់

ជាយចីវរបស់កិក្ខុអង្គនោះទុក ហើយពិតថា ព្រះមានព្រះភាគត្រាស់បញ្ជាឲ្យមកនិមន្ត ។ បុរសនោះ បានទៅឯវិហារម្តងទៀត ហើយបានធ្វើតាមពាក្យដែលពេទ្យជីវក:ណែនាំហើយនោះ កាលទៅដល់វិហារបានធ្វើតាមពាក្យ ដូចដែលប្រាប់មកហើយ កិក្ខុប្រមាណមួយពាន់អង្គក៏បាត់ទៅបុរសនោះ ទើបបាននិមន្តព្រះចុល្លបន្ថក: មកឯនិវេសន៍របស់ពេទ្យជីវក: ។ ព្រះសម្មាសម្ពុទ្ធ ទើបទ្រង់ទទួលប្រគេនយាគូក្នុងខណៈនោះឯង ។

ចំណេះដឹងទាក់ទងនឹងគុណសម្បត្តិ របស់ពេទ្យជីវក:បានក្រាបទូលសួរព្រះលោកនាយក ដែលមានសម្តែងប្រាកដនៅក្នុងបាលី **គម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត** នៃ **ជីវកសូត្រ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះលោកនាថ គង់នៅជីវកម្ពវន គឺចម្ការស្វាយរបស់ពេទ្យជីវកកោមារភច្ច នាក្រុងរាជគ្រឹះ ។ គ្រានោះ ពេទ្យជីវក: ចូលទៅគាល់ព្រះភគវាដល់ទីគង់ប្រថាប់ថ្វាយបង្គំរួចហើយក៏អង្គុយក្នុងទីដ៏សមគួរ **ហើយបានក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន**

បុគ្គលដែលឈ្មោះជាឧបាសក ប្រកបដោយហេតុដូចម្តេច ព្រះអង្គ ? គ្រានោះ ព្រះមហាមុនីត្រាស់តបថា ជីវក: ដោយហេតុ ជាអ្នករាប់អានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ គឺជាទីពឹង ទីរឭក ទាំងនេះទើបឈ្មោះថា ជាឧបាសក ។ ***ពេទ្យជីវក:ក្រាបទូលសួរតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន តើប្រកបដោយហេតុយ៉ាងណា ទើបឈ្មោះថាឧបាសកជាអ្នកមានសីល ព្រះអង្គ ?*** ព្រះសាស្តាត្រាស់តបថា ជីវក: ដែលឈ្មោះថាឧបាសក ជាអ្នកមានសីលនោះ ១- ជាអ្នកវៀរចាកការសម្លាប់សត្វ ២- ជាអ្នកវៀរចាកការលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ ៣- ជាអ្នកវៀរចាកការប្រព្រឹត្តខុសចំពោះប្រពន្ធកូនអ្នកដទៃ ៤- ជាអ្នកវៀរចាកការនិយាយកុហក ៥- ជាអ្នកវៀរចាកការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ។ ដោយហេតុយ៉ាងនេះឯង ទើបឈ្មោះថាឧបាសកជាអ្នកមានសីល ។ ***ពេទ្យជីវក:ក្រាបទូលសួរតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន តើដោយហេតុយ៉ាងណា ឧបាសក ទើបឈ្មោះថាបដិបត្តិដើម្បីប្រយោជន៍ខ្លួន មិនបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ព្រះអង្គ ?***

ព្រះកគវាត្រាស់តបថា ជីវកៈ ដោយហេតុឧបាសកនោះ ១- ខ្ញុំឯង
ជាអ្នកមានសទ្ធាហើយ មិនបានបបួលអ្នកដទៃឲ្យមានសទ្ធាដែរ ២- ខ្ញុំឯង
ជាអ្នកមានសីលហើយ មិនបានបបួលអ្នកដទៃឲ្យមានសីលដែរ ៣- ខ្ញុំឯង
ជាអ្នកមានការបរិច្ចាគហើយ មិនបានបបួលអ្នកដទៃឲ្យមានការបរិច្ចាគដែរ
៤- ខ្ញុំឯងជាអ្នកប្រាថ្នាឲ្យឃើញភិក្ខុសង្ឃហើយ មិនបានបបួលអ្នកដទៃ
ឲ្យប្រាថ្នាឃើញភិក្ខុសង្ឃដែរ ៥- ខ្ញុំឯងជាអ្នកត្រូវការដើម្បីស្តាប់ព្រះ
សទ្ធម្មហើយ មិនបានបបួលអ្នកដទៃ ឲ្យត្រូវការស្តាប់ព្រះសទ្ធម្មដែរ
៦- ខ្ញុំឯងជាអ្នកចាំព្រះធម៌ ដែលខ្ញុំឯងបានស្តាប់មកហើយ មិនបានបបួល
អ្នកដទៃឲ្យចាំព្រះធម៌ដែរ ៧- ខ្ញុំឯងជាអ្នកពិចារណាអត្ថនៃធម៌តែម្នាក់ឯង
មិនបានបបួលអ្នកដទៃឲ្យពិចារណាអត្ថនៃធម៌ដែរ ៨- ខ្ញុំឯងជ្រាបច្បាស់
ដល់អត្ថ និងធម៌ហើយ បដិបត្តិធម៌សមគួរដល់ធម៌តែម្នាក់ឯង មិនបាន
បបួលអ្នកដទៃឲ្យបដិបត្តិធម៌ដ៏សមគួរដល់ធម៌ដូចខ្ញុំផង ។ ម្នាលជីវកៈ
ដោយហេតុយ៉ាងនេះឯង ដែលឈ្មោះថា ឧបាសកជាអ្នកបដិបត្តិដើម្បី
ប្រយោជន៍ខ្លួនឯង មិនបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។

គ្រានោះ ពេទ្យជីវកកោមារភច្ចៈ បានក្រាបទូលសួរតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុយ៉ាងណា ទើបឧបាសកឈ្មោះថា ជាអ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួន និងដើម្បីប្រយោជន៍អ្នកដទៃផង ព្រះអង្គ ?ពេលនោះ ព្រះអង្គត្រាស់តបថា ម្នាលជីវក: ដោយហេតុឧបាសកនោះ ១- ខ្លួនឯងជាអ្នកមានសទ្ធា ហើយដឹកនាំអ្នកដទៃឲ្យមានសទ្ធាដែរ ២- ខ្លួនឯងជាអ្នកមានសីល ហើយដឹកនាំអ្នកដទៃឲ្យមានសីលដែរ ៣-ខ្លួនឯងជាអ្នកមានការបរិច្ចាគ ហើយដឹកនាំអ្នកដទៃឲ្យមានការបរិច្ចាគដែរ ៤- ខ្លួនឯងជាអ្នកប្រាថ្នាឲ្យឃើញភិក្ខុសង្ឃ ហើយដឹកនាំអ្នកដទៃឲ្យប្រាថ្នាឃើញភិក្ខុសង្ឃដែរ ៥- ខ្លួនឯងជាអ្នកត្រូវការ ដើម្បីស្តាប់ព្រះសទ្ធម្ម ហើយដឹកនាំអ្នកដទៃ ឲ្យត្រូវការស្តាប់ព្រះសទ្ធម្មដែរ ៦- ខ្លួនឯងជាអ្នកចាំព្រះធម៌ដែលខ្លួនបានស្តាប់មក ហើយដឹកនាំអ្នកដទៃឲ្យចាំព្រះធម៌ដែរ ៧- ខ្លួនឯងជាអ្នកពិចារណាអត្ថនៃធម៌ ដែលខ្លួនបានស្តាប់ហើយៗ ដឹកនាំអ្នកដទៃឲ្យពិចារណាអត្ថនៃធម៌ដែរ ៨- ខ្លួនឯងដឹងទូទៅនូវអត្ថ និងធម៌ ហើយបដិបត្តិធម៌សមគួរដល់ធម៌ហើយៗ ដឹកនាំ

អ្នកជនៃឲ្យបដិបត្តិធម៌ដ៏សមគួរដល់ធម៌ដែរ ។ ម្នាលជីវក: ដោយហេតុយ៉ាងនេះឯង ទើបឧបាសកឈ្មោះថា ជាអ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួនឯង និងប្រយោជន៍អ្នកជនៃផង ។

ពេទ្យជីវកកោមារភច្ច បានក្រាបបង្គំទូលទទួលយកអាសាព្រះបាទអជាតសត្តុ ដែលជាព្រះរាជានៃដែនមគធ: ឲ្យព្រះរាជាបានចូលទៅគាល់ព្រះលោកនាយក តាមដែលមានរឿងសម្តែងទុកនៅក្នុងបាលី ***គម្ពីរទីឃនិកាយ សីលក្ខន្ធវគ្គ*** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះលោកនាយក ព្រមដោយភិក្ខុសង្ឃប្រមាណ ១២៥០ អង្គ ប្រថាប់គង់នៅឯចម្ការស្វាយរបស់ពេទ្យជីវកកោមារភច្ច ជិតក្រុងរាជគ្រឹះ ក្នុងដែនមគធរដ្ឋ ។ កាលនោះ ព្រះបាទអជាតសត្តុ ដែលជាព្រះរាជានៃដែនមគធ: ទ្រង់ជាព្រះឱរសរបស់ព្រះបាទពិម្ពិសារ ជាមួយនឹងព្រះនាងវេទេហី ។ ក្រោយអំពីព្រះអង្គទ្រង់ធ្វើបិតុឃាត គឺទ្រង់សម្លាប់ព្រះរាជបិតាហើយ ក៏ទ្រង់កើតការមិនសប្បាយក្នុងព្រះរាជហឫទ័យ គឺទ្រង់ផ្ទុំមិនបាន ព្រោះតែសេចក្តីក្តៅក្រហាយចិត្ត ដែលខ្លួន

ធ្វើឲ្យព្រះរាជបិតាទ្រង់សោយទិវង្គតទៅ ទើបទ្រង់មានព្រះរាជបំណង
ដើម្បីស្វែងរកសមណព្រាហ្មណ៍ ជាអ្នកបរិបូណ៌ទៅដោយគុណធម៌
មានសីលស្អាតជាដើម ដែលអាចធ្វើឲ្យព្រះហឫទ័យរបស់ព្រះអង្គមាន
ការសប្បាយឡើងវិញបាន ហើយយាងចេញទៅប្រថាប់នាកណ្តាល
ពពួកមុខអមាត្យ និងរាជបរិវារក្នុងវេលារាត្រី ១៥ កើត ខែកត្តិក
ហើយទ្រង់ឧទានថា ម្នាលអមាត្យទាំងឡាយ រាត្រីថ្ងៃនេះមានដួងព្រះ
ចន្ទពេញវង់ បានភ្លឺព្រោងព្រាយ គួរមនោរមពន់ពេក រាត្រីនេះ មាន
ដួងព្រះចន្ទភ្លឺច្បាស់ល្អណាស់ហ្ន៎ គួរឲ្យរីករាយពន់ពេក ថ្ងៃនេះយើង
គួរនឹងទៅរកសមណៈ ឬព្រាហ្មណ៍ណាល្អហ្ន៎ ដែលអាចជួយធ្វើឲ្យចិត្ត
របស់យើងមានការសប្បាយឡើងវិញ ឬអស់នូវកាពសោកសៅ ថែម
ទាំងអស់នូវកាពក្តៅក្រហាយទៀតផង ។ គ្រានោះ មានពួកអមាត្យ ៦
នាក់ បានក្រាបទូលសរសើរគណាចារ្យទាំង ៦ នាក់ គឺបូរណកស្សប:
១ មក្ខលិគោសាល ១ អជិតកេសកម្ពល ១ បកុទ្ធកច្ចាយន: ១
សញ្ជ័យវេលដ្ឋបុត្រ ១ និគ្រន្ថនាដបុត្រ ១ ដែលខ្លួនរាប់អានរឿងៗ ខ្លួន

ឲ្យទ្រង់ជ្រាប ហើយក្រាបបង្គំទូលព្រះអង្គ ឲ្យស្តេចយាងទៅរកគណាចារ្យ ទាំង ៦ នាក់នោះ ។

តែព្រះបាទអជាតសត្តុ ទ្រង់មិនពេញព្រះរាជហឫទ័យ ទើបទ្រង់នៅស្ងៀម ។ ក្នុងពេលនោះ ពេទ្យជីវក:ដែលបានអង្គុយនៅជិតព្រះរាជា ព្រះបាទអជាតសត្តុនោះ ទើបព្រះរាជាមានព្រះរាជតម្រាស់សួរថា ជីវក: ហេតុអ្វី ទើបលោកនៅស្ងៀមយ៉ាងនេះ ? គ្រានោះ ពេទ្យជីវក:ឃើញឱកាសសមគួរ ទើបក្រាបបង្គំទូលឡើងថា ព្រះករុណាថ្លៃវិសេសវេលានេះ ព្រះជិនស្រីអរហន្តសម្មាសម្ពុទ្ធ ទ្រង់គង់នៅឯអម្ពវនវិហារ របស់ទូលព្រះបង្គំ ព្រមដោយភិក្ខុសង្ឃ សុទ្ធតែទ្រទ្រង់នូវគុណធម៌ មានប្រមាណ ១២៥០ អង្គ ព្រះវិជិតមារអង្គនោះ ទ្រង់មានព្រះកិត្តិសព្ទផ្សាយទូទៅថា **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គធ្វាយចាកសឹកសត្រូវ គឺ កិលេស ព្រមទាំងវាសនា គឺកាយបរិយោគ និងវចីបរិយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌

ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥ **សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គ មានដំណើរល្អយ៉ាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ជាក់ចោលហើយ គឺថា ព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

សូមព្រះករុណាជីវិតមគ្គល់លើតួង ស្តេចយាងទៅគាល់ព្រះភគវាចុះ ទូលបង្គំយើញថា កាលព្រះករុណាជីវិតមគ្គល់លើតួង ស្តេចយាងទៅគាល់ព្រះសម្ពុទ្ធហើយ ព្រះរាជហឫទ័យរបស់ព្រះអង្គប្រាកដជាសប្បាយ ឬមានភាពស្រស់ស្រាយឡើង អស់នូវភាពក្តៅក្រហាយក្នុងព្រះរាជ-ហឫទ័យ ។ គ្រានោះ ព្រះបាទអជាតសត្តុ មានព្រះរាជតម្រាស់ថា ជីវក: បើយ៉ាងនោះ លោកចូរឲ្យត្រៀមហត្ថីយាន គឺជីរព្រះទីនាំងរបស់យើង ជាមួយជីរបស់ពួកស្រីស្នំទាំងឡាយ ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ពេទ្យជីវក:ក្រាបបង្គំទូលស្នងព្រះរាជឱង្ការថា ករុណាថ្លៃវិសេស សូមទទួលព្រះរាជបញ្ជា ហើយទើបក្រាបថ្វាយបង្គំលាចេញ អំពីទីគាល់ទៅជ្រាប់ ឲ្យត្រៀមមេជីរប្រមាណ ៥០០ និងជីរព្រះរាជា ។

*ការឈ្វាសនិងសមត្ថភាព និងភាពស្មោះត្រង់របស់ពេទ្យជីវក: ពាប់ថា រកបុគ្គលប្រៀបធៀបបានដោយលំបាក តាមដែលមានរឿងសម្តែងទុកនៅក្នុង **គម្ពីរអដ្ឋកថាសុមង្គលវិលាសិនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **សាមញ្ញផលសូត្រ** ក្នុង **គម្ពីរទីឃនិកាយ***

សីលក្ខន្ធវគ្គ ដូចមានសេចក្តីថា ៖

កាលព្រះបាទអជាតសត្តុ បញ្ជាឲ្យពេទ្យជីវក:រៀបចំហត្ថីយាននោះ មានពាក្យសួរថា ព្រោះហេតុអ្វី ទើបពេទ្យជីវក: បានចាត់ហត្ថីយាន សុទ្ធតែមេដំរីដល់ទៅ ៥០០ ដោយព្រះបាទអជាតសត្តុមិនបានត្រាស់បញ្ជា ? មានពាក្យឆ្លើយថា ព្រោះថា ពេទ្យជីវក:ជាបុគ្គលឈ្លាស គឺលោកគិតថា កាលព្រះរាជាត្រាស់ថា យើងនឹងទៅក្នុងថ្ងៃនេះ ដូច្នេះ ប្រសិនបើព្រះរាជាទ្រង់ជួបអន្តរាយក្នុងវាងផ្លូវ បុគ្គលទាំងឡាយក៏នឹងតិះដៀលយើងបានថា ពេទ្យជីវក:បានយាងព្រះរាជាទៅ ក្នុងពេលដែលមិនសមគួរ ទាំងព្រះមុនីក៏ត្រូវបុគ្គលជនៃតិះដៀលបានថា ព្រះសមណ-គោតមទ្រង់មិនស្គាល់កាល ដែលឲ្យបុគ្គលទាំងឡាយចូលមកគាល់ព្រោះដូច្នោះ ទើបពេទ្យជីវក:បានចាត់ចែងការរក្សាយ៉ាងល្អ ដើម្បីមិនឲ្យមានការខូចខាតកើតឡើងដល់ខ្លួន និងព្រះភគវាសម្មាសម្ពុទ្ធ ។ ការដែលពេទ្យជីវក: ឲ្យស្រីស្នំឡើងជិះលើជីវតាមជង្ហែព្រះបាទអជាតសត្តុដល់ទៅ ៥០០ នាក់នោះ ព្រោះលោកគិតពិចារណាឃើញថា កយន្តរាយ

រមែងមិនមានដល់បុគ្គលទាំងឡាយ ព្រោះអាស្រ័យស្ត្រី បុរសដែលស្រើរហែហមទៅ រមែងជាសុខ ទើបលោកឲ្យស្រីស្នំ ៥០០ នាក់ តែងខ្ជួនជាបុរសកាន់ជាវ និងលំពែងគ្រប់គ្នា ឡើងជិះលើដីរម្នាក់មួយៗ ។ ក្រោយអំពីពេទ្យជីវក:រៀបចំស្រេចហើយ ទើបគិតថា ព្រះបាទអជាតសត្តុមិនមានឧបនិស្ស័យ ដែលនឹងត្រូវបានសម្រេចមគ្គផលក្នុងជាតិនេះទេ តែព្រះសយម្ភូទាំងឡាយ ទ្រង់រមែងជ្រាបឧបនិស្ស័យរបស់វេនេយ្យសត្វបានល្អ ហើយព្រះអង្គទើបទ្រង់សម្តែងធម៌ ព្រោះដូច្នោះ យើងនឹងត្រូវឲ្យមហាជនតាមហែហមព្រះរាជាទៅផង ទាំងកាលនេះ ពពួកមហាជនតាមព្រះរាជាទៅជាច្រើន ព្រះកគវាក៏ទ្រង់នឹងសម្តែងធម៌ ព្រោះដូច្នោះ យើងនឹងត្រូវឲ្យមហាជន បានតាមដង្ហែព្រះរាជាទៅផង ទាំងនេះកាលមហាជនតាមព្រះរាជាទៅច្រើន ព្រះសាស្តាទ្រង់ក៏នឹងសម្តែងធម៌ប្រោសដោយទ្រង់ឃើញឧបនិស្ស័យរបស់នរណាមួយដោយពិត ហើយព្រះធម៌ទេសនារបស់ព្រះសុគត ក៏នឹងជាប្រយោជន៍ដល់មហាជនដែលកំពុងប្រជុំគ្នា កាលលោកគិតឃើញដូច្នេះហើយ ទើបឲ្យមនុស្សវាយស្គរស្រែក

ប្រកាសទូទៅពេញព្រះនគរថា ក្នុងវេលារាត្រីនេះ **ចមរង្គិយាធិបតី** របស់យើងទាំងឡាយ នឹងយាងទៅគាល់ព្រះបរមគ្រូ ចូរមហាជនទៅចាត់ការរក្សាព្រះកុណាជីវិតតម្កល់លើត្បូងរបស់ពួកយើង តាមសមគួរដល់នាទីរបស់ខ្លួនរៀងៗ ខ្លួនចុះ ។

គ្រានោះ មហាជនបានស្តាប់ការប្រកាសដូច្នេះហើយ ទើបប្រឹក្សាគ្នាថា ក្នុងយប់នេះ ព្រះកុណារបស់ពួកយើង នឹងស្តេចយាងទៅគាល់ព្រះសាស្តា ព្រះធម្មទេសនារបស់ព្រះមានព្រះភាគដូចម្តេចហ្ន៎ យប់នេះពួកយើងមិនត្រូវការទៅមើលមហោស្រព ដែលរកប្រយោជន៍មិនបាន ពួកយើងនឹងនាំគ្នាទៅគាល់ព្រះសម្ពុទ្ធ ដើម្បីឲ្យបានទទួលនូវប្រយោជន៍ដ៏ប្រសើរ ។កាលមហាជនបានគិតឃើញដូច្នេះហើយ ទើបបានកាន់ផ្កា និងគ្រឿងក្រអូបជាដើម ទៅរង់ចាំទទួលព្រះបាទអជាតសត្តុនាផ្លូវដែលនឹងយាងចូលទៅគាល់ព្រះភគវា ។ រីឯពេទ្យជីវក:បានរៀបចំតុបតែងព្រះរាជពាហន:ស្រេចហើយ ទើបបានទៅក្រាបបង្គំទូលព្រះបាទអជាត-សត្តុថា បពិត្រព្រះកុណាជីវិតតម្កល់លើត្បូង ទូលបង្គំបានរៀបចំហត្ថី

យានសព្វគ្រប់ហើយ សូមព្រះករុណា ទ្រង់ធ្វើតាមព្រះរាជអធ្យាស្រ័យ
ក្នុងកាលឥឡូវនេះចុះ ព្រះអង្គ ។ គ្រានោះ ទើបព្រះបាទអជាតសត្តុ
យាងឡើងលើជ័រព្រះទីនង័ ដែលលម្អដោយជ័ររបស់ស្រីស្នំ ដែលមាន
ចំនួន ៥០០ ត្រកូល ស្រីស្នំបរិវារទាំងនោះ សុទ្ធតែតាក់តែងខ្លួនជាប្រុស
មានសំពត់ជូតក្បាល ស្ពាយដាវ និងកាន់កន្ទេរកែវមណី ហើយឡើងជិះ
គជសារចេញទៅចាកព្រះរាជដ្ឋាន ព្រមដោយរាជបរិវារជនៃទៀត មាន
ចំនួនជាច្រើន ទាំងពួកទត្តិយរាជស្រីស្នំ ១ ម៉ឺន ៦ ពាន់នាក់ទៀត ក៏បាន
តាមហែហមព្រះរាជាទៅផងដែរ ។ ស្រីស្នំ ១ ម៉ឺន ៦ ពាន់នាក់នោះ
បានហែហមក្បួនជ័រព្រះទីនង័ទៅ បន្ទាប់អំពីនោះទៅ ជាក្បួនដង្ហែរបស់
បុរសដែលមានទាទីក្សាព្រះរាជវាំង បានហែហមតាមក្រោយបន្តបន្ទាប់ទៅ
បន្ទាប់មកទៀត ជាពួកអាមាត្យ ៦ ម៉ឺននាក់ទៀត សុទ្ធតែតែងខ្លួន
ជាឯកសណ្ឋាន បន្ទាប់អំពីនោះទៅទៀត ជាពួកបុត្ររបស់ទត្តិយអមាត្យ
ប្រមាណ ៦ ម៉ឺននាក់ ម្នាក់ៗ សុទ្ធតែតែងខ្លួនដោយគ្រឿងអលង្ការច្រើន
ប្រភេទ ទាំងមានដៃកាន់អាវុធគ្រប់យ៉ាង ប្រៀបដូចវិទ្យាធរកំលោះ

ដែលទ្រទ្រង់នូវសក្តិដូច្នោះ បន្ទាប់អំពីនោះទៅជាពួកព្រាហ្មណ៍ ១ម៉ឺននាក់ សុទ្ធតែស្លៀកពាក់សំពត់ ដែលមានតម្លៃមួយផ្ទាំង ៥០០ កហាបណៈ ថែមទាំងតាក់តែងដោយគ្រឿងប្រដាប់ ដែលសមគួរសរសើរ មានផ្កាឈើមាសជាដើម និងលើកដៃស្តាំឡើង ស្រែកថ្វាយព្រះពរជ័យរំពងតាមផ្លូវទៅ ។

តអំពីក្បួនជង្ហែរបស់ពួកព្រាហ្មណ៍ ក៏ជាពួកតូរ្យតន្ត្រីសម្រាប់ប្រគំ បន្ទាប់អំពីតូរ្យតន្ត្រី ជាពួកទាហានកាន់ធ្នូយ៉ាងសង្ហារ បន្ទាប់អំពីក្បួនទាហាន ក៏ជាក្បួនដំរី ក្បួនសេះ ក្បួនរថ និងក្បួនថ្មើរជើង ១៨ កងទ័ពទៀត ។ អ្នកដែលឈរនៅខាងក្រៅ ក៏ការពារមិនឲ្យមនុស្សបាញ់ធ្នូចូលទៅ មិនអាចឲ្យធ្លាក់ដល់ព្រះរាជាបាន ។ កាលពេទ្យជីវក:បានចាត់ចែងរក្សាព្រះបាទអជាតសត្តុយ៉ាងល្អដូច្នេះហើយ ចំណែកខ្លួនឯងទើបតាមព្រះរាជាទៅក្នុងទីជិត ដោយគិតថា បើមានកយន្តរាយឯណានីមួយកើតឡើងដល់ព្រះរាជារបស់យើងហើយ យើងនឹងថ្វាយជីវិតរបស់យើងដល់ព្រះអង្គមុនអ្នកដទៃ ។ (ការដែលពេទ្យជីវក:គិត

ដើម្បីលះបង់ជីវិតដើម្បីព្រះបាទអជាតសត្តុនោះ ទាំងនេះរាប់ថា ជាអ្នកមានគុណធម៌ សុចរិតស្មោះត្រង់ ជាមនុស្សដែលរកបានដោយលំបាកក្រៃលែងនៅក្នុងលោកនេះ) ។

ការត្រៀមរៀបចំហត្ថីយាន ដើម្បីដង្ហែព្រះរាជាដែលពេទ្យជីវក: ជាអ្នកទទួលនាទី ជាអ្នកទទួលព្រះរាជឱង្ការ តាមអត្ថន័យដូចតទៅនេះ ដែលមានសម្តែងក្នុងបាលី **គម្ពីរទីឃនិកាយ សីលក្ខន្ធវគ្គ** ថា ៖

កាលពេទ្យជីវកកោមារភច្ច បានចាត់ចែងស្រេចបាច់ហើយ គេទើបចូលទៅក្រាបបង្គំទូលព្រះបាទអជាតសត្តុថា បពិត្រព្រះសម្មតិទេព ទូលបង្គំប្រាប់ឲ្យត្រៀមហត្ថីយានទុកសព្វគ្រប់ហើយ សូមព្រះករុណាជីវិតតម្កល់លើត្បូងយាងទៅក្នុងកាលឥឡូវនេះចុះ ព្រះអង្គ ។ គ្រានោះ ព្រះបាទអជាតសត្តុ ទើបឲ្យពួកស្ត្រីឡើងជំរីទាំង ៥០០ ម្នាក់មួយៗ ចំណែកព្រះអង្គទ្រង់ឡើងគង់ប្រថាប់លើជំរីព្រះទីនង័ និងមានអ្នកកាន់គប់ភ្លើងព្រោងព្រាតទៅទាំងខាងមុខ ខាងក្រោយ ខាងឆ្វេង ខាងស្តាំ ដង្ហែព្រះរាជដំណើរចេញអំពីក្រុងរាជគ្រឹះដោយព្រះរាជានុភាពដ៏ក្រៃលែង

ទ្រង់បែរមុខទៅចម្ការស្វាយរបស់ពេទ្យជីវក: ។ តែព្រះបាទអជាតសត្តុ
យាងទៅជិតដល់ជីវកម្ពវនវិហារហើយ ព្រះរាជាក៏ទ្រង់កើតមានការ
ភ័យខ្លាចព្រឺរោម ដោយបានឃើញសភាពស្ងប់ស្ងាត់ ដូច្នោះ ទើប
ព្រះរាជាត្រាស់សួរពេទ្យជីវក:ថា លោកមិនបានចោកបញ្ឆោតយើងមក
ទេឬ ? ឬថាលោកចោកបញ្ឆោតយើងមកឲ្យដល់សត្រូវ ព្រោះហេតុថា
ភិក្ខុសង្ឃសន្និកសន្ធាប់ដល់ទៅ ១២៥០ អង្គ ដែលលោកថា មាននៅក្នុង
វិហារនេះ តែហេតុអ្វីទើបមិនមានសំឡេងកណ្តាស សំឡេងគ្រហែមក្អក
ឬមិនមានសំឡេងចរចាអ្វីឡើយ ។ គ្រានោះ ពេទ្យជីវក:ក្រាបបង្គំទូល
តបថា សូមព្រះករុណាជីវិតម្តល់លើត្បូង កុំខ្លាចឡើយព្រះអង្គ ទូលបង្គំ
មិនបានចោកបញ្ឆោតព្រះអង្គមកឲ្យដល់សត្រូវទេ ព្រះអង្គ សូមព្រះអង្គ
ព្រះរាជដំណើរឆ្ពោះចូលទៅត្រង់ភេងនោះចុះ ឯភេងនោះនៅមានប្រទីបឆេះ
នៅឡើយ ព្រះអង្គ ។ ព្រះបាទអជាតសត្តុ ទ្រង់ព្រះរាជដំណើរដោយ
ក្បួនជ័រព្រះទីនង័ ទៅរហូតដល់ទីបំផុតនៃផ្លូវ ហើយយាងចុះអំពីជ័រព្រះ
ទីនង័ ទ្រង់បានព្រះរាជដំណើរទៅដោយព្រះបាទរហូតដល់ទ្វារភេងនោះ

ហើយមានព្រះរាជតម្រាស់ សួរពេទ្យជីវក:ថា ម្នាលជីវក: ព្រះភគវា
គង់ប្រថាប់នៅក្នុងទីណា ? ពេលនោះ ពេទ្យជីវក:ក្រាបទូលតបថា
ព្រះករុណាថ្លៃវិសេស ព្រះលោកនាថគង់ប្រថាប់ផ្អែកសសរកណ្តាល
ទ្រង់បែរព្រះកន្ត្រៃទៅកាន់ទិសបូព៌ ដែលមានភិក្ខុសង្ឃចោមរោមនៅនោះ
ព្រះអង្គ ។

គ្រានោះ ព្រះបាទអជាតសត្តុ ទ្រង់ជ្រាបតាមពេទ្យជីវក:ក្រាបទូល
ហើយ ទើបយាងចូលទៅគាល់ព្រះមុនី ប្រថាប់ឈរនៅក្នុងទីដ៏សមគួរ
នាចំណែកម្ខាង ហើយទ្រង់ទតឃើញភិក្ខុសង្ឃអង្គុយស្ងៀមស្ងាត់យ៉ាង
រៀបរយ ដូចជាអន្ទង់ទឹកថ្លា ដែលមានសភាពស្ងប់ស្ងៀមដោយរលកទឹក
ទ្រង់បានបន្ទឺព្រះឧទានឡើងថា សូមឲ្យព្រះឧទយកទូកុមារបស់យើង
មានការស្ងប់រៀបរយ ដូចជាភិក្ខុសង្ឃទាំងនេះ ។ លំដាប់នោះ
ទើបព្រះមហាវីរបុរសត្រាស់ថា មហាបពិត្រ ទ្រង់ពេញព្រះទ័យក្នុងពួក
ភិក្ខុសង្ឃដោយហេតុអ្វី ? ព្រះបាទអជាតសត្តុក្រាបទូលតបថា បពិត្រ

ព្រះមានបុណ្យ ដោយហេតុថា ភិក្ខុសង្ឃទាំងនេះ ស្ថិតនៅក្នុងសភាព
ស្ងប់ស្ងាត់រៀបរយ ខ្ញុំព្រះករុណាត្រូវការឲ្យព្រះឧទយភទ្រកុមារ ដែលជាទី
ស្រឡាញ់របស់ខ្ញុំព្រះករុណា ឲ្យមានសភាពយ៉ាងដូច្នោះដែរ ព្រះអង្គ ។
ហើយតអំពីនោះ ព្រះបាទអជាតសត្តុ ទ្រង់ឱនព្រះសិរសាចុះអភិវាទ
ព្រះលោកនាយក ហើយទ្រង់ក្រាបទូលបញ្ហាទាក់ទងនឹងសាមញ្ញផល
បានដល់ផលរបស់ភាពជាសមណៈ គឺប្រយោជន៍ដែលនឹងបានមកអំពី
ការតម្រង់កេរជាសមណៈ ដែលឃើញបានក្នុងបច្ចុប្បន្ន ហើយទ្រង់
ក្រាបទូលថា ធ្លាប់ទៅសួរគ្រូទាំង ៦ នាក់ មកហើយ តែគ្រូទាំងនោះ
ឆ្លើយមិនត្រូវចំពាក្យសួរ ប្រៀបដូចសួរដល់រឿងស្វាយ តែបែរទៅជា
ឆ្លើយរឿងខ្នុរទៅវិញ ដូច្នេះ ទើបខ្ញុំព្រះករុណា ត្រឡប់បញ្ហានោះមក
សួរព្រះអង្គវិញ ។ គ្រានោះ ព្រះជិនស្រី បានដោះស្រាយប្រាប់ដោយ
ពិស្តារ (តែនឹងសូមនាំមកពោលដោយបង្រួញល្មមជាគួយ៉ាង) ដូចមាន
សេចក្តីថា

បុគ្គលដែលធ្លាប់ជាទាសៈ ឬកម្មករបស់មហាបពិត្រ តែបាន កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវៈ ចេញបួស ជាបព្វជិត ប្រព្រឹត្តប្រតិបត្តិល្អ ហើយមហាបពិត្រទ្រង់ហៅឲ្យត្រឡប់មក ជាទាសៈ ឬកម្មករដូចដើមទៀតឬទេ ? គ្រានោះ ព្រះបាទអជាតសត្តុ ត្រាស់តបថា មិនហៅត្រឡប់ឲ្យមកទេ មានតែសម្តែងការគោរព ថ្វាយ បង្គំ ៤ និងប្រគេនការពារក្សាការពារយ៉ាងល្អ ។ ព្រះវិជិតមារ ត្រាស់ សរុបថា នេះឯងជាសាមញ្ញផល ដែលឃើញប្រចក្សក្នុងបច្ចុប្បន្ន ហើយ ទ្រង់ត្រាស់ដល់សាមញ្ញផលមាតិកាតទៅថា បុគ្គលធ្លាប់ជាអ្នកស្រែ គហបតីដែលបានបង់កាស៊ីអាករ បំពេញព្រះរាជទ្រព្យរបស់មហាបពិត្រ មកអំពីមុន តមកខាងក្រោយ បានកោរសក់ ពុកមាត់ ពុកចង្កា ស្លៀក ដណ្តប់សំពត់កាសាវៈ ចេញបួសជាបព្វជិត ប្រព្រឹត្តប្រតិបត្តិល្អ តាម គោលរបស់សមណវិស័យហើយ តើមហាបពិត្រនឹងទ្រង់ហៅឲ្យត្រឡប់ ទៅជាអ្នកស្រែ ជាគហបតីបង់តម្លៃកាស៊ីអាករ ដូចដើមមុនទៀតដែរឬ ?

ព្រះបាទអជាតសត្តុត្រាស់តបថា មិនហៅត្រឡប់ឲ្យមកធ្វើដូចដើមទេ មានតែនឹងសម្តែងការគោរព មានតែប្រគេនបច្ច័យ ៤ ថែមទាំងអភិបាលការពារយ៉ាងល្អទៀតផង ។ព្រះសម្ពុទ្ធត្រាស់សរុបថា នេះឯងសាមញ្ញផលដែលឃើញប្រចក្សក្នុងបច្ចុប្បន្ន ហើយបានត្រាស់ទាក់ទងនឹងរឿងចុល្លសីល មហាសីល ឥន្ទ្រិយសំវរៈ សតិសម្បជញ្ញៈ សន្តោសចិត្ត ប្រាសចាកនីវរណៈ រូបជ្ឈាន ៤ និងវិជ្ជា ៨ ប្រការ មានវិបស្សនាញាណ ។ល។ មានអាសវក្ខយញ្ញាណជាទីបំផុត ។ គ្រានោះ ព្រះបាទអជាតសត្តុទ្រង់ព្រះសណ្តាប់ហើយ បានក្រាបទូលសរសើរ ហើយទ្រង់ជ្រះថ្លា ទើបទ្រង់ប្រកាសខ្លួនព្រះអង្គជាឧបាសក អ្នកដល់ព្រះរតនត្រ័យជាសរណៈជាទីពឹង ជាទីរឭក ចាប់អំពីថ្ងៃនេះជាដើមទៅ រហូតដល់អស់ជីវិត ហើយទ្រង់ក្រាបទូលសូមខមាទោសកំហុស ដែលព្រះអង្គទ្រង់បានផ្តាច់ព្រះជន្មព្រះរាជបិតា ដែលជាអ្នកទ្រទ្រង់ធម៌ជាព្រះរាជាប្រកបដោយធម៌ ព្រោះហេតុដើម្បីត្រូវការភោពជាធំ សូមព្រះសក្យមុនីទទួលជ្រាបកំហុស

របស់ខ្ញុំព្រះករុណាថា ជាកំហុសពិត ដើម្បីសង្រួមប្រយត្នតទៅខាងមុខទៀត ព្រះអង្គ ។

គ្រានោះ ព្រះភគវា ទ្រង់បានទទួលការសូមខមាទោសកំហុសរបស់ព្រះបាទអជាតសត្តុ ដែលជួយឲ្យព្រះរាជហឫទ័យមានការសប្បាយរីករាយឡើងវិញ ។ ហើយកាលព្រះបាទអជាតសត្តុ យាងត្រឡប់ទៅវិញហើយ ព្រះសយម្ភូត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើព្រះបាទអជាតសត្តុ ទ្រង់មិនបានផ្តាច់ព្រះជន្មព្រះរាជបិតា ក៏នឹងបានធម្មចក្ខុ ហៅថា ជាព្រះសោតាបន្ន ។ រឿងដែលពេទ្យជីវក: ក្រាបទូលយាងព្រះបាទអជាតសត្តុមកគាល់ព្រះលោកនាថ ក្នុងទីបំផុត ព្រះរាជា ទ្រង់បានប្តេជ្ញាខ្លួន ជាឧបាសក នៅក្នុងព្រះពុទ្ធសាសនានេះ ធ្វើឲ្យទ្រង់មានសេចក្តីជ្រះថ្លា ទាំងនេះរាប់ថា ជាផលការងារឯករបស់ពេទ្យជីវក: ដែលនាំព្រះបាទអជាតសត្តុចូលមកកាន់ព្រះពុទ្ធសាសនា ដែលប៉ងនឹងជួយឲ្យព្រះបាទអជាតសត្តុផុតចាកការវេទ្ធនផ្លូវ គឺទ្រង់មិន

វង្វេងទៅរាប់អានបុគ្គលដែលមិនគួររាប់អាន ។ ការនាំយកបុគ្គលដែលជាប្រមុខរបស់ប្រទេសចូលមករាប់អានព្រះពុទ្ធសាសនាបាន ដូចជានាំយកប្រជាពលរដ្ឋរបស់ប្រទេសនោះ ចូលមករាប់អានព្រះពុទ្ធសាសនាព្រោះប្រជាពលរដ្ឋរបស់ប្រទេសនោះ រមែងនិយមធ្វើតាមលោកអ្នកដែលជាប្រមុខ ។ ពេទ្យជីវក:មិនមែនឆ្នាតឈ្លាស មានសមត្ថភាពក្នុងការពិនិត្យរោគពូកែតែម្យ៉ាងប៉ុណ្ណោះទេ តែលោកនៅមានសតិបញ្ញាក្នុងការពិចារណាជ្រើសរើសរាប់អានសាសនាជនៃផង ព្រោះក្នុងយុគ-សម័យនោះ មានលទ្ធិសាសនាជនៃច្រើនសន្ធឹកសន្ធាប់ ហើយម្ចាស់លទ្ធិក្នុងយុគសម័យនោះ ក៏មានវិធីការផ្សព្វផ្សាយលទ្ធិរបស់ខ្លួន ដោយការធ្វើឧបាយផ្សេងៗ ដើម្បីឲ្យបុគ្គលទាំងឡាយជឿ លោកក៏មិនបានជឿក្នុងលទ្ធិផ្សេងៗ ទាំងនោះ តែបានមករាប់អានព្រះពុទ្ធសាសនា រហូតដល់លោកបានជាអ្នកចូលដល់ក្រសែនៃធម៌ ឬក្រសែនៃព្រះនិព្វាន គឺបានជាព្រះសោតាបន្ន ហើយបានទទួលការលើកតម្កើងគុណធម៌ទាំងនោះ

ឲ្យជាអ្នកប្រសើរម្នាក់នៅក្នុងព្រះពុទ្ធសាសនានេះ ទើបរាប់ថាជាកិត្តិប្បវត្តិជាបុគ្គលគំរូ ។

កាលតមកខាងក្រោយ ព្រះលោកនាថប្រថាប់នៅឯវត្តជេតពនទ្រង់បានប្រកាសតែងតាំងពេទ្យជីវកកោមារភច្ចទុកក្នុងតំណែង ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ដែលមានសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ បុគ្គលប្បសន្នានំ យទិទំ ជីវកោកោមារភច្ចោ ម្នាលភិក្ខុទាំងឡាយ ជីវកកោមារភច្ចជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងញុំាងបុគ្គលឲ្យជ្រះថ្លា ។

(ជីវប្រវត្តិរបស់ពេទ្យជីវកកោមារភច្ចឧបាសក ចប់)

✍ ជីវប្រវត្តិរបស់នកុលបិតាគហបតីឧបាសក ✍

“ ជាអ្នកប្រសើរផ្នែកខាងជាអ្នកចេះនិយាយឱ្យអ្នកដទៃស្និទ្ធស្នាល ”

នកុលបិតាគហបតី ជាឧបាសក ដែលមានកិត្តិគុណដ៏កំពូលដែលបានទទួលការលើកតម្កើង អំពីព្រះភគវា ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងជាអ្នកចេះនិយាយឲ្យអ្នកដទៃស្និទ្ធស្នាល ។

ជីវប្រវត្តិរបស់នកុលបិតាគហបតី មានសម្តែងទុកក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖

នកុលបិតាគហបតី បានទៅកើតក្នុងត្រកូលអ្នកមានធនធានម្នាក់នៅក្នុងក្រុងហង្សវតី ត្រង់ទីងពុទ្ធកាលនៃព្រះបទុមុត្តរសម្ពុទ្ធ ហើយកាលទីងរាប់វេលាថយក្រោយត្រឡប់ទៅ អំពីកទូកប្បនេះបានមួយសែនកប្ប ។ ថ្ងៃមួយ កុលបុត្រ (នកុលបិតា) បានទៅស្តាប់ព្រះធម្មទេសនារបស់ព្រះបទុមុត្តរៈ ហើយបានឃើញព្រះលោកនាថ ទ្រង់ប្រកាសតែងតាំង

ឧបាសកម្នាក់ ទុកក្នុងតំណែងឯតទគ្គៈ ឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងជាអ្នកចេះនិយាយឲ្យអ្នកដទៃស្និទ្ធស្នាល ក៏កើតការពេញចិត្តក្នុងតំណែងនោះ ទើបធ្វើកុសលកម្មផ្សេងៗ ហើយតាំងចិត្តប្រាថ្នាក្នុងឋានៈបែបនោះ ។ កាលលោកអស់ជីវិតអំពីជាតិនោះទៅហើយ បានអន្ទោលទៅកើតជាទេវតា និងមនុស្សទាំងឡាយអស់កាលដ៏យូរអង្វែង លុះមកដល់ពុទ្ធកាល ព្រះសមណគោតមបរមគ្រូនៃយើងនេះ លោកបានមកកើតក្នុងត្រកូលសេដ្ឋី ដែលនៅក្នុងសុង្សុមារគិរីនគរក្នុងដែនភគ្គៈ ។ នកុលបិតាឈ្មោះនេះមានន័យថា ឪពុករបស់នកុលៈ នកុលបិតាមានភរិយាឈ្មោះនកុលមាតា មានសេចក្តីថា ម្តាយរបស់នកុលៈ គឺន័យថា លោកទាំងពីរមានកូន ប្រុសឈ្មោះថា **នកុលៈ** គឺមិនហៅឈ្មោះប្រចាំខ្លួន ។ សម័យមួយ ព្រះសម្ពុទ្ធ មានកិក្ខុសង្ឃហែហមបានយាងទៅឯសុង្សុមារគិរីនគរ ហើយគង់នៅត្រង់ព្រៃភេសកឡាវន (ព្រៃជាទីអាស្រ័យនៅរបស់នាងយក្ខឈ្មោះភេសកឡា) ដែលជាស្ថានទីឲ្យអភ័យដល់ពពួកម្រឹគ ។

គ្រានោះ នកុលបិតាគហបតី និងនកុលមាតា ដែលជាភរិយា ព្រមដោយពួកអ្នកស្រុកសុង្សុមារគិរី បានទៅគាល់ព្រះភគវា នៅកន្លែងដែលព្រះមានជោគ គង់ប្រថាប់នៅក្នុងព្រៃភេសកឡាវន ។ ពេលនោះ នកុលបិតា និងភរិយា លុះបានឃើញព្រះលោកនាយកត្រឹមតែគ្រាដំបូង ក៏កើតការស្និទ្ធស្នាល យល់ថា ព្រះមហាវីរៈជាកូនរបស់ខ្លួន ទើបបានប្រញាប់ប្រញាល់ចូលទៅជិតព្រះមហាមុនី ប្រៀបដូចមេគោដែលឃើញកូនគោ ហើយរត់ចូលទៅរកកូនដូច្នោះ ហើយអ្នកទាំងពីរបានបង្អោនក្រាបចុះទៀបព្រះបាទរបស់ព្រះមហាបុរស ហើយក្រាបទូលថា បពិត្រអយ្យបុត្រអើយ លោកកូន ទ្រង់ចោះបង់មាតាបិតាទុកអស់កាលដ៏យូរប្រមាណប៉ុណ្ណោះ តើព្រះអង្គយាងទៅទីណា ទើបយាងមក ។ បានឮមកថា នកុលបិតាគហបតី ធ្លាប់បានជាបិតារបស់ព្រះមានបុណ្យជាប់ៗគ្នាមក ដល់ ៥០០ ជាតិ ធ្លាប់ជាឪពុកមាមក ៥០០ ជាតិ ធ្លាប់បានជាឪពុកធំខាងឪពុក ៥០០ ជាតិ បានធ្លាប់ជាឪពុកធំខាងម្តាយ ៥០០ ជាតិ ។ ចំណែកនកុលមាតាក៏ធ្លាប់បានជាមាតារបស់ព្រះមានជោគមក

៥០០ ជាតិ ធ្លាប់ជាម្តាយមីងមក ៥០០ ជាតិ ធ្លាប់បានជាអ៊ំស្រីខាងម្តាយមក ៥០០ ជាតិ និងធ្លាប់បានជាអ៊ំស្រីខាងឪពុក ៥០០ ជាតិ ។ ដោយហេតុនេះ អ្នកទាំងពីរនាក់នោះ ទើបជាអ្នកមានសេចក្តីស្នេហាព្រោះអាស្រ័យឧបនិស្សយ ដែលមានមកហើយអស់កាលជ័យូរ លុះបានឃើញព្រះជិនស្រី ទើបកើតមនោសញ្ចេតនាស្និទ្ធស្នាល យល់ថា ព្រះភគវាជាបុត្រារបស់ខ្លួន ដូច្នេះហើយ ក៏មិនអាចតាំងសតិទុកបាន ។ គ្រានោះ ព្រះសក្យមុនីទ្រង់មិនបានដេញនកុលបិតាគហបតី និងកវិយាឲ្យចៀសចេញទៅ ក្នុងពេលដែលចិត្តរបស់អ្នកទាំងពីរនោះ នៅមិនទាន់ដឹងខ្លួនហើយកាលព្រះអង្គ ទ្រង់ជ្រាបអធ្យាស្រ័យរបស់អ្នកទាំងពីរនាក់នោះថា បានមានសតិដឹងខ្លួន ហើយជាអ្នកជាក់ចិត្តជាកណ្តាលបានហើយ ទើបទ្រង់ប្រោសប្រទានធម្មទេសនា ហើយក្នុងពេលដែលព្រះសក្យមុនី ទ្រង់ប្រទានធម៌ទេសនាចប់ អ្នកទាំងពីរក៏បានសម្រេចសោតាបត្តិផល ជាព្រះអរិយបុគ្គលថ្នាក់ដំបូង នៅក្នុងព្រះសាសនានេះ ដែលហៅបុគ្គលអ្នកបានសម្រេចធម៌បែបនោះថា **ព្រះសោតាបន្ន** ។ រាប់តាំងអំពីអ្នកទាំងពីរនាក់

បានសម្រេចជាព្រះសោតាបន្ន ក៏បានតាំងអាសនៈទុកក្នុងផ្ទះរបស់ខ្លួន ៥០០ អាសនៈ ដើម្បីភិក្ខុសង្ឃមួយថ្ងៃ ៥០០ អង្គ ។

ការបានត្រង់ត្រាប់ស្តាប់ធម្មីកថា របស់នកុលបិតាគហបតី ដែលស្តាប់មកអំពីព្រះទសពល និងព្រះសារីបុត្រ មានសម្តែងប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ ខន្ធវារវគ្គ** នៃ **ខន្ធសំយុត្ត** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះកគវា ទ្រង់គង់នៅត្រង់មិគទាយវនឧទ្យាន ដែលមានឈ្មោះថា **កេសកឡាវន** ជិតក្រុងសុង្សុមារគិរីនគរ ក្នុងដែនភគ្គៈ។ សម័យនោះ នកុលបិតាគហបតី បានទៅគាល់ព្រះកគវា ថ្វាយបង្គំហើយទើបអង្គុយក្នុងទីដ៏សមគួរ រួចបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាស់ណាស់ហើយ ជាមនុស្សជរា ជាមនុស្សមានវ័យច្រើនហើយ ដល់នូវភាពជាអ្នកមានអាយុច្រើន ទាំងមានកាយរសាប់រសល់ (កាយនេះ មានការរសាប់រសល់ ៣ ប្រការ បានដល់ រសាប់រសល់ដោយជរា ១ ដោយជំងឺ ១ ដោយសេចក្តីស្លាប់ ១) មានរោគរឿយៗ មិនទៀង មិនសូវបានមកឃើញនូវព្រះសាស្តា និងភិក្ខុសង្ឃទាំងឡាយ

ដែលជាទីចម្រើនទូវចិត្តឡើយ ហេតុដូច្នេះសូមព្រះសុគត ទ្រង់ទូន្មានខ្ញុំ
ព្រះអង្គ សូមព្រះបរមគ្រូ ទ្រង់ប្រៀនប្រដៅខ្ញុំព្រះអង្គ ដើម្បីឲ្យបាន
ជាប្រយោជន៍ដល់ខ្ញុំព្រះករុណា អស់កាលជ័យូរអង្វែងផង ព្រះអង្គ ។
គ្រានោះ ទើបព្រះមានជោគគ្រាស់ថា យ៉ាងនុ៎ះឯង គហបតី កាយនេះ
ជារបស់រសាប់រសល់ ដូចជាពងមាន់ (គឺកាយជារបស់មិនមាំមួន
អាចបែកធ្លាយបានយ៉ាងងាយ) ជារបស់មានស្បែកស្រោប បុគ្គលណា
ឃើញថា កាយនេះជារបស់មិនមានរោគ សូម្បីតែមួយខណៈមិនមាន
ឡើយ ព្រោះដូច្នោះ អ្នកគួរសិក្សាថា ចិត្តរបស់យើង ដែលមានកាយ
រសាប់រសល់ នឹងមិនឲ្យមានការរសាប់រសល់នោះឡើយ ។ នកុលបិតា
គហបតី បានស្តាប់ព្រះពុទ្ធតម្រាស់ទូន្មានដូច្នេះហើយ ក៏កើតមានបីតិ
សោមនស្សយ៉ាងខ្លាំង ក៏បានក្រោកឡើងអំពីអាសនៈ ថ្វាយបង្គំហើយ
ក្រាបទូលលាត្រឡប់ទៅវិញ ហើយបានចូលទៅរកព្រះសារីបុត្រ កាល
បានទៅជួបព្រះសារីបុត្រ ក៏បានថ្វាយបង្គំ រួចក៏អង្គុយនៅក្នុងទីដ៏សមគួរ ។
គ្រានោះ ទើបព្រះសារីបុត្រមានថេរវាចាឡើងថា ម្នាលគហបតី ឥន្ទ្រិយ

(រាងកាយ និងចិត្ត) របស់អ្នកផ្សេងៗ ទាំងទឹកមុខ ក៏ស្រស់ស្រាយ តើអ្នកបានស្តាប់ធម្មីកថា ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តាក្នុងថ្ងៃនេះ ដូចម្តេចខ្លះ ? ពេលនោះ នកុលបិតាគហបតី ពិតថេរាថាថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមិនបានស្តាប់ដូចម្តេចកើត ឥឡូវនេះ ខ្ញុំព្រះករុណាត្រូវព្រះលោកនាយក ទ្រង់ស្រោចស្រង់ (ដួតទឹក) ដោយទឹកអមតៈ បានដល់ព្រះធម្មីកថាហើយមែន លោកម្ចាស់ ។ កាលគហបតីពោលដូច្នេះហើយ ទើបពោលឲ្យព្រះថេរៈ បានស្តាប់តាមដែលខ្លួនចូលទៅគាល់ក្រាបទូលព្រះមហាវីរៈ រហូតដល់ព្រះធម្មីកថា ដែលព្រះសាស្តាទ្រង់ទេសនាឲ្យស្តាប់ ហើយប្រាប់ព្រះថេរៈថា ខ្ញុំព្រះករុណាត្រូវបានព្រះសាស្តា ទ្រង់ស្រោចស្រង់ដោយធម្មីកថា យ៉ាងនេះឯង លោកម្ចាស់ ។

គ្រានោះ ទើបព្រះសារីបុត្រសួរថា ម្នាលគហបតី អ្នកមិនបានក្រាបទូលព្រះមានបុណ្យឲ្យក្រៃលែងទៅថា ដោយហេតុត្រឹមប៉ុណ្ណា ទើបឈ្មោះថា មានកាយរសាប់រសល់ និងមានចិត្តរសាប់រសល់ ? ដោយហេតុត្រឹមប៉ុណ្ណា ទើបឈ្មោះថា មានកាយរសាប់រសល់ តែមាន

ចិត្តមិនរសាប់រសល់ ? ពេលនោះ នកុលបិតាគហបតីពិតតបថា បពិត្រ លោកម្ចាស់សារីបុត្រ ខ្ញុំព្រះករុណាបានមកអំពីចម្ងាយ ក៏ដើម្បីនឹងត្រូវការដឹងអត្ថន័យនៃព្រះពុទ្ធវចនៈនេះ នៅក្នុងសម្នាក់របស់លោកម្ចាស់ ហេតុដូច្នេះ សូមលោកម្ចាស់មេត្តាសម្តែងអត្ថន័យ នៃពាក្យទាំងនោះផងចុះ ទាន ។ គ្រានោះ ទើបព្រះសារីបុត្រពោលថា ម្នាលគហបតី បើយ៉ាងនោះ គហបតីចូរស្តាប់ឲ្យបានល្អ អាត្មានឹងសម្តែងឲ្យគហបតីបានស្តាប់ នៅក្នុងពេលឥឡូវនេះ ។ លំដាប់នោះ នកុលបិតាគហបតីក៏ពិតថា សាធុ សាធុ លោកម្ចាស់ ទើបព្រះសារីបុត្របានអធិប្បាយព្រះពុទ្ធដីកាទាំងនោះ ឲ្យនកុលបិតាគហបតី បានស្តាប់ជាគោលៗ ទៅដូច្នេះ ។ម្នាលគហបតី ដូចម្តេចទើបឈ្មោះថា មានកាយរសាប់រសល់ផង និងមានចិត្តរសាប់រសល់ផង ? យ៉ាងនេះ គឺបុថុជ្ជនដែលមិនបានស្តាប់នូវពាក្យប្រៀនប្រដៅរបស់ព្រះអរិយៈ ដែលជាអ្នកមិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ ដែលជាអ្នកមិនបានទទួលការណែនាំក្នុងធម៌របស់ព្រះអរិយៈ ដែលជាអ្នកមិនបានឃើញសប្បុរស ដែលជាអ្នកមិនបាន

ឈ្វាសក្នុងធម៌របស់សប្បុរស ដែលជាអ្នកមិនបានទទួលការណែនាំ
អំពីសប្បុរសរមែងឃើញថា រូបជាខ្លួន ខ្លួនមានរូប រូបនៅក្នុងខ្លួន
ខ្លួននៅក្នុងរូប ។ ចំណែកសេចក្តីប្រកាន់ក្នុងវេទនា សញ្ញា សង្ខារ
វិញ្ញាណ ក៏មានទំនងដូចគ្នា ។រមែងឃើញថា រូបជារបស់ខ្លួន ចំណែក
សេចក្តីប្រកាន់ក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណថា ជារបស់ខ្លួន
ក៏មានទំនងដូចគ្នា ។ កាលគេប្រកាន់យ៉ាងនោះ រូប វេទនា សញ្ញា
សង្ខារ វិញ្ញាណប្រែប្រួលទៅយ៉ាងដទៃ ក៏កើតសោក បរិទេវៈ ទុក្ខ
ទោមនស្ស និងឧបាយាស យ៉ាងនេះឯងគហបតី ហៅថា បុគ្គលមាន
កាយរសាប់រសល់ផង និងមានចិត្តរសាប់រសល់ផងដែរ ។

ចំណែកដែលថា ដូចម្តេចហៅថា បុគ្គលមានកាយរសាប់រសល់
តែមានចិត្តមិនរសាប់រសល់ ? ម្នាលគហបតី យ៉ាងនេះ គឺអរិយសាវក
ដែលជាអ្នកបានត្រង់ត្រាប់ ស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះអរិយៈ
ជាអ្នកបានឃើញព្រះអរិយៈ ជាអ្នកឈ្វាសក្នុងធម៌របស់ព្រះអរិយៈ
ជាអ្នកបានទទួលការអប់រំ ក្នុងធម៌របស់ព្រះអរិយៈជាអ្នកបានឃើញ

សប្បុរស ជាអ្នកឈ្វាសក្នុងធម៌របស់សប្បុរស ជាអ្នកបានទទួលការអប់រំដ៏ល្អក្នុងធម៌របស់សប្បុរស រមែងមិនសម្លឹងឃើញថា រូបជាខ្លួន ខ្លួនមានរូប រូបនៅក្នុងខ្លួន ខ្លួននៅក្នុងរូប ។ ចំណែកសេចក្តីមិនប្រកាន់ក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏មានទំនងដូចគ្នា ។ មិនប្រកាន់ថារូបជារបស់ខ្លួន ឯសេចក្តីមិនប្រកាន់ក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏មានទំនងដូចគ្នា ។ កាលលោកមិនប្រកាន់មាំយ៉ាងនេះ ពេលរូប វេទនា សញ្ញា សង្ខារ វិញ្ញាណប្រែប្រួលទៅជាយ៉ាងដទៃ លោកក៏មិនកើតសោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាស ។ កាលព្រះសារីបុត្រពោលយ៉ាងនេះហើយ នកុលបិតាគហបតី ក៏បានត្រេកអរចំពោះភាសិតរបស់ព្រះសារីបុត្រ ។

រឿងការឈឺចាប់របស់នកុលបិតាគហបតី ក៏បានកើតឡើងជាធម្មតាថា មនុស្សយើងដែលកើតមកហើយ តែងតែជួបនឹងជំងឺតម្កាត់ជាធម្មតា តិចនាក់ណាស់ដែលមិនមានជំងឺតម្កាត់នោះ អ្នកដែលមិនឈឺព្រះពុទ្ធត្រាស់ថា ជាអ្នកដែលមិនមានរោគ ពិតមែន រាងកាយរបស់យើង

ជាសម្បុកនៃរោគ ឯរឿងការឈឺចាប់របស់គហបតីនោះ មានសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត** ថា ៖

សម័យមួយ ព្រះសុគត ទ្រង់គង់នៅត្រង់កេសកឡាមិគទាយវ័ន ជិតក្រុងសុង្សុមារគិរី ក្នុងដែនភគ្គៈ។ គ្រានោះ នកុលបិតាគហបតីមានជំងឺជាទម្ងន់ ។ នកុលមាតាគហបតានី បានទៅរកថ្នាំមកជួយព្យាបាលឲ្យនកុលបិតា តែរោគនោះក៏មិនជា ទើបនាងបានពោលជាសង្កៀតនកុលបិតាគហបតី ដែលជាស្វាមីមិនឲ្យមានការជាប់ជំពាក់ ដោយហេតុផលផ្សេងៗ (អត្ថន័យក្នុងការដែលនកុលមាតាគហបតានីបានពោលជាសង្កៀតដល់ស្វាមីនោះ មានពោលទុកនៅក្នុងរឿងរបស់នកុលមាតាគហបតានីហើយ) ។

*ក្នុងរឿងពោលជាសង្កៀតរបស់នកុលមាតាគហបតានីនោះ មានសម្តែងនៅក្នុង **អដ្ឋកថាមនោរថបូរណី** ពោលថាជាការធ្វើសច្ចកិរិយាគឺការតាំងសត្យាធិដ្ឋានថា ៖*

នកុលមាតាគហបតានី បានព្យាយាមជួយព្យាបាលនកុលបិតា

គហបតីដែលជាស្វាមី តែមិនអាចធ្វើឲ្យជំងឺតម្កាត់សូប់រម្ងាប់ទៅបាន នាងបានអង្គុយនៅទីជិតស្វាមី ដែលកំពុងតែជេកឈឺ ដោយបំណងនឹងរម្ងាប់ការឈឺចាប់របស់ស្វាមី ដែលកំពុងតែមាននៅ ដោយសច្ចកិរិយាគឺការតាំងសត្យាភពចំពោះមុខស្វាមី ដោយប្រារព្ធគុណរបស់ខ្លួនយ៉ាងអង់អាចដោយអង្គ ៣ ប្រការ ព្រមទាំងបានពោលអាងដល់ព្រះសាស្តាជាសក្ខីភាព ហើយទើបបានធ្វើសច្ចកិរិយាអាងដល់គុណធម៌ទាំងឡាយមានសីលជាដើមរបស់ខ្លួនថា ដោយពាក្យសច្ចៈនេះ សូមឲ្យជំងឺក្នុងរាងកាយរបស់នកុលបិតាគហបតី សូប់រម្ងាប់ទៅ ។ ក្នុងទីបំផុតនកុលបិតាគហបតី ក៏ជាអំពីជំងឺដ៏ធ្ងន់នោះ ។

ចំណែកវឿងរបស់នកុលបិតាគហបតី មានសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត** ដូចមានសេចក្តីតទៅនេះថា ៖

កាលនកុលបិតាគហបតី បានស្តាប់ពាក្យពោលជាសំតឿនរបស់នកុលមាតាគហបតានីហើយ អាពាធនោះ ក៏បានសូប់រម្ងាប់ទៅដោយឆាប់រហ័ស ។ កាលនកុលបិតាគហបតីជាអំពីជំងឺហើយ មិនយូរប៉ុន្មាន

បានកាន់ឈើច្រត់ ដើម្បីដើរចូលទៅគាល់ព្រះលោកនាថដល់ទីប្រថាប់ ថ្វាយបង្គំរួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះមហាវីរៈ ទើបត្រាស់នឹងនកុលបិតាគហបតីថា ម្នាលគហបតី អ្នកបានលាភដ៏ល្អ ដែលនកុលមាតាគហបតានី ជាអ្នកអនុគ្រោះដល់អ្នក ដោយប្រាថ្នាប្រយោជន៍ដល់អ្នក បានពោលជាសំតៀនប្រៀនប្រដៅដល់អ្នក ម្នាលគហបតី សាវិការបស់តថាគតដែលនៅជាគ្រហស្ថ ស្បៀកសពាក់សមាននៅប្រមាណប៉ុនណា ដែលជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ បានទទួលការស្ងប់ចិត្ត (សំដៅដល់កម្មដ្ឋាន ដែលធ្វើឲ្យកើតសមាធិ) បានដល់នូវការឈោងចុះ បានដល់នូវទីពឹង បានដល់នូវបស្សទ្ធិ បានអស់នូវសេចក្តីសង្ស័យ និងមាយា បានដល់នូវភាពក្លៀវក្លា ក្នុងធម្មវិន័យនេះ មិនជឿអ្នកដទៃ នៅក្នុងរឿងសាសនានេះ មាននៅប្រមាណប៉ុនណា នកុលមាតាគហបតានី ក៏ជាបុគ្គលម្នាក់នៅក្នុងចំណោមសាវិកាទាំងនោះដែរ ម្នាលគហបតី អ្នកបានលាភដ៏ល្អហើយ ដែលនកុលមាតាគហបតានី ជាអ្នកបានអនុគ្រោះដល់អ្នក ដោយប្រាថ្នាប្រយោជន៍ដល់អ្នក

បានពោលជាសំតៀនប្រៀនប្រដៅដល់អ្នកនោះ ។

ក្នុងសម័យកាល នកុលបិតា និងនកុលមាតា នៅក្នុងវ័យជរា បានក្រាបទូលដល់សេចក្តីប្រាថ្នា ដែលឲ្យខ្លួន និងភរិយាបានជួបគ្នាក្នុងជាតិនេះ និងជាតិខាងមុខទៀត ហើយព្រះភគវាបានត្រាស់គោលធម៌ដែលធ្វើឲ្យស្វាមី និងភរិយា បានជួបគ្នាទាំងក្នុងជាតិនេះ និងក្នុងជាតិខាងមុខទៀតនោះ មានសម្តែងប្រាកដនៅក្នុងបាលី **គម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត** នៃ **សមជីវកសូត្រ** និងក្នុង **អដ្ឋកថាមនោរថបូរណី** ថា ៖

ក្នុងកាលខាងក្រោយមក ព្រះមហាវីរបុរសបានយាងមកប្រថាប់នាភេសកឡាមិគទាយវ័ន ជិតក្រុងសុង្សុមារគីរី ក្នុងដែនភគ្គៈ ។ គ្រានោះ នកុលបិតា និងនកុលមាតាដែលមានវ័យចាស់ជរាច្រើនហើយ កាលអ្នកទាំងពីរនាក់នោះបានឮដំណឹងថា ព្រះមានបុណ្យស្តេចយាងមកហើយ ទើបទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយក្រាបទូលអារាធនាព្រះលោកនាថ ព្រមដោយភិក្ខុសង្ឃ ដើម្បីឲ្យយាងមកទទួលចង្ហាន់ នៅឯផ្ទះរបស់ខ្លួន ក្នុងថ្ងៃស្អែក ហើយកាល

ជ្រាបថា ព្រះលោកនាយកទ្រង់ទទួលហើយ ទើបក្រាបថ្វាយបង្គំលា
ព្រះសក្យមុនីត្រឡប់ទៅវិញ ។ លុះដល់ព្រឹកថ្ងៃស្អែកឡើង ព្រះជិនស្រី
ព្រមដោយភិក្ខុសង្ឃ បានយាងទៅឯនិវេសន៍របស់នកុលបិតាគហបតី
ហើយប្រថាប់គង់លើអាសនៈ ដែលគេក្រាលទុកថ្វាយ ។ ពេលនោះ
នកុលបិតាគហបតី បានអង្គាសភិក្ខុសង្ឃ មានព្រះសយម្ភូទ្រង់ជាអគ្គ
ប្រធាន ដោយភោជនីយាហារទាំងឡាយ មានរសដ៏លើសផ្សេងៗ ក្នុង
និវេសន៍របស់ខ្លួន កាលព្រះលោកនាថ ទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយ
នកុលបិតាគហបតី និងនកុលមាតាគហបតានី បានចូលទៅគាល់
ព្រះសាស្តា ថ្វាយបង្គំរួចហើយ ក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ កាល
នកុលបិតាគហបតីអង្គុយស្រួលបួលហើយ ទើបក្រាបទូលដល់ការ
បរិវិតក្កៈរបស់ខ្លួនថា បពិត្រព្រះអង្គដ៏ចម្រើន រាប់តាំងអំពីកាលនកុល-
មាតាគហបតានី ដែលកំពុងតែនៅក្នុងវ័យក្រមុំ ពពួកញាតិបាននាំនាង
មកឲ្យដល់ខ្ញុំព្រះអង្គ ដែលកំពុងតែស្ថិតនៅក្នុងវ័យកំលោះដែរ ខ្ញុំព្រះ
អង្គមិនដែលមានអារម្មណ៍ថា នកុលមាតាគហបតានីប្រព្រឹត្តកន្ទង សូម្បី

ដោយការគិតតាមផ្លូវចិត្តឡើយ ដូច្នោះ ការប្រព្រឹត្តកន្ទង់តាមផ្លូវកាយ ទើបមិនមាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងពីរនាក់នេះ មានសេចក្តីប្រាថ្នា ដើម្បីជួបគ្នាទាំងក្នុងភពនេះ និងសូមប្រាថ្នាដើម្បីជួបគ្នាក្នុងភពខាងមុខទៀត ព្រះអង្គ ។

ចំណែកនកុលមាតាគហបតានី ក៏បានក្រាបទូលជល់ភាពបរិវិតក្កនេះនឹងព្រះសុគតថា បពិត្រព្រះអង្គដ៏ចម្រើន រាប់តាំងអំពីខ្ញុំព្រះអង្គកំពុងតែនៅក្នុងវ័យក្រមុំ ត្រូវបានពពួកញាតិនាំមក ដើម្បីឲ្យជាភរិយារបស់នកុលបិតាគហបតី ដែលលោកស្ថិតនៅក្នុងវ័យកំលោះដែរ ខ្ញុំព្រះអង្គមិនដែលមានអារម្មណ៍ថា នកុលបិតាគហបតីប្រព្រឹត្តកន្ទង់ សូម្បីដោយការគិតតាមផ្លូវចិត្តឡើយ ដូច្នោះការប្រព្រឹត្តកន្ទង់តាមផ្លូវកាយ ទើបមិនមាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងពីរនាក់ ប្រាថ្នាដើម្បីជួបគ្នានិងគ្នា ទាំងក្នុងជាតិនេះ និងសូមដើម្បីប្រាថ្នាឲ្យបានជួបគ្នាក្នុងជាតិខាងមុខទៀត ព្រះអង្គ ។ គ្រានោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតី និងគហបតានី បើភរិយា និងស្វាមីប្រាថ្នាជួបគ្នានិងគ្នា

ទាំងក្នុងបច្ចុប្បន្នជាតិនេះ និងជាតិខាងមុខទៀតនោះ អ្នកទាំងពីរនោះ ត្រូវតែជាអ្នកមានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា និងមានបញ្ញាស្មើគ្នា ភរិយា និងស្វាមីទាំងពីរនាក់នោះ រមែងបានជួបគ្នាទាំងក្នុងបច្ចុប្បន្នជាតិនេះ និងក្នុងជាតិខាងមុខទៀតដែរ ។ កាលព្រះមុនីត្រាស់ដូច្នេះហើយ ទើបត្រាស់ព្រះគាថាទាំងនេះថា ៖

ភរិយា និងស្វាមីទាំងពីរនាក់ ជាអ្នកមានសទ្ធា ជាអ្នកត្រេកអរក្នុងការឲ្យទាន ជាអ្នកសង្រួម ជាអ្នកចិញ្ចឹមជីវិតដោយប្រពៃ ជាអ្នកពោលពាក្យដែលគួរឲ្យជាទីស្រឡាញ់ដល់គ្នានិងគ្នា រមែងមានសេចក្តីចម្រើនរុងរឿងច្រើន មានភាពផាសុក ភរិយា និងស្វាមីទាំងពីរនាក់នោះ ចំណែកសីលក៏ស្មើគ្នា ជាអ្នកស្រឡាញ់គ្នាច្រើន មិនមានចិត្តកាចចំពោះគ្នា ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ទាំងពីរចំណែកជាអ្នកមានសីល និងវត្តស្មើគ្នា រមែងជាអ្នកសោយកាមារម្មណ៍ (មានសេចក្តីសុខសាន្តល្អ) រមែងទៅរីករាយក្នុងទេវលោក ។

ម្យ៉ាងទៀត បុរាណាចារ្យ បានអធិប្បាយពន្រីកសេចក្តីក្នុងព្រះ

បាលីទាំងនោះទុកថា ពាក្យថា **មានសទ្ធាស្មើគ្នា** បានដល់ជាអ្នកមានការជឿដូចគ្នា ជឿរឿងបាបបុណ្យ គុណទោសដូចគ្នា ជឿពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដូចគ្នា ។ ពាក្យថា **មានសីលស្មើគ្នា** បានដល់ជាអ្នកមានការរក្សាសីល គឺសង្រួមរាំងផ្លូវកាយ វាចាឲ្យរៀបរយជាប្រក្រតី ទាំងភរិយា និងស្វាមី ។ ពាក្យថា **មានចាគៈស្មើគ្នា** បានដល់ចូលចិត្តក្នុងការឲ្យដូចគ្នា ។ ពាក្យថា **មានបញ្ញាស្មើគ្នា** បានដល់ស្គាល់បុណ្យបាបគុណទោសដូចគ្នា គឺចេះលះបាប និងវត្ថុដែលជាទោស និងចេះធ្វើបុណ្យ និងធ្វើវត្ថុដែលជាគុណប្រយោជន៍ទាំងពីរចំណែក ។ ការធ្វើបានគ្រប់ទាំង ៤ ប្រការ ដូច្នេះ ទាំងចំណែកភរិយា និងស្វាមីរមែងជាវត្ថុដែលធ្វើបានដោយលំបាក បើធ្វើបាន ក៏រមែងបានផលល្អ និងបានទទួលផលតាមដែលភរិយា និងស្វាមីចង់បាននោះ គឺប្រាថ្នាឲ្យបានជួបគ្នាទាំងក្នុងជាតិនេះ និងជាតិខាងមុខទៀត ។

ភាពជាឯតទគ្គៈ គឺភាពដ៏ប្រសើររបស់នកុលបិតាគហបតី ដែលបានទទួលការលើកតម្កើងអំពីព្រះសាស្តានោះ មានសម្តែងទុកនៅក្នុង

គម្ពីរអង្គុត្តរនិកាយ ឯកនិបាត ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសាស្តា ជានាយក ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់បានប្រកាសតែងតាំង នកុលបិតាគហបតីឧបាសក នៅកណ្តាលបរិស័ទទាំង ៤ ថា

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ វិស្សាសកានំ យទិទំ នកុល បិតាគហបតី *ម្នាលភិក្ខុទាំងឡាយ នកុលបិតាគហបតី ជាអ្នកប្រសើរ ជាងឧបាសកទាំងឡាយ ដែលជាសាវ័កបស់តថាគត ផ្នែកខាងជាអ្នកចេះនិយាយ ឲ្យអ្នកដទៃស្និទ្ធស្នាល ។*

(ជីវប្រវត្តិរបស់នកុលបិតាគហបតីឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ព្រះអង្គម្ចាស់អភយរាជកុមារ ✍

“ ជាឧបាសកដ៏ឆ្នើមមួយរូបនៅក្នុងព្រះពុទ្ធសាសនានេះ ”

ព្រះអង្គម្ចាស់អភយរាជកុមារ ជាឧបាសកមកអំពីព្រះរាជត្រកូលទ្រង់ក៏ជាអ្នករាប់អានព្រះពុទ្ធសាសនា ថែមទាំងជាអ្នកបានសម្រេចអរិយផល ដែលចាត់ជាសក្ខីភាពរបស់ព្រះពុទ្ធសាសនានេះ អ្នកដែលរាប់អានហើយអាចពិសោធរិះរកសេចក្តីពិតបានថា របស់ពិតដ៏ប្រសើរដែលមាននៅក្នុងព្រះពុទ្ធសាសនា ។

ជីវប្រវត្តិរបស់ព្រះអង្គម្ចាស់អភយរាជកុមារ មានសម្តែងនៅក្នុង ***អដ្ឋកថាបរមត្ថទីបនី*** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង ***គម្ពីរខុទ្ទកនិកាយ ថេរគាថា*** ដូចមានសេចក្តីថា ៖

ព្រះអង្គម្ចាស់អភយរាជកុមារ ជាព្រះរាជឱរសក្រៅព្រះស្ងួតច្ឆត្រ របស់ព្រះបាទពិម្ពិសារ ដែលជាព្រះរាជានៃដែនមគធរដ្ឋ ជាមួយនឹង ***នាងបទុមវតី*** អ្នកក្រុងឧជ្ជេនី ដូចមានរឿងពោលថា ព្រះបាទពិម្ពិសារ

ទ្រង់បានជ្រាបដំណឹងថា ស្រីនគរសោភិនីម្នាក់ឈ្មោះ **បទុមវតី** ដែលនៅក្នុងក្រុងឧជ្ជេនី ដោយមានអ្នកពោលសរសើរដល់រូបសម្បត្តិដ៏ស្រស់ស្អាតជាដើមរបស់នាងហើយ ទើបព្រះបាទពិម្ពិសារត្រាស់ជាមួយព្រះរាជបុរោហិតថា ខ្ញុំបានឮដំណឹងថា នៅក្នុងក្រុងឧជ្ជេនី មានស្រីនគរ-សោភិនីម្នាក់ឈ្មោះនាងបទុមវតី ខ្ញុំមានសេចក្តីត្រូវការចង់ឃើញនាង។ គ្រានោះ រាជបុរោហិតក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ហើយគេបានប្រើកម្លាំងវេទមន្តហៅឈ្មោះ **កុម្ភីរយក្ខ** មកហើយ ប្រើអានុភាពរបស់កុម្ភីរយក្ខ ឲ្យយាងព្រះបាទពិម្ពិសារទៅឯក្រុងឧជ្ជេនី ក្នុងខណៈនោះឯង ។ ព្រះបាទពិម្ពិសារ ទ្រង់បានរួមអភិរម្យជាមួយនាងបទុមវតី ដែលជាស្រីនគរសោភិនីនោះមួយរាត្រី ។ នាងបទុមវតី បានតាំងគភ៌ឡើងជាមួយព្រះបាទពិម្ពិសារ ទើបនាងក្រាបបង្គំទូលឲ្យព្រះបាទពិម្ពិសារទ្រង់ជ្រាបថា ខ្ញុំម្ចាស់មានគភ៌ហើយ ព្រះអង្គ ។ ព្រះបាទពិម្ពិសារ ទ្រង់បានជ្រាបដូច្នោះហើយ ទើបមានព្រះរាជបញ្ជាថា ប្រសិនបើជាបុត្រប្រុស នាងចូរថែរក្សាឲ្យបានល្អទុកឲ្យយើង ហើយព្រះរាជាបានប្រទានព្រះទម្រង់

ឆ្លាក់ព្រះនាមរបស់ព្រះអង្គទុក ហើយក៏យាងត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ។ កាលវេលាកន្លងទៅបាន ១០ ខែ នាងបទុមវតីក៏ប្រសូតបុត្រ ហើយបានដាក់ឈ្មោះឲ្យបុត្រនោះ ឈ្មោះថា **អភ័យ** ។ ក្នុងពេលដែលកូនរបស់នាងមានអាយុបាន ៧ ឆ្នាំ ទើបនាងបានបញ្ជូនកូនឲ្យទៅចូលគាល់ព្រះបាទពិម្ពិសារ ដោយនាងបានប្រាប់ដល់បុត្រថា ព្រះបាទពិម្ពិសារជាព្រះបិតារបស់កូន (ហើយនាងបានប្រគល់ព្រះទម្រង់ ដែលឆ្លាក់ព្រះនាមរបស់ព្រះបាទពិម្ពិសារជាសក្ខីភាព) ។ ព្រះបាទពិម្ពិសារ កាលបើបានដឹងថា ព្រះអង្គម្ចាស់អភយរាជកុមារ ជាឱរសរបស់ខ្លួនហើយក៏មានសេចក្តីស្រឡាញ់ពេញចិត្តចំពោះព្រះរាជឱរសនោះ ហើយទ្រង់បានចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងព្រះរាជឱរសសព្វគ្រប់ ដោយគ្រឿងអាករណៈផ្សេងៗ ជាដើម ។

កាលព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ចម្រើនព្រះជន្មាយុហើយ ទ្រង់បានចិញ្ចឹមពេទ្យជីវកកោមារភច្ច តាំងអំពីតូចរហូតដល់ធំពេញវ័យ ហើយបានជាពេទ្យប្រចាំព្រះរាជសម្នាក់ ទាំងជាពេទ្យដែលជួយព្យាបាល

ព្រះសម្មាសម្ពុទ្ធ និងកិក្ខុសង្ឃជាច្រើនទៀតផង ថែមទាំងជាពេទ្យមានឈ្មោះបោះសំឡេង និងជាពេទ្យដែលបរិបូណ៌ទៅដោយគុណធម៌ ដូចដែលមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបបញ្ចសូទនី** ថា ៖

ថ្ងៃមួយ ព្រះអង្គម្ចាស់អភយរាជកុមារ ស្តេចយាងចូលទៅគាល់ព្រះបាទពិម្ពិសារ បានយាងទៅតាមផ្លូវក្បែរគំនរសំរាម ទ្រង់បានទតឃើញហ្វូងក្អែកកំពុងចោមរោមទារកនៅត្រង់គំនរសំរាមនោះ ទើបត្រាស់សួរថា ម្នាលនាយ ពួកហ្វូងក្អែកកំពុងចោមរោមទីនោះ តើមានហេតុការណ៍អ្វី? គ្រានោះ ភ្នាក់ងារក្រាបបង្គំទូលថា ព្រះករុណាថ្ងៃវិសេស ពួកហ្វូងក្អែកកំពុងចោមរោមទារកក្រាបទូល ។ពេលនោះ ព្រះអង្គម្ចាស់អភយរាជកុមារត្រាស់សួរថា ទារកនោះនៅមានជីវិតទេ ? ភ្នាក់ងារក្រាបបង្គំទូលថា ទារកនោះនៅមានជីវិតក្រាបទូល ហើយព្រះអង្គម្ចាស់អភយរាជកុមារទើបត្រាស់បញ្ជាថា បើយ៉ាងនោះ ពួកលោកចូរនាំទារកនោះទៅក្នុងព្រះរាជវាំង ឲ្យពពួកមេដោះចិញ្ចឹមចុះ ។ ក្នុងកាលតមក ពេទ្យជីវក-កោមារភច្ចក៏ចម្រើនវ័យធំដឹងក្តី ហើយបានទៅរៀនវិជ្ជាពេទ្យនៅឯនគរ

តក្កសិលា កាលរៀនចប់ក៏ត្រឡប់មកវិញ ហើយព្រះអង្គម្ចាស់អភយ-រាជកុមារ បាននាំពេទ្យជីវកកោមារភច្ច ឲ្យទៅជួយព្យាបាលឫសដូងបាត របស់ព្រះបាទពិម្ពិសារ ហើយពេទ្យជីវក: បានទទួលព្រះករុណាប្រោសប្រទានអំពីព្រះបាទពិម្ពិសារ ឲ្យជាពេទ្យហ្លួងប្រចាំនៅក្នុងព្រះរាជវាំង ។

ចំណែកជីវប្រវត្តិក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិរបស់ព្រះអង្គម្ចាស់អភយរាជកុមារ មានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **អភយថេរគាថា** នៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្តីថា ៖

ព្រះអង្គម្ចាស់អភយរាជកុមារ ក៏ជាអ្នកធ្លាប់បានបព្វជ្ជារួចមកហើយ នៅក្នុងសាសនារបស់ព្រះបទុមុត្តរសម្ពុទ្ធ បើនឹងប្រមាណដោយពេលវេលា ក៏បានមួយសែនកប្ប លោកបួសកាលនោះ គឺលោកបានជាធម្មកថិកមួយជើងឆ្នើមដែរ ផ្នែកខាងសម្តែងធម៌ ក្នុងពេលដែលលោកសម្តែងធម៌តាមប្រក្រតី លោកតែងតែបានពោលសរសើរព្រះបទុមុត្តរ-សម្ពុទ្ធ ដោយគាថា ៤ គាថាមុន ហើយទើបសម្តែងធម៌ជាក្រោយ ។

ដោយបុញ្ញកម្មនៃការពោលសរសើរព្រះបទុមុត្តរសម្ពុទ្ធ បានជួយឲ្យលោកមិនទៅកើតក្នុងកំណើតអបាយភូមិ រហូតមួយសែនកប្ប ។ ការសន្សំបុណ្យកុសលទុកក្នុងភពផ្សេងៗ របស់ព្រះអង្គម្ចាស់អភយរាជកុមារ រមែងបានជាឧបត្ថម្ភកប្បច្ច័យ (ជាហេតុគាំទ្រ) ឲ្យដល់លោក ។ ជាតិមួយលោកបានធ្វើការបូជាព្រះវិបស្សីសម្ពុទ្ធដោយផ្ការំចេក ហើយដោយបុញ្ញកម្មដ៏វិសេសដូច្នេះ បានធ្វើឲ្យលោកវិលវល់ នៅក្នុងសុគតិភពតែម្យ៉ាងប៉ុណ្ណោះ ។ លុះមកដល់ពុទ្ធកាលនៃព្រះសមណគោតមបរមគ្រូនៃយើងនេះ លោកបានមកកើតជាព្រះរាជឱរសរបស់ព្រះបាទពិម្ពិសារ (ដូចដែលបានពោលរួចមកហើយពីខាងដើម) ហើយទ្រង់ព្រះនាមថា **អភយរាជកុមារ** ។

ព្រះអង្គម្ចាស់អភយរាជកុមារ មុននឹងទ្រង់មកគោរពរាប់អានព្រះពុទ្ធសាសនានេះ មុនដំបូងទ្រង់បានសិក្សាបញ្ហាដែលមានកំណួចពីរអំពីនិគ្រន្ថនាដបុត្រ។ ប្រើឲ្យទៅទូលសួរព្រះមានព្រះភាគ ទើបមានការសន្ទនាធម៌រវាងព្រះអង្គម្ចាស់អភយរាជកុមារ ដែលទ្រង់ជាកាគីខាង

ទូលសួរ ហើយព្រះសម្មាសម្ពុទ្ធ ទ្រង់ជាអ្នកឆ្លើយ តាមដែលមានរឿងសម្តែងទុកនៅក្នុងព្រះបាលីក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក:** នៃ **អភយរាជកុមារសូត្រ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសាស្តាប្រថាប់នៅឯវត្តវេឡុវ័ន តាំងនៅជិតក្រុងរាជគ្រឹះ ។ ក្នុងសម័យនោះ ព្រះអង្គម្ចាស់អភយរាជកុមារស្តេចបានយាងទៅរកនិគ្រន្ថនាដបុត្រ ទ្រង់ថ្វាយបង្គំហើយ ទើបប្រថាប់គង់ក្នុងទីដ៏សមគួរ ។ គ្រានោះ ទើបនិគ្រន្ថនាដបុត្រទូលឡើងថា ព្រះរាជកុមារ ព្រះអង្គយាងទៅ ទ្រង់ចាប់កំហុសពាក្យសម្តីរបស់ព្រះសមណគោតម ឲ្យបានកិត្តិសព្ទដ៏ល្អរបស់ព្រះរាជកុមារ ប្រាកដជាបានខ្ចរខ្ចាយទៅថា ព្រះអង្គម្ចាស់អភយរាជកុមារ បានយាងទៅចាប់កំហុសពាក្យសម្តីរបស់ព្រះសមណគោតម ដែលជាអ្នកមានឥទ្ធានុភាពដូច្នោះបាន ។ ពេលនោះ ទើបព្រះអង្គម្ចាស់អភយរាជកុមារ ត្រាស់សួរថា ខ្ញុំករុណានឹងចាប់កំហុសពាក្យសម្តីរបស់ព្រះសមណគោតម ដែលជាអ្នកមានឥទ្ធានុភាពច្រើនដូច្នោះបានដូចម្តេច ? ទើបនិគ្រន្ថនាដបុត្រទូលថា សូមព្រះរាជកុមារ

យ៉ាងទៅគ្រាស់ជាមួយព្រះសមណគោតមថា ព្រះតថាគតតែងពោលវាចា ដែលមិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃឬទេ ប្រសិនបើព្រះសមណគោតមត្រាស់តបថា តថាគតពោល សូមព្រះរាជកុមារត្រាស់ថា បើយ៉ាងនោះ នឹងផ្សេងគ្នាយ៉ាងណាពីបុថុជ្ជនដូចម្តេច ព្រោះថា បុថុជ្ជនក៏តែងតែពោលវាចា ដែលមិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃដូចគ្នាដែរតែប្រសិនបើព្រះសមណគោតមត្រាស់តបថា ព្រះតថាគតមិនពោលវាចា ដែលមិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃទេ ឲ្យព្រះរាជកុមារត្រាស់ ជំទាស់ថា បើយ៉ាងនោះហេតុអ្វី ទើបបានជាព្រះសមណគោតម ទ្រង់ព្យាករភិក្ខុទេវទត្តថា ភិក្ខុទេវទត្តនឹងធ្លាក់ទៅកើតនៅក្នុងអវីចីនរកអស់មួយកប្ប ដូច្នេះ ធ្វើឲ្យភិក្ខុទេវទត្តមានការក្រោធ មានការតូចចិត្ត ដោយពាក្យសម្តីរបស់ព្រះសមណគោតម សេចក្តីនេះព្រះសមណគោតម កាលត្រូវព្រះរាជកុមារសួរនូវបញ្ហាកំណួចរបស់ព្រះរាជកុមារដូច្នេះហើយ នឹងលេបមិនចូល ខ្ជាក់មិនចេញ ដូចបុរសដែលត្រូវកូនក្រចាប់ដែកជាប់នៅក្នុង-ក ដូច្នោះ ។

លំដាប់នោះ ព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ទទួលពាក្យសម្តី របស់និគ្រន្ថនាដបុត្រថា ល្អហើយ ទើបបានយាងក្រោកឡើង ហើយ ព្រះរាជាទ្រង់លានិគ្រន្ថនាដបុត្រ ក្នុងបំណងដើម្បីយាងទៅគាល់ព្រះមុនី ទ្រង់ថ្វាយបង្គំហើយ ប្រថាប់គង់នៅក្នុងទីដ៏សមគួរ ។ កាលប្រថាប់គង់រៀបរយហើយ ព្រះរាជកុមារ ទ្រង់ក្រឡេកមើលថ្ងៃឃើញថា ពេលនេះមិនមែនជាពេលដែលត្រូវលើកវាទៈ ជាមួយព្រះលោកនាយកឡើយ ចាំថ្ងៃស្អែកចុះ យើងនឹងលើកវាទៈជាមួយព្រះភគវា ក្នុងនិវេសន៍របស់យើង កាលព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ត្រិះរិះឃើញដូច្នេះហើយ ទើបទ្រង់ក្រាបទូលនិមន្តថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាយាងទៅទទួលចង្ហាន់ឯនិវេសន៍របស់ខ្ញុំព្រះអង្គ ព្រមជាមួយភិក្ខុ ៣ អង្គទៀត រួមជា ៤ អង្គ ទាំងព្រះអង្គក្រាបទូល ។ គ្រានោះ ព្រះសម្ពុទ្ធទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះអង្គម្ចាស់អភយ-រាជកុមារ ទ្រង់បានជ្រាបអាការទទួលនិមន្តរបស់ព្រះមានបុណ្យហើយ ទើបទ្រង់ថ្វាយបង្គំលាត្រឡប់ទៅវិញ ។ លុះដល់ព្រឹកថ្ងៃស្អែកឡើង

ព្រះមានជោគ ទ្រង់បានគ្រងចីវរ ប្រដាប់ដោយបាត្រស្តេចយាងចូលទៅ
ឯព្រះរាជនិវេសន៍របស់ព្រះអង្គម្ចាស់អភយរាជកុមារ ព្រមជាមួយភិក្ខុ
៣ អង្គទៀត លុះយាងទៅដល់ ទើបប្រថាប់គង់លើអាសនៈដែលគេ
រៀបចំថ្វាយ ។ ចំណែកព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ថ្វាយចង្ហាន់
បិណ្ឌបាតដ៏ប្រណីតៗ ដល់ព្រះជិនស្រី ។ កាលព្រះវិជិតមារ ទ្រង់ទទួល
ចង្ហាន់រួចស្រេចហើយ ព្រះអង្គម្ចាស់អភយរាជកុមារ បានគង់ប្រថាប់
នៅក្នុងទីដ៏សមគួរ ហើយទើបទ្រង់ក្រាបទូលសួរឡើងថា បពិត្រព្រះអង្គ
ដ៏ចម្រើន ព្រះតថាគតតែងតែគ្រាស់ព្រះវាចា ដែលមិនជាទីស្រឡាញ់
ពេញចិត្តរបស់អ្នកដទៃខ្លះឬទេ ព្រះអង្គ ? គ្រានោះ ព្រះសាស្តាគ្រាស់
តបថា ម្នាលរាជកុមារ ក្នុងរឿងនេះ ព្រះតថាគតមិនពោលដោយ
ចំណែកមួយ គឺមិនពោលសម្ងាប់ខ្លួនឯងក្នុងប្រការនេះ ។ គ្រានោះ
ព្រះអង្គម្ចាស់អភយរាជកុមារ ទើបទ្រង់ទូលអះអាងដល់ពួកនិគ្រន្ថថា
បពិត្រព្រះអង្គដ៏ចម្រើន ពួកនិគ្រន្ថវិនាសហើយក្នុងរឿងនេះ ព្រះអង្គ ។
លំដាប់នោះ ទើបព្រះទសពលគ្រាស់សួរថា ម្នាលព្រះរាជកុមារ ព្រោះ

ហេតុអ្វី បានជាព្រះរាជកុមារត្រាស់យ៉ាងនេះ ? ពេលនោះ ទើបព្រះអង្គ
ម្ចាស់អភយរាជកុមារ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រការ
ដែលក្រាបទូលថា ពួកនិគ្រន្ថវិនាសហើយក្នុងរឿងនេះនោះ គឺខ្ញុំព្រះ
អង្គបានទៅរកនិគ្រន្ថនាដបុត្រ ថ្វាយបង្គំហើយ ក៏អង្គុយក្នុងទីដ៏សមគួរ
និគ្រន្ថនាដបុត្រប្រាប់នឹងខ្ញុំថា សូមព្រះរាជកុមារ ទៅធ្វើយឆ្ងល់នូវវាទៈ
ចាប់កំហុសពាក្យសម្តីរបស់ព្រះសមណគោតមឲ្យបាន ព្រះរាជកុមារ
នឹងមានកិត្តិយសដ៏ល្អផ្សាយទៅថា ព្រះអង្គម្ចាស់អភយរាជកុមារ
បានចាប់កំហុសពាក្យសម្តីរបស់ព្រះសមណគោតម ដែលជាអ្នកមាន
ឥទ្ធានុភាពច្រើនដូច្នេះបាន ទើបខ្ញុំព្រះអង្គសួរគេថា នឹងឲ្យចាប់
កំហុសពាក្យសម្តីរបស់ព្រះសមណគោតម បានដូចម្តេច ? គេប្រាប់ថា
សូមព្រះរាជកុមារសួរព្រះសមណគោតមថា ព្រះតថាគតដែលពោល
វាចា មិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃឬទេ បើព្រះសមណគោតម
ត្រាស់តបថា ពោលក៏ឲ្យព្រះរាជកុមារពោលថា បើយ៉ាងនោះនឹងប្លែក
ផ្សេងគ្នាអំពីបុថុជ្ជនដូចម្តេច ព្រោះថា បុថុជ្ជនក៏ពោលវាចាដែលមិនជាទី

ស្រឡាញ់ពេញចិត្តរបស់អ្នកជទៃដូចគ្នាដែរ តែប្រសិនបើព្រះសមណ-
គោតមត្រាស់តបថា មិនពោលទេ ក៏ឲ្យព្រះរាជកុមារត្រាស់ជំទាស់ថា
ហេតុអ្វីបានព្រះសមណគោតម ទើបទ្រង់ព្យាករកិក្ខុទេវទត្តថា ក្រោយ
អំពីអស់ជីវិតទៅ នឹងធ្លាក់ទៅកាន់អវីចីនរកអស់មួយកប្ប ដូច្នេះ ធ្វើឲ្យ
កិក្ខុទេវទត្តខឹងក្រោធ មានការអាក់អន់ចិត្ត ចំពោះវាចារបស់ព្រះអង្គ
សេចក្តីនេះ ព្រះសមណគោតម កាលត្រូវព្រះរាជកុមារសួរនូវបញ្ហា
កំណួចពីរដូច្នេះហើយ នឹងមិនអាចលេប នឹងមិនអាចខ្ជាក់បាន ដូចជា
បុរសដែលក្រចាប់ដែកជាប់នៅត្រង់-ក ដូច្នោះ ។

ក្នុងគ្រានោះ មានក្មេងតូចម្នាក់អង្គុយនៅលើភ្លៅរបស់ព្រះអង្គ
ម្ចាស់អភយរាជកុមារ ទើបព្រះភគវាត្រាស់សួរថា ម្នាលព្រះរាជកុមារ
ព្រះរាជកុមារ ទ្រង់ចូលចិត្តសេចក្តីនេះដូចម្តេច គឺប្រសិនបើកុមារនេះ
លេបឈើ ឬអម្បែងចូលទៅជាប់នៅត្រង់-ក ព្រោះការធ្វេសប្រហែស
របស់ព្រះរាជកុមារ ឬព្រោះការធ្វេសប្រហែសរបស់ពួកគីលៀងហើយ
ព្រះរាជកុមារទ្រង់ធ្វើដូចម្តេច ? គ្រានោះ ព្រះអង្គម្ចាស់អភយរាជកុមារ

ទ្រង់ក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងខ្វេះយក
ចេញមក បើខ្ញុំព្រះអង្គមិនអាចខ្វេះយកចេញមក ដោយការធ្វើគ្រាទី
១ ក៏នឹងសង្កត់ក្បាលកុមារនេះទុកដោយដៃខាងឆ្វេង ហើយលូកម្រាមដៃ
ខាងស្តាំចូលទៅខ្វេះយកចេញមកទាំងឈាម ព្រោះការអាណិតអាសូរ
កុមារ ព្រះអង្គ ។ លំដាប់នោះ ព្រះសម្មាសម្ពុទ្ធត្រាស់ថា សេចក្តីនេះ
ក៏ដូច្នោះ គឺព្រះតថាគតដឹងថា វាចាណាជាវាចាមិនពិត មិនប្រកបដោយ
ប្រយោជន៍ វាចានោះក៏មិនជាទីពេញចិត្តរបស់អ្នកដទៃ តថាគតមិនពោល
វាចានោះ ។ តថាគតដឹងថា វាចាណាជារបស់ពិត តែមិនមានប្រយោជន៍
វាចានោះមិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃ តថាគតមិនពោល
វាចានោះ ។ តថាគតដឹងថា វាចាណាជារបស់ពិត ជារបស់មានប្រយោជន៍
តែវាចានោះ មិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃ តថាគតក៏ត្រូវ
កាលវេលាដែលនឹងពោលវាចានោះ ។តថាគតដឹងថា វាចាណាមិនពិត
មិនប្រកបដោយប្រយោជន៍ តែវាចានោះជាទីស្រឡាញ់ ជាទីពេញចិត្ត
របស់អ្នកដទៃ តថាគតមិនពោលវាចានោះឡើយ ។ តថាគតដឹងថា

វាចាណាជារបស់ពិត ជារបស់មានប្រយោជន៍ ទាំងវាចាជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃផង តថាគតក៏សម្គាល់កាលវេលា ដែលនឹងត្រូវពោលវាចានោះ ដោយហេតុថា តថាគតមានការអាណិតអាសូរសត្វលោកទាំងឡាយ ។

គ្រានោះ ទើបព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ក្រាបទូលឡើងថា បពិត្រព្រះអង្គជ័យម្រើន ក្សត្រៃដែលជាបណ្ឌិត ព្រាហ្មណ៍ដែលជាបណ្ឌិត គហបតីដែលជាបណ្ឌិត សមណៈដែលជាបណ្ឌិតពួកណាគិតរៀបចំបញ្ហាចូលមកក្រាបទូលសួរព្រះតថាគត។ មិនធ្លាប់គិតបញ្ហាប្រការនោះទុកហើយថា បុគ្គលពួកណាចូលមកសួរយើងយ៉ាងនេះ យើងនឹងជ្រាប់គេយ៉ាងនេះឬ ឬការដោះស្រាយបញ្ហានោះ បានជ្រាកដដល់ព្រះតថាគតក្នុងមួយរំពេចឬ ព្រះអង្គ ? ពេលនោះ ទើបព្រះលោកនាថ ត្រាស់តបថា ម្នាលព្រះរាជកុមារ តថាគតនឹងសាកសួរព្រះរាជកុមារក្នុងរឿងនេះ សូមឲ្យព្រះរាជកុមារត្រាស់ឆ្លើយ តាមការពេញព្រះទ័យ គឺព្រះរាជកុមារទ្រង់ជាអ្នកមានជំនាញក្នុងគ្រឿងរនេះមិនមែនឬ ? គ្រានោះ ព្រះអង្គ

ម្នាស់អភយរាជកុមារគ្រាស់តបថា មែនហើយព្រះអង្គ ។ លំដាប់នោះ ព្រះលោកនាយកគ្រាស់សួរតទៅទៀតថា បើមានអ្នកមកសាកសួរព្រះរាជកុមារថា នេះជាគ្រឿងអ្វីរបស់វេ ព្រះរាជកុមារទ្រង់បានគិតទុកមុនហើយឬថា បើមានអ្នកមកសួរយើងយ៉ាងនេះ យើងគប្បីឆ្លើយនឹងគេយ៉ាងនេះ ឬព្រះរាជកុមារគ្រាស់ឆ្លើយបានក្នុងមួយរំពេចនោះ ? ព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាជាងវេះ ជាអ្នកឈ្លាសទាក់ទងនឹងគ្រឿងវេ បានស្គាល់គ្រឿងវេទាំងអស់ ខ្ញុំព្រះអង្គឆ្លើយនឹងគេបានមួយរំពេច ក្នុងពេលនោះឯង ព្រះអង្គ ។ កាលព្រះភគវាគ្រាស់ដូច្នេះហើយ ព្រះអង្គម្ចាស់អភយ-រាជកុមារ ទើបទ្រង់ក្រាបទូលសរសើរព្រះធម្មទេសនាថា ព្រះធម្មទេសនានេះរបស់ព្រះភគវាល្អពន់ពេក ព្រះភគវាទ្រង់បានប្រកាសព្រះធម៌ទេសនាដោយអនេកបរិយាយ ដើម្បីឲ្យជាប្រយោជន៍ដល់អ្នកស្តាប់ទាំងឡាយ ដូចជាបុគ្គលផ្ងារបស់ដែលផ្កាប់ បើករបស់ដែលបិទចេញ ប្រាប់ផ្លូវឲ្យដល់អ្នកវង្វេងផ្លូវ ទ្រោលប្រទីបក្នុងទីងងឹត ដើម្បីឲ្យបុគ្គលអ្នកមានភ្នែកភ្លឺ

បានមើលឃើញវត្ថុផ្សេងៗ ដូច្នោះ ខ្ញុំព្រះអង្គសូមដល់ព្រះមានបុណ្យ ព្រះធម៌ ព្រមទាំងព្រះសង្ឃ ជាសរណៈ ជាទីពឹង ជាទីពឹក សូមព្រះមានជោគមេត្តាសម្គាល់ខ្ញុំព្រះអង្គទុកថា ជាឧបាសក ចាប់តាំងអំពីថ្ងៃនេះតទៅ រហូតដល់អស់ជីវិត ព្រះអង្គ ។

មានពាក្យអធិប្បាយព្រះបាលី **អកយរាជកុមារសូត្រ** នៅក្នុង **អដ្ឋកថាបបញ្ចសូទនី** ដូចមានសេចក្តីថា ៖

ពាក្យថា មិនអាចលេប មិនអាចខ្លាក់បាន សំដៅដល់ពាក្យជាវោហារប្រៀបធៀបសេចក្តី ដែលនិគ្រន្ថនាដបុត្រពោលយ៉ាងនេះ ព្រោះគេគិតថា ព្រះសមណគោតមបានទម្លាយពួកសាវ័ករបស់យើង ឲ្យបែកទៅអំពីយើង ហើយកាន់យកជាសាវ័ករបស់ព្រះអង្គ យើងត្រូវតែចង់ប្រស្នាតែមួយ-ខ មិនឲ្យព្រះសមណគោតមអាចដោះស្រាយបាន ពេលគេនាំអាហារចេញទៅអំពីព្រះរាជនិវេសន៍ របស់ព្រះអង្គម្ចាស់អកយរាជកុមារ ហើយបានទៅបរិភោគរហូតឆ្អែតស្កប់ស្កល់ ហើយគេទើបគិតថា ចង់បញ្ហាឡើងច្រើនប្រស្នា តែគេយល់ថា ប្រស្នាដទៃ

ព្រះសមណគោតមនឹងអាចដោះស្រាយបានទើបកាត់ចោលទៅបានលើក យកប្រស្នាមួយនេះ ឲ្យព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ទៅក្រាបទូលសួរដូចបានពោលរួចមកហើយខាងដើម ។ កាលដែលព្រះអង្គម្ចាស់អភយរាជកុមារទ្រង់ឃើញថា ថ្ងៃនេះ មិនមែនជាពេលដែលនឹងទ្រង់ក្រាបទូលសួរ ព្រោះព្រះអង្គម្ចាស់អភយរាជកុមារទ្រង់យល់ថា បញ្ហាមួយនេះ និគ្រន្ថនាដបុត្របានគិតចងបញ្ហាដល់ទៅ ៤ ខែ កាលព្រះសមណគោតមនឹងដោះស្រាយក្នុងថ្ងៃនេះ ពេលវេលាដែលព្រះជិនស្រីទ្រង់មិនអាចដោះស្រាយឲ្យគ្រប់គ្រាន់បាន ទើបព្រះរាជកុមារ ទ្រង់ត្រិះរិះថា នឹងសួរបញ្ហាក្នុងថ្ងៃស្អែកចុះ ហើយទើបទ្រង់ក្រាបទូលនិមន្តព្រះវិជិតមារ និងភិក្ខុ ៣ អង្គទៀត ឲ្យទៅទទួលចង្ហាន់ឯនិវេសន៍របស់ព្រះអង្គក្នុងថ្ងៃស្អែកនេះ ។ មានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់មិនក្រាបទូលនិមន្តភិក្ខុតាមព្រះអង្គទៅឲ្យច្រើន ? មានពាក្យឆ្លើយថា ព្រោះព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ព្រះតម្រិះថា ការនិមន្តភិក្ខុទៅច្រើនអង្គ ក៏នឹងមានការឈ្លោះ ឬមានការ

កើតកោលាហលឡើង ក្នុងការឆ្លើយឆ្លងគ្នា គឺកិកុមួយអង្គក៏នឹងអាង
ព្រះសូត្រមួយ មួយអង្គទៀត ក៏នឹងអាងព្រះសូត្រមួយទៀត នឹងអាង
ហេតុរឿងវ៉ាវផ្សេងៗ គ្នា បើយើងនឹងនិមន្តទៅត្រឹមតែមួយព្រះអង្គ ការ
និទ្ទាក៏នឹងមានឡើងដល់យើងថា ព្រះអង្គម្ចាស់អកយរាជកុមារជាមនុស្ស
កំណាចណាស់ សូម្បីទ្រង់ឃើញព្រះសក្យមុនីធ្លាប់យាងចារិកបិណ្ឌបាត
ជាមួយកិកុទាំងរយទាំងពាន់រូប ក៏ទ្រង់និមន្តទៅត្រឹមតែព្រះលោកនាថ
តែមួយអង្គប៉ុណ្ណោះ កាលយើងនិមន្តកិកុឲ្យតាមព្រះសយម្ភូត្រឹមតែ ៣
រូប ក៏មិនមាននរណាតិះដៀលយើងបាន ។

ចំណែកដែលថា ព្រះតថាគតទ្រង់មិនដោះស្រាយប្រស្នានេះ ដោយ
ចំណែកមួយនោះ គឺការដោះស្រាយប្រស្នាដូចនេះ ត្រឹមតែចំណែកមួយ
រមែងមិនមានដល់ព្រះតថាគត ព្រះវាចាដូចនេះ ព្រះតថាគតត្រាស់ក៏មាន
មិនត្រាស់ក៏មាន កាលទ្រង់ឃើញថា ការដែលនឹងត្រាស់ហើយមាន
ប្រយោជន៍ ទើបត្រាស់ កាលទ្រង់ឃើញថា មិនមានប្រយោជន៍
ក៏មិនត្រាស់ ។ ការដែលព្រះអង្គម្ចាស់អកយរាជកុមារ ទ្រង់ពក្មេងតូច

ឲ្យដេកលើក្តៅ បានដល់ព្រះអគ្គមហេសីអភយរាជកុមារ ទ្រង់ពព្រះឱរសតូច ក្នុងខណៈដែលទ្រង់ក្រាបទូលសួរបញ្ហាចំពោះព្រះសាស្តា ដោយទ្រង់មានលេសឧបាយ តែធម្មតាអ្នកមានលេសឧបាយដែលនឹងលើកវាទៈ រមែងអង្គុយកាន់ផ្លែឈើ ឬផ្កាឈើ ឬស្លឹកឫតឯណានីមួយ កាលគេឈ្នះគេក៏បានសម្តែងភាពជាធំ លើអ្នកដទៃ កាលគេចាញ់ គេនឹងសម្តែងកិរិយា ដូចជាកំពុងបរិភោគផ្លែឈើ ឬហិតផ្កាឈើ ឬអានស្លឹកឫតព្រងើយទៅ ។ ព្រោះដូច្នោះ ទើបព្រះអគ្គមហេសីអភយរាជកុមារ ទ្រង់ត្រិះរិះថា ព្រះសាស្តា ទ្រង់ជាអ្នកជ្ងាប់ចូលសង្គ្រាម ហើយទ្រង់ជាអ្នកញ៉ាំញីពាក្យសម្តីរបស់អ្នកដទៃមកហើយ បើជ័យជម្នះនឹងមានដល់យើង ក៏ជាការល្អ បើយើងចាញ់ យើងក៏ក្តិចទាកនេះឲ្យយំ ហើយក្រាបទូលព្រះសមណគោតមថា ក្មេងនេះយំហើយ ព្រះអង្គ ខ្ញុំព្រះអង្គ សូមក្រោកទៅសិន ហើយខ្ញុំព្រះអង្គ នឹងធ្វើការយល់ក្នុងរឿងនេះ ជាខាងក្រោយទៀត ដោយហេតុនេះឯង ព្រះអគ្គមហេសីអភយរាជកុមារ ទើបទ្រង់ពព្រះឱរសមក ដោយព្រះរាជា បានដាក់ព្រះឱរសនោះលើក្តៅ

ប្រថាប់គង់សន្ទនាជាមួយព្រះសាស្តា ។ តែព្រះភគវា ទ្រង់ព្រះតម្រិះថា តថាគតជាអ្នកមានវាចាដ៏ប្រសើរជាង ព្រះរាជកុមារវាប់រយវាប់ពាន់ដង តថាគតនឹងធ្វើទារកនេះឲ្យជាតួយ៉ាងនៃឧបាយហើយទើបទ្រង់ទម្លាយវាទៈរបស់ព្រះរាជកុមារនេះ កាលទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបទ្រង់តាំងបញ្ហាសួរ ដូចដែលបានពោលរួចមកហើយនៅក្នុងព្រះបាលី ។ ពាក្យថា វាចាដែលមិនជាទីស្រឡាញ់ពេញចិត្តនោះ បានដល់វាចាដែលពោលថា បុគ្គលមិនមែនជាចោរ ថាជាចោរ បុគ្គលមិនមែនជាទាសៈ ថាជាទាសៈ អ្នកដែលមិនធ្វើអំពើអាក្រក់ ថាជាអ្នកធ្វើអំពើអាក្រក់ វាចាដូច្នេះ ព្រះតថាគតមិនត្រាស់ ។

ម្យ៉ាងទៀត វាចាដែលពោលថា ចោរក៏ថាចោរ វាចាប្រកែកនេះជាដើម ព្រះតថាគតក៏មិនត្រាស់ ។ វាចាដែលគួរពោល បានដល់ វាចាដែលពោលសំដៅដល់អត្ថធម៌ ពាក្យប្រៀនប្រដៅឲ្យដល់មហាជនថា បុគ្គលនឹងទៅកាន់សុគតិ នឹងបានកើតជាមនុស្ស ហើយជាជំពូកអ្នកមានសក្តិតូច ព្រោះមិនបានធ្វើបុណ្យទុក ។ ពាក្យថា ព្រះតថាគត នឹង

ដ៏ឆ្ងាយវេលានោះ បានដល់ ព្រះតថាគតដ៏ឆ្ងាយវេលាដែលនឹងពោលវាចានោះ គឺទ្រង់ឃើញថា មហាជននឹងជឿស្តាប់ ទើបនឹងត្រាស់។

កាលព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ជាអ្នកជាក់ព្រះទ័យក្នុងការស្វែងយល់ក្នុងធម៌ ដោយទ្រង់ប្រើវិធីការត្រាស់សាកសួរ ដោយទ្រង់នាំពាក្យប្រៀនប្រដៅរបស់គ្រូទាំង ៦ មកក្រាបទូលសួរព្រះភគវាដូចជាការពិសោធន៍រកហេតុផលនៃសច្ចធម៌ តាមដែលមានរឿងសម្តែងទុកជាគោលនៅក្នុងព្រះបាលីក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ** ក្នុង **អភយសូត្រ** ដែលពោលដល់ការមិនដឹង ការមិនឃើញ មានហេតុមានបច្ច័យ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ប្រថាប់នៅឯភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះអង្គម្ចាស់អភយរាជកុមារ ស្តេចបានយាងចូលទៅគាល់ព្រះសម្ពុទ្ធ ទ្រង់ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន គ្រូបូរណកស្សប:បានពោលយ៉ាងនេះថា ហេតុមិនមាន បច្ច័យមិនមាន ដើម្បីការមិនដឹង ការមិនឃើញ ការមិនដឹង ការមិនឃើញ មិនមានហេតុ

មិនមានបច្ច័យ ហេតុមិនមាន បច្ច័យមិនមាន ដើម្បីការជឹង ការឃើញ ការជឹង ការឃើញ មិនមានហេតុ មិនមានបច្ច័យ ។ គ្រានោះ ព្រះមុនីត្រាស់ឆ្លើយថា ម្នាលព្រះរាជកុមារ ហេតុមាន បច្ច័យមាន ដើម្បីការមិនជឹង ការមិនឃើញ ការមិនជឹង ការមិនឃើញ មានហេតុ មានបច្ច័យ មានហេតុ មានបច្ច័យ ដើម្បីការជឹង ការឃើញ ការជឹង ការឃើញ មានហេតុ មានបច្ច័យ ។ លំដាប់នោះ ព្រះអង្គម្ចាស់អភយរាជកុមារទ្រង់ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដើម្បីការមិនជឹង ការមិនឃើញ ការមិនជឹង ការមិនឃើញ មានហេតុ មានបច្ច័យដូចម្តេច ព្រះអង្គ ? គ្រានោះ ទើបព្រះសាស្តាទ្រង់ត្រាស់អធិប្បាយសេចក្តីនោះថា ម្នាលព្រះរាជកុមារ ក្នុងពេលណាបុគ្គលមានចិត្តរាយមាយដោយកាមរាគៈ ត្រូវកាមរាគៈគ្របសង្កត់ហើយ រមែងមិនជឹង មិនឃើញឧបាយ ជាគ្រឿងរលាស់ចេញចាកកាមរាគៈដែលកើតឡើងហើយ តាមសេចក្តីពិតបាន សេចក្តីនេះឯង ជាហេតុ ជាបច្ច័យ ដើម្បីការមិនជឹង ការមិនឃើញ ការមិនជឹង ការមិនឃើញ

មានហេតុ មានបច្ច័យយ៉ាងនេះឯង ។ម្នាលព្រះរាជកុមារប្រការមួយទៀត ក្នុងពេលណា បុគ្គលមានចិត្តរាយមាយដោយព្យាបាទ ត្រូវព្យាបាទគ្របសង្កត់ហើយ រមែងមិនដឹង មិនឃើញឧបាយ ដែលជាគ្រឿងរលាស់ចេញចាកព្យាបាទដែលកើតឡើងហើយ តាមសេចក្តីពិតបាន សេចក្តីនេះឯង ជាហេតុ ជាបច្ច័យ ដើម្បីការមិនដឹង ការមិនឃើញ ការមិនដឹង ការមិនឃើញ មានហេតុ មានបច្ច័យយ៉ាងនេះឯង ។

ម្នាលព្រះរាជកុមារ ប្រការមួយទៀត ក្នុងពេលណា បុគ្គលមានចិត្តរាយមាយ ដោយថីនមិទ្ធៈ ដែលត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ រមែងមិនដឹងមិនឃើញឧបាយ ជាគ្រឿងរលាស់ចេញចាកថីនមិទ្ធៈ ដែលកើតឡើងហើយ តាមសេចក្តីពិតបាន ប្រការនេះឯង ជាហេតុ ជាបច្ច័យ ដើម្បីការមិនដឹង ការមិនឃើញ ការមិនដឹង ការមិនឃើញ មានហេតុ មានបច្ច័យយ៉ាងនេះឯង ។ ម្នាលព្រះរាជកុមារ ប្រការមួយទៀត ក្នុងពេលណា បុគ្គលមានចិត្តរាយមាយ ដោយឧទ្ធច្ចកុក្កុច្ចៈ ដែលត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ហើយ រមែងមិនដឹងមិនឃើញឧបាយ ជាគ្រឿង

រលាស់ចោលឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ តាមសេចក្តីពិតបាន សេចក្តីនេះឯង ជាហេតុ ជាបច្ច័យ ដើម្បីការមិនដឹង ការមិនឃើញ ការមិនដឹង ការមិនឃើញ មានហេតុ មានបច្ច័យយ៉ាងនេះឯង ។ ម្នាលព្រះរាជកុមារ ប្រការមួយទៀត ក្នុងពេលណា បុគ្គលមានចិត្តរាយមាយ ដោយវិចិកិច្ឆា ដែលត្រូវវិចិកិច្ឆាគ្របសង្កត់ហើយ រមែងមិនដឹង មិនឃើញឧបាយ ដែលជាគ្រឿងរលាស់ចោលវិចិកិច្ឆា ដែលកើតឡើងហើយ តាមសេចក្តីពិតបាន សេចក្តីនេះឯង ជាហេតុ ជាបច្ច័យ ដើម្បីការមិនដឹង ការមិនឃើញ ការមិនដឹង ការមិនឃើញ មានហេតុ មានបច្ច័យយ៉ាងនេះឯង ។ គ្រានោះ ព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ស្តាប់ធម្មតាធិប្បាយនេះហើយ ទ្រង់ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មបរិយាយនេះឈ្មោះអ្វី ព្រះអង្គ ? ពេលនោះ ព្រះភគវាត្រាស់តបថា ម្នាលព្រះរាជកុមារ ធម្មបរិយាយទាំងនេះ ឈ្មោះថា **នីវរណៈ** ។ លំដាប់នោះ ព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះជានីវរណៈពិត បពិត្រព្រះសម្ពុទ្ធ

ធម៌ទាំងនេះជានីវរណៈពិត បពិត្រព្រះលោកនាថ បុគ្គលត្រូវនីវរណៈសូម្បីត្រឹមតែមួយមកគ្របសង្កត់ហើយ ក៏មិនដឹង មិនឃើញទៅតាមសេចក្តីពិតបាន មិនចាំបាច់ពោលដល់ត្រូវនីវរណៈទាំង ៥ ប្រការគ្របសង្កត់ហើយទេ ព្រះអង្គ ។

បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដើម្បីការដឹង ការឃើញ ការដឹង ការឃើញ មានហេតុ មានបច្ច័យ ដូចម្តេច ព្រះអង្គ ? គ្រានោះ ព្រះលោកនាយកត្រាស់ថា ម្នាលព្រះរាជកុមារ ភិក្ខុក្នុងធម្មវិន័យនេះ រមែងអប់រំសតិសម្ពោជ្ឈង្គ ដែលអាស្រ័យវិវេក ដែលអាស្រ័យវិរាគៈ ដែលអាស្រ័យនិរោធ បង្អោនទៅក្នុងការលះបង់ ភិក្ខុនោះអប់រំសតិសម្ពោជ្ឈង្គ រមែងដឹង ឃើញទៅតាមសេចក្តីពិតបានដោយចិត្តនោះ ។ ប្រការនេះឯង ជាហេតុ ជាបច្ច័យ ដើម្បីការដឹង ការឃើញ ការដឹង ការឃើញ មានហេតុ មានបច្ច័យ ដោយប្រការយ៉ាងនេះឯង ។ ម្នាលព្រះរាជកុមារ ប្រការមួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ រមែងអប់រំធម្មវិចយសម្ពោជ្ឈង្គ ។ល។ ម្នាលព្រះរាជកុមារ ប្រការមួយ

ទៀត កិកូក្នុងធម្មវិន័យនេះ រមែងអប់រំវិរិយសម្ពោជ្ឈង្គ ។ល។ ម្នាលព្រះរាជកុមារ ប្រការមួយទៀត កិកូក្នុងធម្មវិន័យនេះ រមែងអប់រំបីតិសម្ពោជ្ឈង្គ ។ល។ ម្នាលព្រះរាជកុមារ ប្រការមួយទៀត កិកូក្នុងធម្មវិន័យនេះ រមែងអប់រំបស្សទ្ធិសម្ពោជ្ឈង្គ ។ល។ ម្នាលព្រះរាជកុមារ ប្រការមួយទៀត កិកូក្នុងធម្មវិន័យនេះ រមែងអប់រំសមាធិសម្ពោជ្ឈង្គ ។ល។ ម្នាលព្រះរាជកុមារ ប្រការមួយទៀត កិកូក្នុងធម្មវិន័យនេះ រមែងអប់រំឧបេក្ខាសម្ពោជ្ឈង្គដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅក្នុងការលះបង់ កិកូនោះអប់រំឧបេក្ខាសម្ពោជ្ឈង្គ រមែងដឹង ឃើញទៅតាមសេចក្តីពិតដោយចិត្តនោះ ។ ប្រការនេះឯង ជាហេតុជាបច្ច័យ ដើម្បីការដឹង ការឃើញ ការដឹង ការឃើញ មានហេតុមានបច្ច័យ ដោយប្រការយ៉ាងនេះឯង ។

គ្រានោះ ព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់បានស្តាប់ព្រះពុទ្ធតម្រាស់ដូច្នេះហើយ ទើបទ្រង់ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មបរិយាយនេះឈ្មោះអ្វី ព្រះអង្គ ? ពេលនោះ ព្រះអង្គត្រាស់តបថា

ម្នាលព្រះរាជកុមារ ធម្មបរិយាយនេះឈ្មោះថា **ពោជ្ឈង្គ** ។ (ធម៌ជាគ្រឿងនៃការត្រាស់ដឹង) ។ លំដាប់នោះ ព្រះអង្គម្ចាស់អកយរាជកុមារទ្រង់សរសើរធម៌ទាំងនោះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះជាពោជ្ឈង្គពិតៗ ព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលប្រកបដោយពោជ្ឈង្គត្រឹមប្រការណានីមួយ គប្បីដឹង យើញទៅតាមសេចក្តីពិតបាន មិនចាំបាច់ពោលដល់ការប្រកបដោយពោជ្ឈង្គ ៧ ប្រការទេ ព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចម្រើន ការនឿយលំបាកកាយ និងចិត្តឯណារបស់ខ្ញុំព្រះអង្គ ខណៈដែលខ្ញុំព្រះអង្គឡើងកាន់ភ្នំគិជ្ឈកូដ ការនឿយលំបាកកាយ និងចិត្តនោះ បាត់ទៅអស់រលីងហើយ ទាំងខ្ញុំព្រះអង្គក៏បានយល់ដឹងក្នុងធម៌ហើយ ព្រះអង្គ ។

ម្យ៉ាងទៀត ព្រះមានជោគ ទ្រង់អធិប្បាយប្រៀបធៀបនីវរណៈ ៥ ប្រការ ដែលមានអាការផ្សេងៗ ឲ្យសគារវព្រាហ្មណ៍ស្តាប់ មានសេចក្តីសម្តែងប្រាកដនៅក្នុង **សគារវសូត្រ** ក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ** ដូចមានសេចក្តីថា ៖

នីវរណៈ គឺកិលេសដែលរារាំងចិត្ត មិនឲ្យធ្វើសេចក្តីល្អ មាន ៥ ប្រការ ជាហេតុ ជាបច្ច័យ ឲ្យកើតការមិនដឹង ការមិនឃើញទៅតាមសេចក្តីពិត ។ ក្នុងពេលបុគ្គលណាកើតកាមរាគៈ គឺសេចក្តីត្រេកត្រអាលចំពោះសេចក្តីស្រឡាញ់ ចូលមកគ្របសង្កត់ចិត្តហើយ រមែងមានឧបមាដូចគ្នានឹងទឹកក្នុងកាជនៈ ដែលលាយឡំដោយពណ៌ផ្សេងៗ បុគ្គលនោះរមែងមើលមិនឃើញស្រមោលមុខខ្លួនឯង ក្នុងកាជនៈដែលជាក់ទឹកនោះបានតាមសេចក្តីពិត ។ ក្នុងពេលដែលចិត្តកើតព្យាបាទ គឺការគិតប្រទូស្តអ្នកដទៃ ចូលមកគ្របសង្កត់ចិត្តហើយ រមែងមានឧបមាដូចជាទឹកដែលកំពុងក្តៅខ្លាំង សេចក្តីពិតខណៈដែលទឹកកំពុងក្តៅ រមែងមានចំហាយផ្សែងកើតឡើង នរណាៗ នឹងសម្លឹងមើលស្រមោលមុខរបស់ខ្លួនក្នុងទឹកដែលកំពុងក្តៅនោះ រមែងឃើញមិនបានច្បាស់លាស់ ។ ក្នុងពេលដែលចិត្តត្រូវថីនមិទ្ធៈ គឺភាពដែលចិត្តរួញរា និងងោកងុយចូលមកគ្របសង្កត់ចិត្តហើយ រមែងមានឧបមា ដូចទឹកដែលគ្របដណ្តប់ដោយសាកយ ចក ពើកជូរច្នោះ នរណាៗ មិនអាចសម្លឹងមើលឃើញស្រមោលមុខរបស់ខ្លួន

ក្នុងទឹកនោះច្បាស់លាស់បាន ។ ក្នុងពេលដែលចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈ គឺការរាយមាយ និងការស្តាយក្រោយចូលមកគ្របសង្កត់ចិត្តហើយ រមែងប្រៀបដូចទឹកក្នុងថាស ដែលខ្យល់ផាត់ផ្តើមកើតជារលក ដែលបុគ្គលមានភ្នែកល្អ មើលស្រមោលមុខរបស់ខ្លួនក្នុងថាសនោះ ក៏មិនឃើញបានច្បាស់ ។ ក្នុងពេលដែលចិត្តត្រូវវិចិកិច្ឆា គឺសេចក្តីសង្ស័យចូលមកគ្របសង្កត់ចិត្តហើយ រមែងមានឧបមាដូចជាទឹកក្នុងថាស ដែលខាប់ដូចជាកក់ ទាំងនៅក្នុងទីងងឹត ដែលនរណាៗ មិនអាចមើលឃើញស្រមោលមុខរបស់ខ្លួនក្នុងថាសទឹកនោះ ឲ្យបានច្បាស់លាស់ឡើយ ។ ព្រោះដូច្នោះ នីវរណៈ ៥ ប្រការ ជាវត្ថុដែលធ្វើឲ្យមិនដឹង មិនឃើញទៅតាមសេចក្តីពិតបាន ។ មិនដឹងមិនឃើញអ្វី ? មិនដឹងមិនឃើញនូវប្រយោជន៍របស់ខ្លួនខ្លះ ប្រយោជន៍របស់អ្នកដទៃខ្លះ ទាំងរបស់ខ្លួននិងរបស់អ្នកដទៃខ្លះ ។

មានរឿងរបស់ព្រះអង្គម្ចាស់អភយរាជកុមារ ដែលបានទទួលព្រះរាជទានរាជសម្បត្តិ ជារង្វាន់អំពីព្រះបាទពិម្ពិសារ ដែលជាព្រះរាជបិតា

ដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **លោកវគ្គ** ក្នុងរឿងរបស់ព្រះអង្គម្ចាស់អភយរាជកុមារ ដូចមានសេចក្តីថា ៖

សម័យមួយ កាលព្រះមហាវីរបុរសប្រថាប់នៅក្នុងវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ បានត្រាស់ព្រះធម្មទេសនា ដោយទ្រង់ប្រារព្ធព្រះអង្គម្ចាស់អភយរាជកុមារឲ្យជាដើមហេតុថា ក្នុងគ្រាមួយ ព្រះអង្គម្ចាស់អភយរាជកុមារ ទ្រង់បានទៅបង្ក្រាបរាជសត្រូវឯបច្ចន្តជនបទ ឲ្យស្ងប់រៀបរយហើយ ទើបយាងត្រឡប់មក ។ គ្រានោះ ព្រះបាទពិម្ពិសារ ដែលជាព្រះរាជបិតា ទ្រង់ពេញព្រះរាជហឫទ័យក្រៃលែងណាស់ ទើបបានព្រះរាជទានស្រីរបាំ ៥០០ នាក់ ដែលជាអ្នកឈ្នះក្នុងការប្រៀងភំនិងប្រគំកូត ហើយបានព្រះរាជទានរាជសម្បត្តិឲ្យសោយរាជ្យ ៧ ថ្ងៃ ។ ពេលនោះ ព្រះអង្គម្ចាស់អភយរាជកុមារ មិនបានយាងចេញទៅខាងក្រៅព្រះរាជមន្ទីរឡើយ បានសោយសិរីរាជសម្បត្តិក្នុងភាពជាព្រះរាជារហូតអស់ ៧ ថ្ងៃហើយ ទើបព្រះអង្គយាងទៅឯកំពង់ទឹកក្នុងថ្ងៃទី ៨ ទ្រង់បានស្រង់ទឹក ហើយយាងចូលទៅឯព្រះរាជឧទ្យាន ប្រថាប់គង់

មើលការរាំ និងការច្រៀងរបស់ស្រីទាំងនោះ ដូចសន្តតិមហាមាត្យដែរ ។ ចំណែកស្រីដែលរាំទៅមកនាកណ្តាលវេទិការាំ ផ្តើមនឹងសម្តែងការរាំ និងច្រៀង ខណៈដែលនាងសម្តែងអាការច្រៀងរាំនោះ ខ្យល់មានពិសកាចដូចសស្ត្រា បានកើតឡើងក្នុងពោះ បានមកកាត់សាច់បេះដូងជាច់ទៅ ព្រោះហេតុតែនាងជាអ្នកបរិភោគអាហារតិច ជាប់តគ្នាមករហូត ៧ ថ្ងៃ ទាំងនេះ ដើម្បីការសម្តែងឲ្យក្លៀវក្លា ដោយសរីរៈ ពងកាយដែលទន់ល្ងន់ល្ងៃ ហើយក្នុងមួយរំពេចនោះឯង នាងមានមាត់ហា ក្អែកត្រឡប់ ហើយក៏ស្លាប់ក្នុងទីនោះឯង ។ ពេលនោះ ព្រះអង្គម្ចាស់អកយរាជកុមារ ត្រាស់បញ្ជាថា អ្នកទាំងឡាយចូរពិនិត្យមើលស្រីរបាំនោះ ទៅជាយ៉ាងណាហើយ ? កាលមានអ្នកក្រាបទូលថា ស្រីរបាំនោះស្លាប់ហើយក្រាបទូល ។

គ្រានោះ ព្រះអង្គម្ចាស់អកយរាជកុមារ ទ្រង់មានសេចក្តីសោកសៅយ៉ាងក្រៃលែង ព្រោះហេតុតែស្រីរបាំនោះស្លាប់ទៅ ទ្រង់ព្រះតម្រិះថា អ្នកជំទៀវព្រះមុនីចេញហើយ នឹងមាននរណាអាចធ្វើឲ្យសេចក្តីសោករបស់យើងរលត់ទៅបាន ហើយទើបយាងទៅគាល់ព្រះមានជោគ ទ្រង់

ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះជិនស្រី ទ្រង់ករុណា
ធ្វើឲ្យសេចក្តីសោកសៅ របស់ខ្ញុំព្រះករុណាអស់ទៅផង ព្រះអង្គ ?
លំដាប់នោះ ព្រះវិជិតមារទ្រង់ត្រាស់លួងលោម ព្រះអង្គម្ចាស់អភយ-
រាជកុមារ ឲ្យទ្រង់សប្បាយព្រះហឫទ័យ ហើយត្រាស់ថា ម្នាលរាជកុមារ
ការប្រមាណទឹកភ្នែកទាំងឡាយ ដែលព្រះរាជកុមារ ទ្រង់ព្រះកន្សែង
នៅក្នុងវេលាដែលស្រីវជ្ជាំនេះស្លាប់ហើយយ៉ាងនេះ រមែងរាប់មិនបាន
ក្នុងសង្សារវដ្ត ដែលរកទីបំផុតមិនមាន ។ លុះព្រះពុទ្ធអង្គទ្រង់ជ្រាបថា
ព្រះរាជកុមារ ទ្រង់មានសេចក្តីសោកធូរស្បើយហើយ ព្រោះទេសនានេះ
ហើយ ទើបត្រាស់ថា ម្នាលព្រះរាជកុមារៗ កុំសោយសោកឡើយ
សេចក្តីសោយសោកនេះ ជាទីធ្លាក់ចុះរបស់បុគ្គលល្ងង់ខ្លៅទាំងឡាយ
ហើយត្រាស់ព្រះគាថាប្រពន្ធថា

***អ្នកទាំងឡាយ ចូរមកមើលលោកនេះ ដែលវិចិត្រស្អាតបាត
ដូចរាជរថ ដែលពួកមនុស្សល្ងង់ខ្លៅលិចចុះ តែពួកអ្នកដឹងជាប់ជំពាក់
នៅមិនបានឡើយ ។***

ក្នុងព្រះគាថានេះ មានពាក្យអធិប្បាយរបស់ព្រះអដ្ឋកថាចារ្យថា ពាក្យថា អ្នកទាំងឡាយចូរមកមើល គឺព្រះសក្យមុនីត្រាស់សំដៅដល់ព្រះអង្គម្ចាស់អកយរាជកុមារនោះឯង ។ ពាក្យថា **លោកនេះ** បានដល់ **អត្តភាព** ដែលរាប់ថាជាខន្ធលោកជាដើម ។ ពាក្យថា **វិចិត្រ** គឺស្អាតដោយគ្រឿងស្បែកជណ្តប់ គ្រឿងប្រដាប់តាក់តែងជាដើម ដូចរាជរថដែលស្អាតដោយគ្រឿងប្រដាប់ មានកែវ ៧ ប្រការជាដើម ។ ពាក្យថា **ពួកមនុស្សល្ងង់ខ្លៅងប់ងុលនៅ** គឺមនុស្សល្ងង់ប៉ុណ្ណោះ ដែលលិចចុះក្នុងអត្តភាពនេះ ។ ពាក្យថា **ពួកអ្នកដ៏ឆ្លាស់** គឺពួកបណ្ឌិតទាំងឡាយ មិនមានការជាប់ជំពាក់ក្នុងកិលេស ជាគ្រឿងជាប់ជំពាក់បានដល់ **រាគៈ** គឺសេចក្តីត្រេកត្រអាលក្នុងកាមជាដើមឡើយ ។

ក្នុងពេលដែលព្រះកគវា ទ្រង់ត្រាស់ទេសនានេះចប់ ព្រះអង្គម្ចាស់អកយរាជកុមារ បានតាំងនៅក្នុងសោតាបត្តិផលព្រះធម្មទេសនាក្នុងពេលនោះ ក៏បានជាប្រយោជន៍ដល់មហាជនជាច្រើនដែរ ។ ម៉្យាងទៀត ក្នុងរឿងរបស់ព្រះអង្គម្ចាស់អកយរាជកុមារនេះ ជាគ្រឿងចង្អុលបង្ហាញ

ឲ្យឃើញថា សេចក្តីទុក្ខសោករបស់សត្វលោក រមែងមានច្រើនប្រការ ណាស់ សូម្បីក្នុងវត្តុដែលនរណាៗ គិតមិនដល់ ក៏នៅមានសន្ធឹកសន្ធាប់ ឧទាហរណ៍ដូចជាស្រីរថ្មាំកំពុងតែរាំ ក៏ស្រាប់តែមានខ្សែចាប់កណ្តាល **វេទិកា** នរណាៗ ក៏គិតមិនដល់ថា មនុស្សដែលកំពុងរាំ នឹងស្លាប់ទៅ យ៉ាងងាយបាន ព្រោះពោលដោយច្រើន ដែលឃើញស្លាប់ងាយៗនោះ មានតែចំពោះអ្នកដេកឈឺប៉ុណ្ណោះ ព្រោះដូច្នោះ ក្នុងលោកនេះសុទ្ធតែ អនិច្ចំទាំងអស់ ។ កាពស្រស់បស់វត្តុគ្រប់យ៉ាងមែនពិត មួយចំណែកធំ រមែងស្រស់ស្អាតដោយគ្រឿងតាក់តែងផ្សេងៗ ដូចជាផ្ទះសម្បែង រទេះ ទូក រហូតដល់រាងកាយមនុស្សទាំងឡាយ ថាស្រស់ស្អាតក៏ដោយការ ប្រដាប់តុបតែងឡើងទាំងអស់ ការពិតមិនស្អាតឡើយ ល្បងពិចារណា មើលមនុស្ស ដែលកំពុងតែដេកលក់ ឬភ្ញាក់ពីដេកថ្មីៗ ពេលដែល ដេកលក់ មានទឹកមាត់ហូរជាដើម ឬពេលដែលភ្ញាក់ពីដេកភ្លាមៗ មុខមាត់ សក់មើលមិនបានឡើយ ក្រឡេកមើលហើយស្អាតត្រង់ណា តែបុថុជ្ជន គឺបុគ្គលដែលជាអ្នកមានកិលេសក្រាស់ ក៏ស្គុតចិត្តវង្វេង អត់សង្កត់ទឹកថា

ស្រស់ស្អាតមិនបាន ព្រោះអ្វី? ព្រោះលោកនេះត្រូវតុបតែង សាងភាព
ចោកបញ្ឆោតភ្នែកតែប៉ុណ្ណោះ ។

ចំណែកបុគ្គលអ្នកមានបុណ្យបារមីគ្រប់គ្រាន់ ដែលបានបំពេញ
មកជាច្រើនហើយប៉ុណ្ណោះ ទើបសម្ផ័ងឃើញបានត្រឹមត្រូវ មិនមានអ្វី
ស្រស់ស្អាតឡើយ (ព្រះអង្គម្ចាស់អភយរាជកុមារ បានក្លាយជាឧបាសក
កាលព្រះបាទពិម្ពិសារ ដែលជាព្រះរាជបិតាទ្រង់សោយទិវង្គតទៅហើយ
ទើបព្រះអង្គទ្រង់កើតការសង្វេគ ហើយទ្រង់បួសជាភិក្ខុនៅក្នុងព្រះពុទ្ធ-
សាសនានេះ ហើយបានសម្រេចអរហត្តផល ជាព្រះអរហន្ត គឺបុគ្គល
មិនមានកិលេស ចំណែកហេតុដែលនាំជីវប្រវត្តិ មករួមទុកនៅក្នុង
ជីវប្រវត្តិពុទ្ធឧបាសកនេះ ពីព្រោះជីវប្រវត្តិចំណែកដោយច្រើន ពោល
ដល់រឿងរ៉ាវមុនទ្រង់ព្រះផ្នួស) ។

(ជីវប្រវត្តិរបស់ព្រះអង្គម្ចាស់អភយរាជកុមារឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ឆត្តមាណពឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

ឆត្តមាណពឧបាសក ជាអ្នកមានភាពឧស្សាហ៍ព្យាយាម ទាំងជាអ្នកស្រឡាញ់ការរៀនសូត្រ និងជាអ្នកប្រព្រឹត្តប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ឪពុកម្តាយ និងគ្រូបាអាចារ្យ និងទាំងជាអ្នកមានភាពទៀងត្រង់ ចេះដឹងគុណរបស់អ្នកដទៃ ហើយបានជាឧបាសកតាំងអំពីនៅវ័យក្មេងម៉្លេះ ។

ជីវប្រវត្តិរបស់ឆត្តមាណពឧបាសក មានសម្តែងប្រាកដនៅក្នុង ***អដ្ឋកថាបរមត្ថទីបនី*** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីពិស្តារក្នុង ***គម្ពីរខុទ្ទកនិកាយ វិមានវត្ថុ ព្រះសុត្តន្តបិដក*** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះទសពលប្រថាប់នៅឯវត្តជេតពនមហាវិហារ ជិតក្រុងសាវត្ថី ។ គ្រានោះ មានមាណពម្នាក់ឈ្មោះ ឆត្តមាណព ជាបុត្ររបស់ព្រាហ្មណ៍ ។ ឆត្តមាណព ជាអ្នកដែលបិតារបស់គេបាន

គេមកដោយសេចក្តីលំបាក អាស្រ័យនៅក្នុងក្រុងសេតព្យៈ ។ កាលឆត្តមាណពចម្រើនវ័យធំដឹងក្តីហើយ ទើបបញ្ជូនគេទៅឯក្រុងឧក្កដ្ឋាដើម្បីឲ្យទៅរៀនវិជ្ជាផ្សេងៗ នៅក្នុងសម្នាក់របស់អាចារ្យបោក្ខរសាតិព្រាហ្មណ៍ គេជាអ្នកបានសិក្សាវិជ្ជាទាំងនោះ បានសម្រេចយ៉ាងឆាប់រហ័ស ទាំងនេះព្រោះគេជាអ្នកមានបញ្ញាល្អ និងឧស្សាហ៍ព្យាយាមរៀនសូត្រទៀតផង ។ កាលគេសម្រេចការសិក្សាទាំងនោះហើយ គេបានប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ ខ្ញុំបាទបានមកសិក្សាសិល្បវិជ្ជា នៅក្នុងសម្នាក់របស់លោកអាចារ្យបានចប់ហើយ តើខ្ញុំនឹងឲ្យវត្ថុណាជល់លោកអាចារ្យដើម្បីជាការបូជាជល់គ្រូដ៏ប្រសើរ ។

គ្រានោះ អាចារ្យបោក្ខរសាតិព្រាហ្មណ៍តបថា ធម្មតាតម្លៃបូជាគ្រូឲ្យសមរម្យទៅតាមទ្រព្យសម្បត្តិរបស់កូនសិស្ស ព្រោះដូច្នោះ អ្នកចូរឲ្យប្រាក់មួយពាន់កហាបណៈមកយើង ដើម្បីជាតម្លៃក្នុងការបូជាគ្រូចុះ ។ ពេលនោះ ឆត្តមាណពក្រាបលាអាចារ្យបោក្ខរសាតិព្រាហ្មណ៍ ត្រឡប់ទៅកាន់ក្រុងសេតព្យៈ ពេលគេទៅដល់ហើយ គេបានទៅថ្វាយបង្គំ

មាតាបិតារបស់គេ ។ ចំណែកមាតាបិតាបានសម្តែងសេចក្តីត្រេកអរ
ជាមួយកូន ដែលកូនប្រុសបានទៅសិក្សាចប់ ហើយត្រឡប់មកធ្វើ
បដិសណ្ឋារៈមាតាបិតា ។ ឆត្តមាណព គេបានប្រាប់ឪពុកម្តាយថា
លោកឪពុក អ្នកម្តាយមេត្តាឲ្យប្រាក់មួយពាន់កហាបណៈដល់ខ្ញុំបាទផង
ខ្ញុំបាទនឹងនាំយកទៅឲ្យដល់អាចារ្យ ដើម្បីជាតម្លៃបូជាគ្រូក្នុងថ្ងៃនេះឯង
ហើយខ្ញុំបាទនឹងត្រឡប់មកវិញ ។គ្រានោះ មាតាបិតាបានពោលជាមួយ
នឹងឆត្តមាណពថា កូនអើយ ថ្ងៃនេះ ល្ងាចណាស់ហើយ ចាំថ្ងៃស្អែក
សិនចុះ សឹមទៅណាកូនណា កាលមាតាបិតាបានពោលដូច្នេះហើយ
ទើបនាំកហាបណៈចេញមកឲ្យ ហើយបានប្រគល់ឲ្យដល់ឆត្តមាណព
ដែលជាកូនប្រុសរបស់ខ្លួន ។ ចំណែកពួកចោរបានជ្រាបដំណឹងអំពី
ឆត្តមាណព ដែលបាននាំយកប្រាក់ទៅឲ្យលោកអាចារ្យបោក្ខរសាតិ-
ព្រាហ្មណ៍ ទើបនាំគ្នាទៅស្កាត់នៅក្នុងវាងផ្លូវ ដែលឆត្តមាណពបានធ្វើ
ដំណើរមក ដោយតាំងចិត្តនឹងប្លន់យកទ្រព្យសម្បត្តិទាំងអស់នោះ ។

ប៉ុន្តែក្នុងវេលាជិតភ្លឺថ្ងៃនោះ ព្រះសយម្ភូទ្រង់បានចេញអំពីមហា

ករុណាសមាបត្តិ ហើយទ្រង់ប្រមើលមើលសត្វលោក ទ្រង់បានឃើញ ឧបនិស្ស័យរបស់ឆត្តមាណពតាំងនៅក្នុងត្រៃសរណគមន៍ និងសីល ពេលដែលគេត្រូវពួកចោរសម្លាប់ស្លាប់ហើយ គេនឹងបានទៅកើតក្នុង ទេវលោក បន្ទាប់មក គេនឹងចុះអំពីទេវលោក ព្រមទាំងវិមាន ដើម្បី ចូលមកគាល់តថាគត ទាំងព្រះអង្គទ្រង់សម្លឹងឃើញពុទ្ធបរិស័ទដែល មកប្រជុំគ្នានៅក្នុងស្ថានទីនោះ បានសម្រេចមគ្គផលជាច្រើនផងដែរ ។ លុះវេលាព្រឹកឡើង ទើបព្រះលោកនាយក យាងទៅមុន ដោយទៅ ប្រថាប់គង់នៅត្រង់គល់ឈើមួយដើមក្បែរផ្លូវ ដែលឆត្តមាណពត្រូវដើរ មកក្បែរនោះ ។ ឆត្តមាណពបានកាន់ស្បោងដាក់ប្រាក់ ដើម្បីយកទៅ ឲ្យដល់លោកអាចារ្យ បានចេញដំណើរអំពីក្រុងសេតព្យៈដោយតម្រង់ ទៅកាន់ឧក្កដ្ឋានោះ ដើរៗ ទៅ បានឃើញព្រះបរមសាស្តាប្រថាប់គង់ នៅខាងក្រោមដើមឈើមួយដើមនោះ ទើបគេចូលទៅក្រាបថ្វាយបង្គំ ។ គ្រានោះ ព្រះមានជោគត្រាស់សួរថា ម្នាលមាណព អ្នកទៅទីណា ? ពេលនោះ ឆត្តមាណពបានក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន

ខ្ញុំព្រះអង្គទៅកាន់ក្រុងឧក្កដ្ឋា ដើម្បីនាំយកប្រាក់ទៅជូនដល់លោក គ្រូអាចារ្យបោក្ខរសាតិព្រាហ្មណ៍ ដែលជាអាចារ្យរបស់ខ្ញុំព្រះអង្គ ព្រះអង្គ ។ លំដាប់នោះ ព្រះលោកនាថត្រាស់សួរថា ម្នាលមាណព អ្នកស្គាល់ត្រៃសរណាគមន៍ និងសីល ៥ ឬទេ ? ឆត្តមាណពក្រាបទូលថា ខ្ញុំព្រះអង្គមិនស្គាល់ត្រៃសរណាគមន៍ និងសីល ៥ យ៉ាងណានោះទេ ព្រះអង្គ ។ លំដាប់នោះ ទើបព្រះទសពល ទ្រង់សម្តែងផលានិសង្ស របស់អ្នកវាប់អានព្រះត្រៃសរណាគមន៍ ឬអ្នកដល់ត្រៃសរណាគមន៍ និង ការរក្សាសីល ៥ ឲ្យឆត្តមាណពបានស្តាប់ ហើយព្រះអង្គត្រាស់ថា អ្នកចូររៀនវិធីក្នុងការដល់ព្រះត្រៃសរណាគមន៍មុន ។ឆត្តមាណពទទួលថា ខ្ញុំព្រះអង្គនឹងរៀន សូមព្រះអង្គមេត្តាត្រាស់បង្រៀនខ្ញុំព្រះអង្គមកចុះ ព្រះអង្គ ។ពេលនោះ ទើបព្រះសម្ពុទ្ធ ទ្រង់សម្តែងវិធីអ្នកវាប់អានព្រះ ត្រៃសរណាគមន៍ ត្រាស់ប្រពន្ធគាថា ដូចមានសេចក្តីថា

បណ្តាអ្នកពោលប្រៀនប្រដៅ (សាស្តា) បុគ្គលណាជាអ្នក ប្រសើរ ក្នុងពពួកមនុស្ស ជាអ្នកប្រាជ្ញរបស់សក្យៈ ជាអ្នកមានជោគ

ជាអ្នកធ្វើកិច្ចស្រេចហើយ ជាអ្នកទៅដល់ច្រាំង (ព្រះនិព្វាន) ហើយ ជាអ្នកដល់ព្រមដោយកម្លាំង និងសេចក្តីព្យាយាម ។ អ្នកចូរវាប់អានបុគ្គលនោះ ជាអ្នកទៅល្អហើយ (សុគត) ជាសរណៈ គឺជាទីពឹង ទីរឭក ។ អ្នកចូរវាប់អានព្រះធម៌ ដែលខ្ចាក់ចោលនូវរាគៈ មិនញាប់-ញ័រ មិនសោយសោក ជាអសង្ខតធម៌ មិនបដិកូល ពីរោះ ស្មោះត្រង់ ដែលតថាគតចែកទុកល្អហើយ ជាសរណៈ គឺជាទីពឹង ទីរឭក ។ អ្នកចូរវាប់អានព្រះអរិយសង្ឃ ៤ គូ ៨ ជំពូក ជាអ្នកសម្តែងធម៌ ដែលបណ្ឌិតទាំងឡាយពោលថា ជាអ្នកធ្វើឲ្យទានដែលថ្វាយហើយ មានផលច្រើន ជាសរណៈ គឺជាទីពឹង ទីរឭកចុះ ។

កាលព្រះសាស្តាត្រាស់បង្រៀន វិធីអ្នកដល់ព្រះត្រៃសរណាគមន៍ ឬអ្នកវាប់អានព្រះត្រៃសរណាគមន៍ ព្រមទាំងចង្អុលគុណរបស់ព្រះត្រៃ-សរណាគមន៍ដូច្នេះហើយ ។ ឆត្តមាណពបានស្តាប់ហើយ ក៏មានចិត្តត្រេកអរជ្រះថ្លា ទើបទទួលព្រះត្រៃសរណាគមន៍ ហើយទើបរឭកដល់ព្រះត្រៃសរណាគមន៍ បានដល់គុណព្រះពុទ្ធ គុណព្រះធម៌ និងគុណ

ព្រះសង្ឃទុកនៅក្នុងខ្លួន ។ គ្រានោះ ទើបព្រះសាស្តា ត្រាស់ប្រកាសសិក្ខាបទ ៥ ប្រការ ដោយទ្រង់ផ្តើមតាំងអំពីប្រការទី ១ រហូតដល់ទី ៥ ទាំងទ្រង់សម្តែងអំពីអានិសង្ស ហើយបានត្រាស់បង្រៀនសមាទានសិក្ខាបទទាំងនោះឲ្យដល់ឆត្តមាណព ដែលតាំងចិត្តបង្អោនទទួលយក ។ លំដាប់នោះ ឆត្តមាណពបានរឭកឃើញ វិធីសមាទាននោះដោយល្អហើយ ក៏មានចិត្តជ្រះថ្លាក្រៃលែងឡើង បានក្រាបទូលលាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំលាទៅមុនហើយ ព្រះអង្គ ហើយគេបានរឭកដល់គុណព្រះរតនត្រ័យ ដើរទៅតាមផ្លូវជារឿយៗ ពេលនោះ ពួកចោរក៏បានទៅស្កាត់រង់ចាំ ។ រីឯព្រះមហាវីរៈ ទ្រង់ព្រះតម្រិះដល់ឆត្តមាណពថា កុសល គឺសេចក្តីល្អ ដែលឆត្តមាណពបានធ្វើហើយត្រឹមប៉ុណ្ណោះ ក៏ល្មមអាចធ្វើឲ្យគេទៅកើតក្នុងទេវលោកបាន ហើយព្រះអង្គ ទើបយាងត្រឡប់ទៅប្រថាប់ឯវត្តជេតពន ជិតក្រុងសាវត្ថីវិញ ។

កាលឆត្តមាណពមានចិត្តជ្រះថ្លា តាំងមាំនៅក្នុងគុណព្រះរតនត្រ័យ ដោយគេមានគំនិតកើតឡើងខាងក្នុងចិត្ត កំណត់យកគុណព្រះរតនត្រ័យ

និងតាំងនៅក្នុងសីល ៥ ដោយបានអធិដ្ឋានចិត្តរក្សាសីល ៥ តាមនយ
ដែលព្រះមហាមុនីត្រាស់បង្រៀនគេទុកហើយនោះ ។ ខណៈដែលធត្ត-
មាណពកំពុងតែធ្វើដំណើរទៅនោះ ចិត្តរបស់គេក៏តែងតែរឭកដល់គុណ
ព្រះរតនត្រ័យជានិច្ចនោះ ពួកចោរក៏បានស្ទុះចេញមកប្រសាចពាសពេញផ្លូវ
ដើម្បីនឹងប្រទូសរ៉ាយគេ តែគេមិនបានជាក់ចិត្តចំពោះពួកចោរទាំងនោះ
ឡើយ ទាំងមិនបាននឹកខ្លាចក្រែងរអាទៀតផង ហើយគេបានដើរនឹកដល់
គុណព្រះរតនត្រ័យតែម្យ៉ាងជារឿយៗ ប៉ុណ្ណោះ ។ ពេលនោះ ចោរម្នាក់
ដែលឈរនៅក្នុងគុម្ពោតឈើបានបាញ់ព្រួញលាបដោយថ្នាំពិស មកត្រូវ
ធត្តមាណព ធ្វើឲ្យធត្តមាណពអស់ជីវិតទៅមួយរំពេចក្នុងពេលនោះឯង
ហើយពួកចោរនោះ បាននាំគ្នាកាន់យកកញ្ចប់ប្រាក់របស់ធត្តមាណព
គេចចេញទៅ ព្រមជាមួយពួកចោរ ដែលជាសម្លាញ់ ។ ចំណែកធត្ត-
មាណព ដែលបានស្លាប់ទៅហើយនោះ ក៏បានទៅកើតក្នុងវិមានមាស
កម្ពស់ ៣០ យោជន៍ក្នុងស្ថានតាវត្តិង្ស ដែលប្រៀបដូចជាការដេកលក់
ហើយក្រាក់ឡើងដូច្នោះ ហើយគេបានមានស្រីទេពអប្សរមួយពាន់នាក់

ជាបរិវារ មានរាងកាយតាក់តែងដោយគ្រឿងប្រដាប់មានទម្ងន់ដល់ទៅ ៦០ រនេះ ហើយវិមានរបស់ឆត្តទេវបុត្រនោះ មានរស្មី គឺពន្លឺផ្សាយចេញទៅ រហូតប្រមាណ ២០ យោជន៍ ។ គ្រានោះ ពួកអ្នកស្រុកក្រុងសេតព្យៈបានឃើញឆត្តមាណពនៅដេកស្លាប់ ទើបបាននាំគ្នាទៅប្រាប់ដល់មាតាបិតារបស់ឆត្តមាណពឲ្យបានជ្រាប ។ចំណែកប្រជាជននៅក្នុងក្រុងឧក្កដ្ឋា ក៏បានទៅប្រាប់ដល់អាចារ្យបោក្ខរសាតិព្រាហ្មណ៍ ឲ្យបានជ្រាបថា ឆត្តមាណពបានស្លាប់ទៅហើយ ។ មាតាបិតា និងញាតិមិត្តរបស់ឆត្តមាណព និងអាចារ្យបោក្ខរសាតិព្រាហ្មណ៍ ព្រមដោយបរិវារបាននាំគ្នាស្រែកយំ មានមុខជោកទៅដោយទឹកភ្នែក បាននាំគ្នាទៅកាន់កន្លែងដែលឆត្តមាណពដេកស្លាប់នោះ ។

ប្រជាជនអ្នកមកកាន់កន្លែង ដែលឆត្តមាណពដេកស្លាប់នោះ ចំណែកច្រើន គឺជាអ្នកក្រុងសេតព្យៈ និងអ្នកក្រុងឧក្កដ្ឋា និងអ្នកក្រុងឥច្ឆានង្គលៈ ក៏បានមកប្រមូលប្រជុំគ្នាជាច្រើន ។ ចំណែកមាតាបិតារបស់ឆត្តមាណពបានរៀបចំជើងឋារឡើងក្នុងទីកន្លែងជិតផ្លូវនោះ ដោយតាំង

ចិត្តថា នឹងយកសាកសពកូនប្រុសរបស់ខ្លួនទៅជាក់បូជា ។ គ្រានោះ ព្រះកគវាទ្រង់ព្រះតម្រិះដល់ធត្តមាណពទេវបុត្រឡើងថា កាលតថាគតទៅកន្លែងដែលប្រជាជនប្រជុំគ្នា ចាត់ចែងបូជាសពរបស់ធត្តមាណពនោះ ធត្តមាណពទេវបុត្រក៏នឹងមកថ្វាយបង្គំតថាគត ហើយតថាគតនឹងឲ្យគេជ្រាប់ដល់កម្មណ្ឌដែលគេបានធ្វើទុកឲ្យជាក់ច្បាស់ដល់មហាជនទាំងឡាយ ហើយតថាគតនឹងសម្តែងធម៌ឲ្យដល់មហាជនបានស្តាប់ កាលមហាជនទាំងនោះ បានស្តាប់ធម៌របស់តថាគតហើយ ក៏នឹងបានត្រាស់ដឹង គឺបានសម្រេចមគ្គផលជាច្រើន ដោយវិធីយ៉ាងនេះឯង ។ កាលព្រះសម្ពុទ្ធទ្រង់ត្រិះរិះដូច្នេះហើយ ព្រមដោយភិក្ខុសង្ឃមានចំនួនច្រើន បានយាងទៅកាន់ទីកន្លែងនោះ លុះព្រះអង្គយាងទៅដល់ ទើបប្រថាប់គង់ត្រង់គល់ឈើមួយដើម ហើយទ្រង់បានបញ្ចេញព្រះរស្មី ៦ ប្រការ ចេញអំពីព្រះវរកាយរបស់ព្រះអង្គ ។ គ្រានោះ ធត្តមាណពទេវបុត្របានពិនិត្យមើលសម្បត្តិរបស់ខ្លួន បានគិតសាឡើងវិញដល់ហេតុ ដែលខ្លួនបានទទួលសម្បត្តិនេះ ក៏រឭកដឹងបានថា ខ្លួនបានទទួលសម្បត្តិបែបនេះ ពីព្រោះជាអ្នករាប់អាន

ព្រះរតនត្រ័យ និងសមាទានសីល ៥ គេគិតឃើញដូច្នេះហើយ ទើបមានសេចក្តីជ្រះថ្លាឡើង ចំពោះព្រះភគវា ហើយគេគិតថា យើងនឹងទៅថ្វាយបង្គំព្រះភគវា និងថ្វាយបង្គំភិក្ខុសង្ឃក្នុងកាលឥឡូវនេះ ថែមទាំងប្រកាសគុណព្រះរតនត្រ័យឲ្យប្រាកដដល់មហាជន ហើយឲ្យមហាជនបានដឹងថា ទេវបុត្រនេះជាអ្នកមានកតញ្ញូ កាលគេគិតឃើញដូច្នេះ ទើបចុះមកអំពីស្ថានតាវត្តិង្ស បណ្តាលឲ្យព្រៃក្នុងទីនោះទាំងមូលមានពន្លឺចិញ្ចាចចិញ្ចែង ហើយឆត្តមាណពទេវបុត្រ បានចុះមកព្រមទាំងវិមានតែក្នុងពេលដែលទេវបុត្រចុះមក ជិតដល់ទីប្រថាប់របស់ព្រះទសពល ហើយទើបចុះអំពីវិមាន ចូលទៅថ្វាយបង្គំព្រះភគវា ដោយត្បូងទៀបព្រះយុគលបាទរបស់ព្រះសម្ពុទ្ធ ហើយថយចេញមកឈរប្រណម្យដៃនៅក្នុងទីដ៏សមគួរ ។ គ្រានោះ មហាជនបានឃើញដូច្នោះហើយ ក៏កើតការចម្ងែកក្នុងចិត្ត ដោយឃើញសភាពដ៏អស្ចារ្យទាំងនោះ ទើបគិតថា បុគ្គលនេះជានរណាហ្ន៎ ជាទេវតា ឬថាជាព្រហ្ម នាំគ្នាចូលមកថ្វាយបង្គំព្រះលោកនាថ ។

លំដាប់នោះ ព្រះអង្គ ទ្រង់មានបំណងដើម្បីនឹងសម្តែងនូវបុញ្ញកម្ម របស់ឆត្តមាណពទេវបុត្រ ដែលបានធ្វើទុកមកហើយឲ្យដល់មហាជន ទាំងនោះបានជ្រាប ទើបព្រះអង្គត្រាស់សួរទេវបុត្រនោះថា ព្រះអាទិត្យ ព្រះចន្ទ ឬផ្កាយឫក្សរះក្នុងផ្ទៃមេឃ ក៏មិនភ្លឺស្វាងដូចវិមាននេះ វិមាននេះ មានរស្មីភ្លឺខ្លាំងណាស់ មិនមានទីប្រៀបប្រដូចបាន ចុះអ្នកជានរណា ទើបចុះអំពីស្ថានសួគ៌ជាន់តាវត្តិង្សមកកាន់ផែនដី អ្នកមានរស្មីផ្សាយ ចេញទៅប្រមាណ ២០ យោជន៍ អាចគ្របសង្កត់រស្មី គឺពន្លឺភ្លើរបស់ ព្រះចន្ទ និងព្រះអាទិត្យបាន ហើយធ្វើពេលយប់ឲ្យដូចជាថ្ងៃ វិមានរបស់ អ្នកស្រស់ស្អាតបរិសុទ្ធ ប្រាសចាកមន្ទិល មានផ្ការបទុម និងផ្កាបុណ្ឌរីកស្អាត ដេរដាសដោយផ្កាឈើទាំងឡាយជាច្រើនទៀត ដណ្តប់ដោយ សំណាញ់មាស ដែលប្រាសចាកលម្អងធូលី សំយុងៗ នៅមានពន្លឺភ្លឺស្វាង នៅកណ្តាលនភាកាស ដូចព្រះអាទិត្យ វិមានរបស់អ្នកមានពពួកនាង ទេពអប្សរ ដែលទ្រទ្រង់សំពត់ក្រហម សំពត់លឿង ថែមទាំងក្រអូប ឈ្ងុយឈ្ងប់ដោយកិនក្រស្នា ផ្កាត្រយង់ និងកិនខ្ទឹមចនូន៍ មានរូបភាង

និងពណ៌សម្បុរឆ្អៀលឆ្ងាត់ដូចមាស ដូចផ្ទៃមេឃ ពេញទៅដោយផ្កាយទាំងឡាយ ទេវបុត្រ និងទេពធីតាក្នុងវិមាននេះ មានយ៉ាងសន្ធឹកសន្ធាប់ចម្រុះពណ៌ ជាអ្នកមានចិត្តរីករាយត្រេកអរ មានអាករណៈ គឺគ្រឿងប្រដាប់ដោយផ្កាឈើ មានកម្រងមាស ស្បៀកដណ្តប់ដោយគ្រឿងប្រដាប់ដែលជាមាស ផ្កាឈើត្រូវខ្យល់បក់ផាត់រំភើយៗ ក៏ជះក្លិនក្រអូបឈ្ងុយឈ្ងប់ទៅតាមខ្យល់ នេះជាវិបាក គឺផលនៃការសង្រួមដូចម្តេច ? អ្នកបានកើតក្នុងវិមាននេះ ដោយផលនៃកម្មអ្វី ? ហើយអ្នកបានវិមាននេះដោយវិធីណា ? អ្នកចូរប្រាប់តថាគតតាមសមគួរដល់វិធីនោះផង ចុះ ។

គ្រានោះ ឆត្តមាណពក្រាបទូលតបថា ព្រះមហាវីរៈបានយាងមកជួបឆត្តមាណពលើផ្លូវនេះ ដោយព្រះអង្គឯង កាលព្រះអង្គទ្រង់មានបំណងដើម្បីអនុគ្រោះ បានត្រាស់ប្រៀនប្រដៅឆត្តមាណព ហើយឆត្តមាណពបានស្តាប់ព្រះធម៌របស់ព្រះអង្គ ដែលជារតនៈដ៏ប្រសើរ ហើយទើបក្រាបទូលថា ខ្ញុំព្រះអង្គធ្វើតាមដែលព្រះអង្គបានត្រាស់ប្រៀនប្រដៅថា អ្នកចូរកាប់អានព្រះជិនវរដ៏ប្រសើរ ទាំងព្រះធម៌ និងព្រះសង្ឃ ជាសរណៈ

គឺជាទីពឹង ទីរឭក ។

បពិត្រព្រះអង្គដ៏ចម្រើន អំពីដំបូង ខ្ញុំព្រះអង្គបានក្រាបទូលថា មិនស្គាល់ព្រះត្រៃសរណាគមន៍ និងសីល ៥ តែតមកខាងក្រោយ ខ្ញុំព្រះអង្គបានស្តាប់ព្រះវាចារបស់ព្រះពុទ្ធអង្គហើយ ទើបបានស្គាល់ហើយបានធ្វើតាមព្រះតម្រាស់របស់ព្រះអង្គ ដោយព្រះអង្គទ្រង់បង្រៀនខ្ញុំព្រះអង្គថា កុំសម្លាប់សត្វ កុំលួចទ្រព្យគេ កុំប្រព្រឹត្តខុសក្នុងប្រពន្ធកូនអ្នកដទៃ កុំនិយាយកុហក កុំផឹកទឹកស្រវឹង ។ ព្រោះជាកម្មដែលមិនស្អាត ទាំងអ្នកមានបញ្ញា ក៏មិនសរសើរ ការមិនសង្រួមរវាំងក្នុងកម្មទាំងនេះមិនល្អទេ ។ ខ្ញុំព្រះអង្គបានតាំងចិត្តធ្វើតាម គឺកាន់សិក្ខាបទទាំង ៥ ប្រការនេះ បានបដិបត្តិក្នុងធម៌របស់ព្រះតថាគតហើយ លុះខ្ញុំព្រះអង្គធ្វើដំណើរទៅតាមផ្លូវនោះ ត្រូវចោរសម្លាប់ ប៉ុន្តែខ្ញុំព្រះអង្គបានរឭកដល់តែបុណ្យកុសល ដែលបានរាប់អានព្រះរតនត្រ័យ និងសីល ៥ ប៉ុណ្ណោះ បុណ្យកុសលដទៃក្រៅអំពីនោះ ខ្ញុំព្រះអង្គមិនមាន ខ្ញុំព្រះអង្គបានទៅកើតក្នុងស្ថានតាវត្តឹង្ស ដែលដល់ព្រមដោយវត្ថុដែល

គួរប្រាថ្នាដោយកម្មដ៏សុចរិត គឺការរាប់អានព្រះត្រៃសរណាគមន៍ និង
សីល ៥ នោះ សូមព្រះមហាមុនី ទ្រង់មេត្តាទតផលនៃការសង្រ្គមត្រឹម
មួយជួរខណៈ និងដោយការបដិបត្តិធម៌តាមសមគួរនេះចុះ ដែលជាហេតុ
ធ្វើឲ្យរុងរឿងដោយយស ។ បុគ្គលជាចំនួនច្រើន ដែលមានការប្រព្រឹត្ត
ដ៏លាមក បានឃើញខ្ញុំព្រះអង្គ ដែលរុងរឿងដោយឫទ្ធិ និងដោយ
បរិវារយ៉ាងនេះ រមែងប្រាថ្នាថា សូមឲ្យយើងបានជាដូច្នេះ សូមព្រះមុនី
មេត្តាទតចុះ ខ្ញុំព្រះអង្គបានទៅកើតក្នុងទីល្អ មានសេចក្តីសុខសប្បាយ
ព្រោះផលនៃការស្តាប់ព្រះធម៌របស់ព្រះអង្គ ត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ ។

ចំណែកបុគ្គលពួកណា ដែលបានស្តាប់ធម៌របស់ព្រះមានជោគ
ជាប់តគ្នាជានិច្ច ជនពួកនោះ នឹងបានសម្ផស្សនៃព្រះនិព្វាន ដែលជាដែន
ក្សេម មែនពិត ។ កម្មល្អដែលធ្វើទុកត្រឹមតែបន្តិចបន្តួច ក៏មានផលធំ
ដ៏បរិបូណ៌ ព្រោះធម៌របស់ព្រះតថាគតពិតៗ សូមមើលឥត្តមាណព
ដែលបានធ្វើបុណ្យទុកមកហើយ ទើបបញ្ចេញវាស្មី គឺពន្លឺទៅ រហូត
ប្រើថពីដូចជាព្រះអាទិត្យ ។ បុគ្គលពួកខ្លះប្រជុំគ្នាហើយប្រឹក្សាថា កុសល

ដូចម្តេច ពួកយើងនឹងប្រព្រឹត្តកុសលអ្វី ពពួកអ្នកដែលបានកើតជាមនុស្ស
ហើយ គប្បីបដិបត្តិមនុស្សធម៌ មានការរក្សាសីល ។ ព្រះលោកនាថ
ទ្រង់មានឧបការៈច្រើន ទ្រង់អនុគ្រោះដល់យើងដោយព្រះមហាករុណា
ខ្ញុំព្រះអង្គរឭកបានយ៉ាងនេះ កាលខ្ញុំព្រះអង្គត្រូវចោរសម្ងាប់ ដើម្បី
ដណ្តើមយកទ្រព្យនោះ ខ្ញុំព្រះអង្គជាអ្នករាប់អានព្រះភគវា នេះជាសច្ចៈ
សូមព្រះអង្គមេត្តាអនុគ្រោះខ្ញុំព្រះអង្គបានស្តាប់ព្រះធម៌ទៀត ព្រះអង្គ
ខ្ញុំព្រះអង្គទាំងឡាយ នឹងតាំងចិត្តស្តាប់ដោយគោរព ។

គ្រានោះ ព្រះភគវាទ្រង់សម្តែងព្រះធម៌ឲ្យស្តាប់ថា ជនពួកណា
ក្នុងសាសនានេះ លះកាមរាគៈ លះអនុសយ គឺកវរាគៈ និងលះមោហៈ
បានដោយសមុច្ឆេទហើយ ជនទាំងនោះមិនបានកើតទៀត ព្រោះដល់
នូវព្រះនិព្វាន ជាអ្នកមានភាពត្រជាក់ត្រជុំនៅជានិច្ចហើយ ។ឆត្តមាណព
ទេវបុត្រជាអ្នកតាំងនៅក្នុងភាពជាអ្នកមាននូវកតញ្ញូតាធម៌ជាអ្នកមិនឆ្អែត
ដោយសេចក្តីល្អ បានចូលទៅជិតព្រះជិនស្រីដើម្បីស្តាប់ព្រះធម៌ ថែមទាំង
បានពោលពាក្យជាច្រើនទៀត ដោយអំណាចសេចក្តីជ្រះថ្លា ដូចដែល

បានពោលរួចមកហើយនោះ ។

គ្រានោះ ព្រះមុនីទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់ទេវបុត្រ និងបរិស័ទដែលមកប្រជុំគ្នាក្នុងទីនោះហើយ ទើបព្រះអង្គទ្រង់សម្តែងអនុបុព្វីកថា ហើយទ្រង់ជ្រាបថា ជនទាំងនោះមានចិត្តទន់ ទើបទ្រង់ប្រកាស **សម្មុក្កង្សិកធម្ម** (ព្រះធម៌ទេសនាដែលព្រះសម្ពុទ្ធ ទ្រង់លើកឡើងសម្តែងខ្លួនឯង គឺមិនចាំបាច់ប្រារព្ធពាក្យសួររបស់អ្នកស្តាប់) ដែលសំដៅដល់ទ្រង់សម្តែងអរិយសច្ចធម៌ទាំង ៤ ។ កាលព្រះកគវា ទ្រង់សម្តែងព្រះធម៌ទេសនានេះចប់ ទេវបុត្រ មាតា និងបិតារបស់ឆត្តមាណពទេវបុត្រ ក៏បានតាំងនៅក្នុងសោតាបត្តិផល ថែមទាំងមានមហាជនជាច្រើន ក៏បានធ្វើឲ្យជាក់ច្បាស់នូវធម៌ដែរ ។ គ្រានោះ ឆត្តទេវបុត្របានតាំងនៅក្នុងព្រះអរិយបុគ្គលថ្នាក់ដំបូង ទើបបានពោលត្រួតសេចក្តីក្នុងព្រះគាថានោះថា

ជនពួកណា តាំងនៅក្នុងព្រះសាសនានេះ រមែងលះ គឺរមែងជកកាមរាគៈបានជាច់ខាត ដោយឥតមានសេសសល់ ជនទាំងនោះ រមែងមិនត្រូវដេកនៅក្នុងកគិតទៅទៀត ព្រោះដកឱរម្ភាគិយសំយោជនៈ គឺ

សំយោជនៈខាងក្រោមបានហើយ ។ ម្យ៉ាងទៀត ជនពួកណា លះមោហៈ គឺជកបានដោយប្រការទាំងពួង ឈ្មោះថាលះអនុសយ គឺកវាគៈបានដែរ ជនទាំងនោះ រមែងមិនចាំបាច់ដេកនៅក្នុងគភ៌ទៀត ព្រោះហេតុអ្វី ព្រោះដល់នូវព្រះនិព្វាន ជាអ្នកមានសេចក្តីត្រជាក់នៅជានិច្ចហើយ ។ សេចក្តីពិត ជនទាំងនោះ ជាឧត្តមបុរស ជាអ្នកដល់នូវព្រះនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ទើបជាអ្នកមានភាពត្រជាក់នៅជាសុខនិរន្តរ៍ ព្រោះថា ភាពក្តៅក្រហាយគ្រប់យ៉ាង ដែលសព្វសត្វបានទទួល ក៏បានអស់ទៅក្នុងព្រះនិព្វាននោះ នុ៎ះឯង ។

គ្រានោះ ឆត្តទេវបុត្រកាលបានប្រកាសនូវភាព ដែលខ្លួនបានសម្រេចជាព្រះអរិយបុគ្គលហើយ ទើបកាន់យកកំពូលនៃទេសនា គឺ អនុបាទិសេសនិព្វានធាតុ ថ្វាយបង្គំលាព្រះភគវា ធ្វើប្រទក្សិណហើយ បានសម្តែងនូវការគោរពរាប់អានព្រះសង្ឃ លាមាតាបិតា ហើយត្រឡប់ទៅកាន់ទេវលោកដូចដើមវិញ ។ ពេលនោះ ព្រះពុទ្ធអង្គ ទ្រង់ក៏ក្រោកអំពីទីប្រថាប់ ហើយយាងទៅព្រមជាមួយភិក្ខុសង្ឃ ។ មាតាបិតារបស់

ឆត្តមាណព និងអាចារ្យបោក្ខរសាតិព្រាហ្មណ៍ និងមហាជន ទាំងអស់ក៏បាននាំគ្នាជូនដំណើរព្រះសយម្ភូ ហើយម្នាក់ៗ ក៏ត្រឡប់ទៅកាន់ទីលំនៅរៀងៗខ្លួនវិញ ។ព្រះមានជោគយាងត្រឡប់ទៅដល់វត្តជេតពនហើយ បានគ្រាស់រឿងវិមាននោះដោយពិស្តារឲ្យពុទ្ធបរិស័ទ ដែលមកប្រជុំគ្នាស្តាប់ហើយ ផលប្រាកដជាព្រះពុទ្ធសាសនានេះ មានប្រយោជន៍ដល់មហាជនច្រើនណាស់ ៕

(ជីវប្រវត្តិរបស់ឆត្តមាណពឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ទីឃនខឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

ទីឃនខអគ្គិវេស្សនៈ ជាឧបាសកម្នាក់ ជាក្មួយប្រុសរបស់ព្រះសារីបុត្រ គេបានបួសជាបរិព្វាជកមុន ហើយពេលដែលគេចូលទៅគាល់ព្រះមានជោគ គេបាននាំយកទិដ្ឋិ គឺការយល់ឃើញដែលជាគតិដែលខ្លួនប្រកាន់ មកក្រាបទូលសួរព្រះសាស្តា ដូចជាការសាកល្បងភូមិនៃបញ្ញា ហើយក៏មានការជឿក្នុងព្រះបញ្ញារបស់ព្រះបរមគ្រូ ។

*ជីវប្រវត្តិរបស់ទីឃនខអគ្គិវេស្សនៈ ក៏មានសម្តែងប្រាកដក្នុង **អដ្ឋកថាបបញ្ចសូទនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីក្នុង **ទីឃនខសូត្រ** នៅក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក:** ថា ៖*

ទីឃនខបរិព្វាជក (បរិព្វាជកដែលមានក្រចកវែង) កាលព្រះសារីបុត្របួសហើយបានកន្លះខែ ទើបគេគិតថា លោកអ៊ំសារីបុត្ររបស់យើង ទៅចូលលទ្ធិដទៃដែលខុស ហើយបដិបត្តិតាមអស់កាល

ដ៏ឃូរ តែឥឡូវនេះ លោកអ៊ីបានទៅគាល់ព្រះសមណគោតមបានកន្លះខែហើយ ទើបគេមានបំណងនឹងទៅគាល់ព្រះសាស្តា ដោយសង្ឃឹមថា យើងនឹងស្តាប់ដំណឹងរបស់លោកអ៊ំ ដើម្បីនឹងបានជីងពាក្យប្រៀនប្រដៅដ៏រុងរឿងនោះខ្លះ ។ ព្រោះដូច្នោះ ទើបទីឃនខបរិព្វាជក ចូលទៅគាល់ព្រះលោកនាយក ក្នុងគុហាសូករខាតា ។ គុហាសូករខាតា ប្រែថា គុហាជ្រូកឈ្មុស នៅហ្នឹងភ្នំមួយកន្លែងក្បែរផ្លូវឡើងទៅលើកំពូលភ្នំគិជ្ឈកូដ ។ មានរឿងពោលទុកថា កាលសាសនារបស់ព្រះកស្សបសម្មុទ្ធគុហានោះ កើតខាងក្រោមផែនដីដែលជុះឡើងក្នុងមួយពុទ្ធន្តរ ។ តមកថ្ងៃមួយ មានជ្រូកមួយក្បាល បានមកឈ្មុសដីក្នុងទីជិតញកភ្នំនោះ កាលមានភ្លៀងធ្លាក់មក ក៏បានប្រាកដជូចជាជំបូលញកភ្នំនោះ ។ មានព្រានព្រៃម្នាក់បានឃើញជូច្នោះហើយ ទើបគេគិតថា ពីមុនគង់មិនមានអ្នកមានសីលមកនៅក្នុងគុហានេះ យើងនឹងធ្វើគុហានេះ ឲ្យជាទីស្នាក់អាស្រ័យបានហើយព្រានព្រៃនោះ ទើបបានជញ្ជួនដីចេញចោសសម្អាតគុហាឲ្យស្អាត ហើយធ្វើជញ្ជាំងជុំវិញ ធ្វើទ្វារបង្អួច ធ្វើគុហាឲ្យមានបរិវេណឲ្យស្អាត

ហើយជញ្ជូនដីឡប់ចាក់មកក្រោលក្នុងគុហានោះ មើលទៅដូចជាកម្រាលប្រាក់ធ្វើយ៉ាងវិចិត្រ លាបកំបោរសរៀបរយល្អហើយ បានរៀបចំគ្រែ និងតាំងហើយបានថ្វាយជាទីប្រថាប់ដល់ព្រះមានព្រះភាគ ។ គុហាសូករខាតាជាគុហាជ្រៅ តែល្មមឡើង និងចុះបានស្រួល ។ពេលដែលទីឃនខ-បរិព្វាជក ចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ ។ គ្រានោះ ព្រះសារីបុត្រ បានគង់បក់ផ្ទិតថ្វាយដល់ព្រះលោកនាថ ។ ទីឃនខបរិព្វាជក មានការ ខ្មាសអៀន និងកោតក្រែង ចំពោះលោកអ៊ំសារីបុត្រ ទើបឈរទូលសួរ បញ្ហានឹងព្រះវិជិតមារ ។

មានរឿងរបស់ទីឃនខបរិព្វាជក ចូលទៅគាល់ទូលសួរបញ្ហា ចំពោះព្រះលោកនាថនោះ មានសម្តែងនៅក្នុងព្រះបាលី **ទីឃនខសូត្រ** នៅក្នុង **មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក:** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមហាវីរៈ ប្រថាប់នៅត្រង់គុហាសូករខាតាភ្នំ គិជ្ឈកូដ នៅក្នុងក្រុងរាជគ្រឹះ ។ គ្រានោះ ទីឃនខបរិព្វាជកចូលទៅគាល់ ព្រះមហាមុនីដល់ទីប្រថាប់ បានជ្រាស្រ័យជាមួយព្រះមហាវីរៈ លុំមឲ្យ

ជាទីរឭកដល់គ្នានិងគ្នាហើយ បានឈរនៅក្នុងទីដ៏សមគួរម្ខាង ហើយទើបទូលសួរថា បពិត្រព្រះគោតម ការពិតខ្ញុំព្រះអង្គ មានប្រក្រតីពោលថា វត្ថុទាំងពួងមិនគួរដល់យើង ។ គ្រានោះ ព្រះភគវាត្រាស់ថា ម្នាលអគ្គិវេស្សន: សូម្បីការឃើញរបស់អ្នកថា វត្ថុទាំងពួងមិនគួរដល់យើងនោះ ក៏មិនគួរដល់អ្នក ។ ទីឃនខបរិព្វាជកបានទូលថា បពិត្រព្រះគោតម បើការឃើញនេះគួរដល់ខ្ញុំព្រះអង្គ សូម្បីការឃើញនោះ ក៏គប្បីជាដូច្នោះៗ ។ ពេលនោះ ព្រះភគវាត្រាស់ថា ម្នាលអគ្គិវេស្សន: ជនក្នុងលោកដែលពោលយ៉ាងនេះថា សូម្បីការឃើញនោះ ក៏គប្បីដូចនោះៗ ដូច្នេះ ជនទាំងនោះ លះការឃើញនោះមិនបាន ទាំងនៅប្រកាន់ទិដ្ឋិដទៃៗ ទៀតជាច្រើន គឺច្រើនជាងបុគ្គលដែលលះបាន ។ ម្នាលអគ្គិវេស្សន: ជនក្នុងលោកដែលពោលយ៉ាងនេះថា សូម្បីការឃើញនោះ ក៏គប្បីជាយ៉ាងដូច្នោះ ជនទាំងនោះៗ ដូច្នេះ ជនទាំងនោះលះទិដ្ឋិនោះបាន ទាំងមិនប្រកាន់ការឃើញដទៃទៀតនោះមានតិច គឺមានតិចជាងបុគ្គលដែលនៅលះមិនបាន ។ គ្រានោះ ព្រះមានជោគ បានត្រាស់ដល់ទិដ្ឋិ

ដែលជាហេតុឲ្យកើតវិវាទគ្នាថា ម្នាលអគ្គិវេស្សនៈ សមណព្រាហ្មណ៍ពួកខ្លះរមែងពោលយ៉ាងនេះ និងរមែងឃើញយ៉ាងនេះថា វត្ថុទាំងពួងគួរដល់យើង ។ សមណព្រាហ្មណ៍ពួកខ្លះ រមែងពោលយ៉ាងនេះ និងរមែងឃើញយ៉ាងនេះថា វត្ថុទាំងពួង មិនគួរដល់យើង ។ សមណព្រាហ្មណ៍ពួកខ្លះ រមែងពោលយ៉ាងនេះ និងរមែងឃើញយ៉ាងនេះ វត្ថុខ្លះគួរដល់យើង វត្ថុខ្លះមិនគួរដល់យើង ដូច្នេះក៏មាន ។ ម្នាលអគ្គិវេស្សនៈ បណ្តាការយល់ឃើញនោះ ការឃើញរបស់សមណព្រាហ្មណ៍ ពួកដែលរមែងពោល និងរមែងឃើញថា វត្ថុទាំងពួងគួរដល់យើងនោះ ជិតខាងកិលេស ដែលប្រព្រឹត្តទៅដោយសេចក្តីតម្រេកត្រេកអរ ជិតខាងកិលេសដែលចង្អុលបង្ហើតសត្វលោកទុក ជិតខាងកិលេសដែលជាហេតុឲ្យក្តៅក្តៃជិតខាងកិលេស ជាហេតុធ្វើឲ្យការប្រកៀកប្រកាន់ទុក ជិតខាងកិលេសជាហេតុធ្វើឲ្យមានការប្រកាន់មាំទៅបាន ។

ម្នាលអគ្គិវេស្សនៈ ការឃើញរបស់សមណព្រាហ្មណ៍ ដែលពោលនិងឃើញថា វត្ថុទាំងពួងមិនគួរដល់យើងនោះ ជិតខាងធម៌ មិនប្រព្រឹត្តទៅ

ជាមួយសេចក្តីតម្រេកត្រេកអរ ជិតខាងធម៌ មិនជាគ្រឿងចងរួបរឹតសត្វទុក ជិតខាងធម៌ មិនជាហេតុធ្វើឲ្យក្តៅក្តៃ ជិតខាងធម៌ មិនជាហេតុធ្វើឲ្យមានការប្រកៀកប្រកាន់ ជិតខាងធម៌ មិនជាហេតុធ្វើឲ្យមានការប្រកាន់មាំ ។ កាលព្រះជិនស្រីត្រាស់យ៉ាងនេះហើយ ទីឃនខបរិព្វាជកទើបក្រាបទូលព្រះវិជិតមារថា បពិត្រព្រះគោតម ទ្រង់សរសើរការយល់ឃើញរបស់ខ្ញុំព្រះអង្គ ។ ពេលនោះ ព្រះលោកនាយកត្រាស់តទៅថា ម្នាលអគ្គិវេស្សនៈ ក្នុងការឃើញផ្សេងៗ នោះ ការឃើញរបស់សមណព្រាហ្មណ៍ពួកដែលតែងតែពោល និងតែងតែឃើញថា វត្ថុខ្លះគួរជល់យើង វត្ថុខ្លះមិនគួរជល់យើងនោះ ។ ចំណែកដែលឃើញថាគួរជិតខាងកិលេស ដែលប្រព្រឹត្តទៅ ដោយសេចក្តីតម្រេកត្រេកអរជិតខាងកិលេសជាគ្រឿងចងចិត្តសត្វលោកទុកជិតខាងកិលេសជាហេតុធ្វើឲ្យក្តៅក្តៃ ជិតខាងកិលេស ជាហេតុធ្វើឲ្យមានការប្រកៀកប្រកាន់ ជិតខាងកិលេស ជាហេតុធ្វើឲ្យប្រកាន់មាំ ។ ចំណែកដែលឃើញថាមិនគួរ ជិតខាងធម៌ មិនប្រព្រឹត្តទៅជាមួយដោយសេចក្តីតម្រេកត្រេកអរ

ជិតខាងធម៌ មិនជាគ្រឿងចង់ចិត្តសត្វលោកទុក ជិតខាងធម៌ មិនជាហេតុធ្វើឲ្យក្តៅក្តៃ ជិតខាងធម៌ មិនជាហេតុធ្វើឲ្យមានការប្រកៀកប្រកាន់ ជិតខាងធម៌ មិនជាហេតុធ្វើឲ្យមានការប្រកាន់មាំ ។

ម្នាលអគ្គិវេស្សនៈ ទិដ្ឋិ គឺការយើញរបស់សមណព្រាហ្មណ៍ដែលតែងតែពោល និងតែងតែយើញថា វត្ថុទាំងពួងគួរដល់យើងនោះ វិញ្ញូជនទាំងឡាយ រមែងយើញច្បាស់ថា យើងនឹងប្រកាន់មាំនូវទិដ្ឋិ គឺការយើញរបស់យើងថា វត្ថុទាំងពួងគួរដល់យើង ហើយបញ្ជាក់ដោយអះអាងថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃមិនពិត យើងក៏គប្បីប្រកាន់ខុសអំពីសមណព្រាហ្មណ៍ពីរពួកនេះ គឺ ១- សមណព្រាហ្មណ៍ដែលតែងតែពោល និងតែងតែយើញថា វត្ថុទាំងពួងមិនគួរដល់យើង ២- សមណ-ព្រាហ្មណ៍ដែលតែងតែពោល និងតែងតែយើញថា វត្ថុខ្លះគួរដល់យើង វត្ថុខ្លះមិនគួរដល់យើង ។ កាលការប្រកាសខុសគ្នាមាន ដូច្នេះ ការឈ្លោះទាស់ទែងគ្នាក៏មានឡើង កាលមានការឈ្លោះប្រកែកគ្នា ការជណ្តើមគ្នាក៏មានឡើង កាលមានការជណ្តើមគ្នា ការបៀតបៀនគ្នា

ក៏មានឡើងវិញ្ញូជនពិចារណាឃើញការប្រកាន់ខុសគ្នា ការឈ្លោះគ្នា ការប្រជែងគ្នា និងការបៀតបៀនគ្នា ក្នុងខ្លួនដូច្នេះ ទើបលះទិដ្ឋិនោះ ហើយមិនប្រកាន់ទិដ្ឋិដទៃទៀត ការលះ គឺលះបង់ទិដ្ឋិ គឺការយល់ឃើញទាំងនោះ រមែងមានបានដោយប្រការដូច្នេះ ។

ម្នាលអគ្គិវេស្សនៈ ទិដ្ឋិ គឺការឃើញរបស់សមណព្រាហ្មណ៍ដែលតែងតែពោល និងតែងតែឃើញថា វត្ថុទាំងពួងមិនគួរជល់យើងនោះ វិញ្ញូជនតាមកំណត់ដឹងថា យើងនឹងប្រកាន់មាំ ប្រកាន់មាំនូវទិដ្ឋិ គឺការឃើញរបស់យើងថា វត្ថុទាំងពួងមិនគួរជល់យើង ហើយបញ្ជាក់ដោយអះអាងថា វត្ថុនោះប៉ុណ្ណោះពិត វត្ថុដទៃមិនពិត យើងក៏គប្បីប្រកាន់ខុសអំពីសមណព្រាហ្មណ៍ពីរពួកនេះ គឺ ១-សមណព្រាហ្មណ៍ដែលតែងតែពោល និងតែងតែឃើញថា វត្ថុទាំងពួងគួរជល់យើង ២-សមណព្រាហ្មណ៍ដែលតែងតែពោល និងតែងតែឃើញថា វត្ថុខ្លះគួរជល់យើង វត្ថុខ្លះមិនគួរជល់យើង ។ កាលការប្រកាន់ខុសមាន ដូច្នេះ ការទាស់ទែងគ្នាក៏កើតមានឡើង កាលមានការទាស់ទែងគ្នា ការប្រណាំងប្រជែងគ្នា

ក៏មានឡើង កាលមានការប្រណាំងប្រជែងគ្នា ការបៀតបៀនគ្នាក៏មានឡើង វិញ្ញូជនពិចារណាឃើញការប្រកាន់ខុស ការទាស់ទែងគ្នា ការប្រណាំងប្រជែងគ្នា ការបៀតបៀនគ្នាក្នុងខ្លួន ដូច្នេះ ទើបលះទិដ្ឋិនោះ មិនបានប្រកាន់មាំទិដ្ឋិដទៃទៀត ការលះ ការលះបង់ទិដ្ឋិ គឺការឃើញទាំងនោះ រមែងមានបានដោយប្រការដូច្នេះ ។

ម្នាលអគ្គិវេស្សនៈ ទិដ្ឋិ គឺការឃើញរបស់សមណព្រាហ្មណ៍បុគ្គលដែលតែងតែពោល និងតែងតែឃើញថា វត្ថុខ្លះគួរដល់យើង វត្ថុខ្លះមិនគួរដល់យើងនោះ ហើយបញ្ជាក់ដោយអះអាងថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃមិនពិត យើងក៏គប្បីប្រកាន់ខុសអំពីសមព្រាហ្មណ៍ទាំងពីរពួកនេះ គឺ ១- សមណព្រាហ្មណ៍ដែលតែងតែពោល និងតែងតែឃើញថា វត្ថុទាំងពួងគួរដល់យើង ២- សមណព្រាហ្មណ៍ដែលតែងតែពោល និងតែងតែឃើញថា វត្ថុទាំងពួងមិនគួរដល់យើង ។ កាលការប្រកាន់ខុសគ្នានៅមានដូច្នេះ ការទាស់ទែងគ្នាក៏មានឡើង កាលមានការទាស់ទែងគ្នា ការប្រណាំងប្រជែងគ្នាក៏មានឡើង កាលមានការ

ប្រណាំងប្រជែងគ្នា ការបៀតបៀនគ្នាក៏មានឡើង វិញ្ញូជននោះពិចារណាឃើញការប្រកាន់ខុសគ្នា ការទាស់ទែងគ្នា ការប្រណាំងប្រជែងគ្នា និងការបៀតបៀនគ្នាក្នុងខ្លួន ដូច្នេះ ទើបលះទិដ្ឋិនោះ និងមិនប្រកាន់ទិដ្ឋិដទៃទៀត ការលះ ការលះបង់ទិដ្ឋិ គឺការឃើញទាំងនោះ រមែងមានបានដោយប្រការដូច្នេះ ។ ម្នាលអគ្គិវេស្សនៈ រាងកាយដែលមានរូបប្រាកដឡើង ប្រកបដោយមហាភូតរូបទាំង ៤ កើតមកអំពីមាតាបិតា ធំចម្រើនឡើងដោយបាយ និងនំត្រូវគេគក់ច្របាច់ និងជូសខាត់មន្ទិលជានិច្ច មានការបែកធ្លាយខ្ចាត់ខ្ចាយជាធម្មតា អ្នកគួរពិចារណាឲ្យឃើញថា រាងកាយនេះជារបស់មិនទៀង ជាទុក្ខ ជារោគ ដូចជាបូស ដូចជាកូនសរ ដូចជាពេជ្ឈឃាត ជារបស់ទ្រុឌ្រោមពុកផុយ ជារបស់ទទេ ជារបស់មិនមែនជាតួខ្លួន ។ កាលពិចារណាឃើញយ៉ាងនេះ អ្នករមែងលះបង់សេចក្តីពេញចិត្តក្នុងកាយ លះបង់សេចក្តីស្រឡាញ់ក្នុងកាយបាន លះបង់សេចក្តីត្រេកអរក្នុងកាយបាន ។

ព្រះមានព្រះភាគ ទ្រង់បង្រៀនអគ្គិវេស្សនៈ អំពីរឿងវេទនា

គឺការសោយអារម្មណ៍ ៣ យ៉ាងថា ម្នាលអគ្គិវេស្សនៈ វេទនា គឺការសោយអារម្មណ៍ មាន ៣ យ៉ាងគឺ ១- សុខវេទនា ២- ទុក្ខវេទនា ៣- អទុក្ខមសុខវេទនា ។ ម្នាលអគ្គិវេស្សនៈ ក្នុងកាលណាមានសុខវេទនា ក្នុងគ្រានោះក៏មិនមានទុក្ខវេទនា មិនមានអទុក្ខមសុខវេទនា មានតែសុខវេទនាប៉ុណ្ណោះ ។ ក្នុងគ្រាណាមានទុក្ខវេទនា ក្នុងគ្រានោះ ក៏មិនមានសុខវេទនា មិនមានអទុក្ខមសុខវេទនា មានតែទុក្ខវេទនាប៉ុណ្ណោះ ។ ក្នុងគ្រាណាមានអទុក្ខមសុខវេទនា ក្នុងគ្រានោះ ក៏មិនមានសុខវេទនា មិនមានទុក្ខវេទនា មានតែអទុក្ខមសុខវេទនាប៉ុណ្ណោះ ។ ម្នាលអគ្គិវេស្សនៈ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ទាំងបីយ៉ាងនេះ សុទ្ធតែជារបស់មិនទៀង មានហេតុ-បច្ច័យតាក់តែងឡើង កើតឡើងព្រោះអាស្រ័យបច្ច័យ មានការអស់ទៅសូន្យទៅ និងមានការរលត់ទៅជាធម្មតា ។ កាលព្រះអរិយសាវ័កដែលបានស្តាប់ ហើយបានសម្លឹងឃើញយ៉ាងនេះ រមែងនឿយណាយ ទាំងសុខវេទនា ទុក្ខវេទនា និងទាំងអទុក្ខមសុខវេទនា កាលនឿយណាយ ក៏រមែងប្រាសចាកតម្រេក កាល

ប្រាសចាកតម្រេក ក៏រមែងរួចផុត កាលរួចផុតហើយ ក៏មានញាណជីងថា រួចផុតហើយ ជីងថា អស់ការកើតហើយ ចប់ព្រហ្មចរិយៈហើយ បានធ្វើកិច្ចដែលគួរធ្វើស្រេចហើយ មិនមានកិច្ចដទៃ ដែលត្រូវធ្វើដើម្បីភាពយ៉ាងនេះទៀត ។

ម្នាលអគ្គិវេស្សនៈ ភិក្ខុដែលមានចិត្តរួចផុតបានហើយយ៉ាងនេះ រមែងមិនទាស់ទែង និងប្រណាំងប្រជែងជាមួយនរណាៗ ពាក្យណាដែលសត្វលោកនិយាយគ្នា ក៏និយាយទៅតាមពាក្យនោះ តែមិនប្រកាន់មាំពាក្យនោះដោយទិដ្ឋិ គឺការយល់ឃើញ ។ ក្នុងគ្រានោះ ព្រះសារីបុត្រដែលកំពុងអង្គុយបក់ផ្ទិត នៅខាងក្រោយព្រះសម្មាសម្ពុទ្ធ បានគិតថា ព្រះលោកនាថ ត្រាស់ការលះធម៌ទាំងនោះ ការលះបង់ធម៌ទាំងនោះ ដោយបញ្ញាដ៏ក្រៃលែងដល់ឃើងទាំងឡាយ កាលលោកពិចារណាយ៉ាងនេះ ចិត្តរបស់លោកក៏រួចផុតអំពីអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ចំណែកទីឃនខបរិព្វាជកបានធម្មចក្ខុ (ជាព្រះសោតាបន្ន) ដែលប្រាសចាកធូលី បានពោលថា វត្ថុណានីមួយ មានការកើតឡើង

ជាធម្មតា វត្ថុទាំងនោះ សុទ្ធតែមានការរលត់ទៅវិញ ជាធម្មតា ។ កាលទីយនទបរិព្វាជកបានឃើញធម៌ហើយ បានដល់នូវធម៌ បានដឹងច្បាស់នូវធម៌ បានឈោងចុះកាន់ធម៌ និងឆ្លងសេចក្តីសង្ស័យបានហើយ មិនមានសេចក្តីសង្ស័យ ដល់នូវភាពជាអ្នកក្លៀវក្លា មិនចាំបាច់ជឿអ្នកដទៃក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ហើយបានក្រាបទូលឡើងថា បពិត្រព្រះគោតមដ៏ចម្រើន ការដែលទ្រង់សម្តែងធម៌របស់ព្រះអង្គជាក់ច្បាស់ល្អក្រៃលែងណាស់ ប្រៀបដូចបុគ្គលផ្ងារបស់ដែលផ្កាប់ បើករបស់ដែលបិទចេញ ប្រាប់ផ្លូវដល់មនុស្សដែលវង្វេងផ្លូវ ឬទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា អ្នកមានភ្នែកក្តី ចូរមើលវត្ថុផ្សេងៗបានយ៉ាងណា ព្រះសមណគោតមសម្ពុទ្ធ ទ្រង់បានប្រកាសធម៌ ដោយអនេកបរិយាយយ៉ាងនោះក៏ដូចគ្នា ។ ខ្ញុំព្រះអង្គ សូមរាប់អានព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាសរណៈ គឺជាទីពឹង ទីរឭក សូមព្រះមហាវីរៈចាំនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដែលជាអ្នករាប់អានព្រះរតនត្រ័យ តាំងអំពីថ្ងៃនេះជាដើមទៅ រហូតដល់អស់ជីវិត ព្រះអង្គ ។

មានអត្ថន័យវគ្គខ្លះ ដែលពោលដល់ការសម្រេចមគ្គផលរបស់ព្រះសារីបុត្រ ទីឃនខបរិព្វាជកនិងរឿងថ្ងៃចតុរង្គសន្និបាត ដែលមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបបញ្ចសូទនី** ដូចមានសេចក្តីថា ៖

ព្រះសារីបុត្របួសមកហើយបានកន្លះខែ បានបញ្ជូនបញ្ជាទៅតាមក្រសែព្រះធម្មទេសនា ដែលព្រះមហាមុនីទ្រង់សម្តែង ដោយទ្រង់ប្រោរព្ធទីឃនខបរិព្វាជក ជាក្មួយប្រុសរបស់លោកៗ ក៏បានសម្រេចព្រះអរហត្ត ចាក់ផ្លុះរហូតដល់ទីបំផុតនៃសាវ័កបារមីញ្ញាណ ។ ចំណែកទីឃនខបរិព្វាជកក៏បានសម្រេចសោតាបត្តិផល ហើយក៏ជាអ្នករាប់អានមាំទាំនៅក្នុងព្រះរតនត្រ័យ ។ ក្នុងពេលដែលព្រះមហាវីរបុរស ទ្រង់សម្តែងទេសនាចប់ ជាពេលដែលព្រះអាទិត្យកំពុងប្រាកដនៅឡើយ ហើយព្រះអង្គយាងចុះអំពីភ្នំគិជ្ឈកូដ យាងទៅឯវត្តវេឡុវនមហាវិហារ ទ្រង់បានប្រជុំភិក្ខុសង្ឃ ដោយធ្វើសន្និបាតប្រកបដោយអង្គ ៤ ដែលហៅថា **ចតុរង្គសន្និបាត** ឬថ្ងៃមាឃបូជា ។ ថ្ងៃធ្វើចតុរង្គសន្និបាត គឺការប្រជុំប្រកបដោយអង្គ ៤ នោះ បានដល់ ១- ថ្ងៃនោះជាថ្ងៃឧបោសថ ១៥ កើត

ត្រូវនឹងថ្ងៃមាឃបូជា ២- ភិក្ខុ ១២៥០ អង្គ ដែលមកប្រជុំគ្នាក្នុងគ្រានោះ គឺនិមន្តមកដោយខ្លួនឯង ដោយមិនបានណាត់គ្នាទុកជាមុនទេ ៣- ភិក្ខុទាំងនោះ សុទ្ធតែជាព្រះអរហន្ត ជាអ្នកបានសម្រេចអភិញ្ញា ៦ មិនមានសូម្បីត្រឹមតែមួយអង្គដែលជាបុថុជ្ជន ឬព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ឬព្រះអរហន្តសុក្ខវិបស្សកៈឡើយ ៤- ភិក្ខុទាំងអស់អង្គនោះ សុទ្ធតែជាអ្នកបួសដោយឯហិភិក្ខុឧបសម្បទា ។ ទាំងនេះសម្តែងឲ្យឃើញថា ព្រះសារីបុត្រ បានសម្រេចព្រះអរហត្តផល ជាព្រះអរហន្តនាថ្ងៃ ១៥ កើតខែមាឃ ហើយថ្ងៃសម្រេចនោះ ព្រះសាស្តាបានប្រជុំភិក្ខុសង្ឃសាវ័ក ដែលជាការប្រជុំប្រកបដោយអង្គ ៤ ដែលហៅថ្ងៃនោះថា ជាថ្ងៃធ្វើនូវចតុរង្គសន្និបាត ឬថ្ងៃមាឃបូជា ហើយព្រះមានជោគ ទ្រង់សម្តែងនូវឱវាទប្បាតិមោក្ខសំដៅដល់ពាក្យប្រៀនប្រដៅដ៏សំខាន់នៅក្នុងព្រះពុទ្ធសាសនានេះ ឬជាពាក្យប្រៀនប្រដៅដែលជាបេះដូងរបស់ព្រះពុទ្ធសាសនានេះដែរ ។

(ជីវប្រវត្តិរបស់ទីឃនខបរិព្វាជកឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ទោណព្រាហ្មណ៍ឧបាសក ✍

“ ជាឧបាសកមួយរូបដំឡើងនៅក្នុងព្រះពុទ្ធសាសនានេះ ”

ទោណព្រាហ្មណ៍ ជាឧបាសកដែលបានសម្រេចមគ្គផលលំដាប់ទី ៣ ជាអ្នកមានចំណេះចេះដឹង និងមានសមត្ថភាពដ៏ល្អ ហើយបានជាអាចារ្យបង្រៀនសិស្សានុសិស្ស យ៉ាងច្រើនសន្ធឹកសន្ធាប់ទៀតផង ជាពិសេសនោះ បានធ្វើនាទីដ៏សំខាន់យ៉ាងក្រៃលែង ក្នុងការហាមនូវការឈ្លោះវិវាទរវាងបណ្តាក្សត្រ និងព្រាហ្មណ៍ និងម្ចាស់ក្រុងទាំងឡាយ ដែលមានបំណងចង់មកសុំចែក ព្រះបរមសារីរិកធាតុរបស់ព្រះសម្មុទ្ធ ដោយលោកបាននិយាយឲ្យបណ្តាពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ព្រមទទួលស្គាប់ហេតុផល ដែលអាចទទួលយកបាន ទើបធ្វើឲ្យសង្គ្រាមក្នុងការដណ្តើមគ្នា យកព្រះបរមសារីរិកធាតុមិនកើតឡើង ។

ជីវប្រវត្តិរបស់ទោណព្រាហ្មណ៍ឧបាសក មានសម្តែងនៅក្នុង ***អដ្ឋកថាបរមត្ថទីបនី*** *និង* ***អដ្ឋកថាសុមង្គលវិលាសិនី*** *ថា ៖*

ទោណព្រាហ្មណ៍ ជាអ្នកមានជំនាញក្នុងវិជ្ជាត្រៃវេទ និងបានបង្រៀនសិស្សានុសិស្សមកជាច្រើន ហួសគណនា ។ មានអ្នកពោលថា ក្នុងផ្ទៃជម្ពូទ្វីប (ប្រទេសឥណ្ឌាបុរាណ) បុគ្គលដែលកើតក្នុងត្រកូលអ្នកមានដោយច្រើនដែលថាមិនមែនជាកូនសិស្សរបស់ទោណព្រាហ្មណ៍មិនមានឡើយដោយច្រើនសុទ្ធសឹងតែជាកូនសិស្សរបស់ទោណព្រាហ្មណ៍ទាំងអស់ ។ ទោណព្រាហ្មណ៍ ក្នុងថ្ងៃដែលបង្រៀនសិល្បវិជ្ជាដល់មាណព ៥០០ នាក់ ទើបលោកក្រោកឡើងអំពីព្រលឹម ងូតទឹកជម្រះកាយហើយបានស្លៀកសំពត់តម្លៃ ១ សែនកហាបណៈ បានដណ្តប់សំពត់តម្លៃ ៥ រយកហាបណៈ បានពាក់ស្បែកជើងខ្សែក្រហម មានមាណព ៥០០ នាក់ជាបរិវារ ។

ការដែលទោណព្រាហ្មណ៍ បានជួបជាមួយនឹងព្រះជិនស្រី ហើយកើតការជឿ និងមានសេចក្តីជ្រះថ្លា នៅក្នុងព្រះសាសនានេះ មានរឿងសម្តែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត** នៃ **ចក្កវគ្គ** ក្នុង **ទោណសូត្រ** ពោលដោយទោណព្រាហ្មណ៍ក្រាបទូលសួរបញ្ហាចំពោះ

ព្រះវិជិតមារ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសក្យមុនី ទ្រង់ពុទ្ធដំណើរផ្លូវឆ្ងាយ នៅក្នុងរវាងក្រុងឧក្កដ្ឋា និងក្រុងសេតព្យៈនោះ ។ ចំណែកទោណព្រាហ្មណ៍ក៏បានធ្វើដំណើរផ្លូវឆ្ងាយ ទៅក្នុងរវាងព្រំដែនរបស់ក្រុងឧក្កដ្ឋា និងក្រុងសេតព្យៈ ដូចគ្នានឹងព្រះទសពលដែរ ។ គ្រានោះ ទោណព្រាហ្មណ៍បានឃើញរូបចក្រ គឺរូបកង់រថ ព្រមដោយកាំ ១០០០ មានរង្វង់ និងដុំបរិបូណ៌ដោយលក្ខណៈសព្វគ្រប់ ក្នុងស្នាមព្រះបាទរបស់ព្រះសយម្ភូ ។ កាលទោណព្រាហ្មណ៍បានឃើញហើយ ក៏ធ្វើឲ្យមានការចម្លែកក្នុងចិត្តដែលមិនធ្លាប់បានឃើញមកពីមុន ទើបគិតថា ស្នាមជើងនេះប្រហែលជាមិនមែនស្នាមជើងរបស់មនុស្សធម្មតាទេ ។ កាលនោះព្រះលោកនាថយាងអំពីផ្លូវគេចចូលទៅ គង់ប្រថាប់នៅត្រង់គល់ឈើមួយដើម ដោយព្រះអង្គពែនព្រះបាទ តាំងព្រះកាយឲ្យត្រង់ ទ្រង់មានស្មារតីឲ្យមានមុខឆ្ពោះទៅកាន់ព្រះកម្មដ្ឋាន ។ ទោណព្រាហ្មណ៍ ក៏ដើរតាមស្នាមព្រះបាទរបស់ព្រះសាស្តាទៅៗ ក៏បានឃើញព្រះសុគត មើលទៅផ្លូវផងគួរឲ្យ

ជ្រះថ្លា ជាអ្នកមានឥន្ទ្រិយស្ងប់រម្ងាប់ ជាអ្នកដល់នូវភាពនៃការអប់រំហើយ ជាអ្នកមានខ្នងទូន្មានហើយ ជាអ្នកមិនធ្វើអំពើបាបក្នុងទីណាៗ គង់ប្រថាប់នៅត្រង់គល់ឈើមួយដើម ហើយទោណព្រាហ្មណ៍ ទើបចូលទៅគាល់ក្រាបទូលសួរថា លោកដ៏ចម្រើនជាទេវតាឬ ? គ្រានោះ ព្រះភគវាត្រាស់តបថា ម្នាលព្រាហ្មណ៍ តថាគតមិនមែនជាទេវតាទេ ។ទោណព្រាហ្មណ៍សួរទៀតថា លោកដ៏ចម្រើនជាគន្ធព្វឬ ? ព្រះជិនវរឆ្លើយថា តថាគតមិនមែនជាគន្ធព្វទេ ។ ទោណព្រាហ្មណ៍សួរទៀតថា លោកដ៏ចម្រើនជាយក្ខមែនឬ ? ព្រះលោកនាថឆ្លើយថា តថាគតមិនមែនជាយក្ខទេ ។ ទោណព្រាហ្មណ៍សួរទៀតថា លោកដ៏ចម្រើនជាមនុស្សឬ ? ព្រះសាស្តាឆ្លើយថា តថាគតមិនមែនជាមនុស្សទេ ។ទោណព្រាហ្មណ៍ ទើបក្រាបទូលថា បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណាសួរថា លោកជាទេវតា... ជាគន្ធព្វ...ជាយក្ខ... ជាមនុស្សឬ លោកដ៏ចម្រើនក៏តបថា មិនមែនទេ បើដូច្នោះ លោកដ៏ចម្រើនជាអ្វីទៅវិញ ?ពេលនោះ ព្រះមានព្រះភាគត្រាស់តបថា ម្នាលព្រាហ្មណ៍ តថាគតនឹងគប្បីជាទេវតា... ជាគន្ធព្វ...

ជាយក្ខ... ជាមនុស្ស ព្រោះអាសវៈពួកណាដែលលះមិនបាន អាសវៈទាំងនោះ តថាគតលះបានហើយ បានកាត់ឫសជាប់ហើយ បានធ្វើឲ្យដូចជាត្នោតកំបុត.ក លែងកើតតទៅទៀត ម្នាលព្រាហ្មណ៍ ផ្កាឧប្បលផ្កាបទុម និងផ្កាបុណ្ឌរិក (ឈូកស) ក្តី ដែលកើតក្នុងទឹក ចម្រើនធំក្នុងទឹក តែលូតមកផុតផ្ទៃទឹកហើយ ក៏មិនមានទឹកជាប់នៅ យ៉ាងណាមិញ តថាគតកើតក្នុងលោក ចម្រើនធំជាត់មកក្នុងលោក តែតថាគតនៅខាងលើលោក មិនជាប់នៅក្នុងលោក ដូច្នោះ ម្នាលព្រាហ្មណ៍ អ្នកចូរចាំតថាគតទុកថា ជាព្រះពុទ្ធ ។ កាលព្រះសម្មាសម្ពុទ្ធត្រាស់ដូច្នេះហើយ ទើបត្រាស់ព្រះគាថាទាំងនេះថា

តថាគតគប្បីបានកំណើតជាទេវតា ឬថាជាគន្ធព្វ ដែលហោះហើរទៅ ក្នុងអាកាសបាន ដោយអាសវៈណា តថាគតនឹងគប្បីបានអត្តភាពយក្ខ និងអត្តភាពមនុស្ស ដោយអាសវៈណា អាសវៈទាំងនោះ របស់តថាគតអស់ហើយ តថាគតទម្លាយ ធ្វើឲ្យដាច់ខ្សែហើយ ។ ម្នាលព្រាហ្មណ៍ ផ្កាឈូករមែងលូតឡើងផុតទឹក ហើយមិនមានទឹក

ជាប់នៅ យ៉ាងណាមិញ តថាគត ក៏មិនជាប់នៅនឹងលោកដូច្នោះ ព្រោះដូច្នោះ ទើបតថាគត ឈ្មោះថា ជាព្រះពុទ្ធ ។

នៅត្រង់សេចក្តីនៃព្រះគាថានេះ មានពាក្យអធិប្បាយរបស់ព្រះអដ្ឋកថាចារ្យក្នុង ***ទោណសូត្រ*** *នេះទុកដើម្បីឲ្យយល់ ក្នុងអត្ថន័យរបស់រឿងវគ្គខ្លះ និងពាក្យខ្លះដូច្នេះ ។ ពាក្យថា* ***ក្រុងឧក្កដ្ឋា*** *ជាឈ្មោះក្រុងដែលបុគ្គលទាំងឡាយត្រូវទំកសាងទាំងយប់ទាំងថ្ងៃ ដើម្បីឲ្យទាន់ឧត្តមឫក្ស ពេលយប់ ទើបត្រូវអុជគប់ភ្លើង ។ ចំណែកក្រុងសេតព្យៈជាឈ្មោះក្រុងដែលកើតឡើងរបស់ព្រះកស្សបសម្ពុទ្ធ ក្នុងអតីតកាល ។ ពាក្យថា* ***ដើរផ្លូវឆ្ងាយ*** *គឺក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ឃើញថា កាលតថាគតធ្វើដំណើរទៅនោះ ទោណព្រាហ្មណ៍នឹងបានឃើញស្នាមជើងរបស់តថាគត ហើយគេនឹងតាមស្នាមជើងតថាគតទៅ ហើយគេនឹងសួរបញ្ហាចំពោះតថាគតៗ នឹងសម្តែងសច្ចធម៌ឲ្យគេបានស្តាប់ គេនឹងបានសម្រេចសាមញ្ញផល ៣ ប្រការ និងសរសើរគុណតថាគត ដោយពាក្យសរសើរឈ្មោះ* ***ទោណគជិត*** *(សីហនាទរបស់ទោណព្រាហ្មណ៍)*

១ ម៉ឺន ២ ពាន់បទ ហើយកាលតថាគតបរិនិព្វានទៅ គេនឹងរម្ងាប់រៀបជ័ធំ ដែលកើតឡើងក្នុងជម្ពូទ្វីបទាំងមូល ហើយនឹងបានជាអ្នកចែកព្រះបរមសារីរិធាតុរបស់តថាគត ព្រះសាស្តា ទ្រង់ឃើញយ៉ាងនេះហើយ ទើបបានយាងទៅតាមផ្លូវនោះ ។ ចំណែកទោណព្រាហ្មណ៍ មានមាណព ៥០០ នាក់ជាបរិវារ ក៏បានធ្វើដំណើរទៅតាមផ្លូវ ដែលព្រះមហាវីរៈយាងទៅជួបគ្នា ។ មានពាក្យសួរថា ក្នុងស្ថានទីដែលព្រះលោកនាយកទ្រង់យាងទៅនោះ ស្នាមព្រះបាទច្រាកជក្នុងស្ថានទីដែលទ្រង់ជាន់ទុកយ៉ាងនោះជានិច្ចឬ ? មានពាក្យឆ្លើយថា មិនមានស្នាមព្រះបាទច្រាកជយ៉ាងនោះជានិច្ចទេ ។ មានពាក្យសួរថា ព្រោះហេតុអ្វី ? មានពាក្យឆ្លើយថា ព្រោះស្នាមព្រះបាទល្អិត ព្រោះព្រះអង្គជាអ្នកបរិបូណ៌ទៅដោយកម្ងាំងជាច្រើន និងទ្រង់អនុគ្រោះឲ្យដល់មហាជនផងដែរ ។

ពិតហើយ ព្រោះព្រះពុទ្ធអង្គទាំងឡាយ ទ្រង់មានព្រះឆវីល្អិត ស្ថានទីដែលព្រះអង្គទ្រង់ជាន់ រមែងដូចជាស្ថានទីដែលសំឡីតាំងនៅ ទើបស្នាមព្រះបាទមិនច្រាកជ ដូចសេះសិន្ធព ដែលមានថ្ងៃជើងរហ័ស

ដូចខ្សល់មានកម្លាំងជាន់លើស្លឹកឈូក ក៏មិនប្រាកដស្នាមជាន់ យ៉ាងណា
ស្តានទីដែលព្រះសាស្តាទាំងឡាយទ្រង់ជាន់ ក៏មិនប្រាកដស្នាមព្រះបាទ
ព្រោះព្រះអង្គ ទ្រង់ជាអ្នកបរិបូណ៌ទៅដោយកម្លាំងដូច្នោះដែរ ។ ពពួក
មហាជនដែលដើរតាមព្រះមហាវីរបុរសទាំងឡាយទៅអំពីក្រោយ កាល
មហាជនទាំងនោះឃើញស្នាមព្រះបាទរបស់ព្រះមានបុណ្យ ក៏មិនអាច
ដើរជាន់ទៅបាន ចាំបាច់ដើរចៀសទៅ ព្រោះដូច្នោះ ស្នាមព្រះបាទណា
ដែលមាននៅក្នុងស្តានទីដែលទ្រង់ជាន់ហើយ ស្នាមព្រះបាទនោះ ក៏វិនាស
បាត់ទៅមួយរំពេច ។ ចំណែកទោណព្រាហ្មណ៍ ដែលអាចឃើញស្នាម
ព្រះបាទបាន ដោយព្រះពុទ្ធទ្រង់អធិដ្ឋានទុក គឺព្រះមុនីមានព្រះបំណង
ដើម្បីទ្រង់សម្តែងព្រះចេតិយ គឺស្នាមព្រះបាទឲ្យដល់បុគ្គលណា ក៏ទ្រង់
អធិដ្ឋានប្រោវឆ្ពដល់បុគ្គលនោះថា បុគ្គលនោះចូរឃើញ ព្រោះដូច្នោះ
ទោណព្រាហ្មណ៍ ទើបបានឃើញស្នាមព្រះបាទ ដោយអំណាចការ
អធិដ្ឋានរបស់ព្រះជិនស្រី ដូចមាគន្ធិយព្រាហ្មណ៍ ។កាលទោណព្រាហ្មណ៍
បានស្តាប់ព្រះធម្មទេសនារបស់ព្រះលោកនាថចប់ហើយ ក្នុងគ្រានោះ

គេក៏បានសម្រេចផល ៣ ប្រការ គឺជាព្រះអនាគាមី ហើយបានពោលសរសើរព្រះសម្ពុទ្ធ ដោយព្រះគាថា ១ ម៉ឺន ២ ពាន់បទផងដែរ ។

ទោណព្រាហ្មណ៍ ដែលជាអ្នកមានឈ្មោះពោះសំឡេង ដែលស្គាល់ដោយទូទៅ ទាក់ទងក្នុងការរម្ងាប់វិវាទ របស់បណ្តាពួកក្សត្រ ដែលជាម្ចាស់នគរទាំង៦ឡាយ និងធ្វើនាទីជាអ្នកចែកព្រះសារីរិកធាតុនោះ មានរឿងពោលទុកនៅក្នុងព្រះបាលី **គម្ពីរទីឃនិកាយ មហាវគ្គ** នៃ **មហាបរិនិព្វានសូត្រ** ដូចមានសេចក្តីថា ៖

កាលថ្ងាយព្រះភ្លើងព្រះបរមសព របស់ព្រះសក្យមុនីស្រេចបាច់ហើយ ។ ព្រះបាទអជាតសត្តុ ដែលជាព្រះរាជានៃដែនមគធៈ ទ្រង់បានឮដំណឹងថា ព្រះទសពលស្តេចបរិនិព្វាននៅក្នុងនគរកុសិនារា ព្រះអង្គទើបទ្រង់បញ្ជូនព្រះរាជទូតទៅរកពួកស្តេចមល្លក្សត្រ នៅក្នុងក្រុងកុសិនារាថា ព្រះសយម្ភូក៏ជាក្សត្រ សូម្បីយើងក៏ជាក្សត្រ យើងគួរបានចំណែកចែកព្រះបរមសារីរិកធាតុរបស់ព្រះភគវាន្ទៈ និងបានធ្វើព្រះស្តូប និងការធ្វើបុណ្យធ្ងន់ ព្រះបរមសារីរិកធាតុរបស់ព្រះសាស្តាផងដែរ ។

ពួកក្សត្រលិច្ឆវីនៅក្រុងវេសាលី ពួកក្សត្រសាក្យៈនៅក្នុងក្រុងកបិលពស្តុ ពួកក្សត្រថូលីនៅក្នុងក្រុងអល្លកប្បៈ ពួកក្សត្រកោលិយៈនៅក្នុងក្រុងរាមគ្រាម ពួកព្រាហ្មណ៍ដែលជាអ្នកគ្រប់គ្រងនៅក្នុងក្រុងវេដ្ឋទីបកៈ និងពពួកក្សត្រនៅក្រុងបាវា ទ្រង់បានជ្រាបដំណឹងថា ព្រះលោកនាថស្តេចបរិនិព្វាននៅក្រុងកុសិនារា ទើបទ្រង់បញ្ជូនព្រះរាជទូតទៅរកពួកមល្លក្សត្រនៅក្រុងកុសិនារាថា ព្រះលោកនាថក៏ជាក្សត្រ សូម្បីយើងក៏ជាក្សត្រ យើងគួរនឹងបានចំណែកព្រះបរមសារីរិកធាតុរបស់ព្រះសាស្តាខ្លះ និងបានធ្វើព្រះស្តូប ឬធ្វើបុណ្យឆ្នងព្រះបរមសារីរិកធាតុរបស់ព្រះសាស្តាផងដែរ ។ កាលបណ្តាពួកក្សត្រ និងព្រាហ្មណ៍ពោលយ៉ាងនេះហើយ ពួកស្តេចមល្លក្សត្រនៅក្រុងកុសិនារា បានត្រាស់ជាមួយគណៈទូតទាំងនោះ ជាការបដិសេធន៍ថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វាននៅក្រុងរបស់យើង ដូច្នេះ ពួកយើងមិនអាចចែកព្រះធាតុ របស់ព្រះសម្មាសម្ពុទ្ធបានឡើយ ។ កាលពួកស្តេចមល្លក្សត្រក្រុងកុសិនារាត្រាស់ដូច្នេះហើយ ទោណព្រាហ្មណ៍បានពោលនឹងគណៈរាជទូតទាំងនោះថា

ម្នាលលោកដ៏ចម្រើនទាំងឡាយ សូមពួកលោកស្តាប់ពាក្យដ៏ឯករបស់ខ្ញុំ ព្រះលោកនាថរបស់យើងទាំងឡាយ ទ្រង់តែងតែពោលសរសើរខន្តិធម៌ ការធ្វើចម្បាំងគ្នា ព្រោះតែចែកចំណែកព្រះបរម-សារីរិកធាតុរបស់ព្រះលោកនាយក ដែលទ្រង់ជាឧត្តមបុរស ដូច្នេះមិនប្រសើរឡើយ សូមពួកយើងទាំងឡាយ ព្រមព្រៀងគ្នាត្រេកអរក្នុងការចែកព្រះបរមសារីរិកធាតុជា ៨ ចំណែកចុះ សូមឲ្យព្រះស្តូបផ្សព្វផ្សាយទៅក្នុងទិសទាំងឡាយ ជនដែលជាអ្នកជ្រះថ្លា ជាមួយព្រះពុទ្ធក៏មានច្រើនដែរ ។

កាលដែលទោណព្រាហ្មណ៍ បានពោលជាមួយគណៈរាជទូតដូច្នេះ មានអត្ថន័យនៅក្នុង ***អដ្ឋកថាសុមង្គលវិលាសិនី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៅក្នុង* ***គម្ពីរទីឃនិកាយ មហាវគ្គ*** *ថា ៖*

ការបញ្ជូនរាជទូត និងបណ្តាការទៅ របស់បណ្តាក្សត្រ និងព្រាហ្មណ៍ទាំងនោះ រមែងមានការត្រៀមកងទ័ពទៅផង ដូច្នេះ ព្រះបាទអជាតសត្តុ ដែលទ្រង់បញ្ជូនរាជទូត និងព្រះរាជសាសន៍ទៅកាន់ក្រុង

កុសិនារាហើយ ទើបទ្រង់បញ្ជាឲ្យត្រៀមចតុរង្គសេនា ហើយព្រះអង្គ
យាងទៅខាងក្រោយ ដោយមានព្រះរាជតម្រិះថា បើពួកស្តេចមល្លក្សត្រ
នៅក្រុងកុសិនារា ព្រមចែកចំណែកព្រះបរមធាតុឲ្យជាការល្អ បើមិន
ព្រមចែកទេ យើងនឹងដណ្តើមយកដោយកម្លាំងរបស់ពលយោធិនទាំ
យកមកឲ្យទាល់តែបាន ។ សូម្បីក្សត្រទាំងឡាយ ក្នុងក្រុងផ្សេងៗ
មានក្សត្រលិច្ឆវីនៅក្នុងក្រុងវេសាលីជាដើម កាលទ្រង់បញ្ជូនរាជទូតទៅ
ហើយ ក៏ទ្រង់លើកចតុរង្គសេនា ជាប់តាមទៅអំពីក្រោយ ដូចព្រះបាទ
អជាតសត្តុ ដែលទ្រង់ធ្វើហើយនោះដែរ ។ មានពាក្យសួរថា បណ្តា
ក្សត្រទាំងនោះ ក្សត្រនៅក្នុងក្រុងបាវា ដែលមានអាណាខេត្តនៅជិតជាង
ក្សត្រទាំងឡាយ ដោយក្រុងបាវានៅឆ្ងាយអំពីក្រុងកុសិនារាត្រឹមតែ ៣
គាវុត (១២ គ.ឡ) សូម្បីព្រះសាស្តាយាងចូលក្រុងបាវាហើយ ក៏គង់
យាងទៅកាន់ក្រុងកុសិនារា កាលបើដូច្នោះ ព្រោះហេតុអ្វី ពួកក្សត្រ
នៅក្នុងក្រុងបាវា ទើបមិនយាងទៅក្រុងកុសិនារាមុនក្សត្រអង្គដទៃ ?
មានពាក្យឆ្លើយថា ព្រោះហេតុថា ពួកក្សត្រនៃក្រុងបាវា ទ្រង់មានបរិវារ

ច្រើន ព្រោះហេតុដូច្នោះ ទើបជាហេតុធ្វើឲ្យយោធមកដល់តាមក្រោយ ។ កាលពួកក្សត្រនិងពួកព្រាហ្មណ៍ដែលជាម្ចាស់ក្រុងទាំងអស់ បានលើកកងទ័ពមកកាន់ក្រុងកុសិនារាមកដល់ព្រមគ្នាហើយ ដោយរួមកងទ័ពទាំងអស់ ៧ កង មកអំពីក្រុងទាំង ៧ ដែលមានម្ចាស់ក្រុងជាមេទ័ព ។ កាលដែលកងទ័ពផ្សេងៗ មកដល់ព្រមគ្នាហើយ ក៏ចូលព័ទ្ធក្រុងកុសិនារាទុកយ៉ាងកុះករគួរឲ្យខ្លាច បញ្ជាដោយពាក្យជាច់ខាតថា ចូរនាំគ្នាចូលទៅកាន់ក្រុងកុសិនារា បើពួកមល្លក្សត្រទាំងនោះ មិនព្រមចែកព្រះបរមសារីរិកធាតុឲ្យដល់ពួកយើង ឬចង់ច្បាំងជាមួយពួកយើង ចូរឲ្យឆ្លើយមក ។ ពួកមល្លក្សត្រនៅក្នុងក្រុងកុសិនារាបានឆ្លើយតបទៅវិញថា ពួកយើងមិនបានអាងធនាឲ្យព្រះសាស្តា ទ្រង់យាងមកបរិនិព្វាននៅឯក្រុងរបស់ពួកយើងទេ តែព្រះអង្គស្តេចយាងមកបរិនិព្វាន ដោយព្រះអង្គឯងវតន: គឺកែវឯណា ដែលកើតឡើងនៅក្នុងក្រុងរបស់អ្នកទាំងឡាយហើយ អ្នកទាំងឡាយ ក៏ទឹងមិនឲ្យវតន:ទាំងនោះ ដល់យើងដូចគ្នា ឈ្មោះថាវតន: ដែលស្មើដោយព្រះពុទ្ធវតន:មិនមានក្នុងមនុស្សលោក ព្រមទាំង

ទេវលោក ពួកយើងបានរតនៈដ៏ប្រសើរឧត្តមបែបនេះហើយ និងមិនព្រមចែកឲ្យដល់នរណាៗ ឡើយ មិនមែនផឹកទឹកដោះម៉ែ តែពួកលោកទេសូម្បីពួកយើងក៏ផឹកទឹកដោះម៉ែដូចគ្នាមិនមែនកូនប្រុសតែពួកលោកទេសូម្បីពួកយើងក៏ជាកូនប្រុសដូចគ្នា បើពួកលោកទាំងឡាយចង់ច្បាំងក៏ពួកយើងមិនខ្លាច ។ ស្តេចទាំងនោះ ធ្វើអហង្ការ ទ្រង់បញ្ជូនរាជសាសន៍ឆ្ពើយឆ្លងគ្នា ប្រើមានៈ គឺការតម្កើងខ្លួន គំរាមចំពោះគ្នាទៅវិញទៅមក ។

មានពាក្យសួរថា ប្រសិនបើមានការច្បាំងគ្នាមែន តើខាងណាជាអ្នកឈ្នះ ? មានពាក្យឆ្លើយថា ប្រសិនបើមានការច្បាំងគ្នាមែន ពពួកក្សត្រនៅក្នុងក្រុងកុសិនារាជាអ្នកឈ្នះ ។ ព្រោះហេតុអ្វី ? ព្រោះទេវតាទាំងឡាយដែលមកបូជាព្រះបរមសារីរិកធាតុ បានទាំគ្នាជួយធ្វើអន្តរាគមន៍ខាងពួកស្តេចមល្លក្សត្រ ។ ក្នុងសម័យនោះ ទោណព្រាហ្មណ៍ដែលជាអាចារ្យធំ របស់បណ្តាពួកក្សត្រក្នុងជម្ពូទ្វីប ដូចមានពាក្យថា មនុស្សជ័ច្រើន ទាំងពួកក្សត្រ និងពួកព្រាហ្មណ៍ ដែលមិនធ្លាប់ជាកូនសិស្សរបស់ទោណព្រាហ្មណ៍មិនមានឡើយ ព្រោះដូច្នោះ លុះទោណ-

ព្រាហ្មណ៍ស្តាប់ការឈ្លោះវិវាទរបស់ពួកក្សត្រ និងពួកព្រាហ្មណ៍ទាំងនោះ
ហើយ ទើបគិតពិចារណាថា ពពួកក្សត្រទាំងនេះ នាំគ្នាមកបង្កការវិវាទគ្នា
ក្នុងស្ថានទីដែលព្រះកគវាទ្រង់ប្រថិនិព្វាននេះ មិនសមគួរទេ ការឈ្លោះ
វិវាទនេះ យើងចាំបាច់ត្រូវតែទៅរម្ងាប់ការឈ្លោះវិវាទនោះចេញ កាល
ទោណព្រាហ្មណ៍គិតពិចារណាយើញដូច្នេះហើយ ទើបឡើងទៅឈរលើ
ជំហូលប៉ាមការពារ ហើយបាននោលគាថា ឈ្មោះថា **ទោណគជ្ជិត**
ដែលជាការស្រែកប្រកាស ហាមពួកក្សត្រទាំងនោះ មិនឲ្យច្បាំងគ្នា ។
កាលពួកក្សត្រទាំងនោះ បានស្តាប់ឮសំឡេងរបស់ទោណព្រាហ្មណ៍
ដែលស្រែកខ្លាំងៗ ដូច្នេះ ក៏ចាំបាន ទើបនោលថា លោកដ៏ចម្រើន
សំឡេងនោះស្តាប់ទៅហើយ ដូចជាសំឡេងរបស់លោកអាចារ្យ ហើយ
គ្រប់ៗ គ្នា ក៏ស្ងប់ស្ងៀមចុះមួយរំពេច ។ គ្រានោះ ទោណព្រាហ្មណ៍ដឹងថា
ពួកក្សត្រទាំងនោះ បានឮសំឡេងរបស់ខ្លួននាំគ្នាស្ងប់ស្ងៀម និងឈរ
នៅមួយកន្លែងហើយ ទើបគេនោលពាក្យសម្តីដែលនោលហើយម្តងទៀត
ដែលមានហេតុផលធ្វើឲ្យគ្រប់ៗ គ្នា យល់បានថា មិនមែនពួកលោក

តែមួយពួកប៉ុណ្ណោះទេ ដែលជាអ្នកមានសេចក្តីជ្រះថ្លា សូម្បីអ្នកដទៃជាច្រើន ក៏មានសេចក្តីជ្រះថ្លាចំពោះព្រះសម្ពុទ្ធ ក្នុងបណ្តាជនទាំងនោះគ្រប់ៗ គ្នា គួរបានចំណែកព្រះបរមសារីរិកធាតុរបស់ព្រះលោកនាយកដូចគ្នាដែរ ហើយគេក៏ពោលព្រមទទួលចែកព្រះបរមសារីរិកធាតុដល់ពួកក្សត្រទាំងឡាយដែលមក ។ បណ្តាក្សត្រទាំងនោះ ក៏ស្រុះស្រួលគ្នាព្រមលើកទោណព្រាហ្មណ៍ជាអាជ្ញាកណ្តាល ដើម្បីធ្វើការចែកព្រះបរម-សារីរិកធាតុ ។ លំដាប់នោះ ទើបទោណព្រាហ្មណ៍ បញ្ជាឲ្យបើកព្រះកោដ្ឋមាស ដែលតម្កល់ព្រះបរមសារីរិកធាតុចេញ ។ ចំណែកក្សត្រទាំងឡាយ ក៏បាននាំគ្នាមកឈរនៅជិតព្រះកោដ្ឋមាសនោះ ។ ពួកក្សត្រទាំងនោះ លុះបានទតឃើញព្រះបរមសារីរិកធាតុទាំងឡាយ មានពណ៌សម្បុរដូចជាមាស ក៏នាំគ្នាស្រែកឃោសថា បពិត្រព្រះលោកនាយក ដែលជាសព្វញ្ញូ អំពីកាលមុន ខ្ញុំព្រះអង្គទាំងឡាយ បានឃើញព្រះសរីរៈរបស់ព្រះអង្គ មានពណ៌ដូចជាមាស ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ លម្អដោយពុទ្ធរស្មីមានពណ៌ទាំង ៦ ប្រការ ល្អរុងរឿង

ដោយអនុព្យញ្ជន: ៨០ ប្រការ តែឥឡូវនេះ សល់ត្រឹមតែព្រះបរម-សារីរិកធាតុ ដែលមានពណ៌ដូចជាមាស បពិត្រព្រះភគវា ការណ៍នេះមិនសមគួរដល់ព្រះអង្គឡើយ ។

ការចែកព្រះបរមសារីរិកធាតុ ដែលទោណព្រាហ្មណ៍បានទទួលការទុកចិត្តអំពីពួកក្សត្រ និងពួកព្រាហ្មណ៍ទាំងនោះ ក៏មានរឿងសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរទីឃនិកាយ មហាវគ្គ** ដូចមានសេចក្តីថា ៖

គណៈរាជទូតទាំងនោះពោលថា បពិត្រលោកអាចារ្យដ៏ចម្រើន បើដូច្នោះ សូមលោកអាចារ្យជួយចាត់ចែង ចែកព្រះបរមសារីរិកធាតុរបស់ព្រះមហាវីរៈជា ៨ ចំណែកឲ្យប៉ុនៗ គ្នាផងចុះ ។នៅក្នុងពេលនោះ ទោណព្រាហ្មណ៍ក៏យល់ព្រមទៅតាមពាក្យ របស់គណៈរាជទូតទាំងនោះ ហើយក៏បានចាត់ចែងចែកព្រះបរមសារីរិកធាតុជា ៨ ចំណែក ប៉ុនៗ គ្នាឲ្យរៀបរយហើយ ទើបបានពោលជាមួយគណៈរាជទូតទាំងនោះថា ម្នាលលោកដ៏ចម្រើនទាំងឡាយ សូមពួកលោកឲ្យនាឡិមាសនេះដល់

ខ្ញុំចុះ ខ្ញុំនឹងធ្វើព្រះស្តូប និងធ្វើបុណ្យឆ្លងនាឡិមាសនេះដែរ ។ គ្រានោះ គណៈរាជទូតនោះ បានព្រមគ្នាឲ្យនាឡិមាសនោះ ដល់ទោណព្រាហ្មណ៍ តាមដែលទោណព្រាហ្មណ៍ស្នើសុំ ។ ការបញ្ជូនរាជទូត និងកងទ័ពទៅ សូមចែកចំណែកព្រះបរមសារីរិកធាតុរបស់ព្រះសម្ពុទ្ធ នៅមានក្សត្រ មួយនគរទៀត ដែលទៅដល់ក្រុងកុសិនារាយឺតជាងគេ គឺពួកក្សត្រ មោលិយៈ ដែលនៅក្នុងក្រុងបិប្ផលិវន កាលទ្រង់បានជ្រាបដំណឹងថា ព្រះបរមសាស្តាស្តេចបរិនិព្វានទៅហើយ នៅក្នុងក្រុងកុសិនារា ទើប ទ្រង់បញ្ជូនរាជទូត ឲ្យទៅរកស្តេចមល្លក្សត្រ នៅក្នុងក្រុងកុសិនារាថា ព្រះមានជោគក៏ជាក្សត្រ សូម្បីយើងក៏ជាក្សត្រ ដូច្នេះ យើងគួរតែបាន ចំណែកព្រះបរមសារីរិកធាតុរបស់ព្រះជិនស្រីខ្លះ និងបានធ្វើព្រះស្តូប និងធ្វើបុណ្យឆ្លងព្រះបរមសារីរិកធាតុនោះដែរ ទៅតាមសេចក្តីជ្រះថ្លា របស់ពួកយើង ។ ស្តេចមល្លក្សត្រ នៅក្នុងក្រុងកុសិនារាបានត្រាស់ថា ចំណែកព្រះបរមសារីរិកធាតុរបស់ព្រះវិជិតមារមិនមាន ព្រោះពួកយើង

បានចែកព្រះបរមសារីរិកធាតុរបស់ព្រះសម្ពុទ្ធអស់ហើយ សូមពួកលោកនាំព្រះអង្គារ (ធ្យូង) ដែលបូជាព្រះសពរបស់ព្រះសាស្តានេះទៅចុះ ។ គ្រានោះ ពួករាជទូតដែលនៅក្នុងបិប្ផលិវ័ន ក៏បាននាំគ្នាយកព្រះអង្គារទៅអំពីស្ថានទីថ្វាយព្រះភ្លើងព្រះបរមសពនោះទៅ ។ ព្រះស្តូបសម្រាប់បញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះលោកនាថទាំងអស់ មាន ៨ កន្លែង ។ ព្រះស្តូបកន្លែងទី ៩ បញ្ចុះតុម្ព គឺនាឡិមាស ដែលប្រើវាល់ព្រះបរមសារីរិកធាតុ ដោយទោណព្រាហ្មណ៍ ជាអ្នកកសាងចាត់ចែងឡើង ។ ហើយព្រះស្តូបកន្លែងទី ១០ ដែលបញ្ចុះព្រះអង្គារ ដោយពួកក្សត្រមោលិយៈបញ្ជាឲ្យកសាងឡើង នៅក្នុងក្រុងបិប្ផលិវ័ន ។

ព្រះបរមសារីរិកធាតុទាំងអស់របស់ព្រះលោកនាថ បានយកទៅប្រតិស្ឋានក្នុងទីផ្សេងៗ ក្នុង **ធាតុបូជនីយកថា** នៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្តីថា ៖

ព្រះបរមសារីរិកធាតុរបស់ព្រះមុនី មាន ១៦ នាឡិ បានប្រតិស្ឋាន

នៅក្នុងជម្ពូទ្វីប ១៤ នាឡិ ស្តេចនាគបាននាំយកអំពីរាមគ្រាមទៅប្រតិស្ឋានទុកក្នុងពិភពនាគ ២ នាឡិ (២ នាឡិនេះ សព្វថ្ងៃនេះនៅក្នុងប្រទេសស្រីលង្កា) ។ ព្រះចង្កូមកែវទាំង ៤ អង្គនោះ មួយអង្គបានយកទៅប្រតិស្ឋាននៅក្នុងស្ថានតាវត្តិង្ស មួយអង្គទៀតបានយកទៅប្រតិស្ឋាននៅក្នុងដែនគន្ធារបុរៈ មួយអង្គទៀតបានយកទៅប្រតិស្ឋាននៅក្នុងដែនកាលិង្គៈ និងមួយអង្គទៀត បានយកទៅប្រតិស្ឋាននៅក្នុងពិភពនាគ ។ ជាការល្អណាស់ ដែលផ្ទៃមហាប្រឹថពីនេះ បានជាទីប្រតិស្ឋានរបស់ព្រះបរមសារីរិកធាតុរបស់ព្រះលោកនាថបានជាច្រើនកន្លែង ដូចបានរៀបរាប់រួចមកហើយ សូមពុទ្ធបរិស័ទទាំងឡាយ តាំងចិត្តនមស្ការព្រះបរមសារីរិកធាតុរបស់ព្រះលោកនាយក ដែលជារបស់រកបានដោយលំបាក ។ ចំណែកព្រះទន្ត ៤០ ព្រះកេសា ព្រះលោមាទាំងអស់ទេវតាបានយកទៅមួយអង្គមួយៗ ហើយយកទៅប្រតិស្ឋានទុកនៅក្នុងចក្រវាឡនីមួយៗ ។

ព្រះបរមសារីរិកធាតុរបស់ព្រះមានជោគ ដែលទោណព្រហ្មណ៍ជាអ្នកចាត់ចែងការចែកនោះ ក៏មានសម្តែងប្រាកដនៅក្នុង ***អដ្ឋកថាសុមង្គលវិលាសិនី*** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង ***គម្ពីរទីឃនិកាយ មហាវគ្គ*** ដូចមានសេចក្តីថា ៖

ខណៈដែលទោណព្រាហ្មណ៍កំពុងតែប្រើនាឡិមាស វាល់ចែកព្រះបរមសារីរិកធាតុនោះ គេបានឃើញថា ពួកក្សត្រទាំងនោះ មិនបានចាប់ក្តីក ទើបចាប់យកព្រះចង្កឹមកែវលើខាងស្តាំមកសៀតទុកនៅត្រង់ផ្នងសក់ ដោយគិតនឹងនាំយកទៅជាចំណែករបស់ខ្លួន ហើយតមកទើបគេចែកព្រះបរមសារីរិកធាតុជា ៨ ចំណែកឲ្យស្មើគ្នា ។ ព្រះបរមសារីរិកធាតុទាំងអស់រួមទៅជា ១៦នាឡិ ។ពពួកក្សត្រទាំងនោះមួយអង្គៗ បានទទួលយកទៅពីរនាឡិស្មើៗ គ្នា ។ តែពេលដែលទោណព្រាហ្មណ៍កំពុងតែវាល់ និងចែកព្រះបរមសារីរិកធាតុនោះ សក្កទេវតាទ្រង់រំពឹងមើលថា នរណាហ្ន៎ ជាអ្នកយកព្រះចង្កឹមកែវខាងស្តាំរបស់ព្រះសាស្តា

សក្តទេវរាជទ្រង់បានជ្រាបថា ទោណព្រាហ្មណ៍ជាអ្នកយកទុក ទើបទ្រង់ព្រះតម្រិះថា សូម្បីទោណព្រាហ្មណ៍ ក៏មិនអាចធ្វើសក្ការៈ ឬរក្សាទុកបានល្អឡើយ ដូច្នេះ យើងនឹងយកព្រះចង្កូមកែវនេះ ហើយព្រះអង្គទើបយាងព្រះចង្កូមកែវអំពីផ្នងសក់របស់ទោណព្រាហ្មណ៍ ហើយទ្រង់បានដាក់ព្រះចង្កូមកែវនោះទៅក្នុងប្រអប់កែវ នាំយកទៅកាន់ទេវលោកប្រតិស្ឋានទុកនៅក្នុងចូឡាមណីចេតិយ នាស្ថានតាវត្តិង្ស ។ ចំណែកទោណព្រាហ្មណ៍ កាលចែកព្រះបរមសារីរិកធាតុស្រេចហើយ បានរកមើលព្រះចង្កូមកែវដែលខ្លួនសៀតទុកនៅក្នុងផ្នងសក់មិនឃើញ តែព្រោះថាខ្លួនកាលយកទុកដោយអាការមិនចង់ឲ្យគេដឹង ទើបមិនហ៊ានសួរគេថា អ្នកណាមកយកព្រះចង្កូមកែវរបស់យើងទៅ ? គេបានពិចារណាឃើញតែការលើកទោសកំហុសក្នុងខ្លួនឯងថា យើងជាអ្នកចែកព្រះបរម-សារីរិកធាតុខ្លួនឯង ហេតុអ្វីមិនដឹងថា ព្រះបរមសារីរិកធាតុ ដែលជាចំណែករបស់ខ្លួនមានឬអត់ ទើបមិនអាចពោលថា អ្នកទាំងឡាយចូរ

ឲ្យចំណែកព្រះបរមសារីរិកធាតុដល់ខ្ញុំផង ។ លំដាប់តអំពីនោះ ទោណ-ព្រាហ្មណ៍កាលពិចារណារកព្រះចង្កឹមកែវមិនឃើញហើយ ទើបគិតថា នាឡិមាសនេះ មានហាន: ដូចជាព្រះបរមសារីរិកធាតុ ដូច្នេះ យើងគួរយកនាឡិមាសនេះ ដែលប្រើសម្រាប់វាល់ព្រះបរមសារីរិកធាតុរបស់ព្រះតថាគតទៅដើម្បីកសាងព្រះស្តូប ហើយបានពោលប្រាប់ទៅពួកក្សត្រទាំងនោះថា លោកជ័ចម្រើនទាំងឡាយ មេត្តាឲ្យនាឡិមាសនេះដល់ខ្ញុំចុះ ។

ពួកក្សត្រទាំងនោះ ក៏បានព្រមព្រៀងគ្នាឲ្យនាឡិមាសនោះដល់ទោណព្រាហ្មណ៍ទៅ ។ កាលទោណព្រាហ្មណ៍បានទទួលនាឡិមាសនោះហើយ ទើបបាននាំយកទៅបញ្ចុះក្នុងព្រះស្តូប ដែលបានកសាងឡើងហៅថា **តុម្ពស្តូប** ប្រែថា ព្រះស្តូបដែលបញ្ចុះនាឡិមាស ។ ទាំងនេះចាត់ជាគំរូបានថា ទោណព្រាហ្មណ៍ជាឧបាសក ដែលបានសម្រេចជាព្រះអនាគាមី ជាអ្នកមានសមត្ថភាពរម្ងាប់ហេតុ ដែលធ្វើមិនឲ្យកើត

សង្គ្រាម ៨-៩ កងទ័ពបាន ដែលមិនមែនជាវិធីងាយឡើយ ព្រោះថា កងទ័ពផ្សេងៗ កំពុងតែមកប្រឈមមុខជាក់គ្នា ថែមទាំងបានពោលទ្រគោះបោះបោកដល់គ្នានិងគ្នាទៀតផង តែលោកអាច ឲ្យពពួកក្សត្រដែលជាមេទ័ពទាំងនោះឈប់បាន ទាំងនេះជាហេតុផលដ៏សំខាន់មួយទៀត ដែលទាក់ទងមកអំពីបារមី ដែលបានសន្សំមកហើយ ណាមួយទោណព្រាហ្មណ៍ក៏ជាអាចារ្យរបស់ពួកក្សត្រទាំងនោះដែរ ទើបជាហេតុធ្វើឲ្យពួកក្សត្រទាំងនោះស្តាប់ផងដែរ ។

(ជីវប្រវត្តិរបស់ទោណព្រាហ្មណ៍ឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ធម្មិកឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

ធម្មិកឧបាសក លោកជាអ្នកយកចិត្តទុកជាក់នៅក្នុងរឿងបុណ្យកុសលជាប្រចាំ ថែមទាំងជាអ្នកដឹកនាំមនុស្សក្នុងត្រកូលទាំងឡាយឲ្យចេះស្រឡាញ់នៅក្នុងបុណ្យកុសល តាមគំរូរបស់លោក ក៏មានរឿងពោលទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **យមកវគ្គ** ក្នុងរឿងរបស់ធម្មិកឧបាសក ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគប្រថាប់នៅវត្តជេតពន ជិតក្រុងសាវត្ថី ព្រះអង្គទ្រង់គ្រាស់សម្តែងព្រះធម៌ ដោយប្រារព្ធធម្មិកឧបាសកឲ្យជាដើមហេតុ ហើយគ្រាស់ព្រះធម្មទេសនា ។ ដូចមានរឿងពោលថា នៅក្នុងក្រុងសាវត្ថី មានឧបាសកអ្នកបដិបត្តិធម៌ប្រមាណ ៥ រយនាក់ បណ្តាឧបាសកទាំង ៥០០ នាក់នោះ ម្នាក់ៗ មានឧបាសក ជាបរិវារ ៥០០ នាក់ផងដែរ ។ ធម្មិកឧបាសក ជាប្រធាន នៃឧបាសកទាំងនោះ

ហើយលោកមានកូនទាំងអស់ ១៤ នាក់ កូនប្រុស ៧ នាក់ កូនស្រី ៧ នាក់ ។ ក្នុងចំនួនកូនប្រុសស្រីទាំង ១៤ នាក់នោះ ម្នាក់ៗ បានធ្វើ ***សលាកកត្ត បក្ខិកកត្ត សង្ឃកត្ត ឧបោសថកត្ត អាគន្តុកកត្ត វស្សាវាសិកកត្ត*** ម្នាក់មួយពេលៗ ។ កូនប្រុសកូនស្រីទាំងអស់របស់ធម្មិកឧបាសក ជាអនុជាតបុត្រទាំងអស់គ្រប់គ្នា ។ ទានវត្តុផ្សេងៗ មានសលាកកត្តជាដើម មាន ១៦ កន្លែង គឺរបស់កូនប្រុស និងកូនស្រី ១៤ កន្លែង របស់ភរិយាមួយកន្លែង និងរបស់ធម្មិកឧបាសកមួយកន្លែង តែងតែមានការរៀបចំទុកគ្រប់កន្លែងទាំង ១៦ នោះដូចគ្នា ។ធម្មិកឧបាសក ព្រមដោយបុត្រ និងភរិយា ជាអ្នកមានសីល មានកល្យាណធម៌ ជាអ្នកមានសេចក្តីត្រេកអរក្នុងការឲ្យទានជានិច្ច ។ក្នុងកាលកន្លងមកខាងក្រោយ ធម្មិកឧបាសកមានជំងឺជាទម្ងន់ ។ ធម្មិកឧបាសកមានបំណងចង់ស្តាប់ព្រះធម៌ ទើបប្រើមនុស្សឲ្យទៅគាល់ក្រាបទូលព្រះសម្មាសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់មេត្តាបញ្ជូនភិក្ខុ ៨ អង្គ ឬ ១៦ អង្គ ឲ្យដល់ខ្ញុំព្រះករុណា ។ គ្រានោះ ព្រះលោកនាថ ទ្រង់បញ្ជូនឲ្យភិក្ខុទៅ

តាមចំនួនដែលធម្មិកឧបាសកត្រូវការក្រាបទូលនិមន្តនោះ ។ ភិក្ខុទាំងនោះ បាននិមន្តទៅឯផ្ទះធម្មិកឧបាសក កាលនិមន្តទៅដល់ហើយក៏អង្គុយនៅលើអាសនៈ ដែលគេរៀបចំទុកក្បែរគ្រែធម្មិកឧបាសក ។ ពេលនោះ ធម្មិកឧបាសក បានពោលជាមួយនឹងភិក្ខុទាំងនោះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ការដែលខ្ញុំព្រះករុណា បានឃើញលោកម្ចាស់ទាំងឡាយ ជាការកម្រហើយ ព្រោះខ្ញុំព្រះករុណា ជាមនុស្សទុព្វលភាព ហេតុដូច្នេះ សូមលោកម្ចាស់ទាំងឡាយ ស្វាធ្យាយព្រះសូត្រត្រឹមតែមួយសូត្រ ប្រោសខ្ញុំព្រះករុណាផង ។

គ្រានោះ ភិក្ខុទាំងនោះសួរថា ម្នាលឧបាសក ញោមចង់ស្តាប់ព្រះសូត្រណា ? ធម្មិកឧបាសកពិតបបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាចង់ស្តាប់សតិប្បដ្ឋានសូត្រ ដែលព្រះសាស្តាគ្រប់ព្រះអង្គទ្រង់មិនលះហើយ ។ ភិក្ខុទាំងនោះ លុះជ្រាបដល់សេចក្តីត្រូវការរបស់ធម្មិកឧបាសក ដូច្នេះហើយ ទើបផ្តើមស្វាធ្យាយថា **ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា** ជាដើម ។ ប្រែថា ម្នាលភិក្ខុទាំងឡាយ

ផ្លូវនេះ ជាផ្លូវឯក ដើម្បីភាពស្អាតនៃសត្វទាំងឡាយ ។

សតិប្បដ្ឋានសូត្រនេះ មានសម្តែងទុកនៅក្នុងព្រះបាលី នៅក្នុង **គម្ពីរទីឃនិកាយ មហាវគ្គ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់គង់នៅក្នុងដែនកុរុ ទ្រង់អាស្រ័យនៅកម្មាសធម្មនិគមនៃអ្នកដែនកុរុទាំងឡាយជាទីគោចរ។ ក្នុងទីនោះឯង ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវ គឺសតិប្បដ្ឋាន ៤ នេះ ជាផ្លូវមួលតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្តីស្អាតវិសេសដល់សត្វទាំងឡាយ ដើម្បីកន្ទងបង់នូវសេចក្តីសោក និងខ្សឹកខ្សួលរំជួលចិត្តទាំងឡាយ ដើម្បីអស្តង្គតរលត់ទៅនៃទុក្ខ និងទោមនស្សទាំងឡាយ ដើម្បីដល់នូវអរិយមគ្គ ជាធម៌ស្រោចស្រង់សត្វ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ សតិប្បដ្ឋានទាំងឡាយ ៤ គឺអ្វីខ្លះ ? ម្នាលភិក្ខុទាំងឡាយ

ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្ចាត់នូវកិលេស ប្រកបដោយប្រជ្ញាដ៏ឆ្លងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។ ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្ចាត់នូវកិលេស ប្រកបដោយប្រជ្ញាដ៏ឆ្លងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្ចាត់នូវកិលេស ប្រកបដោយប្រជ្ញាដ៏ឆ្លងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ពិចារណាឃើញរឿយៗនូវធម៌ក្នុងធម៌ទាំងឡាយមានព្យាយាមជាគ្រឿងដុតកម្ចាត់នូវកិលេស ប្រកបដោយប្រជ្ញាដ៏ឆ្លងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។

ម្យ៉ាងទៀត សតិជាធម៌តែមួយ តែអាចហៅថា សតិប្បដ្ឋាន ៤ នោះ ទាក់ទងនឹងអំណាចរបស់សតិ ដែលចូលទៅតាំងក្នុងអារម្មណ៍ ៤

យ៉ាង គឺចូលទៅតាំងនៅក្នុងកាយ ១ វេទនា ១ ចិត្ត ១ ធម៌ ១ ។ អានិសង្ស គឺផលរបស់សតិប្បដ្ឋានទាំង ៤ ដែលជាហេតុឲ្យបានសម្រេចផលឯណា នីមួយ បានដល់ សម្រេចព្រះអរហត្តផលក្នុងបច្ចុប្បន្ន តែបើនៅមានកិលេសនៅសល់ ក៏នឹងបានសម្រេចជាព្រះអនាគាមីខាងក្នុង ៧ ឆ្នាំ ឬបន្តយវេលាចុះមកដោយលំដាប់ខាងក្នុង ៧ ថ្ងៃ ។

ហេតុដែលព្រះមានព្រះភាគត្រាស់បង្រៀនសតិប្បដ្ឋាន និងការបដិបត្តិសតិប្បដ្ឋាននោះ ជាហេតុដែលធ្វើឲ្យជីវិតបានល្អ ឬរមែងបានទទួលនូវការពោលសរសើរនូវវត្តបដិបត្តិ តាមដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាសុមង្គលវិលាសិនី** ដូចមានសេចក្តីថា ៖

មានពាក្យសួរថា ព្រោះហេតុអ្វី ទើបបានជាព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងសតិប្បដ្ឋានសូត្រប្រោសដល់អ្នកដែនកុរុ ? មានពាក្យឆ្លើយថា ព្រោះថា អ្នកដែនកុរុទាំងនោះ ជាអ្នកបរិបូណ៌ដោយបញ្ញា អាចទទួលការស្តាប់ធម្មទេសនាដ៏ជ្រាលជ្រៅនោះបាន ។ ព្រោះថា បរិស័ទអ្នកដែនកុរុជាអ្នកមានរាងកាយមាំមួន ថែមទាំងជាអ្នកមានចិត្តត្រជាក់ត្រជុំនៅជា

ប្រក្រតីរឿយៗ ដោយបានទទួលការសប្បាយព្រោះវដ្ដវ គឺមានខ្យល់អាកាសល្អជាដើម ។ បរិស័ទទាំង ៤ ក្នុងជនបទនោះ ជាអ្នកប្រកបក្នុងការអប់រំសតិប្បដ្ឋានជាប្រក្រតី ហើយសូម្បីតែទាសកម្មករ ក៏និយាយគ្នាតែក្នុងរឿងសតិប្បដ្ឋានទាំងអស់ មិនថានៅក្នុងទីផ្សេងៗ មានកំពង់ទឹកហូរជាងតម្បាញជាដើម ដោយអ្នកទាំងនោះមិនបានចរចាប្រាស្រ័យគ្នាដោយរឿង ដែលរកសារប្រយោជន៍គ្មាន ។ បើស្រីម្នាក់ណាត្រូវសួរថា អ្នកមានសតិប្បដ្ឋានប្រការណាមួយមកជាអារម្មណ៍ ឬមិនបានបដិបត្តិក្នុងសតិប្បដ្ឋានមាតិកាណាមួយឡើយ កាលបើស្រីនោះតបថា មិនបានបដិបត្តិសតិប្បដ្ឋានណាមួយឡើយ ក៏ត្រូវមានពាក្យតិះដៀលថា ជីវិតនាងគ្មានប្រយោជន៍ សូម្បីនាងមានជីវិតរស់នៅ ក៏ស្មើគ្នានឹងអ្នកដែលស្លាប់ទៅហើយ ហើយបុគ្គលទាំងនោះនាំគ្នាប្រៀនប្រដៅថា នាងកុំធ្វើយ៉ាងនេះទៀត ហើយឲ្យរៀនសតិប្បដ្ឋានប្រការណានីមួយ ។ ប្រសិនបើស្រីណាកាលត្រូវគេសួរហើយ ពោលតបថា ខ្ញុំមានសតិប្បដ្ឋានប្រការនេះជាអារម្មណ៍ ពួកដែលសួរក៏ឲ្យសាធុការថា ល្អហើយ ល្អហើយ ហើយ

ពោលសរសើរថា ជីវិតរបស់នាងជាជីវិតដែលល្អ នាងបានភាពជាមនុស្សហើយ ព្រះសាស្តាទ្រង់កើតឡើង ដើម្បីប្រយោជន៍ដល់នាង ។ មិនមែនត្រឹមតែមនុស្សប៉ុណ្ណោះ ដែលបដិបត្តិក្នុងសតិប្បដ្ឋាន សូម្បីសត្វសេកឈ្មោះ **ពុទ្ធរក្ខិតៈ** ក៏បានបដិបត្តិក្នុងសតិប្បដ្ឋានមកហើយៗ ជួយឲ្យរួចផុតចាកអន្តរាយអំពីស្វាំង ដែលឆាបយកទៅនោះ ។

រឿងរបស់ធម្មិកឧបាសក មានពោលតទៅទៀត នៅក្នុង **គម្ពីរអដ្ឋកថាធម្មបទ** នៃ **យមកវគ្គ** ដូចមានសេចក្តីថា ៖

ក្នុងខណៈដែលធម្មិកឧបាសក កំពុងតែស្តាប់កិក្ខុទាំងឡាយសូត្រធ្វើយសតិប្បដ្ឋាននោះ មានរាជរថ ៦ គ្រឿង ដែលតុបតែងដោយអលង្ការគ្រប់យ៉ាង រថមួយៗ មានប្រវែង ១៥០ យោជន៍ ទឹមដោយសេះសិន្ធព ១០០០ មកអំពីទេវលោកទាំង ៦ ជាន់ ។ ទេវតាដែលឈរនៅលើរថទាំងនោះ ម្នាក់ៗ បានពោលអញ្ជើញថា ខ្ញុំនឹងនាំលោកទៅកាន់ទេវលោករបស់ខ្ញុំៗ ម្នាលលោកដ៏ចម្រើន លោកចូរកើតក្នុងទីនេះ ដើម្បីសេចក្តីត្រេកអរក្នុងទេវលោករបស់ខ្ញុំ ដូចបុគ្គលទម្លាយកាជនៈដី

ហើយកាន់យកភាជនៈមាស ។ គ្រានោះ ធម្មិកឧបាសក មិនត្រូវការ
ឲ្យខូចការស្តាប់ព្រះធម៌ ទើបពោលឡើងថា លោកទាំងឡាយចូរអង់ចាំ
បន្តិចសិន ។ ពេលនោះ ភិក្ខុទាំងឡាយ កាលបើឮដូច្នោះហើយ ទើប
នាំគ្នាឈប់ស្វាធ្យាយព្រះធម៌ ដោយយល់ថា ធម្មិកឧបាសកនិយាយ
ជាមួយនឹងពួកយើង ។ ខណៈនោះ កូនប្រុស និងកូនស្រីរបស់ធម្មិក-
ឧបាសកគិតថា ពីមុនឪពុករបស់ពួកយើង មិនចេះឆ្អែតឆ្អន់ក្នុងការ
ស្តាប់ព្រះធម៌ តែមកដល់គ្រានេះ ឲ្យនិមន្តភិក្ខុទាំងឡាយមកស្វាធ្យាយ
ព្រះធម៌ ហើយបែរមកជាពោលហាមដោយខ្លួនឯងទៅវិញ ឈ្មោះថា
សត្វមិនខ្វាចស្ងាប់មិនមានឡើយ ហើយនាំគ្នាស្រែកយំ ។ លំដាប់នោះ
ភិក្ខុទាំងឡាយប្រឹក្សាគ្នាថា ឥឡូវនេះ មិនមានឱកាសដើម្បីស្វាធ្យាយ
ព្រះធម៌ ហើយទើបបាននាំគ្នាចុះអំពីអាសនៈ និមន្តត្រឡប់ទៅវត្តវិញ ។

ចំណែកធម្មិកឧបាសក បានស្ងប់ស្ងៀមនៅមួយសន្ទុះ ទើបត្រឡប់
មានសតិឡើងវិញ ហើយសួរកូនៗ ថា ព្រោះហេតុអ្វី ទើបពួកកូន
ទ្រហោយំ ដូច្នេះ ? គ្រានោះ ពួកកូនៗ ឆ្លើយថា លោកឪពុកឲ្យនិមន្ត

ភិក្ខុសង្ឃមកដើម្បីស្វាធ្យាយព្រះធម៌ ហើយខណៈដែលលោកឪពុកកំពុងតែស្តាប់ព្រះធម៌នោះ លោកឪពុកបាននិយាយហាមភិក្ខុមិនឲ្យស្វាធ្យាយព្រះធម៌ដោយខ្លួនឯង កាលបើឃើញដូច្នោះ កូនទាំងឡាយ ទើបនាំគ្នាយល់ថា ឈ្មោះថាសត្វដែលមិនខ្ចាចស្ងាប់មិនមាន ហើយបានជានាំគ្នាទ្រហោយំ ។ គ្រានោះ ធម្មិកឧបាសកសួរថា តើលោកម្ចាស់ទាំងឡាយនិមន្តទៅណាហើយ ? ពួកកូនៗ ឆ្លើយថា លោកឪពុក លោកម្ចាស់ទាំងឡាយមានថេរវាចាថា ឥឡូវនេះ មិនមានឱកាស ដើម្បីស្វាធ្យាយព្រះធម៌ទៀតឡើយ ទើបនាំគ្នាក្រោកឡើងពីអាសនៈនិមន្តចេញទៅបាត់ហើយ ។ ពេលនោះ ទើបធម្មិកឧបាសកជ្រាបថា ឪពុកមិនបានពោលជាមួយនឹងលោកម្ចាស់ទាំងឡាយនោះទេ ។ ពួកកូនៗ សួរថា បើដូច្នោះ លោកឪពុកនិយាយជាមួយអ្នកណាទៅវិញ ? ធម្មិកឧបាសកនិយាយរឿងដែលកើតឡើងទាំងនោះ ឲ្យកូនបានស្តាប់ថា មានទេវតាតុបតែងវេ ៦ គ្រឿងមកអំពីទេវលោកទាំង ៦ ជាន់ នៅលើអាកាស ហើយនាំគ្នាស្រែកហៅមកថា សូមលោកត្រេកអរក្នុងទេវលោករបស់ខ្ញុំៗ ឪពុកបាននិយាយ

ជាមួយនឹងទេវតាទាំងនោះទេតើ មិនបាននិយាយជាមួយនឹងលោកម្ចាស់ទាំងឡាយទៀយ ។ ពួកកូនៗ សួរថា រថទាំងអស់នោះនៅឯណា ពួកខ្ញុំមិនឃើញសោះ ? ធម្មិកឧបាសកសួរពួកកូនថា ផ្កាឈើដែលក្រងជាកម្រងទុកដើម្បីពុកមានទេកូន ? ពួកកូនៗ ពោលតបថា មានលោកឪពុក ។ ធម្មិកឧបាសកសួរពួកកូនៗ តទៅទៀតថា ពួកកូនអាចដឹងបានទេថា ទេវលោកជាន់ណាជាទីមនោរម ? គ្រានោះ ពួកកូនៗ តបថា លោកឪពុកទេវលោកជាន់តុសិត ដែលជាទីប្រថាប់នៅរបស់ព្រះពោធិសត្វគ្រប់ៗ អង្គ របស់ព្រះពុទ្ធមាតា និងរបស់ព្រះពុទ្ធបិតាជាទីមនោរម ។ ពេលនោះ ទើបធម្មិកឧបាសកពោលណែនាំពួកកូនៗ ទាំងនោះថា បើយ៉ាងនោះពួកកូនចូរពោលថា សូមឲ្យកម្រងផ្កាឈើនេះទៅប្រតិស្ឋាននៅត្រង់រថ ដែលមកអំពីស្ថានតុសិត ហើយបានបោះកម្រងផ្កាឡើងទៅ ។ ពួកកូនៗ បានពោលហើយ ក៏បោះកម្រងផ្កាឡើងទៅ កម្រងផ្កានោះបានទៅព្យួរត្រង់ចន្ទោលនៃរថ សំយុងអណ្តែតប្រាកដនៅក្នុងអាកាស ។

គ្រានោះ មហាជនបានឃើញត្រឹមតែកម្រងផ្កា តែមិនបានឃើញ

រថ ។ ពេលនោះ ទើបធម្មិកឧបាសកសួរថា កម្រងផ្កានោះកូនបានឃើញឬទេ ? ពពួកកូនៗ ទាំងនោះពោលតបថា ឃើញលោកឪពុក ។ ធម្មិកឧបាសកទើបប្រាប់ដល់កូនៗ ទាំងនោះថា កម្រងផ្កានោះសំយុងនៅត្រង់រថ ដែលមកអំពីស្ថានតុសិត ឪពុកនឹងទៅកាន់ស្ថានតុសិត ពួកកូនៗ កុំបារម្ភឡើយ បើពួកកូនមានសេចក្តីប្រាថ្នាចង់ទៅកើតនៅក្នុងសម្នាក់របស់លោកឪពុក ក៏ចូរធ្វើបុណ្យផ្សេងៗ តាមលំអានដែលឪពុកធ្វើហើយចុះ កាលធម្មិកឧបាសកបានពោលប្រាប់ដល់ពួកកូនទាំងនោះដូច្នេះហើយ ក៏អស់ជីវិតទៅ ហើយទៅកើតត្រង់រថដែលមកអំពីស្ថានតុសិត ។ អត្តភាពរបស់ធម្មិកទេវបុត្រកម្ពស់ប្រមាណ ៣គាវុត ប្រដាប់ដោយគ្រឿងអលង្ការទម្ងន់ ៣ រទេះ បានកើតឡើងក្នុងមួយរំពេចនោះឯង មានស្រីទេពអប្សរ ១០០០ រៃហាម ហើយមានវិមានកែវប្រមាណ ២៥ យោជន៍ប្រាកដឡើង ។ ព្រះមានបុណ្យត្រាស់សួរកិក្ខុទាំងឡាយដែលបាននិមន្តទៅកាន់ផ្ទះធម្មិកឧបាសក ហើយបាននិមន្តត្រឡប់មកដល់វិហារវិញថា ម្នាលកិក្ខុទាំងឡាយ ធម្មិកឧបាសកបានស្តាប់ព្រះធម៌

ហើយឬ ? ភិក្ខុទាំងឡាយក្រាបទូលតបថា បានស្តាប់ហើយ ព្រះអង្គ តែក្នុងខណៈដែលធម្មិកឧបាសកកំពុងតែស្តាប់ព្រះធម៌នោះ គាត់ក៏បានពោលហាមថា សូមអ្នកទាំងឡាយរង់ចាំសិនចុះ លំដាប់នោះ ពួកកូនប្រុសស្រីរបស់ធម្មិកឧបាសក បាននាំគ្នាស្រែកទ្រហោយំឡើងមក ទើបពួកខ្ញុំព្រះករុណាប្រឹក្សាគ្នាថា ឥឡូវនេះមិនមានឱកាសដើម្បីស្វាធ្យាយព្រះធម៌តទៀតឡើយ ទើបនាំគ្នាក្រោកចាកអាសនៈនិមន្តត្រឡប់មកវិញ ។ គ្រានោះ ព្រះលោកនាថត្រាស់ចង្អុលបង្ហាញថា ម្នាលភិក្ខុទាំងឡាយ ធម្មិកឧបាសកមិនបានពោលជាមួយពួកអ្នកទេ តែមានទេវតារៀបចំរថទាំង ៦ មកអំពីទេវលោកទាំង ៦ ជាន់ ដើម្បីមកអញ្ជើញធម្មិកឧបាសក គេមិនត្រូវការឲ្យខូចការស្តាប់ព្រះធម៌ ទើបបាននិយាយច្រាប់ទេវតាទាំងនោះ ។ ទើបភិក្ខុទាំងឡាយក្រាបទូលថា យ៉ាងនោះឬ ព្រះអង្គ ? ព្រះសម្ពុទ្ធត្រាស់ថា យ៉ាងនោះឯងភិក្ខុ ។ ពេលនោះ ភិក្ខុទាំងឡាយត្រូវការនឹងជ្រាបដល់ស្ថានទីដែលធម្មិកឧបាសកត្រូវទៅកើត ទើបក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ធម្មិកឧបាសកបានទៅ

កើតក្នុងទីណា ព្រះអង្គ ? ព្រះភគវាគ្រាស់តបថា ម្នាលភិក្ខុទាំងឡាយ ធម្មិកឧបាសក បានទៅកើតក្នុងស្ថានតុសិតហើយ ។ ភិក្ខុទាំងឡាយ ក្រាបទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មិកឧបាសកជាអ្នកក្បៀវក្លាក្នុងចំណោមពពួកញាតិនៅក្នុងលោកនេះ ពេលស្លាប់អំពីលោកនេះទៅហើយ នៅតែទៅកើតក្នុងទីកន្លែងរីករាយ យ៉ាងនោះទៀតឬ ព្រះអង្គ ? គ្រានោះ ព្រះមហាវីរៈត្រាស់ថា យ៉ាងនោះហើយភិក្ខុ ព្រោះបុគ្គលដែលមិនប្រមាទហើយ ជាគ្រហស្ថក៏ដោយ ជាបព្វជិតក៏ដោយ រមែងរីករាយក្នុងទីទាំងពួងយ៉ាងនោះឯង កាលព្រះពុទ្ធអង្គត្រាស់ដូច្នេះហើយ ទើបបានត្រាស់ព្រះគាថាថា

អ្នកដែលធ្វើបុណ្យទុកមកហើយ រមែងត្រេកអរក្នុងសុគតិភពសប្បាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះផង រីករាយក្នុងលោកខាងមុខផង គេរមែងត្រេកអរក្នុងសុគតិភពសប្បាយ ព្រោះឃើញនូវកម្មដ៏បរិសុទ្ធរបស់ខ្លួន ។

នៅក្នុងព្រះគាថានេះ ព្រះអដ្ឋកថាចារ្យ បានអធិប្បាយអត្ថន័យ

នៃព្រះគាថានេះទុកថា អ្នកដែលធ្វើបុណ្យកុសលផ្សេងៗ ទុកមកហើយ រមែងរីករាយ ដោយសេចក្តីរីករាយ ព្រោះការធ្វើក្នុងលោកនេះថា អំពើអាក្រក់យើងមិនបានធ្វើទុកឡើយ សេចក្តីល្អយើងបានធ្វើទុកហើយ គេរមែងរីករាយដោយសេចក្តីរីករាយ ព្រោះផលល្អរបស់គេ ទាំងនេះ ឈ្មោះថា រមែងរីករាយក្នុងលោកទាំងពីរ ។

សូម្បីធម្មិកឧបាសក បានសម្លឹងឃើញកម្មដ៏បរិសុទ្ធ គឺការដល់ព្រមនៃបុញ្ញកម្មរបស់ខ្លួន មុនពេលដែលនឹងស្លាប់ទៅ គេរមែងរីករាយក្នុងលោកនេះ លុះដល់ពេលគេស្លាប់ទៅហើយ ក៏រមែងទៅរីករាយក្នុងលោកខាងមុខទៀត ។

ក្នុងពេលដែលព្រះមុនីត្រាស់ព្រះគាថានេះចប់ មានពុទ្ធបរិស័ទជាច្រើនបានជាព្រះអរិយបុគ្គល មានសោតាបត្តិផលជាដើម ។ ការសម្តែងព្រះធម៌ក្នុងពេលនោះ ក៏បានជាប្រយោជន៍ដល់មហាជនជាច្រើន ដោយអ្នកខ្លះបានដល់ព្រះរតនត្រ័យ ជាទីពឹង ជាទីរឭក អ្នកខ្លះទៀត ក៏ដល់ព្រមទៅដោយសទ្ធាជាដើម ។

(ជីវប្រវត្តិរបស់ធម្មិកឧបាសក ចប់)

✍ ជីវប្រវត្តិរបស់នន្ទិយឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

នន្ទិយឧបាសក ជាឧបាសកគំរូផ្នែកខាងកសាងសាលាមានមុខ ៤ ដើម្បីឧទ្ទិសថ្វាយដល់កិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ ទាំងជាអ្នកពេញចិត្តក្នុងការទំនុកបម្រុងកិក្ខុសង្ឃជានិច្ច ថែមទាំងគាត់បានធ្វើជីវិតរបស់គាត់ឲ្យប្រព្រឹត្តទៅនៅក្នុងកុសលជារឿយៗ ទៀតផង ។

ជីវប្រវត្តិរបស់នន្ទិយឧបាសក មានសម្តែងទុកនៅក្នុង ***អដ្ឋកថាធម្មបទ*** *នៃ* ***បិយវគ្គ*** *ក្នុង* ***រឿងនន្ទិយឧបាសក*** *និងនៅក្នុង* ***អដ្ឋកថាបរមត្ថទីបនី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលី* ***វេតវិមាន*** *នៅក្នុង* ***គម្ពីរខុទ្ទកនិកាយ វិមានវត្ថុ*** *ដូចមានសេចក្តីថា ៖*

កាលព្រះមហាវីរៈ គង់ប្រថាប់នៅក្នុងព្រៃឥសិបតនមិគទាយវន បានត្រាស់ព្រះធម្មទេសនា ដោយទ្រង់ប្រារព្ធនន្ទិយៈថា នន្ទិយៈជាបុត្ររបស់ត្រកូល ដែលជាអ្នកជល់ព្រមទៅដោយសទ្ធា ក្នុងព្រះសាសនានេះ

នៅក្នុងក្រុងពារាណសី ។ គេជាអ្នកសម្បូរទៅដោយសទ្ធា ក្នុងការជ្រះថ្លាទំនុកបម្រុងភិក្ខុសង្ឃ ដោយតាំងចិត្តប្រព្រឹត្តទៅតាមគំរូរបស់មាតាបិតារបស់គេ ។ កាលនន្ទិយៈចម្រើនវ័យធំដឹងក្តីហើយ មាតាបិតារបស់គេមានបំណងទៅនាំយកកូនស្រីក្រមុំម្នាក់ ដែលជាកូនស្រីរបស់អ៊ំឈ្មោះថា **វេតី** ដើម្បីឲ្យមកធ្វើជាភរិយារបស់នន្ទិយៈកូនប្រុសរបស់ខ្លួន ។ តែនាងវេតីជាស្រីមិនមានសទ្ធា មិនចូលចិត្តចំពោះការឲ្យទាន ទើប **នន្ទិយៈ** មិនត្រូវការយកមកធ្វើជាគូគ្រង ។ ទើបមាតារបស់នន្ទិយៈ បានណែនាំនាងវេតីថា នាងមកនៅក្នុងផ្ទះនេះ នាងត្រូវតែយកចិត្តទុកជាក់ចំពោះភិក្ខុសង្ឃ មានការក្រោលអាសនៈទុកសម្រាប់ភិក្ខុសង្ឃ ចូរតាំងជើងបាត្រហើយក្នុងពេលដែលភិក្ខុសង្ឃទាំងឡាយនិមន្តមកដល់ នាងចូរថ្វាយបង្គំទទួលបាត្រ និមន្តលោកឲ្យគង់ យកធម្មក្រកត្រង៏ទឹកឆាន់ប្រគេនលោក ហើយនាងចូរលាងបាត្រ ក្នុងពេលដែលភិក្ខុសង្ឃឆាន់ស្រេចហើយ កាលនាងធ្វើបានយ៉ាងនេះ នាងក៏ជាទីស្រឡាញ់ពេញចិត្តរបស់នន្ទិយៈកូនប្រុសរបស់យើង ។ នាងវេតីក៏បានធ្វើតាមពាក្យប្រៀនប្រដៅនោះ ។ កាល

តមក មាតាបិតារបស់នន្ទិយៈ បាននិយាយដល់ការប្រព្រឹត្តរបស់នាងវេតី ឲ្យកូនប្រុសបានស្តាប់ថា នន្ទិយៈ នាងវេតីជាអ្នកអត់ធន់ ជាអ្នកទទួលការប្រៀនប្រដៅបានងាយទៀតផង ។កាលនន្ទិយៈពោលទទួលថា ល្អហើយ មាតាបិតារបស់នន្ទិយៈ ទើបកំណត់ថ្ងៃ ហើយធ្វើវិធីអាវាហមង្គលរវាងនន្ទិយៈ និងនាងវេតី ។ កាលនោះនន្ទិយៈពោលទីឆនាងវេតីថា បើនាងទំនុកបម្រុងកិក្ខុសង្ឃ និងឪពុកម្តាយរបស់យើងបាន នាងនឹងបានជាអ្នកមើលការខុសត្រូវក្នុងផ្ទះនេះ ហេតុដូច្នេះ នាងចូរជាអ្នកមិនមានសេចក្តីប្រមាទចុះ ។

គ្រានោះ នាងវេតីទទួលពាក្យថា បាន ហើយនាងក៏ជាអ្នកមានសទ្ធាគ្រប់ពេលវេលា ដោយប្រព្រឹត្តទៅតាមស្វាមីរបស់ខ្លួនឲ្យធ្វើយ៉ាងណាក៏ធ្វើតាមដែរ ។ កាលនាងវេតីនៅគ្រប់គ្រងផ្ទះ ដោយនៅរួមជាមួយនន្ទិយៈ មករហូតប្រសូតបានបុត្រ ២ មាតាបិតារបស់នន្ទិយៈក៏ស្លាប់ទៅ ។ ភាពជាធំទាំងអស់នៅក្នុងផ្ទះនោះ ក៏ធ្លាក់ទៅលើនាងវេតីតែម្នាក់ ។ ចាប់តាំងអំពីមាតាបិតារបស់នន្ទិយៈស្លាប់ទៅហើយ នន្ទិយៈក៏បានជាមហាទានបតី

បានត្រៀមក្នុងការថ្វាយទានដល់កិក្ខុសង្ឃ និងបានតាំងអាហារសម្រាប់ឲ្យដល់អ្នកសម្បត់ទុគ៌ត និងអ្នកធ្វើដំណើរផ្លូវឆ្ងាយជាដើម ទុកនៅត្រង់ទ្វារផ្ទះរបស់ខ្លួន ។ ក្នុងកាលតមក នន្ទិយៈបានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា គេកំណត់អានិសង្សក្នុងការថ្វាយអាវាសបានហើយទើបគេឲ្យកសាងសាលាមុខ ៤ ប្រកបដោយបន្ទប់ ៤ ក្នុងមហាវិហារនៅក្នុងព្រៃឥសិបតនៈ ហើយឲ្យរៀបចំគ្រែ និងតាំងជាដើម កាលគេនឹងវេរថ្វាយអាវាសនោះ គេបានថ្វាយមហាទានដល់កិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយគេបានច្រូចទឹកទក្ខិណោទក ចុះទៅលើព្រះហស្តព្រះមានជោគ ។ ខណៈនោះ ប្រាសាទទិព្វ វិចិត្រទៅដោយកែវទាំង ៧ ប្រការ ទំហំ ១២ យោជន៍ កម្ពស់ ១០០ យោជន៍ បានផុសឡើងនៅក្នុងស្ថានតាវត្តិង្ស ដែលដេរដាសដោយពពួកស្រីទេពអប្សរ ១០០០ នាក់ ជំណាលគ្នានឹងការច្រូចទឹកទក្ខិណោទក ចុះទៅលើព្រះហស្តរបស់ព្រះលោកនាយកនោះឯង ។ មូលហេតុដែលឲ្យជើងរឿងក្នុងការកើតឡើងនៃប្រាសាទទិព្វនោះ ទាក់ទងមកអំពីថ្ងៃមួយ ព្រះមហាមោគ្គល្លានបាន

និមន្តទៅកាន់ទេវលោក លុះទៅបានដល់ស្ថានតាវត្តិង្ស បានទៅឈរនៅជិតប្រាសាទនោះ ទើបសួរពួកទេវបុត្រទាំងឡាយ ដែលនាំគ្នាមកថ្វាយបង្គំលោកថា **ប្រាសាទទិព្វនេះ** ដែលពេញដេរដាសទៅដោយពួកនាងស្រីទេពអប្សរ កើតឡើងហើយ ដើម្បីអ្នកណា ? គ្រានោះ ទេវបុត្រទាំងឡាយ បាននាំគ្នានិយាយប្រាប់អំពីឈ្មោះរបស់ម្ចាស់វិមាននោះឲ្យដល់ព្រះថេរៈបានជ្រាប ទើបបានពោលថាបពិត្រលោកម្ចាស់ដ៏ចម្រើន ប្រាសាទទិព្វនោះកើតឡើងហើយដើម្បីប្រយោជន៍ដល់បុត្ររបស់គហបតីឈ្មោះនន្ទិយៈ ដែលបានឲ្យគេកសាងសាលាមុខ ៤ ឡើង ទុកនៅក្នុងព្រៃឥសិបតនមិគទាយវ័ន ក្នុងក្រុងពារាណសី ថ្វាយដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។

ចំណែកពួកនាងស្រីទេពអប្សរ បានក្រឡេកឃើញព្រះថេរៈហើយនាំគ្នាចុះមកអំពីប្រាសាទទិព្វ មកថ្វាយបង្គំព្រះថេរៈ ហើយពិតថា បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំម្ចាស់កើតនៅក្នុងទីនេះ ដោយសង្ឃឹមថាបានមកបម្រើនន្ទិយទេវបុត្រ តែកាលពួកខ្ញុំម្ចាស់ មិនបានជួបនន្ទិយៈ

ក៏អផ្សុកណាស់ ព្រោះថា សម្បត្តិនៅក្នុងទេវលោក រមែងជាទីរីករាយ
នៃចិត្ត ដូចគ្នានឹងទម្លាយកាជនៈដី ហើយកាន់យកកាជនៈមាស ដូច្នោះ
បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាជ្រាបន្ទិយៈ ដើម្បី
ឲ្យគាត់មកនៅក្នុងទីនេះផង ។ ព្រះមហាមោគ្គល្លានទទួលពាក្យថា សាធុ
ទើបលោកត្រឡប់មកអំពីទេវលោក ហើយចូលទៅគាល់ព្រះមានជោគ
ជៃមទាំងបានក្រាបទូលសួរនៅក្នុងកណ្តាលជំនុំបរិស័ទនោះថា បពិត្រ
ព្រះអង្គដ៏ចម្រើន ទិព្វសម្បត្តិរមែងកើតឡើងដល់ចាំបុគ្គលដែលបានធ្វើ
សេចក្តីល្អ ដែលនៅក្នុងមនុស្សលោកនេះដែរឬ ព្រះអង្គ ? គ្រានោះ
ព្រះសម្ពុទ្ធត្រាស់តបថា ម្នាលមោគ្គល្លាន ទិព្វសម្បត្តិដែលកើតឡើង
ហើយដល់នន្ទិយៈនៅក្នុងទេវលោក គឺអ្នកបានឃើញដោយខ្លួនឯងហើយ
មិនមែនឬ ? ហេតុអ្វី ទើបអ្នកមកសួរតថាគត ដូច្នេះ ។ ពេលនោះ
ព្រះមហាមោគ្គល្លានក្រាបទូលសួរថា ទិព្វសម្បត្តិកើតឡើង បានយ៉ាង
នោះឬ ព្រះអង្គ ? លំដាប់នោះ ព្រះលោកនាថត្រាស់នឹងព្រះថេរៈថា
ម្នាលមោគ្គល្លាន អ្នកនិយាយថ្វី ដូចជាបុគ្គលអ្នកឈរនៅត្រង់ទ្វារផ្ទះ

បានឃើញកូន ឬបងប្អូន ដែលបែកទៅក្នុងកន្លែងផ្សេងៗ អស់កាលជ័យូរ ហើយត្រឡប់មកកាន់ទឹកដីកំណើត ដែលធ្លាប់រស់នៅ ទើបប្រញាប់មកឯផ្ទះ ហើយប្រាប់ពពួកញាតិ និងមិត្រឲ្យជ្រាបថា បុគ្គលឈ្មោះនោះមកហើយ កាលបើដូច្នោះ ពពួកញាតិរបស់គេនោះក៏រីករាយប្រញាប់រួតរះចេញទៅទទួលថា ពុកមកហើយៗ យ៉ាងណា ។ ទេវតាទាំងឡាយ តែងកាន់បណ្ណាការទិព្វ ១០ យ៉ាង មកទទួលដោយគិតថា ខ្ញុំទៅមុនៗ ហើយរមែងត្រេកអរក្រៃលែងចំពោះស្ត្រី ឬបុរសដែលជាអ្នកបានធ្វើបុណ្យទុកនៅក្នុងលោកនេះ ហើយលះចាកលោកនេះទៅកាន់លោកខាងមុខយ៉ាងនោះ ដូចគ្នា ហើយព្រះសម្ពុទ្ធទ្រង់ត្រាស់ព្រះគាថាទាំងនេះថា

ញាតិមិត្រ និងបុគ្គលទាំងឡាយ ដែលមានចិត្តល្អឃើញបុរសដែលទៅកាន់ទឹកដីផ្សេងៗ អស់កាលជ័យូរ ហើយត្រឡប់មកអំពីទីទៅដោយសួស្តី រមែងត្រេកអរក្រៃលែងថា មកហើយយ៉ាងណា ។ បុគ្គលទាំងឡាយ ក៏រមែងទទួលបុគ្គល ដែលបានធ្វើបុណ្យទុក ដែលទៅអំពី

លោកនេះ កាន់លោកខាងមុខ ជូចជាពពួកញាតិ ទទួលញាតិដែលខ្លួនស្រឡាញ់ ដែលត្រឡប់មកដល់ហើយ ដូច្នោះ ។

ពេលដែលព្រះលោកនាថ ទ្រង់ត្រាស់ព្រះធម៌ទេសនានេះចប់ មានមហាជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានថ្នាក់ព្រះសោតាបត្តិផលជាដើម ទៅតាមវាសនាបារមីរៀងៗ ខ្លួន ។

ចំណែកជីវប្រវត្តិរបស់នន្ទិយឧបាសក ដែលមានសម្តែងនៅក្នុង ***អដ្ឋកថាបរមត្ថទីបនី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីក្នុង* ***វេតវិមាន*** *ក្នុង* ***គម្ពីរខុទ្ទនិកាយ វិមានវត្ថុ*** *ដូចមានសេចក្តីថា ៖*

កាលនន្ទិយៈបានស្តាប់ព្រះគាថា របស់ព្រះមហាវីរៈដូច្នេះហើយ បានឲ្យទាន ធ្វើបុណ្យកុសលយ៉ាងច្រើនក្រៃលែងឡើងទៀត ហើយពេលដែលគេត្រូវទៅជួញដូរ គេបានផ្តាំជាមួយនឹងនាងវេតីទុកថា នែប្រពន្ធជាទីស្រឡាញ់ នាងកុំភ្លេចក្នុងការឲ្យទានចំពោះភិក្ខុសង្ឃ ឬការឲ្យទានដល់មនុស្សអនាថា ដូចដែលខ្ញុំបានធ្វើមកហើយឲ្យសោះ ។ ចំណែកនាងវេតីបានទទួលព្រមជាមួយនឹងស្វាមីថា បានបង ។ នន្ទិយឧបាសក

មិនថាគេនិងធ្វើដំណើរទៅដល់ទីណាៗ ទេ គេក៏តែងតែបានថ្វាយទាន
ចំពោះភិក្ខុសង្ឃទាំងឡាយ និងឲ្យទានដល់មនុស្សអនាថាទាំងឡាយ
តាមសមគួរជាមួយនឹងទ្រព្យសម្បត្តិ ដែលគេមានជាប់នឹងខ្លួនជានិច្ចនោះ។
គ្រាមួយ ព្រះខីណាស្រពទាំងឡាយក៏បាននិមន្តមកអំពីទីឆ្ងាយ ដើម្បី
មកទទួលទេយ្យធម៌របស់នទ្ទិយឧបាសក ។ ចំណែកនាងវេតី ក្រោយ
អំពីនទ្ទិយឧបាសក ចេញដំណើរទៅជួញដូរហើយ នាងបានឲ្យទាន
ត្រឹម ២-៣ ថ្ងៃប៉ុណ្ណោះ ហើយនាងបានឈប់ឲ្យទានដល់មនុស្សអនាថា
ចំណែកការឲ្យទាន ចំពោះភិក្ខុសង្ឃនាងនៅធ្វើ តែនាងធ្វើដោយការ
ប្រគេនបបរចុងអង្ករ ផ្សំនឹងស្ករ មានទឹកជ្រក់ជាគម្រប់ពីរ ហើយក្រៅ
អំពីនោះ នាងបានយកគ្រាប់ចាយ ដែលសល់អំពីខ្លួនបរិភោគ លាយ
ជាមួយសាច់ត្រី និងសាច់ដែលមានឆ្អឹងលាយ ចោលរាយពាសពេញ
ក្នុងស្ថានទីដែលភិក្ខុសង្ឃទាំងឡាយមកគង់ឆាន់ចង្ហាន់ ហើយនាងបាន
ប្រាប់ដល់មនុស្សទាំងឡាយទូទៅថា អ្នកទាំងឡាយ ចូរមើលការធ្វើ
របស់ពួកសមណៈៗ ទាំងនេះ បានចោលរបស់របរ ដែលគេប្រគេន

ដោយសទ្ធាយ៉ាងនេះទៅវិញ ។ កាលនន្ទិយឧបាសកសម្រេចការជួញដូរ បានចំណេញហើយត្រឡប់មកផ្ទះវិញ គេបានជ្រាបការប្រព្រឹត្តទៅក្នុងផ្ទះមិនល្អ របស់នាងវេតីដូច្នោះហើយ ទើបគេបណ្តេញនាងឲ្យចុះចេញអំពីផ្ទះទៅ ។ លុះដល់ព្រឹកឡើង នន្ទិយឧបាសកបានរៀបចំថ្វាយមហាទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបានផ្តើមថ្វាយទានជាប្រចាំថ្ងៃ និងឲ្យទានដល់មនុស្សអនាថាទាំងឡាយ តាមដែលខ្លួនធ្លាប់ធ្វើរួចមកហើយ ។

ចំណែកនាងវេតី ដែលត្រូវនន្ទិយៈបណ្តេញឲ្យចុះចេញអំពីផ្ទះទៅ គេបានឲ្យត្រីមជាយស៊ី និងសំពត់ស្បៀកប៉ុណ្ណោះ ។ ក្នុងកាលតមក ពពួកសម្លាញ់របស់នន្ទិយៈ បាននាំនាងវេតីឲ្យត្រឡប់មកវិញ ដោយការនិយាយឲ្យស្រុះស្រួលគ្នាដូចដើម កាលនន្ទិយៈព្រមទទួល គេក៏បានតាំងឲ្យនាងវេតីជាធំ ក្នុងការផ្គត់ផ្គង់ទាក់ទងនឹងរឿងអាហារ ។ កាលកន្លងខាងក្រោយ នន្ទិយៈស្លាប់ទៅហើយ គេបានទៅកើតក្នុងវិមានរបស់គេ នៅក្នុងស្ថានតាវត្តិង្ស ។ ចំណែកនាងវេតី កាលបើស្វាមី

អស់ជីវិតទៅហើយ ក៏ឈប់ឲ្យទានគ្រប់យ៉ាង ហើយថែមទាំងដើរជេរប្រទេចចំពោះភិក្ខុសង្ឃ ដោយយល់ថា ខ្ញុំវិនាសចាកលាភសក្ការៈព្រោះតែពួកសមណៈទាំងអស់នេះឯង ។ គ្រានោះ ស្តេចវេស្សវ័ណបានបញ្ជាឲ្យយក្ខពីរនាក់ថា លោកទាំងពីរចូរទៅស្រែកប្រកាសនៅក្នុងក្រុងពារាណសី ឲ្យមហាជនបានឮថា រាប់អំពីថ្ងៃនេះទៅ ៧ ថ្ងៃទៀត នាងវេតីត្រូវនាំទម្លាក់ទៅក្នុងនរកទាំងរស់ ។ កាលមហាជនបានស្តាប់ឮពាក្យប្រកាសដូច្នេះហើយ ក៏នាំគ្នាកើតមានសេចក្តីសង្វេគ ទាំងមានការភ័យខ្លាច កាលនាងវេតីជ្រាបដំណឹងយ៉ាងនេះហើយ គេបានគេចឡើងទៅនៅលើប្រាសាទបិទទ្វារយ៉ាងជិត ហើយអង្គុយនៅក្នុងប្រាសាទនោះ ។ លុះដល់ថ្ងៃទី ៧ យក្ខទាំងពីរនាក់នោះ មានសក់ និងពុកមាត់ក្រហម មានច្រមុះវៀចខុសប្រក្រតី មានចង្កឹមស្រួច មានភ្នែកក្រហម មានសម្បុរដូចជ័រស្រស់ មានរូបកាយគួរឲ្យព្រឺខ្លាច ដោយស្តេចវេស្សវ័ណ ដែលត្រូវបាបរបស់នាងវេតី បានបណ្តាលឲ្យចិត្តត្រាស់បញ្ជាឲ្យពួកយក្ខទាំងពីរនាក់នោះ ទៅប្រាប់នាងវេតីថា ក្រោក

ឡើងមកនាងវេតីដ៏លាមកថោកទាប ហើយចូរពួកអ្នកជួយគ្នាចាប់ដៃជើងទាំងសងខាងប្រកាសថា សូមឲ្យមហាជនមើល ហើយធ្វើឲ្យនាងជួលត្រឡប់ត្រឡិន ហើយនាំទៅអំពីថ្នល់មួយ ទៅកាន់ថ្នល់មួយទៀត រហូតទូទាំងក្រុងពារាណសី ហើយពួកគេក៏នាំនាងវេតីហោះទៅឯស្ថានតាវត្តិង្សឲ្យនាងបានឃើញវិមាន និងសម្បត្តិរបស់នទ្ធិយឧបាសកហើយក៏បានបញ្ជូននាង ដោយនាងកំពុងតែយំរៀបរាប់ចោះទៅក្នុងឧស្សទនរក។ ពពួកនាយនិរយបាលរបស់ស្តេចយមរាជ ក៏បានជួយគ្នាចាប់នាងវេតីចោះចូលទៅក្នុងឧស្សទនរក ដែលពោរពេញទៅដោយលាមក និងទឹកមូត្រជាច្រើន ។

ម្យ៉ាងទៀត មានពាក្យពោលរវាងយក្ខទាំងពីរ និងនាងវេតី តាមដែលមានសម្តែងប្រាកដនៅក្នុងព្រះបាលី **វេតវិមាន** នៅក្នុង **គម្ពីរខុទ្ទកនិកាយ វិមានវត្ថុ** ដូចមានសេចក្តីថា ៖

យក្ខទាំងពីរនាក់នោះ បានពោលជាមួយនឹងនាងវេតីថា ក្រោកឡើងមកនាងវេតីដ៏លាមកថោកទាប ដែលមិនព្រមបិទទ្វារនរក (គឺ

ដោយអំពើល្អ) ជាអ្នកមិនពេញចិត្តក្នុងការឲ្យទាន ខ្ជិនខ្ជឹនទាំនាងទៅកាន់ស្ថានទី ដែលពួកសត្វនរកទទួលនូវសេចក្តីទុក្ខ ត្រូវអត់ធន់ទ្រាំចំពោះសេចក្តីទុក្ខទាំងនោះ ដែលកើតមកអំពីអំពើបាប ។ យក្ខធំមានភ្នែកក្រហមទាំងពីរនោះ បាននោលដូច្នេះហើយ ទើបចាប់ដៃជើងរបស់នាងវេតីម្នាក់ម្ខាងទាំនាងទៅកាន់ស្ថានទេវលោក ។ ទើបនាងវេតីសួរយក្ខទាំងពីរនោះថា វិមានដំបូលស្អាត មានរស្មីភ្លឺស្វាងដូចជាព្រះអាទិត្យបញ្ចេញពន្លឺភ្លឺស្វាង ដែលគ្របដណ្តប់ដោយសំណាញ់មាស មានស្រីទេពអប្សរជេរជាសនោះ ជាវិមានរបស់អ្នកណា ? រុងរឿងដូចជាពន្លឺព្រះអាទិត្យ មានពពួកទេពនារីលាបវាងកាយដោយខ្លឹមចន្ទន៍ ធ្វើវិមានឲ្យស្រស់ស្អាតទាំងពីរផ្នែក វិមាននោះប្រាកដរស្មីដូចជាព្រះអាទិត្យ អ្នកណាជាអ្នករីករាយក្នុងវិមាននោះ ? គ្រានោះ យក្ខទាំងពីរនោះ បានប្រាប់ដល់នាងវេតីឲ្យបានជ្រាបថា នៅក្នុងក្រុងពារាណសី មានឧបាសកម្នាក់ឈ្មោះនន្ទិយៈ ជាអ្នកមិនកំណាញ់ ជាទានបតី ជាអ្នកជឿងពាក្យសម្តីរបស់អ្នកសុំទាន វិមានដែលមានស្រីទេពអប្សរច្រើន ដែលរុងរឿងដូច

ជាពន្លឺនៃព្រះអាទិត្យ ជារបស់នន្ទិយឧបាសកនោះឯង ពពួកនាងទេពនារី ដែលលាបស្រឡាបរាងកាយដោយទ្វីមចន្ទន៍ ដែលធ្វើឲ្យវិមាននោះល្អល្អះ ទាំងពីរផ្នែក ដែលវិមាននោះប្រាកដរស្មីដូចជាព្រះអាទិត្យ នន្ទិយឧបាសក ជាអ្នកវីកាយនៅក្នុងវិមាននោះ ។ គ្រានោះ ទើបនាងវេតីបានពោលអះអាងថា នាងខ្ញុំជាភរិយារបស់នន្ទិយៈ ជាម្ចាស់របស់ផ្ទះ ជាអ្នកធំក្នុងត្រកូល ឥឡូវនេះ នាងខ្ញុំត្រេកអរនៅក្នុងវិមានរបស់នន្ទិយៈ ដែលជាស្វាមី និងមិនប្រាថ្នា ដើម្បីចង់ឃើញនរកឡើយ ។

យក្ខទាំងពីរនោះ (បានស្តាប់នាងវេតីពោលដូច្នេះហើយ ទើបនាំនាងទៅជិតនរក ហើយពោលនឹងនាងថា នាងប្រាថ្នា ឬមិនប្រាថ្នាក៏ដោយ មិនមានប្រយោជន៍អ្វីដោយសេចក្តីប្រាថ្នារបស់នាង) ហើយពោលថា នែនាងដ៏លាមកថោកទាប នេះឯងនរករបស់នាង នាងមិនធ្វើបុណ្យក្នុងមនុស្សលោក ព្រោះជាបុគ្គលកំណាញ់ ជាអ្នកខឹងក្រោធ មានបាបធម៌ រមែងមិនបានការៈជាមួយនឹងអ្នកដែលកើតនៅក្នុងស្ថានសួគ៌ឡើយ ។ (កាលយក្ខទាំងពីរនោះ ពោលដូច្នេះហើយ បានអន្តរធាន

គឺបាត់ខ្លួនក្នុងទីនោះទុំៈឯង ចំណែកនាងវេតី បានក្រឡេកឃើញនាយនិរយបាលពីរនាក់ មានរូបរាងដូចគ្នាកំពុងអូសទាញនាង ដើម្បីដាក់ក្នុង**គូថនរក** ឈ្មោះថា ***សំសវកៈ***) ។ គ្រានោះ នាងវេតីសួរនិរយបាលថា លាមក ទឹកមូត្រ និងរបស់មិនស្អាត ដែលមានក្លិនស្អុយមហិមាផ្សាយទៅ ហៅឈ្មោះថាអ្វី ? ពេលនោះ នាយនិរយបាលពោលថា នរកនេះឈ្មោះថា សំសវកៈ ជម្រៅ ១០០ ជួរបុរស ជានរកដែលនាងត្រូវឆេះ នៅក្នុងទីនេះជាច្រើនពាន់ឆ្នាំ ។ នាងវេតីសួរថា ខ្ញុំធ្វើកម្មអាក្រក់អ្វីដោយកាយវាចាចិត្ត ទើបត្រូវមកធ្លាក់នៅក្នុងនរកសំសវកៈនេះ ដែលជម្រៅដល់ទៅ ១០០ ជួរបុរស ។ នាយនិរយបាលពោលថា នាងនិយាយកុហកបោកប្រាស ចំពោះសមណព្រាហ្មណ៍ និងស្វាមីយាចកទាំងឡាយ នាងធ្វើបាបទុកយ៉ាងនោះឯង ព្រោះបាបនោះ ទើបនាងត្រូវមកធ្លាក់នៅក្នុងសំសវកនរក ដែលមានជម្រៅ ១០០ ជួរបុរស នាងត្រូវឆេះនៅក្នុងនរកនេះអស់ច្រើនពាន់ឆ្នាំ នាយនិរយបាលទាំងឡាយ កាត់ដៃ និងជើង កាត់ស្លឹកត្រចៀក និងច្រមុះ ហើយនៅមានហ្វូងក្អែក មកចឹកស៊ីនាងៗ បម្រះនៀលទៅ

មក ។ នាងវេតីពោលថា មេត្តាចុះ សូមពួកលោកទាំងឡាយជួយនាំខ្ញុំត្រឡប់ទៅកាន់មនុស្សលោកវិញ ខ្ញុំនឹងតាំងចិត្តធ្វើបុណ្យ ឲ្យទានជាដើម **សមចរិយា** (ការប្រព្រឹត្តស្មើ) **សញ្ញមៈ** (ការសង្រួមក្នុងសីល) **និងទមៈ** (ការទូន្មានចិត្ត) ដែលបុគ្គលទាំងឡាយធ្វើហើយនឹងមានសេចក្តីសុខ និងមិនត្រូវក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។

គ្រានោះ នាយនិរយបាលបានពោលថា កាលមុននាងប្រមាទហើយ ឥឡូវនេះ នាងខ្សឹកខ្សួល នាងនឹងបានទទួលផលនៃអំពើអាក្រក់ទាំងឡាយ ដែលនាងបានធ្វើទុកដោយខ្លួនឯង ។ ទើបនាងវេតីពោលថា អ្នកណាចេញអំពីទេវលោកទៅកាន់មនុស្សលោកវិញ កាលមានអ្នកណាមួយសួរ គប្បីប្រាប់ពាក្យរបស់នាងខ្ញុំយ៉ាងនេះថា សូមអ្នកទាំងឡាយឲ្យទាន និងសំពត់ស្បៀកជណ្តប់ ទឹដេក ថ្វាយទឹក ដល់សមណព្រាហ្មណ៍ដែលជាក់ចុះនូវអាជ្ញាហើយ ព្រោះថាបុគ្គលកំណាញ់ ខឹងក្រោធ មានបាបធម៌ រមែងមិនបានភាវៈជាសម្ងាញ់ ជាមួយអ្នកឡើងទៅកាន់ស្ថានសួគ៌ ។ ខ្ញុំទៅអំពីទីនេះ បានកំណើតជាមនុស្សហើយ នឹងជាអ្នកដឹង

ពាក្យសម្តីរបស់ពួកអ្នកស្ងួម ជាអ្នកបរិបូណ៌ទៅដោយសីល ធ្វើកុសល ឲ្យបានច្រើន ដោយការឲ្យទាន ដោយសមចរិយា សញ្ញមៈ និងទមៈ ជារឿយៗ ។ នាងខ្ញុំនឹងដាំដើមឈើឲ្យជាម្លប់ និងជម្រះផ្លូវចូលទៅកាន់ស្ថានទីដែលដើរទៅមកលំបាក និងជីកអណ្តូង ហើយតម្កល់ទឹកផឹកដោយចិត្តផូរផង់ ។ នាងខ្ញុំនឹងរក្សាឧបោសថសីល ដែលប្រកបដោយអង្គ ៨ ប្រការ គ្រប់ថ្ងៃ ១៤-១៥-៨ និងគ្រប់បាដិហារិយ៍ សង្រ្គមរាំង ក្នុងសីលគ្រប់កាល ហើយនឹងមិនប្រមាទក្នុងការឲ្យទាន ផលកម្មនេះ ខ្ញុំឃើញដោយខ្លួនឯង ។ កាលនាងវេតីកន្ទក់កន្ទេញនៅយ៉ាងនេះ ពួកនាយនិរយបាល បានចាប់នាង បោះចុះទៅក្នុងនរកដែលគួរឲ្យខ្លាច ក្បាលរបស់នាង បានដោតចុះក្នុងលាមក ហើយជើងឡើងលើ ។ នាងវេតីបានពោលជាលើកចុងក្រោយថា កាលមុនខ្ញុំជាមនុស្សកំណាញ់ជេរប្រទេចសមណព្រាហ្មណ៍ ហើយបានពោលរឿងមិនពិត បោកប្រាស ស្វាមី ទើបត្រូវមកឆេះនៅក្នុងនរក ដែលគួរឲ្យខ្លាច ដូច្នេះ ។

រឿងដែលពួកយក្ខចាប់នាងវេតី នាំទៅបាត់សាបសូន្យទាំង

មានជីវិតនៅ ធ្វើឲ្យកិកុទាំងឡាយកើតសេចក្តីសង្វេគ តាមដែលមានសម្តែងទុកនៅក្នុង ***អដ្ឋកថាបរមត្ថទីបនី*** ដូចមានសេចក្តីថា ៖

កិកុទាំងឡាយក្រាបទូលរឿងរបស់នាងវេតី ដែលត្រូវពួកយក្ខចាប់នាំយកទៅនោះដល់ព្រះមានព្រះភាគ ។ គ្រានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ស្តាប់រឿងនោះហើយ ទើបត្រាស់រឿងនេះតាំងពីដើម (ដល់ចប់) ទ្រង់បានសម្តែងព្រះធម៌ឲ្យពិស្តារឡើងទៀត ។ ក្នុងពេលដែលព្រះមុនីទ្រង់ត្រាស់ទេសនានោះចប់ មានមហាជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទៅតាមឧបនិស្សយបុណ្យបារមីរៀងៗខ្លួន ដែលបានធ្វើទុកបួចមកហើយ ដូច្នេះបានជាបច្ច័យធ្វើឲ្យបុគ្គលទាំងនោះ បានសម្រេចនូវគុណធម៌បែបនោះបាន ។ រឿងនេះហៅថា ***វេតវិមាន*** ព្រោះជារឿងដែលទាក់ទងនឹងនាងវេតីដោយច្រើន តែព្រោះនាងវេតីមិនមែនជាទេវតាដែលមានវិមាន ហើយរឿងនេះក៏ប្រកបដោយសម្បត្តិ មានវិមានរបស់នន្ទិយទេវបុត្រ ។

ប្រវត្តិរបស់នន្ទិយឧបាសកនេះ បានសម្តែងឲ្យឃើញរឿងបាប

និងបុណ្យថា អ្នកណាធ្វើអ្នកនោះបាន កុំប្រកាន់ថាស្វាមីធ្វើហើយ ភរិយាបានផលដែរ ឬភរិយាធ្វើហើយ ស្វាមីក៏បានចំណែកផលនោះដែរ ព្រោះរឿងបាបបុណ្យ អ្នកណាធ្វើអ្នកនោះបាន ប្រៀបដូចការបរិភោគអាហារ អ្នកណាបរិភោគអ្នកនោះឆ្អែត ឬអ្នកណាបរិភោគថ្នាំពុល អ្នកនោះក៏ស្លាប់ ចំណែកបាប ឬបុណ្យទាំងឡាយដែលខ្លួនធ្វើទុក រមែងជាប់ទៅតាមឲ្យផលគ្រប់កាល ទាំងក្នុងលោកនេះ និងលោកខាងមុខ យ៉ាងពិតប្រាកដ ឲ្យតែមានឱកាសឲ្យផល ๗

(ជីវប្រវត្តិរបស់នន្ទិយឧបាសក ចប់)

✍ ជីវប្រវត្តិរបស់នាយកេសីឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

នាយកេសីឧបាសក ជាអ្នកមានចំណេះដឹង និងមានភាពជំនាញក្នុងការបង្វឹកសេះ មានសម្នាក់សម្រាប់បង្វឹកសេះ តែមិនមានចំណេះដឹងមិនមានវិធីការសម្រាប់ទូន្មានមនុស្ស បានមកក្រាបទូលសួរព្រះសម្ពុទ្ធទើបបានជាហេតុឲ្យគេក្លាយជាឧបាសក នៅក្នុងព្រះពុទ្ធសាសនានេះ ។

ជីវប្រវត្តិរបស់នាយកេសីឧបាសក មានសម្តែងនៅក្នុងព្រះបាលី ***កេសីសូត្រ*** *នៅក្នុង* ***គម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត*** *នៃ* ***កេសីវគ្គទី ២ ព្រះសុត្តន្តបិដក*** *ដូចមានសេចក្តីថា ៖*

សម័យមួយ នាយកេសីជាអ្នកមានចំណេះដឹង និងមានសមត្ថភាពល្អ ក្នុងវិធីការបង្ហាត់សេះ បានចូលទៅគាល់ព្រះមុនីដល់ទីប្រថាប់ថ្វាយបង្គំព្រះលោកនាយកហើយ ក៏បានអង្គុយក្នុងទីសមគួរ ។ គ្រានោះទើបព្រះមហាវីរៈ ត្រាស់សួរនាយកេសីថា ***កេសី*** *អ្នកជាបុគ្គលដែល*

ជនទូទៅស្គាល់ថា ជាសារថី គឺជាអ្នកបង្ហាត់សេះពូកែ អ្នកមានវិធីការបង្ហាត់សេះដូចម្តេច ? នាយកេសីបានក្រាបទូលតបថា បពិត្រព្រះអង្គជ័ចម្រើន ខ្ញុំព្រះករុណាមានវិធីបង្ហាត់សេះ ដែលគួរបង្ហាត់ច្រើនវិធី គឺ ហ្វឹកហាត់ដោយវិធីទន់ភ្លន់ (គឺឲ្យសេះស៊ីអាហារ ផឹកទឹកដែលល្អ ហើយនិយាយដោយពាក្យសម្តីទន់ភ្លន់ជាមួយសេះនោះ) ។ បង្ហាត់ដោយវិធីខ្ទាំងក្លា (គឺចងជើង ចងមាត់សេះជាដើម ឬប្រើជន្លួញចាក់វាយដោយផ្តៅ ប្រើពាក្យសម្តីកាច) ។ បង្ហាត់ដោយវិធីទន់ភ្លន់ និងខ្ទាំងក្លាផ្សំគ្នា (គឺដំបូងនិយាយល្អៗ មុន បើឃើញថា បង្រៀនយ៉ាងនេះមិនបានផល ក៏ប្រើវិធីខ្ទាំងក្លា) ។ ពេលនោះ ព្រះមហាមុនីត្រាស់សួរតទៅទៀតថា កេសី ប្រសិនបើសេះដែលលោកបង្ហាត់ដោយវិធីទន់ភ្លន់ វិធីខ្ទាំងក្លា ឬដោយវិធីទន់ភ្លន់ និងវិធីខ្ទាំងក្លាហើយ តែសេះនោះ អ្នកនៅតែបង្ហាត់មិនបាន អ្នកនឹងធ្វើយ៉ាងណា ជាមួយវា.តទៅទៀត ? លំដាប់នោះ នាយកេសីក្រាបទូលតបថា បពិត្រព្រះអង្គជ័ចម្រើន ប្រសិនបើសេះដែលខ្ញុំព្រះអង្គបង្ហាត់មិនបាន ដោយវិធីទន់ភ្លន់ វិធីខ្ទាំងក្លា ទាំងវិធី

ទន់ភ្លន់ និងខ្លាំងក្លាហើយ ខ្ញុំព្រះអង្គនឹងសម្លាប់សេះនោះចោលទៅ ការធ្វើដូច្នេះព្រោះហេតុអ្វី ព្រោះដើម្បីការពារការខូចឈ្មោះត្រកូលរបស់អាចារ្យ ដែលជាអ្នកបង្ហាត់នោះ ។

បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាវីរៈក៏ទ្រង់ជាសាវជ គឺជាអ្នកទូន្មានបុគ្គលដ៏កំពូល ព្រះសាស្តាទ្រង់មានវិធីទូន្មានបុគ្គលដែលគួរទូន្មានយ៉ាងណា ព្រះអង្គ ? គ្រានោះ ព្រះភគវាត្រាស់តបថា កេសី តថាគតទូន្មានបុគ្គល ដែលគួរទូន្មាន ដោយវិធីទន់ភ្លន់ខ្លះ ដោយវិធីខ្លាំងក្លាខ្លះ ទាំងវិធីទន់ភ្លន់ និងខ្លាំងក្លាលាយគ្នាខ្លះ ។ ក្នុងវិធីទាំងបីនោះ មានការទូន្មានដូចតទៅនេះ ចំណែកវិធីទន់ភ្លន់របស់តថាគត បានដល់ តថាគតសម្តែងឲ្យស្តាប់ថា កាយសុចរិត (ការប្រព្រឹត្តល្អតាមផ្លូវកាយ មាន ៣ ប្រការ) យ៉ាងនេះ វិបាក (ផល) នៃកាយសុចរិតយ៉ាងនេះ ។ វចីសុចរិត (មាន ៤ ប្រការ) យ៉ាងនេះ វិបាកនៃវចីសុចរិតយ៉ាងនេះ ។ មនោសុចរិត (មាន ៣ ប្រការ) យ៉ាងនេះ វិបាកនៃមនោសុចរិត

យ៉ាងនេះ ។ ទេវតាយ៉ាងនេះ មនុស្សយ៉ាងនេះ ។ ការទូន្មានដោយវិធីខ្ជាំងក្លារបស់តថាគត បានដល់ តថាគតចង្អុលឲ្យយល់ថា កាយទុច្ចរិត (មាន ៣ ប្រការ) យ៉ាងនេះ វិបាកនៃកាយទុច្ចរិតយ៉ាងនេះ ។ វចីទុច្ចរិត (មាន ៤ ប្រការ) យ៉ាងនេះ វិបាកនៃវចីទុច្ចរិតយ៉ាងនេះ ។ មនោទុច្ចរិត (មាន ៣ ប្រការ) យ៉ាងនេះ វិបាកនៃមនោទុច្ចរិតយ៉ាងនេះ ។ នរក យ៉ាងនេះ តិរច្ឆានយ៉ាងនេះ បេតវិស័យយ៉ាងនេះ ។ ការទូន្មានទាំងវិធីទន់ភ្លន់ និងវិធីខ្ជាំងក្លាលាយគ្នានោះ បានដល់ តថាគតចង្អុលឲ្យឃើញថា កាយសុចរិតយ៉ាងនេះ វិបាកនៃកាយសុចរិតយ៉ាងនេះ ។ កាយទុច្ចរិត យ៉ាងនេះ វិបាកនៃកាយទុច្ចរិតយ៉ាងនេះ ។ វចីសុចរិតយ៉ាងនេះ វិបាកនៃវចីសុចរិតយ៉ាងនេះ ។ វចីទុច្ចរិតយ៉ាងនេះ វិបាកនៃវចីទុច្ចរិតយ៉ាងនេះ ។ មនោសុចរិតយ៉ាងនេះ វិបាកនៃមនោសុចរិតយ៉ាងនេះ ។ មនោទុច្ចរិត យ៉ាងនេះ វិបាកនៃមនោទុច្ចរិតយ៉ាងនេះ ។ ទេវតាយ៉ាងនេះ មនុស្ស យ៉ាងនេះ នរកយ៉ាងនេះ តិរច្ឆានយ៉ាងនេះ បេតវិស័យយ៉ាងនេះ ។

លំដាប់នោះ ទើបនាយកេសីក្រាបទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើបុរសដែលព្រះអង្គទ្រង់ទូន្មានហើយ មិនចូលដល់វិស័យ គឺព្រះអង្គទ្រង់ហ្វឹកហាត់មិនបានដោយវិធីទន់ភ្លន់ វិធីខ្ជាំងក្លា ទាំងវិធីទន់ភ្លន់ និងវិធីខ្ជាំងក្លាលាយគ្នា ព្រះអង្គទ្រង់ធ្វើដូចម្តេច ជាមួយគេព្រះអង្គ ? គ្រានោះ ព្រះមានជោគត្រាស់តបថា កេសី ប្រសិនបើបុរសដែលតថាគតទូន្មានមិនបាន ដោយវិធីទន់ភ្លន់ វិធីខ្ជាំងក្លា ទាំងវិធីទន់ភ្លន់ និងខ្ជាំងក្លាលាយគ្នាហើយ តថាគតក៏សម្លាប់គេចោលទៅ ។ នាយកេសីស្តាប់ព្រះពុទ្ធតម្រាស់ត្រាស់ដូច្នេះហើយ ទើបក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ការសម្លាប់សត្វ រមែងមិនសមគួរដល់ព្រះមុនីឡើយ តែហេតុដូចម្តេច ទើបបានជាព្រះវិជិតមារ ត្រាស់ថា សម្លាប់គេចោលព្រះអង្គ ? ពេលនោះ ព្រះកគវាត្រាស់អធិប្បាយថា ពិតដូចអ្នកថាមែន ការសម្លាប់សត្វរមែងមិនគួរដល់តថាគត តែថា បុរសណាតថាគតទូន្មានដោយវិធីទន់ភ្លន់ វិធីខ្ជាំងក្លា ទាំងវិធីទន់ភ្លន់ និងខ្ជាំងក្លាលាយគ្នាហើយ

តថាគតមិនប្រកាន់ថា បុរសនោះជាអ្នកដែលគួរស្តីថា គួរប្រៀនប្រដៅមិត្តសព្រហ្មចារី ដែលជាវិញ្ញូជនទាំងឡាយ ក៏មិនប្រកាន់ថា បុរសនេះជាអ្នកដែលគួរស្តីថា គួរប្រៀនប្រដៅឡើយ ។ ម្នាលកេសី ប្រការដែលតថាគតមិនប្រកាន់ថា ជាបុរសដែលគួរទូន្មាន គួរស្តីថា គួរប្រៀនប្រដៅ (ឈប់ប្រៀនប្រដៅ) នេះឯងជាការសម្ងាប់ដោយល្អ នៅក្នុងអរិយវិន័យនេះ ។

ពេលនោះ ទើបនាយកេសីក្រាបទូលតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ប្រការដែលព្រះភគវា មិនប្រកាន់ថា ជាបុរសដែលគួរទូន្មាន គួរប្រៀនប្រដៅ សូម្បីមិត្តសព្រហ្មចារីដែលជាវិញ្ញូជន ក៏មិនប្រកាន់ថា គួរស្តីថា គួរប្រៀនប្រដៅ នេះឯងជាការសម្ងាប់ដែលល្អពិត ព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចម្រើន កាសិតរបស់ព្រះមុនីនេះ ជាក់ច្បាស់ពេកណាស់ ព្រះអង្គទ្រង់ប្រកាសធម៌ដោយអនេកបរិយាយ នេះប្រៀបដូចជាបុគ្គលផ្ងារបស់ដែលផ្តាច់ បើករបស់ដែលចិទចេញ ប្រាប់ផ្លូវដល់បុគ្គល

ដែលវង្វេងផ្លូវ ឬទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា អ្នកមានភ្នែកល្អ ចូរមើលឃើញវត្ថុផ្សេងៗ ចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃថាជាសរណៈ គឺជាទីពឹង ទីឰក សូមព្រះសាស្តា ទ្រង់ចាំខ្ញុំព្រះអង្គទុកថា ជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យ ចាប់អំពីថ្ងៃនេះជាដើមទៅ រហូតដល់អស់ជីវិត ព្រះអង្គ ។

(ជីវប្រវត្តិរបស់នាយកេសីឧបាសក ចប់)

✍ ជីវប្រវត្តិរបស់បុក្កុសមល្លបុត្តឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

បុក្កុសមល្លបុត្ត ជាឧបាសកបានប្រសព្វឱកាសដ៏ប្រសើរបំផុត ដោយបានទទួលស្តាប់ព្រះធម៌ទេសនាពីព្រះសាស្តា ក្នុងថ្ងៃចុងក្រោយនៃការរំលត់ខន្ធបរិនិព្វាន រហូតដល់កើតការយល់ចូលចិត្ត ក្នុងព្រះសាសនាបានយ៉ាងត្រឹមត្រូវ គេក៏កើតមានសេចក្តីជ្រះថ្លា ទើបបានថ្វាយសំពត់សាច់ម៉ដ្ដមួយគូ ដែលមានឈ្មោះថា **សិង្គីវណ្ណ** ដែលជាសំពត់មង្គលខ្ពង់ខ្ពស់បំផុតចំពោះព្រះសម្មាសម្ពុទ្ធ ដោយការពេញចិត្តយ៉ាងក្រៃលែង និងរាប់ថាជាសំពត់ ដែលជួយលើកឲ្យព្រះឆវីវណ្ណរបស់ព្រះលោកនាថ ឲ្យផូរផង់ឡើង ឲ្យល្អឥតខ្ចោះរុងរឿង វិចិត្រយ៉ាងក្រៃលែងទៀត ។

ជីវប្រវត្តិរបស់បុក្កុសមល្លបុត្តឧបាសក មានសម្តែងទុកនៅក្នុង **អដ្ឋកថាសុមង្គលវិលាសិនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីពាលីក្នុង **គម្ពីរទីឃនិកាយ មហាវគ្គ** នៃ **មហាបរិនិព្វានសូត្រ** ថា ៖

បុក្កុសមល្លបុត្រឧបាសក ជាបុត្ររបស់អ្នកមល្លក្សត្រ នៅក្នុង **នគរកុសិនារា** មានឈ្មោះថា **បុក្កុសៈ** ប៉ុន្តែកាលបើនាំយកឈ្មោះ និងឈ្មោះត្រកូលមករួមគ្នា ទើបបានឈ្មោះថា **បុក្កុសមល្លបុត្រ** ប្រែថា បុក្កុសៈ ជាបុត្ររបស់ព្រះបាទមល្លៈ ។ បានឮមកថា ពួកក្សត្រមល្លៈបានផ្ទាស់ប្តូរគ្នាឡើងគ្រប់គ្រងរាជសម្បត្តិ ក្សត្រមល្លៈពួកណានៅមិនទាន់បានវារៈឡើងគ្រប់គ្រងរាជសម្បត្តិ ក្សត្រមល្លៈពួកនោះ ក៏ធ្វើជំនួញសិនទៅ ។ ចំណែកបុក្កុសមល្លបុត្រនេះ (ជួនពេលដែលនិងបានមកជួបនិងព្រះសាស្តា) បានត្រាច់ទៅធ្វើជំនួញ ដោយគេបានរៀបចំក្រៀមរទេះ ៥០០ (ផ្ទុកទំនិញ) រួចហើយទឹមរទេះទាំង ៥០០ ដឹកទំនិញចេញដំណើរទៅលក់ដូរ ។ ក្នុងពេលដែលគេនាំរទេះទាំងនោះ ធ្វើដំណើរទៅ ពេលដែលមានខ្យល់បក់មកចំពីមុខ គេក៏ទៅខាងក្រោយ កាលមានខ្យល់បក់មកពីខាងក្រោយ គេក៏បញ្ជូនក្រុមរទេះទៅខាងមុខ រីឯខ្លួនគេតាមទៅខាងក្រោយ ។ ក្នុងគ្រានោះ មានខ្យល់បក់មកពីខាងក្រោយ បុក្កុសមល្លបុត្រទើបបញ្ជាឲ្យក្រុមរទេះទៅខាងមុខ ហើយគេអង្គុយនៅលើយាន ដែល

ផ្ទុកសព្វគ្រឿង គឺកែវទាំង៧ពួងតាមទៅខាងក្រោយ ចេញចាកនគរកុសិនារា ដោយគេគិតថា ទៅកាន់ក្រុងបាវា ។ ព្រោះដូច្នោះ សេចក្តីក្នុងព្រះបាលី ទើបមានសេចក្តីថា គ្រានោះ បុក្កុសមល្លបុត្រ បានធ្វើដំណើរចេញអំពីនគរកុសិនារា ទៅកាន់ក្រុងបាវា ។

ហេតុដែលជាបច្ចយាការ (អាការដែលជាហេតុ) ឲ្យបុក្កុសមល្លបុត្របានមកជួបនឹងព្រះមហាវីរៈ ក្នុងថ្ងៃដែលជាបច្ឆិមវារៈ (គឺវារៈចុងក្រោយ) ដែលព្រះលោកនាយក ស្តេចនឹងបរិនិព្វាន តាមដែលមានរឿងសម្តែងនៅក្នុង **គម្ពីរទីឃនិកាយ មហាវគ្គ** នៃ **មហាបរិនិព្វានសូត្រ** សម្តែងដោយហេតុការណ៍ ជិតនឹងពុទ្ធបរិនិព្វានថា ៖

គ្រានោះ បុក្កុសមល្លបុត្រ ដែលជាសាវ័កបស់អាឡារគាបសកាឡាមគោត្រ គេធ្វើដំណើរចេញពីនគរកុសិនារា ទៅកាន់ក្រុងបាវា បានជួបព្រះភគវា គង់ប្រថាប់នៅទៀបគល់ឈើមួយដើម ដែលនៅក្នុងស្ថានទីក្បែរផ្លូវសព្វគ្រប់ទៅមក ។ ម្យ៉ាងទៀត ហេតុដែលព្រះមហាវីរបុរសស្តេចមកគង់ប្រថាប់នៅទៀបគល់ឈើនោះ ទាក់ទងមកពីព្រះសាស្តា

សោយភត្តាហារនៅផ្ទះនាយចុន្ទកម្នាវបុត្រ ក្នុងក្រុងបាវារួចមកហើយ ស្តេចបានចេញអំពីក្រុងបាវា ទៅកាន់នគរកុសិនារា ។ ក្នុងពេលដែលព្រះមានបុណ្យស្តេចទៅតាមផ្លូវដោយមានព្រះអានន្ទជាបច្ឆាសមណៈ (គឺជាសមណៈដែលនិមន្តជាប់តាមក្រោយ) ព្រះអង្គស្តេចបានយាងគេចចេញចាកពីផ្លូវ ទ្រង់ឆៀងចូលទៅគង់ប្រថាប់ ទៀបគល់ដើមឈើមួយដើម ហើយត្រាស់ប្រាប់ព្រះអានន្ទថា ម្នាលអានន្ទ អ្នកចូរក្រាលសំពត់សង្ឃដិ ៤ ជាន់ឲ្យដល់តថាគតៗ ល្អិតល្អៀណាស់ ត្រូវការគង់សម្រាកបន្តិច ។ ពេលនោះ ព្រះអានន្ទ បានក្រាបបង្គំទូលទទួលព្រះពុទ្ធតម្រាស់ហើយ បានប្រញាប់ប្រញាល់ក្រាលសំពត់សង្ឃដិ ៤ ជាន់ថ្វាយដល់ព្រះអង្គ ។ ពេលនោះ ព្រះលោកនាយក ទើបគង់ប្រថាប់នៅលើសំពត់សង្ឃដិ ដែលព្រះអានន្ទក្រាលថ្វាយ លុះព្រះអង្គគង់ហើយ ទើបត្រាស់ប្រាប់ថា ម្នាលអានន្ទ អ្នកចូរទៅដងទឹកមកឲ្យតថាគតផាន់ តថាគតស្រេកទឹក តថាគតត្រូវការនឹងផាន់ទឹក ។ គ្រានោះ ព្រះកគវាត្រាស់ប្រើយ៉ាងនេះហើយ ព្រះអានន្ទទើបក្រាបថ្វាយបង្គំទូលថា បពិត្រ

ព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ មានក្រុមរនេះប្រមាណ ៥០០ បានបរ
ឆ្ងងកាត់ស្ទឹងនេះទៅ ទឹកក្នុងស្ទឹងនេះមានតិច ពេលដែលត្រូវក្រុមរនេះ
បរកាត់ទៅ ធ្វើឲ្យមានទឹកល្អក់ (ប្រើមិនបាន) ស្ទឹងកកុធៈ ដែលនៅ
មិនឆ្ងាយ មានទឹកថ្លាស្អាតត្រជាក់ មានកំពង់រាបស្មើ គួរឲ្យអភិរម្យ
ព្រះជិនស្រីទ្រង់និងបានឆាន់ទឹកនោះ ថែមទាំងទ្រង់បានស្រង់ព្រះវរកាយ
ក្នុងស្ទឹងនោះ ព្រះអង្គ ។ ព្រះសម្ពុទ្ធគ្រាស់ប្រាប់ព្រះអានន្ទ ឲ្យទៅដងទឹក
ជាគ្រាទី ២ ទៀត ។ ព្រះអានន្ទក៏ក្រាបបង្គំទូលនូវពាក្យដដែលឡើងទៀត
ជាគ្រាទី ២ ។ បន្ទាប់មក ព្រះសក្យមុនីគ្រាស់ប្រាប់ជាគ្រាទី ៣ ព្រះអានន្ទ
ទើបក្រាបបង្គំទូលទទួលព្រះពុទ្ធបញ្ជាថា ព្រះករុណា ព្រះអង្គ ហើយលោក
បានកាន់យកបាត្រដើរចុះទៅក្នុងស្ទឹងនោះ លុះព្រះអានន្ទទៅដល់ហើយ
ទឹកក៏ត្រឡប់ជាថ្លាស្អាត មិនកករល្អក់ ព្រះថេរៈបានឃើញដូច្នោះហើយ
គិតថា គួរឲ្យអស្ចារ្យណាស់ហេតុដែលមិនធ្លាប់មាន ក៏បានកើតមានមក
ព្រោះហេតុតែព្រះតថាគត ទ្រង់មានឫទ្ធិច្រើន មានអានុភាពច្រើនដូច្នេះ
ការពិតក្នុងស្ទឹងនេះមានទឹកតិច ត្រូវក្រុមរនេះប្រមាណ ៥០០ បរកិន

យ៉ាងល្អក់ ប៉ុន្តែពេលដែលយើងមកដល់ ទឹកក៏ត្រឡប់ថ្លាមួយរំពេចភ្លាម កាលបើព្រះថេរៈគិតយ៉ាងនេះហើយ ទើបយកបាត្រជងទឹក នាំយកទៅថ្វាយព្រះទសពល បានក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន គួរឲ្យអស្ចារ្យពេកណាស់ ហេតុដែលមិនធ្លាប់មាន ក៏បានកើតមានឡើងហើយ ព្រោះតែព្រះតថាគត ទ្រង់មានឫទ្ធិច្រើន ទ្រង់មានអានុភាពច្រើន ព្រោះអម្បាញ់មិញនេះទឹកក្នុងស្ទឹងនោះ ដែលកំពុងតែល្អក់ ដោយត្រូវពួកក្រុមរទេះបង្ហូរកាត់ទៅនោះ លុះខ្ញុំព្រះអង្គទៅដល់ ទឹកក៏ត្រឡប់ជាថ្លាស្អាតបាត់អស់ភាពល្អក់ទៅ សូមព្រះលោកនាយក ទ្រង់ធាន់ទឹកនេះចុះ ព្រះអង្គ ។ ពេលនោះ ព្រះភគវាទ្រង់ធាន់ទឹកតាមព្រះបំណង ។ ចំណែកបុក្កុសមល្លបុត្រ កាលបានក្រឡេកមើលឃើញព្រះសាស្តា គង់ប្រថាប់នៅទៀបគល់ឈើរក្បែរផ្លូវនោះ ដូច្នោះ ទើបចូលទៅគាល់ក្រាបបង្គំទូលរួចហើយក៏អង្គុយ នៅក្នុងទីដ៏សមគួរ ពេលដែលគេអង្គុយរៀបរយហើយ ទើបក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន គួរឲ្យអស្ចារ្យពេកណាស់ ព្រះអង្គ ក្នុងកាលដែលបព្វជិតទាំងឡាយនៅដោយធម៌ ដែលជាគ្រឿង

នៅជិស្ងប់ រឿងធ្លាប់មានមកហើយ គឺអាឡារតាបសកាឡាមគោត្រ បានធ្វើដំណើរផ្លូវឆ្ងាយ ហើយបានដើរគេចចេញអំពីផ្លូវ ចៀងចូលទៅអង្គុយសម្រាកនៅពេលថ្ងៃ ទៀបគល់ដើមឈើមួយដើម ដែលមាននៅក្បែរផ្លូវនោះ ។

គ្រានោះមានក្រុមរទេះប្រមាណ ៥០០ បានបរកាត់អាឡារតាបសកាឡាមគោត្រទៅហើយ មានបុរសម្នាក់ដើរតាមក្រុមរទេះនោះមក បានចូលទៅរកអាឡារតាបស ហើយសួរថា លោកជ័ចម្រើន បានឃើញក្រុមរទេះប្រមាណ ៥០០ បរឆ្លងកាត់ស្ទឹងនេះដែរឬទេ ? អាឡារតាបសឆ្លើយថា នែបុរសជ័ចម្រើន អាត្មាមិនបានឃើញពួកក្រុមរទេះនោះឡើយ ។ បុរសនោះ ទើបសួរតទៅទៀតថា លោកជ័ចម្រើន បានឮសំឡេងខ្លះឬទេ ? អាឡារតាបសឆ្លើយថា ទេ អាត្មាមិនបានឮសំឡេងអ្វីឡើយ ។ បុរសនោះ ទើបសួរដោយសេចក្តីសង្ស័យថា ប្រសិនបើយ៉ាងនោះ លោកដេកលក់ឬ ? អាឡារតាបសឆ្លើយថា អាត្មាមិនបានដេកលក់ទេ ។ បុរសនោះ សួរទៀតថា លោកនៅមានសញ្ញាឬអត់ ? អាឡារតាបស

ឆ្លើយថា អាត្មានៅមានសញ្ញាទេតើ ។បុរសនោះសួរទៀតថា លោកមានសញ្ញា នៅពេលដែលលោកក្រាក់ឬ ? ប្រសិនបើលោកមិនបានឃើញក្រុមរនេះ ៥០០ និងមិនបានឮសំឡេងរនេះទាំង ៥០០ នោះដែលបរជាប់គ្នានៅក្បែរៗ លោកឆ្ងល់កាត់ទៅ រហូតដល់សំពត់របស់លោកប្រឡាក់ដោយធូលី លោកក៏នៅតែមិនដឹងឬ? គ្រានោះ អាឡារតាបសឆ្លើយថា មែនយ៉ាងនោះហើយ បុរសដ៏ចម្រើន គឺយើងមិនដឹងមែន ។

គ្រានោះ បុរសនោះទើបគិតថា គួរឲ្យអស្ចារ្យណាស់ ការដែលពួកបព្វជិតនៅដោយធម៌ ដែលជាគ្រឿងដ៏ស្ងប់ អាឡារតាបសមានសញ្ញាក្រាក់ ប៉ុន្តែមិនឃើញក្រុមរនេះប្រមាណ ៥០០ និងមិនបានឮសំឡេងពួកក្រុមរនេះ ៥០០ នោះដែលបរជាប់គ្នានៅក្បែរៗ ឆ្ងល់កាត់ទៅបុរសនោះបានប្រកាសសេចក្តីជ្រះថ្លា យ៉ាងក្រៃលែងជាមួយនឹងអាឡារតាបសហើយក៏លាចៀសចេញទៅ ។ លំដាប់នោះ ព្រះលោកនាថ ត្រាស់នឹងបុក្កុសមល្លបុត្រថា ម្នាលបុក្កុសមល្លបុត្រ លោកយល់សេចក្តីនោះយ៉ាងណា គឺអ្នកមានសញ្ញាក្រាក់ ប៉ុន្តែមិនបានឃើញពួកក្រុមរនេះ ប្រមាណ ៥០០

និងមិនបានឮសំឡេង ពួកក្រុមរនេះទាំង ៥០០ នោះ ដែលបរជាប់គ្នា នៅក្បែរៗ ឆ្ងងកាត់ទៅ និងអ្នកមានសញ្ញាក្លាក់ នៅពេលដែលមានភ្លៀងបង្អុរធ្លាក់មកយ៉ាងខ្លាំង មានទាំងផ្លេកបន្ទោរ និងសំឡេងរន្ទះបាញ់ គេក៏មិនឃើញ និងមិនបានឮសំឡេងរន្ទះបាញ់ ដែលបាញ់នៅក្បែរៗ ខ្លួនបុគ្គលទាំងពីរនាក់នេះ នរណាគួរឲ្យអស្ចារ្យ ឬគួរដល់ការសរសើរជាង ? បុក្កុសមល្លបុត្រក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលមានសញ្ញាក្លាក់ ប៉ុន្តែមិនបានឃើញផ្លេកបន្ទោរ និងមិនបានឮសំឡេងរន្ទះបាញ់នោះ គួរឲ្យអស្ចារ្យជាង ឬប្រសើរជាងអ្នកដែលមិនបានឃើញ និងមិនបានឮសំឡេងបរនេះ ៥០០ ឬ ៦០០ រហូតទៅដល់មួយសែនព្រះអង្គ ។

លំដាប់នោះ ព្រះលោកនាថ ទើបត្រាស់ថា ម្នាលបុក្កុសៈ ក្នុងសម័យមួយតថាគតនៅត្រង់កូសាគារគីល្អាងក្បឿង នៅក្នុងក្រុងអាតុមា ក្នុងសម័យនោះ មានភ្លៀងបង្អុរធ្លាក់មកយ៉ាងខ្លាំង មានផ្លេកបន្ទោរធ្លៀលឆ្វាត់ មានរន្ទះបាញ់ជាច្រើន មានអ្នកស្រែពីរនាក់បងប្អូន និងគោ

៤ ក្បាល ត្រូវនេះបាញ់ស្លាប់ នៅជិតល្អាងក្បឿងនោះ ។ ពេលនោះ ពួកមហាជនក្នុងក្រុងអាតុមា បាននាំគ្នាចេញមកមើលអ្នកស្រែពីរនាក់ បងប្អូន និងគោ ៤ ក្បាល ដែលត្រូវនេះបាញ់នោះ តថាគតចេញអំពីល្អាងក្បឿង និមន្តចង្រ្កមក្នុងទីវាល ក្បែរទ្វារល្អាងក្បឿង មានបុរសម្នាក់ បានដើរចេញអំពីពួកមហាជនទាំងនោះ ចូលមកវាគតថាគត ថ្វាយបង្គំតថាគតរួចហើយ អង្គុយនៅក្នុងទីដ៏សមគួរ តថាគតបានសួរបុរសនោះថា មានហេតុអ្វី បានជាមហាជនមកប្រជុំគ្នាជាច្រើននៅក្នុងស្ថានទីនេះ ? បុរសនោះតបថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ មានក្លៀងបង្អុរចុះមកយ៉ាងខ្លាំង ថែមទាំងមានផ្លេកបន្ទោរឆ្វៀលឆ្វាត់ ហើយមានរន្ទះបាញ់ត្រូវអ្នកស្រែពីរនាក់បងប្អូនស្លាប់ និងត្រូវគោ ៤ ក្បាលស្លាប់ផងដែរ ដូច្នេះហើយ ទើបបានជាពួកមហាជននាំគ្នាមកមើល ក្នុងពេលនោះ ព្រះអង្គទ្រង់ប្រថាប់នៅទីណា ព្រះអង្គ ? ព្រះអង្គត្រាស់តបនឹងបុរសនោះថា អម្បាញ់មិញនេះ តថាគតនៅទីនេះទេតើ ។ បុរសនោះ ទើបសួរទៀតថា ព្រះអង្គទ្រង់បានឃើញផ្លេកបន្ទោរនោះឬទេ ព្រះករុណា

ម្ចាស់ ? ព្រះពុទ្ធអង្គតបថា តថាគតមិនបានឃើញទេ ។ បុរសនោះសួរតទៅទៀតថា ព្រះអង្គបានឮសំឡេងនេះបាញ់ឬទេ ព្រះករុណាម្ចាស់ ? ព្រះពុទ្ធអង្គត្រាស់តបថា តថាគតមិនបានឮសំឡេងនេះបាញ់នោះទេ ។ បុរសនោះសួរតទៅទៀតថា ព្រះអង្គទ្រង់ផ្តុំលក់ឬ ករុណាម្ចាស់ ? ព្រះអង្គតបថា តថាគតមិនបានផ្តុំលក់ទេ ។បុរសនោះសួរតទៅទៀតថា ព្រះអង្គទ្រង់នៅមានសញ្ញាឬ ករុណាម្ចាស់ ? ព្រះពុទ្ធអង្គត្រាស់ថា តថាគតនៅមានសញ្ញាទេតើ ។ បុរសនោះសួរតទៅទៀតថា កាលបើព្រះអង្គទ្រង់នៅមានសញ្ញា ពេលដែលមានផ្គរបន្ទោរឆ្មៀលឆ្មាត់ និងមានរន្ទះបាញ់ ព្រះអង្គទ្រង់មិនបានឃើញ និងទ្រង់មិនបានឮយ៉ាងនោះឬ ព្រះករុណាម្ចាស់?ព្រះអង្គត្រាស់តបថា យ៉ាងនោះឯង បុរសជ័ចម្រើន ។ ម្នាលបុក្កុសៈ បុរសនោះទើបគិតថា ពិតជាគួរឲ្យអស្ចារ្យពេកណាស់ ពេលដែលបព្វជិតនៅក្នុងធម៌ដែលជាគ្រឿងដ៏ស្ងប់ដូចនេះ ព្រោះកាលបើនៅមានសញ្ញា នៅក្រាក់ ពេលដែលមានភ្លៀងបង្អុរចុះមកយ៉ាងខ្លាំង មានផ្គរបន្ទោរឆ្មៀលឆ្មាត់ និងមានរន្ទះបាញ់ចុះមកយ៉ាងច្រើន ក៏មិនបាន

ឃើញ និងមិនបានឮសំឡេង បុរសនោះបានប្រកាសនូវសេចក្តីជ្រះថ្លា យ៉ាងក្រៃលែង ចំពោះតថាគត ធ្វើប្រទក្សិណហើយ ក៏ថ្វាយបង្គំលាចៀសចេញទៅ ។

កាលបើព្រះសាស្តា ទ្រង់ត្រាស់ដូច្នេះហើយ បុក្កុសមល្លបុត្រ បានក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមលះបង់ចោលនូវភាពជ្រះថ្លា ដែលមានចំពោះអាឡារតាបសកាឡាមគោត្រ ទៅក្នុងខ្យល់ព្យុះធំ ឬបណ្តែតចុះក្នុងស្ទឹង ដែលមានក្រសែទឹកហូរខ្លាំង ព្រះវាចាដែលព្រះអង្គត្រាស់ប្រាប់ ឲ្យខ្ញុំព្រះអង្គបានស្តាប់នេះ ពីរោះយ៉ាងក្រៃលែងណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រះវាចារបស់ព្រះអង្គច្បាស់ពេកណាស់ ប្រៀបដូចជាបុរសផ្ងារបស់ដែលគេផ្តាប់ បើករបស់ដែលគេបិទចេញ ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬទ្រោលប្រទីបក្នុងទីងងឹត ដោយបំណងឲ្យអ្នកមានភ្នែកល្អ បានមើលឃើញវត្ថុផ្សេងៗ បានយ៉ាងណា ព្រះភគវាទ្រង់ប្រកាសធម៌ដោយអនេកបរិយាយ ដោយហេតុច្រើនយ៉ាងដូច្នេះដូចគ្នា ខ្ញុំព្រះអង្គសូមដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង

ថាជាសរណៈ គឺជាទីពឹង ទីរឭក សូមព្រះសាស្តាមេត្តាចាំទុកខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណៈ រហូតអស់មួយជីវិត ចាប់តាំងអំពីថ្ងៃនេះ ជាដើមតទៅ ព្រះអង្គ ។ បន្ទាប់ពីនោះ បុក្កុសមល្លបុត្រ ទើបប្រាប់បុរសម្នាក់ថា នែនាយ ចូរអ្នកជួយនាំយកសំពត់សង្ឃីវណ្ណមួយគូនេះ គឺសំពត់សាច់រលោង មានពណ៌ដូចមាសសង្ឃី ដែលជាសំពត់សាច់ស្អាតភ្លឺចិញ្ចែងរបស់យើងមក ។បុរសនោះទទួលពាក្យរបស់បុក្កុសមល្លបុត្រ ហើយបាននាំយកសំពត់សង្ឃីវណ្ណមួយគូនោះមកជូនដល់បុក្កុសមល្លបុត្រ។ បុក្កុសមល្លបុត្រ ទើបបន្ទន់កាយ នាំយកសំពត់សង្ឃីវណ្ណ ដែលមានសាច់ស្អាតភ្លឺចិញ្ចែងនោះ ចូលទៅថ្វាយដល់ព្រះសម្មាសម្ពុទ្ធ ព្រមគ្នានឹងក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះលោកនាថមេត្តាទទួលសំពត់សង្ឃីវណ្ណ របស់ខ្ញុំព្រះអង្គមួយគូនេះផងចុះ ។

គ្រានោះ ព្រះលោកនាថទ្រង់ត្រាស់ថា ម្នាលបុក្កុសៈ ប្រសិនបើដូចនោះអ្នកចូរឲ្យតថាគតមួយផ្ទាំង និងឲ្យព្រះអានន្ទគ្រងមួយផ្ទាំងផង ដែរចុះ ។ បុក្កុសមល្លបុត្រក្រាបទូលទទួលថា ករុណាព្រះអង្គ ហើយគេ

បន្ទន់កាយថ្វាយដល់ព្រះមហាវីរៈគ្រងមួយផ្ទាំង និងប្រគេនដល់ព្រះអានន្ទ គ្រងមួយផ្ទាំងផងដែរ ។ លំដាប់នោះ ព្រះមហាវីរបុរស ទ្រង់សម្តែងធម៌អនុគ្រោះដល់បុក្កុសមល្លបុត្រ ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាដូច្នេះ ។ ចំណែកបុក្កុសមល្លបុត្រ កាលបើបានស្តាប់ធម្មីកថាពីព្រះមុនីហើយ ទើបក្រោកឡើងថ្វាយបង្គំលា ធ្វើប្រទក្សិណ (ដើរវិលខាងស្តាំ ៣ជុំ ព្រះមានបុណ្យ) ហើយលាចៀសចេញទៅ ។ លុះបុក្កុសមល្លបុត្រ ក្រាបបង្គំលាទៅមិនយូរប៉ុន្មាន ព្រះអានន្ទបានបន្ទន់កាយថ្វាយនូវសំពត់មួយផ្ទាំងនោះ ចូលទៅជណ្តប់ព្រះកាយ ព្រះមានជោគ (ផ្ទាំងសំពត់សង្ឃាវណ្ណ ដែលព្រះអានន្ទទទួលថ្វាយទុក ដើម្បីប្រាថ្នាឲ្យកើតបុណ្យច្រើនដល់បុក្កុសមល្លបុត្រ និងកាលលោកទទួលហើយ ក៏មិនបានប្រើខ្លួនឯងដោយលោកនាំយកទៅថ្វាយដល់ព្រះជិនស្រី) ។ កាលបើព្រះវរកាយព្រះវិជិតមារជណ្តប់ដោយសំពត់សង្ឃាវណ្ណផ្ទាំងនោះហើយ ក៏ប្រាកដដូចគ្នានឹងរងើកភ្លើង ដែលមិនមានអណ្តាតដូច្នោះដែរ ។

គ្រានោះ ព្រះអានន្ទទើបក្រាបបង្គំទូលថា បពិត្រព្រះសក្យមុនី

គួរឲ្យអស្ចារ្យពេកណាស់ ព្រះឆវីវណ្ណរបស់ព្រះតថាគត បរិសុទ្ធផូរផង់យ៉ាងក្រៃលែង លុះដណ្តប់ដោយផ្ទាំងសំពត់សង្ឃាវណ្ណ ដែលជាសំពត់សាច់ស្អាតក្តីចិញ្ចៀងហើយ រមែងប្រាកដដូចគ្នានឹងរងើកភ្លើង ដែលមិនមានអណ្តាតដូច្នោះដែរ ។ពេលនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា សេចក្តីនេះជាយ៉ាងនោះអានន្ទ កាយរបស់តថាគត រមែងមានឆវីវណ្ណផូរផង់យ៉ាងក្រៃលែងក្នុងកាលទាំងពីរ គឺ ១- ក្នុងពេលរាត្រីដែលតថាគតត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ (ញាណដែលជាគ្រឿងត្រាស់ដឹងឯងដោយប្រពៃយ៉ាងល្អបំផុត) ២- ក្នុងពេលរាត្រីដែលតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ (សការៈដែលរំលត់កិលេស មិនមានបញ្ចក្ខន្ធនៅសេសសល់ គឺអស់ទាំងកិលេស និងជីវិត សំដៅដល់កាយដែលស្ងាប់ទៅហើយរបស់ព្រះអរហន្ត) ។ក្នុងកាលទាំងពីរនេះឯង កាយរបស់តថាគត រមែងបរិសុទ្ធផូរផង់យ៉ាងក្រៃលែងណាស់ ។ម្នាលអានន្ទ ក្នុងបច្ឆិមយាម គឺយាមចុងក្រោយនៃរាត្រីនេះ តថាគតនឹងបរិនិព្វាន ក្នុងចន្លោះនៃជើមសាលព្រឹក្ស នៅក្នុងសាលវនឧទ្យាន របស់ពួកមល្លក្សត្រ

ទាំងឡាយ កែ្បរនេគរកុសិនារា មកអានន្ទ តថាគតនឹងទៅកាន់ស្ទឹង
កកុធនទី ។ ពេលនោះ ព្រះអានន្ទ ក្រាបបង្គំទូលទទួលព្រះតម្រាស់
របស់ព្រះសយម្ភូថា ករុណាព្រះអង្គ ។

បុក្កុសៈនាំយកសំពត់សង្ឃាវណ្ណមួយគូ (គឺសំពត់សាច់ល្អ មានពណ៌
ដូចជាមាសសង្ឃាដិ ចូលទៅថ្វាយដល់ព្រះភគវា ទ្រង់គ្រងសំពត់នោះហើយ
មានព្រះវណ្ណៈ ដូចជាមាសល្អឥតខ្ចោះ ។ ការដែលបុក្កុសមល្លបុត្រ
ប្រសព្វការសម្រេចក្នុងការចូលមកជាឧបាសកក្នុងព្រះពុទ្ធសាសនានេះ
និងការបានធ្វើបុណ្យថ្វាយសំពត់សង្ឃាមួយផ្ទាំងដល់ព្រះលោកនាថ និង
មួយផ្ទាំងទៀតប្រគេនដល់ព្រះអានន្ទ ទាំងនេះរាប់ថា ជាការបំពេញបុណ្យ
ដែលរកឱកាសធ្វើបានដោយកម្រក្រៃពេក ចំពោះការថ្វាយសំពត់សង្ឃា
មួយគូដល់ព្រះបរមគ្រូ ក្នុងកាលដែលជាថ្ងៃបច្ឆិមជន្មាយុ គឺថ្ងៃចុងក្រោយ
ដែលស្ថិតនៅមានព្រះជន្ម តាំងអំពីឆ្នាំ ដែលព្រះអង្គប្រសូតមក គឺ
ក្នុងយប់នៃថ្ងៃនោះ ព្រះអង្គនឹងរំលត់ខន្ធបរិនិព្វាន ដោយការប្រកាន់ថា
ជាឱកាសដែលរកបានដោយកម្រក្រៃលែងបំផុត ព្រោះឱកាសល្អដែល

បានធ្វើបុណ្យដូចនេះ មិនថាបុគ្គលនោះ នឹងទៅកើតក្នុងជាតិណា វណ្ណៈណា ឬត្រកូលដែលជាអ្នកមានធនធានច្រើនយ៉ាងសន្ធឹកសន្ធាប់យ៉ាងណា ប្រសិនបើមិនបានជួបនឹងឱកាសដ៏ល្អ ដូចគ្នានឹងបុក្កុសមល្លបុត្រនេះ ទ្រព្យសម្បត្តិដែលមានច្រើន ទាំងនោះ ក៏មិនគណនាថា ជាវត្ថុសំខាន់ ជាប់ដោយការមិនបានធ្វើបុណ្យកុសល ក្នុងកាលដែលរកបានដោយសែនលំបាកយ៉ាងនេះ ដូច្នោះ ។ រឿងហេតុដែលបានមកជួបនឹងកាលដ៏ប្រសើរ ជាមហាសម័យ គ្រានោះ ត្រូវលើកឲ្យដល់បុក្កុសមល្លបុត្រឧបាសក ។ ម្យ៉ាងទៀត សូម្បីរឿងការធ្វើបុណ្យដោយទូទៅ ដែលយើងគិតឃើញថា ជាវត្ថុដែលយើងធ្វើបានដោយងាយនោះ ការពិតមិនមែនជាវត្ថុដែលធ្វើបានងាយៗ ដូចដែលយើងគិតនោះទេ ការធ្វើបុណ្យកុសលគ្រប់ពេល ត្រូវដល់ព្រមដោយអង្គ ៣ ប្រការ ចំពោះអ្នកធ្វើបុណ្យ គឺ **១- ត្រូវមានបដិគ្គាហក: ២- ត្រូវមានទេយ្យធម៌ ៣- ត្រូវមានសទ្ធា** ។ ប្រសិនបើអ្នកធ្វើបុណ្យមានអង្គប្រកបមិនគ្រប់ គឺខ្វះ១.ណានីមួយ ដូចជាបដិគ្គាហក: គឺអ្នកទទួលទានមិនមាន យើងក៏មិនដឹងឲ្យដល់នរណា

ឬយើងមិនមានទេយ្យធម៌ យើងក៏មិនដឹងនឹងយកអ្វីធ្វើបុណ្យ ឬមានបដិគ្គាហកៈ មានទេយ្យធម៌ព្រមហើយ ប៉ុន្តែយើងមិនមានសទ្ធាដែលនឹងធ្វើបុណ្យ យើងក៏ធ្វើមិនបាន អង្គ ៣ ប្រការនេះ ទើបប្រកាន់ថាជាវត្ថុដ៏សំខាន់ ក្នុងការធ្វើបុណ្យកុសលផ្សេងៗ ។

(ជីវប្រវត្តិរបស់បុក្កុសមល្លបុត្រឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ឆត្តបាណិឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

ឆត្តបាណិឧបាសក ជាអ្នកប្រាជ្ញបានសម្រេចជាព្រះអរិយបុគ្គលថ្នាក់ទី ៣ (អនាគាមី) ជាពិសេសនោះ ជាអ្នកអាចចេះចាំព្រះត្រៃបិដកទាំងបីបាន ទាំងជាអ្នកមានការដ៏ធំជុំវិញខ្លួន ក្នុងផ្លូវលោកបានល្អទៀតផង ទាំងនេះកើតឡើងអាស្រ័យបារមីរបស់លោក ដែលបានសន្សំទុករួចមកហើយក្នុងអតីតជាតិ ។

ជីវប្រវត្តិរបស់ឆត្តបាណិឧបាសក មានសម្តែងប្រាកដនៅក្នុង ***អដ្ឋកថាធម្មបទ*** នៃ ***បុប្ផវគ្គ*** ក្នុងរឿង ***ឆត្តបាណិឧបាសក*** ថា ៖

កាលព្រះមានព្រះភាគ ប្រថាប់នៅក្នុងក្រុងសាវត្ថី បានត្រាស់ព្រះធម៌ទេសនា ដោយទ្រង់ប្រារព្ធឆត្តបាណិឧបាសកឲ្យជាដើមហេតុ ដូចមានសេចក្តីពិស្តារក្នុងរឿងនោះថា នៅក្នុងក្រុងសាវត្ថី មានឧបាសកម្នាក់ឈ្មោះឆត្តបាណិ ឈ្មោះឧបាសកនេះមានន័យថា អ្នកដែលមានឆត្រ

នៅក្នុងដៃ ឬអ្នកដែលកាន់ឆត្រ ។ ឆត្តបាណិឧបាសក ជាអ្នកទ្រទ្រង់ព្រះត្រៃបិដកបានទាំង ៣ និងបានសម្រេចជាព្រះអនាគាមី ។ ថ្ងៃមួយ ឆត្តបាណិឧបាសក បានសមាទានឧបោសថអំពីព្រលឹមហើយ បានទៅគាល់ព្រះសម្ពុទ្ធ ។ សេចក្តីពិតការរក្សាឧបោសថ ដោយការសមាទានគឺទទួលយកសីលមកបដិបត្តិ ព្រះអនាគាមីទាំងឡាយ លោកមិនចាំបាច់សមាទាន (ព្រោះលោកធ្វើឲ្យសីលបរិសុទ្ធជានិច្ចហើយ) ។ ព្រហ្មចរិយៈ គឺការប្រព្រឹត្តធម៌ដ៏ប្រសើរ ហើយការបរិភោគអាហារមួយពេលរបស់ព្រះអនាគាមីទាំងនោះ កើតមកហើយដោយមគ្គ គឺផ្លូវដែលឲ្យដល់ភាពជាព្រះអរិយបុគ្គលតែមួយជាន់ ។ ព្រោះដូច្នោះ ព្រះសាស្តា ទើបទ្រង់បានសម្តែងទុកថា មហាបពិត្រ សូនឆ្នាំងឈ្មោះយដិកាជាអ្នកទទួលទានអាហារមួយពេល ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ជាប្រចាំ ជាអ្នកមានសីល ជាអ្នកមានកល្យាណធម៌ គឺធម៌ដែលល្អ ព្រះអនាគាមីទាំងឡាយ ជាអ្នកបរិភោគអាហារមួយពេល ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ជានិច្ច ។

ម៉្យាងទៀត រឿងសូនឆ្នាំងឈ្មោះយដិកា មានសម្តែងទុកនៅក្នុង

គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក នៃ **ជវាវគ្គ** ក្នុង **ឃដិការសូត្រ** គឺពោលដោយស្ងួនឆ្នាំងឈ្មោះឃដិកា តែនៅក្នុងទីនេះនឹងសូមនាំយកមកពោលដោយបង្រួញដូចមានសេចក្តីថា ៖

សម័យមួយ ព្រះលោកនាយក ស្តេចចារិកទៅក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃជាច្រើន ហើយព្រះអង្គទ្រង់ឈប់គេចទៅក្បែរផ្លូវ ហើយ ទ្រង់ធ្វើអាការញញឹមឲ្យច្បាស់ជាឡើង ពេលនោះ ព្រះអានន្ទបានឃើញអាការញញឹមនោះ ទើបក្រាបទូលសួរដល់ហេតុ ដែលព្រះអង្គទ្រង់ញញឹម ។ គ្រានោះ ព្រះមហាវីរៈត្រាស់ទិទានថា ក្នុងទីកន្លែងនេះធ្លាប់មាននិគមឈ្មោះ **វេភឡិគ** ជានិគមដែលមាំទាំ និងចម្រើនរុងរឿង មានមនុស្សជាច្រើន មានមនុស្សកុះករណែនណាន់តាន់តាប់ ព្រះកស្សបសម្ពុទ្ធ ទ្រង់អាស្រ័យនិគមនេះប្រថាប់នៅអាវាម របស់ព្រះអង្គតាំងនៅក្នុងទីនេះ ហើយព្រះអង្គប្រថាប់គង់ប្រៀនប្រដៅភិក្ខុទាំងឡាយក្នុងអាវាមនេះផងដែរ ។ យុគសម័យនោះ ស្ងួនឆ្នាំងឈ្មោះ ឃដិកាបានជាឧបដ្ឋាក គឺជាអ្នកបម្រើជិតំពូលរបស់ព្រះកស្សបសម្ពុទ្ធ ហើយឃដិកា

មានជោតិបាលមាណពជាសម្ងាញ់ ។ឃដិកាបានបបួលជោតិបាលមាណព ចូលទៅគាល់ព្រះកស្សបសម្ពុទ្ធដល់ទៅ ៣ ដង តែជោតិបាលមាណព ក៏ធ្វើយបដិសេធថា មិនឃើញមានប្រយោជន៍អ្វី ដែលយើងនឹងឃើញ ព្រះសមណៈសីសៈត្រងោលនោះ ។ ឃដិកាទើបបែរជាបបួលជោតិបាល-មាណព ឲ្យយកខ្សែដែលប្រើសម្រាប់ត្រដុស សម្រាប់ជូតខ្លួនទៅកាន់ស៊ីង្គីដើម្បីងូតទឹក ជោតិបាលមាណពក៏យល់ព្រមទទួលពាក្យ ។ឃដិកា កាលឃើញជោតិបាលមាណពងូតទឹកស្រេចហើយ ទើបឆ្ពៀតបបួលទៅគាល់ព្រះកស្សបសម្ពុទ្ធទៀត ដោយអាងថា វត្តនៅមិនឆ្ងាយ យើងមក ចូលទៅគាល់ព្រះសម្ពុទ្ធជាមួយគ្នាណាសម្ងាញ់ ។ គ្រានោះ ជោតិបាល ក៏ពោលបដិសេធដូចដើមដល់ទៅ ៣ ដង ។ឃដិកាក៏មិនលះបង់សេចក្តី ព្យាយាម ទើបចាប់ជាយថ្នក់សំពត់របស់ជោតិបាលមាណព ហើយបបួល ទៀត តែជោតិបាលមាណព ក៏បានពោលជំទាស់ទៀតដែរ ។

កាលនោះ ឃដិកាទើបចាប់សក់ ហើយបបួលទៀត ជោតិបាល-មាណពក៏បានឱកចម្លែកក្នុងចិត្តថា ឃដិកាជាអ្នកមានជាតិខាបមកចាប់សក់

របស់យើង ដែលបានឆ្លងទឹកស្អាតបាតហើយ គង់មិនមែនរឿងបន្តិចបន្តួច ទើបនិយាយថា នែសម្លាញ់ អ្នកបានព្យាយាមមក តាំងអំពីបបួលដោយវាចា ចាប់ត្រង់ជាយថ្នក់ និងចាប់ត្រង់សក់ដើម្បីបបួលឲ្យទៅកាន់សម្នាក់របស់ព្រះសម្ពុទ្ធប៉ុណ្ណោះឯងឬ ? ឃជិកាឆ្លើយទទួលថា ពិតហើយ អះអាងថា ការបានឃើញព្រះសម្ពុទ្ធ ជាការល្អ ។ ជោតិបាលមាណពទើបប្រាប់ឃជិកាឲ្យលែងដៃ ដែលចាប់សក់ ហើយបបួលគ្នាទៅគាល់ព្រះមហាវីរៈ ដើម្បីស្តាប់ព្រះធម្មទេសនា ។ ក្រោយអំពីអ្នកទាំងពីរនោះបានស្តាប់ព្រះធម្មទេសនាអំពីព្រះមានជោគហើយ ជោតិបាលមាណពក៏មានសេចក្តីជ្រះថ្លា បានបព្វជ្ជាឧបសម្បទា នៅក្នុងព្រះពុទ្ធសាសនានោះទៅ ។ ចំណែកឃជិកាមិនអាចចេញបួសបាន ព្រោះត្រូវចិញ្ចឹមមាតាបិតាដែលខ្វាក់ភ្នែកទាំងសងខាង និងជាមនុស្សចាស់ជរាទៀតផង ។ តមក ព្រះកស្សបសម្ពុទ្ធយាងចេញអំពីវេភ្ភគនិគម ទៅប្រថាប់ឯព្រៃឥសិបតនមិគទាយវន នាក្រុងពារាណសី ។ សម័យនោះ ព្រះបាទកិកិដែលជាព្រះរាជានៃដែនកាសីបានយាងទៅគាល់ទ្រង់ស្តាប់ព្រះធម្មទេសនា

ហើយ ទ្រង់ក៏មានសេចក្តីជ្រះថ្លា ទើបទ្រង់ក្រាបទូលព្រះកស្សបសម្ពុទ្ធ ព្រមដោយភិក្ខុសង្ឃ ឲ្យមកទទួលចង្ហាន់ក្នុងថ្ងៃស្អែក ហើយទ្រង់បានក្រាបទូលអាវាធនា ឲ្យព្រះអង្គទ្រង់ចាំវស្សានៅក្នុងក្រុងពារាណសី ។ ព្រះកស្សបសម្ពុទ្ធគ្រាស់បដិសេធ ដោយទ្រង់អាងថា តថាគតទទួលអាវាធនាទុកគេមុនហើយ ។ គ្រានោះ ព្រះបាទកិកិទ្រង់ត្រិះរិះទៅផ្សេងៗ ដោយទ្រង់ខូចព្រះទ័យ ទើបទ្រង់ក្រាបទូលសួរថា មាននរណានឹងជាឧបដ្ឋាកបានក្រៃលែងជាងខ្ញុំព្រះករុណា ព្រះអង្គ ? ព្រះកស្សបសម្ពុទ្ធបានត្រាស់ពណ៌នាគុណ របស់ស្ងួនឆ្នាំងឈ្មោះឃដិកា ដែលនៅក្នុងវេកឡិគនិគមថា ជាអ្នករាប់អានព្រះរតនត្រ័យយ៉ាងមាំទាំ ជាអ្នករក្សាសីល ដែលជារបស់ព្រះអរិយបុគ្គលទាំងឡាយ ជាអ្នកមិនមានសេចក្តីសង្ស័យក្នុងអរិយសច្ចទាំង ៤ ទាំងជាអ្នកបរិភោគអាហារតែមួយពេល ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ជាអ្នកមានធម៌ស្អាត ជាអ្នកមិនជាប់ជំពាក់ក្នុងផ្លូវលោកិយ ជាអ្នកចិញ្ចឹមមាតាបិតាដែលចាស់ជរា និងខ្វាក់ភ្នែកទៀតផង ទាំងជាអ្នកអស់សំយោជនៈខាងក្រោម ៥ ប្រការហើយ

និងបានឡើងទៅកើតក្នុងព្រហ្មលោក ហើយបរិនិព្វានក្នុងព្រហ្មលោក ដោយមិនត្រឡប់មកអំពីព្រហ្មលោកនោះទេ ហើយគេជាអ្នកមានសេចក្តីស្និទ្ធស្នាលជាមួយនឹងតថាគត ។

គ្រានោះ ព្រះបាទកិកិ ទ្រង់ស្តាប់កិត្តិគុណ របស់យជិកាហើយ ទ្រង់ក៏កើតសេចក្តីជ្រះថ្លា ទើបត្រាស់បញ្ជាឲ្យបញ្ជូនអង្ករនៃស្រូវសាលី ដែលមានពណ៌.សដូចផ្កាម្ទិះក្រពុំ ដែលកើតក្នុងជីលឿង ៥ រយរទេះ ព្រមទាំងម្ហូបដែលសមគួរនឹងអង្ករនោះ ទៅព្រះរាជទានឲ្យដល់យជិកាស្ងួនឆ្នាំងនោះ ។ តែយជិកាមិនព្រមទទួលវត្ថុ ដែលជាព្រះរាជទានទាំងនោះទេ ហើយនិយាយនឹងពួករាជបុរសនោះថា ព្រះរាជាមានព្រះរាជ-ករណីយកិច្ចជាច្រើន វត្ថុទាំងនេះមិនសមគួរដល់ខ្ញុំទេ ចូរនាំត្រឡប់ទៅថ្វាយព្រះរាជាវិញចុះ ។ ព្រះលោកនាថត្រាស់និទានដូច្នេះហើយ ទើបត្រាស់សរុបឲ្យព្រះអានន្ទស្តាប់ថា ក្នុងសម័យនោះ តថាគតបានកើតជាជោតិបាលមាណព ហើយព្រះអានន្ទ ក៏មានសេចក្តីត្រេកអរវីរភាយចំពោះព្រះពុទ្ធតម្រាស់នោះណាស់ ។

រឿងរបស់ឆត្តបាណិឧបាសក ក៏មានសម្តែងនៅក្នុង **អដ្ឋកថាគម្ពីរធម្មបទ** ដែរ ដូចមានសេចក្តីថា ៖

ឆត្តបាណិឧបាសក ជាអ្នករក្សាឧបោសថ ដូចស្ងួនធ្នាំងឈ្មោះយដិកាដែរ ហើយគេបានចូលទៅគាល់ព្រះវិជិតមារ ថ្វាយបង្គំរួចហើយក៏អង្គុយស្តាប់ធម្មកថា ។ ក្នុងសម័យនោះ ព្រះបាទបសេនទិកោសលបានយាងចូលទៅគាល់ព្រះសក្យមុនី ។ គ្រានោះ ឆត្តបាណិឧបាសកបានក្រឡេកឃើញព្រះរាជាកំពុងយាងមក ទើបគិតថា តើយើងគួរនឹងក្រោកឡើង ឬអត់ហ្ន៎ ហើយលោកក៏មិនក្រោកឡើង ដោយមានការយល់ឃើញថា យើងអង្គុយនៅក្នុងសម្នាក់ព្រះរាជាដ៏លើស (ធម្មរាជ) ការដែលយើងឃើញព្រះរាជាចំពោះប្រទេស ហើយក្រោកឡើងទទួលវាប់ថា មិនសមគួរ តែបើយើងមិនក្រោកទទួល ព្រះរាជាទ្រោកជជាទ្រង់ពិរោធចំពោះយើង សូម្បីកាលព្រះរាជាទ្រង់កំពុងក្រោធ យើងក៏នឹងមិនក្រោកឡើងទទួល ព្រោះថា យើងឃើញព្រះរាជាហើយក្រោកទទួលក៏ឈ្មោះថា យើងគោរពព្រះរាជា តែមិនគោរពព្រះសម្ពុទ្ធ ដូច្នេះយើង

នឹងមិនក្រោកទទួល ហើយក៏មិនក្រោកឡើងទទួលដំណើរព្រះរាជាមែន ។ ធម្មតាបុរសដែលជាបណ្ឌិត ឃើញបុគ្គលដែលអង្គុយនៅក្នុងសម្នាក់របស់លោកដែលគួរគោរពជាងខ្លួន មិនក្រោកទទួលក៏មិនក្រោធ ។ ពេលនោះ ព្រះបាទបសេនទិកោសល បានទតព្រះនេត្រឃើញឆត្តបាណិឧបាសក មិនក្រោកឡើងទទួលក៏ទ្រង់នឹកពិរោធ ទ្រង់ថ្វាយបង្គំព្រះសយម្ភូហើយប្រថាប់គង់នៅក្នុងទីដ៏សមគួរ ។ ព្រះលោកនាថ ទ្រង់ជ្រាបដល់ព្រះរាជាទ្រង់ពិរោធ ទើបត្រាស់ពណ៌នាគុណរបស់ឆត្តបាណិឧបាសកថា មហាបពិត្រ ឆត្តបាណិឧបាសកនេះ ជាបណ្ឌិត ជាអ្នកឃើញធម៌ហើយ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដកទៀតផង ជាអ្នកឈ្វាសក្នុងវត្ថុដែលជាប្រយោជន៍ និងមិនមែនជាប្រយោជន៍ ។

កាលព្រះបាទបសេនទិកោសល ទ្រង់ស្តាប់គុណកថា របស់ឆត្តបាណិឧបាសកហើយ ទ្រង់ក៏មានព្រះទ័យទន់ទោរទៅវិញ ។ តមកកាលជាខាងក្រោយ ថ្ងៃមួយ ព្រះបាទបសេនទិកោសលប្រថាប់ឈរនៅត្រង់ប្រាសាទជាន់លើ ទ្រង់បានទតឃើញឆត្តបាណិឧបាសក ដែល

បរិភោគអាហារស្រេចហើយ ដែលកំពុងតែដើរចង្ក្រមឆត្រ ពាក់ស្បែកជើងដើរទៅតាមព្រះលានហ្លួង ព្រះអង្គទើបត្រាស់បញ្ជាឲ្យរាជបុរសហៅឆត្តបាណិឧបាសកមកគាល់ ។ គ្រានោះ ឆត្តបាណិឧបាសក ទើបបិទឆត្រ ដោះស្បែកជើងចេញ ហើយចូលទៅគាល់ព្រះរាជា ថ្វាយបង្គំហើយ បានស្ថិតនៅក្នុងទីដ៏សមគួរ ។ លំដាប់នោះ ព្រះបាទបសេនទិកោសលត្រាស់សួរឆត្តបាណិឧបាសកថា ឧបាសកដ៏ចម្រើន ហេតុអ្វីលោកទើបដោះឆត្រ និងដោះស្បែកជើងចេញ ? ពេលនោះ ឆត្តបាណិឧបាសកក្រាបបង្គំទូលថា ព្រះករុណាថ្ងៃវិសេស ទូលបង្គំបានស្តាប់ថា ព្រះរាជាបញ្ជាឲ្យហៅ ហើយទើបចូលគាល់ ក្រាបទូល ។ គ្រានោះ ព្រះបាទបសេនទិកោសល ទើបត្រាស់ថា លោកឃើញ និងជីងថា យើងជាព្រះរាជាក្នុងថ្ងៃនេះទេដឹង ? ឆត្តបាណិឧបាសកក្រាបបង្គំទូលថា ទូលបង្គំដឹងថា ព្រះអង្គជាព្រះរាជាគ្រប់កាល ក្រាបទូល ។ ព្រះបាទបសេនទិកោសលត្រាស់សួរថា កាលលោកដឹងដូច្នេះហើយ ព្រោះហេតុអ្វីក្នុងថ្ងៃដែលយើងចូលទៅគាល់ព្រះអង្គ ហើយលោកអង្គុយនៅក្នុងសម្នាក់

របស់ព្រះមុនី លោកបានក្រឡេកឃើញយើងហើយ ហេតុអ្វីក៏មិនក្រោកឡើងទទួល ? ឆត្តបាណិឧបាសកក្រាបបង្គំទូលថា បពិត្រមហារាជ ទូលបង្គំអង្គុយនៅក្នុងសម្នាក់របស់ព្រះរាជាដ៏ប្រសើរ កាលបានឃើញព្រះរាជាចំពោះប្រទេស ហើយក្រោកឡើងទទួល ចាត់ថាជាអ្នកមិនគោរពក្នុងព្រះសុគតឡើយ ព្រោះដូច្នោះ ទូលបង្គំទើបមិនក្រោកឡើងទទួលព្រះអង្គ ក្រាបទូល ។

គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទើបត្រាស់ថា រឿងនោះចោលទៅចុះ តែបានឮមកថា លោកជាអ្នកដឹងក្នុងវត្តដែលជាប្រយោជន៍ និងមិនមែនជាប្រយោជន៍ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងអនាគត ជាអ្នកចេះចប់ព្រះត្រៃបិដក លោកចូរបង្រៀនធម៌ពួកយើង ខាងក្នុងព្រះរាជវាំងផងចុះ ។ គ្រានោះ ឆត្តបាណិឧបាសកក្រាបបង្គំទូលថា ព្រះករុណាថ្លៃវិសេស ទូលបង្គំមិនអាចបង្រៀនបានទេ ព្រះអង្គ ។ លំដាប់នោះ ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វីឧបាសកដ៏ចម្រើន ? ពេលនោះ ឆត្តបាណិឧបាសក បានក្រាបបង្គំទូលថា ព្រោះ

ហេតុថា ធម្មតាព្រះរាជមន្ទីរ រមែងជាទីកន្លែងដែលមានទោសច្រើន ការធ្វើល្អ និងការធ្វើអាក្រក់នៅក្នុងព្រះរាជមន្ទីរ រមែងប្រាកដផលអាក្រក់ខ្លាំងក្លា ក្រាបទូល ។ព្រះរាជាទើបត្រាស់ឃាត់ថា លោកកុំពោលដូច្នោះឡើយ លោកកុំនឹកខ្លាចក្រែង រវែងចិត្តថា ចំពោះថ្ងៃដែលកន្លងមកហើយឲ្យសោះ ដែលលោកបានឃើញយើង ហើយមិនបានក្រោកឡើងទទួលយើងនោះ ។ គ្រានោះ ធត្តបាណិបានក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ស្ថានទីដែលជាទីត្រាច់ទៅរបស់គ្រហស្ថទាំងឡាយជាស្ថានទីដែលមានទោស សូមព្រះអង្គមេត្តាអាណាបពូជិតមួយអង្គមកបង្រៀនធម៌ចុះ ក្រាបទូល ។

គ្រានោះ ព្រះរាជាទ្រង់បញ្ជូនធត្តបាណិឧបាសកទៅ ដោយព្រះរាជតម្រាស់ថា ល្អហើយអ្នកដ៏ចម្រើន សូមលោកទៅចុះ ហើយព្រះអង្គយាងចូលទៅគាល់ព្រះមានព្រះភាគ ទ្រង់ក្រាបទូលចំពោះព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមល្លិកាទេវី និងវាសភខត្តិយាបានប្រាប់ខ្ញុំព្រះអង្គថា ចង់រៀនធម៌ ហេតុដូច្នេះ សូមព្រះលោកនាថ ព្រមទាំង

ភិក្ខុសង្ឃប្រមាណ ៥០០ សូមស្តេចយាងទៅវាជវាំងរបស់ខ្ញុំព្រះករុណា ជាប្រចាំ ដើម្បីបង្រៀនធម៌ដល់ព្រះនាងទាំងពីរអង្គនោះផងចុះ ព្រះអង្គ ។ លំដាប់នោះ ព្រះទសពល ទ្រង់ត្រាស់ចង្អុលបង្ហាញថា មហាបពិត្រ ធម្មតាព្រះពុទ្ធទាំងឡាយ មិនទៅក្នុងស្ថានទីតែមួយកន្លែងជានិច្ចទេ ។ ពេលនោះ ព្រះរាជាទ្រង់ជ្រាបដូច្នោះហើយ ទើបទ្រង់ក្រាបទូលថា បើយ៉ាងនោះ សូមព្រះមហាវីរៈប្រទានភិក្ខុមួយអង្គដទៃនិមន្តទៅក៏បាន ព្រះអង្គ ។ ព្រះមហាមុនី ទ្រង់ប្រគល់ការៈនេះឲ្យទៅព្រះអានន្ទឲ្យជាអ្នក បង្រៀនធម៌ដល់ព្រះរាជទេវីទាំងពីរព្រះអង្គនោះជាប្រចាំ ។ បណ្តាព្រះ រាជទេវីទាំងពីរព្រះអង្គនោះ ព្រះនាងមល្លិកាទេវី ទ្រង់បានតាំងព្រះទ័យ រៀនសូត្រ ទន្ទេញដោយសេចក្តីគោរព ។ ចំណែកនាងវាសភខត្តិយាទេវី ទ្រង់មិនបានតាំងព្រះទ័យរៀនសូត្រ ទាំងមិនបានទន្ទេញធម៌ ដោយសេចក្តី គោរពទៀតផង ។ តមកថ្ងៃមួយ ព្រះមហាវីរៈត្រាស់សួរព្រះអានន្ទថា ម្នាលអានន្ទ ឧបាសិកាទាំងពីរនាក់នោះ ទ្រង់នៅរៀនធម៌ដដែលឬ ? ព្រះអានន្ទក្រាបទូលថា ឧបាសិកាទាំងនោះ ទ្រង់នៅតែរៀនធម៌ដដែលទេ

ព្រះអង្គ ។ ព្រះមុនីគ្រាស់សួរតទៅទៀតថា ចុះឧបាសិកាទាំងពីរនាក់នោះ មួយណារៀនធម៌ដោយសេចក្តីគោរព ? ព្រះអានន្ទបានក្រាបទូលឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមល្លិកាទេវី ទ្រង់ជាអ្នកសិក្សាទន្ទេញធម៌ ដោយសេចក្តីគោរព ទាំងជាអ្នកគោរពចំពោះព្រះធម៌ ដែលខ្ញុំព្រះអង្គ សម្តែងទៅហើយទៀងផង ព្រះអង្គ ។ ចំណែកធីតាដែលជាព្រះញាតិ របស់ព្រះអង្គ (ព្រះនាងវាសភខត្តិយា ជាធីតារបស់ព្រះមហានាមសក្យរាជ ហើយព្រះមហានាមសក្យរាជជា ព្រះអនុជ (បង្អួនជីដូនមួយ) នឹង ព្រះមានជោគ ដូច្នោះ ព្រះនាងវាសភខត្តិយា ទើបត្រូវជាក្មួយរបស់ ព្រះជិនស្រី) ទ្រង់ជាអ្នកមិនបានសិក្សាទន្ទេញធម៌ដោយគោរព ទាំង ដែលខ្ញុំព្រះករុណាសម្តែងព្រះធម៌ទៅហើយ ព្រះនាងក៏មិនបានតាំង ព្រះទ័យគោរពព្រះធម៌ដែរ ព្រះអង្គ ។ គ្រានោះ ព្រះវិជិតមារ ទ្រង់ស្តាប់ ពាក្យក្រាបទូលរបស់ព្រះអានន្ទហើយ ទើបត្រាស់ថា ម្នាលអានន្ទ ធម៌ ដែលតថាគតសម្តែងទុកល្អហើយ បើបុគ្គលមិនបានស្តាប់ មិនបានរៀន មិនទ្រទ្រង់ចាំទុក មិនបានសម្តែងនូវការគោរព រមែងមិនបានទទួលផល

ប្រៀបដូចផ្កាឈើដែលមានពណ៌សម្បុរ តែមិនមានក្លិនក្រអូបដូច្នោះដែរ ចំណែកបុគ្គលដែលធ្វើកិច្ចទាំងពួង មានការស្តាប់ដោយគោរពជាដើម រមែងបានទទួលផលច្រើន អានិសង្សច្រើនទៀតផង ហើយព្រះអង្គត្រាស់ព្រះគាថាថា

ផ្កាដែលស្អាត តែមិនមានក្លិនក្រអូប យ៉ាងណា វាចាជាសុភាសិត រមែងមិនមានផល ដល់អ្នកមិនធ្វើតាម ដូច្នោះ ។ ចំណែកផ្កាដែលល្អស្អាត មានពណ៌ ព្រមដោយក្លិនក្រអូប យ៉ាងណា វាចាដែលជាសុភាសិត រមែងមានផលដល់អ្នកធ្វើតាម ដូច្នោះដែរ ។

ក្នុងពេលដែលព្រះមុនី ទ្រង់ត្រាស់ទេសនានេះចប់ មានមហាជនជាច្រើនបានសម្រេចអរិយធម៌ទាំងឡាយ មានព្រះសោតាបត្តិផលជាដើម ទៅតាមឧបនិស្ស័យរៀងៗខ្លួន ដែលបានសន្សំទុកតួចមកហើយ ក្នុងអតីតជាតិ ព្រះធម៌ទេសនានៅក្នុងពេលនោះ ក៏បានសម្រេចជាប្រយោជន៍ដល់ពុទ្ធបរិស័ទក្នុងកាលនោះជាច្រើនផងដែរ ។

(ជីវប្រវត្តិរបស់ឆត្តបាណិឧបាសក ចប់)

✍ ជីវប្រវត្តិរបស់ឧបាសិកាគហបតីឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

ឧបាសិកាគហបតី ជាឧបាសកដែលយកចិត្តទុកដាក់ក្នុងព្រះពុទ្ធសាសនានេះ ដោយខាងដើមដំបូង មានការមិនពេញចិត្តចំពោះព្រះភគវា ប៉ុន្តែខាងក្រោយមក កាលគេបានស្តាប់ព្រះធម៌ពីព្រះលោកនាថហើយ បានថ្វាយខ្លួនជាឧបាសកទៅ ។

ជីវប្រវត្តិរបស់ឧបាសិកាគហបតី មានសម្តែងប្រាកដនៅក្នុងព្រះបាលី ***គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក:*** *នៃ* ***គហបតីវគ្គ*** *ក្នុង* ***ឧបាសិកាសូត្រ*** *ដូចមានសេចក្តីថា ៖*

សម័យមួយ ព្រះបរមសាស្តា ប្រថាប់នៅកន្លែងអាបណនិគម អ្នកអង្គុត្តរាប: ក្នុងជែនអង្គុត្តរាប: ។ ក្នុងគ្រានោះ ព្រះជិនវរ ស្តេចបានចារិកបិណ្ឌបាតចូលទៅក្នុងអាបណនិគម លុះពេលស្តេចយាងត្រឡប់អំពីបិណ្ឌបាត ក្រោយទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ស្តេចបានទៅប្រថាប់

ដើម្បីទ្រង់សម្រាកពេលថ្ងៃនៅទៀបគល់ឈើមួយដើមនៅក្នុងព្រៃសណ្ឋៈ មួយកន្លែង ។ ឯគហបតី ក៏បានចូលទៅក្នុងព្រៃសណ្ឋៈ ត្រង់ព្រះសមុទ្ទប្រថាប់សម្រាក ។ កាលបើគហបតីបានចូលទៅដល់ព្រៃសណ្ឋៈនោះហើយ ទើបចូលទៅគាល់ព្រះសមុទ្ទដល់ទីប្រថាប់ បានសម្តែងការគោតសរសើរគ្រែកអរ និងមានវាចាប្រុស្រ័យជាមួយនឹងព្រះសាស្តាតាមសមគួរហើយ ក៏បានឈរនៅក្នុងទីដ៏សមគួរ ។ ពេលនោះ ព្រះលោកនាយកត្រាស់នឹងបោតលិយគហបតី ដែលឈរនៅក្នុងទីដ៏សមគួរដល់ខ្លួនថា ម្នាលគហបតី ទីអង្គុយមាន បើសិនអ្នកប្រាថ្នា ក៏អង្គុយចុះ ។ លំដាប់នោះ បោតលិយគហបតីបានស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ ក៏ក្រោធចំពោះព្រះមហាវីរៈ ដោយនឹកតូចចិត្តថា ព្រះសមណគោតម ហៅយើងដោយពាក្យថា គហបតី ហើយគេបាននៅស្ងៀមព្រងើយ ។ គ្រានោះ ព្រះមុនីបានត្រាស់ប្រាប់បោតលិយគហបតី ដោយត្រាស់ជូចក្នុងគ្រាដំបូងដល់ទៅ ៣ ដង ។ ចំណែកបោតលិយគហបតី ក៏មិនព្រមអង្គុយ ព្រោះគេមិនពេញចិត្តចំពោះវាចារបស់ព្រះសាស្តា ដែលត្រាស់ហៅថា គហបតី ។

កាលបើបោតលិយគហបតី បានស្តាប់ព្រះមានបុណ្យត្រាស់ប្រាប់ក្នុងគ្រាទី ៣ ហើយ ទើបទូលឡើងដោយវាចាមិនពេញចិត្តថា ព្រះគោតម ព្រះតម្រាស់ដែលព្រះអង្គត្រាស់ហៅខ្ញុំម្ចាស់ ដោយពាក្យថា គហបតីនោះ រាប់ថាជាការមិនសមគួរឡើយ ។ គ្រានោះ ព្រះមានជោគ ទើបត្រាស់ថា ម្នាលគហបតី អាការរបស់លោក ភេទរបស់លោក គ្រឿងសម្គាល់របស់លោក ក៏ដូចគ្នានឹងគហបតីទាំងអស់ ។ ពេលនោះ បោតលិយគហបតី ទើបទូលតបថា ការពិតយ៉ាងនោះ ព្រះគោតម ប៉ុន្តែដែលថា ខ្ញុំម្ចាស់បានលះបង់ចោលការងារទាំងអស់នោះហើយ បានកាត់ពាក្យហៅទាំងអស់នោះហើយ ។លំដាប់នោះព្រះមានជោគត្រាស់សួរថាម្នាលគហបតី ដែលលោកថា លោកបានបោះបង់ចោលការងារទាំងអស់ហើយ បានកាត់ពាក្យហៅទាំងអស់នោះហើយ គឺយ៉ាងណា ? គ្រានោះ បោតលិយគហបតីក្រាបទូលតបថា ព្រះគោតម សូមប្រទានឱកាស គឺទ្រព្យ មាស ប្រាក់ បុត្រភរិយា មត៌ក ស្រែចម្ការទាំងអស់ ដែលជារបស់ខ្ញុំម្ចាស់ ដែលខ្ញុំម្ចាស់មាន បានប្រគល់ឲ្យដល់កូនទាំងអស់ហើយ ខ្ញុំម្ចាស់មិន

បានយកចិត្តទុកដាក់ ថែមទាំងមិនបានពោលប្រៀនប្រដៅទៅដោយប្រការណាៗ ទេ ខ្ញុំម្ចាស់បានត្រឹមតែបរិភោគអាហារ និងប្រើប្រាស់សំពត់ស្បៀកដណ្តប់តែម្យ៉ាងប៉ុណ្ណោះ ទើបថាខ្ញុំម្ចាស់បានលះបង់ការងារទាំងអស់នោះហើយ បានកាត់ពាក្យហៅទាំងអស់នោះទៀតផង ។

លំដាប់នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ម្នាលគហបតី ការកាត់វោហារ គឺពាក្យសម្តីការហៅរបស់លោក និងការកាត់ពាក្យហៅរបស់ព្រះអរិយៈផ្សេងពីគ្នា ។ពេលនោះ ឧគ្គតលិយគហបតី ទើបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ការកាត់វោហារ គឺពាក្យសម្តី ការហៅរបស់ព្រះអរិយៈនោះយ៉ាងណា ព្រះអង្គ ? សូមព្រះអង្គមេត្តាអនុគ្រោះសម្តែងឲ្យខ្ញុំព្រះអង្គបានស្តាប់ផងចុះ ។ គ្រានោះ ព្រះសម្ពុទ្ធត្រាស់ថា ម្នាលគហបតី ប្រសិនបើយ៉ាងនោះ អ្នកចូរតាំងចិត្តស្តាប់ឲ្យល្អ តថាគតនឹងសម្តែងឲ្យស្តាប់ក្នុងកាលឥឡូវនេះ ។ ឧគ្គតលិយគហបតីក្រាបទូលថា ខ្ញុំព្រះអង្គនឹងតាំងចិត្តស្តាប់ដោយគោរព ព្រះអង្គ ។ ព្រះលោកនាយក ទើបត្រាស់ថា ម្នាលគហបតី មានធម៌ ៨ ប្រការ ដែលជាហេតុឲ្យកាត់

នូវវោហារ គឺពាក្យសម្តី ការហៅតាមវិន័យរបស់ព្រះអរិយៈធម៌ ៨ ប្រការនោះ ដូចម្តេច ? គឺបុគ្គលគួរលះ **១- លះបាណាតិបាត** ព្រោះអាស្រ័យការមិនសម្លាប់សត្វ **២- លះអទិន្នាទាន** ព្រោះអាស្រ័យការកាន់យកតែវត្ថុដែលគេឲ្យ **៣- លះមុសាវាទ** ព្រោះអាស្រ័យសច្ចវាចា **៤- លះបិសុណាវាចា** អាស្រ័យវាចាមិនញុះញង់ **៥- លះការលោក** ដោយការមិនត្រេកអរ អាស្រ័យការមិនលោក ដោយមិនមាននូវសេចក្តីត្រេកអរ **៦- លះការក្រោធ** ដែលកើតពីការនិន្ទា ព្រោះអាស្រ័យការមិនក្រោធដែលកើតពីការនិន្ទា **៧-លះការថ្នាំងថ្នាក់ដែលកើតពីការក្រោធ** អាស្រ័យការមិនថ្នាំងថ្នាក់ដែលកើតពីការក្រោធ **៨- លះការមើលងាយអ្នកជង្រៃ** ព្រោះអាស្រ័យការមិនមើលងាយអ្នកជង្រៃ ។ម្នាលគហបតី ធម៌ ៨ ប្រការនេះឯង តថាគតពោលដោយសេចក្តីសង្ខេប នៅមិនទាន់ចែកឲ្យពិស្តារ រមែងជាហេតុ ដើម្បីកាត់វោហារ គឺពាក្យសម្តី ការហៅតាមវិន័យរបស់ព្រះអរិយៈ ។ គ្រានោះ ឧបាសកគហបតី ទើបក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គ ទ្រង់ព្រះករុណាចែកធម៌

៨ ប្រការនេះ ឲ្យពិស្តារផងចុះ ព្រះអង្គ ។ លំដាប់នោះ ព្រះមហាវីរៈ
ត្រាស់ថា ម្នាលគហបតី ពាក្យដែលតថាគតពោលរួចមកហើយថា
គួរលះបាណាតិបាត អាស្រ័យការមិនសម្លាប់សត្វ តថាគតពោលអាស្រ័យ
ហេតុផលអ្វី ? ម្នាលគហបតី អរិយសាវ័កនៅក្នុងធម្មវិន័យនេះ រមែង
ពិចារណាឃើញថា យើងបានជាអ្នកបដិបត្តិដើម្បីលះឲ្យដាច់នូវសំយោជនៈ
(គឺកិលេសដែលចងរឹតចិត្តសត្វ) ដែលជាដើមហេតុឲ្យធ្វើបាណាតិបាត
អទិន្នាទាន មុសាវាទ បិសុណាវាចា ការលោកដោយមានតម្រេកត្រេកអរ
ការក្រោធដែលកើតពីការនិន្ទា ការថ្នាំងថ្នាក់ដែលកើតពីការក្រោធ និង
ការមើលងាយអ្នកដទៃ ។ បើយើងនៅតែធ្វើបាណាតិបាត អទិន្នាទាន
មុសាវាទ បិសុណាវាចា ការលោកដោយមានតម្រេកត្រេកអរ ការក្រោធ
ដែលកើតពីការនិន្ទា ការថ្នាំងថ្នាក់ដែលកើតពីការក្រោធ និងការមើលងាយ
អ្នកដទៃហើយ យើងក៏តិះដៀលខ្លួនឯងបាន វិញ្ញូជន (អ្នកចេះដឹង)
ពិចារណាហើយ ក៏នឹងតិះដៀលយើងបាន កាលបើស្លាប់ហើយ នឹង
ត្រូវបានទៅកាន់ទុគ្គតិ ការធ្វើបាណាតិបាត ។ល។ និងធ្វើការមើលងាយ

អ្នកជនៃ ជាសំយោជនៈ ជានីវរណៈ (កិលេសដែលរារាំងមិនឲ្យលុះក្នុងសេចក្តីល្អ) អាសវៈ (កិលេសដែលត្រាំក្នុងសន្តាន) ធ្វើឲ្យកើតការចង្អៀតចង្អល់ និងការក្តៅក្រហាយ ក្រវល់ក្រវាយទាំងនេះ រមែងមិនមានដល់អ្នកធ្វើបាណាតិបាត ។ល។ និងមិនធ្វើការមើលងាយអ្នកជនៃ ពាក្យដែលតថាគតពោលដូច្នេះ ព្រោះអាស្រ័យសេចក្តីយ៉ាងនេះឯង ។

ម្នាលគហបតី ធម៌ ៨ ប្រការ ដែលតថាគតពោលទុកហើយដោយសង្ខេប ប៉ុន្តែមិនបានចែកដោយពិស្តារនេះឯង ជាហេតុឲ្យកាត់ផ្តាច់នូវវោហារ គឺពាក្យសម្តីហៅក្នុងវិន័យរបស់ព្រះអរិយៈនោះ ម្នាលគហបតី ប៉ុន្តែត្រឹមតែប៉ុណ្ណោះ នៅមិនទាន់បានកាត់វោហារ គឺពាក្យសម្តីហៅទាំងពួងបានជាច់ខាតឡើយ ។ គ្រានោះ ឧគ្គតលិយគហបតី ទើបក្រាបបង្គំទូលថាបពិត្រព្រះអង្គដ៏ចម្រើនក៏ការពោលយ៉ាងណាទើបបានឈ្មោះថាជាការកាត់វោហារជាច់បាន ដោយប្រការទាំងពួងក្នុងធម្មវិន័យរបស់ព្រះអរិយៈ សូមព្រះមានព្រះភាគ ទ្រង់មេត្តាសម្តែងឲ្យខ្ញុំព្រះករុណាបានស្តាប់ផងចុះ ព្រះអង្គ ? លំដាប់នោះ ព្រះលោកនាយកត្រាស់ថា

ម្នាលគហបតី ប្រសិនបើយ៉ាងនោះ លោកចូរតាំងចិត្តស្តាប់ ដោយគោរពចុះ តថាគតនឹងសម្តែងឲ្យអ្នកស្តាប់ ។ ពេលនោះ ឧបាលិយគហបតី ក្រាបបង្គំទូលទទួលថា ខ្ញុំព្រះអង្គនឹងតាំងចិត្តស្តាប់ដោយគោរពព្រះអង្គ ។ គ្រានោះ ព្រះមហាវីរបុរស ទ្រង់បានសម្តែងព្រះធម៌ឲ្យដល់ឧបាលិយគហបតីថា ម្នាលគហបតី សុនខដែលកំពុងតែឃ្លាន បានដើរចូលទៅឈរនៅក្បែរជ្រញ៉ាររបស់នាយគោឃាតក: (គឺអ្នកសម្លាប់គោ) នាយគោឃាតក: ឬកូនឈ្នួលរបស់នាយគោឃាតក:ដែលឆ្លាត បានបោះគ្រោងឆ្អឹងដែលពន្លះសាច់ចេញអស់ មិនមានសាច់ នៅសល់ជាប់នឹងឆ្អឹងនោះ មានតែឈាមប្រឡាក់ឲ្យទៅដល់សុនខនោះ តើសុនខនោះលិទ្ធ និងកកេរស៊ីគ្រោងឆ្អឹងនោះ តើអាចបំបាត់ការស្រេកឃ្លានបានដែរឬទេ ? ពេលនោះ ឧបាលិយគហបតីក្រាបបង្គំទូលថា មិនបានទេ ព្រះអង្គ ព្រោះហេតុថា គ្រោងឆ្អឹងនោះមិនមានសាច់នៅជាប់ មានតែឈាមដែលប្រឡាក់ជាប់នឹងឆ្អឹង ត្រឡប់បន្តែមធ្វើឲ្យសុនខនោះ បានទទួលនូវការលំបាក ការចង្អៀតចង្អល់តែប៉ុណ្ណោះ ព្រះអង្គ ។ លំដាប់នោះ

ព្រះមានបុណ្យទើបត្រាស់ថា ម្នាលគហបតី សេចក្តីនេះក៏ដូច្នោះឯង ព្រះអរិយសាវ័កវមែងពិចារណាឃើញថា កាមារម្មណ៍ទាំងឡាយ ព្រះមុនីទ្រង់សម្តែងថា ប្រៀបដូចជាគ្រោងឆ្អឹង ជារបស់មានទុក្ខច្រើន មានការចង្អៀតចង្អល់ច្រើន មានទោសច្រើន កាលបើឃើញទោសនៃកាមនេះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងវៀរជាច់នូវឧបេក្ខា ដែលមានអារម្មណ៍ផ្សេងៗ ដែលអាស្រ័យអារម្មណ៍ផ្សេងៗ នោះចេញ ហើយអប់រំឧបេក្ខា ដែលមានអារម្មណ៍តែមួយ ដែលអាស្រ័យអារម្មណ៍តែមួយ ដែលជាទីរលត់មិនមានសេសសល់ ការប្រកាន់មាំនូវលោកាមិស (គ្រឿងបោកបញ្ឆោតចិត្តឲ្យជាប់ក្នុងលោក បានដល់កាមគុណ ៥) ដោយប្រការទាំងពួង ។

ម្នាលគហបតី ត្នាត ក្អែក ឬត្រដក់ ពាំចំណិតដុំសាច់ហើរទៅបាន មានសត្វត្នាត ក្អែក ត្រដក់ជទៃៗ ហើរជាប់តាមទៅចោមរោម ចឹកជណ្តើមយកដុំសាច់នោះ ប្រសិនបើត្នាត ក្អែក ត្រដក់នោះ មិនប្រញាប់លែងដុំសាច់នោះចេញទេ ត្នាត ក្អែក តាជក់នោះ នឹងត្រូវដល់នូវសេចក្តីស្លាប់

ឬជល់នូវទុក្ខស្ទើរតែនឹងស្លាប់ ព្រោះដុំសាច់នោះ ជាដើមហេតុមិនមែនឬ ?
គ្រានោះ ឧបាសិយគហបតីក្រាបទូលថា មែន ព្រះអង្គ ។ លំដាប់នោះ
ព្រះជិនស្រីទើបត្រាស់បន្តទៀតថា ម្នាលគហបតី សេចក្តីនេះដូច្នោះឯង
ព្រះអរិយសាវ័កវៀរមែងពិចារណាឃើញថា ព្រះសាស្តាទ្រង់សម្តែងទុកថា
កាមារម្មណ៍ទាំងឡាយ ប្រៀបដូចជាដុំសាច់ ជារបស់មានទុក្ខច្រើន មានការ
ចង្អៀតចង្អល់ច្រើន មានទោសច្រើន កាលបើឃើញទោសនៃកាមតាម
សេចក្តីពិត ដោយបញ្ញាដ៏ក្រៃលែងយ៉ាងនេះហើយ រមែងវៀរជាច់នូវឧបេក្ខា
ដែលមានអារម្មណ៍ផ្សេងៗ ដែលអាស្រ័យអារម្មណ៍ផ្សេងៗហើយអប់រំ
ឧបេក្ខាដែលមានអារម្មណ៍តែមួយ ដែលអាស្រ័យអារម្មណ៍តែមួយ
ដែលជាទីរលត់ទៅ មិនឲ្យមានសេសសល់ ការប្រកាន់លោកាមិស
ដោយប្រការទាំងពួង ។ ម្នាលគហបតី មានបុរសកាន់គប់ភ្លើងស្មៅ
ដែលមានភ្លើងឆេះសន្ធោសន្ធៅហើយ ដើរបញ្ឆោះខ្យល់ទៅ ប្រសិនបើ
បុរសនោះមិនប្រញាប់ចោលគប់ភ្លើងនោះទេ គប់ភ្លើងនោះនឹងត្រូវឆេះដៃ
ឆេះជើង ឬឆេះអវយវៈតូចធំ យ៉ាងណានីមួយរបស់គេៗ ក៏នឹងដល់នូវ

សេចក្តីស្លាប់ ឬជល់នូវទុក្ខស្ទើរតែនឹងស្លាប់ ព្រោះគប់ភ្លើងនោះជាដើមហេតុមិនមែនឬ ? ឧបាសិយគហបតីក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ ។ ព្រះវិជិតមារត្រាស់តទៅទៀតថា ម្នាលគហបតី សេចក្តីនេះក៏ដូច្នោះដែរ គឺព្រះអរិយសាវ័កវៀរមែងពិចារណាឃើញថា ព្រះមានព្រះភាគទ្រង់បានសម្តែងទុកថា កាមារម្មណ៍ទាំងឡាយ ប្រៀបដូចជាគប់ភ្លើង ជារបស់មានទុក្ខច្រើន មានការចង្អៀតចង្អល់ច្រើន មានទោសច្រើន កាលបើឃើញទោសរបស់កាមនេះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ វៀរមែងវៀរជាច់នូវឧបេក្ខាដែលមានអារម្មណ៍ផ្សេងៗ ដែលអាស្រ័យអារម្មណ៍ផ្សេងៗ ហើយអប់រំឧបេក្ខា ដែលមានអារម្មណ៍តែមួយ អាស្រ័យអារម្មណ៍តែមួយ ដែលជាទីរលត់ទៅ មិនឲ្យមានសេសសល់នូវការប្រកាន់មាំលោកាមិស ដោយប្រការទាំងពួង ។

ម្នាលគហបតី មានរណ្តៅរងើកភ្លើង ដែលជ្រៅជាងមួយជួរបុរសពេញដោយរងើកភ្លើង ដែលប្រាសចាកអណ្តាតភ្លើង និងផ្សែងភ្លើង បើមានបុរសដែលស្រឡាញ់ចំពោះជីវិត មិនចង់ស្លាប់ ស្រឡាញ់សុខ

ស្អប់ទុក្ខ មកដល់ទីនោះហើយ មានបុរសដែលមានកម្លាំងពីរនាក់ ជួយគ្នាចាប់ដៃខាងស្តាំ ដៃខាងឆ្វេងរបស់បុរសនោះ ទាញចូលទៅត្រង់រណ្តៅរងើកភ្លើងបុរសនោះក៏និងបន្ទន់កាយចូលទៅកាន់រណ្តៅរងើកភ្លើងនោះឬទេ ? ឧបាសិយគហបតីក្រាបបង្គំទូលថា មិនបន្ទន់កាយចូលទៅឡើយ ព្រះអង្គ ព្រោះហេតុថា បុរសនោះដឹងថា យើងនឹងធ្លាក់ចុះទៅក្នុងរណ្តៅរងើកភ្លើង ហើយនឹងដល់នូវសេចក្តីស្លាប់ ឬដល់នូវទុក្ខស្ទើរតែនឹងស្លាប់ ព្រោះការធ្លាក់ចុះទៅក្នុងរណ្តៅរងើកភ្លើងជាដើមហេតុ ព្រះអង្គ ។ គ្រានោះ ព្រះសក្យមុនី ត្រាស់ពន្យល់ថា ម្នាលគហបតី សេចក្តីនេះក៏ដូច្នោះដែរ ព្រះអរិយសាវ័កវមែងពិចារណាឃើញថា ព្រះសាស្តាទ្រង់សម្តែងទុកថា កាមារម្មណ៍ទាំងឡាយ ប្រៀបដូចជារណ្តៅរងើកភ្លើង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន មានទោសច្រើន កាលបើឃើញទោសរបស់កាមារម្មណ៍នេះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ វមែងវៀរដាច់នូវឧបេក្ខា ដែលមានអារម្មណ៍ផ្សេងៗ ដែលអាស្រ័យអារម្មណ៍ផ្សេងៗ ហើយក៏អប់រំឧបេក្ខា ដែលមានអារម្មណ៍តែមួយ ដែល

ជាទីរលត់ទៅ មិនឲ្យមានសេសសល់នូវការប្រកាន់មាំលោកាមិស ដោយប្រការទាំងពួង ។ ម្នាលគហបតី មានបុរសសុបិន្តឃើញសួនដែលគួរឲ្យសប្បាយ ព្រៃដែលគួរឲ្យសប្បាយ កន្លែងដែលគួរឲ្យសប្បាយ ស្រះបោក្ខរណីដែលគួរសប្បាយ លុះបុរសនោះភ្ញាក់ឡើង មិនបានឃើញមានអ្វីសោះ យ៉ាងណា ព្រះអរិយសាវក ក៏ដូច្នោះ រមែងពិចារណាឃើញថា ព្រះមានព្រះភាគទ្រង់សម្តែងទុកថា កាមារម្មណ៍ទាំងឡាយប្រៀបដូចវត្ថុដែលយល់សប្តិឃើញ មានទុក្ខច្រើន មានការចង្អៀតចង្អល់ច្រើន មានទោសច្រើន កាលបើឃើញទោសរបស់កាមនេះតាមសេចក្តីពិតដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងវៀរជាច់នូវឧបេក្ខា ដែលមានអារម្មណ៍ផ្សេងៗ ដែលអាស្រ័យអារម្មណ៍ផ្សេងៗ ហើយអប់រំឧបេក្ខាដែលមានអារម្មណ៍តែមួយ ដែលអាស្រ័យអារម្មណ៍តែមួយ ដែលជាទីរលត់ទៅ មិនឲ្យមានសេសសល់ នូវការប្រកាន់មាំលោកាមិស ដោយប្រការទាំងពួង ។

ម្នាលគហបតី បុរសខ្វីវត្ថុរបស់អ្នកដទៃមក គឺខ្វីកែវមណី និង

កុណ្ឌល (ក្រវិល) យ៉ាងល្អទុក ក្នុងយាន ហើយបរទៅកាន់ទីផ្សារ បុគ្គលទាំងឡាយឃើញគេហើយ នាំគ្នានិយាយថា បុរសនេះ ជាអ្នកមានកោគទ្រព្យច្រើន ចានឮថា ជនទាំងឡាយអ្នកមានកោគទ្រព្យ រមែងប្រើប្រាស់កោគទ្រព្យយ៉ាងនេះ ប៉ុន្តែប្រសិនបើម្ចាស់របស់ចានជួបបុរសនោះ ចូលទៅក្នុងស្ថានទីណាៗ ហើយនាំយករបស់គេវិលទៅស្ថានទីនោះៗ បុរសនោះ នឹងខូចចិត្តឬទេ ? គ្រានោះ ឧបាសិយគហបតីក្រាបបង្គំទូលថា មិនខូចចិត្តទេ ព្រះអង្គ ។ សេចក្តីនោះ ព្រោះហេតុអ្វី ? ព្រោះម្ចាស់របស់តែងនឹងនាំយករបស់ខ្លួន វិលមកវិញជាធម្មតា ព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលគហបតី សេចក្តីនេះក៏ដូច្នោះដែរ ព្រះអរិយសាវ័ករមែងពិចារណាឃើញថា ព្រះលោកនាថទ្រង់សម្តែងទុកថា កាមារម្មណ៍ទាំងឡាយប្រៀបដូចជារបស់ខ្ចីគេមក មានទុក្ខច្រើន មានការចង្អៀតចង្អល់ច្រើន មានទោសច្រើន កាលបើឃើញទោសរបស់កាមនេះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃហើយ រមែងវៀរនូវឧបេក្ខា ដែលមានអារម្មណ៍ផ្សេងៗ ដែលអាស្រ័យអារម្មណ៍

ផ្សេងៗ ហើយអប់រំឧបាសិកាដែលមានអារម្មណ៍តែមួយ ដែលអាស្រ័យអារម្មណ៍តែមួយ ដែលជាទីរលត់ទៅ មិនឲ្យមានសេសសល់ នូវការប្រកាន់មាំលោកាមិស ដោយប្រការទាំងពួង ។ម្នាលគហបតី មានព្រៃដ៏ក្រាស់នៅក្នុងទីជិតស្រុកឬនិគម ដើមឈើក្នុងព្រៃនោះ មានផ្លែ មានរសធ្ងាញ់ ទាំងមានផ្លែច្រើន ប៉ុន្តែមិនមានផ្លែជ្រុះចុះមកលើដី សូម្បីត្រឹមតែមួយផ្លែ ។ មានបុរសម្នាក់ ដែលមានន្ទូវសេចក្តីត្រូវការផ្លែឈើ ទើបទៅស្វែងរកផ្លែឈើ បានចូលទៅក្នុងព្រៃក្រាស់នោះ និងបានឃើញដើមឈើដែលមានផ្លែ មានរសធ្ងាញ់ ទាំងមានផ្លែច្រើននោះ គេគិតថា ដើមឈើដើមនេះ មានផ្លែ មានរសធ្ងាញ់ ទាំងមានផ្លែច្រើនប៉ុន្តែមិនមានផ្លែជ្រុះមកលើដី សូម្បីត្រឹមតែមួយផ្លែ យើងនឹងត្រូវឡើងលើដើមឈើនេះ ដើម្បីបេះស៊ីផ្លែ រហូតឆ្អែតគ្រប់គ្រាន់ហើយ ក៏នឹងបេះ ដាក់ថ្នក់ចុះមក លុះគិតឃើញដូច្នេះ គេក៏ឡើងទៅលើដើមឈើនោះ មែនបេះផ្លែស៊ី រហូតដល់ឆ្អែតហើយ ក៏បេះផ្លែឈើនោះ ដាក់ក្នុងថ្នក់ ចុះមកផងដែរ ។ លំដាប់នោះ បានមានបុរសទី ២ ដែលមានសេចក្តីត្រូវការផ្លែឈើដូចគ្នា

បានលីពូថៅដ៏មុតទៅស្វែងរកផ្លែឈើ បានធៀងចូលទៅក្នុងព្រៃក្រាស់នោះ គេបានក្រឡេកឃើញដើមឈើមានផ្លែមានរសឆ្ងាញ់ ទាំងមានផ្លែច្រើន គេទើបគិតថា ដើមឈើនេះមានផ្លែ មានរសឆ្ងាញ់ ទាំងមានផ្លែច្រើន ប៉ុន្តែមិនមានផ្លែជ្រុះចុះមកលើដី សូម្បីត្រឹមតែមួយផ្លែសោះ យើងក៏ឡើងដើមឈើនេះមិនកើត យើងនឹងត្រូវតែកាប់ផ្តួលដើមឈើនេះ នឹងបេះផ្លែស៊ីឲ្យទាល់តែឆ្អែត ថែមទាំងបេះដាក់ថ្នក់ត្រឡប់ទៅវិញផងដែរ គេគិតឃើញដូច្នេះហើយ ទើបកាប់រំលំដើមឈើនោះ ប្រសិនបើបុរសទី ១ នោះដែលឡើងទៅលើដើមឈើនោះ មិនប្រញាប់ចុះមកឲ្យរហ័សទេ ពេលដែលដើមឈើនោះ រំលំចុះមក ដៃជើង ឬអវយវៈតូចធំរបស់គេក៏នឹងត្រូវបាក់ទៅ គេក៏នឹងដល់នូវសេចក្តីស្លាប់ ឬដល់នូវទុក្ខស្ទើរតែនឹងស្លាប់យ៉ាងនោះមែនឬ ? ពេលនោះ ភោគលិយគហបតីក្រាបទូលថា យ៉ាងនោះពិតមែន ព្រះអង្គ ។ គ្រានោះព្រះសម្មាសម្ពុទ្ធ ត្រាស់ប្រៀបធៀបថា ម្នាលគហបតី សេចក្តីនេះក៏ដូច្នោះដែរ ព្រះអរិយសាវ័ករមែងពិចារណាឃើញថា ព្រះសម្ពុទ្ធទ្រង់សម្តែងទុកថា កាមារម្មណ៍ទាំងឡាយ ប្រៀប

ដូចដើមឈើដែល មានផ្លែ មានទុក្ខច្រើន មានការចង្អៀតចង្អល់ច្រើន មានទោសច្រើន កាលបើឃើញទោសរបស់កាមនេះ តាមសេចក្តីពិតដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងវៀរនូវឧបេក្ខាដែលមានអារម្មណ៍ផ្សេងៗ ដែលអាស្រ័យអារម្មណ៍ផ្សេងៗ ហើយអប់រំឧបេក្ខា ដែលមានអារម្មណ៍តែមួយ ដែលអាស្រ័យអារម្មណ៍តែមួយ ដែលជាទីរលត់ទៅ មិនឲ្យមានសេសសល់ នូវការប្រកាន់មាំលោកាមិស ដោយប្រការទាំងពួង ។

ម្នាលគហបតី ព្រះអរិយសាវកនោះ អាស្រ័យឧបេក្ខាដែលជាហេតុឲ្យកើតសតិបរិសុទ្ធ មិនមានធម៌ដទៃក្រៃលែងជាងនេះ អ្នករមែងរឭកដល់ជាតិមុនបានចំនួនជាច្រើន គឺរឭកបានតាំងពីមួយជាតិជាដើមទៅរហូតដល់សំវដ្តកប្បជាច្រើនខ្លះ រហូតវិវដ្តកប្បជាច្រើនខ្លះ រហូតដល់សំវដ្តវិវដ្តកប្បជាច្រើនខ្លះថា ក្នុងភពនោះ យើងមានឈ្មោះយ៉ាងនោះ មានគោត្រយ៉ាងនោះ មានសម្បុរយ៉ាងនោះ មានអាហារយ៉ាងនោះ សោយសុខទុក្ខយ៉ាងនោះៗ បានទៅកើតក្នុងភពនោះ សូម្បីក្នុងភពនោះ

យើងមានឈ្មោះយ៉ាងនោះ មានគោត្រយ៉ាងនោះ ។ល។ មានកំណត់អាយុត្រឹមប៉ុណ្ណោះ ។ កាលបើចុតិចាកភពនោះហើយ បានមកកើតភពនេះ អ្នករមែងរឭកជាតិក្នុងកាលមុនបានជាច្រើន ព្រមទាំងអាការៈ និងឧទ្ទេសដោយប្រការដូច្នេះ ។ ម្នាលគហបតី ព្រះអរិយសាវ័កនោះ អាស្រ័យឧបេក្ខាជាហេតុឲ្យសតិបរិសុទ្ធ ដែលមិនមានធម៌ដទៃក្រៃលែងជាងនេះ អ្នកឃើញពួកសត្វ ដែលកំពុងចុតិ ស្ទាប់ កំពុងឧប្បត្តិ អាក្រក់ល្អ មានសម្បុរល្អ មានសម្បុរមិនល្អ បានសុប្បាយ លំបាកដោយទិព្វចក្ខុដ៏បរិសុទ្ធក្រៃលែងជាងចក្ខុរបស់មនុស្សធម្មតាទាំងឡាយ រមែងដឹងច្បាស់នូវពួកសត្វអ្នកប្រព្រឹត្តទៅតាមកម្មផ្សេងៗ ថា សត្វទាំងនេះប្រកបកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត តិះដៀលព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់ការធ្វើដោយអំណាចមិច្ឆាទិដ្ឋិ កាលបើគេស្ទាប់ទៅហើយ គេរមែងទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក ចំណែកសត្វទាំងនេះ ប្រកបកាយសុចរិត វចីសុចរិត មនោសុចរិត មិនតិះដៀលព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់ការធ្វើដោយអំណាចសម្មាទិដ្ឋិ កាលបើគេស្ទាប់ទៅហើយ គេរមែង

ទៅកាន់សុគតិទេវលោក ដូច្នេះ អ្នកវមែងឃើញពួកសត្វដែលកំពុងចុតិ
កំពុងឧប្បត្តិ អាក្រក់ល្អ មានសម្បុរល្អ មានសម្បុរមិនល្អ សប្បាយ
លំបាក ដោយទិព្វចក្ខុដ៏បរិសុទ្ធក្រៃលែងជាងចក្ខុរបស់មនុស្សធម្មតា
ទាំងឡាយ រមែងដឹងច្បាស់នូវពួកសត្វអ្នកប្រព្រឹត្តទៅតាមកម្ម ដោយ
ប្រការដូច្នេះ ។ ម្នាលគហបតី ព្រះអរិយសាវកនោះ អាស្រ័យឧបេក្ខា
ជាហេតុឲ្យសតិបរិសុទ្ធ មិនមានធម៌ដទៃក្រៃលែងជាងនេះ អ្នកធ្វើឲ្យច្បាស់
នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលរកអាសវៈ គឺកិលេសដែលជាគ្រឿង
ត្រាំនៅក្នុងសន្តានមិនមាន ព្រោះអាសវៈអស់ទៅដោយបញ្ញាដ៏ក្រៃលែង
ក្នុងបច្ចុប្បន្នដែលចូលដល់ ។ ក្នុងទីបំផុតព្រះលោកនាថ ទើបត្រាស់ថា
ម្នាលគហបតី ការកាត់នូវវោហារ គឺពាក្យសម្តីហៅទាំងអស់ដោយប្រការ
ទាំងពួងក្នុងធម្មវិន័យរបស់ព្រះអរិយៈ រមែងមានដោយហេតុត្រឹមតែប៉ុណ្ណោះ
អ្នកយល់ថា ការកាត់វោហារដូច្នេះមាននៅក្នុងខ្លួនអ្នកដែរឬទេ ? គ្រានោះ
ឧបាសិយគហបតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ
នឹងមានអ្វី ទើបនឹងឈ្វេងយល់បាន ព្រះអង្គ ? ការកាត់វោហារ គឺពាក្យ

សម្តីហៅទាំងអស់ឯណា នៅក្នុងធម្មវិនយរបស់ព្រះអរិយៈ ខ្ញុំព្រះអង្គ
នៅឆ្ងាយពីការកាត់ភៅហារ គឺពាក្យសម្តីហៅទាំងនោះ ក្នុងធម្មវិនយ
របស់ព្រះអរិយៈ ដោយប្រការទាំងពួង កាលពីមុនខ្ញុំព្រះអង្គ យល់ថា
ពួកអន្យតិ្ថរិយបរិព្វាជក ដែលមិនមែនអ្នកជីង ថាជាអ្នកជីង បានគប់រក
ថែរក្សាដោយកោជនាហារ ដ៏សមគួរដល់អ្នកជីង បានលើកសរសើរ
នូវពួកអន្យតិ្ថរិយបរិព្វាជក អ្នកមិនជីងទុកក្នុងហាន:អ្នកជីង បពិត្រព្រះអង្គ
ដ៏ចម្រើន ខ្ញុំព្រះអង្គយល់ថា ភិក្ខុទាំងឡាយដែលជាអ្នកជីង ថាមិនមែន
អ្នកជីង បានគប់រកថ្វាយកោជនាហារ ដែលមិនសមគួរដល់អ្នកជីង
បានតាំងភិក្ខុទាំងឡាយទុកក្នុងហាន: ដែលមិនគួរដល់អ្នកជីងមកហើយ
ឥឡូវនេះ ខ្ញុំព្រះអង្គជីងហើយថា ពួកអន្យតិ្ថរិយបរិព្វាជក មិនមែនពួក
អ្នកជីង និងគប់រកថែរក្សាដោយកោជនាហារ ដ៏សមគួរដល់អ្នកមិនជីង
និងតាំងពួកអន្យតិ្ថរិយបរិព្វាជក ទុកក្នុងហាន:ដ៏សមគួរដល់អ្នកមិនជីង
ខ្ញុំព្រះអង្គបានជីងហើយថា ភិក្ខុទាំងឡាយជាអ្នកជីង និងគប់រកថ្វាយ
កោជនាហារ ដ៏សមគួរដល់អ្នកជីង និងលើកសួយនូវភិក្ខុទាំងឡាយ

ទុកក្នុងឋានៈដ៏សមគួរដល់អ្នកជឹង ។

បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់បានធ្វើឲ្យមានន្ទូវសេចក្តីស្រឡាញ់ មានន្ទូវសេចក្តីជ្រះថ្លា មានការគោរពចំពោះពួកសមណៈកើតឡើងដល់ខ្ញុំព្រះអង្គហើយ ព្រះធម៌ទេសនារបស់ព្រះអង្គជាក់ច្បាស់ណាស់ ប្រៀបដូចជាបុគ្គលផ្ងារបស់ដែលផ្កាប់ បើករបស់ដែលបិទចេញ ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬទ្រោលប្រទីបក្នុងទីងងឹត ដោយប្រាថ្នាឲ្យអ្នកមានភ្នែកល្អ នឹងបានមើលឃើញវត្ថុផ្សេងៗ បានយ៉ាងណា ព្រះភគវា ទ្រង់ប្រកាសធម៌ដោយអនេកបរិយាយ ដោយទ្រង់ប្រាថ្នាល្អឲ្យដល់ខ្ញុំព្រះអង្គ ដូច្នោះ ដូចគ្នានឹងខ្ញុំព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ សូមព្រះអង្គចាំទុកខ្ញុំ ថាជាឧបាសកចាប់តាំងអំពីថ្ងៃនេះជាដើមតទៅ រហូតដល់អស់ជីវិតផងចុះ ព្រះអង្គ ។

(ជីវប្រវត្តិរបស់ឧបាសក ចប់)

✍ ជីវប្រវត្តិរបស់នាយចុន្ទកម្មារបុត្រឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

នាយចុន្ទកម្មារបុត្រ ជាឧបាសកដែលបានសម្រេចអរិយធម៌ គឺ ធម៌ដ៏ប្រសើរ ឬធម៌ដែលជួយឲ្យជាអ្នកឆ្ងាយចាកសឹកសត្រូវ ពោលគឺ កិលេស ហើយជាអរិយឧបាសក ដែលបានថ្វាយមហាទានគ្រាចុងក្រោយ ដល់ព្រះលោកនាថ ហើយព្រះអង្គស្តេចរំលត់ខន្ធបរិនិព្វានទៅ ទាំងនេះ ជារឿងមួយ ដែលគួរឲ្យជ្រះថ្លា ថែមទាំងជារឿងឧទាហរណ៍មួយសម្រាប់ ការថ្វាយមហាទាន ។

ជីវប្រវត្តិរបស់នាយចុន្ទកម្មារបុត្រ មានសម្តែងប្រាកដនៅក្នុង ***អដ្ឋកថាបរមត្ថទីបនី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីក្នុង* ***គម្ពីរខុទ្ទកនិកាយ ឧទាន*** *ដូចមានសេចក្តីថា ៖*

នាយចុន្ទ ជាបុត្ររបស់ជាងមាសម្នាក់ ដែលជាអ្នកមានទ្រព្យ-សម្បត្តិស្តុកស្តម្ភ ជាកុដុម្ពិក គឺជាអ្នកមានស្រូវអង្ករ មាស ប្រាក់ជាច្រើន

ជាអ្នកក្រុងបាវា ស្ថិតនៅក្នុង **ដែនមល្ល:** ។ ឈ្មោះពេញរបស់លោក គឺនាយចុន្ទកម្មារបុត្រ ព្រោះការនាំយកឈ្មោះរបស់លោកថា **ចុន្ទ** មកហៅរួមជាមួយនឹងពាក្យថា **កម្មារ** ដែលប្រែថា **ជាងមាស** ដែលជាឈ្មោះអាជីព នៅក្នុងត្រកូលរបស់លោក ទើបហៅថា **ចុន្ទកម្មារ** ។ ចំណែកពាក្យថា **បុត្រ** ដែលនាំមកតភ្ជាប់ជាមួយ **ចុន្ទកម្មារបុត្រ** ដើម្បីជាគ្រឿងប្រាប់ឲ្យដឹងថា លោកជាបុត្រ គឺជាកូនរបស់ជាងមាស ព្រោះដូច្នោះ ឈ្មោះរបស់លោកថា **នាយចុន្ទកម្មារបុត្រ** ប្រែថា នាយចុន្ទកូនប្រុសរបស់ជាងមាស ។

រឿងដែលជាហេតុ ដែលធ្វើឲ្យនាយចុន្ទកម្មារបុត្រ បានក្រាបទូលប្រកាសខ្លួនជាឧបាសក អ្នករាប់អានព្រះរតនត្រ័យអស់មួយជីវិត នៅចំពោះព្រះកក្រ្តនៃព្រះមានព្រះភាគ ទាំងនេះ ព្រោះបានទទួលព្រះមហាករុណាអំពីព្រះសម្មាសម្ពុទ្ធ ដែលទ្រង់គ្រាស់សួរដល់ការពេញចិត្តទាក់ទងនឹងរឿងភាពស្អាតស្អំរបស់ព្រាហ្មណ៍ និងព្រះពុទ្ធសាសនានេះ តាមដែលមានរឿងសម្តែងប្រាកដនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ**

ទសកនិបាត នៃ **ជាណុស្សោណីវគ្គទី ២** ដែលពោលដោយភាពស្អាតក្នុងធម្មវិន័យរបស់ព្រះអរិយៈ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសម្ពុទ្ធ ទ្រង់គង់នៅក្នុងអម្ពវន (ព្រៃស្វាយ) របស់កម្មារបុត្រឈ្មោះចុន្ទ ជិតក្រុងបាវា ។ គ្រានោះ ចុន្ទកម្មារបុត្រ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះចុន្ទកម្មារបុត្រអង្គុយក្នុងទីសមគួរហើយ ព្រះទសពល ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលចុន្ទ អ្នកពេញចិត្តនឹងការស្អាតរបស់អ្នកណា ? ចុន្ទកម្មារបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់លក្កចាន់ (ប្រដាប់សម្រាប់ជងទឹកក្នុងវេលាដើរផ្លូវ គឺ ក្អម, កំសៀវ, បំពង់, កុណ្ឌី, ទីកោ) ប្រើប្រាស់សំពត់ដូចផ្ការសាវយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច តែងបញ្ញត្តនូវការស្អាតខ្ញុំព្រះអង្គពេញចិត្តចំពោះការស្អាតរបស់ព្រាហ្មណ៍ទាំងនោះ ។ ម្នាលចុន្ទ ចុះពួកព្រាហ្មណ៍ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់លក្កចាន់

ប្រើប្រាស់សំពត់ដូចផ្កាសាវយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច តែងបញ្ញត្តនូវការស្អាត យ៉ាងណាខ្លះ ? បពិត្រព្រះអង្គដ៏ចម្រើន ក្នុងលោកនេះពួកព្រាហ្មណ៍ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់លំក្អាចាន់ ប្រើប្រាស់សំពត់ ដូចផ្កាសាវយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច ព្រាហ្មណ៍ទាំងនោះ តែងបបួលពួកសាវកថា នែ៎ បុរសអើយ អ្នកចូរមកអាយ កាលបើអ្នកក្រោកអំពីដំណេក ក្នុងពេលព្រឹកព្រហាម គប្បីសូបផែនដី បើអ្នកមិនសូបផែនដីទេ គប្បីសូបអាចម៍គោស្រស់ បើអ្នកមិនសូបអាចម៍គោស្រស់ទេ គប្បីសូបស្មៅស្រស់ បើអ្នកមិនសូបស្មៅស្រស់ទេ គប្បីបម្រើភ្លើង បើអ្នកមិនបម្រើភ្លើងទេ គប្បីប្រណម្យអញ្ជលីនមស្ការព្រះអាទិត្យ បើអ្នកមិនប្រណម្យអញ្ជលីនមស្ការព្រះអាទិត្យទេ គប្បីចុះទឹកជាគម្រប់ ៣ ដងនឹងពេលល្ងាច ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់លំក្អាចាន់ ប្រើប្រាស់សំពត់ដូចផ្កាសាវយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច តែងបញ្ញត្តនូវការស្អាត យ៉ាងនេះឯង ខ្ញុំ

ព្រះអង្គតែងពេញចិត្ត នឹងការស្អាតរបស់ព្រាហ្មណ៍ទាំងនោះ ។ នែ៎ចុន្ទ ពួកព្រាហ្មណ៍ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់លក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសាវាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច បញ្ញត្តនូវការស្អាតដោយឡែក ចំណែកការស្អាតក្នុងអរិយវិន័យដោយឡែក ។បពិត្រព្រះអង្គដ៏ចម្រើន ចុះការស្អាតក្នុងអរិយវិន័យ តើដូចម្តេច? បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គសម្តែងធម៌ តាមដំណើរការស្អាតក្នុងអរិយវិន័យឲ្យទានដល់ខ្ញុំព្រះអង្គ ! ម្នាលចុន្ទ បើដូច្នោះ អ្នកចូរស្តាប់ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ចុន្ទកម្មារបុត្រទទួលតបព្រះសមុទ្ទថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទ ការមិនស្អាត ដោយកាយមាន ៣ ប្រការ ការមិនស្អាតដោយវាចា មាន ៤ ប្រការ ការមិនស្អាតដោយចិត្តមាន ៣ ប្រការ ។ ម្នាលចុន្ទ ចុះការមិនស្អាត ដោយកាយមាន ៣ ប្រការ តើដូចម្តេច ? ម្នាលចុន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាអ្នកមានចិត្តអាក្រក់ មានដៃប្រឡាក់ឈាម មានចិត្តជោះជាប់ក្នុងការ

សម្លាប់សត្វ មានចិត្តមិនអាសូរចំពោះពួកសត្វ ១ ជាអ្នកលួចទ្រព្យគេ ១ គឺជាអ្នកកាន់យកនូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ គេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ដែលគេមិនបានឲ្យដែលហៅថា លួច ១ ជាអ្នកប្រព្រឹត្តខុសក្នុងកាម គឺជាអ្នកដល់នូវការប្រព្រឹត្តកន្ទួងក្នុងស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា (កំណត់ទុក) ដោយហោចទៅ សូម្បីតែស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ ១ ។ ម្នាលចុន្ទ ការមិនស្អាត ដោយកាយមាន ៣ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ការមិនស្អាតដោយវាចាមាន ៤ ប្រការតើដូចម្តេច ? ម្នាលចុន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកពោលពាក្យកុហក ទោះបីស្ថិតនៅក្នុងរោងក្តី ស្ថិតនៅក្នុងបរិស័ទក្តី ស្ថិតនៅក្នុងកណ្តាលញាតិក្តី ស្ថិតនៅក្នុងកណ្តាលសេនីក្តី ស្ថិតនៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅធ្វើជាសាក្សី ហើយសួរថា នែ៎ បុរសអើយ ចូរអ្នកមកអាយ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុគ្គលនោះ កាលមិនដឹង ក៏និយាយថា

ខ្ញុំដឹងក៏មាន កាលដឹងនិយាយថា ខ្ញុំមិនដឹងក៏មាន កាលមិនឃើញ
និយាយថា ខ្ញុំឃើញក៏មាន កាលឃើញនិយាយថា ខ្ញុំមិនឃើញក៏មាន
ជាអ្នកពោលពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុតែខ្លួនក្តី ព្រោះ
ហេតុអ្នកដទៃក្តី ព្រោះហេតុសំណូក គឺអាមិសបន្តិចបន្តួចក្តី ១ ជាអ្នក
ពោលពាក្យញុះញង់ គឺឮពាក្យអំពីសម្នាក់ជននេះ ហើយនាំទៅប្រាប់
ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនោះ ឬឮពាក្យអំពីសម្នាក់ជនឯណោះ
នាំមកប្រាប់ជននេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកបំបែកពួកជន
ដែលព្រមព្រៀងគ្នាផង ជាអ្នកជំរុលពួកជន ដែលបែកគ្នាហើយផង
ជាអ្នកត្រេកអរតែក្នុងពួក មានតម្រេកក្នុងពួក ជាអ្នកវីកវាយតែក្នុងពួក
ជាអ្នកពោលវាចាធ្វើឲ្យប្រកាន់ពួក ដោយប្រការដូច្នេះ ១ ជាអ្នកពោល
ពាក្យអាក្រក់ គឺជាអ្នកពោលវាចាទ្រគោះបោះបោក ខ្ទោះខ្ទរពេលវាល
ស្អាក់ដំណើរជនដទៃ ជាវាចាជិតនឹងសេចក្តីក្រោធ មិនប្រព្រឹត្តទៅដើម្បី
សមាធិ ១ ជាអ្នកពោលពាក្យឥតប្រយោជន៍ គឺពោលពាក្យខុសកាល
ពោលពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែន

ជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពោលពាក្យដែលមិនគួរឲ្យតាំងទុក
ក្នុងហឫទ័យបាន ជាពាក្យពោលខុសកាល ប្រាសចាកគ្រឿងអាង
ជាពាក្យមិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ១ ។ ម្នាលចុន្ទ
ការមិនស្អាតដោយវាចាមាន ៤ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ចុះការ
មិនស្អាតដោយចិត្តមាន ៣ ប្រការតើដូចម្តេច ? ម្នាលចុន្ទ បុគ្គលខ្វះ
ក្នុងលោកនេះ ច្រើនដោយអភិជ្ឈា គឺជាអ្នកគយគន់នូវគ្រឿងឧបករណ៍
ដែលជាសម្បត្តិនៃបុគ្គលដទៃ ដោយគិតថា ឱហ្ន៎ ! គ្រឿងឧបករណ៍
ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមក
អញ ១ ជាអ្នកមានចិត្តព្យាបាទ គឺជាមនុស្សមានតម្រិះក្នុងចិត្ត ដែល
ទោសប្រទូស្តហើយថា សត្វទាំងឡាយនេះ ចូរលំបាកខ្លះ ចូរបែកគ្នាខ្លះ
ចូរសាបសូន្យទៅខ្លះ ចូរវិនាសទៅខ្លះ កុំបីមានបាន (អ្វីបន្តិចបន្តួច)
ឡើយ ១ ជាអ្នកមានគំនិតយល់ខុស គឺជាមនុស្សយល់ឃើញនូវសេចក្តី
វិបរិតថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល
ការបូជាតូចមិនមាន ផលវិបាកវបស់កុសលាកុសលកម្មដែលសត្វធ្វើល្អ

ធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតា
មិនមាន បិតាមិនមាន សត្វទាំងឡាយជាឧបបាតិកកំណើតមិនមាន ពួក
សមណព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អបដិបត្តិដោយត្រឹមត្រូវ
ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម
របស់ខ្លួនហើយ សម្តែងប្រាប់មិនមាន ១ ។ ម្នាលចុន្ទ ការមិនស្អាត
ដោយចិត្តមាន ៣ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ការមិនស្អាតទាំង
១០ នេះឯងហៅថា អកុសលកម្មបថ ។ ម្នាលចុន្ទ បុគ្គលដែលប្រកប
ដោយអកុសលកម្មបថទាំង ១០ នេះហើយ បើទុកជាក្រោកឡើងអំពី
ជំណេក ក្នុងវេលាព្រឹកព្រហាម ហើយស្ទាបផែនដីក្តី ក៏នៅតែជាមនុស្ស
មិនស្អាតដដែល បើទុកជាមិនស្ទាបផែនដីក្តី ក៏នៅតែមិនស្អាតដដែល
បើទុកជាស្ទាបអាចម៍គោស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជា
មិនស្ទាបអាចម៍គោស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាស្ទាប
ស្មៅស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិនស្ទាបស្មៅស្រស់ក្តី
ក៏នៅតែមិនស្អាតដដែល បើទុកជាបម្រើភ្លើងក្តី ក៏នៅតែមិនស្អាតដដែល

បើទុកជាមិនបម្រើភ្លើង ក៏នៅតែមិនស្អាតដដែល បើទុកជាប្រណម្យ
អញ្ជលីនមស្ការព្រះអាទិត្យក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិន
ប្រណម្យអញ្ជលីនមស្ការព្រះអាទិត្យក្តី ក៏នៅតែមិនស្អាតដដែល បើទុក
ជាចុះត្រាំទឹកជាគម្រប់ ៣ ដងទីឆ្ងាយពេលល្ងាចក្តី ក៏នៅតែមិនស្អាតដដែល
បើទុកជាមិនចុះត្រាំទឹក ជាគម្រប់ ៣ ដងទីឆ្ងាយពេលល្ងាចក្តី ក៏នៅតែ
មិនស្អាតដដែល ។ ជំណើរនោះ ព្រោះហេតុអ្វី ? ម្នាលចុន្ទ ព្រោះ
អកុសលកម្មបថទាំង ១០ នេះឯង ជាគន្ធធំមិនស្អាតផង ជាផ្លូវកឲ្យកើត
របស់មិនស្អាតផង ។ ម្នាលចុន្ទ មួយទៀត ព្រោះហេតុនៃការប្រកប
ព្រមដោយអកុសលកម្មបថទាំង ១០ ប្រការនេះ នរកក៏ជ្រោកជ តិរច្ឆាន
ក៏ជ្រោកជ បេតវិស័យក៏ជ្រោកជឡើង ឬក៏មានទុគ្គតិ (ជំណើរអាក្រក់)
ក្រៅអំពីនេះណាមួយ (មានទៀតមិនខាន) ។ ម្នាលចុន្ទ ការស្អាត
ដោយកាយមាន ៣ ប្រការ ការស្អាតដោយវាចា មាន ៤ ប្រការ
ការស្អាតដោយចិត្តមាន ៣ ប្រការ ។ ម្នាលចុន្ទ ចុះការស្អាត ដោយ
កាយមាន ៣ ប្រការតើដូចម្តេច ? ម្នាលចុន្ទ បុគ្គលខ្លះក្នុងលោកនេះ

លះបង់នូវបាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា ដាក់ចុះនូវគ្រឿងសស្ត្រាវុធ ប្រកបដោយសេចក្តីខ្មាស ដល់នូវមេត្តាចិត្ត ជាអ្នកអនុគ្រោះដោយប្រយោជន៍ចំពោះពួកសត្វទាំងអស់ ១ ជាអ្នកលះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ជាអ្នកមិនកាន់យកនូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ គេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ដែលគេមិនបានឲ្យដោយចិត្តលួចឡើយ ១ ជាអ្នកលះបង់នូវកាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆាចារ ជាអ្នកមិនដល់នូវការប្រព្រឹត្តកន្ទង់ក្នុងស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ត្រកូលប្រកបដោយធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា (កំណត់ទុក) ដោយហោចទៅ សូម្បីតែស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ ១ ម្នាលចុន្ទ ការស្នាត ដោយកាយមាន ៣ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ចុះការស្នាត ដោយវាចាមាន ៤ ប្រការតើដូចម្តេច ? ម្នាលចុន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកលះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ទោះបីស្ថិតនៅក្នុង

ភេង៉ក្តី ស្ថិតនៅក្នុងបរិស័ទក្តី ស្ថិតនៅក្នុងកណ្តាលញាតិក្តី ស្ថិតនៅក្នុងកណ្តាលសេនីក្តី ស្ថិតនៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅធ្វើជាសាក្សីហើយ សួរថា នែ៎ បុរសអើយ ចូរអ្នកមកអាយ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុគ្គលនោះ កាលមិនដឹងក៏និយាយថា ខ្ញុំមិនដឹង កាលដឹងនិយាយថា ខ្ញុំដឹង កាលមិនឃើញនិយាយថា ខ្ញុំមិនឃើញ កាលឃើញនិយាយថា ខ្ញុំឃើញ ជាអ្នកមិនពោលពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុតែខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុសំណូក គឺអាមិសបន្តិចបន្តួចក្តី ១ ជាអ្នកលះបង់បិសុណាវាចា វៀរស្រឡះចាកបិសុណាវាចា ឬពាក្យអំពីសម្នាក់ជននេះហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនោះ ឬឮពាក្យអំពីសម្នាក់ជនឯណោះហើយ មិននាំមកប្រាប់ជនទាំងនេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកផ្សះផ្សាជនពួកជន ដែលបែកគ្នាផង ជាអ្នកទំនុកបម្រុងពួកជន ដែលរួបរួមគ្នាផង ជាអ្នកត្រេកអរតែក្នុងសេចក្តីព្រមព្រៀងគ្នាផង ជាអ្នកមានតម្រេកក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នក

រីករាយតែក្នុងសេចក្តីព្រមព្រៀងគ្នា ពោលនូវវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀងគ្នា ដោយប្រការដូច្នេះ ១ ជាអ្នកលះបង់ផរុសវាចា វៀរស្រឡះចាកផរុសវាចា ជាអ្នកពោលតែវាចាមិនមានទោស ជាសុខដល់ត្រចៀក គួរឲ្យកើតសេចក្តីស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជាវាចាអ្នកបុរី ជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន ១ ជាអ្នកលះបង់សម្ផប្បលាប វៀរស្រឡះចាកសម្ផប្បលាប ពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យដែលជាវិន័យ ពោលពាក្យដែលគួរតាំងទុកក្នុងហឫទ័យ ជាពាក្យពោលត្រូវតាមកាលវេលា ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបដោយប្រយោជន៍ ១ ។ ម្នាលចុន្ទ ការស្អាតដោយវាចាមាន ៤ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ចុះការស្អាត ដោយចិត្តមាន ៣ ប្រការតើដូចម្តេច ? ម្នាលចុន្ទ បុគ្គលខ្វះក្នុងលោកនេះមិនមានអភិជ្ឈា ជាអ្នកមិនគយគន់នូវគ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃ ដោយគិតថា ឱហ្ន៎ ! គ្រឿងឧបករណ៍ដែលជាសម្បត្តិ

នៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអញ្ជួរច្នេះឡើយ ១ ជាអ្នកមានចិត្តមិនព្យាបាទ គឺជាមនុស្សមានតម្រិះក្នុងចិត្ត ដែលទោសមិនប្រទូស្តហើយថា សត្វទាំងឡាយនេះ កុំមានពៀរនឹងគ្នា កុំព្យាបាទគ្នា កុំមានទុក្ខ ចូរកក្សាខ្លួន ឲ្យបានសេចក្តីសុខចុះ ១ ជាអ្នកមានសេចក្តីយល់ត្រូវ គឺជាមនុស្សយល់ឃើញនូវសេចក្តីមិនវិបរិតថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាកនៃកុសលាកុសលកម្ម ដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមាន បិតាមាន សត្វទាំងឡាយជាឱបបាតិកកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលជាអ្នកប្រព្រឹត្តល្អ បដិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ហើយសម្តែងប្រាប់មាន ១ ។ ម្នាលចុន្ទ ការស្អាតដោយចិត្តមាន ៣ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ការស្អាតទាំង ១០ នេះឯង ហៅថា កុសលកម្មបថ ១០ ។ ម្នាលចុន្ទ បុគ្គលដែលប្រកបដោយកុសលកម្មបថទាំង ១០ នេះហើយ

បើទុកជាក្រោកឡើងអំពីដំណេក ក្នុងវេលាព្រឹកព្រហាម ហើយស្ទុះផែនដីក្តី ក៏នៅជាមនុស្សស្អាតដដែល បើទុកជាមិនស្ទុះផែនដីក្តី ក៏នៅស្អាតដដែល បើទុកជាស្ទុះអាចម៍គោស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាមិនស្ទុះអាចម៍គោស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាស្ទុះស្មៅស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាមិនស្ទុះស្មៅស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាបម្រើភ្លើងក្តី ក៏នៅស្អាតដដែល បើទុកជាមិនបម្រើភ្លើងក្តី ក៏នៅស្អាតដដែល បើទុកជាប្រណម្យអញ្ជលីនមស្ការព្រះអាទិត្យក្តី ក៏នៅស្អាតដដែល បើទុកជាមិនប្រណម្យអញ្ជលីនមស្ការព្រះអាទិត្យក្តី ក៏នៅស្អាតដដែល បើទុកជាចុះត្រាំទឹកជាគម្រប់ ៣ ដង នឹងពេលល្ងាចក្តី ក៏នៅស្អាតដដែល បើទុកជាមិនចុះត្រាំទឹកជាគម្រប់ ៣ ដងនឹងពេលល្ងាចក្តី ក៏នៅស្អាតដដែល ដំណើរនោះតើព្រោះហេតុអ្វី? ម្នាលចុន្ទ ព្រោះកុសលកម្មបថទាំង ១០ ប្រការនេះឯង ជាគន្ធងស្អាតផង ជាផ្លូវ.កឲ្យកើតរបស់ស្អាតផង ។ ម្នាលចុន្ទ មួយទៀត ព្រោះហេតុនៃការប្រកបព្រមដោយកុសលកម្មបថទាំង ១០ ប្រការនេះ ទេវតា

ក៏ប្រាកដ មនុស្សក៏ប្រាកដ ឬក៏មានសុគតិ (ដំណើរល្អ) ក្រៅពីនេះណាមួយ (មានទៀតមិនខាន) ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ចុន្ទកម្មារបុត្រក៏ក្រាបថ្វាយបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ ។ល។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានជោគ ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

នៅមានរឿងពោលដែលទាក់ទងដល់នាយចុន្ទកម្មារបុត្រ ដែលបានមានឱកាសចូលគាល់ព្រះលោកនាយក ដើម្បីក្រាបទូលសួរបញ្ហាតាមដែលមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីពិលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមហាវីរៈ ព្រមដោយភិក្ខុជាច្រើន បានយាងចារិកទៅត្រង់ដែនមល្លៈ ហើយបានយាងគេចចូលទៅប្រថាប់នៅត្រង់ចម្ការស្វាយរបស់នាយចុន្ទកម្មារបុត្រ ដែលនៅជិតក្រុងបាវា ។ លុះដល់

ថ្ងៃស្អែកឡើង ព្រះមានព្រះភាគ ព្រមដោយភិក្ខុសង្ឃ បានយាងទៅទទួលភត្តាហារនៅឯនិវេសន៍របស់នាយចុន្ទកម្មារបុត្រ ។ ចំណែកនាយចុន្ទកម្មារបុត្រ បាននាំភាជន:មាស បង្អោនចូលទៅប្រគេនភិក្ខុសង្ឃទាំងឡាយ ដើម្បីឲ្យលោកប្រើសម្រាប់ទទួលសម្ល និងបាយជាដើមទាំងនេះក្នុងវេលានោះ នៅមិនទាន់មានពុទ្ធប្បញ្ញត្តិសិក្ខាបទហាមមិនឲ្យភិក្ខុចាប់ប៉ះពាល់មាស និងប្រាក់ ។ ភិក្ខុពួកខ្លះ ក៏ទទួលភាជន៍មាស តែភិក្ខុពួកខ្លះ ក៏មិនព្រមទទួល ។ ចំណែកព្រះមហាវីរបុរស ទ្រង់មានបាត្រសិលា ជាភាជន៍សម្រាប់ជាក់ចង្ហាន់ ដែលជាភាជន៍ប្រចាំព្រះអង្គ ។ ការពិត ព្រះពុទ្ធទាំងឡាយ រមែងទ្រង់មិនទទួលប្រគេនភាជន៍ទី ២ ព្រោះព្រះអង្គមានបាត្រសិលាហើយ ទើបទ្រង់មិនទទួលភាជន៍មាស ។ ក្នុងពពួកភិក្ខុសង្ឃដែលតាមព្រះកគវាទៅនោះ មានភិក្ខុលាមកមួយរូប កាលបានទទួលភាជន៍មាស ដែលនាយចុន្ទកម្មារបុត្រប្រគេន ដើម្បីឲ្យប្រើប្រាស់ទទួលចង្ហាន់នោះ លោកក៏បានយកភាជន៍មាសនោះ ជាក់ចុះទៅក្នុងស្លាកបាត្រដោយថេយ្យចិត្ត គឺចិត្តគិតនឹងលួច ។ នាយចុន្ទកម្មារបុត្រ

បានប្រគេនចង្ហាន់បិណ្ឌបាត រហូតដល់ភិក្ខុសង្ឃឆាន់ស្រេចបាច់ហើយ ទើបលាងដៃ លាងជើងហើយ ចូលមកថ្វាយបង្គំព្រះមានជោគ ថែមទាំងបានក្រឡេកមើលភិក្ខុសង្ឃ ក៏បានឃើញភិក្ខុអាក្រក់រូបនោះ លួចភាជន៍មាស ដាក់ចូលទៅក្នុងស្មោកបាត្រ តែគេបែរធ្វើដូចជាមិនឃើញ ហើយមិនពោលថាអ្វីឡើយ ព្រោះតែការគោរពចំពោះព្រះភគវា និងការគោរពព្រះថេរៈទាំងឡាយ ទាំងនេះដោយគេគិតឃើញថា កុំឲ្យពពួកមិច្ឆាទិដ្ឋិតិះដៀលបានឡើយ ។ តែនាយចុន្ទកម្មារបុត្រ គេបានគិតពិចារណាថា អ្នកសង្រួមបែបណា ទើបហៅថាជាសមណៈអ្នកស្ងប់ ឬអ្នកមិនសង្រួមក៏ហៅថាជាសមណៈបានដែរ ។ លុះដល់វេលាល្ងាច ទើបគេចេញទៅគាល់ព្រះវិជិតមារ ដើម្បីក្រាបទូលសួរបញ្ហា ។

ការក្រាបទូលសួរបញ្ហា ដែលនាយចុន្ទកម្មារបុត្រ បានចូលទៅគាល់ក្រាបទូលសួរចំពោះព្រះសម្ពុទ្ធនោះ មានសម្តែងនៅក្នុងព្រះបាលី **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **ឧរគវគ្គ** ក្នុង **ចុន្ទសូត្រ** ដែលពោលអំពីសមណៈមាន ៤ ជំពូក ដូចមានសេចក្តីថា ៖

ចុន្ទកម្មារបុត្រ ក្រាបទូលសួរព្រះមានព្រះភាគថា ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ ជាអ្នកជ្រាជ្រ មានបញ្ញាច្រើន ជាព្រះពុទ្ធជាម្ចាស់នៃធម៌ ជ្រាសចាកតណ្ហា ដ៏ឧត្តមជាងសត្វជើងពីរ ប្រសើរជាងសារបីទាំងឡាយ តើពួកសមណៈក្នុងលោកនេះ **មានប៉ុន្មាន ? សូមព្រះអង្គសម្តែងជ្រាប់នូវពួកសមណៈនោះឲ្យាន !**

ព្រះសាស្តាត្រាស់ថា ម្នាលចុន្ទ សមណៈមានត្រឹមតែ ៤ ពួក មិនមានដល់គម្រប់ ៥ ទេ កាលបើអ្នកសួរបញ្ជាក់ហើយ តថាគតនឹងជ្រាប់នូវសមណៈទាំងនោះដល់អ្នក **គឺសមណៈឈ្នះកិលេសដោយមគ្គ ១ សមណៈសម្តែងជ្រាប់នូវមគ្គ ១ សមណៈរស់នៅក្នុងមគ្គ ១ សមណៈប្រទូស្តនូវមគ្គ ១** ។

ចុន្ទកម្មារបុត្រទូលសួរថា ព្រះពុទ្ធទាំងឡាយតែងសម្តែងនូវសមណៈណា ថាជាសមណៈឈ្នះកិលេសដោយមគ្គ សមណៈជុតបំផ្លាញនូវកិលេសដោយមគ្គ ជាបុគ្គលថ្លឹងមិនបាន រស់នៅក្នុងមគ្គ ? ខ្ញុំសួរហើយ សូមព្រះអង្គសម្តែងជ្រាប់ឲ្យាន មួយទៀត សូមព្រះអង្គ

ប្រាប់នូវសមណៈអ្នកប្រទូស្តនូវមគ្គដល់ខ្ញុំព្រះអង្គ ?

ព្រះសាស្តាត្រាស់ថា សមណៈណាកន្ធង់ផុតនូវសេចក្តីសង្ស័យ ប្រាសចាកសរ គឺកិលេស ត្រេកអរក្នុងព្រះនិព្វាន មិនជាប់ជំពាក់ដោយតណ្ហា ជាអ្នកណែនាំសត្វលោក ព្រមទាំងទេវលោក ព្រះពុទ្ធទាំងឡាយ សម្តែងនូវសមណៈបែបនោះ ថាជាអ្នកឈ្នះកិលេសដោយមគ្គ ។ សមណៈណាក្នុងសាសនានេះ ដឹងនូវព្រះនិព្វាន ថាជាគុណជាតឧត្តមក្រៃលែង ហើយសម្តែងចែកនូវនិព្វានធម៌ក្នុងលោកនេះ អ្នកប្រាជ្ញទាំងឡាយហៅសមណៈដែលជាអ្នកកាត់បង់នូវសេចក្តីសង្ស័យ ជាអ្នកប្រាជ្ញ មិនមានសេចក្តីញាប់ញ័រនោះ ថាជាអ្នកសម្តែងប្រាប់មគ្គ ជាសមណៈទី ២ នៃភិក្ខុទាំងឡាយ ។ សមណៈណា មានស្មារតីសង្រួមហើយ សេពនូវគន្ធង់ មិនមានទោស រស់នៅក្នុងមគ្គ ជាផ្លូវនៃធម៌ គឺព្រះនិព្វាន ដែលព្រះពុទ្ធសម្តែងប្រពៃហើយ អ្នកប្រាជ្ញទាំងឡាយ ហៅសមណៈនោះថាជាអ្នករស់នៅក្នុងមគ្គ ជាសមណៈទី ៣ នៃភិក្ខុទាំងឡាយ ។ សមណៈណា ធ្វើនូវភេទរបស់ពួកអ្នកមានវត្តល្អ ឲ្យជាគ្រឿងបិទបាំង

ជាអ្នកសុះសូ អ្នកទ្រូស្តត្រកូល មានឫក្សពោយ្ហើសឃ្នង មានកលមាយាមិនសង្រ្កែម ពោលពាក្យឡេះឡោះ ប្រព្រឹត្តបន្ទំ សមណៈនោះ ឈ្មោះថាជាអ្នកទ្រូស្តនូវមគ្គ ។ គ្រហស្តណាជ្នាអកចេះដឹង ជាអរិយសាវ័កប្រកបដោយប្រាជ្ញា ស្គាល់ច្បាស់នូវសមណៈទាំងនោះ សទ្ធារបស់គ្រហស្តនោះរមែងមិនសាបសូន្យទេ ព្រោះដឹងថា ពួកសមណៈទាំងអស់មិនដូច្នោះទេ ព្រោះឃើញដូច្នេះ គប្បីប្រៀបនូវសមណៈមិនអាក្រក់ ឲ្យស្មើដោយសមណៈអាក្រក់ ឬគប្បីប្រៀបនូវសមណៈបរិសុទ្ធ ឲ្យស្មើដោយសមណៈមិនបរិសុទ្ធ ដូចម្តេចកើត ។

សេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា របស់នាយចុន្ទកម្មារបុត្រ ចាត់ជាកំពូលមួយពិសេសជាងអ្នកដទៃៗ តាមដែលមានសម្តែងច្រកដនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលបានពោលតអំពីវគ្គមុនថា ៖

នាយចុន្ទកម្មារបុត្រ បានជាព្រះសោតាបន្ន ផ្តើមតាំងអំពីបានឃើញព្រះសាស្តាជាលើកដំបូង ។ កាលតមក នាយចុន្ទកម្មារបុត្រ ទើបបានកសាងព្រះគន្ធកុដិថ្វាយដល់ព្រះសាស្តា នៅក្នុងចម្ការស្វាយរបស់ខ្លួន

ហើយបានកសាងទីស្នាក់ពេលយប់ និងទីសម្រាកពេលថ្ងៃ បានកសាងសាលាសម្រាប់ឆាន់ កុដិ មណ្ឌប និងទីចង្រ្កមសម្រាប់ព្រះភិក្ខុសង្ឃ បានសាងវិហារឡើងក្នុងចម្ការស្វាយរបស់ខ្លួន ថែមទាំងបានធ្វើរបងពន្ធយ៉ាងមាំទាំ និងបានកសាងខ្ទោងទ្វារយ៉ាងល្អទៀតផង ហើយថ្វាយដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ។

ក្នុងវេលាដែលជាបច្ចិមាយុកាលរបស់ព្រះមុនី ព្រះអង្គបានយាងមកប្រថាប់ ស្នាក់ត្រង់ចម្ការស្វាយរបស់នាយចុន្ទកម្មារបុត្រ ព្រមដោយភិក្ខុសង្ឃជាច្រើន តាមដែលមានរឿងសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរខុទ្ទកនិកាយ ឧទាន** នៃ **ចាជលិគាមិយវគ្គ** ក្នុង **ចុន្ទសូត្រ** ថា ៖

ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គ្រាច់ទៅកាន់ចារិក ក្នុងជនបទឈ្មោះមល្ល: ជាមួយភិក្ខុសង្ឃច្រើនរូប បានដល់ក្រុងបាវា ។ បានឮថា ក្នុងទីនោះឯង ព្រះលោកនាថ ទ្រង់គង់ក្នុងសួនអម្ពវនៃរបស់ចុន្ទកម្មារបុត្រ (កូនជាងមាស) ទៀបក្រុងបាវា ។ ចុន្ទកម្មារបុត្របានឮដំណឹងថា ព្រះមានព្រះភាគទ្រង់គ្រាច់មកកាន់ចារិក

ក្នុងមល្លជនបទជាមួយភិក្ខុសង្ឃច្រើនរូប បានដល់ក្រុងបាវា ឥឡូវនេះ
ទ្រង់គង់នៅក្នុងអម្ពវនរបស់អញ ទៀបក្រុងបាវា ។ គ្រានោះឯង ចុន្ទ-
កម្មារបុត្រចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំ
ព្រះលោកនាថ ហើយអង្គុយក្នុងទីសមគួរ ។ លុះចុន្ទកម្មារបុត្រអង្គុយ
ក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ពន្យល់ ឲ្យឃល់ច្បាស់
ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ
ចុន្ទកម្មារបុត្រ ដែលព្រះមានព្រះភាគ ឲ្យឃល់ច្បាស់ ឲ្យកាន់យក
ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បានក្រាបបង្គំទូល
ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះលោកនាថ ព្រមទាំង
ភិក្ខុសង្ឃទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះភគវា
ទ្រង់ទទួលនិមន្ត ដោយតុណ្ហីភាព ។ គ្រានោះ នាយចុន្ទកម្មារបុត្រ
ជ័ងច្បាស់ថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាក
អាសនៈ ក្រាបបង្គំលាព្រះមានព្រះភាគធ្វើប្រទក្សិណចៀសចេញទៅ ។
គ្រានោះ រាត្រីកាលនោះកន្លងហើយ ទើបចុន្ទកម្មារបុត្រឲ្យគេចាត់ចែង

ខាទនីយភោជនីយាហារ មានរសដ៏ឆ្ងាញ់ពិសេស ព្រមទាំងសូករមទូវៈដ៏ប្រសើរ (ពាក្យថា សូករមទូវៈនេះ លោកពោលទុកក្នុងមហាអដ្ឋកថាថា ឈ្មោះសាច់ជ្រូកដែលស្ងាប់ស្រាប់ ដែលជាសាច់ជ្រូកទន់ស្និទ្ធ ។ អាចារ្យមួយពួកពោលថា ពាក្យថា សូករមទូវៈនេះ មិនមែនសាច់ជ្រូកទេ គឺថាទំពាំងឫស្សី ដែលជ្រូកឈ្នូស ។ អាចារ្យដោយច្រើនទៀតពោលថា ផ្សិតដែលដុះត្រង់ប្រទេស ដែលជ្រូកឈ្នូស ។ មួយទៀត អាចារ្យជនៃបានពោលថា ម្ហូបនេះ ជាភោជនមានរសមួយបែប មានឈ្មោះថា សូករមទូវៈ ព្រោះថា នាយចុន្ទកម្មារបុត្របានប្រគេនសូករមទ្ទវៈនោះ ដើម្បីឲ្យព្រះសាស្តាគង់ព្រះជន្មនៅបានយូរ ព្រោះឮថា ព្រះមានព្រះភាគនឹងបរិនិព្វានក្នុងថ្ងៃនេះ ហើយគិតថា ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគសោយសូករមទ្ទវៈនោះហើយ គប្បីគង់ព្រះជន្មនៅបានយូរហ្ន៎) ក្នុងផ្ទះរបស់ខ្លួន ហើយឲ្យគេទៅក្រាបបង្គំទូលភត្តកាលដល់ព្រះមានព្រះភាគបពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះកគវាទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយ

ស្តេចចូលទៅកាន់លំនៅនៃចុន្ទកម្មាបុត្រ ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះភគវាទ្រង់គង់ស៊ប់ហើយ ក៏ត្រាស់ទឹងចុន្ទកម្មាបុត្រថា ម្នាលចុន្ទ សូករមទ្វៈណាដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសតថាគត ដោយសូករមទ្វៈនោះចុះ ឯខាទនីយភោជនីយាហារណាក្រៅពីនេះ ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសចំពោះភិក្ខុសង្ឃ ដោយខាទនីយភោជនីយាហារនោះចុះ ។ ចុន្ទកម្មាបុត្រទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយអង្គាសព្រះភគវា ដោយសូករមទ្វៈ ដែលខ្ជនតាក់តែងហើយ អង្គាសភិក្ខុសង្ឃដោយខាទនីយភោជនីយាហារដទៃ ដែលខ្ជនតាក់តែងហើយ ។ លំដាប់នោះ ព្រះលោកនាថ ទ្រង់ត្រាស់ទឹងចុន្ទកម្មាបុត្រថា ម្នាលចុន្ទ សូករមទ្វៈណារបស់អ្នកដែលនៅសល់ អ្នកចូរកប់សូករមទ្វៈនោះ ក្នុងរណ្តៅចុះ ម្នាលចុន្ទ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញបុគ្គលណាមួយ

ដែលបរិភោគនូវសូករមទូវៈនោះ ហើយសូករមទូវៈនោះ ជល់នូវការ
រលួយទៅល្អឡើយ រៀរលែងតែព្រះតថាគតចេញ ។ ចុន្ទកម្មារបុត្រ
ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគ ព្រះករុណាព្រះអង្គស្រេចហើយ
ក៏បានកប់សូករមទូវៈ ដែលសល់ទៅក្នុងរណ្តៅ ហើយចូលទៅគាល់
ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ
អង្គុយនៅក្នុងទីសមគួរ ។លុះចុន្ទកម្មារបុត្រអង្គុយនៅក្នុងទីសមគួរហើយ
ព្រះមានព្រះភាគក៏ទ្រង់ពន្យល់ឲ្យឃល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន
ឲ្យរីករាយដោយធម្មីកថាហើយ ក្រោកចាកអាសនៈស្តេចចៀសចេញទៅ ។

គ្រានោះ កាលព្រះភគវា ឆាន់កត្តរបស់ចុន្ទកម្មារបុត្ររួចហើយ
ព្រះអាពាធដ៏ខ្លាំងក៏កើតឡើង វេទនាដ៏ក្លៀវក្លា កើតអំពីលោហិតបក្ខន្ទិ-
កាពាធ (អាពាធចុះព្រះលោហិត) ជិតដល់មរណៈ ក៏ប្រព្រឹត្តទៅ ។
បានឮថា ក្នុងទីនោះ ព្រះសាស្តាមានព្រះសតិ និងសម្បជញ្ញៈមិនបាន
លំបាក ដោយទ្រង់អត់សង្កត់វេទនាបាន ។ វេលានោះឯង ព្រះសាស្តា
ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ មកយើងនឹងទៅឯក្រុង

កុសិនារ ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគ ព្រះកុរុណាព្រះអង្គ ។

ខ្ញុំបានឮថា ព្រះសាស្តាជាអ្នកជ្រាជ្រ ទ្រង់សោយកត្តរបស់នាយចុន្ទកម្មារបុត្រហើយ ទ្រង់មានព្រះអាពាធជាទម្ងន់ ជិតនឹងមរណៈ ។ អាពាធដ៏ខ្លាំងក្លាកើតដល់ព្រះកគវា ដែលសោយសូករមទ្ទវៈ ព្រះកគវាទ្រង់ព្រះអាពាធចុះព្រះលោហិតរឿយៗ ទើបមានព្រះពុទ្ធតម្រាស់ថា តថាគតនឹងទៅកាន់ក្រុងកុសិនារ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចៀសចេញអំពីផ្លូវ ទ្រង់ចូលទៅកាន់ម្លប់ឈើមួយដើម លុះចូលទៅដល់ហើយ ទ្រង់ប្រើព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ចូរអ្នកក្រាលសង្ឃាដិមានជាន់ ៤ ឲ្យតថាគតដោយឆាប់ តថាគតល្វើតល្វែណាស់ តថាគតនឹងគង់សិន ។ ព្រះអានន្ទដ៏មានអាយុទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមុនីថា ព្រះកុរុណាព្រះអង្គ ហើយក្រាលសង្ឃាដិ មានជាន់ ៤ ថ្វាយ ។ ព្រះមានព្រះភាគក៏គង់លើអាសនៈដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះទសពលគង់សិប់ហើយ

ទ្រង់ប្រើព្រះអានន្ទថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគត ដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹក បន្តិច ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទ ដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រ ព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ រទេះចំនួន ៥០០ បរឆ្លងទៅហើយ ទឹកនោះតិច កង់រទេះក៏កិនល្អក់រឹតវារហូរមក បពិត្រព្រះអង្គដ៏ចម្រើន កកុធនទីនៅជិតនេះ មានទឹកថ្លា មានរសជាតិស្រួល មានទឹកត្រជាក់ មានទឹករងថ្លា មានកំពង់រាប គួរជាទីរីករាយ ក្នុងសូងនោះ ព្រះកគវា នឹងសោយទឹកក៏បាន នឹងស្រង់ព្រះកាយ ឲ្យត្រជាក់ស្រួលក៏បាន ។ ព្រះសាស្តាត្រាស់ប្រើព្រះអានន្ទដ៏មានអាយុ ជាគម្រប់ពីរដងទៀតថា ម្នាលអានន្ទ ចូរអ្នកដងទឹកឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគត ស្រេកទឹកណាស់ តថាគតនឹងឆាន់ ។ ព្រះអានន្ទដ៏មានអាយុ ក៏ក្រាបបង្គំ ទូលព្រះមានព្រះភាគ ជាគម្រប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ រទេះចំនួន ៥០០ បរឆ្លងទៅហើយ ទឹកនោះតិច កង់

រនេះកិន ល្អក់រឹតរវហូរមក បពិត្រព្រះអង្គដ៏ចម្រើន កកុធនទីនៅជិតនេះ មានទឹកថ្លា មានរសជាតិស្រួល មានទឹកត្រជាក់ មានទឹករងថ្លា មានកំពង់រាប គួរជាទីរីករាយ ក្នុងស្ទឹងនោះ ព្រះមានព្រះភាគ នឹងសោយក៏បាន នឹងស្រង់ព្រះកាយឲ្យត្រជាក់ក៏បាន ។ ព្រះមានព្រះភាគត្រាស់ប្រើព្រះអានន្ទដ៏មានអាយុ ជាគម្រប់បីដងទៀតថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតស្រេក តថាគតនឹងឆាន់ ។ ព្រះអានន្ទដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏បានកាន់យកបាត្រ ដើរឆ្ពោះទៅឯស្ទឹងនោះ ។

គ្រានោះ ស្ទឹងដែលកងរនេះបរឆ្ងែកាត់ មានទឹកតិច ល្អក់រឹតរវហូរមកនោះ កាលដែលព្រះអានន្ទដ៏មានអាយុចូលទៅដល់ ទឹកស្ទឹងក៏ប្រែត្រឡប់ជាថ្លាស្អាត មិនល្អក់រឹតរវហូរមក ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះថា យ៉ីអើ ! អស្ចារ្យណាស់ យ៉ីអើ ! ចម្លែកណាស់ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន ។

អម្បាញ់មិញ ស្ទឹងដែលកង់រនេះបរឆ្លងកាត់ មានទឹកតិច ល្អក់រឹតវេហូរមកនេះ លុះដល់អាត្មាអញចូលមកដល់ ទឹកស្ទឹងក៏ប្រែត្រឡប់ជាថ្លាស្អាត មិនល្អក់រឹតវេហូរមកវិញ ។ ព្រះអានន្ទយកបាត្រទៅដងទឹក ហើយចូលទៅគាល់ព្រះភគវា លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន ។ បពិត្រព្រះអង្គដ៏ចម្រើន ស្ទឹងនោះ កង់រនេះបរឆ្លងកាត់ មានទឹកតិច ល្អក់រឹតវេហូរមក កាលបើខ្ញុំព្រះអង្គចូលទៅដល់ ស្ទឹងក៏ប្រែត្រឡប់ជាថ្លាស្អាត មិនល្អក់រឹតវេទៅវិញ ។ សូមព្រះមានព្រះភាគសោយទឹក សូមព្រះសុគតសោយទឹកចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សោយទឹកនោះឯង ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងសំដៅទៅឯកកុដនទីជាមួយនឹងភិក្ខុសង្ឃច្រើនរូប លុះចូលទៅដល់ហើយ ក៏យាងចុះកាន់កកុដនទី ទ្រង់ស្រង់ និងសោយស្រេចហើយ ទ្រង់ឡើងមក រួចយាងទៅកាន់

អម្ពវន លុះទៅដល់ហើយ ទ្រង់ត្រាស់ទីឆ៍ងចុន្ទក:ដ៏មានអាយុថា ម្នាលចុន្ទក: អ្នកចូរក្រាលសង្ឃដ៏មានជាន់ ៤ ឲ្យតថាគត ម្នាលចុន្ទក: តថាគតល្ហិតល្ហៃណាស់ តថាគតនឹឆ៍សិឆ៍ ។ ចុន្ទកភិក្ខុដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រាលសង្ឃដ៏មានជាន់ ៤ ថ្វាយ ។លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សម្រេចនូវសីហសេយ្យាផ្តៀងទៅខាងស្តាំ ទ្រង់យកព្រះបាទខាងឆ្វេងត្រួតលើព្រះបាទខាងស្តាំ ទ្រង់មានសតិសម្បជញ្ញ:ធ្វើទុកក្នុងព្រះហឫទ័យនូវឧដ្ឋានសញ្ញា ។ ចំណែកខាងចុន្ទក:ដ៏មានអាយុ ក៏អង្គុយនៅចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ក្នុងទីនោះដែរ ។

ហេតុការណ៍ដែលព្រះសាស្តា ត្រាស់ប្រើព្រះអានន្ទទៅដងទឹកតែលោកមិនអាចដងទឹកមកបាន ព្រោះទឹកល្អក់រឹករវ ជាប់ទាក់ទងពីកងរទេះដែលបរឆ្លងកាត់ទៅ ព្រះពុទ្ធអង្គទ្រង់ប្រើដល់ ៣ ដង ព្រះថេរ:ទើបបានទៅដងទឹកយកមកថ្វាយ ដែលជាហេតុធ្វើឲ្យព្រះអង្គត្រូវនៅរង់ចាំយូរ ទាំងនេះ មានដោយបុព្វកម្មរបស់ព្រះមានព្រះភាគ ទ្រង់ធ្វើទុក

ក្នុងអតីតជាតិតាមឲ្យផល ។

ជូចមានរឿងសម្តែងប្រាកដនៅក្នុងព្រះបាលី **គម្ពីរខុទ្ទកនិកាយ អបទាន** ក្នុង **បុព្វកម្មបិលោតិ** គឺបុព្វកម្មរបស់ព្រះពុទ្ធ ជូចមានសេចក្តីនៅក្នុងវគ្គមួយ ដែលព្រះកគវាត្រាស់ដល់បុព្វកម្មរបស់ព្រះអង្គ ទ្រង់គង់លើផ្ទៃនៃថ្ម ជាទីរីករាយ ជិតអនោតត្តស្រះ រុងរឿងដោយរតន:ផ្សេងៗ ក្នុងចន្លោះនៃព្រៃ មានក្លិនផ្កាផ្សេងៗ ជូចមានសេចក្តីថា ៖

ព្រះសាស្តា មានភិក្ខុសង្ឃច្រើនចោមរោម ទ្រង់គង់លើផ្ទៃនៃថ្ម ជាទីរីករាយ ជិតអនោតត្តស្រះ រុងរឿងដោយរតន:ផ្សេងៗ ក្នុងចន្លោះនៃព្រៃ មានក្លិនផ្កាផ្សេងៗ ទ្រង់ព្យាករនូវបុព្វកម្មរបស់ព្រះអង្គក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវអំពើរបស់តថាគត ដែលបានធ្វើទុកមកហើយ ជូចតទៅនេះ តថាគតបានឃើញនូវភិក្ខុមួយរូបនៅក្នុងព្រៃ ហើយបានប្រគេននូវក្រណាត់សំពត់ ក្នុងកាលនោះ តថាគតបានប្រាថ្នាជាព្រះពុទ្ធជាជំបូង ដើម្បីការត្រាស់ដឹង ឯសេចក្តីនោះ ក៏ឲ្យផលក្នុងការត្រាស់ដឹងជាព្រះពុទ្ធ ដោយអំណាចនៃបិលោតិកម្ម ។ក្នុងកាលមុន

តថាគត កើតជានាយគោបាល កៀងគោទៅកាន់ទីគោចរ បានឃើញមេគោ កំពុងផឹកទឹកល្អក់ ហើយដេញចេញ ។ ដោយវិបាកនៃកម្មនោះក្នុងបច្ឆិមភពនេះ តថាគតស្រេកទឹក ហើយមិនបានផឹកទឹកដូចសេចក្តីប្រាថ្នា ។

គុណគឺសេចក្តីល្អរបស់នាយចុន្ទកម្មារបុត្រ ដែលបានទទួលការសរសើរអំពីព្រះលោកនាថ តាមដែលមានរៀងចារឹកទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ ឧទាន** នៃ **ចាជលិគាមិយវគ្គ** ក្នុង **ចុន្ទសូត្រ** ថា ៖

គ្រានោះ ព្រះសាស្តា ទ្រង់យាងសំដៅទៅឯកកុធនទី ជាមួយនឹងភិក្ខុសង្ឃច្រើនរូប លុះចូលទៅដល់ហើយ ក៏យាងចុះកាន់កកុធនទី ទ្រង់ស្រង់ និងសោយស្រេចហើយ ទ្រង់ឡើងមក រួចយាងទៅកាន់អម្ពវន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងចុន្ទក:ដ៏មានអាយុថា ម្នាលចុន្ទក: អ្នកចូរក្រាលសង្ឃាដិមានជាន់ ៤ ឲ្យតថាគត ម្នាលចុន្ទក: តថាគតល្ហិតល្ហៃណាស់ តថាគតនឹងសិង ។ ចុន្ទកភិក្ខុដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រាល

សង្ឃាដិមានជាន់ ៤ ថ្វាយ ។ លំដាប់នោះ ព្រះសាស្តា ទ្រង់សម្រេចនូវសីហសេយ្យា ផ្អៀងទៅខាងស្តាំ ទ្រង់យកព្រះបាទឆ្វេងត្រួតលើព្រះបាទខាងស្តាំ ទ្រង់មានសតិសម្បជញ្ញៈធ្វើទុកក្នុងព្រះហឫទ័យនូវឧដ្ឋានសញ្ញា ។ ចំណែកខាងចុន្ទកៈដ៏មានអាយុ ក៏អង្គុយនៅចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ក្នុងទីនោះឯង ។

ព្រះកគវា ទ្រង់យាងចុះកាន់ស៊ីងកកុធៈ ដែលមានទឹកថ្លាឈ្វង មានទឹកត្រជាក់ រងំថ្លា ព្រះតថាគតជាសាស្តាចារ្យ មិនមានបុគ្គលណាប្រៀបផ្ទឹមបានក្នុងលោក ព្រះអង្គមានសេចក្តីលំបាកព្រះកាយ ទ្រង់ស្រេងំសោយស្រេចហើយ ទើបយាងឡើងមក ព្រះសាស្តាមានភិក្ខុសង្ឃជាបរិវារ គង់នៅត្រង់កណ្តាល ។ ព្រះមុនី ជាសាស្តា ស្វែងរកគុណធំញ៉ាំងធម៌ទាំងឡាយ ឲ្យប្រព្រឹត្តក្នុងលោកនេះ ហើយយាងមកកាន់អម្ពវន ។ ត្រាស់ហៅភិក្ខុឈ្មោះចុន្ទកៈថា អ្នកចូរក្រាលសង្ឃាដិ ៤ ជាន់ ឲ្យតថាគតចុះ តថាគតនឿយសិង ។ ចុន្ទកភិក្ខុនោះ កាលបើព្រះសាស្តា ព្រះអង្គមាន ព្រះហឫទ័យអប់រំ ទ្រង់ជាស់តឿនហើយ ក្រាលសង្ឃាដិ

๔ ជាន់ដោយឆាប់រហ័ស ។ ព្រះសាស្តាមានព្រះកាយលំបាកក្រៃលែង ទ្រង់ផ្ទំ ចំណែកចុន្ទកភិក្ខុក៏អង្គុយចំពោះព្រះភក្ត្រ ក្នុងទីនោះដែរ ។

គ្រានោះ ព្រះមានព្រះភាគ ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ បើមានបុគ្គលណាមួយញុាំងសេចក្តីក្តៅក្រហាយឲ្យកើតឡើងដល់ចុន្ទកម្មារបុត្រថា ម្នាលអាវុសោចុន្ទ អ្នកឥតលាភ អ្នកបានធ្វើអំពើអាក្រក់ ព្រោះថា ព្រះតថាគត ទ្រង់សោយបិណ្ឌបាតរបស់អ្នកជាទីបំផុត ហើយបរិនិព្វាន ។ ម្នាលអានន្ទ អ្នកបន្ទោបង់នូវសេចក្តីក្តៅក្រហាយនៃចុន្ទកម្មារបុត្រយ៉ាងនេះថា ម្នាលអាវុសោចុន្ទ ពាក្យនោះអាត្មាបានស្តាប់ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ បានទទួលចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ បិណ្ឌបាតពីរនេះ មានផលស្មើៗគ្នា មានវិបាកស្មើៗគ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ជាងពួកបិណ្ឌបាតឯទៀត បិណ្ឌបាតពីរ តើដូចម្តេចខ្លះ ? គឺបិណ្ឌបាតដែលតថាគតទ្រង់សោយហើយ ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ๑ បិណ្ឌបាតដែលតថាគតសោយហើយបរិនិព្វាន ដោយអនុបាទិសេស-

និព្វានជាគុ ១ បិណ្ឌបាតទាំងពីរនេះ មានផលស្មើៗគ្នា មានវិបាកស្មើៗគ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ជាងពួកបិណ្ឌបាតឯទៀត ។ កម្មដែលចុនូកម្មារបុត្រដ៏មានអាយុសន្សំហើយ ជាកម្មប្រព្រឹត្តទៅដើម្បីអាយុ កម្មដែលចុនូកម្មារបុត្រសន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីពណ៌សម្បុរ កម្មដែលចុនូកម្មារបុត្រសន្សំហើយ ជាកម្មប្រព្រឹត្តទៅដើម្បីសេចក្តីសុខ កម្មដែលចុនូកម្មារបុត្រសន្សំហើយ ជាកម្មប្រព្រឹត្តទៅដើម្បីសួគ៌ កម្មដែលចុនូកម្មារបុត្រសន្សំហើយ ជាកម្មប្រព្រឹត្តទៅដើម្បីយស កម្មដែលចុនូកម្មារបុត្រសន្សំហើយ ជាកម្មប្រព្រឹត្តទៅដើម្បីកាវៈជាធំ ។ ម្នាលអានន្ទ អ្នកត្រូវបន្ទោបង់នូវសេចក្តីក្តៅក្រហាយរបស់ចុនូកម្មារបុត្រចេញយ៉ាងនេះឯង ។ លំដាប់នោះ ព្រះមានព្រះភាគជ្រាបច្បាស់សេចក្តីនោះហើយ ទើបទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

បុណ្យរមែងចម្រើនដល់បុគ្គលអ្នកឲ្យ បុគ្គលអ្នកសង្រួមរមែងមិនសន្សំទុកនូវពៀរទេ អ្នកឈ្លាសរមែងលះបង់កម្មដ៏លាមក បុគ្គលបរិនិព្វាន ព្រោះអស់ទៅនៃរាគៈ ទោសៈ មោហៈ ។

នៅមានពាក្យអធិប្បាយពន្រឹកសេចក្តីតាមព្រះបាលី ដែលបានពោលមកហើយនោះ ដើម្បីឲ្យយល់ចូលចិត្ត នៅក្នុងអត្ថន័យខាងដើម ឬពាក្យខ្លះៗ នៅក្នុង **អដ្ឋកថាបរមត្ថទីបនី** មានសេចក្តីថា ៖-

ពាក្យថា **មល្លជនបទ** ដែលព្រះសាស្តា ទ្រង់ទៅដល់កាលនោះ ជាឈ្មោះរបស់តំបន់មួយ ។ ពាក្យថា **កិក្ខុសង្ឃក្រុមធំ** បានដល់ កិក្ខុសង្ឃ ដែលជាធំដោយគុណ គឺកិក្ខុសង្ឃ ដែលតាមព្រះមុនីទៅក្នុងពេលនោះ សុទ្ធតែជាធំដោយគុណវិសេស មានសីលជាដើម ព្រោះថា បណ្តាកិក្ខុទាំងនោះ កិក្ខុដែលមានគុណវិសេសទាបបំផុតត្រឹមព្រះសោតាបន្ន និងធំដោយចំនួន ព្រោះកំណត់ចំនួនមិនបាន ។ ចាប់ផ្តើម អំពីគ្រាព្រះពុទ្ធទ្រង់ជាក់អាយុសង្ខារហើយ កិក្ខុសង្ឃទាំងឡាយដែលមកគាល់ព្រះអង្គ មិនមានអង្គណាមួយមកក្រាបទូលលាទៅវិញ មានតែតាមព្រះអង្គទៅទាំងអស់ ។ ពាក្យថា **សូករមទ្ទវៈ** ដែលនាយចុន្ទកម្មារបុត្រថ្វាយនោះ លោកពោលទុក នៅក្នុងអដ្ឋកថាថា បានដល់ សាច់ជ្រូកទូទៅ ដែលនៅទន់ស្និទ្ធ ។ នាយចុន្ទកម្មារបុត្រ បានជ្រាបដំណឹងថា ព្រះមហាវីរៈ

នឹងយាងបរិនិព្វានក្នុងថ្ងៃនេះ ទើបគិតថា ព្រះលោកនាយកសោយសូករមទ្ទវៈនេះហើយ គប្បីទ្រង់តម្កល់នៅអស់កាលដ៏យូរ ទើបគេបានថ្វាយសូករមទ្ទវៈ ដើម្បីបំណងនឹងឲ្យព្រះមានជោគ ទ្រង់តាំងព្រះជន្មបានអស់កាលដ៏យូរ ។

បានឮថា ទេវតាទាំងឡាយក្នុងទីបធំទាំង ៤ (មានទីបតូច ២ ពាន់ជាបរិវារ) បាននាំគ្នាជាក់ឱជាជាទិព្វចុះក្នុងសូករមទ្ទវៈនោះ ព្រោះជូរច្នោះអ្នកជនៃក្រៅអំពីព្រះជិនស្រីហើយ រមែងមិនមាននរណាអាចដើម្បីនឹងបរិភោគសូករមទ្ទវៈនោះឲ្យរលាយទៅបាន ព្រោះភ្លើងធាតុរបស់អ្នកជនៃមិនអាចនឹងជុតសូករមទ្ទវៈឲ្យរលាយទៅបាន មិនថានរណាក្នុងលោកទាំងអស់ គឺក្នុងមនុស្សលោក រហូតទៅដល់ព្រហ្មលោក ។ ព្រះភគវាដើម្បីនឹងទ្រង់ដោះពាក្យអាក្រក់របស់បុគ្គលជនៃ ដែលនឹងពោលប្រទូស្តថា មិនឲ្យរបស់ដែលសល់អំពីខ្លួន បរិភោគដល់កិក្ខុសង្ឃ ឬមិនឲ្យដល់មនុស្សពួកជនៃ ទើបបញ្ជាឲ្យជីករណ្តៅកប់សូករមទ្ទវៈដែលនៅសល់នោះធ្វើឲ្យវិនាសទៅ ។ សេចក្តីពិត ទេវតាទាំងនោះ បានកើតឡើងដល់

ព្រះសក្យមុនី ក្នុងស្រុកវេឡុគ្រាមនោះហើយ តែត្រូវកម្ចាំងនៃសមាបត្តិ
របស់ព្រះអង្គសង្កត់សង្កិនទុក ទើបមិនសម្តែងអាការចេញមក ព្រោះ
ឲ្យសមាបត្តិបង្អោនទៅ ចំពោះរាល់ៗថ្ងៃ រហូតដល់ពេលទ្រង់បរិនិព្វាន
តែទ្រង់បំណងនឹងបរិនិព្វានក្នុងថ្ងៃនោះ ទើបទ្រង់មិនចូលសមាបត្តិ ដើម្បី
ឲ្យសត្វកើតសេចក្តីសង្វេគថា សូម្បីព្រះអង្គទ្រង់មានកម្ចាំងស្មើនឹងដំរី
មួយពាន់កោដិត្រកូល មានព្រះកាយស្មើដោយផ្ទះពេជ្រ មានព្រះបុញ្ញ
សម្ភារ ដែលបានកសាងសន្សំមកអស់កាលដ៏ឃ្លាំ ដោយប្រមាណមិនបាន
កាលភពនៅមាន ទ្រង់បានទទួលវេទនាបែបនេះ ចាំបាច់ពោលថ្វីដល់
សត្វពួកជនៃ ដែលនឹងត្រូវជួបនូវទុក្ខវេទនាយ៉ាងខ្លាំងក្លានោះ ។ មាន
សេចក្តីបន្តទៅថា ព្រះមានជោគ ទ្រង់កើតអាពាធយ៉ាងខ្លាំងក្លា (ចុះព្រះ
លោហិត) មិនមែនសោយសូករមទូវៈ ហើយទ្រង់មានអាពាធយ៉ាង
ខ្លាំងក្លានោះទេ តែអាពាធយ៉ាងខ្លាំងក្លា ដែលកើតឡើងដល់ព្រះសយម្ភូ
បើព្រះអង្គមិនបានសោយសូករមទូវៈនោះ ជាប់ទាក់ទងពីព្រះអង្គបាន
សោយសូករមទូវៈទន់ស្និទ្ធនោះហើយ វេទនាទើបបានធូរស្បើយខ្លះ

ល្មមអាចទ្រង់ព្រះពុទ្ធដំណើរទៅដោយព្រះបាទទៀតបាន ។ ម្យ៉ាងព្រះក្រយាហារដែលព្រះភគវាសោយហើយ មិនបានធ្វើឲ្យគ្រោះថ្នាក់ដល់ព្រះវរកាយព្រះអង្គនោះទេ តែកម្មបានឱកាសចូលមកឲ្យផល ទីឆ៍ស្ងប់ទៅមានប្រមាណតិច ទើបធ្វើកម្លាំងឲ្យកើតឡើងក្នុងព្រះវរកាយ ដែលជាហេតុឲ្យប្រយោជន៍ ៣ យ៉ាង ដែលពោលដល់ការសម្រេចបានព្រោះដួច្នោះ ព្រះក្រយាហារនេះ ទើបដល់នូវការរលាយបានល្អ តែព្រោះវេទនាស្មើរនឹងបរិនិព្វាន ដែលអ្នកដទៃនឹកមិនដល់ ។

ហេតុដែលព្រះសាស្តាទ្រង់ចុះព្រះលោហិតនោះ មានរឿងទាក់ទងមកអំពីអកុសលកម្មក្នុងអតីតជាតិតាមមកឲ្យផល ក៏មានសម្តែងនៅក្នុងព្រះបាលី **គម្ពីរខុទ្ទកនិកាយ អបទាន** ក្នុង **បុព្វកម្មបិលោតិ** គឺបុព្វកម្មរបស់ព្រះសម្ពុទ្ធ ដោយព្រះអង្គត្រាស់ទីឆ៍ភិក្ខុទាំងឡាយឲ្យជ្រាបដល់កម្មក្នុងអតីតជាតិរបស់ព្រះអង្គថា ៖

ម្នាលភិក្ខុទាំងឡាយ កាលមុនតថាគត ធ្លាប់បានកើតជាគ្រូពេទ្យ ហើយបានក្លែងឲ្យថ្នាំបន្ទោបង់ដល់បុត្ររបស់សេដ្ឋីខ្លាំងពេកទៅ ដោយផល

នៃអំពើកម្មអាក្រក់នោះ មកដល់ឥឡូវនេះ រោគមួល (ជ្ងាក់ព្រះលោហិត តាមទ្វារធំ) ទើបបានមានឡើងដល់តថាគត ។ ការបន្ទោបង់ហួសប្រមាណ ជូរច្នោះ ដែលនឹងមកឲ្យទោសក្នុងពេលនេះ មកពីចិត្តដែលគិតមិនល្អ ដល់ចិត្តរបស់សេដ្ឋីបុត្រ ប្រសិនបើមិនមានចិត្តគិតអាក្រក់កើតឡើងទេ ព្រោះច្បាប់ផ្លូវព្រះពុទ្ធសាសនា ប្រកាន់ចេតនាជាគោល ដូចពុទ្ធវចនៈថា **ចេតនាហំ ភិក្ខវេ កម្មំ វទាមិ** ប្រែថា តថាគតពោលថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនាជាតួកម្ម ។

ពាក្យអធិប្បាយសេចក្តីក្នុងព្រះបាលីដែលមាននៅក្នុង **អដ្ឋកថា បរមត្ថទីបនី** ដូចមានសេចក្តីថា ៖

មានពាក្យសួរថា កាលអាពាធកើតឡើងដល់ព្រះសុគតយ៉ាងនោះហើយ ទើបព្រះអង្គបានយាងទៅកាន់នគរកុសិនារា ព្រោះហេតុអ្វី ព្រះអង្គទ្រង់មិនអាចយាងបរិនិព្វាន ក្នុងស្ថានទីដទៃបានឬ ? មានពាក្យឆ្លើយថា មិនមែនព្រះពុទ្ធអង្គទ្រង់មិនអាចយាងបរិនិព្វានក្នុងស្ថានទីដទៃនោះទេ តែព្រះពុទ្ធទ្រង់ព្រះតម្រិះថា កាលតថាគតទៅដល់ក្រុងកុសិនារា

ហើយ ១- នឹងបានសម្តែងមហាសុទស្សនសូត្រ ២- នឹងបានប្រាសជល់សុភទ្ទបរិព្វាជក ឲ្យបានសម្រេចជាព្រះអរហន្ត ជាបច្ឆិមសាវក ៣- ទោណព្រាហ្មណ៍នឹងបានហាមនូវជម្លោះវិវាទដ៏ធំ រវាងក្សត្រទាំងឡាយ ហើយនឹងបានចែកព្រះបរមសារីរិកធាតុរបស់ព្រះតថាគត ដើម្បីការពារនូវចម្បាំង រហូតដល់ឈាមហូរដូចជាទឹកស្ទឹង ព្រោះហេតុនៃព្រះបរមសារីរិកធាតុ ។ ព្រះមានជោគ ទ្រង់ឃើញហេតុ ៣ ប្រការនេះហើយ ទើបបានយាងទៅបរិនិព្វាននៅឯក្រុងកុសិនារា ដោយព្រះមហាឧស្សាហ៍ ។ សេចក្តីពិត ព្រះសាស្តា បានទ្រង់ពុទ្ធដំណើរទៅក្នុងកាលនោះ ដោយអានុភាពរបស់ព្រះអង្គ ក៏វេទនាដ៏ខ្លាំងក្លានោះ ប្រសិនបើកើតនៅក្នុងពួកបុគ្គលដទៃ មិនអាចនឹងលើកជើងដើរទៅបានឡើយ ។ ពាក្យថា ព្រះតថាគត ត្រាស់នឹងចុន្ទកៈថា ម្នាលចុន្ទកៈ តថាគតល្អិតណ្លៃ នឹងសម្រាកសិន ជាពាក្យដែលគួរវិនិច្ឆ័យ ព្រោះហេតុថា កម្លាំងកាយរបស់ព្រះអង្គ មានប្រមាណប៉ុនកម្លាំងរបស់ដំរីមួយពាន់កោដិ តែក្នុងថ្ងៃនោះ កម្លាំងរបស់ព្រះអង្គ បានអស់រលីងទៅ ដូចទឹកដែលគេដាក់ទុកក្នុង

តម្រង់ទឹក រាប់តាំងអំពីសោយភត្តាហារក្នុងថ្ងៃនោះហើយ ។ ព្រះជិនវរ យាងចេញអំពីក្រុងបាវាបាន ៥០០ ព្យាម ចាំបាច់ត្រូវសម្រាកក្នុងចន្លោះផ្លូវ ហើយទ្រង់ធ្វើឧស្សាហ៍យ៉ាងខ្លាំងក្លា ទ្រង់បានយាងតទៅរហូតដល់ក្រុងកុសិនារា ក្នុងពេលដែលព្រះអាទិត្យអស្តង្គត ។

ធម្មតារោគរមែងញាំញីបុគ្គល ដែលជាអ្នកមានបញ្ចក្ខន្ធទាំងអស់បាន កាលព្រះសាស្តា ទ្រង់សម្តែងសេចក្តីនេះ ដែលធ្វើភាពសង្វេគគឺសេចក្តីតក់ស្លុតចិត្តដល់សត្វលោក ព្រមទាំងទេវលោក ទើបត្រាស់ថា ម្នាលចុន្ទៈ តថាគតល្ហិតល្ហៃ ចង់សម្រាកសិន ។ ពាក្យថា ព្រះសម្ពុទ្ធផ្ងើ ដោយសីហសេយ្យា មានពាក្យអធិប្បាយថា ការដេកមាន ៤ ប្រការ បានដល់ **១- កាមភោគិសេយ្យា** គឺការដេករបស់អ្នកបរិភោគកាម **២- បេតសេយ្យា** គឺការដេករបស់ពួកប្រេត **៣- តថាគតពោធិសេយ្យា** គឺការផ្ងើរបស់ព្រះតថាគត **៤- សីហសេយ្យា** គឺការដេករបស់ពួករាជសីហ៍ ។ បុគ្គលដែលបរិភោគកាមដោយច្រើន រមែងដេកផ្អៀងខាងឆ្វេង

ពពួកប្រែតដោយច្រើន រមែងដេកផ្ងារ ឈានទី ៤ ឈ្មោះថា ការផ្ងំរបស់ព្រះតថាគត រាជសីហ៍រមែងដេកផ្អៀងខាងស្តាំ ។ សេចក្តីពិត ការដេករបស់រាជសីហ៍ ឈ្មោះថា ជាការដេកដ៏ឧត្តម ដោយមានឥរិយាបថខ្ពស់ឡើង ព្រោះតេជៈ ។ ព្រោះហេតុនោះ ទើបលោកពោលថា ផ្ងំដោយសីហសេយ្យា គឺការដេកផ្អៀងខាងស្តាំ ។ ការផ្ងំរបស់ព្រះសម្មាសម្ពុទ្ធ នៅត្រង់ច្រាំងស្ទឹងកកុធនទី ជាសីហសេយ្យា គឺផ្ងំផ្អៀងខាងស្តាំ ទ្រង់យកព្រះបាទឆ្វេងត្រួតលើព្រះបាទស្តាំ កាល-កព្រះបាទសង្កត់លើគ្នា ហើយកឝ្ឋាលជង្គង់សង្កត់លើគ្នា រមែងផ្ងំមិនសប្បាយ ព្រោះដូច្នោះ ព្រះមហាវីរៈ ទើបផ្ងំដោយជាក់.កព្រះបាទខាងស្តាំឲ្យលូតជាង-កព្រះបាទខាងឆ្វេង មិនឲ្យ.កព្រះបាទ និងកឝ្ឋាលជង្គង់នៅចំពីលើគ្នា ការផ្ងំក៏ជាផាសុក ។

កាលព្រះមហាមុនី ទ្រង់ផ្ងំមួយស្របក់ហើយ ទើបបានត្រាស់ប្រាប់ព្រះអានន្ទឲ្យទៅដោះស្រាយ ការខូចចិត្តរបស់នាយចុន្ទកម្មារបុត្រ

តាមដែលមាននៅក្នុងព្រះបាលីនោះ ។ មានពាក្យ ដែលគួរសង្ស័យ នៅក្នុងព្រះបាលីថា អាហារបិណ្ឌបាតទាំងពីរ គឺអាហារបិណ្ឌបាតដែលព្រះមហាវីរបុរសសោយហើយ បានត្រាស់ជីងនូវសម្មាសម្ពោធិញ្ញាណ និងអាហារបិណ្ឌបាតដែលព្រះមុនី សោយហើយបរិនិព្វាន ថាមានផលស្មើគ្នា មានវិបាកប៉ុនគ្នា ព្រោះហេតុអ្វី ? ព្រោះអាហារបិណ្ឌបាតដែលនាងសុជាតាថ្វាយនោះ ជាអាហារបិណ្ឌបាតថ្វាយក្នុងគ្រា ដែលព្រះមុនីនៅមិនទាន់អស់កិលេស តែអាហារបិណ្ឌបាតដែលនាយចុន្ទកម្មារបុត្រ ជាអាហារបិណ្ឌបាត ដែលថ្វាយក្នុងគ្រាដែលព្រះសាស្តាអស់កិលេសហើយ ហេតុអ្វី ទើបពោលថា មានផលស្មើគ្នា មានវិបាកប៉ុនគ្នា ? មានពាក្យឆ្លើយថា ១- ព្រោះមានការបរិនិព្វានស្មើគ្នា ២- ព្រោះមានសមាបត្តិស្មើគ្នា ៣- ព្រោះមានការរឭកស្មើគ្នា ។ សេចក្តីពិត ព្រះមុនីសោយអាហារបិណ្ឌបាត ដែលនាងសុជាតាថ្វាយហើយ បានសម្រេចឧបាទិសេសនិព្វាន (កិលេសនិព្វាន តែបញ្ចក្ខន្ធនៅមាន) ។ អាហារ

បិណ្ឌបាតដែលនាយចុន្ទកម្មារបុត្រថ្វាយនោះ លុះព្រះអង្គបានសោយហើយ ក៏បានសម្រេចអនុបាទិសេសនិព្វាន ដោយព្រះអង្គទ្រង់បរិនិព្វានក្នុងវេលាបច្ចូសសម័យនៃរាត្រីថ្ងៃនោះ ។ អាហារបិណ្ឌបាតទាំងពីរនោះ មានផលស្មើគ្នា ព្រោះមានការបរិនិព្វានស្មើគ្នាយ៉ាងនេះឯង ។ ក្នុងថ្ងៃដែលព្រះសម្មាសម្ពុទ្ធត្រាស់ជ័ងនោះ ព្រះអង្គទ្រង់បានចូលសមាបត្តិ ២៤ សែនកោដិសមាបត្តិ ដែលជាហេតុនៃមគ្គដ៏លើស ។ ចំណែកក្នុងថ្ងៃទ្រង់បរិនិព្វាន ព្រះអង្គក៏ទ្រង់បានចូលសមាបត្តិ ២៤ សែនកោដិសមាបត្តិដូចគ្នាដែរ ។ ដូច្នេះទានទាំងពីរនេះ ទើបមានឈ្មោះថា មានផលស្មើគ្នា ព្រោះមានសមាបត្តិស្មើគ្នា ។

សមដូចព្រះពុទ្ធតម្រាស់ត្រាស់ថា បុគ្គលដែលបរិភោគអាហារបិណ្ឌបាតរបស់អ្នកណាហើយ ចូលចេតោសមាធិ ដែលរកប្រមាណមិនបាន ការហូរមកនៃបុណ្យកុសលរបស់បុគ្គលនោះ ក៏រកប្រមាណមិនបានដូចគ្នាដែរ ។កាលនាង់សុជាតា បានថ្វាយអាហារបិណ្ឌបាតដល់

ព្រះទសពលក្នុងគ្រានោះ នាងក៏បានកើតបីតិសោមនស្សយ៉ាងខ្លាំងក្លា ដោយការពេកថា បុគ្គលដែលបរិភោគអាហារបស់យើងនោះ មិនមែនជារុក្ខទេវតាទេ ជាព្រះពោធិសត្វ ដែលបានបរិភោគអាហារបស់យើងហើយ ក៏បានត្រាស់ជីងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ដោយព្រះពោធិសត្វទ្រង់តាំងព្រះជន្មនៅបានដោយអាហារបិណ្ឌបាតនោះ មិនបានបរិភោគអាហារដទៃទៀតដល់ ๗ សប្តាហ៍ រាប់ជាលាភរបស់យើងហើយ ។ ចំណែកនាយចុន្ទកម្មារបុត្រ ក៏បានកើតបីតិសោមនស្សយ៉ាងខ្លាំងក្លា ក្នុងកាលគិតរឿយៗ ថា យើងបានថ្វាយអាហារបិណ្ឌបាតគ្រាចុងក្រោយហើយ យើងបានកាន់យកធម៌ដ៏លើស ព្រះមុនីសោយអាហារបិណ្ឌបាតរបស់យើងហើយ ទ្រង់រំលត់ខន្ធបរិនិព្វាន ដោយអនុបាទិសេសនិព្វាន-ធាតុ តាមដែលព្រះអង្គទ្រង់ប្រថ្នាទុកមកហើយអស់កាលជ័យូរ ទាំងនេះរាប់ថា ជាលាភរបស់យើងពិតមែន ។ អាហារបិណ្ឌបាតរបស់អ្នកទាំងពីរនាក់នេះ ឈ្មោះថា មានផលស្មើគ្នា ព្រោះមានការពេកស្មើគ្នា

យ៉ាងនេះ ។ (នាយចុន្ទកម្មារបុត្រ ជាឧបាសកបានសម្រេចអរិយធម៌ជាព្រះសោតាបន្ន គឺបានជាព្រះអរិយបុគ្គលថ្នាក់ដំបូងក្នុងព្រះសាសនា និងការបានសម្រេចជាព្រះសោតាបន្ននេះ ស្មើគ្នានឹងការបិទទ្វារអបាយភូមិ (កំណើតដែលប្រាសចាកសេចក្តីចម្រើន មាននរក ប្រេត តិរច្ឆាន អសុរកាយ) ដែលមានតែនឹងឈានឡើងឆ្ពោះទៅកាន់អរិយធម៌ថ្នាក់ខ្ពស់ៗ តទៅទៀត និងកិត្តិគុណរបស់នាយចុន្ទកម្មារបុត្រ ដែលពុទ្ធបរិស័ទស្គាល់ទូទៅ បានដល់ ការថ្វាយភត្តាហារ (អាហារបិណ្ឌបាត) ជាបច្ឆិមបិណ្ឌបាត ដែលព្រះពុទ្ធជាម្ចាស់សោយនាគ្រាចុងក្រោយហើយ ព្រះអង្គរំលត់ខន្ធបរិនិព្វាន) ๚๛

(ជីវប្រវត្តិរបស់នាយចុន្ទកម្មារបុត្រឧបាសក ចប់)

✍ ជីវប្រវត្តិរបស់នាយសុមនមាលាការឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

នាយសុមនមាលាការ ជាអ្នកមានសទ្ធាជាប់ខាត បានឧទ្ទិសជីវិតធ្វើពុទ្ធបូជា ដែលចាត់ថាកេបានដោយកម្រ ក្នុងបណ្តាពុទ្ធឧបាសកដែលតាំងចិត្តធ្វើការបូជា ដែលជាហេតុធ្វើឲ្យគេ បានទទួលផលទាន់ភ្នែកដែលហៅថា **ទិដ្ឋធម្មវេទនីយកម្ម** ប្រែថា កម្មដែលឲ្យផលនៅក្នុងបច្ចុប្បន្នជាតិនេះ ។

ជីវប្រវត្តិរបស់នាយសុមនមាលាការ មានសម្តែងទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **ពាលវគ្គ** ក្នុងរឿង **នាយសុមនមាលាការ** ថា ៖

សម័យមួយ កាលព្រះភគវាប្រថាប់នៅក្នុងវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ ព្រះអង្គបានត្រាស់ព្រះធម្មទេសនា ដោយទ្រង់ប្រារព្ធនាយសុមនមាលាការ គឺអ្នកក្រងផ្កាឈ្មោះ **នាយសុមនៈ** ឲ្យជាដើមហេតុថា នាយសុមនមាលាការជាអ្នកមានទាទីនាំផ្កាមួ៉ៃទៅថ្វាយព្រះបាទពិម្ពិសារ

ជាប្រចាំរៀងរាល់ព្រឹក មួយថ្ងៃ ៨ នាឡិ និងគេបានទទួលព្រះរាជទាន
ប្រាក់រង្វាន់ ៨ កហាបណៈ ។ តមកថ្ងៃមួយ ខណៈដែលនាយសុមន-
មាលាការ កាន់ផ្កាដើរចូលទៅក្នុងក្រុងរាជគ្រឹះ ។ ព្រះមុនី មានកិក្ខុសង្ឃ
ហែហមជាច្រើន ព្រះអង្គទ្រង់បានបញ្ចេញព្រះរស្មី ៦ ប្រការ យាងចូលទៅ
បិណ្ឌបាតនៅក្នុងក្រុងរាជគ្រឹះ ដោយមហាពុទ្ធានុភាព ដោយពុទ្ធលីលា
គឺមានអាកប្បកិរិយាដ៏ល្អពន់ពេក ។ សេចក្តីពិត ក្នុងគ្រាខ្លះ ព្រះសម្ពុទ្ធ
ទ្រង់បិទបាំងព្រះរស្មី ៦ ប្រការទុកដោយចីវរហើយ យាងទៅដូចកិក្ខុ
ចារិកបិណ្ឌបាតជាកិច្ចវត្តរបណានីមួយ ដូចជាកាលព្រះអង្គយាងទៅ
ទទួលអង្គុលីមាល អស់រយៈផ្លូវដល់ទៅ ៣០ យោជន៍ ។តែក្នុងគ្រាខ្លះ
ព្រះលោកនាថ ទ្រង់បញ្ចេញព្រះរស្មី ៦ ប្រការឲ្យប្រាកដ ដូចជាកាល
ដែលព្រះភគវា យាងចូលទៅកាន់ក្រុងកបិលពស្តុជាដើម ។ ចំណែក
ក្នុងថ្ងៃ ដែលព្រះមានបុណ្យ ទ្រង់ចូលទៅកាន់ក្រុងរាជគ្រឹះគ្រានោះ
ព្រះអង្គ ទ្រង់បានបញ្ចេញព្រះរស្មី ៦ ប្រការអំពីព្រះវរកាយ យាងទៅ
ដោយព្រះមហាពុទ្ធានុភាព ។គ្រានោះ នាយសុមនមាលាការបានឃើញ

ព្រះវរកាយរបស់ព្រះទសពល ដូចគ្នានឹងរតនៈ និងមាសដែលមានតម្លៃដ៏លើស គេបានក្រឡេកមើលព្រះវរកាយ ដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ ។

នឹងសូមរៀបរាប់មហាបុរិសលក្ខណៈ និងអនុព្យញ្ជនៈមកពោលទុកក្នុងទីនេះ តាមដែលមានសម្តែងនៅក្នុងព្រះបាលី **គម្ពីរទីឃនិកាយ មហាវគ្គ** នៃ **មហាបទានសូត្រ** និងក្នុង **គម្ពីរទីឃនិកាយ បាដិកវគ្គ** នៃ **លក្ខណសូត្រ** ដូចមានសេចក្តីថា ៖

មហាបុរិសលក្ខណៈ គឺលក្ខណៈរបស់មហាបុរស ៣២ ប្រការ បានដល់ ๑- មានផ្ទៃព្រះបាតទាំងគូរាបស្មើ (មិនផតកណ្តាល) ๒- ផ្ទៃព្រះបាតទាំងគូមានរូបចក្រ ๓- ព្រះបណ្តិ គឺកែងវែង ๔- ព្រះអង្គុលី (ម្រាមព្រះហស្ត និងម្រាមព្រះបាទ វែងៗ) ๕- ផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទទន់ល្មើយ ๖- ផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទប្រទាក់ដោយក្រឡាដូចជាសំណាញ់ ๗- ព្រះបាទដូចជាអណ្តែតឡើងខាងលើ ๘- ព្រះជង្ឃាគឺស្នងរៀវមូលត្រសូល ๙- ទ្រង់ឈរមិនបាច់ឱនព្រះអង្គចុះ អាចសាប

អង្អែលព្រះជានុ (ជង្គង់) ១០- ព្រះអង្គាវយវៈលាក់កំបាំងនៅក្នុងស្រោម ១១- ស្បែកសម្បុរថ្លៃ ដូចជាសម្បុរនៃមាស ១២- ព្រះឆវីគឺសម្បុរថ្លៃ ល្អិតផូរផង់រលើងស្រិល រអិលធូលីធ្លាក់មកមិនជាប់ព្រះកាយ ១៣- ព្រះលោមាតែមួយសរសៃៗ គឺក្នុងរណ្តៅរោមមួយ មានរោមមួយ ១៤- ព្រះលោមាមានចុង-ងឡើង ព្រះលោមាដែលជុះឡើងហើយ មានចុងឡើងលើ ជាទក្ខិណាវដ្ត វិលវល់ព័ទ្ធពែនទៅខាងស្តាំ មានសម្បុរខៀវដូចជាសម្បុរនៃផ្កាអញ្ចន កួចមូលដូចជាកុណ្ឌល ១៥- ព្រះកាយត្រង់ដូចជាកាយព្រហ្ម ១៦- ព្រះមំសៈ គឺសាច់ ៧ អន្ទើពេញបរិបូណ៌ (ខ្នងព្រះហស្តទាំងពីរ ខ្នងព្រះបាទទាំងពីរ ព្រះអស្សា (ស្មា) ទាំងពីរ និងជង-ក ១៧- ព្រះវរកាយពាក់កណ្តាលខាងលើ ដូចជាកាយនៃស្តេចរាជសីហ៍ ១៨- ព្រះបិដ្ឋិ គឺខ្នងដ៏ពេញបរិបូណ៌ ១៩- ទ្រង់ទ្រាយព្រះកាយដូចជាបរិមណ្ឌលនៃដើមជ្រៃ ២០- ព្រះសូរង (ក) មូលសម ២១- ព្រះប្រសាទ គឺសរសៃល្អិតធ្មារដ៏លើសលែងសម្រាប់ទទួលរសអាហារ ២២- ព្រះហនុកា (ចង្កា) ដូចជាចង្កានៃរាជសីហ៍ ២៣- ព្រះទន្ត ៤០ គត់

២៤- ព្រះទន្តភបស្មើ ២៥- ព្រះទន្តជិតស្និទ្ធ ២៦- ព្រះទាឋា គឺចង្កូមទាំង ៤ សស្អាត ២៧- ព្រះជិវ្ហា (អណ្តាត) ដ៏ធំវែង (អាចលៀនបិទថ្ងាសបាន) ២៨- ព្រះសូរសព្ទដូចជាសំឡេងនៃព្រហ្ម ២៩- កាលបើបញ្ចេញវាចាលាន់ឮពីរោះ ដូចជាសំឡេងសត្វករវិក ៣០- ព្រះនេត្រខៀវស្រស់ ដួងព្រះនេត្រ ដូចជាភ្នែកនៃកូនគោ ៣១- ព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើម ជុះចន្ទោះនៃព្រះភសុកា (ចិញ្ចើម) មានពណ៌.ស ក្បុស ទន់ល្មើយដូចសំឡី ៣២- មហាបុរសមានព្រះសិរ្ស ហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ។

ចំណែកអនុព្យញ្ជនៈវិញ សំដៅដល់លក្ខណៈតូច ឬលក្ខណៈបន្តិចបន្តួចរបស់មហាបុរស ដែលក្រៅអំពីមហាបុរិសលក្ខណៈ ៣២ ប្រការ ដែលមានទាំងអស់ ៨០ ប្រការ បើហៅតាមភាសាព្រះបាលីថា ***អសីត្យានុព្យញ្ជនៈ*** បានដល់ ១- ម្រាមព្រះហស្ត និងម្រាមព្រះបាទពណ៌លឿងស្រស់ ២- ម្រាមព្រះហស្ត និងម្រាមព្រះបាទរៀវទៅដោយលំដាប់ តាំងអំពីគល់រហូតដល់ចុង ៣- ម្រាមព្រះហស្ត និងម្រាម

ព្រះបាទមូល ដូចនាយជាងក្រឡឹង ដែលក្រឡឹងបានល្អ ๔- ព្រះនខា (ក្រចក) ទាំង ๒๐ មានពណ៌ក្រហម ๕- ព្រះនខាទាំង ๒๐ នោះ អែនស្អាតឡើងលើ មិនខុបចុះក្រោមដូចក្រចកសាមញ្ញជនទាំងពួង ๖- ព្រះនខានោះមានពណ៌រលើបរលោង មិនបែកប្រេះស្រាំ ๗- ក.ព្រះហស្ត និង ក.ព្រះបាទនៅលើមំសំ មិនបានជុះផុតប្រាកដចេញមកខាងក្រៅ ๘- ព្រះបាទទាំងពីរខាងស្មើគ្នា មិនតូច ឬធំជាងគ្នា សូម្បីប៉ុនគ្រាប់ល្ង ក៏មិនមាន ๙-ព្រះជំណើរសង្ហា ដូចអាការដើរបស់ជីរ ๑๐-ព្រះជំណើរសង្ហា ដូចរាជសីហ៍ដើរ ๑๑- ព្រះជំណើរសង្ហា ដូចជំណើរហង្ស ๑๒- ព្រះជំណើរសង្ហា ដូចជំណើរគោឧសភរាជ ๑๓- ខណៈឈរ និងលើក ព្រះបាទយាងទ្រង់លើកព្រះបាទខាងស្តាំយាងទៅមុន ๑๔-ព្រះជានុមណ្ឌល មូលពេញបរិបូណ៌ មិនឃើញឆ្អឹងអង្គញ់ប្រាកដចេញមកខាងក្រៅ ๑๕- មានបុរិសព្យញ្ជនៈបរិបូណ៌ គឺមិនមាន កិរិយាមារយាទដូចស្ត្រី ๑๖- ព្រះនាភី (ផ្ចិត) មិនខុសឆ្គង មូលស្អាត មិនវិកលក្នុងទីឯណានីមួយ ๑๗- ព្រះខនរ (ពោះ) មានសណ្ឋានជ្រៅ ๑๘- ខាងក្នុងព្រះខនរ

មានស្នាមវិលទក្ខិណាវដ្ត ១៩- ព្រះភ្លៅទាំងពីរ មូលស្អាតដូចដើមចេក ២០-ព្រះ.ក (ដើមដៃ) ទាំងពីរស្អាតដូចប្រមោយនៃជីរឯកវណ្ណទេពហត្ថ ២១- ព្រះអង្គាយវៈ អាយវៈតូចធំទាំងពួងមានសណ្ឋានល្អ គឺល្អព្រមគ្រប់កន្លែង រកកន្លែងតិះដៀលមិនបាន ២២-ព្រះមំសៈ (សាច់) ដែលគួរក្រាស់ក៏ក្រាស់ ដែលគួរស្តើងក៏ស្តើង តាមកន្លែងទូទាំងព្រះកាយ ២៣- ព្រះមំសៈមិនបានយុរយោរក្នុងទីឯណាមួយ ២៤- ព្រះវរកាយទាំងពួងមិនមានពក ប្រជ្រុយ ផ្នូក ឬអាចម៍រុយក្នុងទីឯណាមួយឡើយ ២៥- ព្រះវរកាយស្អាតបរិសុទ្ធព្រមសមគ្នា ដោយលំដាប់ទាំងខាងលើ និងខាងក្រោម ២៦- ព្រះវរកាយស្អាតបរិសុទ្ធព្រមទាំងអស់ មិនមានមន្ទិលទាំងពួង ២៧- ទ្រង់មានព្រះកម្លាំងច្រើន ស្មើដោយកម្លាំងនៃជីរប្រមាណដល់មួយពាន់កោដិ បើនឹងប្រមាណដោយកម្លាំងបុរស ក៏បានមួយសែនកោដិនាក់ ២៨- មានព្រះនាសិក (ច្រមុះ) ខ្ពស់ (ស្អាតសមសួន) ២៩- ព្រះសណ្ឋានព្រះនាសិកស្អាតជក់ឃ្យល់ ៣០- ព្រះឱស្ឋ (បបូរមាត់) ខាងលើ និងខាងក្រោម មិនខ្វីវែងជាងគ្នា ស្មើគ្នាយ៉ាងល្អ

និងមានពណ៌ក្រហមដូចផ្លែឳសុំ ៣១- ព្រះទន្តបរិសុទ្ធ មិនមានសំណល់អាហារ ៣២- ព្រះទន្ត.ស ដូចពណ៌សង្ខជិតស្និទ្ធល្អ ៣៣- ព្រះទន្តរលោងមិនច្រពើស ៣៤- ព្រះឥន្ទ្រិយទាំង ៥ មានចក្ខុន្ទ្រិយជាដើមស្អាតបរិសុទ្ធទាំងអស់ ៣៥- ព្រះចង្កឹមកែវទាំង ៤ ស.ស្អាត ភ្លឺរុងរឿងដូចផ្កាយព្រឹក ៣៦- វង់ព្រះភក្ត្រមានសណ្ឋានវែងស្អាត ៣៧- ថ្ពាល់ទាំងពីរ មើលទៅស្អាតស្មើគ្នា ៣៨- ក្រឡាក្រយៅព្រះហស្តមានស្នាមជ្រៅ ៣៩- ក្រឡាក្រយៅព្រះហស្តមានស្នាមវែង ៤០- ក្រឡាក្រយៅព្រះហស្ត មានស្នាមត្រង់មិនវៀច ៤១- ក្រឡាក្រយៅព្រះហស្ត មានស្នាមពណ៌ក្រហមរុងរឿង ៤២- រស្មីភ្លឺស្វាងជាបរិមណ្ឌលដោយជុំវិញ ៤៣- ទ្រង់ទ្រាយថ្ពាល់ទាំងពីរតឹងបរិបូណ៌ ៤៤- ត្របកព្រះនេត្រទូលាយ វែងស្អាតល្មមសមគ្នា ៤៥- កែវភ្នែកប្រកបដោយពណ៌ទាំង ៥ មានពណ៌.ស ជាដើម ថ្ងាបរិសុទ្ធទាំងអស់ ៤៦- ចុងសរសៃព្រះលោមាទាំងឡាយមិនមានវៀច ៤៧- ព្រះជិវ្ហាមានសណ្ឋានដ៏ល្អ ៤៨- ព្រះជិវ្ហាដ៏ទន់ល្មើយមិនរឹង មានពណ៌ក្រហមខ្ចី ៤៩- ព្រះកាណ៌ទាំងពីរ (ត្រចៀក) មាន

សណ្ឋាន វែងដូចត្រចកឈូក ៥០- រន្ធព្រះកាណ៌ មានសណ្ឋានមូលស្អាត ៥១- រចៀបព្រះនហារុ (សរសៃ) ទាំងពួងត្រង់ល្អ មិនវាន់ក្នុងទីឯណានីមួយ ៥២- ជួរព្រះនហារុទាំងឡាយកប់នៅក្នុងព្រះមំសៈទាំងអស់ មិនផុសឡើងឲ្យឃើញ ដូចសាមញ្ញជនទាំងពួង ៥៣- ព្រះសីសៈ មានសណ្ឋានស្អាត ដូចឆត្រកែវ ៥៤- បរិមណ្ឌលព្រះនលាដ (ថ្ងាស) ទទឹងបណ្តាយវែងល្មមសមគ្នា ៥៥- ព្រះនលាដមានសណ្ឋានស្អាតបរិសុទ្ធ ៥៦- ព្រះចិញ្ចើមមានសណ្ឋានស្អាតដូចជងឆ្នុ ៥៧- ព្រះលោមាត្រង់ចិញ្ចើមមានសរសៃល្អិត ៥៨- សរសៃព្រះលោមា ត្រង់ចិញ្ចើមជុះឡើងហើយ ជួលរាបទៅដោយលំដាប់ ៥៩- ព្រះចិញ្ចើមនោះធំ ៦០- ព្រះចិញ្ចើមវែងផុតកន្ទុយព្រះនេត្រ ៦១- សម្បុរស្បែកល្អិតទូទៅពេញព្រះរាងកាយ ៦២- ព្រះរាងកាយរុងរឿង ដោយសិរី (មង្គល) ៦៣- ព្រះរាងកាយមិនសៅហ្មងផូរផង់ជាប់ជានិច្ច ៦៤- ព្រះរាងកាយស្រស់ស្រាយដូចផ្កាឈូក ៦៥- ព្រះសីរសមួសរទន់ល្មើយ មិនរឹងទូទាំងព្រះរាងកាយ ៦៦- ក្លិនព្រះកាយក្រអូបផ្សាយទៅដូចក្លិនក្រស្នា ៦៧- ព្រះលោមា

មានសរសៃស្មើគ្នាទាំងអស់ ៦៨- ព្រះលោមាមានសរសៃល្អិតទូទាំងព្រះកាយ ៦៩- ខ្យល់ដង្ហើមចេញ-ចូលក៏ល្អិត ៧០- ព្រះឱស្ឋមានសណ្ឋានល្អ ដូចញញួម ៧១- ក្លិនព្រះឱស្ឋក្រអូប ដូចក្លិនផ្កាឧប្បល ៧២-ព្រះកេសាខ្មៅឆ្នុះស្រមោល ៧៣-ក្លិនព្រះកេសាក្រអូបឈ្ងុយឈ្ងប់ ៧៤-ព្រះកេសាក្រអូបដូចក្លិនផ្កាកោមល ៧៥-ព្រះកេសាមានសណ្ឋានមូលគ្រប់សរសៃ ៧៦- ព្រះកេសាខ្មៅស្រិលគ្រប់សរសៃ ៧៧- ព្រះកេសាប្រកប ដោយសរសៃល្អិត ៧៨- សរសៃព្រះកេសាមិនជំពាក់ ៧៩-សរសៃព្រះកេសាវិលជាទក្ខិណាវដ្ត គ្រប់ៗ សរសៃ ៨០- មានព្រះកេតុមាលា ពោលគឺជួរនៃព្រះរស្មី វិចិត្រឡើងទៅខាងលើព្រះសីស: ។

រឿងវ៉ាវរបស់នាយសុមនមាលាការ តាមដែលមានសម្តែងទុកនៅក្នុង **អដ្ឋកថាធម្មបទ** ដូចមានសេចក្តីថា ៖

កាលសុមនមាលាការ បានក្រឡេកឃើញមហាបុរិសលក្ខណ: ៣២ ប្រការ និងអនុព្យញ្ជន: ៨០ ប្រការដ៏ប្រសើរដូច្នេះហើយ គេក៏បានកើតមានចិត្តជ្រះថ្លាឡើង ហើយគិតថា យើងនឹងបូជាវត្ថុអ្វីដល់ព្រះមុនី

ទើបជាការល្អហ្ន៎ កាលគេពិចារណាមើលមិនឃើញវត្ថុដទៃ ទើបគិតថា យើងនឹងបូជាព្រះមានព្រះភាគដោយផ្កាម្ទិះទាំងនេះ ហើយគេគិតតទៅទៀតថា ផ្កាម្ទិះនេះជាផ្កាសម្រាប់ទុកថ្វាយព្រះរាជាជាប្រចាំ កាលព្រះរាជាទ្រង់មិនបានផ្កាម្ទិះទាំងនេះទេ ទ្រង់នឹងត្រាស់បញ្ជាឲ្យគេប្រហារជីវិត ឬឲ្យនិរទេសយើង តើយើងគប្បីធ្វើយ៉ាងណាទើបល្អ ហើយគេបានសម្រេចចិត្តថា បើព្រះរាជានឹងទ្រង់សម្ងាប់ ឬនឹងទ្រង់និរទេសយើងក៏ដោយ ព្រោះតែការបូជាផ្កាម្ទិះនេះដល់ព្រះពុទ្ធ ដោយមិនបានយកទៅថ្វាយដល់ព្រះរាជានោះ ចំណែកឯប្រាក់ដែលព្រះរាជា ទ្រង់ព្រះរាជទានមកឲ្យដល់យើង ព្រោះតែបានយកផ្កាម្ទិះនោះ ទៅថ្វាយដល់ព្រះរាជាហើយប្រាក់នោះ អាចចិញ្ចឹមជីវិតបានត្រឹមតែក្នុងអត្តភាពនេះប៉ុណ្ណោះ ចំណែកឯការបូជាចំពោះព្រះភគវា រមែងធ្វើឲ្យយើងបានទូវប្រយោជន៍និងសេចក្តីសុខអស់ កាលជ័យូរអង្វែង លុះគេគិតសម្រេចចិត្តស្រេចបាច់ដូច្នេះហើយ ទើបគិតលះបង់ជីវិតរបស់ខ្លួន ដើម្បីថ្វាយដល់ព្រះមុនី ហើយគេគិតថា យើងមានចិត្តជ្រះថ្លាមិនប្រែត្រឡប់ទៅដរាបណា យើង

ន៏ងធ្វើការបូជានៅដរាបនោះ ហើយគេថែមទាំងមានសេចក្តីរីករាយត្រេកអរក្នុងចិត្ត រួចក៏បានបូជាព្រះមហាវីរៈដោយផ្កាម្ទិះទាំងនោះ ។

មានពាក្យសួរថា នាយសុមនមាលាការបានបូជាព្រះមហាមុនីដូចម្តេច ? មានពាក្យឆ្លើយថា នាយសុមនមាលាការបានបូជាព្រះមុនីយ៉ាងនេះ គឺមុនដំបូងគេបានបាចផ្កាម្ទិះ ២ ក្តាប់ឡើងទៅលើព្រះភគវា ហើយផ្កាម្ទិះពីរក្តាប់នោះ បានឡើងទៅជាំងជាពិតាននៅពីខាងលើព្រះសីសៈ ។ គ្រាទី ២ គេបានបាចផ្កាម្ទិះឡើងទៅពីរក្តាប់ទៀត ហើយផ្កាម្ទិះពីរក្តាប់នោះ បានអណ្តែតទៅត្រជាងការពារផ្នែកខាងស្តាំ ដោយមានអាការដូចក្រឡាសំណាញ់ផ្កាមកបិទជុំង ។ គ្រាទី ៣ គេបានបាចផ្កាម្ទិះពីរក្តាប់ទៅទៀត ហើយផ្កាម្ទិះពីរក្តាប់នោះ បានរសាត់ចុះមកត្រជាងការពារផ្នែកខាងព្រះបិដ្ឋិ (ខ្នង) ដូចគ្រាទី ២ ដែរ ។ គ្រាទី ៤ គេបានបាចផ្កាម្ទិះពីរក្តាបទៅទៀត ហើយផ្កាម្ទិះពីរក្តាប់នោះ បានរសាត់ចុះមកត្រជាងការពារនៅខាងឆ្វេង ដោយមានលក្ខណៈដូចលើកទី ២ និងទី ៣ នោះដែរ ។ ផ្កាម្ទិះ ៨ នាឡិនោះ បានជាផ្កាប្រមាណ ៨ ក្តាប់ ទាំងហែហមព្រះភគវា

ក្នុងទីទាំងពួង ។ ផ្កាម្ជិះទាំងនោះ បានបត់ទងចូលទៅខាងក្នុង បានលាតត្របកចេញមកខាងក្រៅ ។ព្រះសម្ពុទ្ធ ប្រៀបដូចជាពន្ធដោយផែនច្រាក់យាងទៅ ។ ផ្កាម្ជិះទាំងអស់នោះ សូម្បីមិនមានចិត្ត តែព្រោះអាស្រ័យបុគ្គលអ្នកមានចិត្ត ក៏មិនបែកខ្វែកអំពីគ្នា ទាំងមិនជ្រុះចុះ បានអណ្តែតទៅតាមព្រះសម្ពុទ្ធ ហើយបានឈប់នៅក្នុងពេលដែលព្រះលោកនាថទ្រង់ប្រថាប់ឈរ ។ព្រះរស្មីទាំងឡាយ ប្រៀបដូចជាផ្សែកបន្ទោរ រាប់សែនផ្សាយចេញអំពីព្រះវរកាយរបស់ព្រះសាស្តា ហើយព្រះរស្មីបានផ្សាយចេញទៅ ទាំងខាងមុខ ទាំងខាងក្រោយ ទាំងខាងឆ្វេង ទាំងខាងស្តាំ និងខាងលើព្រះសីសៈ ។

ម្យ៉ាងព្រះរស្មីសូម្បីតែមួយខ្សែ ក៏មិនផ្សាយទៅត្រង់ បានធ្វើទក្ខិណាវដ្ត គឺវិលមកខាងស្តាំជុំវិញព្រះមហាវីរៈ ៣ ជុំហើយ ទើបរួមជាព្រះរស្មី មានប្រមាណប៉ុនដើមត្នោត ហើយផ្សាយត្រង់ទៅខាងមុខ ។ អ្នកក្រុងទាំងអស់នាំគ្នាភ្ញាក់ផ្អើលល្បីតៗ ទៅ ។ បណ្តាជន ១៨ កោដិ គឺជនដែលនៅក្នុងក្រុង ៩ កោដិ និងជនដែលនៅខាងក្រៅក្រុង ៩ កោដិ

ប្រុស ឬស្រីសូម្បីត្រឹមតែម្នាក់ ដែលមិនបានយកអាហារ ចេញទៅមិនមានឡើយ ។ មហាជនបានបន្ទឺសំឡេងខ្ទាំងគឹកកង បានលើកទង់សំពត់ឡើងមួយម៉ឺនផ្ទាំង នៅខាងមុខព្រះមហាមុនី ។ចំណែកព្រះភគវា កាលទ្រង់ធ្វើគុណរបស់នាយសុមនមាលាការឲ្យប្រាកដ ទ្រង់បានយាងចារិកទៅក្នុងព្រះនគរ តាមផ្លូវដែលមានមនុស្សជាច្រើន ដែលវាយស្គរបង្កឹកប្រកាស ដែលមានចម្ងាយប្រមាណ ៣ គាវុត ។ រាងកាយរបស់នាយសុមនមាលាការ បានពោរពេញទៅដោយបីតិយ៉ាងខ្ទាំងក្លា ។ នាយសុមនមាលាការ បានទៅជាមួយព្រះលោកនាយកបន្តិចប៉ុណ្ណោះ គេក៏ចូលទៅខាងក្នុងព្រះពុទ្ធរស្មី ប្រៀបដូចបុគ្គលមុជចុះទៅក្នុងទឹកមនោសិលា គេបានពោលសរសើរព្រះភគវា ហើយក្រាបថ្វាយបង្គំលា ហើយបានកាន់កន្ត្រកទទេ ដើរត្រឡប់ទៅឯផ្ទះរបស់ខ្លួនវិញ ។ គ្រានោះ ភរិយាគេបានសួរនាយសុមនមាលាការថា ផ្កានៅឯណាបង ? នាយសុមនមាលាការតបថា ខ្ញុំបានបូជាព្រះជិនស្រីអស់ហើយ ។ ភរិយាទើបសួរទៀតថា ឥឡូវនេះ បងត្រូវធ្វើយ៉ាងណា ចំពោះព្រះរាជា ?

នាយសុមនមាលាការធ្វើយថា បើព្រះរាជាទ្រង់សម្ងាប់ ឬនិរទេសក៏ដោយ ខ្ញុំបានលះបង់ជីវិតបូជាព្រះទសពលហើយ ផ្កាទាំងអស់មាន ៨ ក្តាប់ ការបូជាបានកើតហេតុយ៉ាងនោះៗ មានមហាជនស្រែកឲ្យពរ តាមយាងព្រះកគរាទៅ ន៎ុះសំឡេងហ៊ោរបស់មហាជននៅក្នុងទីនោះៗ ។ ចំណែកភរិយារបស់នាយសុមនមាលាការ ជាស្រីអន្ធពាល (ល្ងង់ដូចជាមនុស្សខ្វាក់ភ្នែក) មិនកើតមានសេចក្តីជ្រះថ្លាក្នុងបាដិហារិយ៍នោះដូច្នោះឡើយ នាងក៏បានជេរគេហើយ ធម្មតាព្រះរាជាទាំងឡាយ ជាបុគ្គលយោរយៅ កាលទ្រង់ក្រោធត្រឹមតែម្តង ក៏ធ្វើសេចក្តីវិនាសបានច្រើន ដោយការទ្រង់ឲ្យគេកាត់ដៃ កាត់ជើងជាដើម ការវិនាសនឹងត្រូវមានដល់ខ្ញុំ ព្រោះតែការធ្វើរបស់អ្នកៗនាងជេរថាដូច្នោះហើយ ទើបនាំពួកកូនៗ ចូលទៅគាល់ព្រះរាជា ។

ព្រះរាជាត្រាស់សួរថា មានរឿងអ្វីឬ ? ទើបនាងក្រាបបង្គំទូលថា ព្រះពរម្ចាស់ ស្វាមីរបស់ខ្ញុំម្ចាស់ បាននាំយកផ្កាសម្រាប់ថ្វាយព្រះអង្គទៅបូជាព្រះទសពលហើយ គេត្រឡប់មកផ្ទះដោយមិនមានផ្កា ខ្ញុំម្ចាស់

សួរគេថា ផ្កានៅឯណា គេឆ្លើយថា ផ្កាខ្ញុំបានបូជាព្រះសយម្ភូអស់ហើយ ខ្ញុំម្ចាស់ជេរគេហើយ ទើបពោលថា ធម្មតាព្រះរាជាទាំងឡាយ ជាបុគ្គលកាច ទ្រង់ក្រោធត្រឹមតែម្តង ក៏ធ្វើសេចក្តីវិនាស ដោយការឲ្យកាត់ដៃកាត់ជើងជាដើម ការវិនាសនឹងត្រូវមានដល់ខ្ញុំ ព្រោះតែការធ្វើរបស់អ្នកដូច្នោះហើយ ក៏លែងគេមកក្នុងទីនេះ វត្ថុដែលគេធ្វើហើយ នឹងជាកម្មល្អ ឬកម្មអាក្រក់ក៏ដោយ សូមកម្មនោះ ចូរជារបស់គេតែម្នាក់ចុះ សូមទ្រង់បានជ្រាបថា ខ្ញុំម្ចាស់បានលែងលះគេហើយ ក្រាបទូល ។ គ្រានោះ ព្រះបាទពិម្ពិសារ ដែលទ្រង់ជាព្រះអរិយបុគ្គល ដោយការឃើញព្រះភគវាក្នុងគ្រាជំបូង ទ្រង់ជាអ្នកសម្បុរទៅដោយសទ្ធា ទ្រង់ព្រះតម្រិះថា ឱ ! ស្រីនេះ ជាស្រីអន្ធពាល មិនកើតមានសេចក្តីជ្រះថ្លាក្នុងគុណដូចនេះ ហើយព្រះអង្គទ្រង់ធ្វើបែរជាខឹង គ្រាស់ថា នាងថានាយសុមន-មាលាការ បានយកផ្កាសម្រាប់មកថ្វាយយើង បូជាដល់ព្រះសាស្តាមែនឬ ? ស្រីនោះក្រាបបង្គំទូលថា ព្រះពរម្ចាស់ ព្រះអង្គ ។ ទើបព្រះបាទពិម្ពិសារគ្រាស់ថា នាងលែងគេជាការល្អហើយ យើងនឹងដឹងដល់

វត្ថុដែលគួរធ្វើជល់នាយសុមនមាលាការ ដែលធ្វើការបូជាដោយផ្ការទាំងឡាយរបស់យើង លុះព្រះអង្គត្រាស់ដូច្នេះហើយ ទើបបញ្ជាឲ្យកែរិយារបស់នាយសុមនមាលាការនោះ ត្រឡប់ទៅវិញ ។ ចំណែកព្រះអង្គប្រញាប់យាងទៅគាល់ព្រះលោកនាថ ទ្រង់ថ្វាយបង្គំហើយ យាងទៅជាមួយព្រះបរមគ្រូ ។ គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបជល់ព្រះទ័យរបស់ព្រះរាជា ដែលទ្រង់មានសេចក្តីជ្រះថ្លា ទើបទ្រង់ចារិកទៅកាន់ព្រះនគរតាមផ្លូវដែលមនុស្សទាំងឡាយ បាននាំគ្នាវាយស្គរបង្ហិកប្រកាសហើយ បានយាងទៅជល់ទ្វារព្រះរាជវាំង របស់ព្រះបាទពិម្ពិសារបរមក្សត្រ ។ ព្រះបាទពិម្ពិសារ ទ្រង់ទទួលបាត្រ ដោយមានព្រះរាជបំណងនឹងទ្រង់អារាធនាព្រះជិនវរ ឲ្យយាងចូលទៅក្នុងព្រះរាជវាំង ។ ចំណែកព្រះមុនីបានសម្តែងព្រះអាការ ដែលនឹងប្រថាប់គង់ក្នុងទីលាននៃព្រះរាជវាំងនោះឯង ។ ពេលនោះ ព្រះបាទពិម្ពិសារ ទ្រង់ជ្រាបព្រះអាការនោះហើយ ទើបបញ្ជាឲ្យធ្វើបាវំឡើងក្នុងខណៈនោះឯង ដោយមានព្រះរាជតម្រាស់បញ្ជាថា អ្នកទាំងឡាយចូរធ្វើបាវំឲ្យបានធាប់រហ័ស ។ ព្រះសម្មាសម្ពុទ្ធ

ក៏ប្រថាប់គង់ជាមួយពួកភិក្ខុសង្ឃនៅខាងក្នុងបារាំ ដែលសាងឡើងនោះឯង ។ មានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះភគវា ទ្រង់មិនចូលទៅខាងក្នុងព្រះរាជវាំង ? មានពាក្យឆ្លើយថា ព្រោះព្រះលោកនាយក ទ្រង់ព្រះតម្រិះថា ប្រសិនបើតថាគតចូលទៅគង់ខាងក្នុងព្រះរាជវាំង មហាជនក៏មិនបានឃើញតថាគត គុណាគឺសេចក្តីល្អរបស់នាយសុមនមាលាការក៏នឹងមិនប្រាកដឡើង តែកាលតថាគតគង់នៅត្រង់ទីលាននៃព្រះរាជវាំង មហាជនក៏បានឃើញតថាគត គុណ គឺសេចក្តីល្អរបស់នាយសុមន-មាលាការ ក៏នឹងប្រាកដ ។

ពិតណាស់ ព្រះពុទ្ធទាំងឡាយ ទ្រង់អាចធ្វើគុណ គឺសេចក្តីល្អរបស់បុគ្គល ដែលមានគុណធម៌ទាំងឡាយឲ្យប្រាកដ ។ សាមញ្ញជនជនៃៗ កាលនឹងពោលដល់គុណរបស់បុគ្គលអ្នកមានគុណធម៌ទាំងឡាយរមែងបិទបាំងគុណ គឺសេចក្តីល្អរបស់អ្នកជនៃ ។ រនាំងផ្ការាំង ៤ ផ្ទាំងបានតាំងនៅក្នុងទិសទាំង ៤ មហាជនបាននាំគ្នាហែហមព្រះមហាវីរៈទៅជាច្រើន ។ ព្រះបាទពិម្ពិសារ ទ្រង់អង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធ

ជាប្រធាន ដោយព្រះក្រយាហារដ៏ប្រណីត ។ ក្នុងពេលដែលព្រះមុនី
សោយភត្តាហារស្រេចហើយ ទើបទ្រង់ធ្វើការអនុមោទនាហើយ កំផែងផ្ការ
ទាំង ៤ ផ្ទាំង បានមកហែហមដូចពីមុនទៀត ហើយមានមហាជនបន្ទឹ
សំឡេងគឹកកងហែហម ព្រះអង្គក៏យាងទៅកាន់ព្រះវិហារវិញ ។ ព្រះបាទ
ពិម្ពិសារទ្រង់ជូនដំណើរព្រះលោកនាថហើយ ទើបទ្រង់ត្រឡប់មកវិញ
ថែមទាំងត្រាស់បញ្ជាឲ្យនាយសុមនមាលាការ ចូលមកគាល់ព្រះរាជា
បានត្រាស់សួរថា អ្នកគិតដូចម្តេច ទើបបានជាបូជាព្រះគគរាដោយផ្ការ
ដែលអ្នកនាំមកឲ្យយើង ? គ្រានោះ នាយសុមនមាលាការក្រាបបង្គំ
ទូលថា ករុណាថ្លៃវិសេស ទូលបង្គំគិតថា ព្រះរាជាសម្ងាប់ ឬនិរទេស
យើងក៏ដោយ ដូច្នេះហើយ ទើបគិតលះបង់ជីវិតបូជាព្រះមានជោគ
ក្រាបទូល ។ លំដាប់នោះ ទើបព្រះបាទពិម្ពិសារ ត្រាស់សរសើរថា
អ្នកឈ្មោះថា ជាមហាបុរស ហើយព្រះរាជាបានព្រះរាជទានរបស់មួយ
មុខៗ ៨ គឺដំរី ៨ សេះ ៨ ខ្ញុំប្រុស ៨ នាក់ ខ្ញុំស្រី ៨ នាក់ គ្រឿង
អលង្ការ ៨ សម្រាប់ ជ្រាក់ ៨ ពាន់កហាបណៈ នារី ៨ នាក់ ដែល

សុទ្ធតែនាំមកអំពីរាជត្រកូល ទាំងប្រជាប់ដោយគ្រឿងអលង្ការជាច្រើន ព្រមទាំងដោយស្រុកសួយ ៨ ទៀតផង ។

ចំណែកព្រះអានន្ទ គិតថា ថ្ងៃនេះតាំងអំពីព្រលឹមមក មានមហាជនបានបន្ទឹសីហនាទទាំងពាន់ៗ មានការលើកទង់ជ្ងាលាជាច្រើន នាយសុមនមាលាការនឹងបានទទួលផលយ៉ាងណាហ្ន៎ ហើយព្រះថេរៈទើបក្រាបទូលសួរព្រះមានជោគ ។ គ្រានោះ ព្រះជិនស្រីត្រាស់តបនឹងព្រះថេរៈថា អានន្ទ អ្នកកុំកំណត់ថា នាយសុមនមាលាការបានធ្វើកម្មត្រឹមតែបន្តិចបន្តួច តែព្រោះគេបានលះបង់ជីវិតធ្វើការបូជាតថាគត គេបានមានចិត្តជ្រះថ្លាជាមួយតថាគតយ៉ាងនេះ គេនឹងមិនទៅកាន់ទុគ្គតិអស់មួយសែនកប្ប កាលព្រះវិជិតមារត្រាស់ដូច្នេះហើយ ទើបត្រាស់តទៅទៀតថា នាយសុមនមាលាការតាំងនៅតែក្នុងទេវតា និងមនុស្ស ប៉ុណ្ណោះ នឹងមិនទៅកាន់ទុគ្គតិរហូតអស់មួយសែនកប្ប នេះជាផលនៃកម្មនោះ កាលជាអនាគតគេនឹងបានជាព្រះបច្ចេកពុទ្ធ នាមថា **សុមននិស្សរ** ។ ក្នុងពេលដែលព្រះសក្យមុនី ស្តេចយាងទៅដល់ព្រះវិហារ ទ្រង់ចូលទៅ

ក្នុងព្រះគន្ធកុដិ រនាំងផ្ការាំងនោះ ក៏ជ្រាក់ចុះនៅត្រង់មាត់ទ្វារៗលុះដល់វេលាល្ងាច ភិក្ខុទាំងឡាយបានសន្ទនាគ្នា នៅក្នុងសាលាធម្មសភាថា ឃើ! អំពើរបស់នាយសុមនមាលាការ គួរឲ្យអស្ចារ្យណាស់គេលះបង់ជីវិតថ្វាយព្រះភគវា ដែលទ្រង់គង់ធរមាននៅ ការធ្វើការបូជាដោយផ្ការហើយគេបានទទួលព្រះរាជទានវត្ថុមួយមុខៗ ចំនួន ៨ ក្នុងមួយរំពេចនោះឯងព្រះភគវាទ្រង់ចេញអំពីព្រះគន្ធកុដិ ហើយយាងទៅកាន់សាលាធម្មសភាបានត្រាស់សួរភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកសន្ទនាគ្នាអំពីរឿងអ្វី ? ភិក្ខុទាំងនោះក្រាបទូលឲ្យព្រះអង្គជ្រាបហើយ ព្រះភគវាទើបត្រាស់ថា ត្រូវហើយភិក្ខុទាំងឡាយ ការមិនក្តៅក្រហាយក្នុងចិត្តជាខាងក្រោយ រមែងមិនមានព្រោះកម្មណា ការរីករាយរមែងកើតឡើងក្នុងខណៈដែលរឭកដល់ហើយ ព្រោះធ្វើកម្មណា បុគ្គលគួរធ្វើកម្មបែបនោះ កាលព្រះអង្គទ្រង់សម្តែងព្រះធម៌បន្តសេចក្តីទៀត ទើបទ្រង់ត្រាស់ព្រះគាថាពន្ធនេះថា

បុគ្គលធ្វើកម្មណាហើយ មិនក្តៅក្រហាយចិត្តក្នុងកាលជាខាង

ក្រោយ ជាអ្នកមានបីតិ មានចិត្តល្អ បានសោយផលរបស់កម្មណា កម្មនោះឯង ដែលបុគ្គលគួរធ្វើ ព្រោះជាកម្មល្អ ។

ពេលដែលព្រះសាស្តា ទ្រង់ត្រាស់ទេសនានេះចប់ មានមហាជនជាច្រើនប្រមាណ ៨៤០០០ នាក់ បានសម្រេចធម៌ទៅតាមវាសនាបារមីរៀងៗ ខ្លួន ដែលធ្លាប់បានសន្សំមកហើយ ក្នុងអតីតជាតិ ក៏ជាហេតុជាបច្ច័យ ធ្វើឲ្យមហាជនទាំងនោះ បានសម្លឹងឃើញសាសនព្រហ្មចរិយ-ធម៌នេះ ដែលជាការប្រព្រឹត្តទៅមិនធ្វើឲ្យមានជាតិកំណើតតទៅទៀតដូច្នេះហើយ ទើបធ្វើឲ្យពួកគេតាំងចិត្តស្តាប់ព្រះធម៌ដោយគោរព ដោយការបញ្ជូនចិត្តទៅតាមក្រសែនៃព្រះធម៌ ទើបធ្វើឲ្យចិត្តនៃបុគ្គលទាំងនោះបានទទួលនូវសម្ផស្សនៃព្រះធម៌ ហើយបញ្ញាញាណក៏បានកើតឡើងដល់ពួកគេរៀងៗ ខ្លួនទៅ ដូចបានរៀបរាប់មកហើយ ។

(ជីវប្រវត្តិរបស់នាយសុមនមាលាការឧបាសក ចប់)

✍ ជីវប្រវត្តិរបស់បញ្ចគ្គទាយកឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

បញ្ចគ្គទាយកព្រាហ្មណ៍ ជាឧបាសក មានគតិប្រចាំខ្លួនរបស់លោកម្ប៉ាង គឺប្រសិនបើមិនបានឲ្យទានដល់បដិគ្គាហក: ដែលមកដល់ផ្ទះរបស់លោកៗ នឹងមិនបរិភោគអាហារ ហើយលោកបានជាឧបាសកដែលបានសម្រេចអរិយធម៌ ជាព្រះអនាគាមិបុគ្គល ។

ជីវប្រវត្តិរបស់បញ្ចគ្គទាយកព្រាហ្មណ៍ មានសម្តែងទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **កិកុវគ្គ** ដូចមានសេចក្តីថា ៖

ក្នុងសម័យកាលព្រះមានព្រះភាគ ប្រថាប់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី បានត្រាស់ព្រះធម្មទេសនា ដោយទ្រង់ប្រារព្ធព្រាហ្មណ៍ឈ្មោះ **បញ្ចគ្គទាយក** ឲ្យជាដើមហេតុ ។ ដូចមានរឿងពោលទុកថា បញ្ចគ្គទាយកព្រាហ្មណ៍ បានថ្វាយទានដ៏លើស ៥ យ៉ាងដូច្នេះ គឺ ១- បានថ្វាយទានឈ្មោះ **ខេត្តគ្គ** គឺទានដ៏លើសក្នុងស្រែ បានដល់ ពេល

ដែលខ្ជិតច្រូតស្រូវក្នុងស្រែស្រេចហើយ ២- បានថ្វាយទានឈ្មោះ **ខលគ្គ** គឺទានដ៏លើសក្នុងលាន បានដល់ ពេលដែលគេដឹកស្រូវចូលលាន ៣- បានថ្វាយទាន **ខលកណ្ឌគ្គ** គឺទានដ៏លើសក្នុងគ្រាបោកបែន បានដល់ ពេលដែលគេបោកបែនស្រូវ ៤- បានថ្វាយទានឈ្មោះ **ខកខលិកគ្គ** គឺទានដ៏លើសក្នុងគ្រាចាក់អង្ករចូលទៅក្នុងឆ្នាំងបាយ បានដល់ ពេលដែលគេនាំយកអង្ករដាក់ចុះទៅក្នុងឆ្នាំង ដើម្បីដាំបាយ ៥- បានថ្វាយទានឈ្មោះ **បាដិគ្គ** គឺទានដ៏លើសក្នុងគ្រាដួសបាយដាក់ក្នុងកាជនៈ បានដល់ ពេលដែលគេដួសបាយចេញអំពីឆ្នាំងដាក់ក្នុងកាជនៈ ។ បញ្ចគ្គទាយកព្រាហ្មណ៍ បើមិនទាន់បានឲ្យទានដល់សមណព្រាហ្មណ៍ ឬស្ងួមយាចកដែលមកដល់ផ្ទះរបស់ខ្លួន ក៏មិនព្រមបរិភោគអាហារ ។ ព្រោះដូច្នោះ ទើបគេមានឈ្មោះថា **បញ្ចគ្គទាយក** ប្រែថា អ្នកឲ្យទានដ៏លើស ៥ យ៉ាង ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់យើញឧបនិស្ស័យ ដែលបញ្ចគ្គទាយក-ព្រាហ្មណ៍ និងនាងព្រាហ្មណីដែលជាភរិយារបស់គេ បានសម្រេចអរិយផលលំដាប់ទី ៣ ទើបព្រះអង្គយាងទៅប្រថាប់ឈរនៅត្រង់មុខ

ទ្វារផ្ទះ ក្នុងពេលដែលបញ្ចគ្គទាយកព្រាហ្មណ៍កំពុងបរិភោគអាហារ ។ ចំណែកបញ្ចគ្គទាយកព្រាហ្មណ៍ បានអង្គុយទទួលទានអាហារនៅចំមុខទ្វារផ្ទះ តែគេអង្គុយបែរមុខចូលទៅក្នុងផ្ទះ ទើបមិនឃើញព្រះសម្ពុទ្ធប្រថាប់ឈរនៅត្រង់មុខទ្វារផ្ទះរបស់ខ្លួន ។ រីឯនាងព្រាហ្មណី កំពុងតែចាត់ចែងអាហារឲ្យដល់បញ្ចគ្គទាយកព្រាហ្មណ៍ គេបានក្រឡេកឃើញព្រះភគវា ទើបគិតថា ព្រាហ្មណ៍ដែលជាស្វាមីរបស់យើង បានឲ្យទានជាមុនហើយ ទើបទទួលទានអាហារ តែឥឡូវនេះ ព្រះសមណាគោតមយាងមកប្រថាប់ឈរនៅត្រង់មុខទ្វារផ្ទះ ប្រសិនបើព្រាហ្មណ៍ដែលជាស្វាមីរបស់យើង បានក្រឡេកឃើញព្រះសមណាគោតមនោះហើយ មុខជានឹងយកអាហាររបស់ខ្លួន ទៅថ្វាយដល់ព្រះគោតមមិនខាន យើងមិនអាចចម្អិនឲ្យគេថ្មីម្តងទៀតបានទេ ។ ហើយនាងព្រាហ្មណីគិតតទៅទៀតថា ព្រាហ្មណ៍ដែលជាស្វាមីរបស់យើង មិនឃើញព្រះសមណាគោតមដោយអាការយ៉ាងនេះ ហើយទើបនាងទៅឈរបែរខ្នងឲ្យព្រះលោកនាយក ដោយឈរបាំងព្រះមហាវីរៈទុកនៅខាងក្រោយបញ្ចគ្គ-

ទាយកព្រាហ្មណ៍ ដូចប្រើបាតដៃបាំងព្រះចន្ទពេញបូណ៌មី ដូច្នោះ ។ ហើយនាងព្រាហ្មណីឈរនៅយ៉ាងនោះ ថែមទាំងប្រើកន្ទុយភ្នែកឆ្លៀងមើលព្រះមុនី ដោយគិតថា ព្រះមហាវីរបុរសយាងទៅហើយឬនៅ ។ ព្រះមានបុណ្យ នៅគង់ប្រថាប់ឈរក្នុងកន្លែងដើមនោះឯង ។ ចំណែកនាងព្រាហ្មណីមិនព្រមនិយាយខ្លាំងៗ ថា សូមនិមន្តយាងទៅប្រោសសត្វខាងមុខចុះ ព្រោះនាងខ្លាចបញ្ហគ្គទាយកព្រាហ្មណ៍ដែលជាស្វាមីរបស់នាងឮ តែនាងដើរសេសៀតិចៗ ថយចេញទៅជិតព្រះមានជោគហើយទូលតិចៗ ថា សូមអារាធនាយាងទៅប្រោសសត្វខាងមុខចុះ ព្រះអង្គ ។ ព្រះមានជោគ ទ្រង់ស្តាប់ពាក្យក្រាបទូលអារាធនារបស់នាងព្រាហ្មណីហើយ ទ្រង់សម្តែងព្រះអាការគ្រវីព្រះសីស:ថា តថាគតមិនទៅទេ ។ កាលព្រះវិជិតមារទ្រង់ជាទីគោរពរបស់សត្វលោក ទ្រង់សម្តែងអាការគ្រវីព្រះសីស:ថា តថាគតមិនទៅទេ នាងព្រាហ្មណីមិនអាចអត់ទ្រាំបាន នាងក៏បានសើចយ៉ាងខ្លាំងៗ ។

ខណៈនោះ ព្រះសក្យមុនី ទ្រង់បញ្ចេញព្រះស្មីចូលទៅក្នុងផ្ទះ

របស់ព្រាហ្មណ៍ ។ ចំណែកបញ្ចគ្គទាយកព្រាហ្មណ៍ សូម្បីអង្គុយបែរខ្នងឲ្យព្រះសាស្តា បានឮសំឡេងសើចរបស់នាងព្រាហ្មណី ដែលជាភរិយានិងបានឃើញពន្លឺនៃព្រះរស្មីទាំង ៦ ប្រការនោះហើយ តអំពីនោះទើបព្រាហ្មណ៍ បានក្រឡេកឃើញព្រះទសពលប្រថាប់ឈរ នៅត្រង់មុខទ្វារផ្ទះរបស់ខ្លួន ។ ពិតណាស់ ព្រះពុទ្ធទាំងឡាយ បើមិនទាន់បង្ហាញខ្លួនឲ្យប្រាកដ (ឲ្យឃើញ) ដល់បុគ្គលទាំងឡាយ ដែលដល់ព្រមដោយហេតុ គឺវាសនាបារមី នៅក្នុងស្រុក ឬនៅក្នុងព្រៃជាមុននោះទេ ទ្រង់នឹងមិនយាងចៀសចេញទៅឡើយ ។ បញ្ចគ្គទាយកព្រាហ្មណ៍ កាលបានឃើញព្រះលោកនាថហើយ ទើបនិយាយជាមួយនឹងនាងព្រាហ្មណីដែលជាភរិយាថា នាងដ៏ចម្រើន នាងបានឃើញព្រះមានព្រះភាគយាងមកប្រថាប់ឈរនៅត្រង់មុខទ្វារផ្ទះហើយ ម្តេចមិនព្រមប្រាប់ដល់យើងនាងធ្វើឲ្យយើងវិនាសហើយ នាងបានធ្វើកម្មធ្ងន់ កាលព្រាហ្មណ៍ពោលដូច្នេះហើយ ព្រាហ្មណ៍ដែលជាស្វាមី ទើបកាន់យកភាជនៈអាហារដែលខ្លួនទទួលទានហើយបានពាក់កណ្តាល តម្រង់យកទៅប្រគេន

ព្រះកគវា ហើយក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះករុណា
បានថ្វាយទានជាមុនហើយ ទើបបរិភោគអាហារជាខាងក្រោយ តែអាហារ
មានតែមួយចំណែកប៉ុណ្ណោះ ដោយខ្ញុំព្រះករុណាបានបែងពាក់កណ្តាល
អំពីអាហារចំណែកនេះ បរិភោគមុនរួចហើយ ចំណែកអាហារដែល
នៅសល់ពាក់កណ្តាលនេះ សូមព្រះអង្គមេត្តាទទួលអាហារចំណែកនេះ
របស់ខ្ញុំព្រះករុណាចុះ ព្រះអង្គ ។ គ្រានោះ ព្រះសាស្តាមិនបានត្រាស់
បដិសេធថា តថាគតមិនត្រូវការអាហារ ដែលជាសំណល់របស់អ្នក
តែព្រះអង្គបែរជាត្រាស់ថា ម្នាលព្រាហ្មណ៍ អាហារដ៏លើសដ៏ដោយ
អាហារដែលបុគ្គលបរិភោគពាក់កណ្តាលហើយក៏ដោយ ជាអាហារដែល
សមគួរដល់តថាគត ឬដោយហោចទៅ សូម្បីអាហារដែលជាសំណល់
ក៏ដោយ ក៏ជាអាហារដែលសមគួរដល់តថាគតដូចគ្នា ព្រោះតថាគត
ជាអ្នកចិញ្ចឹមជីវិតដោយអាស្រ័យអាហារ ដែលអ្នកជនៃចម្ការឲ្យ ដែល
មានសភាពជាអ្នករស់នៅជួចនឹងពួកប្រេតហើយ ទើបព្រះពុទ្ធអង្គត្រាស់
ប្រពន្ធគាថានេះថា

កិក្ខុចិញ្ចឹមជីវិតដោយអាស្រ័យអាហារ ដែលអ្នកដទៃឲ្យ បានអាហារណា អំពីចំណែកដ៏លើសក្តី អំពីចំណែកជាកណ្តាលក្តី ឬអំពីចំណែកដែលសល់ក្តី កិក្ខុនោះមិនគួរសរសើរអាហារនោះ និងមិនគួរបង្អាប់អាហារនោះ ហើយទំពាស៊ីអាហារនោះ ជីវជនទាំងឡាយរមែងសរសើរកិក្ខុនោះថា ជាមុនី ។

បញ្ចគ្គទាយកព្រាហ្មណ៍ លុះបានស្តាប់ប្រពន្ធគាថានេះចប់ហើយ ក៏ជាអ្នកមានចិត្តជ្រះថ្លាគិតឡើងថា ឱ! គួរឲ្យអស្ចារ្យណាស់ ព្រះសាស្តា ដែលទ្រទ្រង់នូវឈ្មោះថា ជាម្ចាស់នៃដួងប្រទីប មិនបានត្រាស់បដិសេធថា តថាគតមិនត្រូវការអាហារ ដែលជាសំណល់របស់អ្នក តែបែរជាត្រាស់យ៉ាងនេះ ។ គ្រានោះ ព្រាហ្មណ៍គិតដូច្នោះហើយ បានឈរនៅត្រង់ទ្វារនោះឯង ទូលសួរបញ្ហាព្រះសុគតថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គត្រាស់ហៅពួកសាវ័ករបស់ព្រះអង្គថា កិក្ខុ ចុះបុគ្គលដែលឈ្មោះថា កិក្ខុ ដោយហេតុត្រឹមប៉ុនណា ព្រះអង្គ ? លំដាប់នោះ ព្រះមុនីទ្រង់ពិចារណាមើលថា ធម្មទេសនាដូចម្តេចហ្ន៎ ទើបជាទីសប្បាយដល់ព្រាហ្មណ៍នេះ

ក៏ទ្រង់ជ្រាបបានថា ក្នុងពុទ្ធសម័យរបស់ព្រះកស្សបសម្ពុទ្ធ ជនទាំងពីរនាក់នេះ ធ្លាប់បានស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយ ដែលពោលថា នាមរូប តថាគតគួរសម្តែងធម៌ដល់ជនទាំងពីរនាក់នេះ ដែលមិនព្រមលះនាមរូបនោះ ហើយទើបព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលដែលមិនមានតម្រេក មិនជាប់ជំពាក់ក្នុងនាមរូប ឈ្មោះថា ជាភិក្ខុ ហើយបានត្រាស់ប្រពន្ធគាថានេះថា

បុគ្គលណា មិនមានការប្រកាន់មាំក្នុងនាមរូបថា ជារបស់អញ ដោយប្រការទាំងពួង និងរមែងមិនសោយសោក ព្រោះនាមរូបនោះមិនមាន បុគ្គលនោះឯង តថាគតហៅថា ជាភិក្ខុ ។

ម្យ៉ាងទៀត ព្រះអដ្ឋកថាចារ្យ បានអធិប្បាយសេចក្តីនៃប្រពន្ធគាថានេះ របស់ព្រះសាស្តាទុកថា នាមរូបទាំងមូល ដែលកើតដោយអំណាចនៃខន្ធ ៥ បានដល់ នាមក្ខន្ធ មាន ៤គឺវេទនា សញ្ញា សង្ខារ វិញ្ញាណ និងរូប បានដល់ រូបក្ខន្ធ ។បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាមរូបថា ជារបស់យើង គឺកាលនាមរូបដល់នូវការអស់ទៅ

សូន្យទៅហើយ មិនមានសេចក្តីសោយសោក គឺមិនក្តៅក្រហាយថា រូបរបស់យើងអស់ទៅហើយ នាម បានដល់ វេទនា សញ្ញា សង្ខារ វិញ្ញាណរបស់យើងវិនាសទៅអស់ហើយ ដោយមានអាការយើញទៅតាមសេចក្តីពិតថា នាមរូបនេះ មានការអស់ទៅ សូន្យទៅ ជាធម្មតា ក៏បានអស់ទៅហើយ ។ បុគ្គលនោះ គឺបុគ្គលដែលមិនមានសេចក្តីប្រកាន់នូវនាមរូបដែលមាននៅថា ជារបស់យើងក្តី មិនមានសេចក្តីសោយសោក ព្រោះនាមរូបនោះ ដែលមិនមាននៅក្តី ព្រះជិនវរត្រាស់ហៅថា ជាភិក្ខុ ។ ក្នុងពេលដែលព្រះសម្ពុទ្ធត្រាស់ទេសនានេះចប់ហើយ បញ្ចគ្គទាយក-ព្រាហ្មណ៍ និងនាងព្រាហ្មណីទាំងពីរនាក់នោះ ក៏បានសម្រេចអរិយធម៌លំដាប់ទី ៣ គឺតាំងនៅក្នុងព្រះអនាគាមិផល ធម្មទេសនារបស់ព្រះសម្ពុទ្ធក្នុងគ្រានោះ បានជាប្រយោជន៍ដល់មហាជនជាច្រើន ដែលមកប្រជុំគ្នាក្នុងទីនោះដែរ ។

(ជីវប្រវត្តិរបស់បញ្ចគ្គទាយកឧបាសក ចប់)

✍ ជីវប្រវត្តិរបស់បិង្គលកោច្ឆឧបាសក ✍

“ ជាឧបាសកមួយរូបដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

បិង្គលកោច្ឆៈ ជាឧបាសក ដែលចូលមកកាន់ព្រះពុទ្ធសាសនា ដោយការនាំយកបញ្ហាចូលមកក្រាបទូលសួរព្រះមានព្រះភាគថា អ្វីជាខ្វីមសារក្នុងព្រះពុទ្ធសាសនា ទើបជាហេតុឲ្យព្រះពុទ្ធអង្គ ទ្រង់ទេសនា ដែលជាខ្វីមសារឲ្យគេបានជ្រាប ។

មុនដំបូងសូមពោលទាក់ទងនឹងរឿងឈ្មោះ របស់ឧបាសកនេះ ដែលមានសម្តែងនៅក្នុង ***អដ្ឋកថាបបញ្ចសូទនី*** *ដូចមានសេចក្តីថា ៖*

ពាក្យថា ***បិង្គលកោច្ឆព្រាហ្មណ៍*** *គឺព្រាហ្មណ៍អ្នកមានឈ្មោះថា* ***កោច្ឆៈ*** *តែលោកជាអ្នកមានបិង្គលធាតុ គឺមានភ្នែកលឿង កាលនាំមករួមជាមួយឈ្មោះដើម ទើបជា* ***បិង្គលកោច្ឆៈ*** *ឬហៅរួមជាមួយវណ្ណៈផង ក៏ជា* ***បិង្គលកោច្ឆព្រាហ្មណ៍*** *ប្រែថា កោច្ឆព្រាហ្មណ៍អ្នកមានភ្នែកលឿង ។ បិង្គលកោច្ឆព្រាហ្មណ៍ មុនដែលលោកចូលមកគាល់ព្រះមានព្រះភាគ*

លោកបានជ្រះថ្លា និងពោលសរសើរពួកគ្រូទាំង ៦ នាក់ គ្រូទាំង ៦ នាក់នោះ បានជាម្ចាស់ក្រុម មានគណៈជាអាចារ្យ មានមនុស្សស្គាល់ជាច្រើន ដែលមានពាក្យអធិប្បាយថា ម្ចាស់ក្រុមនោះ សំដៅដល់ អ្នកដែលជាធំក្នុងពពួកបព្វជិត ។ មេគណៈនោះ សំដៅដល់អ្នកដែលជាធំក្នុងគណៈបព្វជិត ។ គណាចារ្យនោះ សំដៅដល់អ្នកដែលជាអាចារ្យរបស់គណៈបព្វជិត ។ ពាក្យថា មានអ្នកស្គាល់ជាច្រើន សំដៅដល់ មានឈ្មោះ ពោះសំឡេង ប្រាកដថាជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស រហូតដល់មិនស្ងៀក មិនដណ្តប់សំពត់ជាដើម ។ គ្រូទាំង ៦ នាក់នោះ បានដល់ ១- បូរណកស្សប: ២- មក្ខលិគោសាល ៣- អជិតកេសកម្ពល ៤- បកុធកច្ចាយន: ៥- សញ្ជយវេឡដ្ឋបុត្រ ៦- និគណ្ឋនាដបុត្រ ។ ការមកនៃឈ្មោះ និងគោត្ររបស់គ្រូទាំងនោះ ព្រោះហេតុនេះ គឺពាក្យថា **បូរណ:** ជាឈ្មោះរបស់ម្ចាស់លទ្ធិ ។ ពាក្យថា **កស្សប:** ជាឈ្មោះគោត្ររបស់គេ ។ បូរណៈដើមឡើយ ជាខ្ញុំបម្រើរបស់ត្រកូលមួយ ដែលរាប់ជាជនគម្រប់ ១០០ គត់ ដែលហៅឈ្មោះថា **បូរណ:** ប្រែថា ធ្វើឲ្យពេញ

គឺធ្វើឲ្យគ្រប់ចំនួន ១០០ នៃខ្ទុបម្រើ ហើយគេប្រាកដឈ្មោះថា មង្គលទាសៈ ហេតុដែលគេមានឈ្មោះយ៉ាងនេះ ព្រោះវត្តដែលគេធ្វើនោះល្អទាំងអស់ អ្នកដែលពោលថា វត្តដែលគេធ្វើមិនល្អមិនមានឡើយ ឬអ្នកដែលពោលថា គេនៅមិនទាន់បានធ្វើវត្តនោះ វត្តនេះ ក៏មិនធ្លាប់មានឡើយ ។

បុរណកស្សបៈ បានគេចចេញអំពីចៅហ្វាយទៅ ដោយគិតថា យើងនៅក្នុងទីនេះធ្វើអ្វី ពេលដែលគេគេចទៅនោះ គេបានត្រូវពួកចោរជណ្តើមយកសំពត់ទៅអស់ គេមិនបានរកស្បែកឈើ ឬស្មៅមកធ្វើជាគ្រឿងបិទបាំងរាងកាយទេ គេបានដើរចូលទៅឯស្រុកមួយកន្លែង ដោយអាការអាក្រាតកាយយ៉ាងនោះឯង ។ គ្រានោះ ពួកមនុស្សក្នុងភូមិនោះ បានឃើញគេហើយ ម្នាក់ៗ ពោលថា អ្នកឯង គឺជាព្រះអរហន្ត ដែលកំពុងល្បីរន្ទឺនោះ ព្រោះអ្នកប្រាថ្នាតិចដូចជាលោកនេះ មិនមាន កាលបុគ្គលទាំងនោះនិយាយគ្នាដូច្នេះហើយ ក៏នាំគ្នាបង្អោនបាយ ត្រី សាច់ និងអាហារផ្សេងៗ ទៅឲ្យដល់មង្គលទាសៈ ។ គ្រានោះ មង្គលទាសៈ ទើបគិតថា លាភសក្ការៈបានកើតឡើងដល់យើងនេះ ព្រោះយើងមិនបាន

ស្បៀកដណ្តប់សំពត់ ។ រាប់ចាប់ផ្តើមអំពីនោះមក សូម្បីគេបានសំពត់ស្បៀកដណ្តប់មក គេក៏មិនស្បៀកមិនដណ្តប់ គេបានកាន់ភេទអ្នកបួសដោយអាការអាក្រាតកាយ ហើយតមក គេក៏មានកូនសិស្សច្រើនឡើងៗ ដល់ទៅ ៥០០ នាក់ ទើបគេមានឈ្មោះថា លោកគ្រូបូរណកស្សបៈ ។

ពាក្យថា **មក្ខលិគោសាល** ជាឈ្មោះរបស់ម្ចាស់លទ្ធិទី ២ ។ ពាក្យថា **គោសាល** នោះ ព្រោះគេកើតនៅក្នុងរោងគោ ។ ចំណែកពាក្យថា **មក្ខលិ** មានហេតុមកថា ចៅហ្វាយរបស់គេ បានប្រើឲ្យគេកាន់ឆ្នាំងប្រេងដើរទៅក្នុងទីដែលរអិល ចៅហ្វាយបានប្រាប់គេថា **មក្ខលិ** ប្រែថា **កុំរអិល** តែគេក៏បានជ្រាតរអិលដួល ដោយការធ្វេសប្រហែស ទើបគេរត់គេច ដោយខ្លាចចៅហ្វាយដាក់ទោស ហើយចៅហ្វាយបានដេញជាប់តាមទៅទាន់ ហើយទាញជាយសំពត់ ដោយការខ្លាចគេក៏បានរលាស់សំពត់ដែលស្បៀកចោល ហើយគេរត់ទៅ ដោយខ្លួនអាក្រាត ហើយតមក គេបានតាំងខ្លួនជាព្រះអរហន្ត ដូចគ្នានឹងបូរណកស្សបៈដែរ ។ ពាក្យថា **អជិតកេសកម្ពល** មានពីរពាក្យជាមួយគ្នា គឺពាក្យថា **អជិតៈ**

ជាឈ្មោះដើមរបស់គេ ។ ពាក្យថា **កេសកម្ពល** ជាពាក្យដែលបន្ថែមចូលមកតាមក្រោយ គឺជារហស្សនាម ដែលគេបានមកដោយការដែលគេបានស្លៀកសំពត់ ដែលត្បាញដោយសក់មនុស្ស ។ សំពត់ដែលត្បាញដោយសក់មនុស្ស ជាសំពត់ដែលគួរឲ្យខ្ពើមបំផុត សេចក្តីនេះសមដូចដែលលោកពោលទុកនៅក្នុងព្រះបាលីថា សំពត់ដែលត្បាញដោយសក់មនុស្ស ជាសំពត់ដែលត្រជាក់ ក្នុងវេលាត្រជាក់ ជាសំពត់ដែលក្តៅក្នុងវេលាក្តៅ ជាសំពត់ដែលមានពណ៌មិនល្អ មានក្លិនមិនល្អ មានសម្ផស្សមិនល្អ ។ពាក្យថា **បកុធកច្ចាយនៈ** មានពាក្យអធិប្បាយថា **បកុធៈ** ជាឈ្មោះដើមរបស់ម្ចាស់លទ្ធិទី ៤ ។ ពាក្យថា **កច្ចាយនៈ** ជាឈ្មោះគោត្ររបស់គេ គឺកាលគេបានតាំងខ្លួន ជាម្ចាស់លទ្ធិហើយ គេកាន់យកការមិនប្រើទឹកត្រជាក់ ដូចជាវេលាដែលគេបន្ទោបង់ឧច្ចារៈ ហើយ គេមិនលាងដោយទឹកត្រជាក់ បើគេមិនទាន់បានទឹកក្តៅ ឬទឹកពុយជ្រាបណា គេក៏មិនទាន់លាងដៃ និងនៅរង់ចាំជ្រាបនោះ ហើយក្នុងពេលដែលគេឆ្លងស្ទឹង ឬឆ្លងផ្លូវដែលមានទឹក គេប្រកាន់ថា សីសៈដាច់ហើយ

គេក៏អធិដ្ឋានសីសៈជាថ្មី ។

សញ្ជយវេឡដ្ឋបុត្រនោះ ពាក្យថា **សញ្ជ័យ** ជាឈ្មោះដើមរបស់ម្ចាស់លទ្ធិទី ៥ ។ ពាក្យថា **វេឡដ្ឋបុត្រ** ប្រែថា កូនរបស់វេឡដ្ឋៈ គាត់ជាបុត្ររបស់ជាងតម្បាញ (ជាងដែលយកវល្លិ៍ ឬផ្តៅ ឬឫស្សីតា្បញជាវត្ថុផ្សេងៗ) ។ **និគណ្ឋនាដបុត្រ** ជាឈ្មោះរបស់ម្ចាស់លទ្ធិទី ៦ ។ ពាក្យថា **និគណ្ឋៈ** ប្រែថា មិនមានគ្រឿងជាប់ជំពាក់ អធិប្បាយថា គេប្រកាន់ថា គេមិនមានគ្រឿងជាប់ជំពាក់ គឺកិលេស ។ ពាក្យថា **នាដបុត្រ** កូនរបស់អ្នករបាំ គឺម្ចាស់លទ្ធិនេះ ជាកូនរបស់អ្នករបាំ ។

ហេតុដែលបិង្គលកោច្ឆព្រាហ្មណ៍ ចូលមកគាល់ដើម្បីនាំបញ្ហាមកក្រាបទូលសួរព្រះលោកនាថនោះ មានរឿងសម្តែងនៅក្នុងព្រះបាលីក្នុង **គម្ភីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ** ក្នុង **ចូឡសារោបមសូត្រ** សូត្រដែលពោលដោយឧបមាព្រហ្មចរិយៈ ដោយបុរសដែលត្រូវការខ្វឹមឈើ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់

អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រាហ្មណ៍ឈ្មោះ ***បិង្គលកោច្ឆៈ*** ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏វីតកាយជាមួយនឹងព្រះមានព្រះភាគ ហើយបញ្ចប់ពាក្យដែលគួរឲ្យ កើតសេចក្តីវីតកាយ គួរជាទីរឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ឈ្មោះបិង្គលកោច្ឆៈ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន សមណ-ព្រាហ្មណ៍ទាំងឡាយណា មានពួក មានគណៈ ជាអាចារ្យនៃគណៈ មានកេរ្តិ៍ឈ្មោះ យសសក្តិ ធ្វើលទ្ធិដូចជាកំពង់ ជនច្រើននាក់ បានសន្មតថា ជាមនុស្សត្រឹមត្រូវ គឺ ***បូរណកស្សបៈ ១ មក្ខលិគោសាល ១ អជិតកេសកម្ពល ១ បកុធកច្ចាយនៈ ១ សញ្ជយវេឡដ្ឋបុត្រ ១ និគណ្ឋនាដបុត្រ ១*** សមណព្រាហ្មណ៍ទាំងអស់នោះ បានត្រាស់ដឹង ដូចពាក្យប្តេជ្ញារបស់ខ្លួន ឬមិនបានត្រាស់ដឹងទាំងអស់គ្នា ឬថា ត្រាស់ដឹងខ្លះ មិនបានត្រាស់ដឹងខ្លះ ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ កុំនិយាយឡើយ ពាក្យថា សមណព្រាហ្មណ៍ទាំងអស់នោះ បានត្រាស់ដឹង ដូចពាក្យ

ប្តេជ្ញារបស់ខ្លួន ឬមិនបានត្រាស់ដឹងទាំងអស់គ្នាទេ ឬថា ត្រាស់ដឹងខ្លះ មិនបានត្រាស់ដឹងខ្លះ ដូច្នេះនេះ ចូរលើកទុកសិនចុះ ម្នាលព្រាហ្មណ៍ តថាគតនឹងសម្តែងធម៌ដល់អ្នកវិញ ចូរអ្នកប្រុងស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ បិង្គលកោច្ឆព្រាហ្មណ៍ទទួលព្រះពុទ្ធដីការបស់ព្រះសម្ពុទ្ធថា ព្រះកុរណា ព្រះសមណៈដ៏ចម្រើន ។

ព្រះមានព្រះភាគបានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលព្រាហ្មណ៍ ប្រៀបដូចបុរសអ្នកត្រូវការដោយខ្វឹមឈើ ស្វែងរកខ្វឹមឈើ ត្រាច់ទៅស្វែងរកខ្វឹមឈើ កាលបើឈើធំមានខ្វឹមស្ថិតនៅចំពោះមុខ រំលងខ្វឹម ស្រាយ សំបក ក្រមរ ហើយកាត់យកតែមែក និងស្វ៊ីកមក សម្គាល់ថា ខ្វឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុ បានឃើញបុរសនោះ ហើយនិយាយយ៉ាងនេះថា បុរសដ៏ចម្រើននេះ មិនស្គាល់ខ្វឹម ស្រាយ សំបក ក្រមរ មែក និងស្វ៊ីកទេតើ ហេតុនោះ បានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្វឹមឈើ ស្វែងរកខ្វឹមឈើ ត្រាច់ទៅស្វែងរកខ្វឹមឈើ កាលបើឈើធំមានខ្វឹមស្ថិតនៅចំពោះមុខ ក៏រំលងខ្វឹម ស្រាយ សំបក

ក្រមរ ហើយកាត់យកតែមែកឈើ និងស្លឹកមក សម្គាល់ថាខ្ចីម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវធ្វើដោយខ្ចីមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ម្នាលព្រាហ្មណ៍ ដូចជាបុរសអ្នកត្រូវការដោយខ្ចីមឈើ ស្វែងរកខ្ចីមឈើ ត្រាច់ទៅស្វែងរកខ្ចីមឈើ កាលបើឈើធំមានខ្ចីមស្ថិតនៅចំពោះមុខ ក៏រំលងខ្ចីម ស្រាយ សំបក ហើយកែះយកតែក្រមរ សម្គាល់ថាខ្ចីម ហើយចៀសចេញទៅ ។ បុរសមានចក្ខុ បានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា ឱបុរសដ៏ចម្រើននេះមិនស្គាល់ខ្ចីម ស្រាយ សំបក ក្រមរ មែក និងស្លឹកទេ តើហេតុនោះ បានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្ចីមឈើ ស្វែងរកខ្ចីមឈើ ត្រាច់ទៅស្វែងរកខ្ចីមឈើ កាលបើឈើធំមានខ្ចីម ស្ថិតនៅចំពោះមុខ ក៏រំលងខ្ចីម ស្រាយ សំបក ហើយកែះយកតែក្រមរ សម្គាល់ថាខ្ចីម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះត្រូវការធ្វើដោយខ្ចីមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ ដូចជាបុរសអ្នក

ត្រូវការដោយខ្ទឹមឈើ សែ្វងរកខ្ទឹមឈើ ត្រាច់ទៅសែ្វងរកខ្ទឹមឈើ កាលបើឈើធំមានខ្ទឹមស្ថិតនៅចំពោះមុខ ក៏រំលងខ្ទឹម ស្រាយ ហើយ សោះយកតែសំបកមក សម្គាល់ថាខ្ទឹម ហើយចៀសចេញទៅ ។ បុរស មានចក្ខុបានឃើញបុរសនោះហើយនិយាយយ៉ាងនេះថាឱបុរសដ៏ចម្រើន នេះ មិនស្គាល់ខ្ទឹម ស្រាយ សំបក ក្រមរ មែក និងស្លឹកទេ ហេតុនោះ បានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្ទឹមឈើ សែ្វងរកខ្ទឹមឈើ ត្រាច់ទៅសែ្វងរកខ្ទឹមឈើ កាលបើឈើធំមានខ្ទឹម ស្ថិតនៅចំពោះមុខ ក៏រំលងខ្ទឹម ស្រាយ ហើយសោះយកតែសំបកមក សម្គាល់ថាខ្ទឹម ហើយ ចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវការធ្វើដោយខ្ទឹមឈើ ការងារនោះ ក៏និងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាល ព្រាហ្មណ៍ ពុំនោះសោត ដូចបុរសអ្នកត្រូវការដោយខ្ទឹមឈើ សែ្វងរក ខ្ទឹមឈើ ត្រាច់ទៅសែ្វងរកខ្ទឹមឈើ កាលបើឈើធំមានខ្ទឹមស្ថិតនៅ ចំពោះមុខ ក៏រំលងខ្ទឹម ហើយចាំងយកតែស្រាយមក សម្គាល់ថាខ្ទឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុ បានឃើញបុរសនោះហើយ

និយាយយ៉ាងនេះថា ឱបុរសដ៏ចម្រើននេះមិនស្គាល់ខ្លឹម ស្រាយ សំបក ក្រមរ មែក និងស្នឹកទេ ហេតុនោះ បានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹម ស្ថិតនៅចំពោះមុខ ក៏រំលងខ្លឹម ហើយចាំងយកតែស្រាយមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវការធ្វើដោយខ្លឹមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ ពុំនោះសោត ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមស្ថិតនៅចំពោះមុខ ក៏ចាំងយកតែខ្លឹមមក សម្គាល់ថាខ្លឹមពិត ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា ឱបុរសដ៏ចម្រើននេះស្គាល់ខ្លឹម ស្រាយ សំបក ក្រមរ មែក និងស្នឹកមែន ហេតុនោះ បានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹម ស្ថិតនៅចំពោះមុខ ក៏ចាំងយក

តែខ្ញុំមកសម្គាល់ច្បាស់ថាខ្ញុំម ហើយចៀសចេញទៅ ការងារណា ដែលបុរសនោះ ត្រូវការធ្វើដោយខ្ញុំមឈើ ការងារនោះ ក៏ទីឆសម្រេចប្រយោជន៍ដល់បុរសនោះ ។

ម្នាលព្រាហ្មណ៍ សេចក្តីដែលពោលមកហើយនេះ ក៏ដូចគ្នានឹងកុលបុត្រពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធា ដោយគិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរបរឹតហើយ ធ្វើម្តេចហ្ន៎ ទីឆធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដជាន ។ កុលបុត្រនោះ លុះបួសរួចយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះ មានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះ រមែងលើកតម្កើងខ្លួនឯង បន្ទុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះថា អាត្មាអញ

ជាអ្នកមានលាភសក្ការៈ និងសេចក្តីសរសើរ ចំណែកកិក្ខុទាំងឡាយ ដទៃៗ នេះ ជាអ្នកមិនមានកេរ្តិ៍ឈ្មោះ យសសក្តិទេ ។ ធម៌ទាំងឡាយ ដទៃណា ដែលជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងលាភសក្ការៈ និងសេចក្តីសរសើរ កុលបុត្រនោះ មិនបានញុាំងឆន្ទៈឲ្យកើតឡើង មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្ញីមឈើ ស្វែងរកខ្ញីមឈើ ត្រាច់ទៅស្វែងរកខ្ញីមឈើនោះ កាលបើឈើធំមានខ្ញីមស្ថិតនៅចំពោះមុខ ក៏រំលងខ្ញីម ស្រាយ សំបក ក្រមរ ហើយកាត់យកតែមែក និងស្វឹកមក សម្គាល់ថាខ្ញីម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវការធ្វើដោយខ្ញីមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលកាន់ផ្នួស ដោយសទ្ធា ដោយគិតថា អាត្មាអញជាអ្នក

មានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ
ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា ជាអ្នក
មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវ
ទីបំផុតនៃកងទុក្ខ ទាំងអស់នេះឲ្យប្រាកដបាន ។ បុគ្គលនោះ លុះបួស
រួចយ៉ាងនេះហើយ រមែងញុាំងលាភសក្ការៈ និងសេចក្តីសរសើរឲ្យ
កើតឡើង ។បុគ្គលនោះ មិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌
ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ បុគ្គលនោះ មិនលើក
តម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តី
សរសើរនោះ ។ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាង
លាភសក្ការៈ និងសេចក្តីសរសើរ បុគ្គលនោះ រមែងញុាំងឆន្ទៈឲ្យ
កើតឡើង រមែងព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង
ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុរសនោះ
រមែងបាននូវសីលសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្ត មាន
តម្រិះបរិបូណ៌ដោយសីលសម្បទានោះ ។ បុគ្គលនោះ រមែងមិនលើក

តម្កើងខ្លួនឯង បន្ទុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះថា អាត្មាអញជាអ្នកមានសីល មានធម៌ល្អ ចំណែកកិក្ខុទាំងឡាយដទៃៗ នេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងសីលសម្បទា បុគ្គលនោះមិនញុំាងឆន្ទៈឲ្យកើត មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ។ ម្នាលព្រាហ្មណ៍ ដូចជាបុរសអ្នកត្រូវការដោយខ្វឹមឈើ ស្វែងរកខ្វឹមឈើ ត្រាច់ទៅស្វែងរកខ្វឹមឈើនោះ កាលបើឈើធំមានខ្វឹមស្ថិតនៅចំពោះមុខ ក៏រំលងខ្វឹម ស្រាយ សំបក ហើយកែះយកតែក្រមរមក សម្គាល់ថាខ្វឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវការធ្វើដោយខ្វឹមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងសាសនានេះ ។ល។ គប្បីធ្វើនូវទីបំផុតឲ្យជ្រាកជាន ។ បុគ្គលនោះ លុះបួសរួចយ៉ាងនេះ

ហើយក៏ញុាំងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។បុគ្គលនោះ មិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ បុគ្គលនោះ មិនលើកតម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះឡើយ ។ ធម៌ទាំងឡាយដទៃណា ដែលជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងលាភសក្ការៈ និងសេចក្តីសរសើរ បុគ្គលនោះ រមែងញុាំងឆន្ទៈឲ្យកើតឡើង ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះ រមែងបាននូវសីលសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងសីលសម្បទា បុគ្គលនោះ រមែងញុាំងឆន្ទៈឲ្យកើតព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះ

រមែងបាននូវសមាធិសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្ត មាន
តម្រិះបរិបូណ៌ដោយសមាធិសម្បទានោះ ។ បុគ្គលនោះ រមែងលើក
តម្កើងខ្លួនឯង បន្ទុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះថា អាត្មាអញ
ជាអ្នកមានចិត្តខ្ជាប់ខ្ជួន មានចិត្តប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយ ឯកិរ្ដ
ទាំងឡាយដទៃៗ នេះ មិនមានចិត្តខ្ជាប់ខ្ជួន មានចិត្តវិលវែងៗ ។ ធម៌
ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងសមាធិសម្បទា
បុគ្គលនោះ មិនញុាំងឆន្ទៈឲ្យកើត មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់
នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ។
ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្វឹមឈើ ស្វែងរកខ្វឹមឈើ
ត្រាច់ទៅស្វែងរកខ្វឹមឈើនោះ កាលបើឈើធំមានខ្វឹមស្ថិតនៅចំពោះមុខ
ក៏រំលងខ្វឹម ស្រាយ ហើយស្ទុះយកតែសំបកមក សម្គាល់ថាខ្វឹម ហើយ
ចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវការធ្វើដោយខ្វឹមឈើ
ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាល
ព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈគ្របសង្កត់ហើយ ។ល។ នឹងធ្វើនូវទីបំផុតឲ្យប្រាកដបាន ។ បុគ្គលនោះ លុះបួសរួចយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ បុគ្គលនោះ មិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ បុគ្គលនោះ មិនលើកតម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះឡើយ ។ធម៌ទាំងឡាយដទៃណា ដែលជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងលាភសក្ការៈ និងសេចក្តីសរសើរ បុគ្គលនោះ រមែងញុំាងឆន្ទៈឲ្យកើតឡើង ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះ រមែងបាននូវសីលសម្បទា ។ បុគ្គលនោះ មានការពេញចិត្ត ដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទា

នោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាង សីលសម្បទា បុគ្គលនោះរមែងញុាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យ ជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្ត មិនធូរថយផង ។បុគ្គលនោះរមែងបាននូវសមាធិសម្បទា ។បុគ្គលនោះ មានសេចក្តីពេញចិត្ត ដោយសមាធិសម្បទានោះ តែមិនមានតម្រិះ បរិបូណ៌ទេ ។បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងសមាធិសម្បទា បុគ្គលនោះរមែងញុាំងឆន្ទៈឲ្យកើត ព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះ រមែងបាននូវញាណទស្សនៈ ។ បុគ្គលនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយញាណទស្សនៈ នោះ ។បុគ្គលនោះ រមែងលើកតម្កើងខ្លួនឯង បន្ទុះបង្អាប់អ្នកដទៃ ព្រោះ ញាណទស្សនៈនោះថា អាត្មាអញជាអ្នកបានដឹង បានឃើញរូបល្អិត ចំណែកកិក្ខុទាំងឡាយដទៃៗ នោះ ជាអ្នកមិនដឹង មិនឃើញរូបល្អិត ។

ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងញាណទស្សនៈ បុគ្គលនោះមិនញុំាងឆន្ទៈឲ្យកើត មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ។ ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្វឹមឈើ ស្វែងរកខ្វឹមឈើ ត្រាច់ទៅស្វែងរកខ្វឹមឈើនោះ កាលបើឈើធំមានខ្វឹមស្ថិតនៅចំពោះមុខ ក៏រំលងខ្វឹម ហើយចាំងយកតែស្រាយមក សម្គាល់ថាខ្វឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវការធ្វើដោយខ្វឹមឈើ ការងារនោះក៏នឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខ

ទាំងអស់នេះឲ្យច្រាកដបាន ។ បុគ្គលនោះ លុះបួសរួចយ៉ាងនេះហើយ តែងញុាំងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើត ។បុគ្គលនោះ មិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ បុគ្គលនោះ មិនលើកតម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ធម៌ទាំងឡាយដទៃណា ដែលជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងលាភសក្ការៈ និងសេចក្តីសរសើរ បុគ្គលនោះ រមែងញុាំងឆន្ទៈឲ្យកើតឡើង ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះ រមែងបាននូវសីលសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ជាងសីលសម្បទា បុគ្គលនោះ រមែងញុាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្ត

មិនរួញរា ប្រព្រឹត្តមិនធូរថយផង ។បុគ្គលនោះ រមែងបាននូវសមាធិ-
សម្បទា ។បុគ្គលនោះមានសេចក្តីពេញចិត្ត ដោយសមាធិសម្បទានោះ
តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះ មិនលើកតម្កើងខ្លួនឯង
មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ ធម៌ទាំងឡាយ
ដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងសមាធិសម្បទា បុគ្គលនោះ
រមែងញុាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះ
ផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។បុគ្គលនោះ
រមែងបាននូវញាណទស្សនៈ ។បុគ្គលនោះមានសេចក្តីពេញចិត្ត ដោយ
ញាណទស្សនៈនោះ តែមិនមានតម្រិះបរិបូណ៌ទេ ។បុគ្គលនោះមិនលើក
តម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះ ។ធម៌
ទាំងឡាយដទៃណា ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងញាណទស្សនៈ
បុគ្គលនោះរមែងញុាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវ
ធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។
ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយដូចម្តេច ដែលជាធម៌ដ៏លើសលប់ និង

ថ្លៃថ្លាជាងញាណទស្សនៈ ฯ ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះ ฯ ម្នាលព្រាហ្មណ៍ធម៌នេះឯង ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាងញាណទស្សនៈ ฯ ម្នាលព្រាហ្មណ៍ មួយទៀត ភិក្ខុព្រោះរម្ងាប់វិតក្កវិចារៈរួចហើយ ក៏ដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ฯลฯ តតិយជ្ឈាន ฯลฯ បានដល់ចតុត្ថជ្ឈាន ฯ ម្នាលព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលប់ និងថ្លៃថ្លាជាញាណទស្សនៈ ฯ ម្នាលព្រាហ្មណ៍ មួយទៀត ភិក្ខុព្រោះប្រព្រឹត្តកន្លងនូវរូបសញ្ញា (រូបសញ្ញា សេចក្តីសម្គាល់ក្នុងរូប ឯរូបក្នុងទីនេះ សំដៅយករូបាវចរជ្ឈានផង អារម្មណ៍របស់រូបាវចរជ្ឈាននោះផង) ព្រោះអស់ទៅនៃបដិឃសញ្ញា (បដិឃសញ្ញា សេចក្តីសម្គាល់កើតឡើងដោយការ

ប៉ះពាល់ គឺចក្ខុប៉ះពាល់នឹងរូប ត្រចៀកប៉ះពាល់នឹងសំឡេងជាដើម) ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា (នានត្តសញ្ញា សញ្ញាផ្សេងៗ គ្នា ឯសញ្ញាដែលផ្សេងៗ គ្នានោះ មាន ៤៤ គឺកាមាវចរកុសលសញ្ញា ៨ អកុសលសញ្ញា ១២ កាមាវចរកុសលវិបាកសញ្ញា ១១ អកុសលវិបាកសញ្ញា ២ កាមាវចរកិរិយាសញ្ញា ១១) ដោយប្រការទាំងពួង បានដល់ អាកាសានញ្ចាយតនជ្ឈាន ដោយការពិចារណាថា អាកាសមិនមានទីបំផុតដូច្នេះ ។ម្នាលព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលប់ និងថ្លៃថ្លា ជាឥញ្ជាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ មួយវិញទៀត ភិក្ខុព្រោះប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការពិចារណាថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ។ល។ ព្រោះប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការពិចារណាថា អ្វីតិចតួចក៏មិនមានដូច្នេះ ។ល។ ព្រោះប្រព្រឹត្តកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវនេវសញ្ញា-

នាសញ្ញាយតនជ្ឈាន ។ម្នាលព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលប់ និងថ្លៃថ្នាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ មួយវិញទៀត ភិក្ខុព្រោះប្រព្រឹត្តកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈានដោយប្រការទាំងពួង បានដល់នូវសញ្ញាវេទយិតនិរោធ (សេចក្តីរំលត់នូវសញ្ញា និងវេទនា) ។ អាសវៈទាំងឡាយរបស់ភិក្ខុនោះ រមែងអស់ទៅ មិនមានសល់ ព្រោះបានឃើញច្បាស់ដោយបញ្ញា ។ ម្នាលព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលប់ និងថ្លៃថ្នាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយនេះឯង ជាធម៌ដ៏លើសលប់ និងថ្លៃថ្នាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្វឹមឈើ ស្វែងរកខ្វឹមឈើ ត្រាច់ទៅស្វែងរកខ្វឹមឈើនោះ កាលបើឈើធំមានខ្វឹមស្ថិតនៅចំពោះមុខ ក៏ចាំងយកតែខ្វឹមមក ដឹងច្បាស់ថាខ្វឹម ហើយចៀសចេញទៅ ការងារណា ដែលបុរសនោះ ត្រូវការធ្វើដោយខ្វឹមឈើ ការងារនោះ ក៏និងសម្រេចប្រយោជន៍ ដល់បុរសនោះ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

ម្នាលព្រាហ្មណ៍ ព្រហ្មចរិយៈនេះ មិនមែនមានត្រឹមតែលាភសក្ការៈ និងសេចក្តីសរសើរជាអានិសង្សទេ មិនមែនមានត្រឹមតែសីលសម្បទា ជាអានិសង្សទេ មិនមែនមានត្រឹមតែសមាធិសម្បទា ជាអានិសង្សទេ មិនមែនមានត្រឹមតែញាណទស្សនៈជាអានិសង្សទេ ដោយប្រការដូច្នេះឯង ម្នាលព្រាហ្មណ៍ ចេតោវិមុត្តិ ការរួចចាកកិលេសនៃចិត្ត គឺអរហត្តផល ជាធម៌មិនកម្រើកណា ម្នាលព្រាហ្មណ៍ ព្រហ្មចរិយៈនេះ មានអរហត្តផលនោះជាប្រយោជន៍ មានអរហត្តផលនោះជាខ្លឹម មានអរហត្តផលនោះជាទីបំផុត ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់សូត្រនេះចប់ហើយ ។ បិង្គលកោច្ឆព្រាហ្មណ៍ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។ល។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់ផ្តើមតាំងអំពីថ្ងៃនេះតរៀងទៅ ។

សរុបសេចក្តីតាមន័យនៃពុទ្ធាធិប្បាយ

១- លាភសក្ការៈ និងកេរ្តិ៍ឈ្មោះ ប្រៀបដូចមែក និងស្វ៊ីកឈើ **២- សីលសម្បទា** គឺភាពជាអ្នកសម្បូរដោយសីល ប្រៀបដូចក្រមរឈើ **៣- សមាធិសម្បទា** គឺភាពជាអ្នកដល់ព្រមទៅដោយសមាធិ ប្រៀបដូចជាសំបកឈើ **៤- ញាណទស្សនៈ** គឺការដឹង ការឃើញ ដោយបញ្ញា ប្រៀបដូចជាស្រាយនៃឈើ **៥- ចេតោវិមុត្តិ** គឺការរួចផុតចាកកិលេស ដោយកម្លាំងសមាធិ ដែលមិនកម្រើក ប្រៀបដូចជាខ្លឹមនៃឈើ ។

(ជីវប្រវត្តិរបស់បិង្គលកោច្ឆឧបាសក ចប់)

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ដោយប្រធានសមាគមធម្មទានអរិយតឡាយចំស្វូងាត

ឈ្មោះសម្បុរសប្រគេនសម្ភារៈ មានភ្នំព្យូទីរជាដើម ក្នុងកិច្ចការចារជាធម្មទាន

❋ឧបាសិកា ហម យិម

ឧបាសក អ៊ីង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ សុីផូ ឧបាសិកា ចែ សុីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ថា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដាវី កញ្ញា អ៊ីង មុយហៀក

❋លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អឿ សៅ (ទក្ខប្បញ្ញ)

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ីង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យីម សំណាង ឧបាសិកា យីម ច័ន្ទបូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៉ុលីន សុីមប៉ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនជានេត

លោកអាចារ្យ ផាត សាវ៉ឿយ ឧបាសិកា វ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ធាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ(SABOREAK SOK)

ឧបាសក យក់ សុីមួរ៉ ឧបាសិកា តាន់ រ៉ាណា

ឧបាសក អ៊ីង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉ែត

ឧបាសក លីម ស៊ាង

ឧបាសក ឈុន គីមអេង

❋ឧបាសក ឈុំ គីម គីមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ សុធា (ហៅអាហួយ)

ឧបាសក សារុន សេង៉ហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន ឃីម) ឧបាសិកា ណៃ គីមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា ស្ងួន កញ្ញារ័ត្ន

❋ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គីមឆៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គីមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងឆឹម និងស្វាមី ព្រមទាំងកូនចៅ

❋ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ជុះ ចំណាន

ឧបាសិកា វិញ ពូន

❋ឧបាសក ឡាំ ធៀន ឧបាសិកា សឺន ចន្ថា

ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុគី

ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា

ឧបាសក ឡាំ ជាវណ្ណ ឧបាសិកា ឡាំ ចាន់វ៉ារី

❋ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ូន ព្រមទាំងបុត្រ

ញោម ឥម្មន្ទីនិងធូ ញោម ហាន ញោម រ៉ន ញោម ភ័ណ្ឌ ញោម

សុមនា ញោម ជោត ញោម មាស សុកា ញោម ឡៃ លី កញ្ញា នា ញោម ឆាង ញោម ជីង ឡេង ញោម អៀម ញោម ភួង ញោម អុំកា ញោម សុកា ញោម វល័ក្ខ ញោម ឆាលី លីណា ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម សុិន ញោម កាព សារឿន ញោម ហ៊ិន ញោម ប៊ូ សៀកលីវ ញោម យក់ វ៉ាន់ថា ។

❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុន សេរី លោក ដែង រស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ

❋ឧបាសក អ៊ីង ហ្គេចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ លោក ឆៃ ហេង អ្នកស្រី អ៊ីង ស៊ីវគៀង ព្រមទាំងបុត្រ លោក កួ ពុយ អ្នកស្រី អ៊ីង ណង់ពិន ព្រមទាំងបុត្រ លោក អ៊ីង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ លោក ប៊ុ ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា សាម៉ុល គីមធន និងអ្នកម្តាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុកនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អឿន កី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ឺ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ចែ អេង+គីម ធី+ខៀវ វ៉ែន+ គីម

ញោម ទៀង+យាយ ធ័ង+គួង កាង+សើន គា+សៀង+គីម អាង

ញោម សេង ឆេង+ជាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាក៉ាឡែន+ ហ៊ីង+ ចែ ង៉ា+ រី រុត្ន

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណេរ អ៊ុំ វីរៈ

ញោមចែ ង៉ាថ្មគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈឿត

ញោម ហ៊ីង+នាង មឿន+អូនប៉ុច+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង

ញោម គីម ឡេង+តាំង វេន+ឃុន+យាយ ជុច + យាយ ឃន
ញោម ហ៊ីន ស៊ីម ញោម អឿន កី+វ៉ាន់ ស៊ុនឡាយ+ផល្លី+សវាមី
ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លីម+សេង ទូច+ស៊ីវ ទី
ញោម ណា ហ្គេចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណាវ៉ា
ញោម ធាវ៉ា+ឃៀត និង+ស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី
ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គីម អ៊ី
ញោម អៀប សានួន+ យាយ ហឿន+យាយ ឡាំ+កេន សេង+មុំ
ស ខាន់ថង+ស៊ី ណាត+ឃៀន+ចាន់ នី+ផន សាវ៉ន+កោ ហុង ។

ឆាយពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លាជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន

លោកគ្រូធម្មបណ្ឌិត	(ទក្ខប្បញ្ញោ) អឿ សៅ
ឧបាសិកា ធីក ស្រ៊ន	ព្រមទាំងកូនប្រុស អ៊ីង រិទ្ធី និងកវិយោ
ឧបាសក ប៊ូហោ ឆាង	ឧបាសិកា អ៊ីង រិទ្ធារី ព្រមទាំងបុត្រធីតា
ឧបាសក យេម សំណាង	ឧបាសិកា យេម ឡរ៉ា ព្រមទាំងបុត្រ
ឧបាសក សៅ ហ៊ាន	ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ
ឧបាសក ឈៀង សារឿន	ឧបាសិកា ឈុំ ឆជា ព្រមទាំងបុត្រធីតា
ឧបាសក ម៉ៅ វង្ស	ឧបាសិកា ឆាន់ កាន់ជួង ព្រមទាំងបុត្រ
ឧបាសក និន ហាក់	ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ
ឧបាសិកា ម៉ី ចាន់រ៉ាវី	ព្រមទាំងបុត្រធីតា
ឧបាសិកា យ៉ក់ សុីមួរ៉ា	ព្រមទាំងបុត្រ
ឧបាសិកា វ៉ាន់ចាន់	ព្រមទាំងបុត្រធីតា
ឧបាសិកា ខៀវ ណាត	ព្រមទាំងបុត្រធីតា

នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឆាយ អ៊ីវស៊ាង ឧបាសិកា ហុង គីមសៃ កូន+ចៅ
ឧបាសិកា ឃូ ស៊ាងនន្ទលី ព្រមទាំងកូនចៅ

នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ប៊ុន ហោង ឧបាសិកា ជុំ សុខុម
ឧបាសិកា ហោង ស្រីជា ឧបាសិកា ហោង ស្រីចន្ធូ
ឧបាសិកា ហោង គង្គា ឧបាសក ហោង សុកត្រៃ

នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក អ៊ឹង ហ៊ាចឡេង ឧបាសិកា តាំង ប៉ោងជឹង ព្រមទាំងកូនចៅ
ឧបាសក វៀម ឈឺន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ

ឧបាសក ញ៉ែម មឿន ឧបាសិកា រៀម ថុល ព្រមទាំងកូនចៅ
ឧបាសក អ៊ីង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ
ឧបាសក ឈុំ គីមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ
ឧបាសក សោម សាខន ឧបាសិកា ឈុំ សុជា ព្រមទាំងកូន
ឧបាសក ទាង ភ័ ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ
ឧបាសក សៅ ស៊ុនួរ ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ
ឧបាសក ណូ ស្វែង ឧបាសិកា សោម គីមលួន ព្រមទាំងកូនចៅ
ឧបាសិកា ងិន ឃ្លុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ
ឧបាសិកា សោម គីមលឿម និងស្វាមី ព្រមទាំងកូនចៅ
ឧបាសិកា គីម ឆវី និងស្វាមី ព្រមទាំងកូនចៅ
ឧបាសិកា ទាវ គីមយក់ ឧបាសិកា អ៊ឹម គីមជីវ
ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី
ឧបាសិកា ហួត អេង ឧបាសិកា ឡេ សាយហ្គិច
ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ
ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ
ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ
ឧបាសិកា សៀង ព្រមទាំងបុត្រ

ឆាមពុទ្ធបរិស័ទផៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លាជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង សុីម ព្រមទាំងកូនចៅ

លោក លី ហុង លោកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក ផូ ចាន់ថន លោកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក លីម ចាន់ឌី លោកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីជា

លោក ហុង សុវណ្ណតារា និងភរិយា លីម ចាន់មុនីវ័ត្ន

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉ែត

យុវជន ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហោងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអូន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គីមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា លោកស្រី មុំ ជាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័គ លោកស្រី មុំ ជា ព្រមទាំងបុត្រ ធីតា

លោក ឈឺន សាគីម លោកស្រី ខឹម អូន ព្រមទាំងបុត្រ ធីតា

លោក រស់ ប៊ុនឡេង លោកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្ងាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀវ ឆឹម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ជារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គីម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា វ័ត្ន សុផល ព្រមទាំងកូនចៅ

លោកស្រី ជុន បូណាមី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ជា ព្រមទាំងកូនក្មួយ

ឧបាសិកា គីម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និង កុមារី សុជាតា

ឧបាសិកា ជា រួចទៀង ព្រមទាំងកូនចៅ

ឧបាសក ជី សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជី ញ៉ែ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ុំម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ហិន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី បួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ាវិទ្ធ លោកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារ យាន ពិសិដ្ឋ

ឧបាសិកា ឃន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា លីម ម៉ាលី (គីម ហ៊ួយ) និងស្វាមី ព្រមទាំងបុត្រ ធីតា

ឧបាសិកា សុិន ឡាច ព្រមទាំងក្រុមគ្រួសារ

ឧបាសក ប៊ុន បួន ឧបាសិកា ឃុត សួគ៌ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បង៉ស្រី ណៅ សុកី និង ប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឺន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី និង អ្នកស្រី អ៊ួន សាវ៉ែត ព្រមទាំងបុត្រ

លោក ឌិម ឡូត លោកស្រី សុិំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សាវឿន លោកស្រី ម៉ម សុធា ព្រមទាំងបុត្រ

លោក សុីម សាវ៉ាន់ លោកស្រី លី សុខរ៉ែត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហោង វណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គីមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៊ូ ប៊ុក ព្រមទាំងកូនចៅ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា ឈឺន សង់ ព្រមទាំងកូនចៅ

លោក ឈឺន ចំរើន លោកស្រី ហោ វាសនា ព្រមទាំងបុត្រធីតា

ឧបាសិកា ប៉ែ សារ៉ាត(ម្តាយ) ឧបាសក ម៉ើ ធារី

ឧបាសិកា ម៉ៅ ណាវី ព្រមទាំងកូនចៅ

ឧបាសក ប៉ែ សុីថា ឧបាសិកា ង្ហួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៊ូច សាមុត ព្រមទាំងកូនចៅ

ឧបាសិកា មាស អូន ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉ែង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង វ៉ែត ព្រមទាំងកូនចៅ

ឧបាសក ធូ បូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

អ្នកគ្រូ ឌិម សុផាត ព្រមទាំងកូនចៅ

ឧបាសក ឆឺង ផាត់ ឧបាសិកា ណុប សៀងហេង ព្រមទាំងកូនចៅ

លោក អ៊ុត សារឿន លោកស្រី ញឹក សោភ័ណ ព្រមទាំងបុត្រ

នាមពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការចារធម្មទាន

១- ឧបាសិកា ប៉ែង តាំង ឧបាសិកា ហ៊ូ គីមងៀក

២- ឧបាសក ស្រេង ស្រ៊ាង ឧបាសិកា គិម ចន្ថា

៣- ឧបាសក ឡាយ សុខុម ឧបាសិកា គី គីមហាប់

៤- ឧបាសិកា បួ ម៉ាឡា កញ្ញា បួ ជាវី

៥- ឧបាសិកា ង៉ែង យូអេង កញ្ញា អ៊ឹង មុយហៀក

៦- ឧបាសក លីម ខូង ឧបាសិកា កែវ អុន

៧- ឧបាសិកាកែវ កល្យាណ ឧបាសិកា សុខ សុទ្ធី

៨- ឧបាសិកា សឺន ចន្ថា លោក ឡាំ ជាវណ្ណ

៩- ឧបាសិកា គួ ប៊ុនគាង ឧបាសិកា ឈុំ សុជា

១០- ឧបាសិកា នេត្រ នរិន្ទ ឧបាសិកា ទន់

១១-ឧបាសិកា ឱម លក្ខណា ឧបាសិកា ហោង ច័ន្ទបុញ្ញវន្តី

១២-ឧបាសិកា គី យក់បួយ ឧបាសិកា ឈុន ណាត

១៣-ឧបាសិកា អ៊ឹង រិទ្ធារី ឧបាសក អ៊ុន សេរី

១៤-ឧបាសិកា រៀម ថុល ឧបាសិកា ម៉ៅ នី

១៥-ឧបាសិកា សន ឈៀត ឧបាសក ឡាន សុខុម

១៦-ឧបាសិកា គីវណ្ណហាក់ ឧបាសិកា ប៉ាន ណម
១៧-ឧបាសិកា ស្ងួន កល្យាណ ឧបាសិកា កយង កក្តី
១៨-ឧបាសក អ៊ឹង វ៉ៃយ៉ា ឧបាសក កុយ សាមន
១៩-ឧបាសក ហុង សុវណ្ណារិទ្ធ ឧបាសក ហុង សុវណ្ណារ័ត

ខ្ញុំព្រះករុណា អាត្មាភាពមានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ **០១២ ៣០៥ ៧៦៦, ០៨ ៨៨ ៧៧ ៩៩ ៦៦ ០៧៧ ៦៦ ៦៦ ៣៨** ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

-ជីវប្រវត្តិពុទ្ធឧបាសក មាន ៥ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៥ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

-ជីវប្រវត្តិពុទ្ធឧបាសិកា មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយ

សព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។

-វិសុទ្ធិមគ្គ និង **បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេចដែរ ដែលមាន ៣ ភាគ ។

-គម្ពីរសារត្ថសង្គហៈ ហើយសព្វថ្ងៃនេះ បានធ្វើរួចជាស្ថាពរ គឺវាយកុំព្យូទ័ររួចជាស្រេចអស់ហើយទាំង ២ ភាគ ដែលមានកម្រាស់ រហូតទៅដល់ ៦០០ ទំព័រជាង ។

-គម្ពីរអភិធម្មត្ថសង្គហៈ និង **វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៦៥០ ទំព័រជាង ។

-អភិធម្មត្ថសង្គហៈ និង **បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់

រហូតទៅដល់ ៩៨៩ ទំព័រជាង ។

-**គម្ពីរអភិធម្មាវតា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្តាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

-**មិលិន្ទប្បញ្ហា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្តាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

-**រឿង"ការដែលទាកទង់ នឹងពុទ្ធស្តាន** បានធ្វើសម្រេចជាស្តាពរហើយ ដែលមានចំនួន ៥ ភាគ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៦០០-៧០០ ទំព័រជាង៥ក៏មាន ។

-**ខ្ញុំព្រះករុណា អាត្មាភាព** មានចំណងនឹងរាបចំធ្វើ **គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា** បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះ ព្រះត្រៃបិដកយកតាមបិដកខ្មែរយើង **ដែលមាន ១១០ ក្បាល ។**

-**ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយកុំព្យូទ័រចប់ហើយ (០១.០៥.២០១០, ២៧.០៣.២០១១) ។**

-ការជាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះដែល ធ្វើសម្រេចជាស្តាពរនោះ មានដូចខាងក្រោមនេះ គឺ

-គម្ពីរវិនយបិដក បានធ្វើរួចជាស្រេចហើយ **មានចំនួន ១៤ ភាគ**

-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ **មានចំនួន ៦ ភាគ**

-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ **មានចំនួន ៩ ភាគ**

-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ **មានចំនួន ១១ ភាគ**

-គម្ពីរអង្គុត្តរនិកាយ កុំពុងតែប្រែជិតចប់ហើយដែរ

-គម្ពីរខុទ្ទកនិកាយ ប្រែបាន **៦ ភាគហើយ**

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះ បានចំនួន ៥០ ក្បាលជាងហើយ ។

សៀវភៅដែលប្រមូលរៀបរៀង និងចោះពុម្ពហើយដោយ

ខ្ញុំព្រះករុណា អាត្មាភាព

✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មួយភាគ ១

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស ភាគ ១

-ធម៌សូធ្យនមស្ការបែបបុរាណ

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-គម្ពីរសោតត្ថសង្គហៈ ភាគ ១

-ពុទ្ធប្បវត្តិ

សូមអនុមោទនាជម្ងឺមាន !!!

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុជាត